## សាកលវិទ្យាល័យភូមិន្ទកសិកម្ម

### មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ប្រវត្តិសេដ្ឋកិច្ចកម្ពុជា
# CAMBODIA’S ECONOMIC HISTORY


**លោកស្រី ហ៊ីង សាលីន**

**បណ្ឌិត ឈុន ពហុ**



**ឧបត្ថម្ភដោយ**

**២០២១**

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ប្រវត្តិសេដ្ឋកិច្ចកម្ពុជា

## Cambodia’s Economic History

លោកស្រី ហ៊ីង សាលីន

បណ្ឌិត ឈុន ពហុ

២០២១

## គណៈកម្មការបច្ចេកទេស

# ចំណេះដឹងសៀវភៅ៖ ប្រវត្តិសេដ្ឋកិច្ចកម្ពុជា

| ល.រ | គោត្តនាម និងនាម | សមាសភាពគណៈកម្មការ | ហត្ថលេខា |
|---|---|---|---|
| ១ | លោក អេង លេង | ប្រធាន | |
| ២ | បណ្ឌិត ឆាយ គង្គា | អនុប្រធាន | |
| ៣ | បណ្ឌិត អ៊ុន ប៊ុនលាង | សមាជិក | |

២០២១

# រក្សាសិទ្ធ

© ឆ្នាំ ២០២១

## រក្សាសិទ្ធគ្រប់យ៉ាង

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ (ស.គ.ន) នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

## ទំនាក់ទំនងព័ត៌មាន:

អ្នកនិពន្ធ៖ លោកស្រី ហ៊ីង សាលីន

ទូរស័ព្ទ៖ (+៨៥៥) ៩៦ ៣៥៩ ៨៣៤០

អ៊ីមែល៖ salin_hing@outlook.com

©. 2021 Hing Salin, all rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sport, the Kingdom of Cambodia

Enquiries about the book:

Author: Mrs. Hing Salin

Mobile phone: (+855) 96 359 8340

Email: salin_hing@outlook.com

# មុខកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សាជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះនៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទឆ្លាតវៃ និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀតបច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ដែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្ដិសិទ្ធិ និងផ្ដល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ
៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន
៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន
៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ
៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.0 (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពរូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្ដីបញ្ជាក់
# នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្ដល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្ដមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍជនបទនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលបានផ្តល់ការអនុញ្ញាត និងលើកទឹកចិត្តនៅក្នុងការរៀបចំសរសេរសៀវភៅមួយក្បាលនេះ ដើម្បីចែករំលែកចំណេះដឹងខ្លះៗដល់សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ដើម្បីជាស្វ័យសិក្សា ស្វែងយល់ពីចំណេះដឹងដែលទាក់ទងនឹងសេដ្ឋកិច្ច ក្នុងប្រទេសកម្ពុជាយើង។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍នៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានគាំទ្រថវិការជួយជ្រោមជ្រែងនៅក្នុងការងាររៀបចំបង្កើត ក៏ដូចជាការបោះពុម្ពឡើងជាសៀវភៅមួយក្បាលនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តួចផ្តើមនៅក្នុងការលើកទឹកចិត្ត និងធ្វើឱ្យបញ្ញវ័ន្តខ្មែរជាច្រើនអ្នកមានឱកាសបញ្ចេញស្នាដៃនៅក្នុងការបោះពុម្ពសៀវភៅជាខេមរភាសារសម្រាប់និស្សិតបញ្ញវ័ន្ត ក៏ដូចជាភាគីពាក់ព័ន្ធនានាអាចយកទៅធ្វើការសិក្សាស្រាវជ្រាវប្រកបដោយភាពងាយស្រួល។

សូមថ្លែងអំណរគុណជាអនេកដល់ លោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ពហុ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឯកសារ យោបល់ និងគំបូន្មានល្អៗជាច្រើនសម្រាប់ការរៀបរាងសៀវភៅនេះឡើង។

# **អារម្ភកថា**

សៀវភៅប្រវត្តិសេដ្ឋកិច្ចកម្ពុជា ដែលបានរៀបរៀងឡើងនេះ បានពីការស្រាវជ្រាវពី ឯកសារដែលដកស្រង់ចេញ ពីសៀវភៅសម្រាប់ចំណេះដឹងទូទៅ ឯកសារជំនួយផ្សេងៗ និងតាមអ៊ីនធើណែត ជាពិសេសឯកសារយោងសំខាន់ពី សៀវភៅដែល និពន្ធដោយ **បណ្ឌិត ឈុន ពហុ** និង **អនុបណ្ឌិត ងួនហេង**។ គោលបំណងនៃការរៀបរៀង សៀវភៅនេះ គឺដើម្បី ជាឯកសារបន្ថែមទៅកាន់ និស្សិត ដែលកំពុងសិក្សាក្នុង មហាវិទ្យាល័យ អភិវឌ្ឍជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលនាងខ្ញុំកំពុងបង្រៀនផ្ទាល់ផង អោយបានយល់ដឹងពីការវិវត្តន៍នៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។គួរបញ្ជាក់ថា វាពុំមែនជារឿងចៃដន្យនោះទេ ដែលមុខវិជ្ជាប្រវត្តិ សេដ្ឋកិច្ចរបស់ប្រទេសនិមួយៗ ត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ដោយដាក់បញ្ចូលមុខវិជ្ជានេះ ទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិរបស់គេ នៅតាមបណ្ដាគ្រឹះស្ថានឧត្តមសិក្សានានាដើម្បីស្វែងយល់អំពីអត្ថប្រយោជន៏នៃការសិក្សាជាដំបូងយើង គប្បីស្វែងយល់ថាតើមុខវិជ្ជានេះបាននាំមកនូវសារសំខាន់អ្វីខ្លះដល់អ្នកសិក្សា ?ចំពោះការសិក្សាលើមេរៀនប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា បាននាំមកនូវសារសំខាន់ជាច្រើនដូចខាងក្រោមនេះ៖

• ក្រុមទីមួយ៖ សំដៅលើក្រុមអ្នកដែលមានសមត្ថកិច្ចគ្រប់គ្រង ចាត់ចែងគោលនយោបាយសេដ្ឋកិច្ចជាតិ ក្នុងវិធានការដកស្រង់នូវបទពិសោធន៍ល្អៗ សម្រាប់ដាក់បញ្ចូលក្នុងកញ្ចប់យុទ្ធសាស្ត្រនៃការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាតិប្រកបដោយស្ថេរភាព និងប្រសិទ្ធភាពខ្ពស់។

• ក្រុមទីពីរ ៖ សំដៅលើអ្នកសិក្សាទូទៅ ក៏ដូចជាប្រជាពលរដ្ឋដែល ត្រូវចូលរួមក្នុងចរន្តកោសិការនៃសេដ្ឋកិច្ច-សង្គម ហើយដោយផ្អែកលើ បទពិសោធន៍ក្នុងមេរៀននេះ ធ្វើអោយគេចេះបត់បែនសម្របសម្រួល ខ្លួនទៅតាមលំនាំនៃបរិយាកាសនៃការអភិវឌ្ឍសេដ្ឋកិច្ច ដែលកំពុងតែកើតមានឡើងហើយអាចទាញយកអត្ថប្រយោជន៍ដល់សង្គមគ្រួសាររបស់ខ្លួន។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នករាល់គ្នា នាងខ្ញុំសប្បាយចិត្ត ទទួលយកយោបល់ ហើយប្រមូលយកជាគំនិតបន្ថែម ពីអស់លោកអ្នក និង មិត្តអ្នកអានទាំងអស់។ ដោយក្ដីគោរពពីនាងខ្ញុំ ហ៊ីង សាលីន។

ថ្ងៃ .............. ខែ................. ឆ្នាំ..................... ព.ស ............

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........... គ.ស ២០២១

**អ្នកនិពន្ធ**

**លោកស្រី ហ៊ីង សាលីន**

# អ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ លោកស្រី **ហ៊ីង សាលីន**

**អាស័យដ្ឋាន** ៖ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ ភ្នំពេញ

**ស្ថាប័នការងារ** ៖ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ឯកទេស ឬមុខជំនាញ** ៖ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍជនបទ

**ប្រវត្តិការសិក្សា** ៖ អនុបណ្ឌិតផ្នែក សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

**បទពិសោធន៍ការងារ** ៖ គ្រូបង្រៀននៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ១៩៩៨-បច្ចុប្បន្ន

# សហអ្នកនិពន្ធ

នាម និងគោត្តនាម ៖ បណ្ឌិត **ឈុន ពហុ**

អាស័យដ្ឋាន ៖ ចំការឪឡឹក សង្កាត់កាកាប
ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ

ស្ថាប័នការងារ ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

ឯកទេស ឬមុខជំនាញ ៖ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ប្រវត្តិការសិក្សា ៖ អនុបណ្ឌិតផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ច
ថ្នាក់បណ្ឌិតផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ច

បទពិសោធន៍ការងារ ៖ ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច និងមានស្នាដៃ និពន្ធ និងបោះពុម្ពសៀវភៅសេដ្ឋកិច្ចកម្ពុជា, សេដ្ឋកិច្ចកសិកម្ម និងការអភិវឌ្ឍជនបទ , ហិរញ្ញវត្ថុសាធារណៈ , វិធីសា ស្ត្រ ស្រាវជ្រាវ ,មូលដ្ឋានគ្រឹះនៃទ្រឹស្តីទេសចរណ៍ , ការគ្រប់គ្រងគោលដៅទេសចរណ៍ , សេដ្ឋកិច្ចទេសចរណ៍ ។

# មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

**ទំព័រ**

ឧទ្ទិសកថា ................................................ Error! Bookmark not defined.

សេចក្តីថ្លែងអំណរគុណ ................................................ i

អារម្ភកថា ................................................ ii

**ជំពូកទី១ ទ្រឹស្តីជាមូលដ្ឋានជុំវិញបរិបទ ប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច**

១.១ បុព្វកថាបទ ................................................ ១

១.២. សញ្ញាណនៃវាក្យសព្ទ ប្រវត្តិសាស្ត្រ ................................................ ១

១.៣. សញ្ញាណនៃវាក្យសព្ទ សេដ្ឋកិច្ច ................................................ ២

១.៤. អត្ថប្រយោជន៍នៃការសិក្សាអំពី ប្រវត្តិសេដ្ឋកិច្ច ................................................ ៥

**ជំពូកទី២ សេដ្ឋកិច្ចប្រទេសកម្ពុជា សម័យហ្វូណន និងចេនឡា ឆ្នាំ ៥០ ដល់ ៨០២**

២.១. លំនាំកថាបទ ................................................ ៧

២.២. ស្ថានភាពនយោបាយសម័យហ្វូណន និងចេនឡា ................................................ ៨

២.៣. ស្ថានភាពសេដ្ឋកិច្ចសម័យហ្វូណន និងចេនឡា ................................................ ១១

២.៣.១ ការស្វែងយល់អំពីឫសគល់សេដ្ឋកិច្ចមុនសម័យហ្វូណន ................................................ ១១

២.៣.២ សេដ្ឋកិច្ចកម្ពុជាសម័យហ្វូណន ................................................ ១២

២.៣.៣ សេដ្ឋកិច្ចកម្ពុជាសម័យចេនឡា ................................................ ១៥

២.៤. សេចក្តីសន្និដ្ឋាន ................................................ ១៦

**ជំពូកទី៣ សេដ្ឋកិច្ចប្រទេសកម្ពុជានាសម័យអង្គរ ឆ្នាំ ៨០២ - ១៤៣៤**

៣.១. ស្ថានភាពនយោបាយសម័យអង្គរ ឆ្នាំ ៨០២ - ១៤៣៤ ................................................ ១៨

៣.១.១ ស្ថានភាពនយោបាយក្នុងយុគសម័យអង្គរដំបូង ................................................ ១៨

៣.១.២ ស្ថានភាពនយោបាយសម័យអង្គរ ឆ្នាំ ៩៤៤ ដល់ ១២១៩ ................................................ ១៩

៣.១.៣ ស្ថានភាពនយោបាយចុងសម័យអង្គរឆ្នាំ ១២១៩-១៤៣៤ ................................................ ២៤

៣.១.៤ សេចក្ដីសន្និដ្ឋាន ..................................................... ២៦

៣.២. ទស្សនៈទាន នៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអង្គរ ..................................................... ២៧

៣.៣. វិស័យកសិកម្មនាសម័យអង្គរ ..................................................... ៣០

៣.៣.១ ផលិតកម្មដំណាំស្រូវ ..................................................... ៣១

៣.៣.២ ការនេសាទ ចិញ្ចឹមសត្វ និង ដំណាំរួមផ្សំ ..................................................... ៣២

៣.៤. វិស័យសិប្បកម្ម និង ឧស្សាហកម្ម ..................................................... ៣២

៣.៤.១ វិស័យសិប្បកម្មគ្រឿងប្រដាប់ប្រដាប្រើប្រាស់ ..................................................... ៣៣

៣.៤.២ វិស័យសិប្បកម្មចំណីអាហារ ..................................................... ៣៣

៣.៤.៣ វិស័យឧស្សាហកម្ម ..................................................... ៣៣

៣.៥ វិស័យសេវាកម្ម ..................................................... ៣៥

៣.៥.១ វិស័យគមនាគមន៍ ..................................................... ៣៥

៣.៥.២ វិស័យពាណិជ្ជកម្ម ..................................................... ៣៦

៣.៥.៣ ហិរញ្ញវត្ថុនិង ធនាគារ ..................................................... ៣៨

៣.៦. ការធ្លាក់ចុះសេដ្ឋកិច្ចសម័យអង្គរ ..................................................... ៣៨

៣.៦.១ បញ្ហាសង្គ្រាមជាមួយបរទេស ..................................................... ៣៨

៣.៦.២ បញ្ហាបរិស្ថានធម្មជាតិ ..................................................... ៣៨

៣.៦.៣ ការធ្លាក់ចុះនៃផលិតផលកសិកម្ម ..................................................... ៤០

៣.៦.៤ តំហយប្រជាជន ..................................................... ៤០

៣.៦.៥ តម្រូវការធនធានទ្រទ្រង់វិស័យសាសនា ..................................................... ៤១

៣.៦.៦ ចំណាយខ្ពស់លើកិច្ចការសំណង់ប្រាសាទ និងដង្វាយព្រះ ..................................................... ៤២

៣.៧. សេចក្ដីសន្និដ្ឋាន ..................................................... ៤៣

**ជំពូកទី៤ សេដ្ឋកិច្ចប្រទេសកម្ពុជានាសម័យក្រោយអង្គរ ឆ្នាំ ១៤៣៤ - ១៨៦៣**

៤.១. ស្ថានភាពនយោបាយ ..................................................... ៤៤

៤.១.១ ស្ថានភាពនយោបាយសម័យចតុមុខ ឆ្នាំ ១៤៣៤-១៥២៨ ..................................................... ៤៤

៤.១.២ ស្ថានភាពនយោបាយសម័យលង្វែក ឆ្នាំ ១៥២៩-១៥៩៥ ..................................................... ៤៥

៤.១.៣ ស្ថានភាពនយោបាយសម័យឧដុង្គ ឆ្នាំ ១៦២០-១៨៦៣..................................៤៧

៤.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច..................................................... ៥០

៤.២.១ សម័យចតុមុខ (១៤៣៤-១៥២៥) ............................................... ៥០

៤.២.២ សម័យលង្វែក (១៥២៩-១៥៩៥)................................................ ៥១

៤.២.៣ សម័យឧដុង្គមានជ័យ (១៦២០-១៨៦៣) .................................... ៥២

៤.៣. ស្ថានភាពវិស័យសេដ្ឋកិច្ច-សង្គម .......................................................៥៣

៤.៣.១ វិស័យកសិកម្ម.........................................................................៥៣

៤.៣.២ វិស័យសិប្បកម្ម និងឧស្សាហកម្ម.............................................. ៥៤

៤.៣.៣ វិស័យពាណិជ្ជកម្ម.................................................................... ៥៤

៤.៣.៤ វិស័យហិរញ្ញវត្ថុ ......................................................................៥៧

៤.៣.៥ វិស័យសំណង់ និងគមនាគមន៍.................................................. ៥៨

៤.៤. វិស័យសិក្សាធិការជាតិ .................................................................. ៥៨

៤.៥. វិស័យបរិស្ថាន............................................................................... ៥៩

៤.៦. សេចក្តីសន្និដ្ឋាន ............................................................................ ៥៩

**ជំពូកទី ៥ សេដ្ឋកិច្ចប្រទេសកម្ពុជា សម័យអាណានិគមនិយមបារាំង ឆ្នាំ ១៨៦៣-១៩៥៣**

៥.១. ស្ថានភាពនយោបាយ ...................................................................... ៦១

៥.១.១ ស្ថានភាពនយោបាយមុនឆ្នាំ ១៨៦៣ ........................................... ៦១

៥.១.២ ស្ថានភាពនយោបាយក្នុងសម័យអាណាព្យាបាលបារាំង.......................៦៣

៥.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច..................................................... ៦៤

៥.៣. ស្ថានភាពវិស័យសេដ្ឋកិច្ច................................................................. ៦៦

៥.៣.១ វិស័យកសិកម្ម........................................................................ ៦៦

៥.៣.២ វិស័យសិប្បកម្ម និងឧស្សាហកម្ម.............................................. ៨៥

៥.៣.៣. វិស័យសេវាកម្ម...................................................................... ៩១

៥.៤. វិស័យហិរញ្ញវត្ថុ និងធនាគារ ........................................................... ១០២

៥.៤. ១ ការយកពន្ធលើមនុស្ស.............................................................. ១០៣

៥.៤. ២ វិស័យពន្ធដារលើផ្នែកកសិកម្ម ............................................................................ ១០៣
៥.៤.៣ ការប្រើប្រាស់រូបិយវត្ថុ ............................................................................ ១០៥
៥.៥. វិស័យគមនាគមន៍សាធារណៈ ............................................................................ ១០៥
៥.៦. វិស័យសិក្សាធិការជាតិ ............................................................................ ១០៥
៥.៧. សេចក្តីសន្និដ្ឋាន ............................................................................ ១០៦

**ជំពូកទី ៦ ប្រវត្តិសេដ្ឋកិច្ចប្រទេសកម្ពុជា សម័យសង្គមរាស្ត្រនិយម ឆ្នាំ ១៩៥៣ - ១៩៧០**

៦.១. ស្ថានភាពនយោបាយ ............................................................................ ១១០
៦.១.១ ស្ថានភាពនយោបាយមុនឆ្នាំ ១៩៥៣ ............................................................................ ១១០
៦.១.២ ស្ថានភាពនយោបាយ ឆ្នាំ ១៩៥៣-១៩៧០ ............................................................................ ១១២
៦.១.៣ សេចក្តីសន្និដ្ឋាន ............................................................................ ១១៣
៦.២. ទស្សនៈទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ............................................................................ ១១៤
៦.៣. ស្ថានភាព សេដ្ឋកិច្ចសម័យសង្គមរាស្ត្រ ............................................................................ ១១៦
៦.៣.១ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ............................................................................ ១១៦
៦.៣.២ វិស័យកសិកម្ម ............................................................................ ១១៦
៦.៣.៣ វិស័យឧស្សាហកម្ម និងភោគទ្រព្យរ៉ែ ............................................................................ ១២៧
៦.៣.៤ វិស័យសេវាកម្ម ............................................................................ ១៣៨
៦.៤. វិស័យសិក្សាធិការជាតិ ............................................................................ ១៥៤
៦.៥. វិស័យសុខាភិបាលសាធារណៈ ............................................................................ ១៥៨
៦.៦. វិស័យសង្គមកិច្ច ............................................................................ ១៦០
៦.៧. សេចក្តីសន្និដ្ឋាន ............................................................................ ១៦១

**ជំពូកទី ៧ សេដ្ឋកិច្ចប្រទេសកម្ពុជាសម័យសាធារណៈរដ្ឋខ្មែរ ឆ្នាំ ១៩៧០ - ១៩៧៥**

៧.១. ស្ថានភាពនយោបាយ ............................................................................ ១៦៤
៧.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច ............................................................................ ១៦៥
៧.៣. ស្ថានភាពសេដ្ឋកិច្ច ............................................................................ ១៦៥

៧.៣.១ វិស័យកសិកម្ម.......................................................................................១៦៥
៧.៣.២ វិស័យឧស្សាហកម្ម...................................................................................១៦៧
៧.៣.៣ វិស័យសេវាកម្ម .......................................................................................១៦៨
៧.៤. សេចក្តីសន្និដ្ឋាន ..........................................................................................១៧០

**ជំពូកទី ៨ សេដ្ឋកិច្ចប្រទេសកម្ពុជា សម័យកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៥-១៩៧៩**

៨.១. ស្ថានភាពនយោបាយ .....................................................................................១៧១
៨.២. ស្ថានភាពវិស័យសេដ្ឋកិច្ច ...............................................................................១៧៤
៨.២.១ វិស័យកសិកម្ម .......................................................................................១៧៤
៨.២.២ វិស័យឧស្សាហកម្ម និងសិប្បកម្ម ..................................................................១៧៥
៨.២.៣ វិស័យសេវាកម្ម.......................................................................................១៧៦
៨.៣. វិស័យសិក្សាធិការជាតិ.....................................................................................១៧៦
៨.៤. វិស័យសុខាភិបាលសាធារណៈ ............................................................................១៧៧
៨.៥. វិស័យសង្គមកិច្ច ............................................................................................១៧៨
៨.៦.សេចក្តីសន្និដ្ឋាន .............................................................................................១៧៨

**ជំពូកទី ៩ សេដ្ឋកិច្ចកម្ពុជា សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ ១៩៧៩ - ១៩៨៨**

៩.១. ស្ថានភាពនយោបាយ .....................................................................................១៨១
៩.២. ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច - សង្គម .....................................................១៨២
៩.៣. ផលវិបាកនៃការបាត់បង់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច - សង្គម....................................១៨៣
៩.៤. ទស្សនៈទាននៃការស្តារ និងការកសាងសេដ្ឋកិច្ច - សង្គម..........................................១៨៥
៩.៥. ស្ថានភាព សេដ្ឋកិច្ច - សង្គម ឆ្នាំ ១៩៧៩ ដល់ ១៩៨៨ ..........................................១៨៥
៩.៥.១ វិស័យកសិកម្ម.......................................................................................១៨៦
៩.៥.២ វិស័យឧស្សាហកម្ម-សិប្បកម្ម......................................................................១៩០
៩.៦. ការវិនិយោគសាធារណៈ.....................................................................................១៩៦

៩.៧. ការងារសហប្រតិបត្តិការ សេដ្ឋកិច្ចលើពិភពលោក ........ ១៩៧

៩.៨. វិស័យសិក្សាធិការជាតិ សុខាភិបាល និងវប្បធម៌សង្គម ........ ១៩៨

៩.៨.១ វិស័យការសិក្សាអប់រំ ........ ១៩៨

៩.៨.២ វិស័យសុខាភិបាលសាធារណៈ ........ ១៩៩

៩.៨.៣ វិស័យសង្គមកិច្ច ........ ១៩៩

៩.៩. ក្របខណ្ឌការងារពលកម្មសង្គម ........ ២០០

៩.១០.សេចក្តីសន្និដ្ឋាន ........ ២០០

**ជំពូកទី ១០ សេដ្ឋកិច្ចប្រទេសកម្ពុជា នាសម័យរដ្ឋកម្ពុជា ឆ្នាំ ១៩៨៩-១៩៩៣**

១០.១. ព្រឹត្តិការណ៍នយោបាយ ........ ២០៣

១០.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច - សង្គម ........ ២០៤

១០.២.១ ការធ្វើកំណែទម្រង់ក្នុងវិស័យកសិកម្ម ........ ២០៥

១០.២.២ កំណែទម្រង់ឧស្សាហកម្ម ........ ២០៥

១០.២.៣ កំណែទម្រង់វិស័យសេវាកម្ម ........ ២១១

១០.៣. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ........ ២១១

១០.៣.១ ទំហំផលិតកម្មកសិកម្មក្នុង GDP ........ ២១១

១០.៣.២ ទំហំវិស័យឧស្សាហកម្មក្នុង GDP ........ ២១២

១០.៣.៣ ទំហំវិស័យសេវាកម្មក្នុង GDP ........ ២១២

១០.៤. ស្ថានភាពសេដ្ឋកិច្ច-សង្គម ........ ២១៥

១០.៤.១ វិស័យកសិកម្ម ........ ២១៥

១០.៤.៣ វិស័យសេវាកម្មឯកជន និងសាធារណៈ ........ ២១៩

១០.៥. ការងារវិនិយោគ ........ ២២២

១០.៥.១ វិនិយោគសាធារណៈ ........ ២២២

១០.៥.២ វិនិយោគឯកជន ........ ២២២

១០.៦. វិស័យសិក្សាអប់រំ ........ ២២៣

១០.៧. វិស័យសុខាភិបាលសាធារណៈ ..... ២២៤
១០.៨. ការងារសង្គមកិច្ច ..... ២២៥
១០.៩. វិស័យពត៌មាន និងវប្បធម៌ ..... ២២៦
១០.១០. ការគ្រប់គ្រងបរិស្ថាន ..... ២២៦
១០.១១. សេចក្ដីសន្និដ្ឋាន ..... ២២៦

**ជំពូកទី ១១ បង្កើតផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម**

**បណ្ណាល័យសាស្ត្រ**

# ជំពូកទី១
# ទ្រឹស្តីជាមូលដ្ឋានជុំវិញបរិបទ ប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច

## ១.១ មុខសញ្ញា បទ

ក្នុងការសិក្សាអំពីរឿងរ៉ាវប្រវត្តិសាស្ត្រផ្សេងៗ។ ទោះបីជារឿងរ៉ាវ ប្រវត្តិសាស្ត្រ ដែលទាក់ទងទៅនឹងប្រវត្តិពង្សាវតារនៃមនុស្សជាតិ ប្រវត្តិព្រឹត្តិការណ៍នយោបាយ ប្រវត្តិកំណកំណើតនៃផែនដី ឬប្រវត្តិនៃវិស័យ សេដ្ឋកិច្ចសង្គមក៏ដោយ គឺអាស្រ័យដោយមានការសិក្សាស្រាវជ្រាវត្រឹមត្រូវទៅតាមលក្ខណៈវិទ្យាសាស្ត្រជាមូលដ្ឋាន។ ជាពិសេសក្នុងការសិក្សា របស់យើងអ្នកសិក្សាគប្បីស្វែងយល់អំពីសញ្ញាណនៃវាក្យសព្ទ ប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច ជាមុនសិន ដែលជាពាក្យគន្លឹះនៃវិទ្យាសាស្ត្រនេះ។ បន្ទាប់ពីនោះ ទើបដំណើរការនៃការសិក្សា អាចប្រព្រឹត្តទៅបាន តាមរយៈការប្រើប្រាស់ឯកសារស្នាដៃទាំងឡាយ ដែលបានកត់ត្រាទុកឬចារឹកទុកជាព័ត៌មាន និងតាមរយៈវិធីសាស្ត្រផ្សេងៗទៀត។ ហេតុដូចនេះ តើសញ្ញាណនៃវាក្យសព្ទ ប្រវត្តិសាស្ត្រ និង សេដ្ឋកិច្ច មានអត្ថន័យ ខ្លឹមសារដូចម្តេចខ្លះ ?

## ១.២. សញ្ញាណនៃវាក្យសព្ទ ប្រវត្តិសាស្ត្រ

វាក្យសព្ទ ប្រវត្តិ ឬ បវត្តិ សំដៅលើដំណឹង ការប្រព្រឹត្តិទៅ ឬការប្រព្រឹត្តរៀងមក ឬ ពង្សាវតារ ឬរឿងរ៉ាវរបស់មនុស្ស។ ចំពោះ វាក្យសព្ទ សាស្ត្រ សំដៅលើ គម្ពីរ គម្ពីរសាសនា គម្ពីរប្រាប់វិទ្យា ក្បួនតម្រា ច្បាប់ប្រដៅ វិជ្ជា ការសិក្សា ការណែនាំ ពាក្យបង្គាប់។ ពាក្យសាស្ត្រ បានក្លាយមកពីពាក្យ សស្ត្រ។ ហើយពាក្យ សាស្ត្រ ក៏បានប្រើ ទៅជាពាក្យ សាស្ត្រា ដែលក្រោយមកបានប្រើជា សាត្រា ដែលប្រើចំពោះគម្ពី ឬច្បាប់ប្រដៅដែលចារដោយស្លឹករឹត។ ឧទាហរណ៍៖ សាត្រាច្បាប់ ឬសាត្រាទេសន៍។ ម្យ៉ាងទៀត ពាក្យនេះក៏ជាពាក្យឬ ដែលគេប្រើរួមគ្នាដូចជា សាស្ត្រក្រឹត្យ មានន័យថា អ្នកចេះសាស្ត្រ ឬអ្នកប្រាជ្ញខាងសាស្ត្រ។ រីឯពាក្យ សាស្ត្រាចារ្យ សំដៅលើ គ្រូបង្រៀនសាស្ត្រ ។ល។

ដូច្នេះ វាក្យសព្ទ ប្រវត្តិសាស្ត្រ មានន័យថា គម្ពីរ ឬ ក្បួនដែលអត្ថាធិប្បាយអំពីពង្សាវតារប្រទេសជាតិ ឬព្រឹត្តិការណ៍នៃរឿងរ៉ាវនានា។

សរុបសេចក្តីមកវាក្យសព្ទ ប្រវត្តិសាស្ត្រ ក្នុងអត្ថន័យទូលំទូ លាយមានន័យថា ប្រវត្តិសាស្ត្រ ជាទូទៅត្រូវបានគេចាត់ទុកថា ជា រឿងរាវពិតស្តីអំពីអតីតកាលរបស់មនុស្ស។ ត្រង់នេះ សំដៅលើរឿងរ៉ាវប្រវត្តិសាស្ត្រដែលមានប្រភពឯកសារ(សំណេរ) ជាភស្តុតាង ។ទ ប្រហែលគ្នានេះដែរ បើតាមស្នាដៃខ្លះទៀត កំណត់ថាប្រវត្តិសាស្ត្រ ជារឿងរ៉ាវ ឬព្រឹត្តិការណ៍ផ្សេងៗ នៃពង្សាវតារមនុស្ស ឬធម្មជាតិដែលបាន

កើត ឡើងពីអតីតកាល និងត្រូវបានចងក្រងរក្សាទុកជាក្បួនច្បាប់ ដែលមានឈ្មោះអ្នកនិពន្ធបញ្ជាក់អំពីពេលវេលា និងទីកន្លែងហើយរក្សាទុកសម្រាប់ការសិក្សារបស់មនុស្សជំនាន់ក្រោយ។

លើសពីនេះទៀត តាមការសិក្សាស្រាវជ្រាវវាក្យសព្ទ ប្រវត្តិសាស្ត្រត្រូវបានបង្កប់ទៅដោយលក្ខណៈវិនិច្ឆ័យនៃវិទ្យាសាស្ត្ររបស់វា ក្នុងកម្រិតសណ្ឋានផ្សេងគ្នានៃតម្លៃប្រវត្តិសាស្ត្រ តាមរយៈទ្រង់ទ្រាយឯកសារ ២ យ៉ាងដូចខាងក្រោមនេះ ៖

- ឯកសារប្រវត្តិសាស្ត្រពិត

ជាឯកសារ ដែលចងក្រងឡើងដោយមនុស្សដែលរស់នៅកន្លែងនោះ ហើយបានសរសេរក្នុងពេលដែលព្រឹត្តិការណ៍នោះកំពុងកើតឡើង ឬមិនយូរប៉ុន្មានក្រោយពីព្រឹត្តិការណ៍នោះ។ ដូចជានៅតាមតំបន់នានា ជាច្រើននៅអាស៊ី-អាគ្នេយ៍ គឺមានពត៌មានអំពីរឿងរ៉ាវប្រវត្តិសាស្ត្រទាំងឡាយ ដែលបានរកឃើញតាមរយៈសិលាចារឹក ចារនៅលើផ្ទាំងថ្ម ឬលើលោហៈធាតុ។

- ឯកសារមូលប្រវត្តិសាស្ត្រ ( Proto-Historical )

ជាឯកសារ ប្រវត្តិសាស្ត្រមួយប្រភេទទៀត ដែលជាទូទៅគេបាន សរសេរអំពីព្រឹត្តិការណ៍ដែលកើតមានឡើងនៅក្នុងសម័យកាល និងទីកន្លែងដែលអ្នកសិក្សាកំពុងចងក្រង ក៏ប៉ុន្តែបានសរសេរឡើងដោយមនុស្សមកពីទីកន្លែងផ្សេង ដោយយោងទៅលើអ្វីៗ ដែលគេបានឃើញនៅខណៈពេលដែលគេកំពុងស្នាក់អាស្រ័យ ឬធ្វើទស្សនៈកិច្ចនៅទីនោះ ឬតាមរយៈឮគេនិយាយតៗគ្នាអំពីរឿងរ៉ាវទាំងនោះដោយប្រយោល។ ប្រភេទឯកសារមូលប្រវត្តិសាស្ត្រ មានសារៈសំខាន់ណាស់ ក្នុងពេលដែលពុំមានប្រភពព័ត៌មានល្អក្នុងស្រុក ឬក៏មានតិចតួច ហើយចំពោះតំបន់ទាំងឡាយនៅអាស៊ី-អាគ្នេយ៍យើងនេះ ជាទូទៅគឺមានរបាយការណ៍ចិនជាច្រើន ដែលបានកត់ត្រាស្តីអំពីទីកន្លែង ឬប្រវត្តិសាស្ត្រផ្សេងៗ។

គួរបញ្ជាក់ថា មានប្រភពឯកសារ ដែលជាឯកសារប្រវត្តិសាស្ត្រ មួយប្រភេទទៀត សម្បូរនៅអាស៊ី-អាគ្នេយ៍ គឺជាពង្សាវតារប្រវត្តិសាស្ត្រ បាលី ធម៌អារ្យ រឿងព្រេងប្រជាប្រិយនានា ដែលមនុស្សជំនាន់មុនបាន សរសេរនៅលើសម្ភារៈឆាប់ខូច ដូចជា សាស្ត្រស្លឹករឹត ។ ប្រភេទឯកសារ ទាំងនេះមិនបានស្ថិតនៅគង់វង្សលើសពី ២០០ ឆ្នាំនោះទេ ដោយសារ តែឥទ្ធិពលនៃអាកាសធាតុ និងបច្ចេកទេសនៃការថែរក្សាមិនបានប្រក្រតី ហើយដែលត្រូវបានគេចម្លងឡើងវិញជាហូរហែ។

នៅប្រទេសកម្ពុជា និងថៃ ពង្សាវតារប្រវត្តិសាស្ត្រប្រភេទខាងលើនេះ ត្រូវបានមនុស្សជំនាន់ដើម បានចារឹកទុកនៅលើសាស្ត្រស្លឹករឹត នៅសតវត្សទី១៤ ប៉ុន្តែចំណារអក្សរដែលនៅសេសសល់សឹងតែទាំងអស់ ត្រូវបានគេចម្លងឡើងវិញនៅចុងសតវត្សទី ១៨ ឬក្នុងសតវត្សទី១៩។[4]
ក្រៅពីការសិក្សាក្រោយៗទៀត ត្រូវបានគេសិក្សាតាមរយៈវិធីសាស្ត្រកំណាយបុរាណវត្ថុ (វិទ្យាសាស្ត្របុរាណវត្ថុ) នៅតាមបណ្តាស្ថានីយ៍ស្រាវជ្រាវនានា ដែលជាកន្លែងមនុស្សជំនាន់ដើមធ្លាប់បានរស់នៅ ឬស្រាវជ្រាវតាមវិធីសាស្ត្រថ្មីៗទៀត ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបៗធ្វើជាឧបករណ៍។និយាយជារួមបើការប្រមូលបានទិន្នន័យ ភស្តុតាងពីអតីតកាល តាមរយៈវិធីសាស្ត្រទាំងអស់ខាងលើនេះ បានកាន់តែច្រើន ធ្វើអោយយើងកាន់តែមានលទ្ធភាពស្វែងយល់ ជ្រួតជ្រាបបានកាន់តែប្រសើរ អំពីព្រឹត្តិការណ៍រឿងរ៉ាវប្រវត្តិសាស្ត្រទាំងអស់នោះ។

## ១.៣. សញ្ញាណនៃពាក្យសព្ទ សេដ្ឋកិច្ច

វាក្យសព្ទ សេដ្ឋកិច្ច ឬសេដ្ឋកម្ម មានប្រភពមកពីភាសាបាលី ឬសំស្ក្រឹត តែមួយដូចគ្នា ហើយពាក្យនេះ ផ្សំឡើងពីឫស២ គឺ សេដ្ឋ និងកិច្ច។ ពាក្យ សេដ្ឋមានន័យថា ប្រសើរបំផុត ប្រសើរលើសលប់ខ្ពង់ខ្ពស់ ឧដុង្គឧត្តម។ រីឯ វាក្យសព្ទ កិច្ច មានន័យថា ការដែលត្រូវធ្វើ អំពើ ឬការរវល់។[5]

ដូច្នេះ ពាក្យសេដ្ឋកិច្ច សំដៅលើកិច្ចការប្រសើរបំផុត ឬមុខរបរ ដ៏ឧត្តម ឬមុខការនៃរបរដែលមានប្រយោជន៍យ៉ាងសំខាន់។

នៅសម័យបុរាណ ពាក្យខាងលើនេះគេនិយមប្រើប្រាស់ទៅលើ របររកស៊ី ឬបញ្ជាក់អំពីអត្តសញ្ញាណនៃទ្រព្យធនរបស់បុគ្គល។ ឧទាហរណ៍៖ ពាក្យ សេដ្ឋការ (បើស្ត្រីប្រើជា សេដ្ឋការិកា) សំដៅលើអ្នកធ្វើ សេដ្ឋកិច្ច ឬធ្វើសេដ្ឋកម្ម។ រីឯពាក្យ សេដ្ឋា (បើស្ត្រីប្រើជា សេដ្ឋា) ដែលក្នុងសម័យយើងនេះជំនួសដោយពាក្យ សេដ្ឋី (បើស្ត្រីប្រើជា សេដ្ឋីនី) មានន័យថា ជាអ្នកមានទ្រព្យឧត្តម ឬអ្នកមានធំ។

តាមប្រពៃណីក្នុងសម័យបុរាណ បើទោះបីជាអ្នកមានទ្រព្យច្រើនយ៉ាងណាក៏ដោយ បើពុំមានការបញ្ជាក់នូវ ស្វេតចត្រ ទេ (ព្រះរាជក្រឹត្យ សម្រាប់យសសក្តិជាសេដ្ឋី) ដែលព្រះរាជាផ្តល់អោយ ឬអនុញ្ញាត មិនអាចហៅថា សេដ្ឋី បាននោះឡើយ។[7]

ផ្សេងពីនេះទៀត បើតាមការសិក្សារបស់ពួកអ្នកប្រាជ្ញសេដ្ឋវិទូបស្ចិមប្រទេសជាច្រើននាក់ ដែលបានសិក្សាទៅលើខ្លឹមសារនៃពាក្យ សេដ្ឋកិច្ច នេះគឺត្រូវបានពួកគេបកស្រាយផ្សេងៗគ្នា ទៅតាមបរិបទនៃទម្រង់ ផលិតកម្មសង្គម ដែលយើងនឹងពិនិត្យមើលដូចខាងក្រោម។

នៅសម័យបុរេប្រវត្តិសាស្ត្រ (មុនគ.ស) វាក្យសព្ទសេដ្ឋកិច្ចបានកើតចេញមកពីពាក្យឫស២ របស់ចក្រភពក្រិចគឺ OYCOS និងពាក្យ NONOS។ ពាក្យ OYCOS ប្រែថា ផ្ទះ និងការផ្គត់ផ្គង់ជីវភាព។ រីឯពាក្យ NOMOS មានន័យថា ច្បាប់ ឬនីតិ។ បើយើងសំយោគខ្លឹមសារខាងលើនេះ មានន័យថា ការផ្គត់ផ្គង់ជីវភាពគ្រួសារតាមមូលដ្ឋានច្បាប់ ។

ដោយសារតែការវិវត្តទៅមុខឥតឈប់ឈរនៃទម្រង់សេដ្ឋកិច្ច ធ្វើអោយនិយមន័យនៃវាក្យសព្ទសេដ្ឋកិច្ច ចេះតែមានការប្រែប្រួល ស្របទៅតាមបែបផែន ផលិតកម្មសង្គម និងតាមបរិយាកាសជាក់ស្តែង។

ពិសេសទៀត ដើម្បីស្វែងយល់អំពីនិយមន័យនៃពាក្យ សេដ្ឋកិច្ច យើងគប្បីពិចារណាទៅលើការប្រព្រឹត្តិទៅ និងធម្មជាតិនៃសកម្មភាពសេដ្ឋកិច្ចជាមុនសិន។ ពោលគឺបើសិនជាយើងពិនិត្យមើលទៅលើអ្វីៗ ទាំងអស់ដែលស្ថិតនៅជុំវិញយើង នោះត្រូវបានគេបែងចែកជា២ប្រភេទដាច់ពីគ្នា ក្នុងនោះមាន ៖

- សម្ភារៈដែលបានបង្កើតឡើងដោយធម្មជាតិសុទ្ធសាធដូចជា ដី ខ្យល់ សមុទ្រ ស្ទឹង ទន្លេ បឹង រ៉ែធម្មជាតិ ព្រៃព្រឹក្សាជាដើម។
- សម្ភារៈដែលបង្កើតឡើងដោយសារស្នាដៃមនុស្ស តាមរយៈការច្នៃប្រឌិត ប្រើប្រាស់ពីរូបធាតុដើមធម្មជាតិ ដែលរបស់របរទាំងនោះមាន សម្បត្តិជាសម្ភារៈ និងពុំមែនជាសម្ភារៈ(សេវាកម្ម) ។

ម្យ៉ាងទៀតបើការអភិវឌ្ឍនៃផលិតកម្មសង្គមមានសភាពកាន់តែរីកចម្រើន ធ្វើអោយការផលិតទ្រព្យសម្បត្តិ ជាសម្ភារៈ និងពុំមែនជាសម្ភារៈ ក៏មានលក្ខណៈកាន់តែប្រសើរឡើងដែរ។ ដើម្បីធ្វើអោយការរស់នៅរបស់មនុស្សប្រកបដោយភាពរុងរឿង ជាមួយនឹងភាពសម្បូរបែប មនុស្សជាការចាំបាច់ ត្រូវតែធ្វើសកម្មភាពផលិតកម្មឥតឈប់ឈរ នូវទ្រព្យសម្បត្តិដែលជាតម្រូវការរបស់ខ្លួន។

ឆ្លងតាមរយៈខ្លឹមសារខាងលើនេះ អាចធ្វើអោយយើងកំណត់បាននូវនិយមន័យសេដ្ឋកិច្ចបានថា សេដ្ឋកិច្ច គឺជាសកម្មភាពទាំងឡាយណាដែលទាក់ទងទៅនឹងការផលិតទ្រព្យសម្បត្តិជាសម្ភារៈ និងពុំមែនជាសម្ភារៈ(សេវាកម្ម)។[8]

ម្យ៉ាងទៀត ដើម្បីធ្វើអោយការសិក្សារបស់យើងកាន់តែស៊ីជម្រៅ ទៅលើខ្លឹមសារនៃវាក្យសព្ទសេដ្ឋកិច្ចនោះតម្រូវអោយយើងធ្វើការសិក្សាស្វែងយល់បន្ថែមទៀត នូវបាតុភូតនៃការកកើតឡើងនូវទិដ្ឋភាព ទាំងឡាយរបស់សេដ្ឋកិច្ច។ យើងមានឧទាហរណ៍ចំនួន ២ ដូចខាងក្រោម ដែលបង្ហាញអំពីបាតុភូតសេដ្ឋកិច្ចនេះ។

ឧទាហរណ៍ទី១៖ ក្នុងស្ថានការណ៍ដ៏អាក្រក់មួយរបស់បុរសម្នាក់ ដែលបានជិះទូកទៅទើរជាប់នៅលើកោះមួយដែលគ្មានមនុស្សរស់នៅ ហើយពុំអាចចេញដំណើរទៅមុខទៀតបាន ព្រោះទូករបស់គាត់ត្រូវបាន ខូចខាតទាំងស្រុង ដោយសារអំណាចនៃខ្យល់ព្យុះសមុទ្រ។ ដើម្បីបន្ត ជីវិតរស់នៅបុរសនោះ ក៏បានធ្វើសកម្មភាពក្នុងជីវភាពរស់នៅ តាម របៀបនៃមនុស្សនាសម័យបុរេប្រវត្តិសាស្ត្រ ដោយបានយកដុំថ្ម ដំបងមកធ្វើជាឧបករណ៍ប្រម៉ាញ់សត្វជាអាហារ និងបេះផ្លែឈើ បន្លែ ធ្វើជាអាហាររួមផ្សំ។

ឧទាហរណ៍ទី២៖ នៅសម័យបុព្វកាល មនុស្សសម័យដើមបានប្រើប្រាស់នូវឧបករណ៍សាមញ្ញៗ សម្រាប់ប្រម៉ាញ់សត្វធ្វើជាអាហារ។ សកម្មភាពផលិតកម្មបែបនេះ ពុំអាចសម្លាប់សត្វបាន ក្នុងបរិមាណគ្រប់គ្រាន់នោះទេ ហេតុនេះ មេកុលសម្ព័ន្ធ និងព្រឹទ្ធាចារ្យនាសម័យកាលនោះ បានដឹកនាំក្រុមកុលសម្ព័ន្ធ អោយចេះកែច្នៃឧបករណ៍ប្រម៉ាញ់ អោយកាន់តែមានប្រសិទ្ធភាព ដូចជាការប្រើប្រាស់គ្រាប់ព្រួញ ធ្វើអំពីលោហៈ និងប្រើសារជាតិពិសត្រាំជាមួយគ្រាប់ព្រួញ។ ក្រៅពីនោះ កុលសម្ព័ន្ធខ្លះទៀតបានប្រកបរបរដាំដុះជាបន្លែបង្ការ និងបេះផ្លែឈើ សម្រាប់ធ្វើជាចំណីអាហារបន្ថែម។

ការគ្រប់គ្រងផលិតកម្មតាមរយៈការចេះបែងចែកការងារពលកម្មប្រកបរបរចិញ្ចឹមជីវិត ស្របទៅតាមចំណង់ ចំណូលចិត្ត និងទេពកោសល្យពីធម្មជាតិ បានធ្វើអោយផលិតផលរបស់ពួកគេ មានបរិមាណកាន់តែច្រើនឡើងៗ លើសពីតម្រូវការគ្រួសារ ដែលទីបំផុត ជម្រុញអោយពួកគេធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញ ទៅមក តាមរយៈការដោះដូរគ្នានូវផលិតផលលើស ដូចជា សាច់សត្វ ត្រី បន្លែ ផ្លែឈើ ស្មារ ធ្នូ គ្រាប់ព្រួញ និងថ្នាំសង្កូវ ជាដើម។

សរុបមកក្នុងទិដ្ឋភាពនៃឧទាហរណ៍ទី១ យើងឃើញថា គឺមានលក្ខណៈទ្រង់ទ្រាយសាមញ្ញ ដោយធ្វើសកម្មភាពផលិតកម្មសម្រាប់តែការផ្គត់ផ្គង់ជីវិតផ្ទាល់ខ្លួនតែប៉ុណ្ណោះ ពុំទាន់កើតមានលក្ខណៈជាបាតុភូតនៃ សេដ្ឋកិច្ចនោះឡើយ។ ចំពោះទិដ្ឋភាពក្នុងឧទាហរណ៍ទី២ ទើបកើតមានលក្ខណៈទ្រង់ទ្រាយជាសេដ្ឋកិច្ចពិតប្រាកដពីព្រោះថា គេបានធ្វើសកម្មភាពសព្វគ្រប់ នៅក្នុងបាតុភូតសេដ្ឋកិច្ចដោយផ្តើមចេញពីការផលិតទំនិញ ការធ្វើទំនាក់ទំនងរវាងសង្គមមនុស្ស និងតាមរយៈការដោះដូរគ្នានូវរបស់របរនានា។

ដូច្នេះសេដ្ឋកិច្ចកើតមានឡើងនៅពេលណាដែលមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងមនុស្សនឹងមនុស្ស តាមរយៈទំនិញដែលជាសមិទ្ធិផលនៃផលិតកម្មសង្គម។

ដោយឡែកបើតាមទស្សនៈរបស់បិតាសេដ្ឋវិទូ Adam Smith បានកំណត់ថា សេដ្ឋកិច្ចគឺជាវិទ្យាសាស្ត្រនៃទ្រព្យធន ។ មានន័យថាជាទង្វើប្រកបដោយការគិតគូរ ពិចារណា ប្រៀបធៀប វិភាគត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ ដើម្បីទទួលបាននូវទ្រព្យធន។ ចំពោះអ្នកប្រាជ្ញសេដ្ឋ វិទូបារាំងគឺលោក Jean Baptiste Say នៅក្នុងឆ្នាំ ១៨០៣ បានកំណត់ថា សេដ្ឋកិច្ច (នយោបាយ) គឺជាការសិក្សាអំពីរបៀបផលិត បែងចែក និងប្រើប្រាស់ភោគទ្រព្យ។

ក្រៅពីនេះ ក៏មានការកំណត់ន័យនៃពាក្យសេដ្ឋកិច្ច ដែលកើតចេញពីការបញ្ចូលគ្នានូវទស្សនៈផ្សេងៗដោយលោក E.Malinvaud គឺសេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រដែលសិក្សាលើបញ្ហាថា តើធនធានកម្រត្រូវ បានប្រើប្រាស់យ៉ាងណា ដើម្បីបំពេញអោយសេចក្តីត្រូវការរបស់មនុស្ស ដែលរស់នៅក្នុងសង្គម។ វាបានយកចិត្តទុកដាក់មួយផ្នែកទៅលើប្រតិបត្តិការសំខាន់ៗដូចជា ផលិតកម្ម បែងចែក និងប្រើប្រាស់ និងមួយផ្នែកទៀត ទៅលើស្ថាប័ន និងទៅលើសកម្មភាពទាំងឡាយ ក្នុងគោលបំណងសម្របសម្រួលប្រតិបត្តិការទាំងនេះ។[១]

បើយើងធ្វើការសំយោគនិយមន័យទាំងអស់ ដែលបានលើកឡើងខាងលើនេះ យើងអាចកំណត់បានថា សេដ្ឋកិច្ច គឺជាវិទ្យាសាស្ត្រ សង្គមមួយ ព្រោះវាត្រូវបានយកចិត្តទុកដាក់ទៅលើកិច្ចការរបស់ មនុស្សដែលរស់នៅក្នុងការចាត់តាំងសកម្មភាពជាសមូហភាពមួយ។

សរុបសេចក្តីមក វាក្យសព្ទ ប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច ត្រូវបានអ្នកសិក្សាជាច្រើន ធ្វើការសិក្សាស្រាវជ្រាវ និងផ្តល់ជានិយមន័យ ច្រើនបែបយ៉ាង ក៏ប៉ុន្តែក្នុងការសិក្សារបស់យើង ចំពោះមេរៀននេះ មិនតម្រូវអោយយើង សិក្សាលម្អិតអំពីវិទ្យាសាស្ត្រនេះទេ ព្រោះគោលបំណង សំខាន់នៃការសិក្សារបស់យើង ត្រូវផ្តោតជាសំខាន់ទៅលើកត្តាប្រវត្តិសាស្ត្រសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ជាមូលដ្ឋាននៃសិក្សាតែប៉ុណ្ណោះ។

## ១.៤. អត្ថប្រយោជន៍នៃការសិក្សាអំពី ប្រវត្តិសេដ្ឋកិច្ច

គួរបញ្ជាក់ថា វាពុំមែនជារឿងចៃដន្យនោះទេ ដែលមុខវិជ្ជាប្រវត្តិ សេដ្ឋកិច្ចរបស់ប្រទេសនិមួយៗ ត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ដោយដាក់បញ្ចូលមុខវិជ្ជានេះ ទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិរបស់គេ នៅតាមបណ្តាគ្រឹះស្ថានឧត្តមសិក្សានានា។

ដើម្បីស្វែងយល់អំពីអត្ថប្រយោជន៍នៃការសិក្សាជាដំបូងយើង គប្បីស្វែងយល់ថាតើមុខវិជ្ជានេះ បាននាំមកនូវសារសំខាន់អ្វីខ្លះដល់អ្នកសិក្សា?

ចំពោះការសិក្សាលើមេរៀនប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា បាននាំមកនូវសារសំខាន់ជាច្រើនដូចខាងក្រោមនេះ៖

- បានផ្តល់នូវបទពិសោធន៍ទាំងល្អ និងអាក្រក់ផ្នែកសេដ្ឋកិច្ចសង្គមដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ឆ្លងកាត់រយៈពេលរាប់ពាន់ឆ្នាំ នៅគ្រប់សម័យកាល គ្រប់របបនយោបាយ និងគ្រប់របបនៃសង្គមខ្មែរ ។

- យល់ដឹងអំពីទំនាក់ទំនងរវាង វិស័យសេដ្ឋកិច្ច-សង្គម ដែលមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងវិស័យនយោបាយ វិស័យសង្គម-វប្បធម៌ សាសនា ធនធានធម្មជាតិ បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្តុ និង វិស័យសេដ្ឋកិច្ចខ្លួនឯង ក៏ដូចជាស្ថានភាពខាងក្រៅប្រទេស នៅតាមបណ្តាសម័យកាលផ្សេងៗគ្នា។
- យល់ដឹងអំពី ការគ្រប់គ្រងនយោបាយសេដ្ឋកិច្ចរបស់រដ្ឋ និងការប្រកបអាជីវកម្មរបស់ប្រជារាស្ត្រ ចាប់តាំងពីសម័យបុរេប្រវត្តិសាស្ត្រ សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណានិគមបារាំង សម័យសង្គមរាស្ត្រនិយម សម័យសង្គ្រាមសម័យ ប៉ុលពត រហូតមកដល់សម័យរដ្ឋកម្ពុជា។
- យល់ដឹងអំពីសក្តានុពលធនធានធម្មជាតិ លក្ខខណ្ឌធម្មជាតិ និងលក្ខខណ្ឌសេដ្ឋកិច្ចប្រទេសកម្ពុជា ដើម្បីបង្កភាពងាយស្រួលក្នុងការវាយតម្លៃអោយបានត្រឹមត្រូវ និងទាញយកផលប្រយោជន៍។

សរុបមក បើការយល់ដឹងបានស៊ីជម្រៅទៅលើកត្តាទាំងអស់ខាងលើនេះ នោះវានឹងបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់អ្នកសិក្សា ជាពិសេសទៅលើអ្នកសិក្សាពីរក្រុមដូចខាងក្រោមនេះ៖

- ក្រុមទីមួយ៖ សំដៅលើក្រុមអ្នកដែលមានសមត្ថកិច្ចគ្រប់គ្រង ចាត់ចែងគោលនយោបាយសេដ្ឋកិច្ចជាតិ ក្នុងវិធានការដកស្រង់នូវបទពិសោធន៍ល្អៗ សម្រាប់ដាក់បញ្ចូលក្នុងកញ្ចប់យុទ្ធសាស្ត្រនៃការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាតិប្រកបដោយស្ថេរភាព និងប្រសិទ្ធភាពខ្ពស់។
- ក្រុមទីពីរ ៖ សំដៅលើអ្នកសិក្សាទូទៅ ក៏ដូចជាប្រជាពលរដ្ឋដែល ត្រូវចូលរួមក្នុងចរន្តកោសិការនៃសេដ្ឋកិច្ច-សង្គម ហើយដោយផ្អែកលើ បទពិសោធន៍ក្នុងមេរៀននេះ ធ្វើអោយគេចេះបត់បែន សម្របសម្រួល ខ្លួនទៅតាមលំនាំនៃបរិយាកាសនៃការអភិវឌ្ឍសេដ្ឋកិច្ច ដែលកំពុងតែកើតមានឡើង ហើយអាចទាញយកអត្ថប្រយោជន៍ដល់សង្គមគ្រួសាររបស់ខ្លួន។

# ជំពូកទី២
# សេដ្ឋកិច្ចប្រទេសកម្ពុជា សម័យហ្វូណាន និងចេនឡា ឆ្នាំ ៥០ ដល់ ៨០២

## ២.១ លំនាំកថាបទ

ដែលយើង ព្រឹត្តិការណ៍នៃគម្ពីរប្រវត្តិសេដ្ឋកិច្ចប្រទេសកម្ពុជា កំពុងតែសិក្សានេះ ភាគច្រើនជាស្នាដៃដែលជាកំណត់ត្រារបស់បរទេស ជាពិសេស របស់អ្នកស្រាវជ្រាវជនជាតិចិន និងពួកអឺរ៉ុប ដែលធ្លាប់បានចូលមករស់នៅ មកស្រាវជ្រាវ ធ្វើជំនួញ ទំនាក់ទំនងការទូត ផ្សព្វផ្សាយ សាសនា ដំណើរផ្សងព្រេងរុករកទីកន្លែងថ្មីៗជាដើម។ ក្រៅពីនេះមាន ពត៌មានប្រវត្តិសាស្ត្រមួយចំនួនទៀត ទទួលបានតាមរយៈ ការចារឹកទុក លើផ្ទាំងសិលា លើជញ្ជាំងប្រាសាទ ឬសរសេរកត់ត្រាលើស្បែកសត្វ ឬ សាស្ត្រាស្លឹករឹត និងតាមរយៈស្នាដៃអ្នកស្រាវជ្រាវមុនៗ ឬតាមរយៈ មនុស្សដែលជាម្ចាស់ស្រុករស់នៅតំបន់នោះ ដែលពត៌មានទាំងអស់នេះ មានចំនួនតិចតួចណាស់ ហេតុនេះវាជាការលំបាកមួយសម្រាប់យើង ព្រោះឯកសារដែលរកបានមានចំនួនតិចតួចបំផុត ហើយស្ទើរតែពុំមានទំនាក់ទំនងរដោយត្រង់ជាមួយនឹងវិស័យសេដ្ឋកិច្ចទៀតផង។

ម៉្យាងទៀត បើយោងតាមពត៌មានដែលផ្តល់ដោយអ្នកស្រាវជ្រាវ ផ្នែកបុរាណវត្ថុវិទ្យាបារាំងដែលបានធ្វើការសិក្សា (ធ្វើកំណាយបុរាណ) នៅតាមបណ្តាស្ថានីយ៍នានាក្នុងប្រទេសកម្ពុជា ដូចជានៅស្ថានីយ៍សំរោងសែន (ខេត្តកំពង់ឆ្នាំង) ស្ថានីយ៍អន្លង់ល្ពៅ (ស្ថិតនៅ ៣០គ.ម ពី សំ រោងសែន) ស្ថានីយ៍ម្លូព្រៃ(ខេត្តព្រះវិហារ) ដែលបានសិក្សាតាំងពីសម័យ អាណានិគមនិយមមកនោះ បានហុចផលតិចតួចណាស់សម្រាប់វិទ្យាសាស្ត្រនេះ។ ចំពោះការសិក្សាស្រាវជ្រាវ អំពីបុរេប្រវត្តិសាស្ត្រខ្មែរ អោយបានច្បាស់លាស់មួយកម្រិតទៀត អាស្រ័យដោយមានការស្រាវជ្រាវរក ឃើញនៅស្ថានីយ៍ថ្មីៗទៀត ជាពិសេសនៅតំបន់ស្ទួល និងនៅស្រុក សំបូរ ខេត្តក្រចេះ) នៅល្អាងស្ពាន (ខេត្តបាត់ដំបង) និងថ្មីៗនេះទៀត នៅអង្គរបុរី (ខេត្តតាកែវ) និងស្ថានីយ៍ក្បាលរមាស។[10]

នៅលើទឹកដីខ្មែរសព្វថ្ងៃនេះ តាំងតែពីសម័យបុរេប្រវត្តិសាស្ត្រ គេបានរកឃើញនូវសំណង់វប្បធម៌ថ្មបំបែកដែលមានអាយុកាលចាប់ពី ៧០០.០០០ ឆ្នាំ ដល់ ៦៨០.០០០ ឆ្នាំ មុនគ.ស។ ឧស្សាហកម្មថ្មបំបែក ដំបូងនេះ ដែលបានស្រាវជ្រាវដោយលោក អេម៉ុង សូរ៉ង់ នៅឆ្នាំ១៩៦៣ ស្ថិតនៅត្រង់ម្តុំស្រែស្បូវ តាមដងទន្លេមេគង្គ ចន្លោះខេត្តស្ទឹងត្រែង និងក្រចេះ និងតំបន់អង្គរ និងទីកន្លែងផ្សេងទៀត ដូចជា តាមដងទន្លេដូណៃ (កម្ពុជាក្រោម)។ នៅតំបន់ទាំងនោះ គេបានរកឃើញ ឧបករណ៍ពូថៅដៃដែលមានស្នាមភ្លើងរោល ដែលបញ្ជាក់អំពីបុព្វបុរសខ្មែរសម័យនោះ ចេះប្រើភ្លើងរួចទៅហើយ ដើម្បីចំអិនអាហារ ហើយបានរស់នៅជាក្រុម តូចៗ នៅតាមខ្ពង់រាប និង ចង្កេះភ្នំ ប្រកបរបរបាញ់សត្វ បេះភោគផលពី ធម្មជាតិ និងដាំដើមឈើបន្តិចបន្តួចជុំវិញលំនៅដ្ឋាន។ ដោយសំអាង លើលក្ខណៈរបស់

ឧស្សាហកម្មថ្មសម័យនោះ អាចកំណត់បានអំពីអាយុ កាលនៃវប្បធម៌ថ្មបំបែកនេះ គឺ រវាង ៧០០,០០០ ឆ្នាំ ទៅ១២០.០០០ ឆ្នាំ មុន គ.ស។

គួរបញ្ជាក់ថា ភាគច្រើននៃពត៌មានប្រវត្តិសាស្រ្តដែលទទួលបាន ពីការធ្វើកំណាយបុរាណវត្ថុនៅបណ្តាស្ថានីយ៍ស្រាវជ្រាវទាំងនោះ ច្រើនតែឆ្លុះបញ្ចាំងអំពីវត្ថុប្រើប្រាស់របស់ខ្មែរយើង ក្នុងយុគសម័យថ្មរំលីង និងយុគសម័យលោហៈ(រវាង ១០.០០០ ដល់ ៥.០០០ ឆ្នាំ មុនគ.ស) គឺជាសម័យវប្បធម៌លោហធាតុធ្វើអំពីស្ពាន់ បន្ទាប់មកចូល ដល់សម័យកាលវប្បធម៌សំរិទ្ធ។ ចាប់ពីឆ្នាំ ២០០០ ដល់ឆ្នាំ ៥០០ មុន គ.ស ដែលគេបានរកឃើញនូវគ្រឿងសាស្រ្តាវុធ និងរបស់របរប្រើប្រាស់ គ្រឿងអលង្ការ ដែលធ្វើអំពីដែក (យើងនឹងសិក្សាលម្អិត អំពីការងារនេះនៅក្នុងវិស័យសិប្បកម្មផលិតកម្មនៃជំពូកនេះ)។[11]

ផ្សេងពីនេះទៀត គួររំលឹកដែរថា ថ្វីត្បិតតែបាតុភូតនៃការកើត វិស័យសេដ្ឋកិច្ចឡើងជុំវិញវិស័យសេដ្ឋកិច្ច-សង្គម គឺមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធ ជាមួយនឹងវិស័យដ៏ទៃទៀតដូចជា នយោបាយសង្គម-វប្បធម៌ វិស័យច្បាប់ និងកត្តាធនធានធម្មជាតិក៏ដោយ ក៏ប៉ុន្តែការសិក្សារបស់យើងក្នុង ស្នាដៃនេះគឺផ្តោតជាសំខាន់ តែទៅលើការសិក្សាដែលទាក់ទងទៅនឹង វិស័យសេដ្ឋកិច្ច និងសង្គម តែប៉ុណ្ណោះ និងមានការសិក្សាបន្តិចបន្តួចជាមួយនឹងវិស័យនយោបាយ ព្រោះតែវិស័យនេះ ជាទូទៅជាប់ពាក់ព័ន្ធនឹង និងសង្គមច្រើនជាងគេ។

## ២.២. ស្ថានភាពនយោបាយសម័យហ្វូណន និងចេនឡា

ព្រះរាជាណាចក្រហ្វូណន បានចាប់កំណើតក្នុងអំឡុងដើម សតវត្សទី១ នៃគ.ស រហូតដល់ពាក់កណ្តាលនៃសតវត្សទី៦ (គ.ស ៥៥០) ដែលដំបូងឡើយ គ្រប់គ្រងដោយព្រះមហាក្សត្រីមួយអង្គព្រះនាម លីវ យី។ ពាក្យថា "ហ្វូណន" នេះ ចិនបុរាណអានថា ប៉ឺយូណាម ដែលត្រាប់តាមសម្លេងខ្មែរដើមហៅថា "វ្នំ" ដែលបានក្លាយវិវត្តន៍បន្តិចម្តងៗសម្រាប់ភាសាខ្មែរសព្វថ្ងៃហៅថា ភ្នំ ។ ដូច្នេះ សម័យហ្វូណន ឬ សម័យនគរភ្នំ គឺមានន័យតែមួយ។

តាមបម្រាប់ប្រវត្តិសាស្រ្តបង្ហាញថា មកដល់ដើម គ.ស យើងនេះ មានជនជាតិឥណ្ឌាជាច្រើននាក់បាននិរទេសខ្លួន ធ្វើចំណាកស្រុកមក រស់នៅតំបន់អាស៊ី-អាគ្នេយ៍យើងនេះ ក្នុងហេតុផលស្វែងរកមាសប្រាក់ ធ្វើ ជំនួញ ផ្សព្វផ្សាយសាសនា និងធ្វើចម្បាំង។

នៅ គ.ស ឆ្នាំ ៥០ ទ័ពសំពៅឥណ្ឌា ក្រោមការគ្រប់គ្រងរបស់ ព្រាហ្មណ៍ ហ៊ុន ទៀន បានចូលមកដល់ទឹកដីហ្វូណន បង្កើតបានជា ចម្បាំងរាំងជល់ជាមួយស្តេចខ្មែរ គឺព្រះនាង លីវ យី ។ ទ័ពសំពៅរបស់ ព្រាហ្មណ៍ ហ៊ុន ទៀន យកជ័យជំនះលើម្ចាស់ស្រុក ហើយបានប្រកាស តែងតាំងខ្លួនជាស្តេចលើទឹកដីភូមិភាគសណ្តូ។ ក្រោយមកព្រះបាទ ហ៊ុន ទៀន ក៏បានរៀបព្រះរាជអភិសេកជាមួយព្រះនាង លីវ យី ។ តមក ព្រះអង្គ បានរៀបចំទឹកដីវាលទំនាបនៃតំបន់ភូមិភាគទន្លេមេគង្គក្រោម ដែល ជាកំណកំណើតដំបូងនៃរដ្ឋខ្មែរ ស្របទៅតាមលក្ខណៈរដ្ឋបាល រាជា ធិបតេយ្យឥណ្ឌា។ នៅសម័យនោះ រាជធានីព្រះរាជាណាចក្រ ហ្វូណន តាំងនៅស្រុកអង្គរបូរី (ខេត្តតាកែវ) ឈ្មោះថា វ្យាធបុរៈ និងមាន កំពង់

ផែអន្តរជាតិអូរកែវ (ពី គ.ស ៥០ ដល់ គ.ស ៥៥០)។ អាណាចក្រ ហ្វូណន ជាមហាអំណាចដ៏ល្បីមួយ មានឈ្មោះរន្ទឺសុសសាយ នៃភូមិ ភាគអាស៊ី អាគ្នេយ៍ រហូតដល់ពាក់កណ្ដាលសតវត្សទី៦។

នៅលើទឹកដីមហានគរ នៃអាណាចក្រនគរហ្វូណន គឺចាប់ពីរជ្ជកាលព្រះបាទ ហ៊ុន ទៀន បានចូលទីវង្គត់មក ការគ្រប់គ្រងរាជបល្ល័ង្ក ត្រូវបានផ្ទេរទៅអោយរាជ្យវង្សានុវង្សក្រោយៗទៀត មានដូចជាព្រះចៅ ហ៊ុន ប៉ានហ្គួង (ចូលទីវង្គត់ក្នុងជន្មាយុ ៩០ព្រះវស្សា) ព្រះរាជបុត្រទី២ ព្រះនាម ហ៊ុន ប៉ានប៉ាន (សោយរាជ្យសម្បត្តិបាន ៣ឆ្នាំចូលទីវង្គត់) ក្រោយមកឧត្តមសេនីយ៍ ព្រះចៅ ហ្វាន់ចេម៉ាន់ ឡើងគ្រងរាជ្យសម្បត្តិ បន្ត។[14] ព្រះចៅ ហ្វាន់ចេម៉ាន់ បានវាយលុកដណ្ដើមយកតំបន់មេគង្គ កណ្ដាល ព្រមទាំងរដ្ឋតូចៗជាចំណុះ និងវាយយកភាគខាងជើងនៃ ជ្រោយម៉ាឡាកា ដើម្បីត្រួតត្រាផ្លូវជំនួញតាមឈូងសមុទ្រ រហូតដល់ ឈូងសមុទ្រនគរភ្នំ (ឈូងសមុទ្រសៀមបច្ចុប្បន្ន)។ ក្រោយពីបានចូលទីវង្គត់ព្រះរាជ្យបុត្ររបស់ព្រះចៅ ហ្វាន់ចេម៉ាន់ ក្នុងនោះមានព្រះអង្គ ព្រះនាម គីន ឆេង ព្រះចៅព្រះនាម ផាន់ផាំង ព្រះអង្គ ផាន់ ស៊ីយុន (គ.ស ២៨៧) បានសោយរាជ្យសម្បត្តិជាបន្តបន្ទាប់។

លុះមកដល់ឆ្នាំ ៣៥៧ ទើបដឹងថា នៅអាណាចក្រហ្វូណន មានព្រះចៅអធិរាជ្យមួយព្រះអង្គ ព្រះនាម ទៀនឈូឆាន់តាន់ជាអ្នកគ្រប់គ្រងរាជ្យសម្បត្តិ ដែលធ្លាប់បានថ្វាយដំរីដល់ស្ដេចក្រុងចិន។ តាំងពីនោះ មករហូតដល់ដើមសតវត្សទី៥ គឺពុំមានឯកសារគ្រប់គ្រាន់ បញ្ជាក់អំពី ប្រវត្តិនៃនគរហ្វូណននោះទេ។

ប៉ុន្តែចាប់ពីដើមសតវត្សទី៥ ដល់ដើមសតវត្សទី ៦ ទើបដឹងថា នៅអាណាចក្រហ្វូណនមានអធិរាជ្យ ៣ព្រះអង្គបានគ្រងរាជ្យសម្បត្តិ គឺ ព្រះបាទកៅណ្ឌិន្យ ព្រះបាទស្រីឥន្ទ្រវរ្ម័ន និងព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន។ ក្នុងរជ្ជកាលរបស់ព្រះមហាក្សត្រពីរអង្គក្រោយនេះ យើងឃើញថា មានទំនាក់ ទំនងយ៉ាងខ្លាំងជាមួយប្រទេសចិន លើវិស័យបេសកកម្មការ ទូត និងវិស័យពាណិជ្ជកម្មរបស់ប្រទេសហ្វូណនទៅកាន់ប្រទេសចិន។ នៅឆ្នាំ ៥០៣ តាមសេចក្ដីស្នើសុំរបស់ស្ដេចក្រុងចិន ប្រទេសហ្វូណន បានបញ្ជូនបព្វជិតពុទ្ធសាសនា ពីរព្រះអង្គ អោយជួយរៀបចំបកប្រែគម្ពីរពុទ្ធសាសនាទៅជាភាសាចិនទៀតផង។ [15]

ក្នុងអំឡុងឆ្នាំ ៥១៤ ព្រះបាទរុទ្រវរ្ម័ន បានឡើងជ្រែករាជ្យ ដោយ ធ្វើគុត ព្រះអង្គម្ចាស់គុណវរ្ម័ន (ព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន) ហើយបានគ្រងរាជ្យសម្បត្តិរហូតដល់ឆ្នាំ៥៣៩ ទើបចូលទីវង្គត់។ ក្រោយ មក មាន ព្រះបាទភវវរ្ម័ន (ជាខ្សែព្រះរាជវង្សហ្វូណន) ដែលគ្រប់គ្រង រាជ្យសម្បត្តិនៅនគរចេនឡា (រដ្ឋហ្វូណនខាងជើង) បានវាយដណ្ដើម យកអំណាចអាណាចក្រភ្នំទាំងស្រុង ដែលចាប់ពីពេលនោះមក ប្រទេស ហ្វូណន បានប្រែឈ្មោះថា ជាប្រទេសចេនឡា វិញ។ ប៉ុន្តែការគ្រប់គ្រងលើរដ្ឋហ្វូណនទាំងមូលមិនទាន់បានទេ លុះពេល២រជ្ជកាលនៃស្ដេច ក្រោយទៀត ទើបអាចដណ្ដើមយកទឹកដីហ្វូណន មកកាន់ទាំងស្រុង គឺក្នុងរជ្ជកាល ព្រះបាទមហេន្ទ្រវរ្ម័ន និង ព្រះបាទឦសានវរ្ម័ន (រវាង ពាក់កណ្ដាលសតវត្សទី៦ និងទី៧ នៃគ.ស)។

ចំពោះស្ថានភាពនយោបាយ របស់អាណាចក្រចេនឡា (គ.ស ៥៥០-៨០២) យើងឃើញថា នៅក្នុងរជ្ជកាល ព្រះបាទឦសានវរ្ម័នទី១ បានចាប់ផ្ដើមនៅឆ្នាំ ៦៣៥ ។ មានអត្ថបទជាសិលាចារឹកជា

ច្រើន បានរៀបរាប់អំពីការសោយរាជ្យ និងការស្នងព្រះរាជ្យសម្បត្តិបន្ត ដោយរាជ្យបុត្ររបស់ព្រះអង្គ ព្រះនាម ជ័យវរ្ម័នទី១ ដែលគេបានសន្មត់ថា ព្រះអង្គ បានឡើងគ្រងរាជ្យប្រហែលជា ៦៥១ រហូតដល់ឆ្នាំ ៦៨១ (រយៈពេល ៣០ឆ្នាំ)។សិលាចារឹក ដែលបានរកឃើញក្នុងរជ្ជកាលព្រះអង្គជ័យវរ្ម័នទី១ មានតាំងពីវត្តភូ (បច្ចុប្បន្ននៅក្នុងប្រទេសឡាវ) រហូតដល់ឈូងសមុទ្រសៀមបច្ចុប្បន្ននេះ ក្នុងសម័យកាលដែលព្រះអង្គជ័យវរ្ម័នទី១ បានសោយរាជ្យបល្ល័ង្ក ប្រទេសខ្មែរមានសេចក្ដីសុខសានត្រាណ និង មានទំនាក់ទំនងខាងការទូតបានល្អ ជាមួយប្រទេសចិន ក្នុងរាជ្យវង្សថាង។ នៅឆ្នាំ៧១៣ ប្រទេសខ្មែរត្រូវគ្រប់គ្រងរាជ្យសម្បត្តិដោយមហាក្សត្រីយ៍ជ័យទេវី ប៉ុន្តែព្រះនាងពុំសូវមានសមត្ថភាពគ្រប់គ្រាន់ទេ ធ្វើអោយប្រទេសខ្មែរបែកបាក់ ចែកចេញជាពីរ (ដែលហៅថា ចេនឡាដីគោក និង ចេនឡាទឹកលិច) និងមានភាពអនាធិបតេយ្យ។

មូលហេតុនៃការបែកបាក់អាណាចក្រចេនឡា បណ្ដាលមកពី ព្រះបាទជ័យវរ្ម័នទី១ ពុំមានព្រះរាជ្យបុត្រស្នងរាជ្យសម្បត្តិ។ ដូច្នេះបានជានៅឆ្នាំ ៧១៨ ព្រះនាងជ័យទេវី ឡើងគ្រងរាជ្យសម្បត្តិ។ ក្នុងសម័យ កាលនោះ ក៏មានព្រះអង្គម្ចាស់ បុស្ករៈ នៅអនិន្ទិតបុរៈ បានប្រកាស ឡើងគ្រងរាជ្យនៅ សម្ភុបុរៈ (គឺនៅក្នុង ស្រុកសម្បូរ ខាង លើក្រុងក្រចេះ បច្ចុប្បន្ន)។ តាមមតិខ្លះយល់ថា ការឡើងគ្រងរាជ្យសម្បត្តិនៃក្សត្រអង្គ នេះ គឺជាការជ្រែករាជ្យបល្ល័ង្ក (ដែលនៅទំនេរគ្មានព្រះអង្គជាព្រះក្សត្រា) ខ្លះទៀតយល់ថា ដោយសារការរៀបព្រះរាជាអភិសេក។ ប៉ុន្តែទោះជា យ៉ាងណាក៏ដោយ ព្រះអង្គបានតាំងអំណាចរបស់ខ្មែរ នៅសម្ភុបុរៈ អាណាចក្រចេនឡាទឹកលិច (រដ្ឋចេនឡាទឹកលិច) ក្នុងពេលដែលប្រទេសខ្មែរចែកចេញជាពីរៗ រដ្ឋចេនឡាទឹកលិច ជាតំបន់មានបឹង ទន្លេ លាតសន្ធឹងលើអាងទន្លេមេគង្គ តាំងពីល្បាក់ខោន រហូតដល់មាត់សមុទ្រ ដែលមានរាជធានី គឺស្ថិតនៅសម្ភុបុរៈ (ស្រុកសម្បូរ ខេត្តក្រចេះ តាមដងទន្លេមេគង្គ)។ នៅចន្លោះឆ្នាំ ៧៧០ ដល់ឆ្នាំ ៧៨១ មានព្រះរាជា មួយអង្គ ព្រះនាម ជ័យវរ្ម័នទី១ "ស្ទួន" បានឡើងគ្រងរាជ្យសម្បត្តិ។

ចំណែកឯចេនឡាដីគោក ស្ថិតនៅត្រង់ភូមិសាស្ត្រចាស់ អតីត ភវបុរៈ ដែលលាតសន្ធឹងលើប្រទេសឡាវភាគខាងក្រោម និងកណ្ដាល។ រាជធានីរបស់រដ្ឋចេនឡាដីគោក ស្ថិតនៅតំបន់ប៉ាក់ហ៊ុនប៊ុន (ប្រទេស ឡាវបច្ចុប្បន្ន)។ រដ្ឋនេះជារាជាណាចក្រឯករាជ្យមួយ រហូតដល់ពាក់ កណ្ដាលសតវត្សទី១០ (សិលាចារឹកនៅប្រាសាទបក្សីចាំក្រុងក្នុង គ.ស ៩៤៨ រជ្ជកាល ព្រះបាទរុទ្រវរ្ម័ន) ហើយព្រះរាជាដែលមានសកម្មភាពល្បី ជាងគេនៅសម័យកាលរដ្ឋចេនឡាដីគោក គឺ ព្រះបាទជ័យសីង្ហវរ្ម័ន (មានសិលាចារឹក នៃព្រះរាជាអង្គនេះនៅម្តុំនគររាជសីមាប្រទេសថៃបច្ចុប្បន្ន)។ រដ្ឋចេនឡាដីគោកតែងមានទំនាក់ទំនងការទូតជាមួយចិន ហើយនៅឆ្នាំ ៧៥៥ ព្រះរាជបុត្រនៃព្រះរាជា បានទៅជួយច្បាំងទ័ពចិន ជាមួយពួក ណានចាវទៀតផង និងបានដាក់ទូត នៅឆ្នាំ៧៧១ និង ឆ្នាំ៧៩៩។

រីឯ រដ្ឋចេនឡាទឹកលិចវិញ ដោយមានទំហំធំធេង ពិបាកនឹងថែ រក្សាឯករាជ្យភាពយូរអង្វែងបាន ធ្វើអោយរដ្ឋតូចៗជាច្រើនបានបំបែក ខ្លួនចេញពីអាណាចក្រចេនឡាទឹកលិច។ ការបែកបាក់គ្នានេះ កើតឡើង ស្របពេលជាមួយនឹងប្រទេសជិតខាងរបស់ខ្លួន កំពុងមានកម្លាំងខ្លាំងក្លា ទាំងខាងនយោបាយ និងខាងសេដ្ឋកិច្ច ដែលជាកាលៈទេសៈគ្រោះថ្នាក់បំផុត។ ជាក់ស្ដែងនៅឆ្នាំ ៧៧៤ និង

៧៨៧ ប្រទេសជ្វាបានវាយលុក ដណ្ដើមយកឆ្នេរសមុទ្រកូសាំងស៊ីន និងកោះត្រឡាច និងចូលលុកលុយ រហូតដល់ឆ្នេរសមុទ្រប្រទេសចម្ប៉ាទៀត។ ព្រមជាមួយគ្នានោះ ពួកជ្វា បានចូលមកដល់រាជធានីចេនឡាទឹកលិច ដុតបំផ្លាញទីក្រុងសម្ភុបុរៈនិង បានធ្វើគុតព្រះរាជបុត្ររបស់ព្រះបាទរាជេន្ទ្រវរ្ម័នទៀតផង។

យោងតាមរបាយការណ៍របស់ឈ្មួញអារ៉ាប់ឈ្មោះស៊ុយ ឡេម៉ាន់ ដែលបានមកធ្វើជំនួញនៅប្រទេសចេនឡាទឹកលិច បានអះអាងថា ប្រទេសខ្មែរសម័យនោះ (នាចុងសតវត្សទី៩ នៃគ.ស) ស្ថិតនៅក្រោមការត្រួតត្រារបស់ស្ដេចជ្វា។ មានសិលាចារឹកខ្លះ ក៏បានបញ្ជាក់អំពីព្រឹត្តិ ការណ៍នយោបាយនេះដែរ ហើយថែមទាំងបានលើកឡើងអំពីការតស៊ូ រំដោះជាតិឡើងវិញអោយផុតពីនឹមត្រួតត្រារបស់ជ្វាក្រោមព្រះរាជស្នាដៃ របស់ ព្រះបាទជ័យវរ្ម័នទី ២ ដែលបានឡើងសោយរាជ្យនាឆ្នាំ ៨០២ ដល់ ឆ្នាំ ៨៥៩។[18] ព្រះបាទជ័យវរ្ម័នទី ២ ត្រូវបានប្រជារាស្ត្រខ្មែរចាត់ទុកជា វីរៈជនដ៏ឆ្នើមនៅសម័យកាលនោះ ព្រោះបានធ្វើការតស៊ូរំដោះជាតិ ដណ្ដើមបានឯករាជ្យពីពួកជ្វាឈ្លានពាន។ ជាងនេះទៀត ព្រះអង្គគឺជាវីរៈជនដំបូងបង្អស់ ដែលបានបើកទំព័រសករាជថ្មីរបស់ប្រទេសកម្ពុជា ពោលគឺសករាជនៃការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជាក្នុងសម័យអង្គរ។

## ២.៣. ស្ថានភាពសេដ្ឋកិច្ចសម័យហ្វូណាន និងចេនឡា

### ២.៣.១ ការស្វែងយល់អំពីឫសគល់សេដ្ឋកិច្ចមុនសម័យហ្វូណាន

បើយើងងាកមើល អំពីបុរប្រវត្តិសាស្ត្រខ្មែរអោយបានឆ្ងាយបន្តិច ពោលគឺក្នុងសម័យកាលមុន គ.ស (មុនពេលកកើតរដ្ឋ ហ្វូណាន) និងតាមរយៈលទ្ធផលកំណាយបុរាណវត្ថុនៅស្ថានីយ៍ ស្រាវជ្រាវ (ស្ថានីយ៍សំរោង សែន រន្លង់ផ្ដៅ និងម្លូព្រៃ) គឺបានរកឃើញនូវវត្ថុតាងជាច្រើន ខ្លះជារបស់របរប្រើប្រាស់ធ្វើពីដែក ស្ពាន់ លង្ហិន ខ្លះទៀតធ្វើអំពីដីឥដ្ឋ ឬដុត ខ្លះទៀត ធ្វើពីឆ្អឹងសត្វ និងខ្លះទៀត ធ្វើពីថ្មរំលីង)។

ចំពោះប្រដាប់ប្រដាប្រើប្រាស់ធ្វើអំពីថ្មរំលីង គេឃើញមាន ផ្លែ ពូថៅគ្រប់យ៉ាង ពន្លាក ញញួរ អន្លូងដ៏សម្បកឈើ កាំបិត ថ្មសំលៀង អង្រែ ពុម្ពចាក់កវ ត្រល់ ខ្មោសកោសស្បែក កងដៃ កងជើង អង្កាំ និងគ្រឿងអលង្ការផ្សេងៗទៀត។ រីឯប្រដាប់ប្រដាធ្វើអំពីឆ្អឹងសត្វ គេឃើញមាន ផ្លែព្រួញ ផ្លែសន្ទូច ម្ជុលដេរ កាំបិត កណ្ដៀវ និងធ្វើគ្រឿងអលង្ការ ដែលមានខ្លះទៀតធ្វើអំពីសម្បកខ្យងដែរ។ ដោយឡែកប្រដាប់ប្រដាធ្វើអំពីដីឥដ្ឋរួមមាន បំណែកឆ្នាំង ក្រឡ ចានគ្រប់ប្រភេទ គ្រឿងអលង្ការប្រកបដោយក្បូរក្បាច់រចនាល្អបវរ ក្នុងកម្រិតសិល្បៈទឹកដៃ យ៉ាងស្ទាត់ជំនាញទៀតផង។ វត្ថុប្រើប្រាស់ដែលធ្វើអំពីលោហៈធាតុវិញ គេឃើញមានផ្លែព្រួញ ផ្លែដឹង កណ្ដៀវ ពន្លាក ជាដើម ដែលធ្វើឡើង ពីលោហៈធាតុដែក និងស្ពាន់។ ក្រៅពីបានរុករកឃើញនូវសំណល់ បុរាណវត្ថុទាំងអស់នេះ គេក៏បានប្រទះឃើញទៀតនូវ ឆ្អឹងសត្វត្រកួត ឆ្អឹងអណ្ដើក កន្ធាយ ត្រី ជ្រូក គោ ឆ្កែ មាន់ និងឆ្អឹងសត្វចតុបាទផ្សេងៗ ជាច្រើនទៀត ។[20]

សរុបសេចក្តីមក បើយើងពិនិត្យពិចារណាទៅលើកាកសំណល់ កំណាយបុរាណវត្ថុតាងទាំងអស់ ដែលពួកកុលសម្ព័ន្ធខ្មែរដើម បានផលិត និងបានប្រើប្រាស់នោះ យើងអាចធ្វើសេចក្តីសំយោគបានដូចខាងក្រោមនេះ៖

- ខ្មែរយើងនៅយុគថ្មរំលីង និងយុគលោហៈ មានការរីកលូតលាស់ខាងវិស័យសិប្បកម្មយ៉ាងទូលំទូលាយប្រកបដោយទេពកោសល្យ ច្នៃប្រឌិតខ្ពស់រួចស្រេចទៅហើយ។
- ចំពោះ វត្ថុតាងសម្រាប់ចាក់ពុម្ពផ្នែកល្ពៅ អង្រែ (សម្រាប់បុកស្រូវ) ផ្លែសន្ទូច និងឆ្អឹងសត្វស្រុកគ្រប់ប្រភេទ បង្ហាញថា ខ្មែរយើងចេះធ្វើរបរកសិកម្មដាំដុះ ការចិញ្ចឹមសត្វ និងនេសាទ ដែលជាវិស័យសេដ្ឋ កិច្ចកសិកម្មដ៏សំខាន់បំផុត ក្នុងការផ្គត់ផ្គង់ស្បៀងអាហារ។
- រីឯវត្ថុប្រើប្រាស់ដែលផលិតពីវត្ថុធាតុផ្សេងៗ ដូចជា ផ្លែព្រួញ កណ្តៀវ ផ្លែជីង ពន្លាក បានស្តែងឡើងអោយឃើញនូវពន្លកនៃការចាប់ ផ្តើមក្នុងវិស័យឧស្សាហកម្មស្លលោហៈ។

លើសពីនេះទៀតបើយើងវិភាគទៅតាមគោលការណ៍និយមន័យ សេដ្ឋកិច្ច យើងឃើញថា ជីវភាពរស់នៅ និងទម្រង់ផលិតកម្មរបស់ខ្មែរ នាជំនាន់បុរេប្រវត្តិ ព្រមទាំងទំនាក់ទំនងដោះដូរ ក្នុងសង្គមកុលសម្ព័ន្ធ យើងអាចសន្និដ្ឋានបានថា នៅសម័យកាលនោះ គឺបានកើតមានឡើង នូវទម្រង់បឋមនៃសកម្មភាពសេដ្ឋកិច្ច សង្គម រួចស្រេចទៅហើយ។

### ២.៣.២ សេដ្ឋកិច្ចកម្ពុជាសម័យហ្វូណន

សេដ្ឋកិច្ចប្រទេសកម្ពុជាក្នុងសម័យហ្វូណន បានបន្តដំណើររបស់ខ្លួន តភ្ជាប់ពីជំនាន់បុរេប្រវត្តិសាស្ត្រ ដែលជាមូលដ្ឋានគ្រឹះនៃវិស័យសេដ្ឋកិច្ចដំបូងបង្អស់ ក្នុងនោះមានវិស័យកសិកម្ម សិប្បកម្ម និងសេវាកម្ម ដែលបានបន្តនិរន្តរភាព ចូលមកដល់សម័យកាលក្រោយៗទៀត។ ផ្អែកតាមឯកសារមួយចំនួន បានបង្ហាញអំពីការរីកលូតលាស់ គួរអោយកត់សម្គាល់ លើវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់ខ្មែរយើង ក្នុងសម័យហ្វូណន ដែលបានធ្វើអោយរដ្ឋនេះ ក្លាយទៅជាអាណាចក្រនគរភ្នំ ដែលជាមហាអំណាចមួយមានអនុភាពនយោបាយ កិត្យានុភាពល្បីល្បាញ និងឥទ្ធិពលយោធាដ៏ខ្លាំងក្លា គ្របដណ្តប់លើជ្រោយនៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។

- វិស័យកសិកម្ម

នៅសម័យហ្វូណន វិស័យកសិកម្មមានការរីកចម្រើនយ៉ាងខ្លាំងក្លា នេះបើតាមការបញ្ជាក់ពីឯកសារមួយចំនួន ព្រោះវិស័យនេះ បានផ្គត់ផ្គង់សេចក្តីត្រូវការស្បៀងអាហារសម្រាប់ប្រជាជនក្នុងស្រុក ហើយព្រមទាំងបាន បម្រើអោយការនាំចេញទៀតផង ជាពិសេសផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំគ្រឿងទេស និងសត្វព្រៃ។ ភាពជោគជ័យលើវិស័យកសិកម្មនេះ បណ្តាលមកពីព្រះរាជានូវគ្រប់រជ្ជកាលនៃអាណាចក្រហ្វូណនបានយកចិត្តទុកដាក់ខ្ពស់លើការរៀបចំនយោបាយអភិវឌ្ឍន៍ សេដ្ឋកិច្ចកសិកម្មបានត្រឹមត្រូវជាពិសេសបានរៀបចំនយោបាយធារាសាស្ត្រ ពោលគឺការកសាងនូវទំនប់ទឹក ប្រឡាយជីកស្រះទឹក អាងស្តុកទឹកដើម្បីផ្គត់ផ្គង់ធនធានទឹកបម្រើអោយវិស័យកសិកម្មអោយបានគ្រប់គ្រាន់ និងគ្រប់រដូវកាល។

ចំពោះវិស័យសិប្បកម្ម នាសម័យហ្វូណន ក៏មានសន្ទុះលឿន លឿនខ្លាំងក្លាណាស់ដែរ។ ខ្មែរយើងជំនាន់នោះ ចេះធ្វើកិច្ចការជាច្រើន ដែលទាក់ទងនឹងវិស័យសិប្បកម្ម។ សិប្បករហ្វូណន អាចផលិតនូវផលិតផលប្រើប្រាស់ជាច្រើនប្រភេទដូចជា ចេះត្បាញរវៃអំបោះសូត្រ ត្បាញក្រណាត់ ចេះស្លូរកែវយ៉ាងស្ទាត់ជំនាញ ឆ្លាក់គ្រឿងអលង្ការ ធ្វើពី លោហៈមានតម្លៃ ក្នុងនោះមានការធ្វើចិញ្ចៀន កងដៃ កងជើង ខ្សែដៃ ខ្សែកាន់ កងកាន់ អង្កាំ មានចានប្រាក់ ចានមាស ថាស ប្រកបដោយ សិល្បៈក្បូរក្បាច់ រចនាចម្លាក់ក្នុងទេពកោសល្យទឹកដៃដ៏ល្អ ប៉ិនប្រសព្វ ខ្ពស់ណាស់។ វត្ថុសិប្បកម្មរបស់សិប្បករខ្មែរសម័យហ្វូណន បាននាំ ចេញទៅបង្អួតនៅតាមទីផ្សារក្រៅប្រទេស នៃភូមិភាគអាស៊ីខាងត្បូង ជាពិសេស នាំចេញទៅប្រទេសចិន។ ក្រៅពីនេះទៀត គេឃើញមាន សិប្បកម្មធ្វើទូក សំពៅធំៗឆ្លងកាត់សមុទ្រ ធ្វើរទេះធ្វើគ្រឿងក្រអូប និងចេះសូនរូប និងធ្វើចម្លាក់ទេវរូបពីលោហៈធាតុសំរិត ពីថ្ម និងពីឈើ។

- វិស័យពាណិជ្ជកម្ម

គួរបញ្ជាក់ថា ព្រះរាជាណាចក្រហ្វូណន ជារដ្ឋមួយដែលមានសកម្មភាពពាណិជ្ជកម្មយ៉ាងខ្លាំងក្លា។ នៅសម័យនោះ ដោយសារតែការរៀបចំស្រុកទេសបានត្រឹមត្រូវ ធ្វើអោយវិស័យពាណិជ្ជកម្មជួញដូរ ទូទៅ ហាក់មានដំណើរការទៅមុខជាលំដាប់។ ម្យ៉ាងទៀត យើងមានកំពង់ផែ អន្តរជាតិអូរកែវ ដែលបានបំពេញតួនាទីរបស់ខ្លួនប្រកបដោយភាពទាក់ទាញ ហេតុដូចនេះហើយទើបកំពង់ផែអន្តរជាតិមួយនេះ បានក្លាយទៅជាទីគាប់ចិត្ត និង ទីជំនួបប្រសព្វពាណិជ្ជកម្មអន្តរជាតិយ៉ាងសំខាន់ ពាណិជ្ជកម្មក្នុងស្រុក និងឈ្មួញបរទេស (ចម្រុះជាតិសាសន៍ យ៉ាងច្រើនកុះករ។ សកម្មភាពពាណិជ្ជកម្មទាំងអស់នេះ បញ្ជាក់អំពីការរីកលូតលាស់ផ្នែកផលិតកម្មក្នុងស្រុកសម្រាប់ការនាំចេញ និងបង្ហាញអំពីតម្រូវការប្រើប្រាស់របស់ប្រជាជនម្ចាស់ស្រុកចំពោះការនាំចូល ហើយក៏ឆ្លុះបញ្ចាំងអំពីការរីកលូតលាស់នូវទម្រង់មីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច ក្នុងបរិបថបើកចំហរទៀតផង។

- វិស័យគមនាគមន៍

យើងដឹងហើយថា វិស័យគមនាគមន៍ គឺជាវិស័យគន្លឹះ ព្រោះជាមធ្យោបាយសម្រាប់សម្របសម្រួលដល់ការដឹកជញ្ជូនផលិតផលទៅ កាន់ទីផ្សារគោលដៅ និងការធ្វើដំណើររបស់ប្រជាជនទៅគ្រប់ទិសទីទាំងអស់ ហើយការរីកលូតលាស់វិស័យពាណិជ្ជកម្ម ក៏ដូចជាវិស័យសេដ្ឋកិច្ច និងសង្គមផ្សេងៗ ទៀតទៅបានអាស្រ័យដោយមានការទ្រទ្រង់សម្របសម្រួលពីវិស័យគមនាគមន៍ដឹកជញ្ជូននេះឯង។

នៅសម័យអាណាចក្រហ្វូណន វិស័យគមនាគមន៍មិនទាន់មាន ការរីកចម្រើនខ្លាំងក្លាទេ ហើយប្រជាជនខ្មែរនិយមធ្វើដំណើរ និងដឹក ជញ្ជូនផលិតផលតាមផ្លូវគោក និងផ្លូវទឹក។ ហេតុដូចនេះហើយដើម្បីងាយស្រួលក្នុងការដឹកជញ្ជូនទំនិញទៅកាន់កំពង់ផែសមុទ្រ ឬដឹកជញ្ជូនទំនិញដែលនាំចូលពីក្រៅប្រទេសមកកាន់រាជធានី និងទីប្រជុំជន គេបានអោយប្រជារាស្ត្រ ជីកព្រែកខ្វាត់ខ្វែងប្រទាក់គ្នាតភ្ជាប់រហូតដល់កំពង់ផែសមុទ្រអន្តរជាតិអូរកែវ។

- វិស័យសំណង់

សំណង់រាជធានី វ្យាធបុរៈ (បច្ចុប្បន្ននៅអង្គរបុរី ខេត្តតាកែវ) ក៏ ដូចជាសំណង់ ទីក្រុងដ៏ទៃទៀត ក្នុងព្រះរាជាណាចក្រហ្វូណនដែរ បានរៀបចំឡើងដោយមានកំពែងយ៉ាងរឹងមាំសម្រាប់ការពារខ្លួន និងមានជីក គួរទឹកព័ទ្ធជុំវិញ ព្រមទាំងមានចិញ្ចឹមសត្វក្រពើក្នុងនោះផង។ សំណង់ស្ថាបត្យកម្មនៃព្រះបរមរាជវាំងទាំងអស់ បានស្ថាបនាឡើង អំពីឈើដែល មានធ្វើជាប្រាសាទ ឬធ្វើជាដំណាក់ជាច្រើនជាន់។

នៅសម័យអាណាចក្រហ្វូណន គេឃើញមានផងដែរនូវសំណង់ បណ្ណាល័យជាតិធំៗ ដែលសម្បូរទៅដោយសៀវភៅ មានក្បួនតម្រាសាស្ត្រាគម្ពីរ និងកម្រងឯកសារសព្វបែបយ៉ាងតម្កល់ទុកនៅទីនោះ។ទាំងនេះបង្ហាញថាអ្នកគ្រប់គ្រងរបស់ខ្មែរយើងនៅសម័យនោះ បានយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំសិក្សាធិការ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ។

នៅក្រៅក្រុង ប្រជារាស្ត្រខ្មែរតែងតែប្រមូលផ្តុំគ្នារស់នៅ ដោយបង្កើតជាភូមិ ស្រុក ទីប្រជុំជនធំៗ ដែលមានផ្ទះពី ៥០ ទៅ ៦០ខ្នង និងមានជីកស្រះទឹកសម្រាប់ការប្រើប្រាស់រួមគ្នា។[23] សំណង់លំនៅដ្ឋានរបស់ពួកគេសង់ឡើងអំពីឈើ សង់លើជន្ទល់ខ្ពស់ពីដី និងមានប្រកស្លឹកចាក។

- វិស័យហិរញ្ញវត្ថុ

យោងតាមឯកសារប្រវត្តិរូបិយវត្ថុខ្មែរ បានបញ្ជាក់ថា រូបិយវត្ថុរបស់ខ្មែរយើងក្នុងសម័យកាលនោះមាន ៣ប្រភេទ ដែលបានបោះពុម្ពប្រើប្រាស់ក្នុងសតវត្សទី២ រហូតដល់ សតវត្សទី៦ រូបិយវត្ថុ ក្នុងសម័យកាលហ្វូណន។ តាមរយៈស្ថានីយ៍កំណាយបុរាណវត្ថុនៅឯ អង្គរបុរី ខេត្តតាកែវ និងនៅស្ថានីយ៍អូរកែវ (ខេត្តក្រមួនសរ ទឹកដីកម្ពុជាក្រោម) គឺបានរកឃើញនូវវត្ថុតាងនៃរូបិយវត្ថុខ្មែរទាំងអស់នេះ។ រូបិយវត្ថុទាំង ៣ប្រភេទនោះ មានរូបិយវត្ថុ ខ្យងស័ង្ខ រូបិយវត្ថុ ព្រះអាទិត្យ និង រូបិយវត្ថុ រូបពស់ ដែលមានទំហំ វិជ្ជមាត្រ និងទម្ងន់ខុសៗគ្នា។ គេអាចប្រើប្រាស់រូបិយវត្ថុទាំងមូលតែម្តង ឬអាចយកទៅពុះជៀកជាជម្លៀកៗ សម្រាប់ការចរាចរលើទីផ្សារ ស្របទៅតាមតម្រូវការប្រើប្រាស់ និងសមាមាត្រនឹងតម្លៃទំនិញ ដែលត្រូវដោះដូរគ្នា។[24] ក្រៅពីនេះ តាមរយៈឯកសារផ្សេងទៀត បានអះអាងថា នៅសម័យនោះ ក៏មានការប្រើប្រាស់នូវរូបិយប័ណ្ណបរទេសជាច្រើនប្រភេទជាពិសេស នៅតំបន់កំពង់ផែអន្តរជាតិអូរកែវ ដែលជាទីក្រុងបុរាណនៅ ជាប់មាត់សមុទ្រ ដែលរូបិយប័ណ្ណបរទេសទាំងនោះមានរូបិយប័ណ្ណ រ៉ូម៉ាំង ឥណ្ឌា និងចិន(អាយុកាលនៃរូបិយប័ណ្ណបរទេសទាំងនោះ ស្ថិតក្នុង គ.សទី១ មកម្ល៉េះ)។ ចំពោះកិច្ចការពន្ធដារវិញ ប្រជាជនហ្វូណនបានបង់ពន្ធជូនរាជការ ជារូបិយវត្ថុ ជាមាសប្រាក់ ត្បូងមានតម្លៃ គុជ គ្រឿង ក្រអូប និងផ្សេងៗទៀត។

សរុបមក ពត៌មានជាមូលដ្ឋាន និងភស្តុតាងទាំងអស់នេះ អាចអោយយើងសន្និដ្ឋានបានថា នៅសម័យហ្វូណនមានការរីកលូតលាស់ ខាងវិស័យហិរញ្ញវត្ថុសាធារណៈមួយកម្រិតរួចទៅហើយ ព្រោះមានស្ថាប័នរដ្ឋដែលទទួលខុសត្រូវលើកិច្ចការទាំងអស់នេះ ពោលគឺមានប្រព័ន្ធធនាគារ ដែលជាស្ថាប័នគ្រប់គ្រងកិច្ចការនយោបាយរូបិយវត្ថុជាតិ និងមានបេឡាជាតិជាឃ្លាំងប្រាក់ (ឃ្លាំងព្រះរាជទ្រព្យ) ដែលមានតួនាទីក្នុងការរក្សាការពារ និងចាត់ចែងចំណូលចំណាយរដ្ឋ។

### ២.៣.៣ សេដ្ឋកិច្ចកម្ពុជាសម័យចេនឡា

- វិស័យកសិកម្ម

នៅសម័យចេនឡា ពុំបានរកឃើញឯកសារណាមួយដែលបាន បញ្ជាក់ច្បាស់លាស់ អំពីការរីកលូតលាស់នៃវិស័យកសិកម្មនោះឡើយ ប៉ុន្តែអ្វីដែលយើងអាចកំណត់បាននោះ យើងឃើញថា មានការទាក់ទង នឹងការបង្កើតទីក្រុង ឦសានបុរៈ (នៅក្បែរស្ទឹងសែន) និងការឡើងគ្រងរាជ្យសម្បត្តិរបស់ព្រះអង្គម្ចាស់បុស្សរៈ នៅឯសម្ភុបុរៈ ដោយតាំងអំណាច ជាអាណាចក្រចេនឡាទឹកលិច (រដ្ឋចេនឡាទឹកលិច) ដែលបច្ចុប្បន្នស្ថិតនៅស្រុកសម្បូរ ខាងលើក្រុងក្រចេះ។

ហេតុការណ៍ខាងលើនេះ តិចឬច្រើនមានការទាក់ទងទៅនឹងការ សិក្សាច្បាស់លាស់អំពីនយោបាយទឹក ព្រោះស្ទឹងសែន អាចបង្ហូរចូលក្នុងស្រះ ឬប្រឡាយព័ទ្ធជុំវិញទីក្រុង ឬក្នុងអាងស្តុកទឹកឯទៀតៗ ដែលធ្វើអោយមានទឹកគ្រប់គ្រាន់បម្រើអោយវិស័យកសិកម្មដាំដុះ។ ចំពោះការកំណត់យកទីក្រុងសម្ភុបុរៈ សម្រាប់ជារាជធានីនៃរដ្ឋចេនឡាទឹកលិច ប្រហែលជានៅតំបន់នោះជាតំបន់មានបឹងទន្លេលាតសន្ធឹងលើអាងទន្លេ មេគង្គ ពីល្បាក់ខោន រហូតមកដល់សមុទ្រ។ ដោយឡែកនៅរាជធានី វ្យាធបុរៈវិញ ដំណើរការវិស័យកសិកម្ម បានបន្តសកម្មភាពដូចធម្មតា ប្រកបដោយភាពជោគជ័យ តាំងពីសម័យអាណាចក្រហ្វូណនមកម្ល៉េះ។ ដូច្នេះបើពិនិត្យលើហេតុផលជាមូលដ្ឋានខាងលើនេះ យើងអាចសន្និដ្ឋានថា វិស័យកសិកម្មនៅសម័យចេនឡា មានការរីកលូតលាស់ជាប្រក្រតី។

- វិស័យសិប្បកម្ម

វិស័យសិប្បកម្មបានរស់រានជាមួយនឹងជីវភាពរស់នៅរបស់ខ្មែរយើងតាំងពីសម័យយូរលង់ណាស់មកហើយ ហេតុនេះយើងមិនមានមន្ទិលណាមួយអំពីការលូតលាស់របស់វិស័យនេះទេ។

យោងតាមឯកសារខ្លះក៏បានបញ្ជាក់បន្ថែមអំពីស្ថានភាពរបស់វិស័យសិប្បកម្មនេះដែរ ពោលគឺនៅសម័យចេនឡា សិប្បកម្មផលិតកម្មពីវត្ថុធាតុដើមនានា ត្រូវបានសិប្បករខ្មែរចេនឡាបន្តកិច្ចការរបស់ខ្លួនជាធម្មតា។ ក្នុងនោះយើងឃើញមាន របស់របរដែលធ្វើអំពីវត្ថុធាតុដើមដី មានដូចជា ភាជន៍ចាន ឆ្នាំង ក្អម កោដ្ឋ (ធ្វើពីដីដុត) ឥដ្ឋ ផលិតបាយអរ (ដែលផ្សំពីកំបោរលាយជាមួយស្ករ សម្រាប់សំណង់ផ្ទះ និងប្រាសាទ) និងរបស់របរប្រើប្រាស់ផ្សេងៗទៀត។ ម្យ៉ាងទៀត ដូចគ្នាដែរនឹងសម័យហ្វូណន ប្រជារាស្ត្រចេនឡា គឺជាជាងទងប្រកបដោយទេពកោសល្យ ស្ទាត់ជំនាញ ក្នុងការធ្វើគ្រឿងអលង្ការពីលោហៈធាតុផ្សេងៗ ដូចជា ការ ធ្វើចិញ្ចៀន ក្រយ៉ា កងដៃ ក្រវិលមាស ក្រវិលប្រាក់ ពីស្ពាន់ និងសំណ និងចេះស្លៀកែវធ្វើជាកងដៃ ធ្វើអង្កាពាក់នៅកដៃ និងក ដែលជាគ្រឿង លម្អ។[25]

ក្រៅពីនេះសិប្បកម្មតម្បាញសូត្រ ក្រណាត់សំពត់ ការសូនរូប សិប្បកម្មចម្លាក់ពីលោកហៈពីថ្ម និងឈើ ចេះធ្វើទូកធ្វើរទេះ និងធ្វើ សំពៅតូច ធំ បម្រើអោយវិស័យពាណិជ្ជកម្ម និងចម្បាំងទៀតផង។

- វិស័យគមនាគមន៍

ដូចដែលយើងបានដឹងរួចមកហើយថា វិស័យគមនាគមន៍ គឺជាវិស័យមួយដ៏សំខាន់ក្នុងការធ្វើទំនាក់ទំនង សម្របសម្រួលគ្រប់ចលនា សង្គម សេដ្ឋកិច្ច និងនយោបាយ។ មានឯកសារខ្លះ ក៏បានលើកឡើង អំពីស្ថានភាពនេះដែរក្នុងសម័យចេនឡា ដោយគ្រាន់តែបានបញ្ជាក់ថា វិស័យគមនាគមន៍

ក្នុងសម័យកាលនោះ មាន២ប្រភេទ គឺ គមនាគមន៍ ផ្លូវគោក និងផ្លូវទឹក ហើយប្រជាជនបានប្រើប្រាស់សត្វដំរី គោ សេះ និងប្រើស្នែងរទេះ សម្រាប់ធ្វើជាមធ្យោបាយដឹកជញ្ជូនផ្លូវគោក និងប្រើប្រាស់ ទូក សំពៅ សម្រាប់ធ្វើគមនាគមន៍តាមផ្លូវទឹក និងមានកំពង់ផែ ជាចំណត និងជាទីប្រសព្វសំខាន់ៗ។

- វិស័យហិរញ្ញវត្ថុ

នៅសម័យចេនឡា គេបានរកឃើញរូបិយប័ណ្ណបរទេសជាច្រើន ដែលមានប្រភពមកពីបណ្ដាទីបផ្សេងៗគ្នា ដូចជា រូបិយប័ណ្ណឥណ្ឌា រូម៉ាំង ក្រិច និងចិន ដែលធ្លាប់បានចូលមកធ្វើទំនាក់ទំនងពាណិជ្ជកម្ម នៅកំពង់ផែអន្តរជាតិអូរកែវ ឬមានទំនាក់ទំនងនយោបាយការទូត នៅ អង្គរបុរី នៅ សុផានបុរី នៅ កញ្ចនៈបុរី (ប្រទេសថៃបច្ចុប្បន្ន)។

ម្យ៉ាងទៀត រាជរដ្ឋាភិបាលនាសម័យអាណាចក្រចេនឡា ដែលមានប្រពៃណីគ្រប់គ្រងប្រទេសតាមលទ្ធិរាជាធិបតេយ្យឥណ្ឌា ក៏បានបន្តរៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈដូចសម័យហ្វូណននោះដែរ។ តាមឯកសារខ្លះ លើកឡើងថា ប្រភពចំណូលរបស់រដ្ឋ បានមកពីការបង់ពន្ធរបស់ប្រជារាស្ត្រ ប្រាក់កាក់ ជាមាស ជារបស់របរមានតម្លៃ និងជាគ្រឿងក្រអូប ដែលអាចលក់ប្ដូរយកសាច់ប្រាក់ ឬទុកសម្រាប់ការប្រើប្រាស់របស់រដ្ឋ។

## ២.៤. សេចក្ដីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវ អំពីប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ក្នុងសម័យកាលអាណាចក្រនគរភ្នំ (ហ្វូណន) និងចេនឡា យើងអាចធ្វើសេចក្ដីសន្និដ្ឋានបានថា នៅយុគសម័យកាលនោះ ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើងបានដំណើរការឡើង ដោយឯករាជ្យស្របតាមនិន្នាការសេដ្ឋកិច្ច-សង្គមមួយ ដែលបានបញ្ចូលគ្នានូវវប្បធម៌ នៃការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ច តាមបែបប្រព័ន្ធវប្បធម៌ចម្រុះ គឺតាមបែបខ្មែរនិយម និងបែបឥណ្ឌាកម្ម។ ការរួមបញ្ចូលគ្នានូវទស្សនៈវប្បធម៌អភិវឌ្ឍន៍សេដ្ឋកិច្ចបរទេស ដែលមានអរិយធម៌ខ្ពង់ខ្ពស់ជាងជាមួយនឹងមូលដ្ឋានធនធានធម្មជាតិដែលមានស្រាប់ ធនធានមនុស្ស ដែលមានទេពកោសល្យ និងវប្បធម៌ឧស្សាហ៍ព្យាយាម ដែលមាន តាំងពីយូរលង់មកហើយនោះ វារឹងរឹតតែបានជួយអោយវិស័យសេដ្ឋកិច្ច និងសង្គមមានការរីកលូតលាស់ទៅមុខបានមួយកម្រិតធំទៀត។ ជាងនេះទៀត ការបើកចំហរអោយមានទំនាក់ទំនងជាមួយនឹងពិភពខាងក្រៅ ពោលគឺការបង្កើតនូវទំនាក់ទំនងនយោបាយការទូត និងសេដ្ឋកិច្ច ជាមួយបរទេស ក៏ជាមធ្យោបាយដ៏ល្អមួយ ឬជាឱកាសមាសបន្ថែមទៀតដែលជួយញុំាងអោយប្រទេសជាតិមានលទ្ធភាពពង្រីកនូវសមត្ថភាព ផលិតកម្ម និងការនាំចេញទំនិញ ដែលជាគោលនយោបាយសេដ្ឋកិច្ចដ៏ពិសិដ្ឋ ។ ហេតុដូច្នេះហើយ ទើបយើងសង្កេតឃើញថាពីសម័យកាលមួយទៅសម័យកាលមួយទៀតសមត្ថភាពផលិតកម្មលើគ្រប់វិស័យ (វិស័យកសិកម្ម សិប្បកម្ម ពាណិជ្ជកម្ម សំណង់ គមនាគមន៍ ហិរញ្ញវត្ថុ) សម្រាប់សេដ្ឋកិច្ចរបស់ខ្មែរយើង ហាក់មានដំណើរការទៅមុខគួរអោយ មោទនៈ។

សរុបសេចក្ដីមក ចំពោះអ្វីដែលជាកត្តាអវិជ្ជមាន រំខានដល់ការ អភិវឌ្ឍសេដ្ឋកិច្ច-សង្គម នាសម័យកាលទាំងនោះ គឺតែងតែបណ្ដាមកពី បញ្ហាសង្គ្រាម និងទំនាស់ផ្ទៃក្នុងរាជ្យវង្សានុវង្ស ដែលតែង

តែចង់បាន អំណាច និងប្រយោជន៍បុគ្គល និងប្រយោជន៍ក្រុមរបស់ខ្លួនជាធំ។ ទាំងអស់នេះទុកជាបទពិសោធន៍ដ៏មានតម្លៃសម្រាប់មនុស្ស ដែលជាកូនខ្មែរជំនាន់ក្រោយត្រូវតែស្វែងយល់អោយច្បាស់លាស់ មុននឹងធ្វើសេចក្តីសម្រេចការងារប្រទេសជាតិណាមួយ គប្បីឈរលើគោលការណ៍តុចរចារអោយបានច្រើន និងយកភាពយុត្តិធម៌ យកច្បាប់ និងយកផលប្រយោជន៍ជាតិតម្កល់ជាធំ ជាជាងការប្រើអំពើហិង្សា ឬឧបករណ៍ណាមួយ ដែលមិនទទួលបានការគោរពពីប្រជាជាតិរបស់ខ្លួន និងនាំមកនូវភាពអន្តរាយដល់ប្រទេសជាតិ។

# ជំពូកទី៣
# សេដ្ឋកិច្ចប្រទេសកម្ពុជានាសម័យអង្គរ ឆ្នាំ ៨០២ - ១៤៣៤

## ៣.១. ស្ថានភាពនយោបាយសម័យអង្គរ ឆ្នាំ ៨០២ - ១៤៣៤

វិបត្តិនយោបាយផ្ទៃក្នុងរបស់ស្តេចខ្មែរ នៅចុងសតវត្សទី៨ បាន ធ្វើអោយអាណាចក្រចេនឡា បែងចែកជាពីរចំណែក។ ចេនឡាដីគោក ជារដ្ឋឯករាជ្យ។ ចេនឡាទឹកលិចជារដ្ឋតូចៗ និងស្ថិតក្រោមការត្រួតត្រារបស់ជ្វា ព្រមទាំងត្រូវបានចាប់រាជវង្សានុវង្សជាច្រើនព្រះអង្គទៅ ស្រុកជ្វា ក្នុងចំណោមនោះ ក៏មាន ព្រះបាទជ័យវរ្ម័នទី២ ផងដែរ។ ព្រះ អង្គបានគេចខ្លួនត្រឡប់មកស្រុកខ្មែរវិញ ហើយបានធ្វើការបង្រួបបង្រួម កម្លាំងអ្នកស្នេហាជាតិពីគ្រប់នគរនៃប្រទេស វាយដណ្តើមបានឯករាជ្យ មកវិញ និងបានអភិសេកឡើងគ្រងរាជ្យសម្បត្តិឆ្នាំ ៨០២ រហូតដល់ ៨៥០ ដែលជាសករាជថ្មីនៃការចាប់ផ្តើមឡើងនូវយុគសម័យអង្គរ។

### ៣.១.១ ស្ថានភាពនយោបាយក្នុងយុគសម័យអង្គរដំបូង

ដើម្បីបង្រួបបង្រួមជាតិ បង្រួបបង្រួមទឹកដី អោយមានឯកភាពជាតិ ឡើងវិញ ព្រះអង្គបានកសាងរាជធានីថ្មីគឺ មហេន្ទ្របុរៈ (លើភ្នំគូលែន) ដែលមានលក្ខណៈពិសេស ព្រោះជាកន្លែងដែលស្ថិតនៅចំកណ្តាល នគរនៃប្រទេស ព្រោះព្រះអង្គចង់ក្លាយជាមហាក្សត្រភ្នំ និងចង់ក្លាយជា ព្រះមហាក្សត្រចក្រវាឡ និងបានកសាងប្រាសាទនៅគ្រប់រាជធានីទាំង ៥ ដែលធ្លាប់មានពីមុនៗមក។ មូលដ្ឋានគ្រឹះ នៃឫទ្ធិអំណាចនយោបាយរបស់ព្រះបាទជ័យវរ្ម័នទី ២ គឺបណ្តាលមកពីព្រះអង្គមានព្រះបញ្ញាញាណខ្ពង់ខ្ពស់ ហើយបានកំណត់ទិសដៅនយោបាយច្បាស់លាស់របស់ប្រទេស ដែលត្រូវតែមានព្រះមហាក្សត្រជាចក្រពត្តិគ្រប់គ្រងជានិរន្ត ទើបជាការប្រសើរ។ ដើម្បី សម្រេចព្រះមហិច្ឆិតាដ៏ឈ្លៀសវៃនេះ ទ្រង់បានប្រឹក្សាយោបល់ជាមួយពួកមហាព្រហ្មណ៍ល្បីល្បាញ ដែលបណ្ឌិតស្សរជនទាំងនោះបានផ្តល់ នូវឧត្តមគំនិតសំខាន់ៗដូចខាងក្រោមនេះ៖

- កសាងព្រះទេវរូប (លទ្ធិទេវរាជ) ទុកជាវត្ថុសក្តិសិទ្ធិ និងជាទីសាការៈនៃព្រះមហាក្សត្រ និងប្រជារាស្ត្រ។
- បណ្តុះអរិយធម៌ជាតិ បណ្តុះទឹកចិត្តស្នេហាជាតិ សាមគ្គីភាពជាតិ ភាពក្លាហាន និងហាត់រៀនវិជ្ជាយុទ្ធសាស្ត្រសង្គ្រាម ។
- ផលិតគ្រឿងសព្វាវុធ និងកសាងកម្លាំងយោធា សម្រាប់ ការពារមាតុភូមិ និងធ្វើសង្គ្រាមពង្រីកទឹកដី។

យោងតាមនិន្នាការនយោបាយខាងលើនេះ ក្នុងសម័យកាល នោះ បណ្តាកិច្ចការប្រទេសជាតិនានា មានការរីកលូតលាស់គួរអោយ កត់សម្គាល់ គឺការបង្រួបបង្រួមក្សត្របុរីតូចៗអោយនៅក្រោមចក្រភពអង្គរ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នរដ្ឋ ដែលត្រួតត្រាលើ ព្រះរាជាណាចក្រទាំងមូល

ពង្រីកប្រពៃណីមហារាជ ការអនុវត្តលទ្ធិ ព្រហ្មណ៍សាសនា និងលើកតម្កើងព្រះរាជាទុកជា អាទិទេព តាមរយៈ

លទ្ធិទេវរាជដែលអនុវត្តន៍បានជោគជ័យអស់រយៈកាលជិតមួយសតវត្សកន្លះ (រយៈពេល ១៤២ឆ្នាំ) គឺក្នុងគ.ស ៨០២ ដល់គ.ស ៩៤៤ និង ឆ្លងកាត់អស់ ៧រាជ្យនៃស្តេច ដែលសុទ្ធតែជាព្រះញាត្តិវង្សរបស់ព្រះបាទ ជ័យវរ្ម័នទី២។ ក្នុងតំណាក់កាលនោះ ត្រូវបានចាត់ទុកថា ជាយុគសម័យដំបូង ដែលជាសម័យកាលមួយមានមូលដ្ឋានគ្រឹះរឹងមាំ សម្រាប់ស្ពានចម្លងចូលដល់សម័យអង្គរពិតប្រាកដ។

ដោយសារមាគ៌ានយោបាយខាងលើនេះ ព្រះបាទជ័យវរ្ម័នទី២ បានបង្កើតឡើងនូវមូលដ្ឋានគ្រឹះនៃព្រះបារមីរបស់ព្រះអង្គ ពេញទៅដោយឫទ្ធិអនុភាពខ្លាំងក្លា ផ្នែកនយោបាយ វប្បធម៌ និងសេដ្ឋកិច្ច ដែលមានលក្ខណៈសម្គាល់ ៣យ៉ាងដូចខាងក្រោមនេះ ៖

- ការអនុវត្តលទ្ធិទេវរាជក្នុងនយោបាយរដ្ឋ

លទ្ធិនេះមានជំនឿថា ព្រះមហាក្សត្រគឺបានចាប់ព្រះបដិសន្ធិ ពីព្រះសិវៈ ពីព្រះវិស្ណុ ឬពីព្រះពោធិសត្វ ជាអ្នកមានឫទ្ធិអំណាចនៅលើលោក មានព្រះបារមីដ៏អស្ចារ្យ អាចសុំទឹកភ្លៀង អាចធ្វើអោយភោគផល ដំណាំលូតលាស់បានល្អ អាចធ្វើអោយប្រទេសជាតិទទួលបានឯករាជ្យ អាចធ្វើអោយព្រះអង្គមានព្រះឋានៈជា ស្តេចចក្រវាឡ។

- ការកសាងប្រាសាទភ្នំ

ដោយសារការជាប់ទាក់ទងនឹងលទ្ធិទេវរាជ (ដែលជាអរិយធម៌របស់ ខ្មែរសម័យអង្គរ និងជាលទ្ធិនយោបាយរដ្ឋ) ដែលជំនឿនេះហើយ បានធ្វើអោយព្រះមហាក្សត្រខ្មែរ មានព្រះបារមីមានអំណាចគ្រប់គ្រាន់ក្នុង ការស្ថាបនាប្រាសាទធំៗស្កឹមស្កៃ ដែលបានសាងសង់នៅលើកំពូលភ្នំជាច្រើនជាន់ នៅចំកណ្តាលរាជធានី ជានិមិត្តរូបនៃភ្នំព្រះសុមេរុ ដែលជាទីស្ថានរបស់ទេវៈនៃចក្រវាឡយើងនេះ។

- ការបង្កើតនយោបាយទឹក

លក្ខណៈសម្គាល់សម្ខាន់បំផុតមួយទៀតគឺ ការបង្កើតឡើងនូវ ប្រព័ន្ធបញ្ចេញបញ្ចូលទឹក និងព្រែកជីក ដែលអាចធានាការប្រមូលផល ដំណាំកសិកម្មបាន២ដង ឬ៤ដងក្នុងមួយឆ្នាំ។ សមិទ្ធិផលដំណាំនេះ ធ្វើអោយជីវភាពប្រជារាស្ត្របានធូរធា និងផ្តល់លទ្ធភាពដល់រាជការ (តាមរយៈការបង់សួយសារអាករ) សម្រាប់ពង្រឹងចក្រភពខ្មែរ ដើម្បីធ្វើសង្គ្រាមពង្រីកទឹកដី ការកសាងប្រាសាទនានា ស្ថាបនាវិមានធំស្កឹមស្កៃ កសាងអាងស្តុកទឹកថ្មីៗ ដែលត្រូវគ្នានឹងពាក្យចាស់ពោលថា ធ្វើស្រែនឹង ទឹកធ្វើសឹកនឹងបាយ សេដ្ឋកិច្ចជាកាយនយោបាយជាចិត្តដែល សេដ្ឋកិច្ច និងនយោបាយសម័យនោះ បានដើរទន្ទឹមគ្នា។

### ៣.១.២ ស្ថានភាពនយោបាយសម័យអង្គរ ឆ្នាំ ៩៤៤ ដល់ ១២១៩

គួររំលឹកថា ការចាប់ផ្តើមឡើងនៃយុគសម័យអង្គរ ពាក់ព័ន្ធទៅ នឹងការសាងសង់រាជធានីអង្គរតាំងពីរជ្ជកាល ព្រះបាទយសោវរ្ម័នទី១ (គ.ស ៨៨៩-៩១០) មកម្ល៉េះ ប៉ុន្តែបញ្ហាស្ថិតនៅត្រង់ថា ការ

ស្ថាវ និងការ ពង្រីកអាណាចក្រកម្ពុជា សម្រេចបានតែលើទឹកដីអតីតចេនឡាទឹកលិច រីឯចំណែកអតីតរាជាណាចក្រចេនឡាដីគោក គឺហាក់ដូចជាស្ថិតនៅដោយឡែកព្រោះខ្មែរភាគខាងជើងបានរក្សាទំនៀម

ទំលាប់ប្រពៃណី វង្សព្រះអាទិត្យ(សូរវង្ស) ជាកូនចៅរបស់ឥសីកម្ពុស្វ័យម្ភាវៈ ហើយពួកខ្មែរភាគខាងត្បូងប្រកាន់យកទំនៀមទំលាប់វង្សព្រះច័ន្ទ (សោមវង្ស) ដែល ជាកូនចៅរបស់ព្រះនាងសោមា។ ថ្វីត្បិតតែខ្មែរទាំងពីរក្រុមនេះមានទឹកដីដោយឡែកពីគ្នាមានប្រពៃណីផ្សេងគ្នា ប៉ុន្តែពួកគេមានទំនាក់ទំនងរវាងគ្នាមិនចេះដាច់ ជាពិសេសទំនាក់ទំនងផ្នែកអាពាហ៍ពិពាហ៍ ការដោះដូរផលិតផល ដែលធ្វើអោយសេដ្ឋកិច្ចតំបន់ទាំងពីរ ចេះតែបន្ត ការអេភិវឌ្ឍជារៀងរហូត។

លក្ខណៈពិសេសផ្នែកនយោបាយក្នុងយុគសម័យនោះ ស្ថិតនៅ ត្រង់ថា ព្រះបាទរាជេន្ទ្រវរ្ម័នទី ២ (គ.ស ៩៤៤ ដល់ ៩៦៨) បានឡើង សោយរាជ្យសម្បត្តិ ហើយព្រះអង្គមានខ្សែស្រឡាយពីអង្គក្សត្រមុនៗ ទាំងសងខាង គឺខ្សែខាងព្រះបិតា សូរវង្ស អតីតចេនឡាដីគោក) និងខ្សែខាងព្រះមាតា (សោមវង្ស អតីតចេនឡាទឹកលិច) ដែលជាហេតុ នាំអោយទឹកដីនៃតំបន់ទាំងពីរនេះ កាន់តែខិតជិតគ្នា មានឯកភាពគ្នា ជា ឱកាសបើកទំព័រសករាជថ្មី ក្នុងការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍ រាជាណាចក្រកម្ពុជាសម័យអង្គរ។ ស្ថានការណ៍នយោបាយដ៏រឹងមាំដែល បានកើតឡើងក្នុងសម័យនោះ បានកើតចេញពីការរួបរួមកម្លាំងរបស់ ប្រជារាស្ត្រខ្មែរទាំងពីរក្រុម ដែលធ្វើអោយផុសចេញនូវមហិច្ឆិតាពង្រីក ទឹកដីរបស់ព្រះរាជា។

ជាក់ស្តែង ការធ្វើសង្គ្រាមពង្រីកទឹកដីលើកទី ១ ជាមួយប្រទេសចាមត្រូវបានចាប់ផ្តើមឡើង ហើយបានវាយលុកចូលក្នុងទឹកដីចម្ប៉ា និងបាននាំយកមកស្រុកខ្មែរវិញនូវ រូបដិមាធ្វើពីមាស និងវត្ថុជ័យភ័ណ្ឌ ផ្សេងៗទៀត។ ក្រៅពីនយោបាយវាទីនិយម ព្រះមហាក្សត្រខ្មែរបានដឹកនាំចលនាក្នុងនយោបាយអភិវឌ្ឍន៍វប្បធម៌ជាតិ ដោយបានស្ថាបនាជា ប្រាង្គប្រាសាទជាច្រើន ដូចជា ប្រាសាទជុំមានប្រាង្គ៣ ប្រាសាទមេបុណ្យ ខាងកើត (គ.ស ៩៥២) ប្រាសាទប្រែរូប (គ.ស ៩៦១) ប្រាសាទភិមានអាកាស។ ក្រៅពីសំណង់របស់ព្រះរាជា គេសង្កេតឃើញមានសំណង់ផ្សេងៗទៀត ដែលផ្តួចផ្តើមឡើងដោយពួកព្រាហ្មណ៍ និងមន្ត្រីជាន់ខ្ពស់ ដូចជា បានស្ថាបនាប្រាសាទបន្ទាយស្រី (គ.ស ៩៦៧ នៅខាងជើងក្រុង យសោធរបុរៈ) និងបានសាងសង់ស្រះទឹកមួយដ៏សែនមនោរម្យ គឺ ស្រះ ស្រង់ ។[30]

គួរបញ្ជាក់ថា ស្ថានភាពនយោបាយរបស់ប្រទេសកម្ពុជាចន្លោះ ឆ្នាំ ៩៦៨ ដល់ ១១៧៧ គឺអស់រយៈកាលជាង២សតវត្ស កន្លងមកនេះ គឺបានឆ្លងកាត់អស់ ១០រាជ្យនៃព្រះរាជា (ភាគច្រើនមានខ្សែស្រឡាយ នឹង ព្រះបាទរាជេន្ទ្រវរ្ម័នទី២) យើងឃើញថា ប្រទេសកម្ពុជាក៏បានជួប ប្រទះនូវវិបត្តិផ្ទៃក្នុងជាញឹកញាប់ដែរ។ យ៉ាងណាមិញ បន្ទាប់ពីព្រះបាទ រាជេន្ទ្រវរ្ម័នទី ២ ត្រូវបានគេធ្វើគុតនៅគ.ស ៩៦៧ (ព្រោះមានកុបកម្មជា ច្រើនបានកើតឡើង) ក៏ប៉ុន្តែ ការអភិវឌ្ឍជាតិលើគ្រប់វិស័យ នៅតែបន្ត ដំណើរទៅមុខឥតឈប់ឈរ។ ហើយមានព្រះរាជបុត្រមួយអង្គរបស់ ព្រះអង្គព្រះនាមព្រះបាទជ័យវរ្ម័នទី៥ បានឡើងគ្រងរាជ្យបន្ត (គ.ស ៩៦៩ ដល់ ១០០០) ។

ព្រះបាទជ័យវរ្ម័នទី៥ ក្នុងនយោបាយកសាងជាតិ ព្រះអង្គបានបន្តការកសាងសំណង់ជាច្រើន ដើម្បីឧទ្ទិសដល់សាសនាព្រះវិស្ណុ។ រីឯព្រះពុទ្ធសាសនាក៏ត្រូវបានព្រះអង្គជួយការពារដោយបានកសាងព្រះពុទ្ធរូបថ្មីៗថែមទៀត ព្រមទាំងបានបញ្ជាទិញពីបរទេសនូវឯកសារនានា ដែលទាក់ទងទៅនឹងពុទ្ធសាសនាមហាយាន។

ក្នុងសម័យនោះ ឃើញមានការកសាងរាជធានីថ្មីនៅក្បែរបារាយណ៍ខាងកើត (យសោធរតដាក) នៅគ.ស ៩៧៨ ដោយមានប្រាសាទតាកែវនៅចំកណ្តាល។ ចំពោះស្ថានភាពនយោបាយវិញមានសភាពស្ងប់ស្ងាត់ជាធម្មតាដែរ។

ក្រោយគ.ស ១០០០ បន្ទាប់ពីព្រះបាទជ័យវរ្ម័នទី ៤ បានសោយ ទីវង្គត់ ស្ថានភាពនយោបាយនៅក្នុងប្រទេសមានភាពច្របូកច្របល់មួយ រយៈកាល ព្រោះព្រះអង្គពុំមានបុត្រស្នងរាជ្យ ក្មួយរបស់ព្រះអង្គ ព្រះនាម ឧទ័យាទិត្យវរ្ម័នទី១ បានឡើងសោយរាជ្យជំនួស ប៉ុន្តែមិនបានយូរអង្វែងទេ។ នៅខណៈពេលនោះ មានលេចឡើងនូវស្តេចជាច្រើនអង្គនៅលើ ឆាកនយោបាយ ដែលមានមហិច្ឆិតាដណ្តើមរាជ្យបល្ល័ង្គគ្នា (ដូចជាព្រះបាទជ័យវរៈវរ្ម័ន និងព្រះបាទសូរ្យវរ្ម័នទី១ បានធ្វើសង្គ្រាមដណ្តើមរាជ្យ បល្ល័ង្គគ្នា) ដែលទីបំផុត ព្រះបាទជ័យវរៈវរ្ម័ន បានទទួលជ័យជំនះ (គ.ស ១០០២ ដល់ ១០១០)។ ម៉្យាងទៀត

សង្គ្រាមស៊ីវិល ដែលបានអូសបន្លាយ អស់រយៈកាល ៩ឆ្នាំ បានធ្វើអោយក្រុងអង្គរទី១ វិនាសខ្ទេចខ្ទី និងបាន បង្កើតរាជ្យវង្សានុវង្សថ្មីទៀត ដើម្បីគ្រប់គ្រងប្រទេសកម្ពុជា រហូតដល់ ចុងសតវត្សទី១១។

ជាក់ស្តែង ក្នុងគ.ស ១០១០ រហូតដល់ ១០៥០ ក្នុងរជ្ជកាល ព្រះ បាទសូរ្យវរ្ម័នទី១ យើងឃើញថា ប្រទេសកម្ពុជាបានស្ថាបនាទីក្រុងអង្គរទី២ ដោយបានកសាងប្រាសាទភ្នំមួយនៅចំកណ្តាលគឺ ប្រាសាទបាពួន ប៉ុន្តែសំណង់ទីក្រុងនេះមិនទាន់បានសម្រេចរួចរាល់ទេ)។ ក្រោយមក ក្នុងរជ្ជកាលព្រះបាទឧទ័យាទិត្យទី២ (ត្រូវជាព្រះរាជបុត្រ ព្រះបាទ សូរ្យវរ្ម័នទី១) ដែលបានសោយរាជ្យសម្បត្តិក្នុងគ.ស ១០៥០ ដល់ ១០៦៦ ទើបក្រុងអង្គរទី២បានសង់រួចរាល់។ ក្រៅពីនោះ គេឃើញមានសំណង់ប្រាសាទមេបុណ្យខាងលិច និងបារាយណ៍ទឹកថ្លា (បារាយណ៍ ខាងលិច) ដែលមានបណ្តោយ ៨គ.ម និង ទទឹង ២,២គ.ម ក៏បានកសាង ឡើងនូវក្នុងសម័យកាលនោះដែរ។ បារាយណ៍នេះ ពុំមែនឆ្លើយតបតែ ទៅនឹងនយោបាយសាសនាមួយមុខនោះទេ តែក៏ឆ្លើយតបទៅនឹងទិស ដៅនយោបាយសេដ្ឋកិច្ចជាតិផងដែរ។ ការឡើងសោយរាជ្យសម្បត្តិ របស់អង្គស្តេចក្នុងគ.ស១០១០ ងគ.ស១០១០ ដល់១០៥០ និងព្រះរាជបុត្រមួយ ព្រះអង្គដែលសោយរាជ្យចន្លោះឆ្នាំ ១០៥០ ដល់ ១០៦៦ និងមួយព្រះអង្គ ទៀតសោយរាជ្យចន្លោះឆ្នាំ ១០៦៦ ដល់ ១០៨០ យើងសង្កេតឃើញថា ស្ថានភាពនយោបាយ វប្បធម៌ សេដ្ឋកិច្ច សង្គមកិច្ច របស់ប្រទេសកម្ពុជា នៅតែបន្តការអភិវឌ្ឍ និងមានភាពរុងរឿង។

ក្រោយមក ប្រទេសកម្ពុជាបានធ្លាក់ចុះក្នុងសភាពបែកបាក់អស់រយៈកាល ២រាជ្យនៃស្តេច គឺព្រះបាទជ័យវរ្ម័នទី៦ ក្នុងគ.ស ១០៨០ ដល់ ១១០៧ និងព្រះបាទធរណិន្ទ្រវរ្ម័នទី១ ក្នុងគ.ស ១១០៧ ដល់ ១១១៣ ដែលនាំអោយប្រទេសកម្ពុជាបាត់បង់ឱកាសក្នុងការកសាងប្រទេស។

ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ សោយរាជ្យសម្បត្តិ ក្នុងគ.ស១១១៣ រហូតដល់ ១១៦២ ទើបបានធ្វើអោយស្ថានភាពនយោបាយនៃ ប្រទេសកម្ពុជាទទួលបានឯកភាពជាតិ និងការបង្រួបបង្រួមជាតិជាថ្មីឡើងវិញ ធ្វើអោយប្រទេសជាតិមានសុខសន្តិភាព និងការអភិវឌ្ឍ។ នៅក្នុងសម័យកាលនោះ សមិទ្ធិផលនយោបាយធំៗ ដែលបានកសាងឡើង ជូនប្រទេសជាតិ សម្រេចលទ្ធផលបានដូចខាងក្រោម ៖

- ការអនុវត្តន៍នយោបាយសង្គ្រាមពង្រីកទឹកដី

បានធ្វើសង្គ្រាមពង្រីកទឹកដីជាច្រើនលើក ជាមួយ នគរដោយវៀត ក្នុងគ.ស ១១២៨ ដោយមានការចូលរួមពីទ័ពជើងទឹកប្រមាណ ៧០០ សំពៅចូលដល់តំបន់ឆ្នេរសមុទ្រ ថាញ់វា និងវាយលុកម្តងទៀតនៅ គ.ស ១១៣ ២ ។ ក្រោយមក បានធ្វើសង្គ្រាមជាមួយ ប្រទេសចម្ប៉ា នៅ គ.ស ១១៣៨ និងទទួលបានជ័យជំនះនៅគ.ស ១១៤៥ ដោយយក ប្រទេសចម្ប៉ាធ្វើជាខេត្តចំណុះ។ បានធ្វើសង្គ្រាមជាមួយ ពួកមន ដោយ វាយលុករហូតដល់អាងទន្លេមេណាម (បច្ចុប្បន្នប្រទេសថៃ)។ សម័យ កាលនោះទឹកដីខ្មែរមានសភាពទូលំទូលាយណាស់ ដែលលាតសន្ធឹងពី ប្រទេសឡាវ ភាគខាងក្រោម រហូតដល់ ឈូងសមុទ្រសៀម ។

- នយោបាយការបរទេស

នៅសម័យកាលនោះ ប្រទេសកម្ពុជា បានចងស្ពានមេត្រីលើ ផ្នែកនយោបាយការបរទេសជាមួយប្រទេសចិន ដោយបានដាក់បេសកកម្មការទូតជាមួយគ្នា និងបានចុះកិច្ចព្រមព្រៀងធ្វើពាណិជ្ជកម្មអន្តរជាតិ ចំនួន ២លើក គឺនៅគ.ស ១១៣១ និងគ.ស ១១៤៧។

- នយោបាយអភិវឌ្ឍន៍វប្បធម៌ជាតិ

ទាក់ទងនឹងចលនាលើកិច្ចការនយោបាយវប្បធម៌ ក្នុងសម័យនោះយើងឃើញថា បានកសាងនូវប្រាសាទជាច្រើន ដូចជា ប្រាសាទវត្តភូ ប្រាសាទព្រះវិហារ ប្រាសាទភ្នំជីសូរ ប្រាសាទភ្នំសណ្តក ប្រាសាទព្រះខ័ន ប្រាសាទធម្មនន្ទ ប្រាសាទចៅសាយ ប្រាសាទពិធូរ ប្រាសាទ បន្ទាយសម្រែ ប្រាសាទអង្គរវត្ត (អង្គរតូច)។ ដោយសារការកសាង ប្រាសាទ ដ៏ច្រើននេះហើយ ទើបព្រះបាទសូរ្យវរ្ម័នទី២មានមរណៈនាមថា ព្រះបរមវិស្ណុលោក ដែលតំណាងអោយសាសនាព្រាហ្មណ៍គណៈវិស្ណុ ដែលជាសាសនារបស់រដ្ឋ ក្នុងសម័យកាលនោះ។[32]

ក្រោយពេលដែលព្រះអង្គបានចូលទីវង្គត់, ប្រទេសកម្ពុជាបាន ជួបប្រទះនូវវិបត្តិនយោបាយសារជាថ្មីទៀត អស់រយៈកាលជាច្រើនឆ្នាំ គឺពីឆ្នាំ ១១៦ ២ ដល់ ១១៨១ ដោយបានឆ្លងកាត់អស់កាល ៣រាជ្យនៃ ព្រះរាជា ដែលវិបត្តិនយោបាយនេះ ភាគច្រើនជាប់ទាក់ទងទៅនឹងវិបត្តិ ដណ្តើមរាជ្យបល្ល័ង្ក ការជ្រែករាជ្យ ការធ្វើគុតសងសឹកគ្នាដើម្បីតែ ប្រយោជន៍បុគ្គល និងការឈ្លានពានពីសំណាក់ប្រទេសជិតខាង។ អង្គស្តេចដែលបានសោយរាជ្យក្នុងសម័យកាលនោះមាន ព្រះបាទធរណិន្ទ្រវរ្ម័នទី២ (គ.ស ១១៦២ ដល់ ១១៦៣) ដែលជាព្រះរាជបិតា ព្រះបាទជ័យវរ្ម័នទី៧ ព្រះបាទយសោវរ្ម័នទី២ (គ.ស ១១៦៣ ដល់ ១១៦៥) និងព្រះបាទត្រីភូវនាទិត្យវរ្ម័ន (គ.ស ១១៦៥ ដល់ ១១៧៧) ដែលជាស្តេចជ្រែក រាជ្យ ព្រមទាំងបានធ្វើគុត ព្រះបាទយសោវរ្ម័នទី២។

គួរបញ្ជាក់ថា ការបែកបាក់ផ្ទៃក្នុងនៃនយោបាយរបស់ស្តេចខ្មែរ នាសម័យកាលនោះ បានធ្វើអោយស្តេចចាម ឈ្មោះ ជ័យឥន្ទ្រវរ្ម័នទី៤ បានលើកទ័ពជើងទឹកវាយចូលតាមទន្លេមេគង្គ និងទន្លេសាបចូលដល់ក្នុងអង្គរ និងបានវាយបំផ្លាញទីក្រុងអង្គរស្ទើរខ្ទេចខ្ទី ព្រមទាំងរឹបអូស ប្រមូលយកទ្រព្យសម្បត្តិជាច្រើនទៅប្រទេសចាម ក្នុងគ.ស ១១៧៧។ ស្តេចខ្មែរ គឺ ព្រះបាទត្រីភូវនាទិត្យវរ្ម័ន ក៏បានសុគតនៅសមរភូមិ ហើយប្រទេសចាមបានគ្រប់គ្រងរាជធានីអង្គរ និងបានដាក់អោយប្រទេស កម្ពុជាស្ថិតនៅជាចំណុះរបស់ខ្លួនចាប់ពីឆ្នាំ ១១៧៧ ដល់ឆ្នាំ ១១៨១។

ក្រោយពីព្រឹត្តិការណ៍នយោបាយដ៏អាក្រក់នេះ បានកើតឡើង យើងឃើញថា មានមេទ័ពការពារព្រំប្រទល់ខ្មែរ-ចាម បានបង្កើតចលនា តស៊ូរំដោះជាតិ ប្រឆាំងនឹងពួកអាណានិគមចាម ចាប់តាំងពីឆ្នាំ ១១៧៧ រហូតដល់ឆ្នាំ១១៨១ ទើបទទួលបានជ័យជំនះ ហើយបានឡើងគ្រងរាជ្យសម្បត្តិក្នុងឆ្នាំ ១១៨១ រហូតដល់ ១២១៩។ ស្តេចខ្មែរដែលបាន តស៊ូរើបម្រាស់ពីអាណានិគមចាមនោះ គឺ ព្រះបាទ ជ័យវរ្ម័នទី៧ ។ ចំពោះស្ថានភាពនយោបាយ ក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី៧ មានលក្ខណៈពិសេសគួរអោយសម្គាល់ដូចខាងក្រោមនេះ ៖

- ការអនុវត្តនយោបាយរំដោះជាតិ

ក្នុងសម័យកាលនោះ ប្រទេសកម្ពុជា មិនត្រឹមតែបានរំដោះខ្លួន អោយរួចផុតពីនឹមត្រួតត្រារបស់ប្រទេសចាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង វាយបករំលាយទឹកដីចម្ប៉ា អោយទៅជាទឹកដីខ្មែរតែមួយ អស់រយៈពេល ជិតកន្លះសតវត្ស (៤៥ឆ្នាំ) ចាប់ពីឆ្នាំ ១១៨១ រហូតដល់ឆ្នាំ ១២ ២៦ ។

- ការអនុវត្តនយោបាយពង្រីកទឹកដី

នៅសម័យនោះ ប្រទេសខ្មែរបានវាយដណ្តើមកាន់កាប់មកវិញ នូវអតីតរដ្ឋខ្មែរ ក្នុងតំបន់ទន្លេមេណាម (បច្ចុប្បន្នប្រទេសថៃ) ដណ្តើមតំបន់ខ្ពង់រាប នគររាជ លពបុរី វាយពង្រីកទឹកដីកាន់តែឆ្ងាយទៅៗខាងជើងទល់នឹងប្រទេសចិន ខាងលិចទល់នឹងភូមា ខាងកើតទល់នឹងឈូង សមុទ្រចិន (គិតជាខេត្តមានចំនួន ១០១ខេត្ត)។ អំណាចរបស់ព្រះរាជាណាចក្រខ្មែរ បានជះឥទ្ធិពលលើភូមិភាគអាស៊ី-អាគ្នេយ៍។

- ការអនុវត្តនយោបាយវប្បធម៌

ក្នុងសម័យកាលនោះ មានស្ថាបត្យកម្មប្រាសាទបុរាណជាច្រើនត្រូវបានសាងសង់ឡើង ដូចជាប្រាសាទតាព្រហ្ម (គ.ស ១១៨៦) ប្រាសាទជ័យស្រី (គ.ស ១១៩១) ប្រាសាទនាគព័ន្ធ ប្រាសាទបន្ទាយក្តី ប្រាសាទបាយ័ន (ជាប្រាសាទធំជាងគេ ដែលមានព្រះភ័ក្ត្រមុខ៤ ចំនួន៥២) ប្រាសាទវត្តនគរ (ខេត្តកំពង់ចាម) ប្រាសាទតាព្រហ្មទន្លេបាទី ប្រាសាទបន្ទាយឆ្មារ និងប្រាសាទជាច្រើនទៀត។ ក្រៅពីនេះ គេឃើញមានចលនាសាងសង់នូវ សាលាជំណាក់ នៅគ្រប់ទិសទីនៃប្រទេសខ្មែរប្រមាណ ១២១ សាលាជំណាក់ មន្ទីរពេទ្យចំនួន ១០២កន្លែង។ សាងសង់សាកលវិទ្យាល័យ និងលើកតម្កើងសិប្បកម្មធ្វើព្រះពុទ្ធរូបអំពី មាស ប្រាក់ សំរិទ្ធ ថ្ម ចំនួន ២០៤០០អង្គ។

- ចលនានយោបាយស្ថាបនាក្រុងអង្គរទី៣ (អង្គរធំ)

ក្នុងសម័យកាលព្រះបាទជ័យវរ្ម័នទី៧ បានស្ថាបនាឡើងនូវក្រុងអង្គរទី៣ តាមបែបទស្សនៈព្រហ្មណ៍និយមផង និងបែបពុទ្ធសាសនាមហាយានផង ដែលមានប្រាសាទបាយ័ន (ឬអង្គរធំ) ជាចំណុចកណ្តាលនៃរាជធានី ហ៊ុំព័ទ្ធទៅដោយកំពែង ឬ២ជាន់ហើយខាងក្រៅមានគូរទឹកហ៊ុំព័ទ្ធជុំវិញថែមទៀត។

## ៣.១.៣ ស្ថានភាពនយោបាយចុងសម័យអង្គរឆ្នាំ ១២១៩-១៤៣៤

ក្រោយពីរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ បានផុតរលត់ទៅ ស្ថានភាពនយោបាយប្រទេសកម្ពុជាតែងតែមានការប្រេះស្រាំ និងបែកបាក់គ្នាជាញឹកញាប់ ជាមួយនឹងសង្គ្រាមឈ្លានពាន ដែលបានកើតឡើងជាច្រើនលើក ទាំងអស់នេះបានគំរាមគំហែងដល់បូរណៈភាពទឹកដី ដល់ការរីកលូតលាស់នៃវប្បធម៌ អរិយធម៌ សេដ្ឋកិច្ច សង្គម និងនយោបាយ។ តាមរយៈឯកសារប្រវត្តិសាស្រ្ត ចន្លោះឆ្នាំ ១២១៩ ដល់ឆ្នាំ ១៣៥៣ ប្រទេសកម្ពុជា ត្រូវបានសោយរាជ្យសម្បត្តិអស់រាជ្យស្តេចចំនួន ៥ ព្រះអង្គ គឺព្រះបាទឥន្ទ្រវរ្ម័នទី២ ព្រះបាទជ័យវរ្ម័នទី ៨ ព្រះបាទ ឥន្ទ្រវរ្ម័នទី៣ ព្រះបាទស្រីន្ទ្រជ័យវរ្ម័ន និងព្រះបាទជ័យវរ្ម័នទី៩។ គ្រោះ ថ្នាក់ខាងលើនេះ បានក្លាយទៅជាវិបត្តិនយោបាយដ៏ធ្ងន់ធ្ងរ រហូតដល់ អាណាចក្រខ្មែរបានបោះបង់កងអង្គរចោលតែម្តង។ មូលហេតុនៃការធ្លាក់ចុះ នៃអរិយធម៌អង្គរបណ្តាលមកពីកត្តាខាងក្រោម ៖

- វិបត្តិជំលោះនយោបាយផ្ទៃក្នុងរាជ្យវង្សានុវង្ស

ពិតមែនតែក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ នយោបាយ និង អរិយធម៌ខ្មែរមានភាពរុងរឿង ប៉ុន្តែការបែកបាក់សាមគ្គីផ្ទៃក្នុង ក៏កើតមាន ដែរ។ ប្រការគួរអោយកត់សម្គាល់នោះគឺ មរណៈភាពដ៏អាថ៌កំបាំងរបស់ ព្រះបាទសូរ្យវរ្ម័នទី២ និងការបាត់ព្រះកាយរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលគ្មានអ្នកណាម្នាក់បានដឹងថា ព្រះអង្គសោយទីវង្គត់នៅពេលណា និងនៅទីកន្លែងណានោះទេ។ តាមកំណត់ហេតុរបស់ ជីវតាក្វាន់ បញ្ជាក់ថា អង្គស្តេចមុនៗមិនដែលហ៊ានចេញទៅណាទេ ព្រោះខ្លាចមានរឿង កើតឡើង ព្រោះមានសត្រូវជុំវិញខ្លួន អាចជាស្តេចដូចគ្នា ឬរវាងប្រជារាស្រ្ត និងមានទំនាស់ពីបញ្ហារាជ្យ

សម្បត្តិ។[33] ជាក់ស្តែង ព្រះបាទឥន្ទ្រវរ្ម័ន ទី៣ ( ក្នុងគ.ស ១២៩៥-១៣០៧ ) បានបង្ខំព្រះបិតាក្មេកអោយផ្ទេរ រាជ្យសម្បត្តិអោយខ្លួន ហើយបង្ខំអោយមហេសីទៅលួចព្រះខ័នរាជ្យ ពីព្រះបិតាក្មេក (ការបែកបាក់នេះធ្វើអោយពួកកុលសម្ព័ន្ធសៀមមើលស្រាលហើយមានឱកាសវាយដណ្តើមទឹកដី)។

- បញ្ហាទំនាស់ផ្នែកសាសនា

ព្រឹត្តិការណ៍នយោបាយសម្ខាន់មួយទៀត គឺទាក់ទងទៅនឹង បញ្ហាទំនាស់សាសនា និងការគាំទ្រលើវិស័យនេះ។ យើងឃើញថា ព្រះបាទជ័យវរ្ម័នទី៧ បានកាន់សាសនាព្រះពុទ្ធ តែពួកព្រហ្មណ៍ដែលនៅជុំវិញព្រះកាយព្រះអង្គ សុទ្ធតែកាន់សាសនាព្រហ្មណ៍ ដែលធ្វើអោយអំណាចរបស់ព្រះរាជាពុំមានស្ថេរភាពល្អ ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ និងបានចុះទន់ខ្សោយ ព្រោះបញ្ហានយោបាយសាសនារបស់រដ្ឋ ក្នុងសម័យកាលនោះ គឺជាបញ្ហាសំខាន់បំផុតនៃអាយុជីវិតជាតិ។

- ការឈ្លានពានរបស់ពួកបរទេស

នៅសតវត្សទី ១២ ការបាក់បែកនៃ រដ្ឋណានចារមួយរបស់ពួក សៀម នៅតំបន់ យូណាម (ជាប់ប្រទេសចិន) និងការរាតត្បាតរបស់ពួកម៉ុងហ្គោល ក្នុងសតវត្សទី១៣ បានធ្វើអោយពួកសៀម ជ្រៀតចូលមកក្នុងដែនដីឥណ្ឌូចិនកាន់តែច្រើនឡើងៗ បង្កើតបានជាកុលសម្ព័ន្ធតូចៗ នៅក្នុងរដ្ឋមន លើទឹកដីខ្មែរភាគខាងលិច និងភាគពាយ័ព្យ។ ពួកកុល សម្ព័ន្ធសៀម បានប្រឆាំងនឹងចៅហ្វាយខេត្តខ្មែរ នៅខេត្តសុខោទ័យ និងខេត្តសុវណ្ណលោក។ នៅគ.ស ១២៦២ ពួកឡាវជាកុលសម្ព័ន្ធសៀម បាន បង្កើតរដ្ឋឈៀងរ៉ាយ ហើយនៅគ.ស ១២៨៧ ស្តេចនៅឈៀងរ៉ាយបាន រួមគ្នាជាមួយកុលសម្ព័ន្ធសៀម បង្កើតបានជារដ្ឋដ៏រឹងមាំដែលទទួលយកវប្បធម៌ ចិត្តគំនិត ពីពួកម៉ុងហ្គោល ជនជាតិសៀម បានចាត់ទុ ថា ពួកសៀម អ្នកជា ក្រៅពីសៀម គឺជាអ្នកងារ ដែលវប្បធម៌នេះ ជាគ្រោះ ថ្នាក់ធំបំផុតសម្រាប់កម្ពុជា និងជាបុព្វហេតុនៃការធ្លាក់ចុះអរិយធម៌អង្គរ។

ចាប់ពីពេលនោះមក សង្គ្រាមរវាងសៀម និងខ្មែរបានចាប់ផ្តើមនៅឆ្នាំ ១២៩៦ (ក្នុងរជ្ជកាល ឥន្ទ្រវរ្ម័នទី៣) ហើយបានដណ្តើមយកខេត្តខ្មែរដូចជា រដ្ឋអយុធ្យា និងពង្រីកទឹកដីមកលើរាជាណាចក្រ កម្ពុជា ។ នៅឆ្នាំ ១៣៥១ ស្តេចសៀម (ព្រះនាមរាមាធិបតីទី១) បានលើកទ័ពយ៉ាងច្រើនមកវាយព្រះ រាជាណាចក្រកម្ពុជា (ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៩) ប៉ុន្តែពួកសៀមទទួលបរាជ័យ។ នៅឆ្នាំ ១៣៥២ សៀមបានលើកទ័ពមកឈ្លានពានម្តងទៀត ក្នុងបរិមាណទ័ពច្រើនជាងមុន ១០ដង ប្រយុទ្ធ គ្នាអស់រយៈកាល ៦ ទៅ ៧ខែ ធ្វើអោយក្រុងអង្គរបានធ្លាក់ទៅក្នុងកណ្តាប់ដៃសៀម។

ដោយឡែក ចាប់ពីមានព្រឹត្តិការណ៍នាយត្រសក់ផ្អែម អនុជន (ពូជសម្រែ) បានធ្វើគុតអង្គស្តេ ចដែលមានពូជពង្សព្រះគោរមងារ " វរ្ម័ន ដើម្បីគ្រងរាជ្យសម្បត្តិមកយើងពិនិត្យឃើញថា លទ្ធិទេវរាជ ព្រហ្មណ៍សាសនា ត្រូវបានលុបបំបាត់ចោលទាំងស្រុង ជាហេតុនាំអោយស្តេចខ្មែរលែងមានលក្ខណៈ ជាអាទិទេពទៀត និងមិនមានស្តេចស្ថាបនិកទីក្រុង និងប្រាសាទទៀតដែរ។ ចាប់ពីពេលនោះមកខ្មែរ យើងគោរពព្រះពុទ្ធសាសនាថេរវាទ រហូតរៀងមក។ ជាងនេះទៀត ចម្បាំងរាំងជលជាមួយប្រទេស សៀម ក៏ចេះតែកើតមានឡើងជាញឹកញាប់ និងមានទ្រង់ទ្រាយធំ។

គួរបញ្ជាក់ថា រជ្ជកាលចុងក្រោយរបស់ព្រះបាទជ័យវរ្ម័នទី៩ ដែលគ្រងរាជសម្បត្តិឆ្នាំ ១៣២៧ ដល់ឆ្នាំ ១៣៣៦ ត្រូវបានប្រជារាស្ត្រ សាមញ្ញពូជសម្រែធ្វើគុត ក្នុងបដិវត្តន៍មួយខាងសាសនា និងខាង នយោបាយ នេះបើតាមទស្សនៈរបស់ប្រវត្តិវិទូខ្លះ D. Meunler ដូចជាលោក Pierre Max និងសាស្ត្រា ចារ្យ ត្រឹង ងា ជាដើម។ រាជពង្សាវតាបិទបាំងរឿងនេះ ហើយបកស្រាយជារឿងព្រេងទៅវិញ។ នៅឆ្នាំ ១៣៣៦ នាម្ចាស់ចំការត្រសក់ផ្អែម (ឯកសារខ្លះថា ឈ្មោះ ឆាយ ខ្លះថាឈ្មោះ ពៅ) បានធ្វើគុតព្រះ រាជាដោយលំពែង ដែលព្រះអង្គប្រទានកថៃរក្សាចំកា ត្រសក់ ដែលស្តេចល្បែង ចង់ដឹងថា តើនាយនេះ ចេះថែរក្សាចំការបាន ហ្មត់ចត់ឬទេ ។ ព្រះបាទត្រសក់ផ្អែម គ្រងរាជ្យសម្បត្តិពីឆ្នាំ ១៣៣៦ ដល់ ឆ្នាំ ១៣៤០ ដោយទទួលយកបុត្រីមួយព្រះអង្គរបស់ព្រះបាទជ័យវរ្ម័នទី ៩ ជាអគ្គមហេសី ដើម្បីធ្វើអោយ រាជ្យរបស់ខ្លួនមានលក្ខណៈស្របច្បាប់។

ស្ថានភាពនយោបាយរបស់ប្រទេសកម្ពុជា ក្នុងរយៈពេល ៨២ឆ្នាំ (ចន្លោះឆ្នាំ ១៣៥២ ដល់ ១៤៣៤) ដែលជាសម័យកាលចុងក្រោយរបស់ យុគសម័យអង្គរ ប្រទេសកម្ពុជាបានគ្រប់គ្រងដោយ អង្គព្រះមហាក្សត្រ ពូជសម្រែ អស់កាល ៥ រាជ្យ នៃអង្គស្តេច ក្នុងនោះមាន ព្រះបាទស្រីសុរិយោវង្សទី ១ ព្រះបាទធម្មសោក ព្រះបាទសុរិយោវង្សទី ២ ព្រះបាទបរមសុខា និង ព្រះបាទថៅពញាយ៉ាត យើង ឃើញថា ស្ថានភាពនយោបាយប្រទេសកម្ពុជាស្ថិតក្នុងសភាពវឹកវរ មានកលយុគ ពុំមានសន្តិភាព នោះ ទេ ព្រោះតែមានសង្គ្រាមឈ្លានពានពីសំណាក់ប្រទេសសៀមឥតឈប់ឈរ។ ចម្បាំងសៀម-ខ្មែរ បាន ប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ចំនួន៥ លើក (លើកទី១ នៅគ.ស ១៣៥២ លើកទី២ នៅគ. ១៣៥៤ លើក ទី៣ នៅ គ.ស ១៣៩៣ លើកទី៤ នៅគ.ស ១៤០១ និងលើកទី៥ នៅគ.ស ១ ៤២០ ) ដែលជាទី អវសាននៃអរិយធម៌អង្គរ។

## ៣.១.៤ សេចក្តីសន្និដ្ឋាន

សរុបមក ឆ្លងតាមការសិក្សាទៅលើប្រវត្តិនៃស្ថានភាពនយោបាយរបស់ប្រទេសកម្ពុជាក្នុងយុគ សម័យអង្គរ យើងអាចសាកល្បង ធ្វើសេចក្តីសន្និដ្ឋានបានថា ការធ្លាក់ចុះនៃអរិយធម៌ដ៏រុងរឿងរបស់ខ្មែរ បណ្តាលមកពីមូលហេតុជាច្រើនដូចខាងក្រោមនេះ ៖

- ព្រឹត្តិការណ៍សង្គ្រាមស៊ីវិលរវាងគ្នាឯង ដោយសារការបះបោរ ដណ្តើមរាជ្យបល្ល័ង្កគ្នា ដែលជាគំរូ ដ៏អាក្រក់សម្រាប់អ្នកគ្រប់គ្រងជំនាន់ ក្រោយៗទៀត។
- ការវាយលុកឈ្លានពានទឹកដីពីសំណាក់ប្រទេសជិតខាង ដូចជា ក្នុងរជ្ជកាល ព្រះបាទសូរ្យវរ្ម័ន ទី២ ជាមួយដាយវៀត ជាមួយប្រទេស ចាម (គ.ស ១១៧៧) ជាមួយកុលសម្ព័ន្ធសៀម ក្នុង សតវត្សទី១៤ និង សតវត្សទី១៥ ដែលធ្វើអោយប្រទេសខ្មែរចុះទន់ខ្សោយ បាត់បង់ឥទ្ធិពល នយោបាយ និងអំណាចបន្តិចម្តងៗ មិនអាចស្តារឡើងវិញបាន។
- ការបំផ្លាញដោយសង្គ្រាម បានធ្វើអោយខូចខាតហេដ្ឋារចនា សម្ព័ន្ធសេដ្ឋកិច្ចកសិកម្ម បាត់បង់ ជំនឿលើការវិនិយោគ ធ្វើអោយប្រជារាស្ត្រឈប់ប្រឹងប្រែងធ្វើសេដ្ឋកិច្ច រស់តាមកម្មផល។
- បំលាស់ប្តូរសាសនាក្នុងសាសនារដ្ឋ និងការប្រកាន់យកជំនឿ សាសនាផ្សេងៗគ្នា ធ្វើអោយ សង្គមខ្មែរពិបាកទទួលយក នាំមកនូវវិវាទសង្គម។
- បំលាស់ប្តូរ រាជ្យវង្សានុវង្ស ជាពិសេសអង្គក្សត្រពូជត្រសក់ផ្អែម (ដែលជាពូជរាស្រ្តធម្មតា ហើយបានជ្រែករាជ្យ ធ្វើគុតព្រះមហាក្សត្រ) ដែលនាំឲ្យអោយមានការផ្លាស់ប្តូរលទ្ធិទេវរាជ ធ្វើ អោយប្រជារាស្ត្របាត់បង់ជំនឿលើពូជស្តេច ឈប់ប្រើភាសាសំស្ក្រឹត ដែលជំនួសដោយភាសា បាលីវិញ ។
- ការបាក់ទឹកចិត្តដោយសារបរាជ័យក្នុងសង្គ្រាម បាត់ជំនឿទុក ចិត្តលើខ្លួនឯង និងសេចក្តីទុក វេទនាក្នុងសង្គ្រាម ដែលជះឥទ្ធិពលលើសតិអារម្មណ៍ប្រជាជន ក្នុងការតស៊ូបន្តទៀតដើម្បីបុព្វ ហេតុទឹកដី។

- ការស្លាប់បាត់បង់ជីវិតនៃកម្លាំងពលកម្មធំៗ ដែលត្រូវចំណាយកម្លាំងមនុស្ស និងធនធានសេដ្ឋកិច្ចអស់ជាច្រើន ជាហេតុនាំអោយអនុភាពសេដ្ឋកិច្ចចុះដុនដាប។
- ភាពខ្ជះខ្ជាយនៅក្នុងសេដ្ឋកិច្ច ព្រោះព្រះរាជាបានចំណាយធនធានសាងសង់សំណង់ប្រណិតៗគ្រប់សម័យកាល បានប្រើប្រាស់របស់របរ ធ្វើពីមាស ពីប្រាក់ យ៉ាងល្អប្រណិតក្នុងបរិមាណច្រើន (ទាំងស្តេច ទាំងនាហ្មឺនសព្វមុខមន្ត្រី និងពួកអភិជន) បានចិញ្ចឹមព្រះមហេសីដល់ទៅ៥អង្គ និងស្រីស្នំស្រីស្នំ រហូតដល់ ២.០០០ នាក់ និងស្រីស្នំ ៥.០០០ នាក់ និងការចំណាយប្រាក់យ៉ាងខ្ជះខ្ជាយក្នុងការរៀបចំពិធីបុណ្យទានផ្សេងៗ ទៀត។

## ៣.២. ទស្សនៈទាន នៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអង្គរ

យើងពិនិត្យឃើញថា ព្រះរាជារបស់ខ្មែរយើងបានជ្រើសរើស យកទីតាំងភូមិសាស្ត្រតំបន់អង្គរដើម្បីតាំងរាជធានី មិនមែនប្រព្រឹត្តទៅ ដោយចៃដន្យនោះទេ ពីព្រោះថា តំបន់នេះស្ថិតនៅចំកណ្តាលនៃព្រះរាជាណាចក្រ។ ម្យ៉ាងទៀត តំបន់នេះ ជាទីប្រជុំជននៃផ្លូវជំនួញ ទាំងផ្លូវ គោក និងផ្លូវទឹក ហើយសម្បូរទៅដោយធនធានធម្មជាតិគ្រប់បែបយ៉ាង ដូចជា មច្ឆជាតិ (នៅតំបន់បឹងទន្លេសាប) ម្រឹគីម្រឹគា និងនៅក្នុងព្រៃ មាន ប្រភេទឈើល្អៗ។ ក្រៅពីនោះ តំបន់នេះមានថ្មភក់សម្រាប់ជាវត្ថុធាតុដើម ក្នុងការសង់ប្រាសាទនៅលើភ្នំគូលែន។ល។ ឯវាលទំនាបជុំវិញតំបន់នោះសុទ្ធសឹងជាវាលទំនាបដែលពោរពេញទៅដោយជីជាតិ សម្រាប់ប្រកបរបរដំណាំកសិកម្មសព្វសារពើ។[35]

ស្ថានភាពភូមិសាស្ត្រដ៏ប្រពៃនេះ រួមផ្សំជាមួយនឹងបច្ចេកទេសផលិតកម្មដ៏ចំណាន និងធនធានមនុស្សដែលឧស្សាហ៍ព្យាយាម ចេះ តស៊ូស្វិតស្វាញក្នុងការងារ បានធ្វើអោយវិស័យកសិកម្មខ្មែរនៅសម័យ កាលនោះមានការរីកចម្រើនជាអតិបរមា។

ម្យ៉ាងទៀត នៅប្រទេសកម្ពុជាយើងនាសម័យកាលនោះ ការអភិវឌ្ឍសេដ្ឋកិច្ច ពឹងផ្អែកលើវិស័យកសិកម្ម ហើយវិស័យកសិកម្មតែង តែពឹងផ្អែកទៅលើមេឃ ឬប្រវាស់នឹងមេឃ។ បើខ្យល់រដូវមានការប្រែប្រួល ភ្លៀងធ្លាក់ច្រើនខែ ធ្វើអោយវិស័យកសិកម្មអាចទទួលរងគ្រោះខូច ខាតដោយសារតែទឹកជំនន់។ ម្យ៉ាងទៀត មានឆ្នាំខ្លះភ្លៀងធ្លាក់តិចពេក ធ្វើអោយដំណាំស្រូវផ្តល់ផលមិនគ្រប់គ្រាន់ សម្រាប់បំពេញសេចក្តីត្រូវ ការក្នុងស្រុក។ ដូច្នេះហើយ ទើបនៅសម័យអង្គរ ព្រះរាជាមានបំណង ចង់គ្រប់គ្រងទៅលើការប្រែប្រួលវិស័យជលសាស្ត្រ ដែលតែងតែមាន ភាពមិនទៀងទាត់ តាមរយៈការស្ថាបនានៅជុំវិញរាជធានីអង្គរ នូវបឹងធំៗដែលហៅថា បារាយណ៍ សម្រាប់សន្សំទឹកភ្លៀងនូវរដូវវស្សា គួបផ្សំជាមួយទឹកស្ទឹងសៀមរាប ដែលហូរចុះពីលើភ្នំគូលែន។ លុះផុតរដូវវស្សា គេអាចចែកចាយទឹកបារាយណ៍ទាំងនោះ តាមប្រឡាយនានាបង្ហូរចូលទៅក្នុងស្រែ។ តាមរយៈមធ្យោបាយនេះ នាំអោយគេអាចធ្វើស្រែបានពីរដង បន្តបន្ទាប់គ្នា ហើយនៅរដូវប្រាំង គេអាចធ្វើដំណាំស្រូវម្តងទៀតនៅបាតបារាយណ៍ដែលទីនោះមានដីល្បាប់ដ៏មានជីជាតិ ហើយនឹងមានសភាពសើមស្រាប់។

ការស្ថាបនាបារាយណ៍ជំនាន់នោះគឺជាសមិទ្ធិមួយធំសម្បើមណាស់។ បើយើងគ្រាន់តែលើកយកបារាយណ៍បីសំខាន់ៗមកពិភាក្សា យើងឃើញថា គួរឲ្យស្ងើចសរសើរពន់ពេកណាស់ ដូចជាបារាយណ៍ លលៃ មានបណ្តោយប្រវែង ៣ គ.ម និងទទឹង ០,៨ គ.ម អាចផ្ទុកទឹក បានរហូតដល់ ៦.០០០.០០០ ម៣ រីឯបារាយណ៍ខាងកើត មានបណ្តោយ ប្រវែង ៧ គ.ម និងទទឹងប្រវែង ១,៨ គ.ម អាចផ្ទុកទឹកបានប្រមាណជាង ៣០.០០០.០០០ម៣ ចំណែកឯបារាយណ៍ខាងលិចមានបណ្តោយប្រវែង ៨គ.ម និងទទឹងមានប្រវែង ២,២ គ.ម អាចផ្ទុកទឹកមិនតិចជាង ៤០.០០០.០០០ម៣ នេះយើងមិនទាន់រាប់បណ្តាញជលគតិជាច្រើនទៀត ដែលគេស្ថាបនារបៀបគ្នានេះ នៅតាមបណ្តាខេត្តទាំងឡាយទៀតផង។

ហេតុដូចនេះហើយ ទើបលោក B.Groslier បានពោលថា នៅសម័យនោះ ធនធានទឹកនៅតំបន់អង្គរមិនជាខ្វះទេ តែចំណោទបញ្ហា ស្ថិតនៅត្រង់ថា តើធ្វើយ៉ាងណាដើម្បីចែកចាយទឹកអោយបានទៅដល់ គ្រប់ទីកន្លែង។ លោកបានបន្ថែមទៀតថា ដោយខ្មែរមានដូនតាជាអ្នកជំនាញខាងនយោបាយទឹក គេក៏បានបន្តនយោបាយទឹកនេះតទៅទៀត ដោយបានបោះជំហានយ៉ាងវែងក្នុងវិស័យនេះ បានសេចក្តីថា គេបានផ្លាស់ប្តូរបច្ចេកទេសបញ្ចេញទឹកពីស្រែ ទៅជាការបញ្ចូលទឹកទៅក្នុងស្រែវិញ។ ឯនយោបាយសន្សំទឹក ដើម្បីបង្ហូរទៅក្នុងស្រែនៅពេលដែលគេត្រូវការ ត្រូវបានរៀបចំយ៉ាងម៉ត់ចត់ តាំងពីសម័យកាល ព្រះបាទឥន្ទ្រវរ្ម័នទី១ ដោយព្រះអង្គបានយកព្រះទ័យទុកដាក់នឹងវិស័យកសិកម្ម ដែលជាធម្មតាពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង និងខ្យល់រដូវ។ ការកើនឡើងនូវចំនួនប្រជាពលរដ្ឋ តម្រូវអោយគេធ្វើការប្រឹងប្រែងបង្កើនផលិត ផលកសិកម្មបន្ថែមទៀត យ៉ាងណាមិញ ព្រះបាទឥន្ទ្រវរ្ម័នទី១ បានរៀបចំនយោបាយទឹក តាមរបៀបដែលប្រទេសចេនឡា ធ្លាប់មានរួចមកហើយ ពោលគឺ ទប់ទឹកបង្ខាំងទុកនៅក្នុងទំនប់ធំៗ រួចជីកប្រឡាយបង្ហូរ ទឹកនោះ បញ្ចូលទៅក្នុងស្រែផង ហើយបញ្ចូលទៅក្នុងស្រះធំៗ និងប្រឡាយផ្សេងៗទៀតនៅក្នុងទីក្រុងផង ក្នុងទិសដៅ ទុកប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

នយោបាយទឹករបៀបនេះ ត្រូវបានព្រះរាជានៅជំនាន់ក្រោយៗ ជាពិសេស នៅសម័យអង្គរតែម្តង ដែលគេបានអនុវត្តជាបន្តទៀតយ៉ាង ម៉ត់ហ្មត់ជាហេតុនាំអោយកើតមានភាពសម្បូរសប្បាយដល់ប្រទេស ជាតិអស់រយៈកាលជាច្រើនសតវត្ស។ យើងគួរធ្វើការសិក្សាអំពីនយោបាយទឹក និងការរីកចម្រើននៃសេដ្ឋកិច្ចខ្មែរនៅសម័យអង្គរអោយបាន ពិស្តារបន្ថែមទៀត ព្រោះវាជាមូលដ្ឋានមួយដ៏សម្ខាន់ដែលញ៉ាំងអោយ អរិយធម៌ខ្មែរជំនាន់នោះមានការរីកលូតលាស់រុងរឿងដល់កំពូល។

ក្រៅពីនេះទៀត មានអ្នកប្រាជ្ញជាច្រើនបានធ្វើការត្រិះរិះពិចារ អោយណាអំពីឥទ្ធិពលនៃមជ្ឈដ្ឋានរូបវ័ន្តទៅលើកំណើននៃអរិយធម៌ខ្មែរ ដូចជាលោក P.Gourou បានសរសេរថា កត្តាភូមិសាស្ត្រ និងនយោបាយទឹក ប្រាកដជាមានសារៈសំខាន់ណាស់ក្នុងការញ៉ាំងអោយអរិយធម៌នៃប្រទេសមួយមានការរីកចម្រើនរុងរឿង ក៏ប៉ុន្តែជួនកាលគេអាចជួបប្រទះនូវបញ្ហាចំឡែកមួយទៅវិញ ពោលគឺដោយសារតែស្ថានភាពទឹកដីអំណោយផល អាចធ្វើអោយមនុស្សទៅវាខ្ជិលច្រអូស មិនចេះប្រឹងប្រែងប្រយុទ្ធជាមួយនឹងធម្មជាតិ ព្រោះគេអាចរស់នៅបានស្រួលដោយមិនចាំ បាច់រវល់ខ្វាយខ្វល់ច្រើននោះ

ឡើយ។ ហេតុនេះតើមានអ្វីទៀតជាគ្រឿងផ្សំដែលជំរុញអោយគេ ធ្វើដំណើរឆ្ពោះទៅរកវឌ្ឍនភាព។ ត្រង់ចំណុចនេះយើងមានការពិភាក្សាថា តើត្រូវការកត្តាផ្សេងៗអ្វីទៀត ដែលជាមូលដ្ឋានទស្សនៈទាន នៃការអភិវឌ្ឍសេដ្ឋកិច្ច នាយុគសម័យអង្គរ។

ក្នុងចំណុចនេះ ប្រសិនបើយើងលើកយកកត្តាមរត៌កវប្បធម៌ពីអតីតកាលមកពិចារណា ពោលគឺ កត្តាមរត៌កជាទេពកោល្យ និងសមិទ្ធិ ផល ដែលខ្មែរក្នុងយុគសម័យមុនៗបានបន្សល់ទុក នោះយើង អាចយល់ បានបន្ថែមទៀតអំពីមូលហេតុនៃការរីកចម្រើនរបស់អរិយធម៌អង្គរ។ ខាងក្រោមនេះ គឺជាមរ ត៌កវប្បធម៌ ក្នុងសម័យហ្វូណន និងចេនឡា។

- កត្តាមនុស្ស និងមរត៌កពីអតីតកាលជុំវិញវិស័យសេដ្ឋកិច្ច

គេដឹងថាខ្មែរនៅសម័យអង្គរជាជនជាតិឧស្សាហ៍ ហើយបំណងធំបំផុតគឺការធ្វើអោយរីកចម្រើន លូតលាស់លើគ្រប់វិស័យ និងភាពសម្បូរសប្បាយរុងរឿងរបស់ប្រទេសជាតិ។ ជាភស្តុតាងនៃវត្ថុបំណង នេះ ព្រះរាជានៅសម័យអង្គរ បានបញ្ជាអោយវិចិត្រករអង្គរឆ្លាក់ក្បាច់ រឿងកូរសមុទ្រទឹកដោះនៅលើ ប្រាសាទជាច្រើន និងនៅគ្រប់ច្រកទ្វារ ចូលនៃបុរីអង្គរធំជាដើម ព្រោះទឹកអម្រឹតដែលហូរចេញពីការកូរ សមុទ្រ ទឹកដោះនេះ គឺជានិមិត្តរូបនៃថាមពលខាងការងារ និងការប្រណាំង ប្រជែងបង្កើតផលិតផល យ៉ាងជាក់ច្បាស់។ ម្យ៉ាងទៀតការសិក្សាតាម ផ្លូវចិត្តវិទ្យា អំពីសិល្បៈខ្មែរបុរាណ បានផ្តល់ព័ត៌មានជា ច្រើនទៀត ស្តីពីការតស៊ូ ចិត្តអំណត់ និងសេចក្តីប្រាថ្នាយ៉ាងមុតមាំរបស់ខ្មែរជំនាន់នោះ ចំពោះអ្វីដែល ខ្លួនចាត់ថា ល្អប្រសើរ។

ប៉ុន្តែបើយើងពិនិត្យឲ្យបានដិតដល់ យើងឃើញថាការប៉ងប្រាថ្នា អោយមានការរីកលូតលាស់ នេះ មានតាំងពីសម័យមុនៗមកម្ល៉េះ ពោលគឺ តាំងពីសម័យហ្វូណន និងសម័យចេនឡា។ ប្រវត្តិវិទូជា ច្រើនយល់ថា ពេលដែលខ្មែរមកតាំងរាជធានីនៅអង្គរ ខ្មែរមានអរិយធម៌ខ្ពង់ខ្ពស់ មួយរួចទៅហើយ ជាងនេះទៀតអរិយធម៌នេះគ្រាន់តែធ្វើ
អោយលូត លាស់ថែមទៀត នៅសម័យអង្គរតែប៉ុណ្ណោះ។ យើងនឹងធ្វើការបង្ហាញនូវលក្ខណៈសម្បត្តិ ទាំងឡាយដែលជាមរត៌កពីអតីតកាល ដោយត្រួសៗ ដូចតទៅ ៖

- នៅសម័យហ្វូណន អ្នកស្រុកចេះប្រកបការងារជំនាញ ៖
  - ពូកែរកស៊ីលក់ដូរ ជាពិសេស ធ្វើជំនួញតាមផ្លូវសមុទ្រ
  - ជាសិប្បករយ៉ាងចំណាន ចេះឆ្លាក់ឈើ ត្បាញសូត្រ និង ផលិតប្រដាប់ប្រដាផ្សេងៗ យ៉ាងស្ទាត់
    
    ជំនាញ
  - ជាជាងចម្លាក់ និងជាងសំណង់រាជវាំង ប្រាសាទ
  - ជាអ្នកជំនាញខាងនយោបាយទឹកផ្នែកជីសណ្តរ
- នៅសម័យចេនឡា ខ្មែរមានជីវភាពរស់នៅផ្សេងពីមុនបន្តិចហើយខ្មែជំនាន់នោះ ៖
  - ជាសិប្បករយ៉ាងស្ទាត់ជំនាញ។
  - ជាជាងសំណង់យ៉ាងប៉ិនប្រសព្វបង្គួរទៅហើយ

- ជាអ្នកបន្តវេននយោបាយទឹកពីសម័យហ្វូណន ប៉ុន្តែតាមបែបទំនើបថ្មីមួយ ពោលគឺគេលើកទំនប់ ឃាំងទឹកទុកប្រើប្រាស់នៅរដូវរាំងស្ងួត
- ជាអ្នកជំនាញខាងចម្បាំង និងពង្រីកទឹកដី។

ដូច្នេះមរតកវប្បធម៌ ដែលខ្មែរហ្វូណន និងចេនឡាបានបន្សល់ ទុកអោយខ្មែរសម័យអង្គរ គឺមានតម្លៃពន់ពេកណាស់ នេះពុំទាន់និយាយ ពីមរតក ជាប្រពៃណីផ្នែកវប្បធម៌ទេ។ ទេពកោសល្យរបស់មនុស្សខ្មែរ បានធ្វើអោយអ្វីៗដែលមានកាលពីមុនមក អោយកាន់តែរីកលូតលាស់ និងកាន់តែប្រសើរឡើងជាលំដាប់ ដែលនៅក្នុងលោកយើងនេះសឹងរក អរិយធម៌ណា មកប្រៀបផ្ទឹមអោយស្មើពុំបានឡើយ។

## សេចក្តីសន្និដ្ឋាន

សរុបមក ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នាយុគសម័យអង្គរ មានខ្លឹមសារដូចខាងក្រោមនេះ ៖

- ព្រះរាជា បានកំណត់យកទីតាំងភូមិសាស្ត្រតំបន់អង្គរ មកតាំង ជារាជធានី ក៏ព្រោះតែតំបន់នេះមានជ័យភូមិល្អ ម្យ៉ាងទៀតគឺជាតំបន់ ដែលសម្បូរទៅដោយសម្បត្តិធនធានធម្មជាតិគ្រប់ប្រភេទ ដែលជួយទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- ការបន្តការអភិវឌ្ឍនយោបាយធារាសាស្ត្រ គឺជាមធ្យោបាយមួយ ដ៏សំខាន់បំផុត ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចកសិកម្មផលិតកម្ម។
- ការប្រើប្រាស់ទេពកោសល្យ ដែលជាកេរ្តិ៍មរតកវប្បធម៌របស់ប្រជារាស្ត្រខ្មែរដែលមានស្រាប់តាំងពីសម័យកាលមុនៗ បានជួយធ្វើអោយវិស័យសេដ្ឋកិច្ចផលិតកម្មគ្រប់ប្រភេទ បន្តការរីកលូតលាស់ទៅ មុខឥតឈប់ឈរ។
- ការប្រកាន់យករបបរាជានិយមបែបលទ្ធិទេវរាជ និង សាសនា ដែលធ្វើអោយប្រជារាស្ត្រមានការជឿជាក់ និងគោរពប្រតិបត្តិតាមបញ្ជា របស់ព្រះមហាក្សត្រ (ជាអាទិទេព) ចូលរួមក្នុងកិច្ចការសាធារណៈ និង កិច្ចការ អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

សរុបសេចក្តីមក ដោយមានការគ្រប់គ្រងគោលនយោបាយ សេដ្ឋកិច្ចបានត្រឹមត្រូវ តាមរយៈការសំយោគបញ្ចូលគ្នានូវទីតាំងភូមិសាស្ត្រដែលមានលក្ខណៈអំណោយផល មានសម្បត្តិធម្មជាតិគ្រប់គ្រាន់ មានគោលនយោបាយធារាសាស្ត្រល្អ មានមរតក និងទេពកោសល្យដ៏ ល្អប្រពៃ រួមផ្សំជាមួយនឹងការប្រកាន់យកលទ្ធិទេវរាជដ៏មានប្រសិទ្ធិភាព (សម្រាប់យុគសម័យកាលនោះ) ដែលទាំងអស់នេះ គឺជាគោលគំនិត និងជាមូលដ្ឋានគ្រឹះនៃទស្សនៈអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ព្រមទាំងអរិយធម៌អង្គរយ៉ាងពិតប្រាកដ។

## ៣.៣. វិស័យកសិកម្មនាសម័យអង្គរ

### ៣.៣.១ ផលិតកម្មដំណាំស្រូវ

នៅយុគសម័យអង្គរ ខ្មែរយើងបានទទួលជោគជ័យសម្បើមណាស់ខាងវិស័យកសិកម្ម ហើយជោគជ័យនេះគឺ ជារបស់ប្រជាពលរដ្ឋ ខ្មែរនាសម័យនោះ។ ដោយសារមធ្យោបាយនេះ ទើបគេមានលទ្ធភាព ទប់ស្កាត់នឹងគ្រោះមហន្តរាយធម្មជាតិជាយថាហេតុ ក្នុងកំឡុងពេលជាច្រើនសតវត្ស។ គេអាចនិយាយដោយសមរម្យថា នៅសតវត្សទី ១៣ គ្មានទឹកភ្លៀងមួយដំណក់ណាដែលធ្លាក់ពីលើមេឃ ឬគ្មានទឹកស្ទឹងមួយដំណក់ណាដែលហូរចុះពីភ្នំគូលែន ដែលពុំបានរត់ឆ្លងកាត់តាមគន្លងបណ្តាញ ព្រែក ប្រឡាយ អូរ និង អាងទឹកទាំងឡាយ រួចហើយហូរ ទៅជួយផ្គត់ផ្គង់ដល់ដំណាំសព្វបែបយ៉ាងរបស់ខ្មែរទេ។ ភស្តុតាងម្យ៉ាងទៀតដែលបញ្ជាក់ថា ខ្មែរយើងមានបច្ចេកទេសច្បាស់លាស់ណាស់ខាងនយោបាយទឹក ព្រោះគេអាចបង្កើតក្រុងថ្មី នៅតំបន់រីងស្ងួតបាន ដូចជា រាជធានីកោះកេរ នៅសតវស្សទី១០ដែលនៅទីនោះ គេបានស្ថាបនា បារាយណ៍មួយឈ្មោះ ហោល ( ពិតមែនតែក្រុងថ្មីនេះពុំមានស្ថានភាព ភូមិសាស្ត្រប្រសើរដូចបូរីអង្គរ និងមានអាយុមិនបានយឺនយូរក៏ដោយ)។

នយោបាយទឹកដដែលនេះ បានធ្វើអោយយើងឆ្លងផុតពីដំណាក់ កាលសេដ្ឋកិច្ចចិញ្ចឹមគ្រួសារ ចូលទៅកាន់ដំណាក់សេដ្ឋកិច្ចម្យ៉ាងទៀតដែលហៅថា, សេដ្ឋកិច្ចកសិកម្មអតិផល ដោយសារតែកម្លាំងការងាររបស់មនុស្ស ដែលបានរៀបចំដោយមនុស្ស។ គេធ្លាប់បានឃើញរួចមកហើយ នៅក្នុងប្រវត្តិអរិយធម៌បុរាណទាំងឡាយថា ជនជាតិអេហ្ស៊ីបនៅលើដងទន្លេនីល ជនជាតិចិននៅតាមដងទន្លេលឿង។ល។ បានតាក់តែងជីវភាព និងសេដ្ឋកិច្ចរបស់គេតាមរបៀបប្រហាក់ប្រហែលគ្នានេះដែរ។

តាមរយៈការសិក្សានៅលើផ្ទាំងសិលាចារឹកនានា គេអាចធ្វើការសន្និដ្ឋានបានថា ផលិតកម្មដំណាំស្រូវនៅតំបន់អង្គរនាចុងសតវត្សទី១២ បានកើនឡើងដល់កម្រិតកំពូលដោយកាលនោះប្រទេសខ្មែរអាចផលិត ស្រូវបានជាមធ្យម១ឆ្នាំ ប្រហែល ៤០០គ.ក សម្រាប់មនុស្សម្នាក់ៗ។ តាមកំណត់ហេតុរបស់លោក ជីវ តាក្វាន់ បានអះអាងថា នៅឆ្នាំ ១២៩៤ ប្រជារាស្ត្រខ្មែរអាចធ្វើស្រែ បាន៣ ឬ៤ដងក្នុង១ឆ្នាំ។ ដោយឡែកលោក ហង់រី ស្ទែរលីង អ្នកឯកទេសជនជាតិស្វីសម្នាក់បានធ្វើការវាយ តម្លៃថានៅលើផ្ទៃដី ១.០០០ គ.ម$^{២}$ នៅតំបន់អង្គរ គេអាចផលិតស្រូវបានក្នុងមួយឆ្នាំប្រហែល ១៥០.០០០ តោន អាចចិញ្ចឹមប្រជាជនដល់ទៅ ៨០០.០០០ នាក់ និងនៅសល់ ៤០% ទៀតអាចបញ្ជូនទៅតំបន់ផ្សេងៗ ទៀត។

កាលណាសេដ្ឋកិច្ចរឹងមាំ គេមានលទ្ធភាពធំទូលាយ ក្នុងការបំពេញកិច្ចការទាំងឡាយទៀត។ សរុបសេចក្តីមក គឺកត្តាសេដ្ឋកិច្ចនេះហើយដែលអនុញ្ញាតអោយខ្មែរយើង មានឱកាសកសាងប្រាសាទបានល្អៗ ហើយអាចធ្វើសង្គ្រាមវាតទីទឹកដីបានយ៉ាងទូលាយនាសម័យកាលនោះ។ ជាទូទៅកន្លែងណាមានការកសាងប្រាសាទ កន្លែងនោះ តោងមានទឹកសម្រាប់កសិកម្ម និងជាទីប្រជុំជន ដែលមានភាពសុខដុមរមនាដែលជាអរិយធម៌មួយ ។

### ៣.៣.២ ការនេសាទ ចិញ្ចឹមសត្វ និង ដំណាំរួមផ្សំ

នៅសម័យអង្គរ ក្រៅពីដំណាំស្រូវ ប្រជារាស្ត្រខ្មែរប្រកបរបរ នេសាទត្រី ព្រោះមានរូបចម្លាក់នៅលើប្រាសាទបាយ័ន បានបង្ហាញស្រាប់។ ចំពោះត្រីនេះ (ដែលសម្បូរហូរហៀរហូតមកដល់សព្វថ្ងៃនេះ ជាពិសេសនៅក្នុងបឹងទន្លេសាប ក្បែរក្រុងអង្គរតែម្តង) គេសន្មតថា ជាចំណីអាហារដ៏សំខាន់ជាងគេរបស់ខ្មែរនៅជំនាន់នោះ ក៏ដូចជាសម័យ បច្ចុប្បន្នដែរ បន្ទាប់ពីស្រូវ។

ចំពោះវិស័យចិញ្ចឹមសត្វ ដើម្បីយកសាច់បរិភោគប្រហែលមាន មិនខ្វះទេ ឬមួយគេបរិភោគសាច់បក្សី និងសាច់ម្រឹគទាំងឡាយដែលគេបរបាញ់ នៅក្នុងព្រៃ។ គួរបញ្ជាក់ថា ប្រជារាស្ត្រខ្មែរនៅសម័យអង្គរ មានការចិញ្ចឹមសត្វបន្ថែម ក្រៅពីសត្វពាហនៈដែលបម្រើអោយការងារកសិកម្ម (គោ ក្របីសេះ ) មានដូចជា ជ្រូក មាន់ ទា ជាដើម ដែលយកសាច់ ទទួលទានជាធម្មតា និងនៅពេលមានពិធីបុណ្យម្តងៗ។

ចំណែកឯការដាំដុះនូវដំណាំរួមផ្សំវិញយើងឃើញថា នៅសម័យអង្គរ ផលិតផលបន្លែបង្ការ គឺមានបរិមាណច្រើន ព្រោះផលិតផលរបស់ ខ្មែរ បាននាំចេញទៅកាន់ប្រទេសឆ្ងាយៗដូចជាប្រទេសជប៉ុនជាដើមនូវផ្លែត្រសក់។ តាមកំណត់ហេតុរបស់ ជីវ តាក្វាន់ តំបន់ទូទៅ ដែលខ្មែរ យើងជំនាន់នោះបានដាំដុះ មានដូចជា មើមខ្ទឹមស ត្រាវ ផៃថាវ មើមខ្ទឹម ក្រហម ត្រសក់ សណ្តែកជាច្រើនប្រភេទ អំពៅ ។ល។ ក្រៅពីនោះ គេឃើញមានការដាំដើមផ្កាគ្រប់ប្រភេទមានច្រើនពូជ និងច្រើនសណ្ឋាន ទុកសម្រាប់ជាគ្រឿងលម្អ ខ្លះសម្រាប់អប់យកក្លិន (ធ្វើទឹកអប់) និងមាន បរិមាណដ៏ច្រើន ដែលត្រូវប្រើប្រាស់នៅក្នុងពិធីក្នុងព្រះរាជវាំង និងក្នុង ពិធីជាជង្វាយ ដល់ព្រះអាទិទេពនៅតាមបណ្តាប្រាសាទនានា។

ជាងនេះទៀត នៅក្នុងព្រៃទៀតសោត សម្បូរទៅដោយឈើល្អៗ សម្រាប់យកមកសង់គេហដ្ឋានប្រាសាទឬវត្តអារាម និងធ្វើគ្រឿង ប្រដាប់ប្រើប្រាស់ផ្សេងៗ មាន គុ ទូតាំង កៅអី រទេះនង្គ័ល ជាដើម ។ សម្បត្តិធម្មជាតិទាំងអស់ ពិតជាបានជួយបំពេញមុខងារដ៏សំខាន់ដែរ នៅក្នុងការលូតលាស់នៃអរិយធម៌ខ្មែរ ឬមួយក៏ដោយសារហេតុនេះ ហើយ បានជាមានអ្នកប្រាជ្ញខ្លះបញ្ចូលអរិយធម៌ខ្មែរ ក្នុងពពួក "អរិយធម៌ រុក្ខជាតិ" តាមរូបមន្តរបស់លោក P.Gourou ។

## ៣.៤. វិស័យសិប្បកម្ម និង ឧស្សាហ៍កម្ម

គេពុំមានពត៌មានច្បាស់លាស់ស្តីអំពីបច្ចេកទេសផ្សេងៗ ក្នុងការផលិតប្រដាប់ប្រដាប្រើប្រាស់ ឬគ្រឿងឧបភោគបរិភោគនៅសម័យអង្គរនោះទេ។ ប៉ុន្តែគេអាចសន្និដ្ឋានបានថា ពិតជាមានរបរសិប្បកម្ម និង ឧស្សាហកម្មមួយបែបរបស់ប្រជារាស្ត្រ ដោយគេឃើញមាននៅសេសសល់នូវគ្រឿងប្រដាប់ប្រើប្រាស់ពីជំនាន់នោះជាច្រើន និងដោយសំអាងទៅលើឯកសារ (ដ៏ស្តួចស្តើង) របស់លោក ជីវ តាក្វាន់។

### ៣.៤.១ វិស័យសិប្បកម្មគ្រឿងប្រដាប់ប្រដាប្រើប្រាស់

ប្រទេសមួយដែលប៉ិនប្រសព្វខាងផ្នែកសិល្បៈ ចម្លាក់លើថ្ម ខាង ផ្នែកសំណង់អំពីឈើ ឬអំពីថ្ម ប្រទេសនោះប្រាកដជាមានប្រជាជនដែល ស្ទាត់ជំនាញខាងផ្នែកសិប្បកម្មនេះយ៉ាងច្បាស់ណាស់។ ម្យ៉ាងទៀត រូបចម្លាក់នៅលើជញ្ជាំងប្រាសាទនានា បានប្រាប់យើងអោយដឹងថា ខ្មែរយើងជំនាន់អង្គរ ចូលចិត្តគ្រឿងប្រដាប់ប្រណិតៗ មានគ្រឿងអលង្ការជាដើម។ ដូច្នេះគេអាចសន្និដ្ឋានបានថា របស់អស់ទាំងនេះមិនមែនសុទ្ធ តែជាទំនិញដែលយើងនាំចូលពីបរទេសទាំងអស់នោះឡើយ ហើយ ប្រាកដជាមានរបរសិប្បកម្ម សម្រាប់ផលិតគ្រឿងប្រដាប់ទាំងនេះនៅក្នុងប្រទេសខ្មែរ។

លោក ជីវ តាក្វាន់ គាត់បានកត់សម្គាល់ថា នៅសតវត្សទី ១៣ គេចេះត្បាញសំពត់ស្លៀកពាក់ មានដាំមន និងចិញ្ចឹមដង្កូវនាង ដើម្បីយកសូត្រ ដោយយកពូជពីស្រុកសៀម។ គេចេះធ្វើទូកធំ តូច ធ្វើរទេ គ្រឿង សង្ហារឹមគ្រប់យ៉ាងដ៏ល្អវិចិត្រ ចេះឆ្លាក់វត្ថុផ្សេងៗអំពីឈើ និងភ្លុក ដើម្បីធ្វើជាគ្រឿងលម្អរ ធ្វើល្អី កញ្ច្រោងកន្ទេលសព្វសារពើ ។ល។ ប្រដាប់ប្រដា ទាំងអស់នេះ គេអាចដឹងបានដោយសាររូបចម្លាក់នៅលើប្រាសាទនានា និងដោយសិលាចារឹក ដែលរៀបរាប់នូវមុខទំនិញ ជាច្រើនអនេក សម្រាប់ប្រើប្រាស់នៅក្នុងប្រាសាទតាព្រហ្ម និងព្រះខ័ន(អង្គរ)។ ការសិក្សាអំពីទេពអប្សរា និងទេវតា បញ្ជាក់បន្ថែមទៀតថា ខ្មែរនិយមគ្រឿង អលង្ការជាទីបំផុត។

គ្រឿងអលង្ការទាំងនេះ មានច្រើនបែបច្រើនយ៉ាង ណាស់ មានតាំងពីស្នៀតសក់ដាំត្បូង រហូតដល់កងដៃ កងជើង ខ្សែក ខ្សែក្រវ៉ាត់ ចិញ្ចៀនដាំពេជ្រភ្នែកឆ្មារនៅគ្រប់ម្រាមដៃ។ល។ ហើយ ដោយមានក្បាច់រចនារបស់ជាងទងយ៉ាងល្អប្រណិតទៀតផង ។

ដូចខាងស្ថាបត្យកម្ម និងសិល្បៈសំណង់ដ៏ទៃទៀតដែរ សិប្បកម្ម បង្ហាញយ៉ាងច្បាស់នូវចំណូលចិត្តរបស់ខ្មែរចំពោះវត្ថុប្រណិត (វត្ថុទាំងនោះរមែងប្រកបទៅដោយក្បូរក្បាច់រចនាជារៀងដរាប) ហើយជាមួយគ្នានេះ បង្ហាញនូវទេពកោសល្យរបស់ខ្មែរសម័យអង្គរដែលគួរអោយគេ នឹកស្ងើចសរសើរមិនចេះចប់ ។

### ៣.៤.២ វិស័យសិប្បកម្មចំណីអាហារ

រីឯវិស័យសិប្បកម្មគ្រឿងបរិភោគ នៅសម័យអង្គរយើង ពិនិត្យ ឃើញថា ខ្មែរយើងសម័យនោះចេះបិតស្រា ៤ប្រភេទ, ហើយនៅតាម ឆ្នេរសមុទ្រចាប់ពី ចេនភូ (ច័ន្ទបូរី) និងប៉ាកាង (បាកាន) គេចេះធ្វើអំបិល ពីទឹកសមុទ្រ។ នៅក្នុងភ្នំមានរ៉ែដែលគេអាចយកទៅស្លធ្វើជាអំបិលបាន មានលក្ខណៈប្រសើរ ជាងអំបិលសមុទ្រទៅទៀត។ បន្ទាប់មកលោក ជីវ តាក្វាន់ បានសរសើរថា ខ្មែរចេះផ្សំគ្រឿងម្ហូរយ៉ាងឆ្ងាញ់ពិសារហើយថែមទាំងចេះ ធ្វើ ទឹកស៊ីអ៊ីវផង ទាំងអស់នេះបានសេចក្តីថា ខ្មែរយើង ជំនាន់អង្គរមានទម្រង់សិប្បកម្មសម្រាប់ផលិតគ្រឿងបរិភោគម្យ៉ាងដែរ។

### ៣.៤.៣ វិស័យឧស្សាហកម្ម

- ❖ ឧស្សាហកម្មគ្រឿងសំណង់ (ឥដ្ឋ និងគ្រឿង)

នាសម័យអង្គរ គេឃើញមានសម្ភារៈ ឥដ្ឋ ក្បឿង ព្រមទាំង គ្រឿងភាជន៍ គ្រឿងប្រដាប់ប្រើប្រាស់ផ្សេងៗ និងរូបបដិមាជាច្រើនធ្វើអំពីលោហៈធាតុ។

មកដល់សតវត្សទី៧ យើងពិនិត្យឃើញថា ការធ្វើសម្ភារៈអំពីឥដ្ឋ មានបច្ចេកទេសល្អត្រឹមត្រូវហើយ។ ដុំឥដ្ឋមានរាងប្រលេពីប៉ែត តាន់ ជាប់មាំល្អ ហើយគេធ្វើដោយល្អិតល្អន់ណាស់។ នៅពីលើឥដ្ឋគេតែង បិតបាយអរម្យ៉ាងធ្វើពីកំបោរលាយខ្សាច់និងស្ករត្នោត។ ឥដ្ឋនេះគេនិយម ប្រើជាទូទៅក្នុងប្រទេស។ ក្រោយសតវត្សទី ១៣ គេឈប់ប្រើថ្មភក់ ហើយ ហើយត្រឡប់ទៅប្រើប្រាស់ឥដ្ឋវិញ ។

អត្ថបទសិលាចារឹកនៅប្រសាទបន្ទាយឆ្មារ និងប្រាសាទបាយ័ន បានបញ្ជាក់ថា មានប្រាសាទខ្លះសង់អំពីសម្ភារៈស្រាលៗ (ឈើ) ហើយ ប្រក់សំណ ឬក្បឿង។ អាគារដែលប្រក់សំណពុំឃើញមានសេសសល់ នោះទេ។ អាគារដែលប្រក់ក្បឿងសម្បូរណាស់ នៅសម័យអង្គរ ជាពិសេសគេហដ្ឋានរបស់ពួកអភិជន។ កំណាយក្នុងដីនៅក្នុងបរិវេណ ក្រុងអង្គរ បានបង្ហាញអោយឃើញនូវសំណល់កំទេចក្បឿងជាច្រើន។ ឯក្បឿងនេះ មានគុណភាពប្លែកៗគ្នាទៅតាមមជ្ឈដ្ឋានដីឥដ្ឋ ខ្លះពណ៌ ផ្កាឈូកលឿងបន្តិច រីឯនៅតំបន់វរដីឥដ្ឋមានពណ៌ស្ទើរតែស។

តើក្បឿងនេះបានវិវត្តន៍ឯកឯងចេញពីឥដ្ឋ ដែលគេប្រើប្រាស់ជាទូទៅសម្រាប់សង់ប្រាសាទទាំងឡាយនៅសម័យមុនៗ ឬក៏មកពីភាជន៍ដី ឬក៏ជាផលិតផលកើតចេញពីបច្ចេកទេស ដែលគេស្គាល់ដោយសារបរទេសនៅពេលក្រោយ(ចិន) ព្រោះនៅសម័យហ្វូណន អត់មានភស្តុតាង ឬសក្ខីភាពណាប្រាប់យើងដឹងថា គេចេះប្រើ ឬធ្វើក្បឿងនៅឡើយទេ។ ឯកសារចិនទាំងឡាយ ដែលតំណាលពីប្រទេសខ្មែរសម័យនោះក៏ មិនបានបញ្ជាក់ពីរឿងនេះទេ។

ក្នុងករណីនេះ ក្បឿងពិតជាសមិទ្ធិផលមួយគួរអោយសរសើររបស់ខ្មែរសម័យអង្គរ ទោះបីជាសម្ភារៈទាំងនេះកើតឡើងដោយសារ ឥទ្ធិពលបរទេសណាមួយក៏ដោយចុះ(ចិន)។ នៅពេលណាដែលគេចេះ យកក្បឿងទៅប្រើជំនួសស្លឹកត្នោត ស្លឹកចាក ឬស្បូវ នៅពេលនោះបាន សេចក្តីថា គេបានបោះជំហានទៅមុខមួយយ៉ាងធំ ឆ្ពោះទៅរកវឌ្ឍនភាព ចំពោះសំណាវិញយើងឃើញថា កាន់តែគួរអោយស្មុគស្មាញណាស់ទៅទៀត។

### ❖ ឧស្សាហកម្មភាជន៍ និងការកែច្នៃលោហៈធាតុ

នៅសម័យអង្គរ ភាជន៍ និងការកែច្នៃលោហធាតុ គេនិយមប្រើប្រាស់ណាស់ ព្រោះដីខ្មែរសម្បូរទៅដោយដីឥដ្ឋ និងខ្សាច់ ដែលមានគុណភាព និងមានសារជាតុកៅឡាំង ហើយសម្បូរព្រៃឈើសម្រាប់ប្រើ ប្រាស់ក្នុងការដុតឡ។

ប្រជាជនធម្មតា ត្រូវការគ្រោងភាជន៍ ដើម្បីដាក់ ទឹកត្រី ទឹកស៊ីអ៊ីវ បិតស្រា ដាក់ស្រា ដាក់គ្រាប់ធញ្ញជាតិនានា ពីកន្លែងមួយទៅកន្លែងមួយ និងដាក់ជាតិជ័រផ្សេងៗ ។ អ្នកស្រុកតែងតែប្រើគ្រឿងភាជន៍ធ្វើពីដី។ រីឯពពួកអភិជន និងស្តេច គេច្រើនប្រើគ្រឿងប្រដាប់ដែលច្រើនធ្វើអំពីសំរិទ្ធ ស្ពាន់ ប្រាក់ មាសសម្រាប់ដាក់គ្រឿងក្រអូប ឬប្រើប្រាស់ក្នុងពិធីផ្សេងៗ។

លោក សុង ស៊ីវ ក្នុងសៀវភៅឈ្មោះ ចលនាអរិយធម៌ បានអះ អាងថា នៅសម័យអង្គរមានដុតរំលាយដែកស្ពាន់ ប្រាក់ លន សំរិទ្ធ មាស ធ្វើគ្រឿងប្រដាប់ប្រើប្រាស់គ្រប់យ៉ាង។[41] អ្នកស្រី ម៉ាដឺឡែន

ហ្សិត្ត ក៏បានសរសេរដែរថា ខ្មែរសម័យអង្គរប្រហែលជាចេះស្លដែក ស្ពស័រិទ្ធ ព្រោះមានភស្តុតាងដែលគេរកឃើញរូបបដិមាព្រះវិស្ណុ កំពុងផ្ទុះមួយ យ៉ាងធំសម្បើមធ្វើពីសំរិទ្ធតែបានបាក់បែកអស់មួយភាគធំទៅហើយ។ (រូបនេះគេចាត់ថា ជាស្នាដៃយ៉ាងវិសេសមួយក្នុងលោក ខាងផ្នែកគ្រឿងសំរិទ្ធ)។[42] ចំពោះគ្រឿងប្រដាប់ធ្វើពីលោហធាតុដដែលនេះ គឺមានគ្រឿង អាវុធយុទ្ធភ័ណ្ឌសព្វបែបយ៉ាង ក្រៅពីនោះមានឧបករណ៍សម្រាប់ប្រើ ប្រាស់ក្នុងពេងជាង និងចម្លាក់លើថ្ម ម្យ៉ាងទៀតឧបករណ៍ទាំងឡាយ នោះប្រាកដជាផលិតផល ដែលបានផលិតចេញក្នុងចំនួនយ៉ាងច្រើន ហើយគេតែងផលិតប្រដាប់ណា ដែលមានលក្ខណៈជាប់រឹងមាំ មានទំហំ ធំ រហូតដល់តូចឆ្មារបំផុត ដើម្បីបង្កើតអោយចេញបានជាក្បាច់ចម្លាក់ និងមានក្បូរក្បាច់រចនាដ៏ល្អិតល្អន់ និងយ៉ាងប្រណិត។

## ៣.៥ វិស័យសេវាកម្ម

### ៣.៥.១ វិស័យគមនាគមន៍

នៅសម័យអង្គរ ក្រៅពីបណ្ដាញជលគតិទាំងអម្បាលម៉ាន ដែល យើងបានរៀបរាប់ពីខាងលើនៅមានបណ្ដាញផ្លូវថ្នល់ជាច្រើនទៀត។ បណ្ដាញផ្លូវថ្នល់ទាំងនោះបូករួមជាមួយផ្លូវទឹក នានា ទោះផ្លូវទឹកនោះមានកំណើតពីធម្មជាតិក្ដី ឬស្ថាបនាដោយមនុស្សក្ដី សុទ្ធសឹងតែមាន សារៈសំខាន់ណាស់ចំពោះការដឹកជញ្ជូនផ្នែកពាណិជ្ជកម្ម។ នេះដោយពុំទាន់លើកឡើងអំពីប្រយោជន៍ខាងផ្នែកសាធារណៈ និងយុទ្ធសាស្ត្រ សង្គ្រាមនោះផង។

តាមធម្មតាទំនប់ដែលគេលើកព័ទ្ធជុំវិញបារាយណ៍នីមួយៗ សុទ្ធសឹងជាផ្លូវថ្នល់សម្រាប់ចរាចរ។ ជាឧទាហរណ៍នៃការស្ថាបនាផ្លូវថ្នល់ក្នុងរជ្ជកាល ព្រះបាទយសោវរ្ម័នទី១ ព្រះអង្គបានអោយគេសង់ផ្លូវភូមិន្ទ មួយក្រាលថ្មីពីយសោធរបុរៈទៅកាន់ ហរិហរាល័យ (រលួស)។ ជាពិសេស ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ គេដឹងថាព្រះអង្គបាន អោយគេសង់ថ្នល់ជាច្រើនខ្វាត់ខ្វែងក្នុងព្រះរាជាណាចក្រ មានជាអាទិ៍ ផ្លូវថ្នល់ពី ក្រុងអង្គរ (យសោធរបុរៈ) ទៅកាន់ក្រុងវិជ័យ នៅប្រទេសចំប៉ា និងពីក្រុងអង្គរដដែលទៅកាន់ភិមាយ នៅប្រទេសសៀមសព្វថ្ងៃ ។

សរុបមកប្រទេសកម្ពុជាយើងនាសម័យអង្គរ មានផ្លូវសំខាន់ៗ សម្រាប់ទំនាក់ទំនងធ្វើចរាចរចំនួន ៧ខ្សែ គឺ ៖

- ផ្លូវពីក្រុងអង្គរ ទៅកំពង់ធំ
- ពីអង្គរទៅប្រាសាទព្រះខ័នក្នុងស្រុកកំពង់ស្វាយ(ខេត្តសៀមរាប) ផ្លូវពីប្រាសាទបឹងមាលាទៅវត្តភូ (បច្ចុប្បន្ននៅឡាវ) ដែលឆ្លង តាមប្រាសាទកោះកេរ
- ផ្លូវពីប្រាសាទបឹងមាលា ទៅកាន់បឹងធំ
- ផ្លូវពីក្រុងអង្គរទៅភិម៉ាយ (បច្ចុប្បន្ននៅសៀម) ដោយឆ្លងកាត់ តាមខ្លង់រាប កូរ៉ាត
- ផ្លូវពីទីក្រុងអង្គរ ទៅកាន់ប្រាសាទបន្ទាយឆ្មារ
- និង ផ្លូវពីអង្គរ ទៅកាន់បឹងធំៗ។ [43]

ផ្លូវសំខាន់ៗ ទាំងនោះមានទទឹងពី ១០ ទៅ ២៥ម៉ែត្រ និងក្រាលដោយឥដ្ឋ និងមានកម្ពស់ពី ២ ទៅ ៦ ម៉ែត្រ ដើម្បីការពារទឹកជំនន់នៅ រដូវវស្សា។ ផ្លូវទាំងនោះសម្រាប់ប្រើចំពោះការធ្វើដំណើរជាផ្លូវការរបស់មន្ត្រី និងព្រះមហាក្សត្រ តែរាស្ត្រសាមញ្ញទូទៅក៏អាចប្រើបានដែរ។ ក្នុងការធ្វើដំណើរទៅតំបន់នានា ឬទីកន្លែងដាច់ស្រយាលពិបាកនឹងទៅដល់ មន្ត្រី ឬអ្នករាជការជាន់ខ្ពស់បានប្រើដំរីជាយានដើម្បីសម្រួលការធ្វើដំណើរ។ ចំពោះយុទ្ធនាការយោធា ឬធ្វើសង្គ្រាមជាដើម គេក៏ប្រើដំរី និងសេះជាយានជំនិះដែរ តែកងទ័ពភាគច្រើនដើរដោយថ្មើរជើងតាម ពីក្រោយទ័ពដំរី។ សម្រាប់ដំណើរផ្លូវឆ្ងាយ ហើយពិបាកគេចូលចិត្តប្រើប្រាស់នាវាតាមផ្លូវទឹកជាង។

លោក ជីវ តាក្វាន់ បានអះអាងថា នៅតាមដងផ្លូវទាំងនោះមាន ស្ពានសាលាដំណាក់ជាច្រើន សម្រាប់អោយឈ្មួញទូទៅ និងអ្នកដំណើរផ្លូវឆ្ងាយអាចឈប់សម្រាកបាន។ សាលាដំណាក់ទាំងនោះចម្ងាយ ពីមួយទៅមួយប្រមាណជា ១៥ គ.ម ហើយគេរាប់ឃើញសាលាដំណាក់ ចំនួន ៥៧ នៅតាមផ្លូវ

ពី អង្គរ ទៅកាន់ក្រុងវិជ័យ ប្រទេសចំប៉ាចំនួន ១៧ នៅតាមផ្លូវពី ក្រុងអង្គរ ទៅកាន់ ភិម៉ាយ (នៅប្រទេសសៀមសព្វថ្ងៃ)និង ៤៤ នៅតាមបណ្តាញផ្លូវមួយទៀត ដែលគេពុំដឹងទីកន្លែងច្បាស់លាស់ តែផ្លូវនោះត្រូវឆ្លងកាត់ភ្នំដឹសូរ។ ប្រព័ន្ធផ្លូវថ្នល់ ស្ពាន និងសាលារៀន បានធ្វើអោយ លោក ជីវ តាក្វាន់ កោតសរសើរជាខ្លាំង នៅសតវត្សទី១៣ ដោយគេពុំទាន់រាប់បញ្ចូលនូវបារាយណ៍ និងជលគតិទាំងអស់ដែល មានប្រយោជន៍ខាងសង្គមកិច្ច និងសេដ្ឋកិច្ចជាតិ។

រីឯជំនួញតាមផ្លូវទឹកវិញនៅតែមានសកម្មភាពយ៉ាងមមាញឹក ដដែល គ្រាន់តែមានការខុសប្លែកពីសម័យហ្វូណនត្រង់ចំណុច ដែលថាសម័យនោះ គេចូលចិត្តទាក់ទងធ្វើជំនួញជាមួយបរទេសតាមសមុទ្រ។ ម្តងនេះសកម្មភាពជំនួញច្រើនធ្វើនៅតាមផ្លូវទឹកសាបក្នុងប្រទេស។ ក្រៅពីទន្លេ បឹងបួរ និងស្ទឹងដែលមានជាច្រើនរួចមកហើយនោះ ខ្មែរយើង បានជីកព្រែកប្រឡាយជាច្រើនទៀតដែលបង្កភាពងាយស្រួលដល់ទូក ជំនួញតូចធំ អាចធ្វើដំណើរឆ្លងកាត់ចុះឡើងបានរហូតដល់កំពែងនៃ បូរីអង្គរធំ។ លោក B.Groslier បានសរសេរថា នាវាសមុទ្រធំៗ អាច ឡើងតាមទន្លេមេគង្គឆ្លងចូលបឹងទន្លេសាប ហើយឡើងរហូតទៅដល់ មាត់ច្រាំងនៅក្បែតំបន់អង្គរ។

ដូច្នេះទីក្រុងអង្គរស្ថិតជាទីប្រសព្វនៃចរន្តពាណិជ្ជកម្មក្រៅស្រុក និងក្នុងស្រុក ដោយសារតែបណ្តាញផ្លូវគោក និងផ្លូវទឹកទាំងឡាយ។ ហេដ្ឋារចនាសម្ព័ន្ធនេះមានសារៈប្រយោជន៍ធំធេងណាស់ ដែលមានអ្នកស្រាវជ្រាវខ្លះបានអះអាងថា ខ្មែរមាន "អរិយធម៌ គឺផ្លូវថ្នល់ ស្ពាន និង កំពង់ផែ"។

## ៣.៥.២ វិស័យពាណិជ្ជកម្ម

ដូចដែលយើងបានបង្ហាញពីខាងលើរួចហើយថា តំបន់អង្គរស្ថិត លើផ្លូវត្រឡែងកែង នៃចរន្តពាណិជ្ជកម្មទាំងឡាយទាំងក្នុងប្រទេស និង ក្រៅប្រទេស ដោយសារតែបណ្តាញគមនាគមន៍មានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងព្រះរាជាណាចក្រខ្មែរ និង ដោយសារការរីកលូតលាស់នៃ វិស័យកសិកម្ម វិស័យសិប្បកម្មគ្រប់ប្រភេទ និងវិស័យសេវាកម្ម។

ចំពោះវិស័យពាណិជ្ជកម្មក្នុងស្រុក តាមរយៈរូបចម្លាក់នៅលើ ជញ្ជាំងប្រាសាទបាយ័ន បានបង្ហាញអំពីទីផ្សារប្រកបដោយមនុស្សអ៊ូអរ មានតាំងរាន តាំងតុទាបៗ តាំងកញ្ជើល្អ ហើយអ្នកលក់ដូរច្រើនតែស្រីៗ ដូចដែល លោក ជីវ តាក្វាន់ បានសរសេរប្រាប់ថា មានការប៉ិនប្រសព្វ ខ្លាំងណាស់ក្នុងរឿង ជំនួញជួញប្រែនេះ។ តាំងពីព្រលឹមទល់ថ្ងៃត្រង់គេលក់ គេដូរគេជជែកតថ្លៃគ្នាយ៉ាងអ៊ូអរ ដើរចុះឡើងតាមចន្លោះគំនរផ្លែ ឈើគ្រប់ប្រភេទដូចជា គ្រប់ ត្រឡាច ល្ពៅ ម្ទេសផ្លោក ខ្ទឹម ចេក ក្រូច ។ល។ និងបន្លែត្រីសាច់សព្វយ៉ាង ខ្លះដាក់ក្នុងល្អី ឬកញ្ជើ ខ្លះដាក់លើ កន្ទេលក្រាលផ្ទាល់នឹងដី។ ក្រៅពីបន្លែផ្លែឈើ និងត្រីសាច់ គេឃើញ មានលក់ស្រូវ អង្ករ ក្រណាត់ល្អៗ មកពីស្រុកចិន ស្រុកសៀម និង ស្រុកថាម ព្រមទាំងថ្នាំសង្កូវគ្រប់មុខទៀតផង។ ដើម្បីមានសិទ្ធិលក់ដូរនៅ ទី នោះ គេត្រូវបង់ពន្ធជូនរាជការសិន ដែលយើងហៅថា ប៉ាតង់ ឬ ភាស៊ី។

ប៉ុន្តែខ្មែរសម័យអង្គរ ក៏បានធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយ បរទេសដែរ។ ទំនិញដែលយើងនាំចេញទៅក្រៅ ច្រើនតែជារបស់ដែល កើតពីធម្មជាតិ តែយើងពុំអាចបញ្ជាក់ឲ្យបានច្បាស់លាស់នោះទេ គ្រាន់តែអាចស្មានបានថា ប្រហែលជាមាននាំចេញនូវ ក្រវាញ ភ្លុកដំរី កុយ រមាស ជ័រុក្ខជាតិ ផ្សេងៗ និងស្លាបបក្សីល្អៗ។ល។ ទំនិញអស់នេះ គេ មិនលក់យកកម្រៃជាប្រាក់នោះទេ គឺគេដូរយកវត្ថុប្រណិតៗ និងប្លែកៗ ដែលខ្មែរយើងពុំមាន ឬមិនមានផលិតក្នុងស្រុក។ នៅសម័យនោះ ពួកឈ្មួញចិនបានមកជាវទិញសត្វដំរី សម្រាប់អូសទាញរបស់របរធ្ងន់ៗ និងបានទិញផលិតផលក្រមួនឃ្មុំ ដែលសម្បូរនៅប្រទេសយើង និងបាន ដាក់ក្នុងសំពៅនាំយកទៅស្រុកចិន។

ចំពោះវិស័យពាណិជ្ជកម្មនាំចូលមកពីប្រទេសវិញ យើងសង្កេត ឃើញថានៅសម័យអង្គរ ទំនិញនាំចូលពីស្រុកចិនមានដូចជា មាស ក្រណាត់ សំពត់ច្រើនពណ៌ សំណ ថាំងតែ ថូផ្កាលាបពណ៌ ទឹកប្រាក់ ក្រដាសសរសេរ ស្ពាន់ធ័រ បារត ជាតិអាកុល ឈើក្រអូប ថ្មដុត ឆ័ត្រ ឆ្នាំងដែក ថាសស្ពាន់ គុជ ក្រាស់ឈើ ម្ជុលជាដើម។[44] ពីប្រទេសសៀម យើងនាំចូលច្រើនតែក្រណាត់សំពត់ដូចជាមកពីប្រទេសចំប៉ាដែរ។ ប៉ុន្តែសំពត់ដែលមានសាច់ម៉ដ្ឋល្អនោះ ច្រើននាំមកពីប្រទេសនៅភូមិភាគ សមុទ្រខាងលិច ហើយមានតែព្រះរាជា ឬនាម៉ឺនធំៗទេ ដែលប្រើសំពត់ បែបនេះ។ តាមសិលាចារឹក ពិសេសសិលាចារិកប្រាសាទព្រះខ័ន និងប្រាសាទតាព្រហ្មបានបញ្ជាក់ថា ខ្មែរយើងនៅសម័យនោះមានប្រើប្រាស់ របស់របរទាំងនេះប្រាកដមែន។ ដូចនេះ ផលិតផលទាំងនោះ យើងអាច ចាត់ទុកថា ជាផលិតផលដែលនាំចូលពីប្រទេសចិន។

ដូច្នេះទំនាក់ទំនងផ្នែកពាណិជ្ជកម្មជាមួយបរទេស គឺជាកត្តាមួយ យ៉ាងសម្ខាន់ ដែលនាំអោយមានការប្រៀបធៀបគ្នា រវាងអរិយធម៌ក្នុង ស្រុក និងបរទេស។ ហើយបទពិសោធន៍ទាំងនេះ ធ្វើអោយប្រជារាស្ត្រ ខ្មែរស្វែងយល់បន្ថែមទៀត នូវបច្ចេកទេសថ្មី របៀបរស់នៅថ្មី និងរបៀប រិះគិត ច្នៃប្រឌិតថ្មីៗទៀត។

### ៣.៥.៣ ហិរញ្ញវត្ថុនិង ធនាគារ

នៅសម័យអង្គរ ពុំទាន់មានរូបិយវត្ថុនៅឡើយទេ គេធ្វើការចាយវាយ ជាមាស ប្រាក់ សំរិទ្ធ គុជ និងដោះដូរទំនិញ និងទំនិញនៅឡើយ។

នៅរាជធានីអង្គរមានឃ្លាំងធំៗ ដែលហៅថា ឃ្លាំងព្រះរាជទ្រព្យ សម្រាប់រក្សាទ្រព្យសម្បត្តិដែលបានមកពីការទារពន្ធដារ និងសួយសារ អាករដែលខេត្តសាមន្តរដ្ឋ និងប្រទេសរណប យកមកថ្វាយព្រះចក្រពត្តិធិរាជនៅយសោធបុរៈ។ ទ្រព្យខ្លះបានមកដោយសារអំណោយរបស់ ឈ្មួញធំៗដែលមកពីបរទេសជាដើម ខ្លះទៀត បានមកពីការរឹបអូសពី ប្រទេសសត្រូវ ដែលបានចាញ់ដោយសារចម្បាំង។

ព្រះរាជា ជាអ្នកចាត់ចែងប្រើប្រាស់ឃ្លាំងព្រះរាជ្យទ្រព្យ ក្នុងកិច្ចការផែនដីទាំងមូល ក្នុងការបង្កសង្គ្រាម ជួយជ្រោមជ្រែងសង្គមកិច្ច ឬ ឧបត្ថម្ភសាសនាអោយកាន់តែរុងរឿងជាដើម។ ព្រះបាទជ័យវរ្ម័នទី៧បាន ព្រះបរិច្ចាកនូវព្រះរាជទ្រព្យដ៏ច្រើនអនេកផ្គត់ផ្គង់ដល់ប្រាសាទ ដាក់ ទានដល់ល្មម ឬជនក្រីក្រ ចាស់ជរា ដើម្បីជួយសម្រាលទុក្ខដល់ជន ទាំងនោះ។ ការចំណាយសំខាន់ៗ ជាលក្ខណៈផលប្រយោជន៍ជាតិ ច្រើនតែចំណាយលើវិស័យយោធា ពេលស្រុកកើតសង្គ្រាម ពេលសាងសង់ ប្រាសាទធំៗសម្រាប់បុព្វហេតុសាសនា និងសុខមាលភាពរបស់ប្រជារាស្ត្រនៅពេលស្រុកសាន្តត្រាណ ដូចក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី៧ ជាដើម។

## ៣.៦. ការធ្លាក់ចុះសេដ្ឋកិច្ចសម័យអង្គរ

### ៣.៦.១ បញ្ហាសង្គ្រាមជាមួយបរទេស

ដូចដែលយើងបានដឹងហើយថា ពួកសៀមដែលចូលមកវាយប្រទេសខ្មែរយើង មិនមែនបំផ្លាញតែផ្ទះសម្បែង ឬប្លន់យកទ្រព្យសម្បត្តិ កំទេចផលដំណាំសម្លាប់ និងកៀរយកអ្នកស្រុកនោះទេ តែពួកនេះ បានបំផ្លាញដល់ឫសគល់នៃសេដ្ឋកិច្ចខ្មែរយើង តែម្តង គឺពួកសត្រូវទាំងនេះ បានបំផ្លាញទំនប់បារាយណ៍ និងបណ្តាញជលគតិអង្គរអោយខូចខ្ទេចខ្ទី ទាំងអស់។ ដោយសារហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនេះ បានខូចខាត ច្រើនពេក និង ច្រើនលើកច្រើនសារផង នោះ ម្យ៉ាងទៀត ដោយយើង រវល់តែធ្វើចម្បាំងទប់ទល់នឹងសត្រូវផង ធ្វើអោយយើងពុំមានលទ្ធភាពជួសជុល និងថែទាំបរិក្ខារនៃប្រព័ន្ធនយោបាយទឹកនេះបានឡើយ។

### ៣.៦.២ បញ្ហាបរិស្ថានធម្មជាតិ

លោក B.Groslier បានបង្ហាញថា អាកាសធាតុ និងស្ថានភាព ធរណីនៅតំបន់អង្គរ បានជំរុញអោយមានប្រតិកម្មមួយយ៉ាងខ្លាំងក្លា ធ្វើអោយប្រព័ន្ធជលសាស្ត្ររបស់ខ្មែរមិនអាចជួសជុលបាន ហើយដែល គ្មានអ្នកណាម្នាក់អាចស្មានទុកជាមុនបានឡើយ។ លោកពន្យល់ថា ការបង្ហូរទឹកលើដងស្ទឹងទាំងឡាយ ដែលពោពេញទៅដោយភក់ល្បាប់ និង មានជម្រាលយ៉ាងទាបបែបនេះ ពុំអាចគេចផុតពីគ្រោះថ្នាក់មួយ ដែលមានការគំរាមកំហែងជានិច្ចកាល គឺការកកស្ទះដោយល្បាប់នេះឯង។ ស្ទឹង

ទាំងឡាយត្រូវចាល់គាំងដោយសារដីល្បាប់ ដែលនាំអោយទឹកហូរ ខុសផ្លូវ ជាហេតុនាំអោយប្រឡាយបង្ហូរទឹកសម្រាប់ប្រើប្រាស់ក្នុងក្រុង និងប្រឡាយបង្ហូរផ្សេងៗទៀត ដែលតភ្ជាប់នឹងស្ទឹងទាំងនោះ ត្រូវគាំងដំណើរ។ លោកយកឧទាហរណ៍នៅសម្បូរព្រៃគុហ៍ ដែលខ្មែរយើងរស់នៅទីនោះ យ៉ាងហោចណាស់ក៏រហូតដល់សតវត្សទី១៣ ក៏ត្រូវសាបសូន្យ ព្រោះថា ស្ទឹងសែនដែលផ្តល់ទឹកអោយទីក្រុងនោះ ត្រូវចាល់ហើយបែរក្បាលមុខទឹកពង្វាងប្រហែល៣គ.ម ទៅទិសខាងកើត ដូច ដែលយើងបានឃើញសព្វថ្ងៃនេះ។

ម្យ៉ាងវិញទៀត ទោះជាស្ទឹងទាំងនោះមិនហូរចាក់ខុសផ្លូវដើមក៏ដោយ ក៏ដីល្បាប់ដែលស្ទឹងទាំងនោះបាននាំមក ត្រូវកកគាំងខាងក្នុង និងខាងក្រៅបារាយណ៍ ឬកកតាមប្រឡាយបង្ហូរចែកចាយផ្សេងៗ យូរៗទៅបារាយណ៍ និងប្រឡាយទាំងនោះ ត្រូវគោកអស់ ជាហេតុនាំអោយប្រើប្រាស់លែងកើតតែម្តង។

ច្បាស់ណាស់ថា ខ្មែរយើងកកាយបារកក់ល្បាប់ទាំងនោះចេញ ហើយជីកប្រឡាយថ្មី និងលើកបារាយណ៍ថែមទៀតផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយក៏មហន្តរាយនេះ ពុំអាចជៀសរួចដែរ ពីព្រោះបារាយណ៍ និងប្រឡាយថ្មីៗទាំងនោះ ត្រូវគាំងទៀតតាមលក្ខណៈដូច ដែលយើងបានបង្ហាញខាងលើ។ ពិសេសទៅទៀត នៅក្នុងរាជធានី យើងពុំអាចផ្លាស់ប្តូរគូរទឹកដែលហ៊ុំព័ទ្ធប្រាសាទទាំងឡាយ ឬស្រះទឹក បានទេ ហើយបារាយណ៍ថ្មីៗក៏គេអាចស្ថាបនាបានតែនៅខាងក្រៅ និងដែលស្ថិតនៅឆ្ងាយពីរាជធានីប៉ុណ្ណោះ។ ដូច្នេះនៅទីបំផុត ធម្មជាតិបាន បង្ខំអោយយើង បោះបង់ចោលរាជធានីចាស់ ហើយសាងរាជធានីថ្មី នៅតំបន់ផ្សេងទៀតតែម្តង។

នៅពេលដែលខ្មែរយើងពង្រីកដីស្រែបញ្ចូលទឹក ហើយសាងរាជធានីថ្មីៗនោះ ចាំបាច់ត្រូវតែកាប់ឆ្ការដើមឈើ ធ្វើអោយព្រៃតំបន់នោះ អន្តរាយអស់ជាច្រើន។ ដូច្នេះ ចំហាយក្តៅដែលដុតដោយព្រះអាទិត្យ បានភាយចេញពីដីត្រងោលគ្មានព្រៃឈើនោះ ធ្វើអោយពពកទឹកភ្លៀងនេះ រសាតឆ្ងាយទៅៗ ជាហេតុធ្វើអោយទឹកភ្លៀងថយចុះជាបន្តបន្ទាប់។ នេះជាបាតុភូតធម្មជាតិ ដែលសម្លាប់អរិយធម៌អង្គរដ៏រុងរឿង។

ម្យ៉ាងទៀតការបង្ហូរទឹកបញ្ចូលស្រែត្រូវការទឹកដែលនាំមកនូវ ល្បាប់មានជីជាតិ ដូចដែលទន្លេមេគង្គនាំមកតាមទឹកជំនន់រាល់ៗឆ្នាំនោះ ដែរ។ ប៉ុន្តែបារាយណ៍អង្គរទទួលតែទឹកភ្លៀងប៉ុណ្ណោះ ព្រោះទឹកស្ទឹងផ្សេងៗដែលនាំមកនោះ ត្រូវបានបាត់បង់បន្តិចម្តងៗ។ ហេតុដូចនេះ ហើយ ទើបខ្មែរយើងពង្រីកដីដាំដំណាំ កាន់តែឆ្ងាយទៅៗ ពីប្រភពទឹក ដែលហូរចាក់ដីស្រែចំការដែលគ្មានជីជាតិ។

ជាងនេះទៀត លោក B.P.Groslier បានរកឃើញនូវតួនាទីនៃការផ្លាស់ប្តូរប្រតិកម្ម រូប-គីមី នៃដីដាំដំណាំ។ នៅតំបន់អង្គរទាំងមូល នៅជម្រៅពុំជ្រៅប៉ុន្មាន គឺមានស្រទាប់ដីឥដ្ឋមួយស្រទាប់ ដែលពុំអាចអោយទឹកហូរធ្លោះទៅក្រោមបាន។ នៅសម័យបុរាណ តាមការអះអាង របស់បុរាណវិទូរូបនេះថា បារាយណ៍ និងស្រះទាំងឡាយ បានរក្សា អោយមានទឹកដក់មួយស្រទាប់នៅចន្លោះដីស្រទាប់លើ និងស្រទាប់ដីឥដ្ឋ។ ដីសើមផ្នែកក្រោមបែបនេះសម្រួលយ៉ាងច្រើន ដល់ការលូតលាស់នៃរុក្ខជាតិ។ ដីស្រែបញ្ចូលទឹកទាំងនោះ គឺអាចការពារដីស្រែកុំអោយខូច ហើយបន្តការហួតហែងនូវទឹកដែលនៅស្រទាប់

ក្រោមនេះ។ ប៉ុន្តែដោយហេតុថា បណ្តាញជលគតិខូចខាតទៅ ទឹកក្នុងស្រទាប់ក្រោមក៏ហូតរីង បន្សល់ទុកក្នុងដីនូវអុកស៊ីតដែក ដែលចេញពីស្រទាប់ដីឥដ្ឋផ្នែកខាង ក្រោម ហើយប្រតិកម្មនេះធ្វើអោយដីតំបន់អង្គរ ក្លាយជាដីថ្មបាយក្រៀម មិនអាចប្រកបដំណាំកសិកម្មបាន។ បញ្ហានេះ ជារឿងបច្ចេកទេសសុទ្ធសាធ ប៉ុន្តែចាំបាច់យើងត្រូវទទួលស្គាល់ថា កំហូចបរិស្ថានដីនេះ មានសភាពធ្ងន់ណាស់មកលើសេដ្ឋកិច្ច ដែលជាអាយុជីវិតនៃអរិយធម៌អង្គរ។

## ៣.៦.៣ ការធ្លាក់ចុះនៃផលិតផលកសិកម្ម

យើងដឹងហើយថា សេដ្ឋកិច្ចខ្មែរសម័យអង្គរជាសេដ្ឋកិច្ចដែល ផ្អែកលើកសិកម្មអតិផល (Agriculture Intensive) ទាំងស្រុង។ លោក B.PGroslier បានបញ្ជាក់ថា ខ្មែរសម័យអង្គរអាចធ្វើស្រែបានយ៉ាងហោច ណាស់ ២ ឬ ៣ដង ដោយការបញ្ចូលទឹកក្នុងស្រែ តាមបណ្តាញជលគតិដូចដែលយើងបានដឹងរួចមកហើយ។ ប៉ុន្តែដោយសារតែបារាយណ៍ បានខ្ទេចខ្ទាំដោយសង្គ្រាម និងខូចខាតដោយសារបាតុភូតធម្មជាតិ ព្រមទាំង ដីកសិកម្មសឹងក្លាយទៅជាថ្មបាយក្រៀមទៅហើយនោះ ដូច្នេះពុំអាចប្រកបរបរកសិកម្មអតិផលបានទៀតទេ។ ប្រជារាស្ត្រធ្វើស្រែបាន ដោយសារតែទឹកភ្លៀងក្នុងមួយឆ្នាំបានតែម្តងគត់ ហើយទិន្នផលក៏បានចុះថយ។

## ៣.៦.៤ គំហាយប្រជាជន

ដោយសារការធ្លាក់ចុះនៃផលិតផលកសិកម្ម ធ្វើអោយមានផល វិបាកយ៉ាងធ្ងន់ធ្ងរចំពោះបញ្ហាប្រជាសាស្ត្រ។ កង្វះស្រូវ អង្ករ បង្កើតជា គ្រោះទុរភិក្ស ហើយធ្វើអោយប្រជារាស្ត្រស្លាប់ជាច្រើននាក់។ មនុស្សដែលទទួលរបបអាហារមិនបានគ្រប់គ្រាន់ ពុំអាចទប់ទល់នឹងជម្ងឺតម្កាត់ផ្សេងៗ ដែលមកយាយីបាននោះទេ។ ដូច្នេះ បន្ថែមពីលើការស្លាប់ដោយ សារការអត់បាយ ប្រជាជនបានស្លាប់ដោយសារជម្ងឺផ្សេងៗថែមទៀត។

លោក P.Gouou បានានប្រសាសន៍ថា ជម្ងឺគ្រុនចាញ់បានរាតត្បាតយ៉ាងខ្លាំងក្លានៅតំបន់អង្គរ។ លោក B.PGroslier ក៏យល់ស្រប ចំពោះរឿងជម្ងឺគ្រុនចាញ់នេះដែរ។ យើងដឹងហើយថា មូសដែកគោលពុំ អាចរស់ក្នុងទឹកហូរបានទេ ប៉ុន្តែវាអាចរីករាលដាលគួរអោយខ្លាចនៅក្នុង ទឹកនឹងថ្កល់ នៃបណ្តាញជលសាស្ត្រដែលបានខូចខាតទាំងអស់នោះ។ លោកមានប្រសាសន៍បន្ថែមទៀតថា ចំពោះមតិដែលថាជម្ងឺគ្រុនចាញ់ជាកត្តាមួយ ដែលធ្វើអោយមានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ នៃអរិយធម៌អង្គរ នោះជាការត្រឹមត្រូវណាស់ដែរ ព្រោះគេសង្កេតឃើញថា មកដល់ បច្ចុប្បន្ននេះ ជម្ងឺដ៏ចង្រៃនេះ នៅតែបន្តការរាតត្បាតយ៉ាងខ្លាំងនៅឡើយ នៅតំបន់អង្គរ។ ដូច្នេះវិបត្តិប្រជាសាស្ត្រ បានកើតមានឡើងកាន់តែធ្ងន់ ធ្ងរថែមទៀត ដោយសារតែជម្ងឺគ្រុនចាញ់នេះឯង។

កត្តាមួយទៀត ដែលនាំអោយមានការថយចុះនូវចំនួនប្រជាជន ដែរនោះគឺបណ្តាមកពីបញ្ហាសង្គ្រាម។ ប្រវត្តិវិទូខ្លះមានលោក P.Devillers បានមានប្រសាសន៍ថា នៅសម័យអង្គរប្រជាជនបានរស់នៅប្រមូលផ្តុំគ្នាយ៉ាងកុះករ នៅភាគខាងជើងនៃបឹងទន្លេសាប។[47] ហើយម្យ៉ាងទៀត សង្គ្រាមដែលនាំ

អោយអរិយធម៌អង្គរដួលរលំ ភាគច្រើនកើតមានឡើង នៅតំបន់នោះឯង។ ដូច្នេះ ប្រាកដណាស់ថា ប្រជាជនមួយចំនួនត្រូវ បានស្លាប់ដោយសារសង្គ្រាម។ លោក ដឺរ តាក្វាន់ ក៏បានអះអាងដែរថា អ្នកស្រុកត្រូវបានស្លាប់យ៉ាងរង្គាល ព្រោះតែត្រូវបានគេកេណ្ឌយកទៅ ប្រយុទ្ធក្នុងសមរភូមិទាំងកម្លាំងបាយ ដោយពុំទាន់បានហាត់រៀនយុទ្ធ សាស្ត្រសង្គ្រាមអ្វីទាំងអស់។ ម្យ៉ាងវិញទៀត ពួកខ្មាំងសត្រូវ មិនត្រឹមតែសម្លាប់ប្រជារាស្ត្រខ្មែរនោះទេ ប៉ុន្តែពួកនេះបានចាប់និងកៀរប្រពៃ ជនយកធ្វើជាឈ្លើយទៀតផង។ បើតាមទិន្នន័យរបស់ប្រវត្តិវិទូខ្លះថា អ្នកស្រុកដែលសៀមកៀរយកទៅស្រុកវា មានចំនួនពី ៧០.០០០ នាក់ ទៅ ៩០.០០០នាក់។[48]

ក្នុងបុព្វហេតុផ្សេងទៀត ដែលនាំអោយមានតំហយប្រជាជននោះ គឺដោយសារការកសាងប្រាសាទ ដ៏សន្ធឹកសន្ធាប់នៅមុនសតវត្សទី ១៣ ដែលធ្វើអោយប្រជារាស្ត្រខ្មែរបានស្លាប់អស់ជាច្រើន។

លោក P.Gourou បានគណនាឃើញថា ប្រាសាទអង្គរវត្តតែមួយប៉ុណ្ណោះ គេត្រូវប្រើថ្មអស់ប្រហែលបីលានតោន ចុះចំណែកឯប្រាសាទបាយ័ន និងប្រាសាទឯទៀតៗទាំងអស់ជិតពីរពាន់ប្រាសាទ តើគេត្រូវ ប្រើថ្មអស់ប៉ុន្មានលានតោន ។ បើយើងពិចារណាមើលទៅ តើត្រូវប្រើមនុស្សប៉ុន្មាននាក់ ដើម្បីវាយបំបែកថ្មពីភ្នំគូលែន ហើយដឹកជញ្ជូនយក មកក្រុងអង្គរ ដែលចម្ងាយផ្លូវប្រមាណ ៣៦ គីឡូម៉ែត្រ ហើយត្រូវបន្តបពីលើគ្នា ដើម្បីអោយក្លាយទៅជាប្រាសាទ ព្រមទាំងជាប់ឆ្លាក់ថ្មីផងនោះ។

ដូច្នេះចំនួនមនុស្សដែលបានស្លាប់ដោយសារការសាងប្រាសាទក្នុង យុគសម័យអង្គរគឺមិនតិចជាងចំនួនមនុស្សដែលបានស្លាប់ដោយសារចម្បាំង (ជាលក្ខណៈចក្រពត្តិនិយមក្តី ឬចម្បាំងការពារស្រុកទេសក្តី)។

កត្តាទាំងអស់ខាងលើនេះហើយ ដែលធ្វើអោយមានតំហយចុះ នៃចំនួនប្រជាជននៅតំបន់អង្គរ ដែលពីដើមឡើយមានមនុស្សរស់នៅ យ៉ាងច្រើនសន្ធឹកសន្ធាប់។ ការស្រុតចុះនៃចំនួនប្រជាជននេះកាន់តែច្បាស់ទៅទៀត បើយើងលើកយកស្ថិតិនៃប្រវត្តិវិទូខ្លះមកពិនិត្យមើល។ លោក Louis Cheminais ក្នុងសៀវភៅ Le Cambodge ( ប្រទេសកម្ពុជា) ទំព័រ ១៤៨ បានសរសេរថា នៅគ.ស ១២០០ គឺនៅក្នុងរជ្ជកាល ព្រះបាទ ជ័យវរ្ម័ន ទី ៧ ប្រទេសកម្ពុជាមានប្រជាជនចំនួន ១០លាននាក់ ហើយ នៅគ.ស ១៨៦៣ គឺនៅពេលដែលប្រទេសខ្មែរយើងធ្លាក់ទៅក្នុងអាណាព្យាបាលបារាំង ប្រទេសកម្ពុជាយើងមានប្រជាជនតែចំនួន ៨សែននាក់ ប៉ុណ្ណោះ។ ដូច្នេះ យើងអាចធ្វើការប៉ាន់ប្រមាណបានថា មុនពេលដែល ខ្មែរយើង បោះបង់ក្រុងអង្គរចោល គឺតែពីរសតវត្សកន្លះ ក្រោយទីវង្គត់នៃ ព្រះបាទជ័យវរ្ម័នទី៧ ប្រទេសកម្ពុជាយើងត្រូវបាត់បង់ប្រជាជនយ៉ាង ហោចណាស់ក៏ ៤៥% ដែរ។

### ៣.៦.៥ តម្រូវការធនធានទ្រទ្រង់វិស័យសាសនា

កត្តាមួយទៀត ដែលធ្វើអោយសេដ្ឋកិច្ចខ្មែរយើងដួលរលំ ហើយ ដែលអ្នកនិពន្ធល្បីៗធ្លាប់បានលើកយកមកពិភាក្សា គឺបណ្តាលមកពី បុព្វហេតុនៃសេចក្តីត្រូវការច្រើនលើសលប់របស់សាសនា ផ្នែកសម្ភារៈ ប្រើប្រាស់ និងគ្រឿងដង្វាយនានាដែលមានតម្លៃខ្ពស់។

នៅសម័យនោះ ភូមិព្រះកាន់តែរីកធំឡើងៗជាលំដាប់ ហើយរីក ធំមែនទែននៅរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដែលសិលាចារឹកតាព្រហ្ម និងព្រះខ័នបានរៀបរាប់យ៉ាងច្បាស់អំពីរឿងនេះ ។

ចំពោះមនុស្សដែល ជាពលព្រះ បានបម្រើអោយកិច្ចការសាសនា គឺមានចំនួនច្រើនលើសលប់ ដូចជា ប្រជារាស្ត្រដែលបម្រើអោយកិច្ចការសាសនាសម្រាប់តែប្រាសាទតាព្រហ្មមួយប៉ុណ្ណោះ ត្រូវការមនុស្ស ៧៩.២៦៥នាក់។ រីឯមនុស្សដែលបម្រើអោយកិច្ចសាសនារបស់ប្រាសាទព្រះខ័ន គឺមានចំនួនរហូត ដល់ ៩៧.៨៤០នាក់ ឯណោះ។

ចុះសម្រាប់ប្រាសាទឯទៀត មានប្រាសាទបាយ័នជាដើម តើគេត្រូវកេណ្ឌមនុស្សប៉ុន្មាននាក់ សម្រាប់សេចក្តីត្រូវការខាងសាសនានោះ ព្រោះមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ទាំងអស់នេះ មួយភាគធំ ពុំមានមុខងារដែលបានផ្តល់ផលប្រយោជន៍ដល់ផ្នែកសេដ្ឋកិច្ចនោះឡើយ ពោលគឺពុំបានចូលរួមក្នុង ផ្នែកផលិតកម្មជា "សម្ភារៈ" នោះទេ ពីព្រោះកិច្ចការ មួយភាគធំនៃមនុស្សទាំងអស់នោះ គឺជាកិច្ចការ ដែលមិនបង្កើតផល។ គួរបញ្ជាក់ថា នៅសម័យកាលនោះ មនុស្ស និងធនធានផ្នែកសាសនា ពុំមានអ្នក ណាម្នាក់ហ៊ានប៉ះពាល់បានឡើយ ទោះបីជាព្រះរាជាក៏ដោយ ជាងនេះទៀត យើងឃើញថា សង្គម សាសនាបានស្រូបយកធនធាន ទ្រព្យសម្បត្តិសាធារណៈយ៉ាងច្រើនសន្ធឹកសន្ធាប់។ គ្រាន់តែសម្រាប់ ប្រាសាទតាព្រហ្មមួយប៉ុណ្ណោះ ក្នុងមួយឆ្នាំៗ គេត្រូវប្រើប្រាស់សំលៀក បំពាក់ផ្នែកសាសនា ចំនួន ៤០.០៩៥ សម្រាប់ក្រណាត់សំពត់មកពី ស្រុកចិនចំនួន ៦៦៧ គំនរ ហើយក្រណាត់សូត្រចំនួន ៥១២ គី។ ចំពោះប្រាសាទព្រះខ័នវិញ គេត្រូវចំណាយធនធានដែលយក ពីឃ្លាំងរាជទ្រព្យ សម្រាប់ការប្រើប្រាស់ក្នុងមួយឆ្នាំៗ នូវសំលៀកបំពាក់ អាទិទេព និងសំលៀកបំពាក់ផ្សេងៗទៀតចំនួន ៣.៧១២គូរ គ្រែដេក ១១៣ មុងធ្វើអំពីសូត្រប្រទេសចិន ចំនួន ៣២៣។ លោក G.Coedes បាន គណនាឃើញថា ពលព្រះរបស់ប្រាសាទព្រះខ័ន និងប្រាសាទផ្សេងៗទៀត ត្រូវទទួលទានស្រូវក្នុង មួយឆ្នាំៗចំនួន ៣៨,០០០ តោន។ ដូច្នេះ យើងឃើញថា សង្គមសាសនា ដូចដែលយើងបានរៀបរាប់ មកខាងលើនេះ មានលក្ខណៈជាសង្គមបរិភោគច្រើនជាងសង្គម សេដ្ឋកិច្ចផលិតកម្ម។

### ៣.៦.៦ ចំណាយខ្ពស់លើកិច្ចការសំណង់ប្រាសាទ និងដង្វាយព្រះ

តាមការស្រាវជ្រាវបង្ហាញថា ពីរាជ្យមួយទៅរាជ្យមួយទៀត ព្រះមហាក្សត្រខ្មែរ បានស្ថាបនា ប្រាសាទកាន់តែមានទំហំធំឡើងៗ និងមានចំនួនច្រើន។ កិច្ចការនេះបង្ហាញថា ព្រះរាជានាសម័យអង្គរ ហាក់ដូចជា មានការប្រកួតប្រជែងគ្នាយ៉ាងខ្លាំងក្លា ក្នុងការលើកតម្កើងកិត្យានុភាព និងព្រះកិត្តិនាម របស់ខ្លួន។ ប្រាសាទនិមួយៗដែលបានកសាងឡើង គឺ តម្រូវអោយប្រជារាស្ត្រខ្មែរ មានភារកិច្ច និងតួ នាទីផ្គត់ផ្គង់គ្រឿងប្រដាប់ប្រើប្រាស់ និងគ្រឿងដង្វាយនានា សម្រាប់បម្រើ និងថែរក្សាប្រាសាទទាំង នោះទៀត។ ជាក់ស្តែងប្រាសាទតាព្រហ្ម ដែលបានកសាងឡើង ក្នុងគ.ស ១១៨៦ ដោយ ព្រះបាទ ជ័យវរ្ម័នទី៧ ត្រូវមានភូមិចំណុះរហូត ដល់ ៣.១៤០ ភូមិ សម្រាប់ការផ្គត់ផ្គង់ប្រាសាទ និងមានមនុស្ស នៅថែទាំប្រមាណ ៧៩.៣៦៥ នាក់។

ដោយឡែក ចំពោះគ្រឿងប្រដាប់ប្រដាប្រើប្រាស់ជាដង្វាយមាន ចានមាស បានប្រាក់និមួយៗ ទម្ងន់ ៥តោន ត្បូងពេជ្រគ្រាប់ធំ ៣៥គ្រាប់ ត្បូងមុក្តា ៤០.៦២០ គ្រាប់ ត្បូងប្រណិត ៤.៥៤០ គ្រាប់ ផ្តិលមាសយ៉ាងធំ មួយ នាំងស្រុកចិន ៩៦៧ គ្រែធ្វើដោយសំពត់ល្អ ៥១២ ក្លស់ ៥២៣។ ចំពោះ

ស្បៀងអាហារសម្រាប់ផ្គត់ផ្គង់មាន អង្ករស្គរ ទឹកដោះគោ ប្រេង ទឹកឃ្មុំ ក្រមួន ខ្លឹមច័ន្ទ គ្រឿង ស្បង់ជីវរ។ នេះចំពោះប្រាសាទ តែមួយផង ចុះបើខ្មែរយើងមានប្រាសាទរហូតដល់ទៅរាប់ពាន់ តើតម្រូវការទាំង ផ្នែក ធនធានទ្រព្យសម្បត្តិសាធារណៈ និងឯកជន ក៏ដូចជាតម្រូវការធនធាន មនុស្សមានដល់ប៉ុន្មាន បញ្ហានេះ ប្រវត្តិវិទូ ជាច្រើននាក់បានចាត់ទុកថា ការកសាងប្រាសាទរួមនឹងចម្បាំងដ៏វែងឆ្ងាយ (ជាមួយយួនផង ចាមផៃ សៀមផង និងមនផង) ជាកត្តាមួយដែលរួមចំណែកដល់ការធ្លាក់ចុះនៃអរិយធម៌អង្គរ។

## ៣.៧. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ អំពីស្ថានភាពប្រវត្តិសេដ្ឋ កិច្ចនៃប្រទេសកម្ពុជា ក្នុងយុគសម័យអង្គររួចមក យើងអាចធ្វើសេចក្តី សន្និដ្ឋានបានដូចខាងក្រោមនេះ ៖

- តាមរយៈសិលាចារឹកបានបង្ហាញអំពី ការរីកលូតលាស់នៃវិស័យ កសិកម្មរបស់ខ្មែរយ៉ាងខ្លាំងក្លា ព្រោះគេមិនត្រឹមតែបានផលិតនូវផលិត ផលកសិកម្មច្រើនមុខនោះទេ ប៉ុន្តែគេថែមទាំងបានផលិតក្នុងបរិមាណ ច្រើនទៀតផង សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងការនាំចេញ។
- ចំពោះវិស័យសិប្បកម្ម និងឧស្សាហកម្មវិញ យើងពិនិត្យឃើញ ថា ខ្មែរយើងជំនាន់នោះ ដោយបានបន្តកេរ្តិ៍មរត៌កពីសម័យចេនឡាផងនោះ ធ្វើអោយសិប្បករខ្មែរសម័យអង្គរ រិតតែមានសមត្ថភាពខ្ពស់ជាង មុន ដោយបានផលិតនូវរបស់របរសិប្បកម្មជាច្រើនមុខទាំងរបស់របរ ប្រើប្រាស់ និងសិប្បកម្មចំណីអាហារ ក៏ដូចជា ឧស្សាហកម្មឥដ្ឋ ក្បឿង ភាជន៍ និងសូលោហៈធាតុ។
- ចំណែកឯ វិស័យពាណិជ្ជកម្មវិញ តាមរយៈសិលាចារិក និងកំណត់ត្រារបស់លោក ជីវ តាក្វាន់ ក៏បានបង្ហាញពីសកម្មភាពជួញដូរក្នុងស្រែកយ៉ាងមមាញឹក ជាមួយនឹងមុខទំញដែលផលិតក្នុងស្រុក និង ទំនិញនាំចូលពីបរទេសនានា។
- វិស័យគមនាគមន៍ ក៏មានសកម្មភាពយ៉ាងផុលផុសផងដែរ ជាពិសេសនូវក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័ន
  ទី ៧ ដោយព្រះអង្គបានស្ថាបនា ផ្លូវជាតិជាច្រើន ពីទីក្រុងអង្គរ ទៅតំបន់ឆ្ងាយៗ ព្រមទាំងបានសាងសង់សាលាជំណាក់ជាង ១០០កន្លែង បានសាងសង់មន្ទីរពេទ្យ ស្ពាន និងសាកលវិទ្យាល័យជាច្រើនដែលមិនអាចគណនាបាន។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អរិយធម៌អង្គរដ៏រុងរឿងគ្មានពីរនៅក្នុងលោក ក៏ត្រូវបានធ្លាក់ចុះមកវិញរហូតដល់ចំណុចសូន្យ ដែលតាមការស្រាវជ្រាវ បណ្តាលមកពីមូលហេតុច្រើនយ៉ាងដូចជា បញ្ហាសង្គ្រាម បញ្ហាធម្មជាតិ ការធ្លាក់ចុះនៃផលិតផលកសិកម្ម តំហយប្រជាជន តម្រូវការធនធានទ្រទ្រង់វិស័យសាសនា ចំណាយខ្ពស់លើកិច្ចការសំណង់ប្រាសាទ និងជង្វាយព្រះ។

# ជំពូកទី ៤
# សេដ្ឋកិច្ចប្រទេសកម្ពុជានាសម័យក្រោយអង្គរ ឆ្នាំ ១៤៣៤ - ១៨៦៣

## ៤.១. ស្ថានភាពនយោបាយ

### ៤.១.១ ស្ថានភាពនយោបាយសម័យចតុមុខ ឆ្នាំ ១៤៣៤-១៥២៨

ព្រឹត្តិការណ៍នយោបាយសំខាន់ៗរបស់ប្រទេសកម្ពុជានាសម័យចតុមុខ គឺទាក់ទងទៅនឹងការសម្រេចចិត្តផ្លាស់ប្តូររាជធានីពីក្រុងអង្គរនៅឆ្នាំ១៤៣១ ទៅកាន់តំបន់ស្រីសន្ធរ (ទួលបាសាន) ដែលជាមូលដ្ឋាន ចលនាតស៊ូរំដោះជាតិរបស់ព្រះបាទពញាយ៉ាត ហើយក្រោយមកប្តូរទៅកាន់ចតុមុខវិញ ក្នុងឆ្នាំ១៤៣៤ គឺស្ថិតនៅត្រង់រាជធានីភ្នំពេញបច្ចុប្បន្ននេះ។[51] ចំពោះការដែលព្រះអង្គបានសម្រេចព្រះទ័យចាកចោលក្រុងអង្គរ គឺបណ្តាមកពីមូលហេតុសំខាន់ៗដូចខាងក្រោមនេះ៖

- សង្គ្រាមឈ្លានពានពីសំណាក់ពួកសៀម ធ្វើអោយក្រុងអង្គររងនូវការខូចខាតយ៉ាងធំណំ ហើយពួកសៀមនៅតែបន្តប៉ុនប៉ងវាយលុកក្រុងអង្គរបន្ថែមទៀត ដែលធ្វើអោយប្រទេសខ្មែរពិបាកនឹងទប់ទល់។
- ចំនួនប្រជាជនបានថយចុះយ៉ាងច្រើន បណ្តាមកពីជីខ្វះជីជាតិ កង្វះទឹកធ្វើស្រែ ព្រោះប្រព័ន្ធធារាសាស្ត្រត្រូវបានខូចខាត និងរងនូវការកកស្ទះ។ ហើយប្រជាជនរាប់សែននាក់ត្រូវបានសៀមកៀរយកទៅធ្វើជាឈ្លើយសឹក ខ្លះទៀតក៏បានភៀសខ្លួនទៅរស់នៅតំបន់ឆ្ងាយៗធ្វើអោយដីស្រែចំការមួយភាគធំនៅជុំវិញតំបន់អង្គរត្រូវបានទុកចោលទំនេរ គ្មានសកម្មភាពផលិតកម្មកសិកម្ម។
- មានកិច្ចប្រជុំនយោបាយមួយ ក្រោមអធិបតីភាពរបស់ព្រះមហាក្សត្រខ្មែរ ព្រះបាទពញាយ៉ាត (ក្នុងរជ្ជកាលឆ្នាំ ១៤២១-១៤៦៧) នៅគ.ស១៤៣១ ដែលជាលទ្ធផលនៃកិច្ចប្រជុំនេះ បានបញ្ជាក់ច្បាស់ថា រាជាណាចក្រសៀមជាសត្រូវរបស់យើង ហើយអាណាខេត្តភាគខាងលិចនៅសល់ប្រជាជនតិចតួច ព្រោះសៀមបានចាប់ធ្វើជាឈ្លើយសឹក ជាងនេះទៀត រាជធានីអង្គរមានទំហំធំធេងណាស់ មានជញ្ជាំងរឹងមាំមែន ប៉ុន្តែសឹងតែគ្មានប្រជាជនរស់នៅនោះទេ ដូច្នេះគួរពិចារណា និងធ្វើការផ្លាស់ប្តូររាជធានីទៅស្រីសន្ធរវិញ។ ទីបំផុតនៅឆ្នាំ១៤៣១ ប្រទេសកម្ពុជាបាន ប្តូររាជធានីពីអង្គរមកស្រីសន្ធរ ក្រោយមកទៅចតុមុខនាឆ្នាំ១៤៣៤។

ព្រឹត្តិការណ៍នយោបាយរបស់ប្រទេសកម្ពុជាផ្សេងៗទៀត យើងសង្កេតឃើញថាច្រើនទាក់ទងទៅនឹងបញ្ហាសង្គ្រាមឥតឈប់ឈរ គឺសង្គ្រាមជាមួយបរទេសជិតខាង និងសង្គ្រាមជាមួយរាជ្យវង្សានុវង្សគ្នាឯង ដើម្បីដណ្តើមរាជបល្ល័ង្កគ្នា។ ដូចជាក្នុងរជ្ជកាល ព្រះបាទព្រះនាមស្រីរាជា (គ.ស ១៤៦៨-១៤៨៥) ជាបុត្ររបស់ព្រះបាទពញាយ៉ាត ដែលព្រះអង្គបានចេញច្បាំងដណ្តើមទឹកដីពីសៀមមកវិញ ក្នុងឆ្នាំ ១៤៧៥ ដោយទទួលបានជ័យជំនះ ពេលនោះក្មួយរបស់ព្រះអង្គ គឺ ព្រះបាទស្រីសុរិយោទ័យបានវាយដណ្តើមខេត្តភាគខាងកើត ហើយប្រកាសខ្លួនជាព្រះមហាក្សត្រគ្រប់គ្រងភាគខាងកើតនៅតំបន់ស្រីសន្ធរ(ទួលបាសាន) រីឯប្អូនប្រុសបង្កើត គឺព្រះបាទធម្មរាជា (ដែលជាបុត្រពៅរបស់ព្រះបាទពញាយ៉ាត) បានក្បត់នឹងព្រះរាមរបស់ខ្លួន បានឡើងសោយរាជ្យសម្បត្តិខ្លួនឯង ក្នុងពេលដែលបង

51 ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២, ទំព័រ ៤៧-៤៨

របស់ខ្លួនរវល់ជាប់ដៃប្រយុទ្ធនឹងពួកសៀម។ ខណៈនោះ ព្រះបាទធម្មរាជាបានធ្វើការសុំជំនួយពីស្តេចសៀមបានទ័ព ៣០.០០០ នាក់ ហើយប្រើល្បិចកលអោយបងបង្កើត (ព្រះបាទស្រីរាជា) និងក្មួយបង្កើត(ព្រះបាទស្រីសុរិយោទ័យ) ដើម្បីអោយចូលមកចរចាគ្នានៅចតុមុខ ហើយក៏បានចាប់ខ្លួនអ្នកទាំងពីរយកទៅស្រុកសៀម។

ព្រះបាទធម្មរាជា (បុត្រពៅរបស់ព្រះបាទពញាយ៉ាត) បានបន្តការសោយរាជ្យ តាំងពីពេលនោះមក ចាប់ពីឆ្នាំ១៤៨៥ ដល់ឆ្នាំ ១៥០៤ ដែលមានព្រះរាជបុត្រពីរនាក់ ជាអ្នកស្នងរាជ្យ គឺព្រះបាទស្រីសុគន្ធបទ ដែលសោយរាជ្យឆ្នាំ១៥០៤-១៥១២ ហើយព្រះអនុជ ព្រះអង្គចន្ទរាជាសោយរាជ្យនៅឆ្នាំ ១៥២៦-១៥៦៧។ ពេលនោះ ព្រះបាទស្រីសុគន្ធបទ បានផ្លាស់រាជធានីទៅស្រីសន្ធរវិញ ហើយអោយព្រះអនុជគ្រប់គ្រងនៅ ចតុមុខ(ភ្នំពេញ)។ ព្រឹត្តិការណ៍នយោបាយសំខាន់ៗនាពេលនោះ គឺទាក់ទងទៅនឹងសង្គ្រាមជាមួយស្តេចកន (ព្រះស្រីជេដ្ឋាធិរាជរាមាធិបតី) ដែលជាប្អូនថ្លៃរបស់ព្រះបាទស្រីសុគន្ធបទ ហើយស្តេចកន បានទទួលជ័យជំនះ និងបានធ្វើគុតព្រះបាទស្រីសុគន្ធបទនៅឆ្នាំ ១៥១២។

បន្ទាប់មក ព្រះអនុជរបស់ព្រះអង្គ គឺព្រះអង្គចន្ទរាជា ដែលជាព្រះមហាឧបរាជបានតស៊ូប្រឆាំងជាមួយស្តេចកនអស់រយៈពេល ១០ឆ្នាំ រហូតបានជ័យជំនះ និងបានធ្វើគុតស្តេចកននៅឆ្នាំ ១៥២៦។ ក្រោយមក ព្រះអង្គចន្ទរាជាបានគ្រប់គ្រងប្រទេសរហូតដល់ឆ្នាំ១៥៦៧។ ដែលគ្រានោះ រាជធានីរបស់ប្រទេសកម្ពុជា គឺស្ថិតនៅឯតំបន់បន្ទាយមានជ័យ (សព្វថ្ងៃស្រុកក្រគរត្រង់វាលសម្តេចយស ខេត្តពោធិសាត់)។ ក្រោយមកព្រះអង្គបានមានព្រះតម្រិះឃើញថា រាជធានីនេះគឺស្ថិតនៅជិតនឹងប្រទេសសៀមពេក ហេតុនេះគួរផ្លាស់ទៅកាន់តំបន់លង្វែកវិញ។

### ៤.១.២ ស្ថានភាពនយោបាយសម័យលង្វែក ឆ្នាំ ១៥២៩-១៥៩៥

ការស្ថាបនាទីក្រុង និងបន្ទាយលង្វែក គឺនៅឆ្នាំ ១៥២៩ ក្នុងរជ្ជកាល ព្រះបាទអង្គចន្ទរាជា។ បន្ទាយលង្វែកមានរាងចតុកោណកែង មានទទឹង ២គ.ម និងបណ្តោយ ៣គ.ម (៦គ.ម$^{២}$) មានកំពែងដី ទឹក និងរបងឫស្សីកម្រាស់ ១៦០ម ព័ទ្ធជុំវិញ ។ តាមទស្សនៈខ្លះទៀត បញ្ជាក់ថា បន្ទាយលង្វែក គឺ

ជាបន្ទាយដ៏ធំអស្ចារ្យណាស់ (សម្រាប់សម័យនោះ) សូម្បីតែសត្វសេះ ដែលមានកម្លាំងខ្លាំងក្លាយ៉ាងណាក៏ដោយ ក៏មិនអាចបោលអោយជុំបន្ទាយនេះបានឡើយ។[53]

នៅក្នុងបន្ទាយលង្វែកមានតម្កល់រូបបដិមា ព្រះគោ និងព្រះកែវ ដែលគេតែងតែគោរពបូជាទុកជាវត្ថុសក្តិសិទ្ធិ (តាមលក្ខណៈជារឿង ព្រេងក្នុងព្រះគោ ព្រះកែវនោះ មានរក្សាទុកនូវក្បួនតម្រាផ្សេងៗ ជាច្រើន)។

ចំណុចនេះ តំបន់បន្ទាយលង្វែកជាបន្ទាយមួយដែលមានលក្ខណៈជាបន្ទាយដ៏រឹងមាំមួយមានលក្ខណៈយុទ្ធសាស្ត្រសង្គ្រាមផង និងជាឃ្លាំងវប្បធម៌របស់ជាតិផង (បន្ទាប់ពីរាជធានីអង្គរ) និងជាតំបន់ សេដ្ឋកិច្ច ដែលមានផ្លូវគមនាគមន៍ខ្វាត់ខ្វែងទៀតផង។ ក្នុងការកសាងទី ក្រុងលង្វែក យើងសង្កេតឃើញថា ព្រះអង្គបានបញ្ជាអោយគេធ្វើរបងការពារបន្ទាយយ៉ាងរឹងមាំ ព្រោះព្រះអង្គបានឈ្វេងយល់ច្បាស់ថា ថ្ងៃណាមួយសៀមនឹងលើកទ័ពមកសងសឹកវិញ ព្រោះថ្មីៗនេះនៅពេល ដែលស្តេចសៀមចង់ដាក់អាណាព្យាបាលរបស់ខ្លួន មកលើប្រទេសខ្មែរ ព្រះអង្គបានធ្វើការវាយបក ធ្វើអោយសៀមបាក់ទ័ពរត់ត្រលប់ទៅវិញ ហើយកន្លែងដែលសៀមបាក់ទ័ពយ៉ាងដំណំនោះ គឺនៅខេត្តសៀមរាបសព្វថ្ងៃនេះ។ ជាងនេះទៀត សម័យកាលនោះ ប្រទេសកម្ពុជាក៏បានវាយដណ្តើមខេត្តចាន់បុរី ពីសៀមមកវិញ ព្រមទាំងវាយលុករហូតជិត ដល់ក្រុងអយុធ្យាទៀតផងនាឆ្នាំ ១៥៥៧។ លុះនៅឆ្នាំ ១៥៦៧ ព្រះអង្គ ចន្ទរាជា ក៏បានចូលទីវង្គត់ ។

ការឡើងគ្រងរាជ្យបន្ត គឺព្រះរាជបុត្រច្បងរបស់ព្រះអង្គចន្ទរាជា ព្រះនាម ព្រះបាទបរមរាជាទី១ ក្នុងរជ្ជកាលឆ្នាំ១៥៦៧ ដល់ឆ្នាំ១៥៧៩។ ក្នុងរជ្ជកាល ព្រះបាទបរមរាជាទី១ ប្រទេសកម្ពុជា ជាប្រទេសដែលមាន ឫទ្ធិអំណាចខ្លាំងក្លា រហូតដល់វាយដណ្តើមយកបាន ខេត្តនគររាជសីមា ពីប្រទេសសៀមមកវិញទៀតផង។ ខណៈនោះសៀមបានចុះទន់ខ្សោយ ហើយក៏បានបញ្ជូនរាជទូត មកសុំចងសម្ព័ន្ធមេត្រីភាព មិត្តភាព នាឆ្នាំ ១៥៧៦។ ព្រះមហាក្សត្រខ្មែរទ្រង់បានយល់ព្រម។ ប៉ុន្តែក្រោយពីព្រះអង្គ បានចូលទីវង្គត់ក្នុងឆ្នាំ១៥៧៩ សភាពការណ៍នយោបាយប្រទេសកម្ពុជា មានការផ្លាស់ប្តូរជាអវិជ្ជមាន។

ការឡើងសោយរាជ្យសម្បត្តិជាបន្តបន្ទាប់មកទៀត ក្នុងនោះមាន ព្រះរាជបុត្រព្រះនាម ព្រះសត្ថា ដែលជាបុត្រច្បងរបស់ព្រះបរមរាជាទី១ ក្នុងរជ្ជកាលឆ្នាំ១៥៧៩ ដល់ ១៥៨៦។ នៅឆ្នាំ ១៥៨០ ក្នុងនាមជា ប្រទេសបានចងមេត្រីភាពជាមួយគ្នា (នៅឆ្នាំ ១៥៧៦) ព្រះអង្គបានបញ្ជា អោយព្រះអនុជរបស់ព្រះអង្គព្រះនាមសុរិយោពណ៌ ទៅជួយសៀមច្បងជាមួយភូមា រហូតទទួលបានជ័យជំនះ

នាឆ្នាំ ១៥៨០។

ប៉ុន្តែអ្វីដែលគួរអោយឈឺចាប់នោះ គឺស្តេចរមិលគុណដោយរយៈពេល ៨ឆ្នាំ ក្រោយមក គឺក្នុងឆ្នាំ ១៥៨៨ ពួកសៀមបានវាយបកមកលើខ្មែរវិញ ដោយដណ្តើមយកខេត្តនគររាជសីមា បាត់ដំបងពោធិសាត់ បរិបូរណ៍ រហូតដល់ក្រុងលង្វែក (ក្នុងរយៈពេលតែ ៧ខែ ប៉ុណ្ណោះ)។ ប៉ុន្តែ មិនអាចវាយចូលក្នុងក្រុងលង្វែកបាន ព្រោះមានគុម្ពឫស្សីការពារក្រាស់ៗពេក។ ក្នុងឆ្នាំ ១៥៩៤ សៀមបានលើក

ទ័ពមកម្តងទៀត ហើយវាយយកក្រុងលង្វែកយ៉ាងងាយស្រួល ព្រោះរបងគុម្ពឫស្សីត្រូវបានប្រជាជនកាប់ឆ្ការស្ទើរគ្មានសល់ ដើម្បីយកប្រាក់ដួង។ រីឯព្រះសត្ថាទី១ និងព្រះបុត្រាព្រះនាម ព្រះបាទជ័យចេស្តាទី១ បានរត់ទៅរស់នៅឯព្រំដែនឡាវ (ក្នុងឆ្នាំ១៥៨៦-១៥៩៤) ហើយបានសុគតនៅទីនោះ។ ដោយឡែកព្រះអនុជព្រះបាទសុរិយោពណ៌ ដែលតស៊ូក្រាញនៅលនៅបន្ទាយលង្វែកត្រូវបានសៀមចាប់យកទៅឆ្នាំ១៥៩៥ ជាមួយនឹងគម្ពីរ ក្បួនខ្នាត ព្រះពុទ្ធបដិមា និងកងទ័ព ១០០.០០០ នាក់។[54]

ក្រោយមក ព្រះបាទរាមាជើងព្រៃ ឆ្នាំ១៥៩៥-១៥៩៦ បានវាយដណ្តើមយកបន្ទាយលង្វែកបានវិញ តែក្រោយមកត្រូវបានពួកទាហាន អេស្ប៉ាញ ធ្វើគុត (ពេលនោះមានពួកបរទេសចូលមករកស៊ី ផ្សព្វផ្សាយ សាសនាគ្រីស្ត មានដូចជា ពួកអេស្ប៉ាញ ព័រទុយហ្កាល់ ហូឡង់ ចិន ជប៉ុនជាដើម) ហើយមេទ័ពអេស្ប៉ាញបានជួយជ្រោមជ្រែងលូកដៃក្នុងនយោបាយខ្មែរ រហូតដល់បានតែងតាំងព្រះបាទពញាតន់ អោយឡើងសោយរាជ្យសម្បត្តិនៅឆ្នាំ ១៥៩៦ (ជាបុត្ររបស់ព្រះសត្ថាទី១)។ សរុបមក ស្ថានភាពនយោបាយរបស់ប្រទេសកម្ពុជានៅសម័យលង្វែក ក្នុងឆ្នាំ ១៥២៩ ដល់ឆ្នាំ ១៥៨៦ មានសភាពរឹងមាំ និងអនុភាពយោធាខ្លាំងក្លា ហើយមានលទ្ធភាពអាចវាយដណ្តើមយកខេត្តជាច្រើនពីសៀមមកវិញ ដែលធ្វើអោយពួកសៀមព្រួយបារម្ភ និងសុំចងមិត្តភាព។ ប៉ុន្តែនៅចុងក្រោយបង្អស់នៃសម័យលង្វែក ប្រទេសកម្ពុជាបានស្ថិតក្រោមអំណាចរបស់សៀមវិញ ហើយស្តេចសៀមក្លាយជាអ្នកកំណត់ បញ្ហារាជបល្ល័ង្ករបស់ខ្មែរ។ រីឯការផ្លាស់ប្តូររាជធានី ក៏បានផ្លាស់ប្តូរជាញឹកញាប់ ពីលង្វែកទៅស្រីសន្ធរ ពីស្រីសន្ធរទៅលង្វែក និងពីលង្វែក ទៅល្វាឯម (ខេត្តកណ្តាល) គឺអស់រយៈកាលជាង២០ឆ្នាំតែប៉ុណ្ណោះ។ រហូតដល់ឆ្នាំ១៦២០ មហាក្សត្រខ្មែរបានសម្រេចផ្ទេររាជធានីទៅឧដុង្គ ដោយព្រះបាទជ័យជេដ្ឋាទី២ ដែលបានសោយរាជ្យសម្បត្តិ នៅឆ្នាំ ១៦១៨ ដល់ឆ្នាំ ១៦២៥។

### ៤.១.៣ ស្ថានភាពនយោបាយសម័យឧដុង្គ ឆ្នាំ ១៦២០-១៨៦៣

ក្នុងសម័យឧដុង្គជាសម័យកាលមួយ ដែលប្រទេសកម្ពុជាស្ថិតក្នុងសភាពអាប់អួរ និងដ៏អាក្រក់បំផុត ជាងសម័យកាលណាៗទាំងអស់ ព្រោះប្រទេសខ្មែរដែលពីមុនៗមកធ្លាប់តែជាប្រទេសដែលមានឥទ្ធិពលលើគេឯង មានអំណាចមហាសាល ជាចក្រភពដ៏ល្បីរន្ទឺ មានអនុភាពយោធា សេដ្ឋកិច្ចនយោបាយខ្លាំងក្លា ប៉ុន្តែពេលនេះគឺក្លាយជាប្រទេសដ៏ទន់ខ្សោយរណបគេពឹងពាក់គេ បណ្តោយអោយប្រទេសជិតខាងធ្វើបាបកេងប្រវ័ញ្ច គៀបសង្កត់ ទន្ទ្រានយកទឹកដីធ្វើបាបប្រជារាស្ត្រតាមតែទំនើងចិត្ត។

យោងតាមបំរាប់ប្រវត្តិសាស្ត្រ ព្រឹត្តិការណ៍នយោបាយសំខាន់ៗនាសម័យឧដុង្គ គឺទាក់ទងទៅនឹងបញ្ហាជម្លោះផ្ទៃក្នុងរវាងរាជ្យវង្សានុវង្ស ដើម្បីដណ្តើមអំណាចគ្នាតែប៉ុណ្ណោះ និងការពឹងពាក់ប្រទេសជិតខាង អោយជួយដោះស្រាយបញ្ហារាជបល្ល័ង្ករៀងៗខ្លួន ដែលធ្វើអោយបរទេស ជិតខាងស្គាល់ច្បាស់អំពីសារជាតិ និងចរិតស្តេចខ្មែរ ហើយឆ្លៀតឱកាសនេះកេងយកចំណេញទឹកដី។

តាំងពីដំបូងមកម្ល៉េះ វិបត្តិរាជបល្ល័ង្ក ដែលបានកើតមានឡើងនា សម័យឧដុង្គ ក្នុងសម័យកាលស្តេចជ័យជេដ្ឋាទី ២ ដែលបានគ្រងរាជ្យសម្បត្តិ នាឆ្នាំ១៦១៨-១៦២៥ នៅក្រុងឧដុង្គ ដែលស្តេចអង្គ

នេះបាន រៀបអភិសេកជាមួយបុត្រីស្តេចយួនព្រះនាមអង្គចូវ គឺដើម្បីពឹងពាក់កម្លាំងទ័ពយួនជាដៃគូរក្នុងការវាយទប់ទល់នឹងទ័ពសៀម និងដើម្បីការពាររាជ្យបល្ល័ង្គ។ ដោយឡែកឆ្នាំ១៦៣៥ ពេលដែលព្រះអង្គទងបានចូលទីវង្គត់ បើតាមច្បាប់អ្នកស្នងរាជ្យសម្បត្តិ គឺប្អូនប្រុស (ព្រះបាទ ពញាចន្ទ) ប៉ុន្តែឪពុកមា (ព្រះបាទឧទ័យរាជា) បានបង្វែរទៅថ្វាយរាជ្យបុត្ររបស់ខ្លួន គឺ ព្រះអង្គបទុមរាជាអង្គនន់ ទៅវិញ អោយសោយរាជ្យ បាន ៣ឆ្នាំ គឺនៅឆ្នាំ ១៦៣៥ ដល់ឆ្នាំ ១៦៣៨។ ធ្វើអោយកើតមានអំពើសងសឹកគ្នាបាន កើតមានឡើងរហូតដល់ព្រះបាទពញាចន្ទបានធ្វើគុតព្រះបទុមរាជាអង្គនន់ (បងប្អូនជីដូនមួយ) ហើយឡើងសោរាជ្យសម្បត្តិ នៅឆ្នាំ ១៦៣៥-១៦៥៣ ជាដើម។ បន្តមកទៀត ក្នុងរជ្ជកាលព្រះបរមរាជា អង្គសូរ ឆ្នាំ១៦៥៦ ដល់ ១៦៧០ ត្រូវបានកូនប្រសារ (និងត្រូវជាក្មួយបង្កើតផងនោះ) ព្រះនាម បទុមរាជាស្រីជ័យជេដ្ឋា ធ្វើគុតបិតាក្មេករួចឡើងសោយរាជ្យនៅឆ្នាំ ១៦៧០-១៦៧២ បន្ទាប់មកត្រូវបានបក្សម្ខាង ទៀតធ្វើគុតដណ្តើមរាជ្យសម្បត្តិមកវិញ។

នៅសម័យឧដុង្គ មហាក្សត្រទាំងអស់មានគំនិតដូចគ្នា គឺខ្លាចតែម្យ៉ាងប៉ុណ្ណោះគឺ ការបាត់បងរាជ្យបល្ល័ង្គ ម្លោះហើយរាជ្យសម្បត្តិត្រូវផ្ទេរ ពីឪពុកទៅកូន ពីកូនទៅឪពុក ដោយពុំសម្លឹងលើសមត្ថភាពអ្វីឡើយ។ ព្រះមហាក្សត្រខ្លះសោយរាជ្យ ៤ដង (ព្រះជ័យចេស្តាអង្គសូរសោយ រាជ្យក្នុងរជ្ជកាល ឆ្នាំ ១៦៧៥-១៦៩៥, ១៦៩៦-១៧០០, ១៧០១-១៧០២, ១៧០៤-១៧០៦) រីឯ ព្រះរាជ្យបុត្រព្រះអង្គ គឺ ព្រះស្រីធម្មរាជា មានព្រះជន្មតែ ១៣ព្រះវស្សាប៉ុណ្ណោះ បានសោយរាជ្យសម្បត្តិ ៣ដង ក្នុងរជ្ជកាលឆ្នាំ ១៧០២-១៧០៤, ១៧០៦-១៧១៤, ១៧៣៨-១៧៤៧។ រីឯព្រះកែវហ្វាអង្គអឹម សោយរាជ្យសម្បត្តិ ៣ដង ក្នុងរជ្ជកាលឆ្នាំ ១៧០០ ដល់ ១៧០១, ១៧១៤-១៧២២, ១៧២៩ បាន ៧ខែ ចំណែកឯព្រះអង្គសត្ថាអង្គជី សោយរាជ្យសម្បត្តិបាន ២ដង គឺឆ្នាំ១៧២២-១៧២៩ និងឆ្នាំ ១៧២៩-១៧៣៧។[56]

ប៉ុន្តែសម័យឧដុង្គ ក៏មានព្រះមហាក្សត្រខ្មែរខ្លះ មានគំនិតល្អ ចង់ផ្សះផ្សារបង្រួបបង្រួមជាតិដែរ ដូចជាព្រះនារាយណ៍រាជាទី២ (ឆ្នាំ១៧៥៨-១៧៧៥) ក្រោយពីច្បាំងគ្នាជាមួយព្រះរាមាធិបតីអង្គនន់អស់ កាលដ៏យូរមក ក៏សម្រេចបញ្ចប់សង្គ្រាមសុំយាងព្រះអង្គនន់ចូលមក ថ្វាយរាជ្យសម្បត្តិជំនួសខ្លួន។ ចំពោះព្រះអង្គទទួលព្រះរាជកិច្ចជាស្តេចឧភយោរាជវិញ។

តាមការស្រាវជ្រាវបង្ហាញថា ចាប់ពីឆ្នាំ១៧៧៥-១៨៦៣ រយៈពេលជិតមួយសតវត្សនេះ នយោបាយរបស់ប្រទេសកម្ពុជាកាន់តែមានសភាពដុនដាបទៅៗ បាត់បង់ម្ចាស់ការលើខ្លួនឯងទាំងស្រុង ស្ថានភាព នយោបាយស្ថិតក្នុងសភាពទ័លច្រក ឆ្ពោះទៅរកការរលាយបាត់បង់ទឹក ដីទៅ ហើយបើយើងពិនិត្យមើលក្នុងរជ្ជកាល ព្រះរាមាធិបតីអង្គនន់ (១៧៧៥-១៧៩១) ក្សត្រអង្គនេះ បានពឹងពាក់សៀមទាំងស្រុងដើម្បីជួយជ្រោមជ្រែងឡើងសោយរាជ្យសម្បត្តិ ហើយបានកែនប្រជាជនខ្មែរប្រុសៗអោយទៅបម្រើសៀម ជួយជីកព្រែក ជីកស្រះ ដុតឥដ្ឋនៅវត្តស្រះកែវ ឯស្រីៗបុកអង្ករផ្តល់អោយសៀម អ្នកណាប្រឆាំងត្រូវប្រហារជីវិត។ ក្នុងរជ្ជកាលព្រះអង្គចន្ទ (១៨០៦-១៨៣៤) បានទៅពឹងពាក់យួនអោយ ទប់ទល់នឹងព្រះអង្គស្ងួន (ជាព្រះអនុជ) ដែលមានសៀមគាំទ្រ។ ម្យ៉ាងទៀត ព្រះ

រាមរបស់ ព្រះអង្គចន្ទ ព្រះនាមអង្គអិម និងព្រះបាទអង្គឌួងបានយាងទៅគង់នៅឯប្រទេសសៀម ដែលព្រះចៅសៀម បានតែងតាំងព្រះអង្គអិម ជាឧបរាជ និងព្រះអង្គស្ងួន ជាឧភយោរាជ។ ទង្វើនេះបានធ្វើអោយព្រះអង្គចន្ទរឹតតែមិនសព្វព្រះហឫទ័យ ព្រោះស្តេចសៀមពុំបានសួរ យោបល់ពីព្រះអង្គក្នុងការតែងតាំងនេះ ជាហេតុធ្វើអោយព្រះអង្គចន្ទកាន់តែងាកខិតជិតទៅរកជំនួយពីស្តេចយួន ទាំងផ្នែកស្មារតី ទាំងផ្នែកនយោបាយ និងយោធា។

ក្នុងស្ថានភាពខាងលើនេះ ព្រះអង្គចន្ទដោយមានជំនួយពីកងទ័ពយួន បានសោយរាជ្យសម្បត្តិរហូតដល់ឆ្នាំ ១៨៣៤។ ក្នុងឱកាសនោះ ធ្វើអោយយួនមានលទ្ធភាពទន្ទ្រានទឹកដីខ្មែរ កែនប្រជារាស្ត្រខ្មែរអោយ ជីកព្រែកវិញតេ ប្រវែង ៥៣ គ.ម តភ្ជាប់ពីមាត់ជ្រកទៅ សមុទ្រនៅតំបន់ពាម ព្រែកមួយទៀត ប្រវែង ១៣,៧ គ.ម តភ្ជាប់ពីទន្លេធំទៅទន្លេ បាសាក់ និងបានធ្វើបាបប្រជារាស្ត្រខ្មែរអោយធ្វើការគ្មានឈប់សម្រាក ស៊ីបាយទៅហើមពោះ ផឹកទឹកមានក្លិនលាមក និងបើកទឹកបង្ហូរចូល ព្រែកបណ្តាលអោយ

56 ដ-ង-ដ

កម្មករកំណែនខ្មែរលិចលង់ស្ទើរស្លាប់ទាំងអស់ ប៉ុន្តែព្រះបាទអង្គចន្ទឥតមានការតវ៉ាអ្វីសោះឡើយ។[57]

បន្ទាប់ពីព្រះអង្គចន្ទចូលទីវង្គត់នៅឆ្នាំ១៨៣៤ យើងពិនិត្យឃើញថាក្រោមកិច្ចជ្រោមជ្រែងរបស់ព្រះចៅយួន មិញម៉ាង ក៏បានលើកបុត្រីព្រះអង្គចន្ទ ព្រះនាមអង្គម៉ី អោយឡើងគ្រងរាជ្យសម្បត្តិបន្តពីព្រះបិតា ក្នុងព្រះជន្ម ២០ ព្រះវស្សា(ក្នុងរជ្ជកាល ឆ្នាំ ១៨៣៤-១៨៤០) ហើយបុត្រីមួយអង្គទៀតព្រះនាមអង្គពៅ ធ្វើជាឧបរាជិនី។ គួរបញ្ជាក់ថា ការតែងតាំងក្សត្រីអង្គម៉ីនេះ គឺមានឋានៈត្រឹមតែស្មើនឹងចៅហ្វាយ ខេត្តប៉ុណ្ណោះ ព្រោះពេលនោះប្រទេសខ្មែរត្រូវបានទុកជាប្រទេសសាមន្ត រដ្ឋរបស់យួន (តាំងពីសម័យកាលព្រះបិតាព្រះនាងមកម្ល៉េះ គឺព្រះអង្គចន្ទ) ដោយ ៣ឆ្នាំម្តង បានយកសួយសាអាករ ទៅថ្វាយព្រះចៅយួន ។ ក្នុងឋានៈប្រទេសខ្មែរជាសាមន្តរដ្ឋ និងគ្មានស្តេចជាក្សត្រាជាអ្នកគ្រងរាជ្យសម្បត្តិនោះ ធ្វើអោយប្រទេសយួនមានឥទ្ធិពលខ្លាំងក្លាមកកិច្ច ការនយោបាយរបស់ប្រទេសខ្មែរ ហើយនាម៉ឺនមន្ត្រីរបស់យួន ជាច្រើននាក់ បានជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ខ្មែរខ្លាំងឡើងៗ ដែលធ្វើអោយប្រជារាស្ត្រខ្មែរងើបឡើងបះបោរប្រឆាំង។ ចំណែកក្សត្រីអង្គមីត្រូវ ក្រុងវ៉េ យកទៅឃុំទុកជាមួយស្តេចខ្មែរជាច្រើនអង្គទៀតនៅឆ្នាំ ១៨៤១។ ក្រោយមកក្នុងឆ្នាំ ១៨៤៤ និង១៨៤៥ សង្គ្រាមរវាងយួន និងសៀមនៅលើទឹលដីខ្មែរ បានកើតមានឡើងយ៉ាងសាហាវបំផុតក្នុងទ្រង់ទ្រាយធំ ដែលមិនធ្លាប់មានពីមុនមក ហើយទាំងសងខាងបានរងការខូចខាត យ៉ាងដំណំដូចគ្នា។ យួន និងសៀមបានច្បាំងគ្នានៅស្រុកខ្មែរក្នុងបំណង ដណ្តើមអំណាចអោយស្តេចខ្មែរដែលពឹងពាក់ខ្លួន អោយបានសោយរាជ្យរៀងៗខ្លួន ដែលបង្កភាពងាយស្រួលអោយពួកគេ លេបយកទឹកដីខ្មែរតែប៉ុណ្ណោះ។

លុះដល់ឆ្នាំ ១៨៤៦ យួន និងសៀម សម្រេចផ្លាស់ប្តូរនយោបាយរបស់ខ្លួន ដោយបញ្ឈប់ការធ្វើសង្គ្រាមនៅក្នុងប្រទេសខ្មែរ។ ពួកគេប្តូរឈ្លើយសង្គ្រាមគ្នា សៀមរុះរើបន្ទាយយួន យួនរុះរើបន្ទាយសៀម។ នៅឆ្នាំ១៩៤៧ ក្រុងបាងកក និងក្រុងវ៉េ បានឯកភាពគ្នាយល់ព្រមអោយ ព្រះអង្គឌួងរៀបពិធី

អភិសេកឡើងគ្រងរាជ្យសម្បត្តិនៅក្រុងឧដុង្គ រហូតដល់ឆ្នាំ ១៨៦០។ ក្នុងរជ្ជកាល ព្រះអង្គឌួង គឺបានទទួលស្គាល់សៀម និងយួនជាអាណាព្យាបាល។ គួរបញ្ជាក់ថា នៅសម័យនោះប្រទេសខ្មែរ ភាគច្រើនទទួលឥទ្ធិពលពីសៀមច្រើនជាង ព្រោះយួនរវល់ទប់ទល់នឹងការបះបោររបស់កសិករ និងធ្វើសង្គ្រាមជាមួយបារាំងហេតុនេះធ្វើអោយខេត្តខ្មែរជាច្រើនត្រូវបានសៀមទន្ទ្រានយក (ដូចជាខេត្តបាត់ដំបង សៀមរាប ស្ទឹងត្រែង ទន្លេរពៅ មូលព្រៃ ជាដើម)។ ចំពោះភាគីយួនវិញ តែងតែធ្វើទុក្ខបុកម្នេញ ក្នុងបំណងបណ្តេញជនជាតិខ្មែរទាំងអស់អោយចាកចេញ ពីទឹកដីកម្ពុជាក្រោមដូចដែលយួនបានធ្វើចំពោះប្រទេសចម្ប៉ាដែរ។ ដូច្នេះ ការសោយរាជ្យរបស់ស្តេចខ្មែរ គ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ ពុំមានសិទ្ធិគ្រប់គ្រងអ្វីឡើយហើយកិច្ចការប្រទេសជាតិទាំងឡាយរបស់ខ្មែរស្រេចតែលើស្តេចសៀមជាអ្នកចាត់ចែង។[58]

ហេតុការណ៍ទាំងអស់នេះ បានធ្វើអោយព្រះអង្គឌួង មានព្រះទ័យឈឺចាប់ ហើយសម្រេចសុំជំនួយពីប្រទេសមហាអំណាចអឺរ៉ុបដោយ ចាប់ផ្តើមធ្វើទំនាក់ទំនងសម្ងាត់ជាមួយកុងស៊ុលបារាំងនៅសឹង្ហបុរី ។

[57] ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២, ទំព័រ ២០១–២០២

## ៤.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច

តាមការស្រាវជ្រាវបង្ហាញថា ទាក់ទងទៅនឹងទស្សនៈនៃការកសាងសេដ្ឋកិច្ច-សង្គម នៅសម័យក្រោយអង្គរ ជាទូទៅគឺពាក់ព័ន្ធទៅនឹងការជ្រើសរើសទីតាំងភូមិសាស្ត្រសម្រាប់សំណង់ស្ថាបត្យកម្មរាជធានីរបស់ខ្មែរដែលមានភាពអំណោយផលទាំងផ្នែកប្រព័ន្ធធារាសាស្ត្រ ដើម្បីបម្រើអោយវិស័យកសិកម្មផលិតកម្មផង និងជាទីតាំងដែលមានលក្ខណៈជាយុទ្ធសាស្ត្រសង្គ្រាម ការពារពីខ្មាំងសត្រូវផង និងជាកំពង់ផែជាតិ និងអន្តរជាតិផង។ ទន្ទឹមនឹងនោះដែរ យោងតាមលក្ខណៈទំនៀមទំលាប់ និងវប្បធម៌របស់ខ្មែរយើង ដែលបានចាក់ឫសគល់ចូលជ្រៅទៅក្នុងជំនឿផ្សេងៗ ដូច្នេះសម្រាប់ការសាងសង់សំណង់រាជធានីម្តងៗ ព្រះរាជាខ្មែរតែងតែគន់គូរត្រាស់បង្គាប់អោយហោរាក្នុងរាជវាំង និងមន្ត្រីសំខាន់ៗមួយចំនួនទៀត ទៅពិនិត្យមើលទីតាំងភូមិសាស្ត្រអោយស្របតាមក្បួនតម្រាសព្វគ្រប់ និងមានជ័យភូមិល្អ ទើបសម្រេចកំណត់យក ទីតាំងនោះធ្វើជារាជធានី (ដូចជាករណីព្រះបាទពញាយ៉ាត, ដែលបានបង្គាប់អោយ សម្តេចចៅពញាកែ និងឧកញ៉ាហោរាធិបតីខៀវ និងមន្ត្រីរាជវាំងជាច្រើននាក់ទៀត អោយទៅពិនិត្យមើលទីតាំងចតុមុខ លុះពិនិត្យឃើញថា អ្វីៗទាំងអស់មានតាមក្បួនតម្រាត្រឹមត្រូវហើយ ទើបព្រះអង្គសម្រេចព្រះហរទ័យ កំណត់យកតំបន់ចតុមុខធ្វើ ជារាជធានី)។

### ៤.២.១ សម័យចតុមុខ (១៤៣៤-១៥២៥)

នៅសម័យចតុមុខ (១៤៣៤-១៥២៥) ព្រះបាទពញាយ៉ាត បានត្រាស់បង្គាប់អោយចៅហ្វាយស្រុកសំរោងទង ចៅពញាតេជោ កែនរាស្ត្រលើកដីចាក់បំពេញតំបន់ជុំវិញវត្តភ្នំ និងក្នុងរាជវាំង ដើម្បីអោយតំបន់នេះរាបស្មើល្អ រហូតដល់មាត់ទន្លេ ដែលប្រជាជននិយមហៅថា កំពង់រាប។ សម្រាប់ជាកិច្ច

ការការពាររាជវាំង ព្រះរាជាទ្រង់បញ្ជាអោយប្រជារាស្ត្រជីកប្រឡាយ និងលើកដីជាកំផែងការពារបន្ទាយព័ទ្ធជុំវិញ រាជធានី។ ចំពោះការជីកដីមកប្រើប្រាស់នេះ បង្កើតបានជាបឹងដ៏ធំមួយដែលមានជម្រៅជ្រៅ ហៅថា បឹងតេជោ (ត្រង់មុំផ្សារថ្មីសព្វថ្ងៃ) ដែលបឹង នេះផ្ទុកទឹកបានយ៉ាងច្រើន ទុកសម្រាប់ប្រើប្រាស់ទូទៅក្នុងរាជធានី។ បន្ទាប់មកទៀត ព្រះអង្គបានត្រាស់បង្គាប់អោយចៅហ្វាយស្រុកបាទី ឧក ញ៉ាវង្សាអនុជិតផ្លុង ជីកព្រែកបង្ហូរទឹកទន្លេ ចូលទៅក្នុងបារាយមួយនៅ ក្នុងរាជធានីសម្រាប់ទុកទឹកប្រើប្រាស់ទូទៅ ដល់ប្រជារាស្ត្រទាំងអស់គ្នា បារាយនេះ គេហៅថា ព្រែកឧកញ៉ាផ្លុង។ តាមការស្រាវជ្រាវបង្ហាញថា កាលពីដើមព្រែកនេះ ស្ថិតនៅតាមបណ្តោយសួនច្បារមុខស្ថានីយ៍នៃអយស្ម័យាន រហូតដល់ផ្សារចាស់សព្វថ្ងៃ គឺស្របនឹង វិថីឧកញ៉ាផ្លុង។

ចំពោះការជីកព្រែកភាគខាងត្បូងវិញមាន ព្រែកតាកែវ ខាងលិច មានព្រែកអូគរ និងខាងជើងមាន ព្រែកពោងពាយឬ ព្រែកចិនដំដែក (ព្រោះនៅទីកន្លែងនេះមានជនជាតិចិនរកស៊ីរបរដំដែក) ដែលតភ្ជាប់គ្នាព័ទ្ធជុំវិញរាជធានីចតុមុខ តភ្ជាប់មកដៃទន្លេសាប និងទន្លេបាសាក់។ ចំពោះមុខងារដ៏សំខាន់បំផុតរបស់ព្រែកដ៏វែងទាំងនេះ គឺជារបងការពារ ទីក្រុងផង និងពិសេសទៅទៀតធ្វើជាអាងស្តុកទឹកគ្រប់រដូវកាលសម្រាប់ ប្រជារាស្ត្រខ្មែរ ក្នុងការប្រកបរបរកសិកម្ម ធ្វើស្រែចំការនៅភាគខាងលិច នៃរាជធានីចតុមុខ ដែលជាដង្ហើមសេដ្ឋកិច្ចដ៏សំខាន់។

នៅតំបន់ចតុមុខនេះ ក៏មានបឹងធម្មជាតិជាច្រើនទៀតដែរ ដូចជា បឹងកក់ បឹងកេងកង បឹងទំពន់ និងបឹងផ្សេងៗទៀតដែលមានមុខងារជួយ ដល់ការអភិវឌ្ឍវិស័យកសិកម្មក្នុងសម័យកាលនោះ។

### ៤.២.២ សម័យលង្វែក (១៥២៩-១៥៩៥)

ចំពោះនៅសម័យលង្វែកវិញ យើងពិនិត្យឃើញថា ព្រះបាទអង្គចន្ទរាជា បានសព្វព្រះរាជហឫទ័យផ្លាស់ប្តូរទីតាំងរាជធានីពីបន្ទាយមានជ័យ (តំបន់វាលសម្តេចយស ស្រុកក្រគរ ខេត្តពោធិសាត់) ទៅលង្វែកវិញ ក៏ព្រោះតែដោយសារហេតុផលនយោបាយ និងសង្គ្រាមក៏ពិតមែន (ព្រោះស្ថិតនៅជិតប្រទេសសៀមពេកដែលងាយនឹងធ្វើការឈ្លានពានហើយមានទីតាំងល្អ ដែលមានលក្ខណៈយុទ្ធសាស្ត្រសម្រាប់ការធ្វើសឹកសង្គ្រាម និងងាយស្រួលការពារខ្លួនពីសត្រូវ) ក៏ប៉ុន្តែមូលហេតុសំខាន់ មួយទៀតដែលនាំអោយមានការជ្រើសរើសយកភូមិសាស្ត្រតំបន់លង្វែក ក៏ដោយសារនៅតំបន់នោះមាន ដៃទន្លេសាប សម្បូរដោយបឹង ដូចជា បឹងប្រាំង បឹងដុត និងបឹងផ្សេងទៀត ព្រមទាំងមានព្រែកជាច្រើនដែលហូរខ្វាត់ខ្វែងសរសៃឈាមជុំវិញតំបន់នោះ បង្កភាពងាយស្រួលក្នុងការប្រកបរបរកសិកម្ម និងចរាចរតាមផ្លូវទឹករបស់ប្រជារាស្ត្រ និយាយជារួមតំបន់ដែលមានលក្ខណៈអំណោយផលផ្នែកសេដ្ឋកិច្ចយ៉ាងប្រពៃ។

## ៤.២.៣ សម័យឧដុង្គមានជ័យ (១៦២០-១៨៦៣)

រីឯនៅសម័យឧដុង្គមានជ័យវិញ ចំពោះការកំណត់យកភូមិសាស្ត្រតំបន់នេះ ធ្វើជារាជធានីនោះក៏មានលក្ខណៈវិនិច្ឆ័យប្រកបដោយ សុទិដ្ឋិនិយម មិនខុសពីតំបន់ទាំងឡាយ នាសម័យកាលមុនៗនោះដែរ។ បើយើងសិក្សាស្រាវជ្រាវទៅលើការរៀបចំស្ថាបត្យកម្មក្រុងឧដុង្គ យើងឃើញថា ភូមិសាស្ត្រនេះជាតំបន់ទីទួលខ្ពស់មិនលិចទឹក មានកូនភ្នំក្បែរ គ្នា (ភ្នំឧដុង្គ ភ្នំប្រសិទ្ធ) ដែលជាតំបន់យុទ្ធសាស្ត្រផ្នែកសង្គ្រាមងាយស្រួលប្រយុទ្ធ និងការពារខ្លួន។ ចំពោះទស្សនៈសេដ្ឋកិច្ចវិញ វារឹតតែមានវិសាលភាពគ្រប់ដណ្តប់ធំធេងទៅទៀត ព្រោះថាជាតំបន់ភូមិសាស្ត្រដែលសម្បូរទៅដោយប្រភពទឹកមិនចេះរីងស្ងួតនៅរដូវប្រាំងដូចជា បឹង ខ្យង (ភាគខាងជើង) បឹងទំនប់កប់ស្រូវ (ភាគខាងត្បូង) តភ្ជាប់ដល់ បឹង បឹងភាគខាងកើតនៃភ្នំឧដុង្គ រីឯខាងលិចជាវាលទំនាប ពោងពាយដោយមានលក្ខណៈភូមិសាស្ត្របែបនេះហើយទើបញ៉ាំងអោយប្រជារាស្ត្រអាចមានលទ្ធភាពធ្វើកសិកម្មបានគ្រប់ប្រភេទ និងគ្រប់រដូវកាល។ ក្រៅពីដំណាំស្រូវ និងបន្លែគ្រប់មុខ គឺមានមច្ឆាជាតិ ដែលទាំងអស់នេះជាប្រភពស្បៀងអាហារគ្រប់គ្រាងសម្រាប់ទ្រទ្រង់សេដ្ឋកិច្ច សង្គម និងគាំទ្រដល់ការធ្វើសឹកសង្គ្រាមនៅតំបន់នេះៗ បើយើងពិនិត្យទៅលើ កត្តា ពាក់ព័ន្ធ ផ្សេងៗទៀតយើងឃើញថា រាជធានីឧដុង្គនៅជិតដៃទន្លេសាប និងកំពង់ផែ (បច្ចុប្បន្នកំពង់ចម្លងព្រែកក្តាម) ដែលជាកំពង់ផែប្រវត្តិសាស្ត្រ និងជាចំណុចប្រសព្វមុខគ្នានៃខេត្តជាច្រើន (នាសម័យនោះ) បង្កភាពងាយស្រួលដល់ការធ្វើចរាចរចំពោះទំនាក់ទំនងសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ហើយអាចចល័តទ័ពតាមនាវាចរ ទប់ទល់នឹងសង្គ្រាមផ្លូវ ទឹកផងដែរ។

ឧទាហរណ៍ ចាប់តាំងពីសតវត្សទី ១៧មក ខ្មែរយើងបានចាប់ ផ្តើមទំនាក់ទំនងជាមួយពួកអឺរ៉ុបជាពិសេស ពួកហូឡង់ អេស្ប៉ាញ និងព័រទុយហ្គាល់នេះឯងលើវិស័យសាសនា ការទូត និងជំនួញ ដូចជា ករណីថ្ងៃទី ២២ សីហា ១៦២០ ពួកហូឡង់បានចូលតាមពាមទន្លេមេគង្គ ក្រោមហើយមកដល់ទីក្រុងភ្នំពេញ លុះ៣ឆ្នាំក្រោយមក ពួកគេបានបើកគ្រឹះស្ថានជំនួញជាលើកដំបូងនៅកំពង់ហ្លួង ក្បែររាជធានីឧដុង្គ។

ក្រៅពីទស្សនៈខាងលើនេះ យើងក៏អាចធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់បន្ថែមទៀតថា រាជធានីឧដុង្គ ស្ថិតនៅចន្លោះ អតីតរាជធានី ចាស់ៗពីរ គឺ រាជធានីចតុមុខ និងរាជធានីតំបន់លង្វែក ដែលទីនោះមាន ប្រជារាស្ត្រ បាននិងនៅតែកំពុងរស់នៅយ៉ាងច្រើនកុះករ និងប្រកបរបរ កសិកម្ម សិប្បកម្ម និងសេវាកម្ម ដែលបង្កភាពងាយស្រួលក្នុងទំនាក់ ទំនងសេដ្ឋកិច្ច និងសង្គម ពោលគឺបង្កើតអោយមានការដោះដូរផលិតផល ការប្រាស្រ័យទាក់ទងរបស់ប្រជារាស្ត្រ ហើយស្ថានភាពបែបនេះ ក៏អាចជួយទ្រទ្រង់បន្ថែមទៀតលើវិស័យស្បៀងអាហារ និងប្រមូលទ័ព។

សរុបសេចក្តីមក បើពិនិត្យទៅលើទស្សនៈទាននៃការអភិវឌ្ឍ សេដ្ឋកិច្ច-សង្គម ក្នុងសម័យក្រោយអង្គរ យើងអាចកំណត់បានថា ការជ្រើសរើសយកភូមិសាស្ត្រទាំងបី ធ្វើជាសំណង់ស្ថាបត្យកម្មរាជធានីនេះគឺពិតជាការជ្រើសរើសដ៏ត្រឹមត្រូវមួយ ព្រោះបានឈរលើមូលដ្ឋានជាយុទ្ធសាស្ត្រដែលមានពីរលក្ខណៈវិនិច្ឆ័យពោលគឺ ការពារ និងការអភិវឌ្ឍសេដ្ឋកិច្ច។ ជាងនេះទៀត បើយើងពិនិត្យមើលតែទៅលើទស្សនវិស័យ នៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិវិញ ចំពោះការកំណត់យកទីតាំងទាំងនោះសម្រាប់

ការសាងសង់រាជធានី ក៏ព្រោះតែតំបន់នោះមានគុណសម្បត្តិ គ្រប់គ្រាន់ផ្នែកសេដ្ឋកិច្ចជាអាទិភាព ដូចខាងក្រោមនេះ ៖

- ជាតំបន់ដែលមានលក្ខណៈអំណោយផលពីធម្មជាតិ ផ្នែកប្រព័ន្ធ ធារាសាស្ត្រ ដែលងាយស្រួលក្នុងការកែលម្អបន្ថែម បម្រើអោយវិស័យផលិតកម្មកសិកម្មទាំងរដូវប្រាំង និងរដូវវស្សា។
- មានបណ្តាញផ្លូវទឹកខ្វាត់ខ្វែង ជាសរសៃឈាម ងាយស្រួលក្នុងការធ្វើចរាចរតាមផ្លូវទឹក ជាពិសេស ការដឹកជញ្ជូនផលិតផល និងអ្នកដំណើរ។
- ជាតំបន់កំពង់ផែ ដែលជាចំណុចប្រមូលផ្តុំនៃការធ្វើទំនាក់ទំនងសេដ្ឋកិច្ច និងជាឃ្លាំងស្តុកទំនិញដែលត្រូវបម្រុងទុកនាំចេញ នាំចូល។ ជាតំបន់ដែលមានមូលដ្ឋានភូមិស្រុក ដែលមានប្រជាជនរស់នៅយូរអង្វែង ជាមូលដ្ឋានគ្រឹះនៃវប្បធម៌ សង្គម និងសេដ្ឋកិច្ច។
- ការរៀបចំទីក្រុង គួបផ្សំ និងធារាសាស្ត្រនេះ គឺជាការទាក់ទាញ អោយប្រជាកសិករចូលមករស់នៅច្រើនមានន័យថា ជាប្រភពថាមពល នៃធនធានមនុស្ស (ជាកម្លាំងទ័ព និងផលិតកម្មសេដ្ឋកិច្ចគ្រប់ប្រភេទ)។
- បើវិភាគតាមនិយមន័យសេដ្ឋកិច្ចវិញ (វិស័យកសិកម្ម វិស័យសិប្បកម្ម វិស័យសេវាកម្ម) គឺអាចបញ្ជាក់ពីទំនាក់ទំនងសេដ្ឋកិច្ចដ៏សកម្មបំផុត ព្រោះជាមូលដ្ឋាននៃការទំនាក់ទំនងដោះដូរទីផ្សារគ្មានទីបញ្ចប់ និងជាគ្រឹះនៃកំណើនសេដ្ឋកិច្ច-សង្គមតែម្តង។

## ៤.៣. ស្ថានភាពវិស័យសេដ្ឋកិច្ច-សង្គម

### ៤.៣.១ វិស័យកសិកម្ម

យោងតាមឯកសារស្រាវជ្រាវនៅសម័យនោះ យើងឃើញថា ដើម្បីទ្រទ្រង់វិស័យសេដ្ឋកិច្ចជាតិ ព្រះរាជាតែងតែជ្រើសរើសទីតាំងភូមិ សាស្ត្រសម្រាប់ធ្វើជាសំណង់រាជធានី ដែលមានលក្ខណៈអំណោយផល ពីធម្មជាតិ(ពិសេសផ្នែកធារាសាស្ត្រ) និងបានកសាងហេដ្ឋារចនាសម្ព័ន្ធ រូបវន្តសាធារណៈ ដែលក្នុងកិច្ចការនេះ ទ្រង់បានកែនប្រជារាស្ត្រអោយ បំពេញការងារដូចជាការលើកផ្លូវថ្នល់ សង់ស្ពាន ជីកព្រែកជីកអូរ លើកទំនប់ទឹក ជីកប្រឡាយទឹក។ល។ សម្រាប់ជាផលប្រយោជន៍រួមផង ក៏ដូចជាសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មបានគ្រប់រដូវកាលផង និងកិច្ចការខ្លះទៀត សម្រាប់បម្រើផលប្រយោជន៍របស់ព្រះរាជា។ នៅក្នុងរជ្ជកាលព្រះបាទចៅពញាយ៉ាត ព្រះអង្គបានយកព្រះទ័យទុកដាក់យ៉ាងខ្លាំងទៅលើកិច្ចការនយោបាយទឹក ដើម្បីអោយប្រជារាស្ត្រមានលទ្ធភាព ប្រកបរបរកសិកម្មដែលជាវិស័យដ៏សំខាន់បំផុតរបស់សេដ្ឋកិច្ចជាតិ។

សកម្មភាពសេដ្ឋកិច្ចដ៏សំខាន់ៗបំផុត នៅសម័យចតុមុខ មិនខុសពីសម័យមុនៗ គឺទាក់ទងនឹងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវដែលជាដំណាំមូលដ្ឋានរបស់ខ្មែរយើងតាំងពីយូរលង់ណាស់មកហើយ។ ក្រៅពីនោះ គឺមានដំណាំរួមផ្សំ ជាបន្លែ និងផ្លែឈើ ដែលមានដាំដុះស្ទើរគ្រប់ ភូមិស្រុក។

ដូចគ្នានេះដែរនៅសម័យលង្វែក ព្រះរាជាបានមានព្រះតម្រិះផិតដល់ណាស់ចំពោះបញ្ហាដីធ្លីអោយប្រជារាស្រ្តសម្រាប់ធ្វើស្រែចំការ ដូចជាក្នុងរជ្ជកាលព្រះអង្គចន្ទរាជា ទ្រង់បានបញ្ជាអោយប្រជាពលរដ្ឋកាប់ឆ្ការព្រៃ ដើម្បីពង្រីកទំហំផ្ទៃដីធ្វើកិច្ចការកសិកម្មអោយបានធំទូលំទូលាយ។

ចំពោះកាលៈទេសៈផលិតស្រូវ និងប្រមូលផលយើងឃើញថា ក្នុងគ្រាដែលមានសង្រ្គាមក្នុងស្រុកម្តងៗ នៅរដូវវស្សា ភាគីជម្លោះទាំង សងខាងតែងតែចរចាគ្នា ស្រុះស្រួលផ្អាកសង្រ្គាម រំសាយទ័ពអោយពល ទាហានត្រឡប់ទៅកាន់លំនៅដ្ឋានរៀងៗខ្លួន ដើម្បីប្រកបកិច្ចការស្រែចំការ។ ទាំងអស់នេះគឺបង្ហាញអំពីការចេះគោរពគ្នា និងសេចក្តីថ្លៃថ្នូរ នៃអ្នកនយោបាយនាម័យកាលនោះ។ ព្រោះដូនតារបស់យើងយល់ ច្បាស់ពីការធ្វើសឹកសង្រ្គាម ដែលត្រូវតែមានការគាំទ្រ ពីស្បៀងអាហារ ដែលសំខាន់ជាងអ្វីៗទាំងអស់ ហេតុនេះហើយទើបមានពាក្យចាស់បានពោលថា "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ"។

គួរបញ្ជាក់ថា តាមការពិតដីស្រែរបស់ខ្មែរយើងមានជីជាតិល្អណាស់ ដែលក្នុង១ហិកតា អាចផលិតស្រូវបាន ពី ២ ទៅ ៣តោន ជាង។ ប៉ុន្តែ ដោយសារតែបញ្ហាសង្រ្គាម និងការបង់ពន្ធដារធ្ងន់ធ្ងរពេក (១/១០នៃផលដំណាំស្រូវ)បានធ្វើអោយកសិករខ្មែរ ជួបប្រទះនូវភាព ក្រីក្រតោកយ៉ាកស្ទើរគ្រប់សម័យកាល។

### ៤.៣.២ វិស័យសិប្បកម្ម និងឧស្សាហកម្ម

វិស័យសិប្បកម្ម និងឧស្សាហកម្ម គឺជាវិស័យសេដ្ឋកិច្ចមួយដ៏ សំខាន់ដែលបម្រើអោយសេចក្តីត្រូវការប្រើប្រាស់ក្នុងស្រុក និងការនាំចេញ។ នៅសម័យចតុមុខ ប្រជារាស្រ្តខ្មែរ ចេះធ្វើសិប្បកម្មកែច្នៃត្រីស្រស់អោយទៅជាត្រីងៀត និងផលិតទឹកត្រីសម្រាប់ការនាំចេញ និងការប្រើប្រាស់ក្នុងស្រុក។

ចំណែកពួកជនជាតិចិន ដែលរស់នៅរាជធានីចតុមុខ បានប្រកបមុខរបរជាជាងដំដែក។ ជារួមវិស័យសិប្បកម្ម កែច្នៃត្រីងៀត ទឹកត្រី ធ្វើរទេះគោ ចាន ឆ្នាំង ភាជន៍ ទូកសម្រាប់ប្រើប្រាស់ ទូកប្រណាំង ធ្វើកាំជ្រួច (ពេលបុណ្យ អុំទូក មានការដុតកាំជ្រួចផងដែរ) ត្រូវបានប្រជារាស្ត្រខ្មែរប្រកាន់យក នូវគ្រប់សម័យកាលទាំងអស់។[63] រីឯសិប្បកម្មត្បាញក្រមា ត្បាញសំពត់ សូត្រ មានឆ្លាក់រូបបដិមាពីលោហៈ និងពីឈើមានតម្បាញសម្ភារៈពី ឫស្សី បិតស្រោ ក៏មានការរីកចម្រើននៅគ្រប់សម័យកាលទាំងអស់ដែរ។ វិស័យឧស្សាហកម្មដែលសំខាន់ជាងគេក្នុងសម័យ ព្រះអង្គចន្ទរាជា គឺទាក់តងទៅនឹងឧស្សាហកម្មស្លដែក ដោយមានការទំនុកបំរុងយ៉ាងខ្លាំង ពីព្រះរាជា ជាពិសេស ផលិតកម្ម ដំដែកធ្វើជាឧបករណ៍ប្រើប្រាស់ផ្សេងៗ និងធ្វើជាគ្រឿងសព្វាវុធ។ នៅសម័យឧដុង្គ ដោយសារប្រទេសជួបប្រទះនូវសង្រ្គាម ដូច្នេះសិប្បកម្មសម័យនោះមានការរីកចម្រើនតែខាងផ្នែកស្លូរំសេវ។[64]

### ៤.៣.៣ វិស័យពាណិជ្ជកម្ម

តាំងពីសម័យចតុមុខមកម្ល៉េះ ដោយសារតែមានវត្តមាននៃជនបរទេសដូចជា យួន និងចិន ធ្វើអោយវិស័យពាណិជ្ជកម្មក្នុងស្រុកមាន ដំណើរការជាប្រក្រតីនៅគ្រប់ទីកន្លែងនៃទីប្រជុំជន។ នៅតាមទីផ្សារសំខាន់ៗ ជាពិសេសតំបន់កំពង់ផែអន្តរជាតិចតុមុខនេះតែម្តង មានសកម្មភាពលក់ដូរទំនិញ

ផលិតផលក្នុងស្រុកគ្រប់យ៉ាងរួមមានស្រូវ អង្ករ គ្រឿងទេស ភ្លុកដំរី ស្បែកសត្វ ជ័រកំញាណ លក្ខ័ និង គ្រឿងមាស ប្រាក់។ល។ យោងតាមឯកសារលោក Van Wuystoft គ.ស ១ ៦៤១ ដែលធ្វើដំណើរ តាមទន្លេមេគង្គឆ្លងកាត់តាមទីក្រុងភ្នំពេញ ដើម្បីស្វែងរកទិញទំនិញផ្សេងៗ លោកបានអះអាងថា នៅ ទីក្រុងភ្នំពេញអាចរកទិញអ្វីៗដែលគេមានតម្រូវការ ដូចជា ជ័រកំញ៉ាណ និងល័ក្ខ។

បើតាមពត៌មានដែលឈ្មួញហូឡង់ម្នាក់ឈ្មោះ Indijx បានអះអាងថា នៅសម័យនោះគេអាច ទិញនៅភ្នំពេញជារៀងរាល់ឆ្នាំដូចជា ស្បែកប្រើស រហូតដល់ ១០០.០០០ ផ្ទាំង/ឆ្នាំៗ។ ទិន្នន័យនេះ បញ្ជាក់ថា នៅស្រុកខ្មែរសម័យនោះសម្បូរសត្វព្រៃណាស់ ហើយក៏មានប្រជារាស្ត្រជាច្រើន ដែលប្រកប របរបាញ់សត្វជាអាហារ និងមានការលក់ដូរស្បែកសត្វផងដែរ។ ម្យ៉ាងវិញទៀតតាមឯកសាររបស់លោក Aymonier បានបញ្ជាក់ថា តាំងពីនៅគ.ស ១៤២១ម្ល៉េះ ព្រះបាទពញាយ៉ាត បានបញ្ជូនអង្គរាជទូតទៅ ស្រុកចិន ដោយនាំយកទៅជាមួយ នូវសត្វដំរី ភ្លុកដំរី ល័ក្ខ ម្រេច ក្រមួន កុយរមាស គ្រឿងក្រអូប និង សត្វក្ងោក។ល។ ទៅថ្វាយជូនព្រះចៅក្រុងចិន។

ចំពោះវិស័យពាណិជ្ជកម្មអន្តរជាតិវិញ នៅសម័យលង្វែក ក្នុងរជ្ជកាលព្រះសត្ថាទី១ (១៥៧៦-១៥៨៦) ទ្រង់បានឈ្វេងយល់ថា បន្ទាប់ពីមកដល់នៃពួកបព្វជិតអឺរ៉ុបពេលនោះសកម្មភាពជំនួញជួញ ដូរនឹងកើតមានឡើង ហេតុនេះទើបមានការអំពាវនាវអោយអង្គការធំៗ ខាងសាសនាគ្រឹះបញ្ជូនអ្នក ផ្សាយសាសនាពួកព័ទុយហ្គាល់ និងអេស្ប៉ាញមកកាន់ប្រទេសកម្ពុជា ដោយជួយឧបត្ថម្ភនូវទាយ្យទាន ជាស្បៀងអាហារដល់ពួកបព្វជិតទាំងអស់នោះថែមទៀតផង។

នៅសតវត្សទី១៧ ប្រទេសខ្មែរ បានបន្តទំនាក់ទំនងជាថ្មី ជាមួយពួកអឺរ៉ុប គឺ ពួកហូឡង់ នៅ ក្នុងវិស័យសកម្មភាពជំនួញតែប៉ុណ្ណោះ។ ចាប់ពីឆ្នាំ ១៥៩៥ ពួកហូឡង់ បានបើកគ្រឹះស្ថានជំនួញនៅ ប្រទេសឥណ្ឌា កោះសិរីលង្ការ ប្រទេស សៀម និងជប៉ុន។ ហើយទើបតែនៅគ.ស ១៦២០ នាសម័យ ឧដុង្គ (ក្នុងរជ្ជកាល ព្រះបាទជ័យជេដ្ឋាទី២ គ.ស ១៦១៨-១៦២៨) ដែលពួកហូឡង់បានចូលមក បង្កើតគ្រឹះស្ថានជំនួញនៅប្រទេសខ្មែរដំបូងគឺថ្ងៃទី ២២ សីហា ១៦២០ ដោយឈ្មួញ Jacob Graerman (នៅកំពង់ហ្លួងជិត រាជធានីឧដុង្គ)។ នៅគ.ស ១៦២៣ គណៈបេសកកម្មការទូតយួន ក៏ បានបញ្ជូនមកស្រុកខ្មែរយើង (រាជធានីឧដុង្គ) ដើម្បីសូមព្រះរាជាខ្មែរ អនុញ្ញាតអោយបើកគ្រឹះស្ថាន ជំនួញ នៅភាគខាងត្បូងប្រទេសខ្មែរ គឺនៅ តំបន់ព្រៃនគរ បច្ចុប្បន្ន (ពីមុនហៅថា កំពង់ក្របី) ព្រម ទាំងសុំសិទ្ធិកាន់ កាប់ក្រសួងគយនៅតំបន់នោះផង។ តាមឯកសារខ្លះទៀតបញ្ជាក់ថា ការបង្កើត គ្រឹះស្ថានជំនួញដំបូងនៅប្រទេសខ្មែរ គឺនៅគ.ស ១៦៣៧ ទៅវិញ ដោយក្រុមហ៊ុនឥណ្ឌាខាងកើត នៅ តំបន់ភាគខាងជើង ពញាឮបន្តិច។

នៅឆ្នាំ ១៦៣៨ មានតំណាងគ្រឹះស្ថានជំនួញថ្មីពីរនាក់ទៀតរបស់ហូឡង់ បានបញ្ជូនមកស្រុក ខ្មែរ (មកឧដុង្គ) គឺលោក Paulus Croes និង Johannes Van der Hagen ដើម្បីជំនួសលោក Jan Galen។ ពួកនេះបានធ្វើអោយព្រះអង្គ (ព្រះបាទអង្គនន់រាជា) យកព្រះទ័យទុកដាក់យ៉ាងខ្លាំងក្លា ក្នុង ទំនាក់ទំនងពាណិជ្ជកម្ម និងហិរញ្ញវត្ថុ។ នៅគ.ស ១៦៣៨ ដដែលនេះ ព្រះអង្គបានអោយក្រុមហ៊ុន ជំនួញឥណ្ឌាខាងកើត លក់ ជ័រមក្សណ៍ លក់ខ្លឹមច័ន្ទ និងភ្លុកដំរី ព្រមទាំងអោយផ្តល់ប្រាក់កម្ចីទៅអោយ

ក្រុមហ៊ុនហូឡង់ទៀតផង។[70] នៅឆ្នាំ ១៦៤១ តាមឯកសារ របស់លោក Van Wuystoff បញ្ជាក់ថា ទំនិញនាំចូលមកលក់នៅទីផ្សារ ចតុមុខរួមមាន ជាគ្រឿងអលង្ការ ទំនិញជាស្ពាន់ ចាន កែវព័រសឺឡែន កម្រាលព្រំ ជាដើម។

ក្រោយឆ្នាំ១៦៤១-១៦៥៩ ក្នុងរជ្ជកាល ព្រះបាទចៅពញាចន្ទ (ព្រះរាជបុត្រពៅរបស់ព្រះជ័យជេដ្ឋាទី ២ ជាមួយបុត្រីស្តេចយួន ព្រះនាង អង្គចូវ) យើងឃើញថា ទំនាក់ទំនងពាណិជ្ជកម្មរបស់ពួកហូឡង់បាន ធ្លាក់ចុះយ៉ាងខ្លាំង ដូចជានៅខែកញ្ញា ឆ្នាំ ១៦៤៣ ឧប្បត្តិហេតុមួយបាន កើតឡើង ក្នុងរឿងតវ៉ាចំពោះព្រះរាជា ព្រោះតែមានទំនាស់ជាមួយគ្រឹះ ស្ថានជំនួញរបស់ខ្លួន ទីបំផុតពួកក្រុមរក្សាព្រះរាជា បានសម្លាប់លោក Pierre de Regemotes (ប្រធានក្រុមហ៊ុនហូឡង់) និងបរិវារ ហើយថែមទាំងបានធ្វើការរឹបអូសយកទ្រព្យសម្បត្តិទាំងអស់។

ដើម្បីការសងសឹក ក្រុមហ៊ុនហូឡង់បានបញ្ជូនកងនាវា ៥គ្រឿង និងទាហានជើងទឹក ១៦០ នាក់ មកដល់ទីក្រុងចតុមុខ នាថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ១៦៤៤ ហើយឈប់ចតនៅទីនោះ រហូតដល់ថ្ងៃទី ២០ ខែមករា ឆ្នាំ ១៦៤៥។ ដោយពុំទទួលបានសំណាងពីព្រះមហាក្សត្រខ្មែរ ពួកគេសម្រេចចិត្តបន្តដំណើរមករហូតដល់រាជធានីឧដុង្គ។ ដែលទីបំផុតត្រូវប៉ះទង្គិចគ្នាយ៉ាងខ្លាំង ដោយកងទ័ពខ្មែរបានយកកាំភ្លើងធំបាញ់ពីច្រាំងទន្លេទាំងសងខាង ធ្វើអោយមេបញ្ជាការហូឡង់បានស្លាប់ និងពួកទាហានជើងទឹករបស់គេ បានស្លាប់ជាច្រើននាក់។ ហេតុការណ៍ខាងលើនេះ ប្រហែលជាមានការឃុតឃិតគ្នារបស់ក្រុមហ៊ុនឥណ្ឌា ជាមួយក្រុម ព្រះបាទពញាចន្ទ ដែលកន្លងមកតែងតែមិនពេញចិត្តចំពោះក្រុមហ៊ុនហូឡង់ ដែលគាំទ្រដោយ អង្គស្តេចមុនៗ (ដែលជាស្តេចជ្រែករាជ្យហើយត្រូវជាក្មួយរបស់ខ្លួន)។[72]

រហូតដល់ឆ្នាំ ១៦៥៥ ទើបមានកិច្ចព្រមព្រៀងនយោបាយមួយ បានសម្រេចឡើងជាមួយក្រុមហ៊ុនជំនួញឥណ្ឌាខាងកើត ដោយយល់ព្រមផ្តល់សំណងខាតបង់ដល់គ្រឹះស្ថានជំនួញហូឡង់ ដែលរងការខូចខាតយ៉ាងធំធំ ហើយទំនិញដែលបានរឹបអូស ក៏បានសងវិញ និង ពួកឈ្លើយសឹកក៏បានដោះលែង។ ឆ្នាំ ១៦៦៧ គ្រឹះស្ថានជំនួញហូឡង់ នៅកំពង់ហ្លួង គឺបានបើកដំណើរការឡើងវិញ (ប៉ុន្តែត្រូវពួកចិនចូលប្លន់ ទ្រព្យសម្បត្តិអស់) ហើយបានដំណើរការយ៉ាងត្រដាបត្រដួស និងបិទជាស្ថាពរនៅឆ្នាំ ១៦៨២។

ចាប់ពីពាក់កណ្តាលសតវត្សទី១៧ ដល់សតវត្សទី១៨ ស្ថានភាពនយោបាយប្រទេសកម្ពុជារងនូវការរើករវើយ៉ាងខ្លាំង ពីសំណាក់ប្រទេសជិតខាង ដែលធ្វើអោយបាត់បង់ឱកាសក្នុងការកសាងសេដ្ឋកិច្ច-សង្គម។ យើងពុំឃើញមាននូវស្នាដៃណាមួយ ដែលបានកត់ត្រាពីបញ្ហាសេដ្ឋកិច្ច នៃប្រទេសកម្ពុជានោះទេ។

ប៉ុន្តែរហូតមកដល់សម័យឧដុង្គ យើងសង្កេតឃើញថា វិស័យពាណិជ្ជកម្មក្នុងប្រទេសកម្ពុជាហាក់ដូចជាមានដំណើរការជាប្រក្រតី។ នៅសម័យកាលនោះ ព្រះបាទអង្គឌួងបានខិតខំទាក់ទាញចិន និងឥណ្ឌាអោយចូលមកធ្វើពាណិជ្ជកម្មក្នុងប្រទេសទៀតផង។

## ៤.៣.៤ វិស័យហិរញ្ញវត្ថុ

នៅសម័យចតុមុខ ក្នុងរជ្ជកាលស្ដេចកន (ឆ្នាំ ១៥១២-១៥២៥) មានការបោះពុម្ពរូបិយវត្ថុជាលោហៈធាតុធ្វើពីមាស ប្រាក់ និងស្ពាន់។ ទម្ងន់ប្រាក់ស្លឹងមាសឆ្នឹង និងតម្លៃសមមូលរវាងគ្នាយ៉ាងណានោះ ពុំ មានឯកសារណាមួយបញ្ជាក់ទេ។ មកដល់ចុងសតវត្សទី១៦ មានឯក សារខ្លះបញ្ជាក់ថា រូបិយវត្ថុលោហៈធាតុ មានវិជ្ជមាត្រជាង ១០ ម.ម ត្រា រូបសត្វស្លាប បែរមុខទៅឆ្វេង ខាងខ្នងប្រាក់នេះ គ្មានត្រាទេ។ រូបិយវត្ថុ នេះ ធ្វើពីលោហៈធាតុប្រាក់ និងមានវិជ្ជមាត្រខុសៗគ្នា ហើយពុំមាន កាលបរិច្ឆេទបោះពុម្ពត្រឹមត្រូវឡើយ។

នៅសម័យលង្វែក មានព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សម្ខាន់មួយ ដែលកូនខ្មែរចាំរហូតមក គឺនៅពេលដែលសៀមវាយយកបន្ទាយលង្វែក ពុំបាននៅ គ.ស ១៥៨៨ នោះ ។ ក្រោយមក សៀមបានបាចប្រាក់ ដួងចូលក្នុងគុម្ពឫស្សីដែលជារបងព័ទ្ធបន្ទាយលង្វែក ។ ទង្វើបែបនេះ គឺក្នុងគោលបំណងអោយប្រជាជនខ្មែរ កាប់ឆ្ការឫស្សី ព្រោះឫស្សីជា ឧបសគ្គដ៏សម្ខាន់មួយ ក្នុងការវាយយកបន្ទាយលង្វែក។ ភស្តុតាងនេះបញ្ជាក់ថា ប្រាក់ឌួង ត្រូវបានធ្វើចរាចរនៅក្នុងប្រទេស បានជាប្រជាពលរដ្ឋខ្មែរត្រូវការប្រាក់នោះ។

លុះក្រោយៗទៀត ការបោះពុម្ពរូបិយវត្ថុប្រភេទនេះ ចេះតែបន្តតែគេមិនអាចសន្និដ្ឋានបានថាប្រាក់ស្លឹងត្រារូបនាគជំនាន់ស្ដេចកន និងប្រាក់ស្លឹងនាចុងសតវត្សទី១៦ មានលក្ខណៈដូចគ្នាយ៉ាងណាទេ (ទំហំ និងទម្ងន់)។ ឯប្រាក់ស្លឹងក្រោយនេះ មានវិជ្ជមាត្រ ១៥ ម.ម ទម្ងន់ ៤.៥ជី (អាចប៉ាន់ប្រមាណថា ៥ជី បើគិតទាំងសាច់ប្រាក់ដែលសឹកខ្លះផង)។

នៅសម័យឧដុង្គ មានការប្រើប្រាស់រូបិយវត្ថុធ្វើអំពីស័ង្កសី។ ក្នុងការដោះដូរយករូបិយវត្ថុនេះ ដោតជា៦០កាសគេអោយឈ្មោះថា ១គៀន ហើយ១០គៀនស្មើ ១ត្រណោត។ ក្រៅពីកាសនេះ គឺមានប្រាក់ណែន។ ប្រាក់ណែនមានសណ្ឋានដូចស្នូកជ្រូក ទម្ងន់ ១០ ឬ១០,២ តម្លឹង និង១ណែន ស្មើ ១០០ ត្រណោត កាសធ្វើពីស័ង្កសី។

នៅគ.ស ១៨៤៦ ព្រះបាទអង្គឌួង បានបង្គាប់អោយបោះពុម្ព រូបិយវត្ថុ ចំនួន ៣ប្រភេទ សម្រាប់ប្រើប្រាស់ដូចខាងក្រោម៖

- ប្រាក់ប្រាសាទ មានទម្ងន់ ៤ជី ៣៥ ម.ម។ នៅគែម ជុំវិញមានដាក់កាលបរិច្ឆេទនៃការបោះប្រាក់ ជាពុទ្ធសករាជ និងគ្រឹស្ដ សករាជ ។ ផ្ទៃម្ខាងត្រង់កណ្ដាលមានរូបហង្ស ជាតំណាងអោយព្រះសំអាងហង្ស ជាចាងហ្វាង ដែលបានទៅរៀនសូត្រនៅក្រៅប្រទេស ឯកទេសខាងបោះប្រាក់។ ផ្ទៃម្ខាងទៀតមានរូបប្រាសាទអង្គរនៅពីក្រោម រូបនេះមានអក្សរថា ក្រុងកម្ពុជា។
- ប្រាក់ស្លឹងមានត្រា និងអក្សរដូចប្រាក់ប្រាសាទខាងលើដែរ (រូបហង្ស និងរូបប្រាសាទ) និងមានទម្ងន់ ១ជី។ ដូច្នេះ ៤ស្លឹង ស្មើនឹង ១ ប្រាសាទ។[74]
- ប្រាក់ឌួងមានត្រា និងអក្សរដូចប្រាក់ទាំងពីរខាងលើ មានទម្ងន់តែ ៥ ហ៊ុន ទេ។

ក្នុងឆ្នាំ ១៨៦០ រជ្ជកាលព្រះបាទនរោត្តម (១៨៥៩-១៩០៤) ទ្រង់បានអនុញ្ញាតអោយបោះពុម្ពរូបិយវត្ថុលោហៈធាតុម្យ៉ាង ជាល្បាយសំរិទ្ធ លាយទង់ដែងច្រើន មានវិជ្ជមាត្រ ៣០ម.ម ទម្ងន់ ១០

ក្រោម។ ត្រានៅលើរូបិយវត្ថុនេះជាអក្សរខ្មែរសរសេរថា ១តៀន និងជាអក្សរបារាំងដាក់ថា Dix Centimes។

ចំពោះកិច្ចការពន្ធដារ ត្រូវបានអនុវត្តតាមរបបភាស៊ី និងមិនតម្លើងពន្ធដារថ្មីនោះទេ។ ជាងនេះទៀត ព្រះរាជាតែងតែចេញវិធានការបង្ក្រាបទៅលើអំពើចងការប្រាក់ ដែលយកការប្រាក់ធ្ងន់ធ្ងរពេកក្នុងការខ្ចីបុលគ្នា។ ម៉្យាងវិញទៀតតម្រូវអោយមានធ្វើជា "កិច្ចសន្យាខ្ចីប្រាក់" លាយលក្ខ័ណអក្សរត្រឹមត្រូវរវាងម្ចាស់បំណុល និងកូនបំណុល។[75] ការប្រាក់ត្រូវបានបន្ថយមកនូវត្រឹម ៣០% ប៉ុណ្ណោះ ក្នុង១ឆ្នាំ។ រីឯពន្ធអាករ ដ៏សំខាន់ឈ្មោះថា ពន្ធអាករពេងស្រូវ គឺមានចំនួន ១/១០ នៃ ផលិតផលស្រូវដែលកសិករទទួលបាន។ ក្រៅពីពន្ធពងស្រូវ ប្រជារាស្ត្របានបង់ពន្ធ ជាច្រើនជំពូកទៀត ដែលមានទំហំ ១/៤ នៃផលិតផលកសិកម្ម។

### ៤.៣.៥ វិស័យសំណង់ និងគមនាគមន៍

ទាក់ទងទៅនឹងការអភិវឌ្ឍវិស័យសំណង់ និងគមនាគមន៍ យើងឃើញមានឯកសារខ្លះ ដែលបានលើកឡើងអំពីការកសាងហេដ្ឋារចនា សម្ព័ន្ធទីក្រុង និងផ្លូវ។ ជាពិសេសនៅសម័យឧដុង្គ កិច្ចការសាងសង់ សំខាន់ៗគឺ ការកសាងស្ថាបនារាជធានីឧដុង្គឡើងវិញ និងការសាងសង់ ផ្លូវជាតិពីឧដុង្គ ទៅខេត្តកំពត នៅគ.ស ១៨៥១-១៨៥៧ ដែលជាតំបន់កំពង់ផែអន្តរជាតិសមុទ្ររបស់ខ្មែរយ៉ាងសំខាន់ ព្រោះកំពង់ផែព្រៃនគរ ត្រូវបានអោយទៅយួនជាស្ថាពរហើយ។[76] នៅឆ្នាំ ១៨៥២ ព្រះអង្គបានបញ្ជាអោយលើកផ្លូវមួយទៀត តភ្ជាប់ពីរាជធានីឧដុង្គទៅកំពង់ហ្លួង ជាកំពង់ផែជាតិ និងអន្តរជាតិសំខាន់មួយទៀតរបស់ខ្មែរនាសម័យនោះ។

## ៤.៤. វិស័យសិក្សាធិការជាតិ

ដោយសារតែស្ថានភាពនយោបាយនាសម័យក្រោយអង្គរ មានសភាពរឹករវខ្លាំង ធ្វើអោយវិស័យសិក្សាធិការជាតិស្ទើរគ្រប់រជ្ជកាលនៃអង្គស្តេច ពុំសូវបានយកចិត្តទុកដាក់នោះឡើយ។ ជាទូទៅប្រជារាស្ត្រ ខ្មែរបានចូលរៀនខ្លះៗនៅតាមទីវត្តអារាមរៀនជាភាសាបាលី និងភាសាខ្មែរក្រោយសម័យអង្គរ។[78] ការសិក្សា បង្រៀនដោយគ្រូព្រះសង្ឃរាជ្យ ឬជាព្រះសង្ឃ ដែលសិក្សាតាមសៀវភៅគម្ពីអក្សរសាស្ត្រ វិស្វកម្មសាស្ត្រ ហោរាសាស្ត្រ គណិតវិទ្យា និងយុទ្ធសាស្ត្រផ្សេងៗ។[79]

នៅសម័យនោះ ព្រះបាទអង្គចន្ទរាជា(នៅដើមសម័យលង្វែក) ក្រៅពីកិច្ចការធ្វើសឹកសង្គ្រាម ព្រះអង្គតែងតែយកព្រះទ័យទុកដាក់យ៉ាង ខ្លាំងក្នុងវិស័យសិក្សាធិការជាតិ។ ក្នុងកិច្ចការនេះ យើងពិនិត្យឃើញថា ក្រោយពីពេលដែលព្រះអង្គឡើងគ្រងរាជ្យសម្បត្តិហើយនោះព្រះអង្គ ចាត់អោយមន្ត្រីរបស់ខ្លួន ដើរស៊ើបរកអ្នកប្រាជ្ញបណ្ឌិត បញ្ញាវន្ត ដើម្បីមកចិញ្ចឹមទំនុកបំរុងសម្រាប់ប្រើប្រាស់ផ្តល់គំនិតយោបល់ រួមចំណែក ក្នុងការកសាងប្រទេសជាតិ។ ទង្វើបែបនេះ ជាគុណសម្បត្តិដ៏វិសេស វិសាលមួយដែលគេកម្រនឹងឃើញមានក្នុងសណ្តានចិត្តនៃអ្នកដឹកនាំជាតិក្នុងសម័យកាលនោះ ដែលផ្ទុយទៅវិញ គេតែងតែព្យាយាមធ្វើទុក្ខបុកម្នេញ ចំពោះពួកបញ្ញាវន្ត ពួកអ្នកមានសិល្ប៍ ឬអ្នកមានមហិទ្ធិរិទ្ធ ខ្លាំង

ពូកែជាដើម។ ដោយហេតុនេះហើយ ទើបមានស្នាដៃអ្នកនិពន្ធដែលនៅសេសសល់មួយចំនួន ច្រើនតែពុំមានឈ្មោះអ្នកនិពន្ធ និងរក្សាទុក ក្នុងទីវត្តអារាម។លុះមកដល់រជ្ជកាល ព្រះបាទអង្គឌួង (១៨៤៧-១៨៥៩) ទើបឃើញមានឯកសារខ្លះ ដែលបានលើកឡើងអំពីបូជនីយ៍កិច្ចរបស់ព្រះអង្គលើការងារអភិវឌ្ឍន៍វិស័យសិក្សាធិការជាតិ។ នៅសម័យនោះគេ ឃើញមានការសាងសង់សាលារៀនតាមទីវត្តអារាមជាច្រើន ហើយព្រះរាជាតែងតែលើកទឹកចិត្តពួកអ្នកប្រាជ្ញបណ្ឌិតកវី ព្រមទាំងបានទ្រទ្រង់ នូវថវិកា សម្រាប់ដល់ប្រជារាស្ត្រណាដែលចង់សិក្សា និងស្វែងរក ចំណេះវិជ្ជា។ ព្រះអង្គតែងតែសព្វព្រះហរទ័យ ពិភាក្សាជាមួយព្រះសង្ឃ លើការងារព្រះពុទ្ធសាសនានិងអក្សរសាស្ត្រ។ ព្រះអង្គក៏ជាអ្នកនិពន្ធដ៏ល្បីល្បាញផងដែរ ដូចជាស្នាព្រះហស្តរបស់ព្រះអង្គ នៅក្នុងវិស័យអក្សរសិល្ប៍ ដែលមានដូចជា៖

- ចម្ប៉ាថោង (គ.ស ១៨១០)
- រឿងកាកី (គ.ស ១៨១៥)
- និងច្បាប់ស្រី (គ.ស ១៨៣៧)។

### ៤.៥. វិស័យបរិស្ថាន

នៅសម័យឧដុង្គ ព្រះរាជាបានយកចិត្តទុកដាក់ លើកិច្ចការ ការពារបរិស្ថានធម្មជាតិ។ ក្នុងកិច្ចការនេះ ព្រះរាជាតែងតែហាមប្រាមមិនអោយប្រជារាស្ត្រធ្វើការបរបាញ់សត្វព្រៃ មិនអោយរាំងព្រួលពេញព្រៃក ដើម្បីចាប់ត្រី ព្រោះបាននាំមកនូវការវិនាសដាច់ពូជ និងបាត់បង់សម្បត្តិធម្មជាតិ ដែលអាចទុកប្រើប្រាស់បានយូរអង្វែងសម្រាប់មនុស្សជំនាន់ក្រោយ។

### ៤.៦. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជានាយុគសម័យក្រោយអង្គរ ឆ្នាំ១៤៣៤ ដល់ឆ្នាំ ១៨៦៣ យើងអាចធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោមនេះ ៖

- នៅគ្រប់សម័យកាលក្រោយអង្គរទាំងអស់យើងពិនិត្យឃើញថាការជ្រើសរើសទីតាំងភូមិសាស្ត្រសម្រាប់សំណង់ស្ថាបត្យកម្មរាជធានី និមួយៗតែងតែឈរលើគោលការណ៍យុទ្ធសាស្ត្រការពារទីក្រុង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិជាមូលដ្ឋាន។
- នៅគ្រប់សម័យកាល វិស័យកសិកម្មផលិតកម្មហាក់មានដំណើរការលូតលាស់ជាធម្មតា ប៉ុន្តែជីវភាពប្រជារាស្ត្រ ជួបប្រទះនូវការលំបាក ពុំមានស្បៀងគ្រប់គ្រាន់សម្រាប់ការផ្គត់ផ្គង់ជីវភាពរស់នៅ ព្រោះត្រូវការបង់ពន្ធជូនរដ្ឋ ម្យ៉ាងទៀតត្រូវរងនូវបន្ទុកនៃការបរិច្ចាគដល់ការចិញ្ចឹមកងទ័ពគ្រប់ភាគីទាំងអស់ទៀតផង (ទ័ពខ្មែរ សៀម និងយួន)។
- ចំពោះវិស័យសិប្បកម្ម និងឧស្សាហកម្មក៏មានដំណើរការលូតលាស់ជាប្រក្រតី ព្រោះគេឃើញមានប្រជារាស្ត្របានផលិតនូវផលិតផល សិប្បកម្មជាច្រើនប្រភេទ បម្រើអោយសេចក្តីត្រូវការលក់ដូរលើទីផ្សារក្នុងស្រុក និងការនាំចេញ។

- វិស័យពាណិជ្ជកម្ម យើងឃើញថាទាំងពាណិជ្ជកម្មក្នុងស្រុក និងពាណិជ្ជកម្មអន្តរជាតិ គឺមានដំណើរការជាធម្មតានៅតាមទីប្រជុំជន និងតំបន់កំពង់ផែជាពិសេស នៅទីផ្សារចតុមុខជាតំបន់កំពង់ផែអន្តរជាតិ។
- វិស័យហិរញ្ញវត្ថុ ក៏មានដំណើរការជាធម្មតា។ យើងឃើញមានការបោះពុម្ពសាច់ប្រាក់សម្រាប់ការប្រើប្រាស់ក្នុងស្រុកការប្រមូលពន្ធដារ បង្កើតបានជាចំណូល និងចំណាយរបស់រដ្ឋ។
- វិស័យសិក្សាធិការ ក៏ត្រូវបានយកចិត្តទុកដាក់ខ្លះដែរ ដូចជានៅក្នុងសម័យលង្វែក និងសម័យឧដុង្គជាដើម។
- ចំពោះវិស័យសំណង់ និងគមនាគមន៍វិញ យើងឃើញថា បានដំណើរការឡើងនៅគ្រប់សម័យកាល។ នៅសម័យឧដុង្គ យើងឃើញមានការលូតលាស់ ទាំងសំណង់រាជធានីសំខាន់ៗ ទាំងសំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជាតិ និងសាលារៀន។

ពិតប្រាកដណាស់ថា នាយុគសម័យក្រោយអង្គរ បញ្ហានយោបាយជម្លោះផ្ទៃក្នុងរាជ្យវង្សានុវង្សការគិតគូរតែពីផលប្រយោជន៍នៃក្រុមគ្រួសាររបស់ខ្លួន ចង់បានតែអំណាចរាជ្យបល្ល័ង្ក កង្វះសមត្ថភាពរបស់ ព្រះមហាក្សត្រ និងបញ្ហាសង្គ្រាមឈ្លានពាន គឺជាឧបសគ្គដល់ការរីកលូតលាស់នៃសេដ្ឋកិច្ចរបស់ប្រទេសខ្មែរ និងការបាត់បង់ទឹកដី។ យើងអាចអះអាងថា បើគ្មានជម្លោះផ្ទៃក្នុងរាជ្យវង្សានុវង្ស បើព្រះមហាក្សត្រ គ្រប់សម័យកាលចេះពិភាក្សាគ្នាយោគយល់គ្នាអនុវត្តព្រះរាជកិច្ចដោយឈរលើមូលដ្ឋានច្បាប់ និងតម្កល់ផលប្រយោជន៍ជាតិធំជាងប្រយោជន៍បុគ្គលម្ល៉េះសមគ្មានបរទេសណាហ៊ានមើលងាយជ្រៀតជ្រែកធ្វើអាណាព្យាបាល មកលើប្រទេសខ្មែរនោះឡើយ ព្រោះការសាមគ្គីធ្វើអោយយើងរស់ និងមានភាពរឹងមាំជាអមតៈ ដូចពាក្យចាស់ពោលថា *ចង្កឹះមួយដើមគេអាចកាច់បាក់តែចង្កឹះមួយបាច់គេកាច់មិនបាក់ឡើយ។*

# ជំពូកទី ៥
# សេដ្ឋកិច្ចប្រទេសកម្ពុជា សម័យអាណានិគមនិយមបារាំង
# ឆ្នាំ ១៨៦៣-១៩៥៣

## ៥.១. ស្ថានភាពនយោបាយ

### ៥.១.១ ស្ថានភាពនយោបាយមុនឆ្នាំ ១៨៦៣

ចាប់តាំងពីសតវត្សទី១៧ នៅលើពិភពលោកបានចាប់ផ្តើមរីកចម្រើននូវទំនាក់ទំនងនៃរបបមូលធននិយម ជាពិសេសក្នុងបណ្តាប្រទេសនានានៅទ្វីបអឺរ៉ុប ដែលជាហេតុផលនៃការចាប់ផ្តើមបើកឡើងនូវទំព័រប្រវត្តិសាស្ត្រថ្មី នៃការរីករាលដាលនូវនយោបាយវាទីនិយមរបស់ប្រទេសអឺរ៉ុបមួយចំនួនទៅលើបណ្តាប្រទេសទន់ខ្សោយទាំងឡាយនៅលើពិភពលោក។ ក្រោយមកនិន្នាការខាងលើនេះ ក៏បានរីករាលដាលពាសពេញពិភពលោក ហើយក៏មានប្រទេសនៅតំបន់អាស៊ី-អាគ្នេយ៍ផងដែរ ដែលត្រូវបានរងនូវការដាក់នឹមត្រួតត្រា អស់រយៈកាលដ៏យូរអង្វែងដែលក្នុងនោះមានទាំងប្រទេសឥណ្ឌូចិនទាំងមូលផងដែរ។

ដោយសារស្ថានភាពភូមិសាស្ត្រ និងធនធានធម្មជាតិនៃប្រទេសកម្ពុជាមានភាពទាក់ទាញអារម្មណ៍របស់ពួកអាណានិគមបារាំង ពីព្រោះថាប្រទេសកម្ពុជាជាប្រទេសមានលក្ខណៈអំណោយផលល្អ ដែលអាចពង្រីកអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច ទៅលើទឹកដីកូសាំងស៊ីន ហើយកំពុងកាន់កាប់ដោយប្រទេសបារាំង ដែលគេអាចបង្កើតជាមូលដ្ឋានសម្រាប់ការជ្រៀតជ្រែកយ៉ាងជ្រៅទៅទិសឧត្តរ និងទិសបស្ចឹមនៃដែនដី ឥណ្ឌូចិនដែលស្របពេលជាមួយគ្នានោះចក្រភពអង់គ្លេសកំពុងតែមានបំណងចង់លេបត្របាក់។

ក្នុងតំណាក់កាលទី១ នៃការជ្រៀតជ្រែកចូលប្រទេសកម្ពុជាគឺឆ្នាំ ១៨៥២ ដែលរដ្ឋាភិបាលបារាំងខិតខំប្រើប្រាស់មធ្យោបាយ ទំនាក់ទំនង ការទូត។ ទន្ទឹងនឹងនោះ អ្នកតំណាងប្រទេសបារាំងត្រូវបានមកចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយប្រទេសកម្ពុជា ប៉ុន្តែពេលនោះ ប្រទេសសៀមបានថ្លែងប្រឆាំងយ៉ាងដាច់អហង្ការ ហើយពិធីចុះ ហត្ថលេខាក៏ត្រូវបានផ្អាកទៅវិញ។[82]

នៅខែវិច្ឆិកា ឆ្នាំ១៨៥៣ ព្រះបាទអង្គឌួង បានបញ្ជូនព្រះរាជសារសម្ងាត់ថ្វាយជូនទៅព្រះចៅអធិរាជបារាំង ណាប៉ូលេអុងទី៣ ដើម្បីស្វែងរកការជួយអន្តរាគមន៍ផ្នែកនយោបាយបន្ថែមទៀតពីបារាំង ព្រោះដំណាក់កាលនោះ ប្រទេសកម្ពុជាកំពុងតែស្ថិតក្នុងមាត់ជ្រោះនៃការបាត់បង់ឯករាជ្យភាព បូរណៈភាពទឹកដីរបស់ខ្លួន។ ជាលទ្ធផល អ្នកការទូតបារាំង បានមកដល់ក្រុងឧដុង្គនៅថ្ងៃទី១២ ខែតុលា ឆ្នាំ ១៨៥៦ ដោយបារាំងបានថ្លែងសារនយោបាយចំពោះព្រះមហាក្សត្រខ្មែរ ដោយបញ្ជាក់អំពីឫទ្ធានុភាពនៃប្រទេសបារាំង អំពីការយកចិត្តទុកដាក់របស់ព្រះចៅអធិរាជបារាំងចំពោះប្រទេសខ្មែរ និងមានបំណងចង់ស្ថាបនាទំនាក់ទំនងរវាងប្រទេសទាំងពីរ។ ចំពោះព្រះបាទអង្គឌួង ក៏បាស្នើសុំអោយអ្នកការ

ទូតបារាំង ជួយធ្វើយ៉ាងណាដើម្បីយកទឹកដីកម្ពុជាក្រោម ដែលបាត់បង់នៅដើមសតវត្សទី១៩ នោះមកវិញ។

ព្រឹត្តិការណ៍នយោបាយជាប្រវត្តិសាស្ត្រ ដែលបានកើតឡើងជាមួយបារាំង គឺនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ១៨៥៦ គឺបានទាក់ទងនឹងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបារាំង-ខ្មែរ រវាងព្រះចៅក្រុងកម្ពុជាជាមួយនឹងតំណាងការទូតនៃព្រះចៅអធិរាជបារាំងដែលកិច្ចព្រមព្រៀងទាំងនោះមាន ១៤មាត្រា ហើយខ្លឹមសារសំខាន់ៗ គឺពាក់ព័ន្ធទៅនឹងសិទ្ធិនយោបាយរបស់បារាំងលើកិច្ចការពារពេញលេញលើប្រទេសកម្ពុជាទាំងមូល សិទ្ធិលើវិស័យពាណិជ្ជកម្ម សាសនា និងវិទ្យាសាស្ត្រ។

គួរបញ្ជាក់ដែរថា ការចុះហត្ថលេខាខាងលើនេះធ្វើអោយក្រុងបាងកកមានការស្តីបន្ទោសព្រះបាទអង្គឌួងយ៉ាងខ្លាំងដោយប្រើពាក្យ ពេចន៍ធ្ងន់ៗដែលមានន័យស្មើនឹងអំពើក្បត់ ព្រោះថាពេលនោះប្រទេសខ្មែរ ស្ថិតនៅក្រោមការត្រួតត្រារបស់សៀម។

តំណាក់កាលបន្ទាប់នៃការជ្រៀតជ្រែកចូលក្នុងប្រទេសកម្ពុជា ដោយប្រទេសបារាំងនៅឆ្នាំ ១៨៥៨-១៨៦២ មានការទាក់ទងជិតស្និទ្ធ ទៅនឹងការបញ្ជូនបេសកកម្មកងទ័ពរបស់បារាំងទី២ ទៅវៀតណាមខាងត្បូងដើម្បីឈានចូលទៅក្នុងប្រទេសកម្ពុជា។

ភារកិច្ចសំខាន់ៗ នៅក្នុងនយោបាយបារាំងនាឆ្នាំ១៨៦១-១៨៦៣ គឺខិតខំទប់ស្កាត់នឹងបំណងរបស់សៀម ដើម្បីកុំអោយប្រទេសនេះក្រសោបចាប់យកប្រទេសកម្ពុជា ព្រោះវាជារឿងគ្រោះថ្នាក់ដ៏ធំបំផុតដល់ទឹកដីវៀតណាមខាងត្បូង (ទឹកដីកូសាំងស៊ីន) ដែលបានកាន់កាប់តាំង ពីថ្ងៃទី ១៧ កុម្ភៈ ឆ្នាំ១៨៥៩ ដោយហេតុថា នៅពីក្រោយខ្នងសៀម គឺមានអង់គ្លេសដែលនឹងមានលទ្ធភាពចូលមកដល់ព្រំដែននៃវៀតណាមខាងត្បូង។

ក្រោយមកនៅដើមឆ្នាំ ១៨៦៣ រដ្ឋអំណាចបារាំងនៅវៀតណាម ខាងត្បូង បានស្នើជាផ្លូវការដល់ប្រទេសវៀតណាម អោយប្រគល់ទឹកដីកម្ពុជាក្រោម ដែលវៀតណាមបានកាន់កាប់តាំងពីដើមសតវត្សទី១៩ មកអោយបារាំងគ្រប់គ្រងវិញ ដោយសម្អាងថាទឹកដីនេះគឺជារបស់ខ្មែរ ហើយព្រះរាជវាំងឌុង្គ បានទទួលស្គាល់បារាំងជាអាណាព្យាបាល។ ដោយឡែក ចំពោះប្រទេសសៀមវិញ ដោយមានអង់គ្លេសនៅពីក្រោយខ្នងនោះពុំយល់ព្រមតាមសំណើណាមួយរបស់បារាំងទេ ស្តីពីការប្រគល់ប្រទេសខ្មែរអោយទៅបារាំងគ្រប់គ្រងនោះឡើយ។

បន្ទាប់ពីការចូលទីវង្គត់របស់មហាក្សត្រអង្គឌួង នាខែតុលា ឆ្នាំ១៨៦០ នៅពេលនោះព្រះបាទនរោត្តម (១៨៦០-១៩០៤) ជាបុត្ររបស់មហាក្សត្រអង្គឌួងបានឡើងសោយរាជ្យលើប្រទេសកម្ពុជា។ នៅពេលជាមួយគ្នានោះ មហាក្សត្រប្រទេសសៀមបានបញ្ជូនប្អូនរបស់ព្រះបាទនរោត្តម ព្រះនាមស៊ីវត្ថា មកប្រទេសកម្ពុជាក្នុងគោលបំណងធ្វើសកម្មភាព ប្រឆាំងនឹងព្រះមហាក្សត្រនរោត្តមដើម្បីឡើងសោយរាជ្យដែរ។

ចំណុចខាងលើនេះ គឺជាស្ថានភាពដ៏ធ្ងន់ធ្ងរសម្រាប់ព្រះបាទនរោត្តម ហើយដើម្បីទប់ស្កាត់បញ្ហាខាងលើនេះ ទីបញ្ជាការបារាំងបានចាប់ផ្តើមរៀបចំការទំនាក់ទំនងជាមួយ ព្រះមហាក្សត្រនរោត្តម ដែលធ្វើនៅថ្ងៃទី ២៤ ខែមិនា ឆ្នាំ១៨៦១។ តាងនាមរដ្ឋាភិបាលបារាំងបានផ្ញើសារពិសេសមួយមកថ្វាយជូន

ព្រះមហាក្សត្រនរោត្តមដែលបញ្ជាក់អំពីសណ្ឋានចិត្តមេត្រីភាព។ ក្នុងការឆ្លើយតបទៅនឹងសកម្មភាពបារាំងបែបនេះមហាក្សត្រនរោត្តម បានសុំបង្កើតស្ថានទូតមួយយ៉ាងធំនៅក្នុងទីក្រុងព្រៃនគរហើយក៍បានបញ្ជាក់ដល់រដ្ឋាភិបាលបារាំង ដើម្បីអោយជ្រាបនូវមេត្រីភាពរបស់ព្រះមហាក្សត្រ។

ព្រះបាទនរោត្តមមានបំណងតែមួយគត់គឺចង់ទទួលការគាំទ្រពីសំណាក់ប្រទេសបារាំង ដោយព្រះអង្គមានព្រះតម្រិះថាជាប្រទេសមិនសូវមានគ្រោះថ្នាក់ដល់ប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀតនាពេលនោះ សៀមកំពុងតែប្រើគ្រប់វិធីសាស្ត្រដើម្បីក្រសោបយកប្រទេសកម្ពុជាអោយស្ថិតនៅក្រោមរង្វង់នៃឥទ្ធិពលរបស់ខ្លួន។

បន្ទាប់ពីបានចរចាគ្នាជាច្រើនលើក មហាក្សត្រខ្មែរបានយល់ព្រមអោយលោកឡាគ្រង់ឌីយែរមកធ្វើទស្សនៈកិច្ចនៅប្រទេសកម្ពុជា។ នៅថ្ងៃទី ១១ ខែសីហា ឆ្នាំ១៨៦៣ ក៏មានការរៀបចំពិធីចុះហត្ថលេខាលើ សន្ធិសញ្ញាបារាំង-កម្ពុជាស្ដីអំពីការទទួលយកប្រទេសបារាំង ជាអាណាព្យាបាល។ ក្នុងមាត្រា ១៩ នៃកិច្ចព្រមព្រៀងបញ្ជាក់ថា រដ្ឋាភិបាលបារាំងសន្យាថាជួយឧបត្ថម្ភគាំទ្រព្រះរាជាណាចក្រកម្ពុជាក្នុងការកម្ចាត់សត្រូវឈ្លានពាន និងបង្ក្រាបការបះបោរក្នុងប្រទេស។[84]

## ៥.១.២ ស្ថានភាពនយោបាយក្នុងសម័យអាណាព្យាបាលបារាំង

ក្នុងពេលដែលបារាំងបានត្រួតត្រាលើប្រទេសកម្ពុជា ក្រោយឆ្នាំ១៨៦៣ មកគឺយើងអាចពិនិត្យមើលទៅលើស្ថានភាពនយោបាយមួយចំនួន ដែលបានកើតឡើងពាក់ព័ន្ធនឹងភាគីបារាំងភាគីប្រទេសជិតខាង និងភាគីខ្មែរម្ចាស់ស្រុកដូចខាងក្រោមនេះ ៖

- ដំណាក់កាលទី១៖ តាំងពីឆ្នាំ ១៨៦៣ មកម្ល៉េះ បារាំងបានប្រើប្រាស់វិធីត្រជាក់ ក្នុងការត្រួតត្រាប្រទេសកម្ពុជា ដោយប្រើប្រាស់ព្រះហត្ថលេខាលើក្រឹត្យច្បាប់ជាច្រើន ដែលសុទ្ធតែជាច្បាប់បានផ្ដល់ផលប្រយោជន៍ដល់នយោបាយ និងសេដ្ឋកិច្ចរបស់បារាំង។
- ដំណាក់កាលទី ២៖ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ បារាំងបាន, ប្រើវិធីគម្រាមកំហែងដោយប្រើប្រាស់កម្លាំងយោធាឡោមព័ទ្ធព្រះរាជវាំង ដើម្បីអោយព្រះបាទនរោត្តម ចុះព្រះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួនទៀត ដែលផ្ដល់ផលប្រយោជន៍នយោបាយច្រើនឡើងៗ ដល់ប្រទេសបារាំង។ កិច្ចព្រមព្រៀងទាំងនោះមានដូចជាព្រះមហាក្សត្រ និងរាជវង្សទទួលប្រាក់ខែរដ្ឋាភិបាលបារាំង ចៅហ្វាយខេត្តទាំងអស់ត្រូវស្ថិតក្រោមការត្រួតត្រារបស់បារាំងហើយរាជធានីភ្នំពេញ ក៏ត្រូវស្ថិតក្រោមការត្រួតត្រារបស់បារាំងដែរ។
- ដំណាក់កាលទី៣៖ នៅឆ្នាំ ១៨៨៧ បារាំងបានប្រើវិធីក្នុងការសម្រេចកិច្ចការអធិបតេយ្យភាពប្រទេសខ្មែរ ដោយឯកតោភាគីដោយបញ្ចូលប្រទេសកម្ពុជាទៅក្នុងសហភាពឥណ្ឌូចិនរបស់បារាំង មានន័យថាប្រទេសកម្ពុជា ជាដែនដីមួយចំណែករបស់បារាំង។
- ដំណាក់កាលទី៤៖ មកដល់ឆ្នាំ ១៨៩៧ បារាំងបាន បង្ខិតបង្ខំអោយព្រះមហាក្សត្រ ចុះព្រះហស្ថលេខាលើព្រះរាជក្រឹត្យមួយទៀត ដែលមានន័យថាព្រះមហាក្សត្រសោយរាជ្យ ប៉ុន្តែ

មិនត្រួតត្រាប្រទេសនោះទេ ពោលគឺបារាំងបានដកព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រខ្មែរ លើកិច្ចការនយោបាយ និងរដ្ឋបាលទាំងស្រុង។

[84] ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២, ទំព័រ ២២៤-២២៦

គួររំលឹកដែរថា នៅដើមសតវត្សទី២០ បារាំងបានចុះសន្ធិសញ្ញាសំខាន់ៗចំនួន២ ជាមួយសៀម គឺ សន្ធិសញ្ញាបារាំង-សៀម នៅឆ្នាំ១៩០៤ ដែលធ្វើអោយប្រទេសខ្មែរបាត់បង់ទឹកដី តំបន់ម្លូព្រៃ ទន្លេរពៅ និងព្រះវិហារ។ ប៉ុន្តែសន្ធិសញ្ញាបារាំង-សៀមនៅឆ្នាំ១៩០៧ ប្រទេសខ្មែរទទួលបានខេត្តបាត់ដំបង និងសៀមរាបមកវិញ។

ផ្សេងពីនេះទៀត ចំពោះស្ថានភាពនយោបាយក្នុងប្រទេស យើងសង្កេតឃើញថាមានការបះបោរជាច្រើនលើកបានកើតមានឡើង ដើម្បីប្រឆាំងនឹងវត្តមានអាណាព្យាបាលបារាំង ក៏ដូចជាប្រឆាំងនឹងព្រះរាជា ដែលចុះកិច្ចព្រមព្រៀងសម្ព័ន្ធភាពរវាងកម្ពុជា-បារាំង។ ដូចជាការបះបោររបស់ ព្រះអង្គម្ចាស់ស៊ីវត្ថា នៅឆ្នាំ ១៨៦១ និងឆ្នាំ ១៨៦៧ ។ ការបះបោររបស់អាចារ្យស្វានៅឆ្នាំ ១៨៦៤ និងការបះបោររបស់ពោធិកំបោរ នៅឆ្នាំ ១៨៦៦ និងឆ្នាំ ១៨៦៧។ ការបះបោររបស់ក្រឡាហោមគង់ នៅឆ្នាំ ១៨៨៥ ដល់ ១៨៨៦ ដែលបានប្រើល្បិចកល ហើយចាប់លោកក្រឡាហោមគង់ ធ្វើទារុណកម្មដ៏សែនឈឺចាប់ ដោយបានចងផ្គោបនឹងបំពង់ផ្សែងកប៉ាល់។ ចលនារបស់ពិស្ណុលោកឈូក ដើម្បីប្រយុទ្ធប្រឆាំងនឹងពួកអាណានិគមបារាំង។

## ៥.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច

ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រដ្ឋការបារាំងមានគោលបំណងបង្កើតសិទ្ធិឯកជនលើដីធ្លី ស្រែចំការតាមបែបមូលធននិយម។ ស្របតាមកិច្ចព្រមព្រៀងចុះថ្ងៃទី ១៧ មិថុនា ១៨៨៤ និងស្របទៅតាមក្រមមួយចំនួនរបស់ព្រះមហាក្សត្រនរោត្តម និងសារាចរនានារបស់ទេសាភិបាលជាន់ខ្ពស់រដ្ឋការអាណានិគមបារាំងបានអនុវត្តច្បាប់នៃការផ្តល់កម្មសិទ្ធឯកជនលើដីធ្លី។ នៅក្នុងកិច្ចព្រមព្រៀងខាងលើនេះបានចែងថា "ចាប់ពីពេលនេះតទៅ ដីទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ដែលពីមុនជាកម្មសិទ្ធិផ្ទាល់របស់រាជបល្ល័ង្ក ឈប់ទៅជាដីដែលគេមិនអាចទិញបានទៀតឡើយ"។ នៅក្នុងរាជក្រឹត្យព្រះបាទនរោត្តម ចុះថ្ងៃ ទី ១១ កក្កដា ១៨៩៧ មានសេចក្តីបញ្ជាក់ថា "រាជរដ្ឋាភិបាលរក្សាទុកនូវសិទ្ធិក្នុងការបែងចែកដីទំនេរទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា ហើយម្ចាស់កម្មសិទ្ធិដីសម្បទាន អាចប្រើប្រាស់ពេញច្បាប់របស់ខ្លួន ក្នុងការរក្សាកម្មសិទ្ធិឯកជនចំពោះវិញ ឬក៏ផ្តល់ជាសម្បទាន" មាត្រា ១២។ នៅក្នុងសារាចរចុះថ្ងៃទី ២៩ ធ្នូ ១៨៩៧ ស្ថានភាពច្បាប់បានត្រូវ កំណត់ច្បាស់លាស់ដោយមានសេចក្តីបញ្ជាក់ថា "រាជរដ្ឋាភិបាលរក្សា នូវសិទ្ធិរបស់ខ្លួនក្នុងការលក់ ឬបែងចែកដីទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធ្វើអោយដីទាំងនោះ ទៅជាកម្មសិទ្ធិឯកជនរបស់ម្ចាស់ដីធានាប់រងដល់ស្ថេរភាពនៃកម្មសិទ្ធិលើដីទាំងនោះ ហើយព្រមទាំងបង្កបង្កើតល័ក្ខខ័ណ្ឌដ៏ប្រសើរក្នុង

ការប្រើប្រាស់ដីអោយ មានទំហំច្រើនជាអតិបរមា ក្នុងការធ្វើដំណាំស្រូវ ដែលអាចបង្កើត ទ្រព្យសម្បត្តិរបស់ម្ចាស់ដីព្រោះថា នៅក្នុងប្រទេសកម្ពុជាមានសល់ដី ទំនេរ និងមិនទាន់ត្រូសត្រាយមានទំហំធំផេង" ។

ដើម្បីដំណើរការឡើងនូវក្រឹត្យច្បាប់ខាងលើអោយមានប្រសិទ្ធ ភាពនៅថ្ងៃទី២៥ មេសា ១៩០២ មានការចុះផ្សាយរាជក្រឹត្យរបស់ព្រះមហាក្សត្រនរោត្តម ដែលនៅក្នុងនោះមានសេចក្តីបង្គាប់ដល់ភូមិទាំងអស់អោយចុះបញ្ជីដីធ្លី និងម្ចាស់ដីត្រូវបញ្ជាក់អំពីទំហំដីច្បាស់លាស់។

និន្នាការបែបនេះ ទាក់ទងនឹងការបង្កើតក្រសួងសុរិយោដី ការរៀបចំគម្រោងកសិដ្ឋានតាមបែបអឺរ៉ុប និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចក្នុងការផ្តល់ដីសម្បទាន ដល់ក្រុមហ៊ុនទាំងឡាយដោយរដ្ឋការអាណានិគមបារាំង។

ពួកអាណានិគមបារាំង បានខិតខំបង្កើតក្រសួងសុរិយោដីនៅក្នុងប្រទេស ដើម្បីដំណើរការចុះបញ្ជីដីធ្លី។ ការចុះបញ្ជីដោយក្រសួង សុរិយោដី បានប្រព្រឹត្តទៅនៅឆ្នាំ ១៩០៦ ម្តង ឆ្នាំ ១៩១៨ ម្តង និងនៅ សម័យឆ្នាំ ១៩៣០-១៩៤៥ ម្តងទៀត។ បើនិយាយអោយខ្លីទៅ ការចុះបញ្ជីដីធ្លីបានប្រព្រឹត្តទៅនៅក្នុងសម័យកាលនៃរបបអាណានិគមនិយមទាំងមូល។ ម្ចាស់ដីដែលអាចក្លាយទៅជាអ្នកមានកម្មសិទ្ធិដីធ្លីលុះត្រាតែដីរបស់ខ្លួន ត្រូវបានចុះបញ្ជីត្រឹមត្រូវដោយក្រសួងសុរិយោដីដោយមានលិខិតបញ្ជាក់ថា មានការបង់ពន្ធ និងចុះបញ្ជីត្រឹមត្រូវ ។

ដោយយោងតាមច្បាប់ស្តីពីការកាន់កាប់ដីធ្លីដែលបានអនុម័តរួចមក រដ្ឋការអាណានិគម បានបែងចែកដីឡូត៍ធំៗ ដល់ពលរដ្ឋបារាំងជាពិសេសដល់ក្រុមហ៊ុនផ្តាច់មុខសម្រាប់ការដាំដំណាំកសិកម្មស្រូវ ពោត កាហ្វេ ម្រេច កៅស៊ូ និងសម្រាប់ការចិញ្ចឹមសត្វ។ ដីឡូត៍ធំៗ ជាច្រើនបានត្រូវបែងចែកដល់បណ្តាមន្ត្រីខ្មែរដែលបានធ្វើការសហការ យ៉ាងសកម្មជាមួយរដ្ឋបាលអាណានិគមបារាំង។

តាំងដើមដំបូងមកម្ល៉េះ បន្ទាប់ពីការតែងតាំងរបបអាណាព្យាបាលបារាំងនៅកម្ពុជា ទេសាភិបាលជាន់ខ្ពស់ មានសិទ្ធិបែងចែកដីធ្លី ជាលក្ខណៈសម្បទានដោយឥតគិតថ្លៃ ហើយដោយមានទំហំរហូតដល់ ១.០០០ ហិកតា។ លុះនៅឆ្នាំ ១៩២៨ ទំហំដីសម្បទាន ដែលរដ្ឋការអាណាព្យាបាលបានបែងចែកអោយបានត្រឹមតែកម្រិតប្រមាណជា ៣០០ ហិកតា វិញប៉ុណ្ណោះ។ នៅឆ្នាំ ១៩៣១ ការផ្តល់ដីសម្បទានត្រូវបានផ្លាស់ប្តូរទៅតាមលក្ខណៈរូបភាពលក់ដេញថ្លៃ ហើយដែលមានការអនុញ្ញាតអោយចូលរួមដេញថ្លៃ មិនមែនសម្រាប់តែពលរដ្ឋបារាំងនោះទេ ប៉ុន្តែពួកអភិជន ឬនាហ្មឺនខ្មែរក៏អាចចូលរួមផងដែរ។ តាមទិន្នន័យនាឆ្នាំ ១៩៣០ ទំហំដីសម្បទានដែលបែងចែកដោយរដ្ឋការអាណាព្យាបាលបារាំង មានចំនួនពី ១៩០.០០០ ដល់ ២០០.០០០ ហិកតា។ ក្នុងនោះពលរដ្ឋបារាំង បានទទួលដីសម្បទានដែលមានទំហំទៅដល់ ៧០% រីឯដីសម្បទានដែលនៅសល់ត្រូវបានបែងចែកជាពិសេសដល់អភិជនខ្មែរទាំងឡាយ។

គួរបញ្ជាក់ថា កសិករជាង ៨០% ដែលជាអ្នកស្រែចំការ ក៏បានក្លាយជាម្ចាស់កម្មសិទ្ធិឯកជនលើដីធ្លីរបស់ខ្លួន។ កាលនោះនៅប្រទេស កម្ពុជា នៅមានដីទំនេរច្រើន ហើយការត្រួតត្រាលើដីទាំងនោះ មិនចាំបាច់ទាមទារអោយមានការចំណាយប្រាក់ច្រើនទេ។ ដីស្រែទាំងឡាយ ប្រកបដោយដីជាតិហើយជាមធ្យម

កសិករម្នាក់ៗ មានកម្មសិទ្ធិមិន លើសពី ៥ហិកតា។ ក្នុងបណ្តាកសិករទាំងនោះ មានកសិករចំនួនពី ១,២ ទៅ ២% ប៉ុណ្ណោះដែលមានដីស្រែចំការលើសពី១០ហិកតា។

ក្រៅពីគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចខាងលើនេះ រដ្ឋការអាណាព្យាបាលបារាំងបានបង្កើតវិធីសាស្ត្រទាញយកផលប្រយោជន៍ ផ្សេងទៀត តាមរយៈការបង្កើតរបាំងពន្ធអាករគ្រប់ប្រភេទ តាំងពីការយកពន្ធលើមនុស្ស លើការចិញ្ចឹមសត្វ និងលើផលដំណាំកសិកម្ម រហូត ដល់ពន្ធនាំចេញ-នាំចូល ដែលតម្លៃអត្រាពន្ធទាំងនោះមានការប្រែប្រួលគ្រប់ពេលវេលា ដោយធ្វើយ៉ាងណា បម្រើផលប្រយោជន៍ដល់សេដ្ឋកិច្ច របស់ប្រទេសបារាំង។ ជាងនេះទៀត ប្រទេសកម្ពុជានៅក្នុងសម័យកាលនោះ ក៏បានក្លាយទៅជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម សម្រាប់បម្រើអោយឧស្សាហកម្មបារាំង ហើយក្លាយជាអ្នកទទួលទិញនូវទំនិញ ផលិតសម្រេចពីប្រទេសបារាំងមកវិញ។

សរុបសេចក្តីមក ទស្សនៈទានសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា នាសម័យអាណានិគម គឺទាក់ទងនឹងនយោបាយបែងចែកដីសម្បទាន ដើម្បីក្លាយទៅជាកម្មសិទ្ធិឯកជន ក្នុងទិសដៅអភិវឌ្ឍន៍ វិស័យកសិកម្ម និងឈានទៅរកការអភិវឌ្ឍឧស្សាហកម្មធុនស្រាល។ ក្នុងលក្ខណៈនេះ រដ្ឋមានតួនាទីជាអ្នកបែងចែកដ៏ស្របច្បាប់ និងទទួលបានមកវិញនូវប្រាក់ចំណូលតាមរូបភាពបង់ពន្ធលើដីធ្លី និងលើផលដំណាំ ក៏ដូចជាលើប្រាក់ចំណេញ។ ទន្ទឹមនឹងនោះដែរ អាណាព្យាបាលបារាំង បានបង្កើតគោលនយោបាយពន្ធអាករ ដែលកេងប្រវ័ញ្ចលើប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់ ហើយធ្វើអោយសេដ្ឋកិច្ចខ្មែរទាំងមូល បានស្ថិត នៅក្នុងសភាពក្រីក្រដដែល។ រីឯការវិនិយោគសាធារណៈ និងការបែងចែកមកវិញនូវចំណូលពន្ធអាករ មិនបានផ្តល់នូវភាពយុត្តិធម៌ និងការរីកចម្រើនដល់សេដ្ឋកិច្ចជាតិ និងសង្គមខ្មែរ នាសម័យកាលនោះឡើយ។

## ៥.៣. ស្ថានភាពវិស័យសេដ្ឋកិច្ច

### ៥.៣.១ វិស័យកសិកម្ម

នៅក្នុងរបបអាណានិគមនិយមបារាំង ដំណាំកសិកម្មជាប្រពៃណី ត្រូវបានពង្រីកដូចជា ដំណាំស្រូវ ពោត សណ្តែកគ្រប់មុខ និងបន្លែ បង្ការគ្រប់យ៉ាង។ ក្រៅពីនោះ ក៏មានដំណាំផ្សេងៗទៀតដែលពុំធ្លាប់មាន ពីមុនមកដូចជា កាហ្វេ ម្រេច និងដំណាំកៅស៊ូ។ល។

#### ដំណាំស្រូវ

យើងដឹងហើយថា អរិយធម៌របស់ប្រទេសខ្មែរយើង គឺផ្សារភ្ជាប់ទៅនឹងការផលិតស្រូវ នេះបើយោងតាមរឿងទេវកថា រឿងព្រេងសិល្បៈ ចំរៀងប្រជាប្រិយនានា ដែលបានរស់នៅក្នុងសង្គមខ្មែរតាំងពីបុរាណមក គឺជាអាយុជីវិតនៃប្រជារាស្ត្រខ្មែរគ្រប់សម័យកាល។ ជាញឹកញាប់ ស្រូវ គឺជាអាហារចម្បងប្រចាំថ្ងៃ និងជាមធ្យោបាយដោះដូរយកគ្រឿង ឧបភោគបរិភោគ ផ្សេងៗទៀតផងដូចជា ដូរយកត្រីងៀតរបស់របរប្រើ ប្រាស់ផ្សេងៗឬលក់យកសោហ៊ុយសម្រាប់បង់ពន្ធ។ យោងតាមឯកសារ ស្រាវជ្រាវរបស់បារាំង ប្រជាជនខ្មែរដែលជាអ្នកស្រែចំការមុនឆ្នាំ ១៨៩៨ គឺគ្មានដីស្រែជារបស់ខ្លួននោះទេ ពួកគេ

ជាទាសកររបស់ម្ចាស់ដីជនបទ ឬធ្វើការងារជាសិប្បករបម្រើអោយថៅកែផ្សេងៗ ឬជាកម្មករក្នុងសហគ្រាសតូចៗនៅក្នុងទីប្រជុំជន ឬធ្វើការងារក្នុងការដ្ឋាន ឬជាកម្មករនៅ ក្នុងទីក្រុង។

នៅសម័យអាណាព្យាបាលបារាំង ការធ្វើស្រែចំការរបស់កសិករ ខ្មែរ មិនដែលជៀសផុតពីការរងគ្រោះដោយទឹកភ្លៀង ទឹកជំនន់ ឬគ្រោះ រាំងស្ងួតនោះទេ។ ទិន្នផលដំណាំស្រូវ តែងតែស្ថិតនៅក្រោមឥទ្ធិពលមិន ទៀងទាត់ពីអាកាសធាតុ និងវិស័យជលសាស្ត្រនោះឡើយ។

រដូវធ្វើស្រែចំការ គឺបានចាប់ផ្តើមនៅពេលដែលមានខ្យល់ព្យុះ ដំបូងៗ ពីខែឧសភា ដែលនាំមកនូវទឹកភ្លៀងស្រោចស្រពពាសពេញផ្ទៃប្រទេស រហូតដល់ខែវិច្ឆិកា។ ចំពោះកសិករដែលមានដីស្រែចំការគេ បាននាំគ្នាចាកចេញពីការដ្ឋាន ដែលជាកន្លែងធ្វើការជាយថាហេតុ ដើម្បីទៅភ្ជួររាស់ ដាស់ដីសាបសំណាប និងព្រុសស្រូវដែលពួកគេបានជ្រើសរើសពូជរួចៗ នៅខែសីហា ចាប់ផ្តើមស្ទូង ក្រោយមកធ្វើការថែទាំ ហើយចាប់ផ្តើមច្រូតកាត់ស្រូវ នៅខែធ្នូ រហូតដល់ខែកុម្ភៈ។ ចង្វាក់ផលិតកម្មនេះ ជាញឹកញាប់ត្រូវបានរំខានដោយការផ្លាស់ប្តូរនៃរបបទឹកភ្លៀង។ ភ្លៀងដំបូងៗ អាចមានការយឺតយ៉ាវហើយមិនទៀងទាត់ ធ្វើអោយការសាបព្រួស មានការយឺតយ៉ាវ។ ក្នុងខែកក្កដា និងខែសីហា ទឹកភ្លៀង មិនសូវ មានច្រើនទេ ប៉ុន្តែបើមានទឹកភ្លៀងតិចតួចនៅខែកក្កដា នោះកសិករមិនអាចភ្ជួររាស់ និងដកស្ទូងបានឡើយ។ ប៉ុន្តែពេលខ្លះ កសិករត្រូវបង្ខំចិត្តចាប់ភ្ជួររាស់ ដកស្ទូងឡើងវិញ នៅខែសីហា ឬខែកញ្ញាហើយបើមាន ភាពរាំងស្ងួតចាប់ផ្តើមភ្លាមៗ ត្រូវបានធ្វើអោយមានគ្រោះមហន្តរាយ ដល់ដំណាំស្រូវរបស់ពួកគេ។ ផ្ទុយទៅវិញ បើរដូវវស្សាចាប់ពីខែមិថុនា ដល់ខែសីហា មានភ្លៀងច្រើន ទឹកទន្លេមេគង្គឡើងខ្លាំងធ្វើអោយលិចលង់វាលទំនាបមួយចំនួនរបស់ប្រទេសកម្ពុជា ប៉ុន្តែវាបានធ្វើអោយដី មានដីជាតិល្អទៅវិញ និងមានទឹកបញ្ចូលស្រែ តែទឹកជំនន់នេះ បើកាលណាវាឡើងខ្លាំងហើយហ៊ៀស វាអាចធ្វើអោយលិចលង់សំណាបដែល ទើបតែលាស់ខ្ចីធ្វើអោយស្រូវឈ្លក់ទឹកហើយរលួយ។ រាល់ភាពមិនទៀងទាត់នេះ កើតឡើងយ៉ាងខ្លាំងហើយញឹកញាប់ផងដែរ ដូចជា គ្មានភ្លៀង ភាពរាំងស្ងួតក្នុងខែមិថុនា និងទឹកជំនន់ក្នុងខែសីហា ហើយវាមានស្ថានភាពធ្ងន់ធ្ងរ។ ម្យ៉ាងទៀត នៅតំបន់នានា ក្នុងខេត្តតែមួយ តំបន់ទំនាបគឺត្រូវអន្តរាយដោយសារទឹកជំនន់ ចំណែកឯតំបន់ដែលខ្ពស់ត្រូវ អន្តរាយដោយភាពរាំងស្ងួត។ តាមរបាយការណ៍របស់អភិបាលបារាំង បានកត់សម្គាល់ថានៅពេលណាដែលកសិករខ្មែរប្រមូលផលស្រូវ វស្សា មិនបានល្អទេនោះ ឬក៏ក្រោយពីការច្រូតកាត់បានផលតិចតួចក្នុងខែកុម្ភៈ កសិករក៏ចាប់ផ្តើមធ្វើ ស្រែក្នុងរដូវក្តៅ ដែលហៅថា ស្រែប្រាំង។ បើធ្វើការដកស្ទូងនៅខែកុម្ភៈ នោះការច្រូតកាត់នឹងចាប់ផ្តើមនៅខែ ឧសភា។ ជាឧទាហរណ៍ មាននៅក្នុងខេត្តមួយចំនួនដូចជា កំពង់ចាម កណ្តាល ដែលមានផ្ទៃដីស្រែប្រាំងធំធេងណាស់។

ផលិតកម្មស្រូវ ក្នុងសម័យអាណានិគមនិយមបារាំង មានទិន្នផលប្រែប្រួលខុសៗគ្នាមិនទៀងទាត់ឡើយ អាស្រ័យដោយកត្តាអាកាសធាតុ។ តាមការស្រាវជ្រាវ ឆ្នាំដែលមានភាពរាំងស្ងួតខ្លាំង មានដូចជា ឆ្នាំ ១៨៩៩ ឆ្នាំ១៩០២ និង ឆ្នាំ១៩១១ រីឯឆ្នាំដែលមានទឹកជំនន់ធំៗ រួមមាន ឆ្នាំ១៩០៤ ឆ្នាំ១៩០៥ និង ឆ្នាំ១៩០៧ ដែលគ្រោះធម្មជាតិនេះ បានធ្វើអោយទិន្នផលស្រូវសរុបរបស់ប្រទេសកម្ពុជាបានធ្លាក់ចុះពី ៥០០.០០០ តោន រហូតដល់ ៣០០.០០០ តោន។

ជាងនេះទៀត នៅពេលដែលមានគ្រោះរាំងស្ងួត និងទឹកជំនន់កើតឡើងព្រមគ្នា ដូចជានៅឆ្នាំ ១៩១១ និង ឆ្នាំ ១៩១៨ បានធ្វើអោយកើតមាននូវគ្រោះទុរ្ភិក្ស។ ប៉ុន្តែនៅពេលដែល អាកាសធាតុ និងវិស័យផលសាស្ត្រអំណោយផល ទិន្នផលស្រូវសរុបក៏មានការកើនឡើងខ្ពស់តាមនោះដែរ គឺកើនពី ៦០០.០០០ តោន រហូត ដល់ ៩០០.០០០ តោន ជាក់ស្តែងដូចជាក្នុងឆ្នាំ ១៩០៩ ឆ្នាំ ១៩១២ ឆ្នាំ ១៩១៣ និងឆ្នាំ ១៩១៤។ ខាងក្រោមនេះ គឺជាតារាងទិន្នន័យផលិតផល ដំណាំស្រូវរបស់ប្រទេសកម្ពុជា ចន្លោះឆ្នាំ១៩១៣ រហូតដល់ ឆ្នាំ១៩១៨។

| បរិយាយ | ទិន្នផលស្រូវសរុប |
|---|---|
| ឆ្នាំ ១៩១៣ | ៨០០.០០០ តោន |
| ឆ្នាំ ១៩១៤ | ៩០០.០០០ តោន |
| ឆ្នាំ ១៩១៥ | ៦០០.០០០ តោន |
| ឆ្នាំ ១៩១៦ | ៦៥០.០០០ តោន |
| ឆ្នាំ ១៩១៧ | ៦៧០.០០០ តោន |
| ឆ្នាំ ១៩១៨ | ៥៨០.០០០ តោន |

*តារាងទិន្នផលស្រូវសរុបនៅកម្ពុជា ឆ្នាំ ១៩១៣ - ១៩១៨*[90]

ដូច្នេះយោងតាមទិន្នន័យខាងលើ បរិមាណផលិតកម្មស្រូវចន្លោះ ឆ្នាំខាងលើនេះមានការប្រែប្រួលខុសៗគ្នា អាស្រ័យដោយភាពអំណោយផល ឬមិនអំណោយផលពីរបបទឹកភ្លៀង ហើយបើគិតជាមធ្យមប្រចាំឆ្នាំទិន្នផលស្រវមានប្រមាណជា ៧០០.០០០ តោន/ឆ្នាំ។

បើយើងធ្វើការសិក្សាប្រៀបធៀប អំពីទិន្នផលស្រូវជាមធ្យមក្នុង ១ហិកតា ជាមួយនឹងបណ្តាប្រទេសនៅក្នុងតំបន់ឥណ្ឌូចិនដូចគ្នា នាសម័យកាលនោះយើងឃើញថា ទិន្នផលផលិតកម្មស្រូវនៅប្រទេសកម្ពុជាមានសភាពអន់ថយបំផុត។ តារាងខាងក្រោម បង្ហាញអំពីការប្រៀបធៀបទិន្នផលដំណាំស្រូវរបស់ប្រទេសកម្ពុជា ជាមួយនឹងប្រទេស នៅឥណ្ឌូចិន ចន្លោះឆ្នាំ ១៩១៩ ដល់ ឆ្នាំ ១៩២២។

| បរិយាយ | ទិន្នផលស្រូវ/ហិកតា | ទិន្នផលស្រូវ/មនុស្សម្នាក់ |
|---|---|---|
| កម្ពុជា | ១.១០០ គ.ក | ២០០ គ.ក |
| កូសាំងស៊ីន | ១.៣០០ គ.ក | ៧០០ គ.ក |
| លាវ | ១.០០០ គ.ក | ៣០០ គ.ក |
| អាណាម | ១.៣០០ គ.ក | ៣០០ គ.ក |
| តុងកឹង | ១.៤០០ គ.ក | ៣០០ គ.ក |

*ការប្រៀបធៀបទិន្នផងស្រូវរបស់កម្ពុជា និងប្រទេស ឥណ្ឌូចិន ចន្លោះឆ្នាំ ១៩១៩ ដល់ ១៩២២*

ទិន្នន័យនៅក្នុងតារាងខាងលើ បានបញ្ជាក់យ៉ាងច្បាស់ អំពីភាពទន់ខ្សោយរបស់វិស័យកសិកម្មដំណាំស្រូវនៃប្រទេសកម្ពុជា ក្នុងរបបអាណានិគម ដែលមិនត្រូវបានយកចិត្តទុកដាក់។

តំបន់ភូមិសាស្ត្រ ដែលផលិតស្រូវសំខាន់ៗរបស់ប្រទេសកម្ពុជា ស្ថិតនៅជុំវិញតំបន់វាលទំនាបទន្លេសាប ជុំវិញទន្លេមេគង្គលើ មេគង្គក្រោម និងត្រើយខាងកើតនៃទន្លេបាសាក់។ យោងតាមស្ថិតិឆ្នាំ ១៩១៩ ដល់ ឆ្នាំ១៩២២ ភូមិសាស្ត្រសំខាន់ៗ សម្រាប់ផលិតកម្មដំណាំស្រូវ មានលក្ខណៈដូចខាងក្រោម៖

| ចំណាត់ថ្នាក់តំបន់ដាំដុះ | ផ្ទៃដីដាំដុះ (ហ.ត) | ចំណាត់ថ្នាក់ទិន្នផលតាមតំបន់ | ទិន្នផល/ហ.ត (គ.ក) |
|---|---|---|---|
| ១. បាត់ដំបង | ១២២.០០០ | ១. ក្រចេះ | ១.៥០០ |
| ២. ស្វាយរៀង | ៦១.០០០ | ២. កណ្តាល និងកំពង់ស្ពឺ | ១.៤៥០ |
| ៣. កំពត | ៥៨.០០០ | | ១.៤០០ |
| ៤. ព្រៃវែង | ៥៤.០០០ | ៣. កំពត | ១.៤០០ |
| ៥. កំពង់ចាម | ៤៥.០០០ | ៤. បាត់ដំបង | ១.៣០០ |
| ៦. កណ្តាល និងកំពង់ស្ពឺ | ៤០.០០០ | ៥. កំពង់ឆ្នាំង<br>៦.កំពង់ចាម | ១.៣០០<br>១.២០០ |
| ៧. កំពង់ធំ | ៣៤.០០០ | ៧. កំពង់ធំ | ១.២០០ |
| ៨. តាកែវ | ២៨.០០០ | ៨. ព្រៃវែង | ១.១០០ |
| ៩. កំពង់ឆ្នាំង | ២៦.០០០ | ៩. ពោធិសាត់ | ១.១០០ |
| ១០. ពោធិសាត់ | ១៥.០០០ | ១០. ស្វាយរៀង | ១.១០០ |
| ១១. ក្រចេះ | ៥.០០០ | ១១. តាកែវ | ៩០០ |
| ១២. ស្ទឹងត្រែង | ៣.០០០ | ១២. ស្ទឹងត្រែង | ៥០០ |

*តារាងទិន្នន័យដំណាំស្រូវចន្លោះឆ្នាំ១៩១៩ ដល់ ឆ្នាំ១៩២២*

| ចំណាត់ថ្នាក់តំបន់ដាំដុះ | ទិន្នផល/ម្នាក់ (គ.ក) | ចំណាត់ថ្នាក់ផ្ទៃដីដាំដុះ | ផ្ទៃដីដាំដុះ/ផ្ទៃដីទាំងអស់(%) |
|---|---|---|---|
| ១. បាត់ដំបង | ៥០០ | ១. ស្វាយរៀង | ២១.៨% |
| ២. ស្វាយរៀង | ៥០០ | ២. ព្រៃវែង | ១១.២% |
| ៣. កំពង់ឆ្នាំង | ៣០០ | ៣. តាកែវ | ៦.៤% |
| ៤. ព្រៃវែង | ៣០០ | ៤. កំពង់ចាម | ៥.៨% |
| ៥. ពោធិសាត់ | ៣០០ | ៥. កំពង់ឆ្នាំង | ៤.៦% |
| ៦. កំពង់ធំ | ៣០០ | ៦. កណ្តាល និងកំពង់ស្ពឺ | ៤.២% |
| ៧. កំពត | ២០០ | | |
| ៨. កំពង់ចាម | ២០០ | ៧. បាត់ដំបង | ៤.២% |
| ៩. កណ្តាល និងកំពង់ស្ពឺ | ១៥០ | ៨. កំពត<br>៩. កំពង់ធំ | ៣.២%<br>១.៤% |
| ១០. ក្រចេះ | ១០០ | ១០. ពោធិសាត់ | ១.២% |
| ១១. ស្ទឹងត្រែង | ១០០ | ១១. ក្រចេះ | ០.២% |
| ១២. តាកែវ | ១០០ | ១២. ស្ទឹងត្រែង | ០.១% |

*ទិន្នផលស្រូវសម្រាប់ពលរដ្ឋម្នាក់ៗ និងផ្ទៃដីដាំដុះ/ ផ្ទៃដីទាំងអស់*

តាមការ ដំណាំស្រូវនៅប្រទេសកម្ពុជា មានប្រហែលជា ៣០០.០០០ ហិកតា។ លុះនៅឆ្នាំ ១៩២១ ទំហំផ្ទៃដីដាំដុះសម្រាប់ដំណាំស្រូវ ត្រូវបានពង្រីក រហូតដល់ជិត ៥០០.០០០ ហិកតា។ នៅឆ្នាំ១៩២៧ ផ្ទៃដីដំណាំស្រូវត្រូវ បានពង្រីកប្រមាណជិតពីរដង គឺ ៩០០,០០០ ហិកតា។ ក៏ប៉ុន្តែទោះបីមានការខិតខំពង្រីកផ្ទៃដីលើដំណាំស្រវយ៉ាងណាក្តី ក៏ផលដំណាំស្រូវ ក្នុងសម័យអាណានិគម មិនសូវមានការរីកចម្រើនឡើយ ហើយក្នុងមួយ ហិកតា បានផលស្រវប្រមាណពី ១តោន ទៅ ១.២ តោន ប៉ុណ្ណោះ។ តាមទិន្នន័យខាងលើនេះ ផលិតផលស្រវដែលយើងទទួលបាននាសម័យនោះ ស្មើនឹង ១.០៨០.០០០ តោនក្នុងឆ្នាំនោះ។ ដំណាំស្រូវដែលសម្បូរ ជាងគេ មាននៅខេត្តបាត់ដំបង ខេត្តស្វាយរៀង និងខេត្តព្រៃវែង។

## ការចិញ្ចឹមសត្វ

សិក្សាស្រាវជ្រាវ នៅឆ្នាំ១៩០៤ ទំហំផ្ទៃដីដាំដុះនៅសម័យអាណានិគមនិយមបារាំង ការចិញ្ចឹមសត្វពាហនៈ និងសត្វស្លាបជាផ្នែកមួយយ៉ាងសម្ខាន់នៃវិស័យសេដ្ឋកិច្ចជនបទនៅប្រទេសកម្ពុជា។ កសិករខ្មែរយើង ចិញ្ចឹមសត្វស្រុកសម្រាប់ប្រើប្រាស់ជាអាហារផង និងជាកំលាំងអូសទាញចាំបាច់បម្រើអោយវិស័យកសិកម្ម និងការដឹកជញ្ជូនផលិតផល។ ការចិញ្ចឹមសត្វ បានធ្វើអោយកសិករខ្មែរ ទទួលបានប្រាក់កម្រៃមួយចំនួនទៀត តាមរយៈការលក់ក្នុងស្រុក និងការនាំចេញទៅលក់នៅឯប្រទេសក្នុងតំបន់ឥណ្ឌូចិន និងហ្វីលីពីន។ តាមការស្រាវជ្រាវប្រជាជនខ្មែរសម័យនោះ ចិញ្ចឹមសត្វពាហនៈ សម្រាប់តែប្រើប្រាស់ក្នុងវិស័យកសិកម្ម និងធ្វើជាមធ្យោបាយដឹកជញ្ជូនហើយមិនសូវប្រើប្រាស់សាច់សត្វពាហនៈធ្វើជាអាហារនោះទេ។ ជាទូទៅក្នុងឱកាសនៃពិធីបុណ្យផ្សេងៗ ឬពិធីមង្គលការ កសិករខ្មែរនិយមប្រើប្រាស់សាច់បក្សីដូចជា សាច់មាន់ ទា ក្ងាន ឬប្រើសាច់ជ្រូកដែលបានចិញ្ចឹមស្ទើរគ្រប់ផ្ទះសម្រាប់ធ្វើជាម្ហូបអាហារ។ ម្យ៉ាងទៀត សត្វគោ ឬក្របី គឺជាទ្រព្យសម្បត្តិដ៏ថ្លៃថ្លារបស់កសិករខ្មែរនាសម័យកាលនោះ។ សត្វពាហនៈ មានសារៈសំខាន់ចំពោះការងារស្រែចំការ ហើយមានតម្លៃថ្លៃនៅលើទីផ្សារបើគិតជាមធ្យមក្របីមួយមានតម្លៃប្រហែលជា ៥០រៀល (ឬ ៥០ Piastress រូបិយវត្ថុឥណ្ឌូចិន) ដែលសមមូលទៅនឹង ១០០ ថ្ងៃ ទៅ ២០០ថ្ងៃ នៃតម្លៃពលកម្មរបស់កសិករធម្មតាម្នាក់ (គឺប្រហែល ០,២ រៀលទៅ ០,៥ រៀល ប៉ុណ្ណោះ/ថ្ងៃ)។[93] សត្វពាហនៈគេអាចជួល ក្នុងតម្លៃស្រូវ ៦០០គ.ក ក្នុងគោមួយនឹម ឬ ៩០០គ.ក ក្នុងក្របីមួយនឹម នារដូវធ្វើស្រែ។ ប៉ុន្តែបញ្ហានេះមិនសូវទូលំទូលាយទេ លើកលែងតែពេលណា ដែលមានរោគរាត្បាតដល់សត្វចិញ្ចឹមទាំងអស់នោះប៉ុណ្ណោះ។

បើយើងពិនិត្យមើលតាមរយៈទំព័រប្រវត្តិសាស្ត្រនៃការចិញ្ចឹមសត្វពាហនៈនៅប្រទេសកម្ពុជាតាំងពីដើមដំបូងនាពេលដែលបារាំងបានចូលមកកាន់កាប់ យើងឃើញថា វាមិនបានបង្ហាញនូវស្ថានភាពគាប់ប្រសើរប៉ុន្មាននោះទេ។ ដូចជានៅឆ្នាំ ១៨៩៧ រហូតដល់ឆ្នាំ ១៩១៣ ត្រូវ បានកត់សម្គាល់ថាមានការលេចឡើងនូវរោគរាត្បាតយ៉ាងធ្ងន់ធ្ងរចំពោះសត្វពាហនៈ និងបានរីករាលដាលស្ទើរគ្រប់តំបន់នៃប្រទេស។ ជាក់ស្តែង នៅឆ្នាំ ១៨៩៨ នៅតំបន់ភ្នំពេញ រោគរាត្បាតបានឆក់យកជីវិតសត្វគោចំនួន ៦៦១ ក្បាល និងក្របី ២២៧ ក្បាល។ ក្នុងឆ្នាំដដែលនេះដែរ នៅខេត្តព្រៃវែងរោគរាត្បាតបានសម្លាប់សត្វគោប្រមាណ ៩០៤ ក្បាល ក្របី ២១៥ ក្បាល និងសេះចំនួន ២៥ក្បាល។ ឆ្នាំ ១៩០០ នៅខេត្ត

កំពត មានសត្វស្លាបស្លាប់ប្រហែល១៧០ ក្បាល តែក្នុងរយៈពេល១ខែ ប៉ុណ្ណោះ។ បន្ទាប់មកនៅឆ្នាំ ១៩០៨ ក្នុងខែសីហា នាស្រុកគងពិសី (កំពង់ស្ពឺ) មានមេគោស្លាប់ចំនួន ៣៣៧ ក្បាល។ ចាប់ពី ខែកក្កដាឆ្នាំ ១៩១០ ដល់ខែកក្កដា ឆ្នាំ ១៩១១ បានរកឃើញថា ជម្ងឺរាត្បាតបាន សម្លាប់សត្វក្របីចំនួន ១៥០០ ក្បាលនៅខេត្តបាត់ដំបង។ គ្រាន់តែនៅ ក្នុងត្រីមាសទី២ ឆ្នាំ ១៩១៣ នៅខេត្តកំពង់ចាម ក្របីបានស្លាប់ចំនួន ៩១៣ ក្បាល។ សរុបមក បញ្ហាទាំងអស់នេះបានផ្តល់ផលប៉ះពាល់យ៉ាង ខ្លាំងដល់វិស័យចិញ្ចឹមសត្វ និងសេដ្ឋកិច្ចជនបទរបស់ប្រជាជនខ្មែរ នាសម័យកាលនោះ ដែលមិនអាចធ្វើអោយអាណាព្យាបាលបារាំងឈរ នៅស្ងៀមបានឡើយ។

ឆ្លើយតបទៅនឹងហេតុការណ៍ដ៏អាក្រក់នេះ រដ្ឋបាលអាណានិគមនិយមបារាំងបានស្ទុះស្ទារដាក់ចេញនូវវិធានការណ៍ដ៏មានប្រសិទ្ធភាព ចុះជួយព្យាបាល ចាក់វ៉ាក់សាំងបង្ការការពាររោគរាត្បាត ដែលបានយាយីដល់អាយុជីវិតសត្វពាហនៈ។ ជាងនេះទៀតអាណាព្យាបាលបារាំង ក៏បានជួយពង្រឹងឡើងវិញ នូវវិស័យចិញ្ចឹមសត្វស្រុកផងដែរ។ ទាំងនេះជាទង្វើវិជ្ជមានដ៏កម្រមួយនៃកិច្ចការរបស់អាណាព្យាបាលអាណាគម។ ហើយជាលទ្ធផល យើងឃើញថាក្រោយឆ្នាំ ១៩១៣ ជម្ងឺរាត្បាតនានា ចំពោះសត្វពាហនៈ មានការថយចុះយ៉ាងគំហុក ហើយគេស្ទើរតែមិនដែលឮអំពីការស្លាប់ដោយសារជម្ងឺរបស់សត្វនោះទេ។ ជាងនេះទៀត ផ្អែកលើឯកសារដែលផ្តល់ដោយលោក J.Delvert (១៩៥៥) បានអះអាងថា ការរីកចម្រើនពិតប្រាកដនៃវិស័យចិញ្ចឹមសត្វនាសម័យបារាំង គឺចាប់តាំងពីឆ្នាំ ១៩១០ ដល់ឆ្នាំ១៩២០

[93] ១ plastres (ជារូបិយវត្ថុឥណ្ឌូចិន) គឺស្មើនឹង ១រៀល ឬស្មើនឹង ១ដុង ឬស្មើនឹង១ឯកតារូបបិយវត្ថុ របស់ឡាវ។

ហើយមានស្ថេរភាពរហូតមក ដោយសារតែការការពារថែទាំ អនុវត្តបានត្រឹមត្រូវផ្នែកបសុព្យាបាល។[94] ជាភស្តុតាង យើងអាចធ្វើការប្រៀបធៀបទិន្នន័យ នៃការចិញ្ចឹមសត្វពាហនៈរបស់កសិករខ្មែរ ជាមួយនឹងកសិករនៅក្នុងបណ្តាប្រទេស ឥណ្ឌូចិន ក្នុងឆ្នាំ ១៩២២ មានដូចខាងក្រោម៖

| បរិយាយ | គោ | ក្របី | ជ្រូក | សេះ |
|---|---|---|---|---|
| កម្ពុជា | ៨២៧.០០០ | ៥៥៣.០០០ | ៦០០.០០០ | ៤០.០០០ |
| អាណាម | ៣៣៨.០០០ | ២៣៥.០០០ | ៣៩១.០០០ | ២០.០០០ |
| កូសាំងស៊ីន | ៤១០.០០០ | ? | ៣៩០.០០០ | ១៣.០០០ |
| តុងកឹង | ១៩៧.០០០ | ៣៨០.០០០ | ៨៦៥.០០០ | ២១.០០០ |
| លាវ | ៥៦៨.០០០ | ? | ២២៥.០០០ | ១០.០០០ |

*តារាងប្រៀបធៀបទិន្នន័យស្ថិតិសត្វពាហនៈ ឆ្នាំ១៩២២*

តាមខ្លឹមសារនៃតារាងខាងលើបង្ហាញថា ប្រទេសកម្ពុជាមានប្រៀបលើបណ្តាប្រទេសនៅឥណ្ឌូចិន ក្នុងវិស័យចិញ្ចឹមសត្វពាហនៈ។ ជាពិសេស លើការចិញ្ចឹមសត្វគោ ក្របី និងសេះ ដែលជាអត្រាទិន្នន័យ មួយគួរអោយមោទនៈ ចំពោះកសិករខ្មែរក្នុងសម័យកាលនោះ។

ដើម្បីធ្វើការអះអាងបន្ថែមទៀត យើងអាចពិនិត្យមើលទៅលើ ការប្រៀបធៀបចំនួនសត្វពាហនៈ ដែលកសិករខ្មែរបានចិញ្ចឹមធៀបទៅនឹងចំនួនប្រជាពលរដ្ឋ ក្នុងឆ្នាំ ១៩២២ នៅតាមភូមិសាស្ត្រនៃខេត្តនានា ដូចខាងក្រោមនេះ៖

| **បរិយាយ** | **ចំនួនប្រជាពលរដ្ឋ/ឯកតា សត្វពាហនៈ** |
|---|---|
| **១. ស្ទឹងត្រែង** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ២.៤ នាក់ |
| **២. កំពង់ចាម** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ២.៣ នាក់ |
| **៣. ក្រចេះ** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ២.២ នាក់ |
| **៤. ស្វាយរៀង** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ២ នាក់ |
| **៥. កណ្តាល** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៩ នាក់ |
| **៦. ព្រៃវែង** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៩ នាក់ |
| **៧. ពោធិសាត់** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៨ នាក់ |
| **៨. កំពត** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៦ នាក់ |
| **៩. កំពង់ធំ** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៥ នាក់ |
| **១០. តាកែវ** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៥ នាក់ |
| **១១. កំពង់ឆ្នាំង** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៤ នាក់ |
| **១២. បាត់ដំបង** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៣ នាក់ |

យោងតាមតារាងខាងលើនេះ ខេត្តដែលមានសន្ទស្សន៍ការញ្ចឹមសត្វពាហនៈខ្ពស់ជាងគេនោះរួមមាន ខេត្តបាត់ដំបង កំពង់ឆ្នាំង តាកែវ កំពង់ធំ និងកំពត។ ប៉ុន្តែស្ថានភាពនៃសន្ទស្សន៍ការចិញ្ចឹមសត្វ មានការប្រែប្រួលទៅតាមបណ្តាឆ្នាំខុសៗគ្នា ហើយមាននិន្នាការប្រសើរ ឡើងក្រោយឆ្នាំ ១៩១៣ បន្ទាប់ពីអាណាព្យាបាលបារាំង បានធ្វើការយកចិត្តទុកដាក់លើវិស័យនេះ។ យើងមានតារាងទិន្នន័យស្តីអំពី

សន្ទស្សន៍នៃការចិញ្ចឹមសត្វពាហនៈ នៅប្រទេសកម្ពុជាតាមបណ្តាឆ្នាំផ្សេងៗគ្នា ដូច ខាងក្រោមនេះ៖

| **បរិយាយ** | **ចំនួនប្រជាពលរដ្ឋ/ឯកតា សត្វពាហន(ប៉ាន់ស្មាន)** |
|---|---|
| **ឆ្នាំ ១៩០៤** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ២.៤ នាក់ |
| **ឆ្នាំ ១៩១១** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ២.១ នាក់ |
| **ឆ្នាំ ១៩១៤** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៨ នាក់ |
| **ឆ្នាំ ១៩១៦** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១.៦ នាក់ |
| **ឆ្នាំ ១៩១៨** | សត្វពាហនៈ១ក្បាលសម្រាប់ប្រជាពលរដ្ឋ ១ នាក់ |

*ការប្រៀបធៀបសន្ទស្សន៍ការចិញ្ចឹមសត្វពាហនៈចន្លោះឆ្នាំ ១៩០៤ ដល់ឆ្នាំ ១៩១៨*

តាមឯកសារដដែល រហូតដល់ឆ្នាំ ១៩២២ នៅប្រទេសកម្ពុជា អត្រាកំណើននៃការចិញ្ចឹមសត្វពាហនៈ មានការកើនឡើងគួរអោយកត់សម្គាល់ ក្នុងនោះការចិញ្ចឹមសត្វគោបានកើនឡើង ៦០% និងក្របី ៤០%។

### ដំណាំម្រេច

ដំណាំម្រេច ជាបាតុភូតថ្មីនៃដំណាំឧស្សាហកម្មរបស់ខ្មែរក្នុង សម័យអាណានិគមនិយមបារាំង។ ដំណាំនេះបានចូលមកដល់ប្រទេសកម្ពុជានៅចុងសតវត្សទី១៩ ហើយហេតុផលសំខាន់ៗដែលធ្វើអោយ ដំណាំម្រេចមានវត្តមាន និងសន្ទុះខ្លាំងក្លានោះ គឺបណ្តាលមកពីមូលហេតុ ២យ៉ាងដូចខាងក្រោម ៖

ទីមួយ៖ បញ្ហាសង្គ្រាមនៅចក្រភពអាច៉ប់ជាមួយពួកអាណានិគម ពេលនោះស្តេច Sultan Atjeh (១៨៧៣-១៩០៨) បានបញ្ជាអោយដុតចំការម្រេចចោលទាំងអស់នៅឆ្នាំ ១៨៧៣ ដល់ឆ្នាំ ១៨៧៤ ដើម្បីកុំអោយភោគទ្រព្យទាំងនេះ ធ្លាក់ចូលទៅក្នុងដៃសត្រូវរបស់ខ្លួន គឺពួកហូឡង់។ តាមឯកសាររបស់លោក Auguste Pavie ក្នុងឆ្នាំ ១៨៧៨ ចំការម្រេចជាច្រើនត្រូវបានគេដាក់គ្រាប់បំផ្ទុះកំទេចចោលគិតជាបរិមាណ ប្រហែល ៥០០ តោន ដែលត្រូវបានគេបំផ្លាញចោល។ ម្យ៉ាងទៀត ការរីករាលដាលនៃការបះបោរនៅអាច៉ប់ប្រឆាំងនឹងពួកអាណានិគម ក្នុងឆ្នាំ១៨៨៥-១៨៨៦ បានធ្វើអោយម្ចាស់កសិដ្ឋានដំណាំម្រេចភាគច្រើនបានបោះបង់ចោល ហើយដើមម្រេចជាច្រើនបានខូចខាត ដោយសារគ្មានការថែទាំត្រឹមត្រូវ។ ហេតុការណ៍នេះធ្វើអោយផលិតផលម្រេចនៅ លើពិភពលោក មានការខ្វះខាតតម្រូវអោយប្រទេសនាំចូលម្រេច ស្វែងរកប្រភពផ្គត់ផ្គង់ថ្មីៗទៀតដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន។

ទីពីរ៖ ឆ្លើយតបនឹងព្រឹត្តិការណ៍នេះ អាណាព្យាបាលបារាំងបានប្រញាប់ប្រញាល់ដាក់ចេញនូវច្បាប់មួយ ប្រកាសអោយប្រើប្រាស់នៅថ្ងៃ ១១ ខែមករា ឆ្នាំ១៨៩២ ស្តីពីការជម្រុញ និងតម្រង់ទិសចំពោះផលិតកម្ម ដំណាំម្រេច ទៅរកទីផ្សារប្រទេសដែលស្ថិត នៅក្រោមអាណានិគមរបស់ខ្លួន។ [95]

ដោយមានគោលនយោបាយគាំទ្រ លើកស្ទួយដំណាំម្រេច ពីអាណាព្យាបាលបារាំង ជាមួយនឹងលក្ខខណ្ឌប្រកបនៃទីផ្សារផងដែរនោះ កសិករខ្មែរបានចាប់ផ្តើមប្រកបរបរដាំម្រេច ពិសេសនៅតំបន់កូនភ្នំទឹកដីខេត្តកំពត តំបន់កំពង់ត្រាច និងតំបន់៣ម។ គិតត្រឹមឆ្នាំ ១៨៩៦ ដំណាំម្រេចបានដាំក្នុងបរិមាណរហូតដល់ ៧១.០០០គុម្ព ដែលម្ចាស់ចំការភាគ ច្រើនជាជនអន្តោប្រវេសន៍ចិនហៃណាំ។ ម្រេចខ្មែរពេលនោះងាយនឹង រកទិញក្នុងតម្លៃទាបជាងតម្លៃទីផ្សារនៅប្រទេសកូសាំងស៊ីន។ ការពង្រាតដីដាំម្រេច បានបំពេញសេចក្តីត្រូវការរបស់ប្រទេសបារាំង បានយ៉ាងលឿន និងលើសពីសេចក្តីត្រូវការផងព្រោះម្រេចមិនសូវមានការ ប្រកួតប្រជែងនៅលើទីផ្សារពិភពលោក ម្យ៉ាងទៀតដោយសារតែរបាំងពន្ធគយនាំចូលទៅស្រុកបារាំង សម្រាប់បរទេសមានតម្លៃខ្ពស់ជាងពីរដងនៃការនាំចូលមកពីបណ្តាប្រទេសក្រោមអាណានិគម ពោលគឺច្បាប់ពន្ធបារាំង កំណត់យកតែ ១០៤ ហ្វ្រង់ ប៉ុណ្ណោះ/១០០គ.ក ប៉ុន្តែបើមកពី ប្រទេសផ្សេងៗគឺ ២០០ ហ្វ្រង់/១០០គ.ក។ វិធានការនេះ បានធ្វើអោយកសិករពេញចិត្ត ហើយបានពង្រីកការដាំដុះតាំងពីពេលនោះមក។

ក៏ប៉ុន្តែរយៈពេល ១០ ឆ្នាំ ក្រោយមក ដោយសារទំហំផលិតកម្ម ម្រេចពីប្រទេសក្រោមអាណានិគមកើនឡើងក្នុងល្បឿនលឿនពេកធ្វើអោយសន្និធិម្រេច ក្នុងឃ្លាំងនៅប្រទេសបារាំង សល់លើសពីសេចក្តីត្រូវការ ចំនួនពីរដង ដែលធ្វើអោយតម្លៃមានការដែលមុនឆ្នាំ ១៩០០ ហាងឆេងម្រេច ១គ.កតម្លៃ ១,១៥ រៀល (១,១៥ Piastre) នៅឆ្នាំ ១៩០២ ដល់ ១៩០៥ ម្រេចបានធ្លាក់តម្លៃនៅត្រឹមតែ ០,៧២ រៀល/គ.កហើយបន្តធ្លាក់ចុះទៀតនៅឆ្នាំ១៩០៧រហូតដល់តម្លៃទាបបំផុតគឺ០,៣៦រៀល/គ.ក។

ហេតុការណ៍នៃវិបត្តិម្រេចនេះបានធ្វើអោយ កសិករចិនដាំម្រេចតូចតាចជួបការលំបាក និងជំពាក់បំណុលគេ ហើយកសិករភាគច្រើនបានលក់ចំការម្រេចទៅអោយអ្នកមានចំការធំៗ ព្រោះតែខ្វះមធ្យោបាយដែលប្រសើរជាងនេះ។ រីឯកសិករខ្លះទៀត បានសាកល្បងនាំគ្នាស្វែងរកទីផ្សារនាំចេញម្រេចទៅលក់នៅប្រទេសផ្សេងទៀត ដូចជាទៅប្រទេសសឹង្ហបុរី ប្រទេសថៃ និងប្រទេសនៅអឺរ៉ុប ប៉ុន្តែយើងឃើញថា ការប្រឹងប្រែងរបស់ពួកគេគឺមិនបានសម្រេចសមតាមបំណងឡើយ ដោយសារតែផលិតករម្រេចទាំងនោះមានទំនាស់នឹងគ្នា ខ្វះការឯកភាព ភាគច្រើនជំពាក់បំណុលគេ។ ចំពោះហាងឆេងម្រេច នៅសាខាពាណិជ្ជកម្មធំៗ នៅកូសាំងស៊ីន កំណត់តម្លៃម្រេចក្នុងតម្លៃថោក បើកសិករមិនយល់ព្រមលក់ម្រេចទៅអោយបារាំងទេ បារាំងអាច គៀបសង្កត់លើផលិតករខ្មែរ តាមរយៈតារាងតម្លើងពន្ធនាំចេញថ្មីដែលមានតម្លៃខ្ពស់។ ហេតុនេះចង់ ឬមិនចង់ ប្រទេសបារាំងនៅតែជាកន្លែងដែលត្រូវនាំចេញយ៉ាងសំខាន់ ក្រៅពីប្រទេសបារាំង ម្រេចមិនអាចនាំចេញក្រៅទៅបានទេ ចំណែកចំការម្រេចនៅកម្ពុជា ពីមួយថ្ងៃទៅមួយថ្ងៃ ចេះតែបន្តការជំពាក់ និងផ្តល់ផលច្រើន។ ចំពោះអ្នកដែលទ្រាំតស៊ូ ចំពោះវិបត្តិនេះនិងអ្នកទើបតែបានដាំដំណាំនេះ ក៏បានបោះបង់ចោលទៅអោយម្ចាស់បំណុល។ កម្មករត្រូវបានបណ្តេញចេញ និងត្រូវគេមើល ងាយ។

95 ផៃ ប៉េងស៊ីម, ទិន្នន័យសរុបនៃសេដ្ឋកិច្ចកម្ពុជា, (បកប្រែពីភាសាបារាំង), ភ្នំពេញ,ឆ្នាំ ២០០៤,ទំព័រ ៣៣-៣៤

យោងតាមការស្រាវជ្រាវវិបត្តិដំណាំម្រេចនៅប្រទេសកម្ពុជា បានទទួលរងនូវវិបត្តិធ្ងន់ធ្ងរ នៅក្នុងចន្លោះឆ្នាំ ១៩០២-១៩០៥ និងឆ្នាំ ១៩០៧- ១៩០៩ ហើយស្របពេលជាមួយគ្នានោះ បរិមាណនៃការដាំដុះ ក៏បានកើនដល់កម្រិតកំពូលគឺ ៣លានគុម្ព (ឆ្នាំ១៩០៥) បើគិតក្នុងមាត្រដ្ឋានដំណាំម្រេចបច្ចុប្បន្ន មានប្រមាណជា ១២០០ ហ.ត ។ ពេលវេលាក្រោយមក ជំនោរនៃការដាំម្រេច ត្រូវបានកើតឡើងសាជាថ្មី ដោយសារនៅខែធ្នូ ឆ្នាំ ១៩០៩ រដ្ឋាភិបាលអាណានិគមបារាំងបានចេញច្បាប់ពន្ធថ្មីមួយទៀត ស្តីពីការបន្ថយពន្ធនាំចូលម្រេចទៅប្រទេសបារាំង ដែលពេលនោះដែរបារាំងបានកំណត់បរិមាណនាំចូលពីតំបន់កូសាំងស៊ីនប្រមាណ ៥០០ តោន/ឆ្នាំ ហើយប្រទេសកម្ពុជា២០០០តោន/ឆ្នាំ។ សភាពការណ៍នេះ បានធ្វើអោយមានភាពធូរស្រាល បន្តិចចំពោះកសិករដាំម្រេច ប៉ុន្តែអ្នកដែលទន់ខ្សោយត្រូវបានបាត់បង់ឱកាសរួចទៅហើយ រីឯអ្នកដែលឈ្លាសវៃ ទទួលបានអាជ្ញាប័ណ្ណបញ្ចុះពន្ធ ក្នុងការនាំចេញទៅប្រទេសបារាំង ចេញដោយអង្គភាពគយ និងរដ្ឋាករ ដែលជាកម្មវត្ថុនៃអំពើពុករលួយហួសហេតុ និងអយុត្តិធម៌ សម្រាប់កសិករសាមញ្ញនាសម័យកាលនោះ។ និយាយជារួម អ្នកដែលជោគជ័យ ជាអ្នកដែលត្រូវបានរក្សាការពារដោយពាណិជ្ជករនៅព្រៃនគរ ក្រោមឥទ្ធិពលនៃរដ្ឋអំណាចកូសាំងស៊ីនដដែល។

មួយរយៈកាលក្រោយមក រហូតដល់ឆ្នាំ ១៩១៦-១៩១៧ តម្លៃម្រេចត្រូវបានកើនឡើងវិញរហូតដល់ ០,៩ រៀល/គ.ក ទៅ ១,២រៀល/គ.ក។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ១៩១៧-១៩២០ ដោយសារតែតម្លៃប្រាក់រៀលឡើងថ្លៃខ្លាំង ធៀបទៅនឹងលុយហ្វ្រង់ ម្យ៉ាងទៀតគ្រោះរាំងស្ងួតបានកើនឡើងពីឆ្នាំជាប់ៗគ្នា ហើយទំហំទីផ្សារម្រេចនៅបារាំងមានដែនកំណត់ បណ្តាលអោយកសិករបោះបង់ចំការម្រេចចោលមួយចំនួនទៀត។ បើយើងពិនិត្យមើលចំនួនដើមម្រេចដែលបានដាំនៅឆ្នាំ

១៩០៥ មានរហូតដល់ ៣លាន ជ្រលង់ ប៉ុន្តែនៅចន្លោះឆ្នាំ ១៩១៧-១៩២០ បានថយចុះមកនៅត្រឹមតែ ២លាន ជ្រលង់ប៉ុណ្ណោះ គឺថយចុះពី ១.២០០ ហ.ត មកនៅត្រឹម ៨០០ ហ.ត។ [96]

សរុបមក បញ្ហាវិបត្តិស្មុគស្មាញដែលបានកើតឡើងគួរអោយឈឺចាប់សម្រាប់កសិករខ្មែរចំពោះដំណាំម្រេចនៅសម័យបារាំង គឺកើតឡើងដោយសារនយោបាយពន្ធគយរបស់បារាំងដែលមិនអនុញ្ញាតអោយមាន ទីផ្សារផ្សេងក្រៅពីប្រទេសបារាំង ព្រោះវាប្រឆាំងទៅនឹងផលប្រយោជន៍សេដ្ឋកិច្ចរបស់បារាំង។ រីឯបញ្ហាផ្សេងៗទៀតនោះគ្រាន់តែជារឿងបន្ទាប់បន្សំប៉ុណ្ណោះ។

**កប្បាស**

នៅដើមសតវត្សទី២០ គ្មានការសិក្សាណាមួយ និងប្រហែលជាគ្មានឯកសារណាមួយ ដែលចងក្រងពីលទ្ធភាពរបស់ប្រទេសកម្ពុជា ក្នុងការដាំដុះដំណាំកប្បាសនោះទេ។ ក្រោយឆ្នាំ១៨៩៧ អ្នកស្រាវជ្រាវបារាំង លោក Dumier បានកត់ត្រាអំពីដំណាំនេះ ព្រមទាំងលើកឡើងពីបញ្ហានានាដែលកើតឡើង ក៏ដូចជាភាពល្បីល្បាញ និងពេញនិយមនូវសំឡីកប្បាសរបស់ខ្មែរយើងទៀតផង នៅក្នុងទីផ្សារមជ្ឈិមបូព៌ា និង ប្រទេសជប៉ុន។

តំបន់ដំណាំកប្បាសសម្ខាន់ៗនៅប្រទេសកម្ពុជានាសម័យនោះគឺស្ថិតនៅតាមបណ្តោយជួរមាត់ទន្លេមេគង្គលើ ក្នុងមណ្ឌលនៃខេត្តក្រចេះ ស្ទឹងត្រែង និងតំបន់ត្បូងឃ្មុំ ដែលមានចំនួន ១/៤ នៃផលិតកម្ម សំឡីកប្បាសទាំងអស់។ នៅខេត្តកំពង់ចាម តំបន់ដាំកប្បាសមាននៅស្រុកមុខកំពូល (បច្ចុប្បន្នខេត្តកណ្តាល) ស្រុកខ្សាច់កណ្តាល (បច្ចុប្បន្ន ខេត្តកណ្តាល) ស្រីសន្ធរ និងស្រុកកំពង់សៀម។ គេដាំកប្បាសនៅស្រុកល្វាឯម ដែលជាចំការធំៗ មានទទឹងពី ១០០ ទៅ ៦០០ម៉ែត្រ និងបណ្តោយរហូតដល់ ៣០ គ.ម។ ដំណាំកប្បាសមានដាំនៅតាមជួរមាត់ ទន្លេផ្សេងៗទៀតដែលមានទំហំល្មម។ ដូចជានៅខេត្តកណ្តាល តាកែវ នៅមណ្ឌលលើកដែក ក្នុងដីទំនាបដែលបានចាក់លុបក្នុងឆ្នាំ ១៩០៦-១៩០៨។

តាមការសិក្សាពីចង្វាក់ផលិតកម្មដំណាំកប្បាសនេះ បានបង្ហាញថា ដំណាំកប្បាសត្រូវបានកសិករខ្មែរ ចាប់ផ្តើមដាំនៅខែសីហា និងកញ្ញា តាមជួរមាត់ទន្លេមេគង្គលើ ពេលដែលទឹកទន្លេចាប់ផ្តើមស្រកចុះ ហើយចេញផ្កានៅខែកុម្ភៈ និងត្រូវប្រមូលផលនៅខែមិនា និងឧសភា។

តាមកំណត់ត្រារបស់លោក Dumier ផលិតផលកប្បាស ងាយស្រួលទិញណាស់នៅលើទីផ្សារអាស៊ីពិសេសនៅប្រទេសជប៉ុន ដែលជាកន្លែងនាំកប្បាសទៅលក់ដោយឈ្មួញកណ្តាលពាណិជ្ជករចិននៅទីក្រុងហុងកុង។ សម័យនោះ កប្បាសដុល និងកប្បាសមិនទាន់ប្រឡេះគ្រាប់ ត្រូវបាននាំចេញទៅលក់នៅទីផ្សារហុងកុង។ សេចក្តីត្រូវការវត្ថុធាតុដើមកសិកម្មដំណាំកប្បាសនេះកើតមានតាំងពីឆ្នាំ ១៨៩៦-១៩០០ ដែលញ៉ាំងអោយកសិករខ្មែរក្នុងគ្រានោះ ធ្វើការដាំដុះ និងមានការរីកលូត លាស់គួរអោយកត់សម្គាល់ រហូតដល់ឆ្នាំ ១៩០៥។ ចំពោះការប្រមូលផលកប្បាសរបស់ប្រទេសកម្ពុជា មានចំនួនប្រហែល ១.៥០០ តោន នៅ ឆ្នាំ ១៨៩១ និងប្រហែលជា ៤.០០០ តោន នៅឆ្នាំ ១៩០៤ និងលើសពី ៥.០០០ តោននៅឆ្នាំ១៩០៥។ នៅសម័យកាលនោះ ក្នុងខេត្តកំពង់ចាម ដំណាំកប្បាស គេ

អាចទទួលផលបានប្រហែលជា ៧០ គ.ក/ហិកតា នៅឆ្នាំ ១៩០២ និងជិត ៤០០ គ.ក/ហិកតា នៅឆ្នាំ ១៩០៦ និងកើន ដល់ជាង ៥៣០ គ.ក/ហិកតា នៅឆ្នាំ ១៩០៨។ [97]

ក្រោយឆ្នាំ ១៩០៧ ដំណាំកប្បាសនៅប្រទេសកម្ពុជាហាក់ដូច ជាស្ថិតនៅក្នុងស្ថានភាពទ្រឹង គ្មានការរីកដុះដាលទាំងផ្នែកផ្ទៃដី និងទាំងបរិមាណទិន្នផល។ ភាពនៅទ្រឹងរបស់ដំណាំកប្បាស បណ្ដាមកពីការកំណត់ និងការរក្សាអត្រាពន្ធនាំចេញរបស់រដ្ឋបាលអាណានិគមអោយមានតម្លៃខ្ពស់ ចំពោះផលិតផលនេះ ដែលធ្វើអោយតម្លៃកប្បាសឡើងថ្លៃ ពិបាកប្រកួតប្រជែងនៅលើទីផ្សារបរទេស។ ទង្វើនយោបាយពន្ធបែបនេះ បានបង្កលក្ខណៈដ៏ប្រសើរចំពោះប្រទេសឧស្សាហកម្មកប្បាស ដែលមិនស្ថិតនៅក្រោមអាណានិគមនិយមបារាំងទៅវិញ។

យោងតាមឯកសារលោក Dumier នៅឆ្នាំ ១៩១២ អត្រាពន្ធនាំចេញផលិតផលកប្បាសដែលមានតម្លៃស្មើនឹង ២ ហ្វ្រង់/១០០ គ.ក ហើយសំឡីកប្បាសដែលប្រឡះគ្រាប់ហើយ ត្រូវបានបង់ពន្ធនាំចេញស្មើនឹង ៣ ហ្វ្រង់/១០០ គ.ក ដែលតម្លៃពន្ធគយនេះ គឺស្មើនឹងជិត ១០% នៃតម្លៃរបស់សំឡីកប្បាសគិតជាមធ្យម។ ហើយអត្រានេះ ជានិច្ចកាលបារាំងបដិសេធមិនអោយបញ្ចុះថ្លៃទេ ព្រោះប្រឆាំងនឹងផលប្រយោជន៍ នៃសេដ្ឋកិច្ចបារាំង។ មូលហេតុផ្សេងទៀត ភាពនៅទ្រឹងរបស់ដំណាំ កប្បាសនៅដំណាក់នោះ បណ្ដាលមកពីទីផ្សារនាំចេញមានភាពតូចចង្អៀត គឺសង្ឃឹមតែទៅលើទីផ្សារប្រទេសបារាំងតែប៉ុណ្ណោះ។ ជាក់ស្ដែង ក្នុងឆ្នាំ ១៩០៦ ប្រទេសកម្ពុជាបាននាំចេញកប្បាសទៅប្រទេសបារាំង ចំនួន ៦៥៩ តោន និងឆ្នាំ ១៩០៧ បាននាំចេញចំនួន ៣៦០ តោន ប៉ុណ្ណោះ។ ចំពោះការប្រឹងប្រែងរកកន្លែងនាំចេញផ្សេងៗទៀតមានការប៉ះទង្គិចគ្នា និងជាប់របាំងពន្ធគយរបស់បារាំង ជាហេតុធ្វើអោយបាត់បង់ឱកាសក្នុងការតម្រង់ទិសឆ្ពោះទៅរកទីផ្សារខាងក្រៅ។

[97] ផៃ ប៉េងស៊ីម, ទិន្នន័យសរុបនៃសេដ្ឋកិច្ចកម្ពុជា (បកប្រែពីភាសាបារាំង), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ៣៨

សរុបមក ហេតុដែលបារាំងមិនអនុញ្ញាតអោយ ដំណាំកប្បាសនៅស្រុកខ្មែរ មានការរីកលូតលាស់ទៅបាន អាចបណ្ដាមកពីកង្វះផលប្រយោជន៍ដល់ឧស្សាហកម្មវាយណភ័ណ្ឌរបស់បារាំង ដែលធ្វើអោយបារាំងស្ទាក់ស្ទើរក្នុងការគិតគូរពិចារណា ដល់វិធានការអេតិ-ឧបត្ថម្ភនិយម ដែលចេញដោយប្រទេសបារាំងដូចករណីដំណាំម្រេច។ លើសពីនេះទៅទៀត បារាំងក៏មិនបានធ្វើសម្បទានដោយប្រយោលណាមួយ ដែលជួយទ្រទ្រង់អោយវិស័យនេះអាចរស់រានបាន និងមិនជួយតម្រង់ទិសទៅរកទីផ្សារបរទេស ដែលមានស្ថេរភាព និងតម្លៃសមរម្យ។ ប៉ុន្តែនៅពេលនេះយើងសប្បាយចិត្តនឹងទទួលយកនូវបទពិសោធន៍ និងរស់ជាតិ ពុតត្បូតអាក្រក់ និងរៀចរេ នៃទង្វើរបស់ម្ចាស់អាណានិគមដែលតែងតែធ្វើឡើងដោយចៀសមិនរួចនឹងគ្មានទីបញ្ចប់ ។ សមិទ្ធិផលទាំងអស់ ប្រព្រឹត្តទៅបានទេ ក្នុងលក្ខណៈសមិទ្ធិផលទាំងនោះ ជំទាស់ទៅនឹងផលប្រយោជន៍របស់បារាំង។ លើសពីនេះទៀត អត្រាសារពើពន្ធនៅប្រទេសឥណ្ឌូចិន បានបន្ថែមទម្ងន់ថែមទៀតទៅលើជីវភាពរស់នៅរបស់ប្រជាជនខ្មែរ ដែលធ្វើអោយយើងចុះខ្សោយ និងមានភាពក្រីក្រដោយចៀសមិនរួច។

## ដំណាំថ្នាំជក់

ដំណាំរុក្ខជាតិថ្នាំជក់ ជាដំណាំយ៉ាងសំខាន់មួយដែលប្រជនជនខ្មែរធ្លាប់បានដាំដុះតាំងពីសម័យដើមរៀងមក។ នៅសម័យអាណាព្យាបាលបារាំង ដំណាំថ្នាំជក់បានដាំនៅស្ទើរគ្រប់ទីកន្លែងនៃប្រទេស មានដូចជា នៅខេត្តកំពង់ចាម ក្នុងស្រុកកំពង់សៀម កោះសូទិន ស្រីសន្ធរ និងកងមាស។ នៅខេត្តកណ្តាល ដំណាំថ្នាំជក់ ត្រូវបានដាំនៅតំបន់គៀនស្វាយ ពញាឮ និងមុខកំពូល។ នៅខេត្តក្រចេះ មានដាំនៅតំបន់ កញ្ជរ នៅខេត្តព្រៃវែង មានដាំនៅស្រុកបាភ្នំ ហើយនៅខេត្តកំពត មានដាំនៅស្រុកបន្ទាយមាស និងកំពង់ត្រាច។ រីឯនៅខេត្តបាត់ដំបង មានដាំ នៅតំបន់ត្រែង និងក្តុល។

កសិករខ្មែរយើងចាប់ផ្តើមដាំថ្នាំជក់ នៅខែវិច្ឆិកា និងខែធ្នូ ហើយធ្វើការប្រមូលផលក្នុងខែមិថុនា មេសា និងឧសភា ក្នុងពេលជាមួយនឹងដំណាំកប្បាសដែរ។ នៅសម័យនោះ ការផលិតថ្នាំជក់មានលក្ខណៈសាមញ្ញ កសិករមិនទាន់ចេះធ្វើជាឡចំហុយស្លឹកថ្នាំទេ។ ក្នុងចង្វាក់ប្រតិបត្តិការផលិតកម្មថ្នាំជក់ កសិករយកស្លឹកថ្នាំជក់ដែលបេះមកពីចំការ ទៅសំដិលអោយស្រពាប់ រួចហាន់អោយទៅជាសរសៃថ្នាំ ជួនកាលហាន់ទាំងទ្រនង់ ជួនកាលហាន់ដោយយកទ្រនង់ចេញ ហើយថ្នាំជក់ដែលគ្មានទ្រនង់ គេអាចលក់ក្នុងតម្លៃថ្លៃរហូតដល់ ១រៀល/គ.ក។

ក្រោយឆ្នាំ ១៩០០ ដំណាំថ្នាំជក់បានទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំង ពីការបង់ពន្ធអាករជាពិសេស ពន្ធអាករតម្លៃបន្ថែមពេល ដែលមានចរាចរថ្នាំជក់ក្នុងទីផ្សារ។ អត្រាពន្ធនេះ ត្រូវបង់ស្ទើរតែ
ទ្វេរដងទៅហើយនៃតម្លៃលក់រាយអោយអ្នកប្រើប្រាស់ ហើយឈ្មួញកណ្តាលមិនសូវទិញថ្នាំជក់ពីកសិករទេ។

នៅឆ្នាំ ១៩០២ ផលិតផលថ្នាំជក់ដែលបានដាំដុះ មានច្រើនជាងគេ នៅខេត្តកំពង់ចាម ដែលគេអាចប្រមូលផលបានរហូតដល់ ៦០០ តោន។ ប៉ុន្តែក្រោយឆ្នាំ ១៩០៦-១៩១០ តម្លៃថ្នាំជក់បានធ្លាក់ចុះជាបន្ត បន្ទាប់រហូតដល់ ០,៣ រៀល/គ.ក ហើយអត្រាពន្ធអាករបានកើនឡើង រហូតដល់ ០,៥ រៀល/គ.ក។ ហេតុការណ៍នេះ បានធ្វើអោយផលិតកម្ម ថ្នាំជក់ធ្លាក់ចុះជាស្ថាពរ។ ក្នុងខណៈនោះដែរ ភាពមិនសប្បាយចិត្តរបស់កសិករខ្មែរ មានសន្ទុះកាន់តែខ្លាំងឡើងៗមានជាអាទិ៍គឺ កម្មកសិករ ខេត្តព្រៃវែងក្នុងស្រុកបាភ្នំ ដែលបាននាំគ្នាត្អូញត្អែរអំពីតម្លៃអត្រាពន្ធខ្ពស់លើចរាចរថ្នាំជក់ដែលជាលទ្ធផលបានធ្វើអោយក្រុមប្រឹក្សា រ៉េស៊ីដង់ បារាំងសុំអោយលុបពន្ធនោះចោល។ ហេតុការណ៍បានធ្វើអោយផលិតកម្ម និងអាជីវកម្មថ្នាំជក់ ហាក់ដូចជាមានភាពធូរស្រាលជាងមុនបន្តិច។ ក្នុងរឿងនេះ ចំពោះលោក រ៉េស៊ីដង់បារាំង នៅខេត្តកំពង់ចាម ក៍បានកត់សម្គាល់ដែរថា ដំណាំថ្នាំជក់ក្នុងខេត្តកំពង់ចាមត្រូវបានកសិករបោះបង់ចោលច្រើនឡើងៗ បើទោះបីជា គុណភាពថ្នាំជក់របស់ខ្មែរ នាសម័យនោះ មានការពេញនិយម និងគាំទ្រពីសំណាក់ប្រទេសដែលនៅជុំវិញ គឺប្រទេសសៀម និងកូសាំងស៊ីនក៏ដោយ។

- ដំណាំពោត

ដំណាំពោត គឺជាដំណាំដែលកសិករខ្មែរបានដាំដុះស្ទើរគ្រប់ទី កន្លែង តាំងពីមុនឆ្នាំ ១៨៩៩។ ពោតត្រូវបានកសិករដាំ នៅតំបន់ដួរមាត់ទន្លេមេគង្គលើ មេគង្គក្រោម ជុំវិញទន្លេបាសាក់ តាមតំបន់ជុំវិញដៃទន្លេ និងមាត់ព្រែកទាំងអស់ ហើយដំណាំពោត គឺជាដំណាំចាំបាច់របស់កសិករខ្មែរ និងងាយ

ស្រួលក្នុងការដាំដុះណាស់។ កសិករដាំពោត នៅក្រោយពេលទឹកស្រក និងមុនពេលទឹកឡើង ឬដាំនៅក្នុងចំការតំបន់ខ្ពង់រាបនាដើមរដូវវស្សា ដែលខួបផលិតកម្មរបស់វា មានរយៈពេល ៩០ថ្ងៃ។ ដំណាំពោតមិនមានដាំនៅក្នុងដីស្រែទេហើយគេក៏បានសាកល្បងដាំ នៅតាមវាលស្រែទំនាបនៅខេត្តបាត់ដំបង (ឆ្នាំ១៩១៤-១៩១៥) ប៉ុន្តែត្រូវទទួលបរាជ័យទាំងស្រុង។ យោងតាមការអះអាងរបស់លោក រ៉េស៊ីដង់បារាំងម្នាក់ដែលបានលើកឡើងថា ដំណាំពោតគឺជាដំណាំដ៏ថ្លៃថ្លាសម្រាប់កសិករខ្មែរ ព្រោះវាអាចបំពេញនូវការខ្វះខាតអាហារជំនួសអង្ករ បានដូចជានៅឆ្នាំ ១៩១២ ប្រទេសកម្ពុជា បានជួបប្រទះនូវគ្រោះទុក្ខយ៉ាងធ្ងន់ធ្ងរ ព្រោះតែទឹកជំនន់ និងគ្រោះរាំងស្ងួតកើតឡើងព្រមគ្នា ហើយបានធ្វើអោយតម្លៃស្រូវអង្ករ បានឡើងថ្លៃកប់ពពក ពេលនោះសម្រាប់ការបរិភោគចាំបាច់កសិករបានយកពោតធ្វើជាអាហារជំនួសអង្ករ រង់ចាំដល់ពេលវេលាច្រូតកាត់ថ្មីមកដល់។ [98]

នៅតំបន់ជុំវិញមាត់ទន្លេមេគង្គនាសម័យនោះ ការរីកលូតលាស់លើវិស័យកសិកម្មដំណាំពោតមិនសូវជាទទួលបាននូវទំហំច្រើនប៉ុន្មាននោះទេ បើទោះបីជារ៉េស៊ីដង់បារាំងបានខិតខំធ្វើការលើកទឹកចិត្តក្នុងការដាំដុះក៏ដោយ ក្នុងនិន្នាការជំនួសដំណាំថ្នាំជក់របស់កសិករខ្មែរ ដែលមានវិបត្តិក្នុងឆ្នាំ ១៩០៦-១៩០៧ នៅខេត្តកំពង់ចាម និងខេត្តព្រៃវែងយ៉ាងណាក៏ដោយ។ នៅក្នុងរយៈនៃពេលសង្គ្រាមលោកលើកទី១ ឆ្នាំ ១៩១៤-១៩១៨ ដំណាំពោត បានជួបប្រទះនូវការថយចុះបន្តិចបន្តួច ព្រោះតែ

[98] ផៃ ប៉េងស៊ីម, ទិន្នន័យសរុបនៃសេដ្ឋកិច្ចកម្ពុជា, (បកប្រែពីភាសាបារាំង), ភ្នំពេញ,ឆ្នាំ ២០០៤, ទំព័រ ៤២

ពេលនោះ អាជ្ញាធរអាណាព្យាបាលបារាំងបានលើកទឹកចិត្ត ដល់កសិករអោយដំណាំល្ហុងខ្មែរវិញម្តង ព្រោះជាតម្រូវការប្រេងក្នុងពេលសង្គ្រាម។

❖ ដំណាំល្ហុងខ្មែរ

តាមការស្រាវជ្រាវ ដំណាំល្ហុងខ្មែរ មុនឆ្នាំ ១៩១៧ មានដាំតិចតួច ប៉ុណ្ណោះនៅតំបន់នានាក្នុងខេត្តព្រៃវែង សម្រាប់នាំយកទៅលក់ក្នុងសភាពជាគ្រាប់មិនទាន់ស្ងួទៅកាន់ព្រៃនគរ-ចូឡុង។ ក្រោយឆ្នាំ ១៩១៧ រ៉េស៊ីដង់បារាំងទាំងឡាយ បានធ្វើការឃោសនា លើកទឹកចិត្តដល់កសិករខ្មែរអោយដាំដំណាំនេះ (ពីព្រោះ វាជាសេចក្តីត្រូវការរបស់រដ្ឋាភិបាលបារាំងក្នុងពេលសង្គ្រាម)។ ខណៈពេលនោះរដ្ឋាភិបាលបារាំងបានចែកចាយគ្រាប់ពូជល្ហុងខ្មែរដល់កសិករ ហើយអ្នកដាំដំណាំនេះ ត្រូវបានប្រមូលទិញ និងលើកលែងពន្ធ។ ប៉ុន្តែដំណាំល្ហុងខ្មែរ ហាក់ដូចជាមិនសូវស៊ីគ្នាជាមួយនឹងអាកាសធាតុរបស់កម្ពុជានោះទេ ដែលការសាបព្រោះលើកទី១ នៅខែតុលា ឆ្នាំ១៩១៧ ត្រូវបានបំផ្លាញចោលដោយ សារទឹកភ្លៀងជោកជាំពេក រីឯការសាកល្បងលើកទី២ នៅត្រីមាសទី១ ឆ្នាំ ១៩១៨ ក៏ត្រូវជួបប្រទះនូវភាពរាំងស្ងួត ហើយបានងាប់អស់ពាក់កណ្តាល។ ក្នុងឆ្នាំដដែលនោះ ទឹកជំនន់ក៏បានជន់លិចបំផ្លាញដំណាំដែរ នៅសល់តែមួយចំនួនប៉ុណ្ណោះ។

ទោះជាបែបនេះក្តី ដោយសារកម្លាំងនៃឆន្ទៈរបស់កសិករខ្មែរ និងការធ្លាក់ចុះតម្លៃផលិតផលពោត បានធ្វើអោយផលិតកម្មល្ហុង ខ្មែរទទួលបានទិន្នផលខ្លះៗដែរគឺ ១៧០,៥ តោន នៅឆ្នាំ ១៩១៧ និង ១.១៩៥តោន នៅឆ្នាំ ១៩១៨។ ឆ្នាំ ១៩១៩ ដំណាំល្ហុងខ្មែរ ត្រូវបានរងផលប៉ះពាល់ជាថ្មីទៀត

ដោយសារភាពរាំងស្ងួត និងទឹកជំនន់ ប៉ុន្តែសង្គ្រាមលោកក៏ត្រូវបានបញ្ចប់ ហើយដំណាំល្ហុងខ្មែរ ក៏គ្មានសារៈសំខាន់ទៀត សម្រាប់ប្រទេសបារាំង ធ្វើអោយរ៉េស៊ីដង់បារាំង ពុំបានធ្វើការយកចិត្តទុកដាក់ និងចុះបញ្ជីរបាយការណ៍តទៅទៀត។ [99]

❖ ដំណាំមន និងត្រុំ

ដើមមន បានដាំជាសភាពលាក់លៀម នៅតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា។ ដូចជានៅក្នុងភាគខាងកើតនៃខេត្តកំពត ផ្ទះនិមួយៗគឺមានច្បារមនគ្រប់ៗផ្ទះ អ្នកភូមិធ្វើការចិញ្ចឹមដង្កូវនាងក្នុងមួយឆ្នាំៗ ៣ ទៅ ៤ ដង ហើយត្បាញសំពត់សូត្រសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។ ដូចគ្នានេះដែរ នៅខេត្តកំពង់ឆ្នាំងក្នុងភូមិវៀតណាមមួយចំនួន និងនៅខេត្តពោធិសាត់ តំបន់ផ្សារលើ លលកស ដែលជាកន្លែងដាំមនដោយជនជាតិវៀតណាម និងដោយកូនកាត់ខ្មែរ-ចិន។ ប៉ុន្តែនៅក្នុងតំបន់នេះ មនមិនមានរបៀបរៀបរយទេ ហើយដើមមនតូចៗក៏គ្មានការថែទាំដែរ ធ្វើបែបនេះដើម្បីគេចពីការបង់ពន្ធ។

តំបន់ដាំដើមមនសំខាន់ៗនោះគឺ ខេត្តក្រចេះ ដែលជាដំណាំទី៣ នៅតាមជួរមាត់ទន្លេនៃមណ្ឌលនេះ។ នៅខេត្តកណ្តាល តំបន់ខ្សាច់ កណ្តាល លើកដែក គៀនស្វាយ និងជាពិសេសនៅខេត្តព្រៃវែង ដែលដំណាំមនត្រូវបានដាំនៅក្នុងភូមិមាត់ក្រសះ និងភូមិ គីម ឡុង ស្រុកបាភ្នំ រីឯនៅខេត្តតាកែវ គេដាំនៅស្រុកព្រៃកប្បាស ។

[99] ផៃ ប៉េងស៊ីម, ទិន្នន័យសរុបនៃសេដ្ឋកិច្ចកម្ពុជា (បកប្រែពីភាសាបារាំង), ភ្នំពេញ, ឆ្នាំ ២០០៤,ទំព័រ ៤៣

បរិមាណដំណាំមនក្នុងឆ្នាំ ១៩១៦ មានផ្ទៃដីចំនួន ៦.០០០ ហ.ត និងការចិញ្ចឹមសម្បុកដង្កូវនាង មានចំនួនប្រហែល ៥០០-៥៥០ តោន ហើយដែលមួយភាគធំ ត្រូវបានស្រាវជាសរសៃសូត្រនៅនឹងកន្លែងជាលក្ខណៈគ្រួសារ។ តាមការប៉ាន់ស្មាន ផលិតផលប្រហែល១/៤ នៃ សរសៃសូត្រឆៅដែលបានទទួលត្រូវបានត្បាញដោយគ្រួសារ ដែលជាអ្នកផលិតផ្ទាល់ រីឯចំណែកដែលនៅសល់ ត្រូវបានដឹកតាមកប៉ាល់ កាត់តាមព្រៃនគរ ទៅកាន់ប្រទេសចិន សឹង្ហបុរី និងបាងកក។

ទោះបីជាមានការលើទឹកចិត្តពីបារាំងយ៉ាងណាក៏ដោយ ដូចជាការបង្កើតស្ថានីយ៍សាកល្បងឈ្មោះតាកែវតូច ដែលចែកចាយដើមមន ដោយឥតគិតថ្លៃដល់កសិករខ្មែរក៏ដោយ និងការបើករោងជាងស្រាវសរសៃសូត្រ និងត្បាញសំពត់សូត្រ នៅឆ្នាំ ១៩១៦-១៩១៧ និងការបង្កើតរោងចក្រតម្បាញនៅចាក់អង្រែ ការលើកលែងពន្ធលើដំណាំមន ក្នុងឆ្នាំ ១៩១៥-១៩២០ ក៏ដំណាំនេះហាក់ដូចជាមិនមានការរីកចម្រើននោះទេ។

ដំណាំត្រុំ មានដាំនៅគ្រប់ទីកន្លែង ជាថ្នាលតូចៗនៅលើដីចំការ។ ក្នុងខែមិនា នៅពេលប្រមូលផល ធុងឈើធំៗត្រូវបានរៀបចំនៅតាមបណ្តោយទន្លេមេគង្គ ដែលនៅក្នុងធុងឈើនោះ មានដើមត្រុំដែលទើបនឹងកាប់ថ្មីៗ ត្រូវលាង និងចោះសម្រិតដោយម្ចាស់ចំការ។ ប៉ុន្តែដំណាំ ត្រុំនេះ ប្រើជាពិសេសសម្រាប់សេចក្តីត្រូវការរបស់ប្រជាជនក្នុងការជ្រលក់ពណ៌ តែដំណាំនេះមិនសូវមានការពេញនិយមនោះទេក្នុងឆ្នាំ ១៩០០-១៩២០។

❖ ដំណាំសណ្តែកសៀង និងកាហ្វេ

សណ្តែកសៀង និងកាហ្វេ ជាដំណាំដោយឡែកដែលត្រូវសិក្សាបន្ថែមទៀត និងមានការរីកចម្រើនគួរសមនៅប្រទេសកម្ពុជាក្នុងសម័យនោះ ហើយពេលខ្លះក៏មានការចាប់អារម្មណ៍ពីរ៉េស៊ីដង់បារាំង និងការ យកចិត្តទុកដាក់ខ្លះដែរ។

ព័ត៌មានដំណាំកាហ្វេទើបតែលេចចេញមួយដងគត់ក្នុងឯកសារ នៅពេលដែលរ៉េស៊ីដង់នៅខេត្តព្រៃវែង ជូនដំណឹងថា ការសាកល្បង ដំណាំកាហ្វេ ត្រូវបានទទួលជោគជ័យដោយពួកចិន នៅក្នុងស្រុកបាភ្នំ។

ចំណែកឯសណ្តែកសៀង រ៉េស៊ីដង់ជាន់ខ្ពស់ បានណែនាំអោយចាប់ផ្តើមដាំនៅក្នុងប្រទេសកម្ពុជា រវាងឆ្នាំ ១៩១០។ ដំណាំនេះ មានដាំនៅខេត្តកណ្តាល តំបន់គៀនស្វាយ និងពញាឮ និងនៅខេត្តព្រៃវែង។ ប៉ុន្តែក្រោយមករបាយការណ៍ទាំងឡាយ មិនមានចែងតទៅទៀត ក្រោយពីឆ្នាំ ១៩១៣ មក។

❖ ជ័រវង្គ ដើមត្នោត និងក្រវាញ

ជ័រវង្គ ត្នោត និងក្រវាញ គឺជាការសិក្សាដោយឡែក ពីព្រោះវាមិន មែនជាដំណាំនៅមាត់ទន្លេទេ ជ័រវង្គ និងត្នោតគឺផលិតដោយអ្នកស្រែ មិនមែនជាអ្នកចំការនោះទេ ហើយក្រវាញត្រូវបានថែរក្សា និងប្រមូល ផលដោយអ្នកភ្នំក្រវាញ។

ការផលិតជ័រវង្គ គឺមាននៅតាមតំបន់មួយចំនួននៃខេត្តកំពត កំពង់សោម និងម៉ុំវាលរេញ នៅកំពង់ស្ពឺ មាននៅស្រុកសំរោងទង និងភ្នំស្រួច។ មុនឆ្នាំ ១៩០០ ជ័រវង្គត្រូវបាននាំចេញ ទៅប្រទេសអឺរ៉ុប

កាត់តាម ក្រុងបាងកក។ ប៉ុន្តែសកម្មភាពពាណិជ្ជកម្មតូចតាចនេះ ត្រូវបានផ្អាកនៅ ក្រោយឆ្នាំ ១៩០០ មានតែប្រជាជននៅស្រុកសំរោងទង និងភ្នំស្រួចទេ ដែលបន្តលក់ជ័រវង្គនៅលើទីផ្សារភ្នំពេញ និងកំពង់ស្ពឺ។

ដើមត្នោត មានដុះពាសពេញនៅតាមតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសកម្ពុជា។ ក្នុងឆ្នាំ ១៩១៥ ក្នុងចំណោមដើមត្នោតទាំងអស់ ចំនួន ១៥០.០០០ ដើមដែលដុះនៅក្នុងប្រទេសមាន ៩០.០០០ ដើមដុះនៅខេត្តកណ្តាល ១៨.០០០ ដើមដុះនៅខេត្តព្រៃវែង ១៦.០០០ ដើមដុះនៅខេត្តកំពង់ឆ្នាំង ១៥.០០០ ដើមដុះនៅខេត្តតាកែវ និងផ្នែកដែលនៅសល់បានដុះរាយប៉ាយទៅតាមតំបន់ផ្សេងៗទៀតដូចជា ខេត្តពោធិសាត់ កំពង់ចាម និងកំពង់ធំ។ ជាទូទៅទិន្នផលទឹកត្នោត១/៤ គឺទុក ប្រើប្រាស់ សម្រាប់ជាអាហារ ជាទឹកត្នោតស្រស់ ឬជាទឹកត្នោតជូរ ដែលបានលក់ដោយអ្នកផលិតផ្ទាល់ នៅតាមភូមិ និងតាមទីផ្សារ។ ទិន្នផលទឹកត្នោត ៣/៤ទៀត ត្រូវបានរំងាស់ធ្វើជាស្ករត្នោត ឬជាស្ករវង្វេ។ កសិករខ្មែរបានទាញយកកម្រៃពីស្ករនេះ បានច្រើនគួរសមនៅពេលណាដែលការច្រូតកាត់មិនបានផលល្អ។ ផលិតករស្ករត្នោត មិនលក់អង្ករទេ ព្រោះគេមានចំណូលបន្ថែមដ៏សមរម្យពីការលក់ស្ករត្នោត។ នៅតំបន់ភ្នំពេញ និងព្រែកព្នៅ ស្ករត្នោតត្រូវបានដូរយកជា ត្រីងៀត និងគ្រឿងឧបភោគបរិភោគផ្សេងៗទៀត។ ក្រៅពីនោះ ស្ករត្នោត ត្រូវបាននាំចេញ ទៅលក់នៅកូសាំងស៊ីន។

នៅសម័យបារាំង មានតែផលិតកម្មក្រវាញប៉ុណ្ណោះ ដែលគេចផុតពីប្រភេទផលិតផលដែលផតព្រាងទុក និងបានស្ថិតនៅក្រោមសកម្មភាពនៃការលក់ និងការនាំចេញរបស់ប្រទេសកម្ពុជា។ ធនធានដ៏ចំណាស់នេះ មានតម្លៃសម្រាប់ជាវត្ថុធាតុនៃការផ្សំឱសថបុរាណរបស់ប្រជាជនអាស៊ី ជាពិសេសជនជាតិចិនដែលជាចំណែកមួយផ្គត់ផ្គង់ ដោយជនជាតិភាគតិចនៅភ្នំក្រវាញ គឺជាជនជាតិភាគតិចដែលត្រូវបានចាត់ទុកថាជាទាសករ ។

នៅពេលដែល ទាសករត្រូវបានកំទេចចោលនៅឆ្នាំ១៨៩៨ រដ្ឋាភិបាលបារាំង បានទទួលបន្ទុកប្រមូលនូវផលិតផលទាំងអស់ ហើយលក់ផលិតផលទាំងនោះជាលក្ខណៈដេញថ្លៃ។ រវាងរដ្ឋាភិបាលអាណានិគម និងអ្នកភ្នំក្រវាញ គឺជាកិច្ចការដែលប្រព្រឹត្តទៅដោយគ្មានការអន្តរាគមន៍ពីរាជការខ្មែរទេ គឺធ្វើឡើងតែតាមរយៈអាជ្ញាកណ្តាលរបស់ មេស្រុក ដែលបានជ្រើសតាំងដោយអ្នកភូមិ និងមានបាឡាត់ស្រុកម្នាក់ ជាអ្នកទទួលខុសត្រូវទូទៅនៃតំបន់ភ្នំក្រវាញ។ របៀបចាត់ចែងការងារនេះ ត្រូវបានកែលម្អក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមក ក្នុងទិសដៅនៃការគ្រប់គ្រងអាជ្ញាធរ ការបង្ក្រាបការបន្លំ និងការលួច និងដើម្បីសម្រួល ដល់ការលក់ក្រវាញតាមការដេញថ្លៃប៉ុណ្ណោះ។ របៀបចាត់ចែងនេះត្រូវបានកត់សម្គាល់ ដោយការកាត់ផ្តាច់យ៉ាងមានប្រសិទ្ធភាព នូវការកេងប្រវ័ញ្ចរបស់មន្ត្រីរាជការ ឬរបស់ពួកចិនដែលជាអ្នកទិញ។ ម្យ៉ាងទៀត គឺអាចអោយពួកអាណាព្យាបាលបារាំង រ៉ាប់រងនូវការទារពន្ធអោយបានត្រឹមត្រូវ។ ប៉ុន្តែជាអកុសល ប្រភេទផលិតកម្មនេះ ដែលធ្លាប់បានផ្តល់ ទិន្នផលប្រហែលពី ៦ ទៅ១០ តោន ចន្លោះឆ្នាំ ១៩០៤ ដល់ ១៩០៧ ក្រោយមកមិនសូវមានការរីកចម្រើននោះទេ។ ហើយសេចក្តីត្រូវការ ក៏មានកម្រិត និងការដាំដុះមានការថយចុះចាប់តាំងពីឆ្នាំ ១៩១៤ ហើយ ប្រហែលជាចាប់ផ្តើមមានការប្រឆាំងនៅលើទីផ្សារ ដោយការលេចឡើងនូវឱសថរបស់ពួកបស្ចឹមប្រទេស។

❖ វិស័យនេសាទ

នៅសម័យនោះ ក្នុងការផ្គត់ផ្គង់ចំណីអាហារ ប្រទេសកម្ពុជាប្រើត្រីជាអាហារសំខាន់ទីមួយ ជាមួយនឹងបាយ ប៉ុន្តែគេប្រើប្រាស់សាច់ជាម្ហូបអាហារសម្រាប់ពិធីបុណ្យផ្សេងៗជំនួសវិញ។ ត្រីស្រស់ត្រូវបានគេយកធ្វើជាម្ហូបភ្លាមៗបន្ទាប់ពីនេសាទបាន ឬធ្វើជាត្រីងៀត ត្រីឆ្អើរ ឬត្រីក្រៀម។ គេអាចយកត្រីទៅធ្វើជាគ្រឿងស្ល ដូចជាទឹកត្រី ឬប្រហុកផ្អកជាដើម។ ប្រហុកត្រូវបានអ្នកស្រុកធ្វើដោយខ្លួនឯងនៅមាត់ទន្លេ ក្រោយពីបានដោះដូរស្រូវជាមួយត្រី។

អ្នកស្រុកធ្វើការនេសាទនៅតាមទន្លេមេគង្គ ទន្លេបាសាក់ ជាពិ សេសនៅព្រៃវែង ដែលគេធ្វើការនេសាទ នៅតាមព្រែកនៃស្រុកបាភ្នំ ដែលមានភាពឈ្មោះល្បីដោយគុណភាព និងរស់ជាតិរបស់ត្រីនិងនៅខេត្តកំពង់ចាម ខេត្តតាកែវផងដែរ។ ប៉ុន្តែកន្លែងជម្រុកត្រីរបស់បឹងទន្លេសាប ដែលឡោមព័ទ្ធទៅដោយភូមិអ្នកនេសាទ ក្នុងនោះភូមិសំខាន់ៗ គឺភូមិកំពង់ឃ្លាំង (ខេត្តសៀមរាប) និងឆ្នុកទ្រូ (ខេត្តកំពង់ឆ្នាំង)។ នៅមានកន្លែងនេសាទតាមមាត់សមុទ្រទៀតដែរ ដូចជានៅខេត្តកំពត កំពង់សោម និងនៅស្រែអំបិល និងនៅទឹកដីកោះកុង ដែលជាកន្លែងនេសាទបង្គារ និងត្រីសមុទ្រ។

ទាក់ទងនឹងអាជីវកម្មឡូត៍នេសាទ បើតាមលោក A.Leclère ប្រហែលជាមានហេតុផលរបស់ខ្លួន បានជាអះអាងថាប្រជារាស្ត្រខ្មែរ គ្មានប្រាក់កក់ទុកក្នុងការបង់ពន្ធ ឬជួលកន្លែងនេសាទដែលខ្លួន

បានបង្កើតនោះទេ ហើយបានបោះបង់ចោលនូវការនេសាទធំៗ ដោយផ្តល់ផលប្រយោជន៍ទៅថៅកែចិន វៀតណាម និងចាមវិញ។ ក្នុងរឿងនេះ ក្រៅពីបញ្ហាសេដ្ឋកិច្ច មានបញ្ហាមួយចំនួនទៀត ដែលទាក់ទងនឹងជំរើសមុខរបរនៃជាតិពន្ធ។ ពួកចិន ដែលមានដើមទុនច្រើន ក៏បានក្លាយជាអ្នកចាត់ចែងតំបន់នេសាទ ហើយរស់នៅទីនោះ។

ពិតណាស់ថា ប្រជាកសិករខ្មែរយើងបានចាត់ទុកការនេសាទ ជាសកម្មភាពបន្ថែម ដូចនេះពួកគេគ្មានពេលវេលាគ្រប់គ្រាន់ ដើម្បីនឹងធ្វើការនេសាទតាមការចង់បានរបស់អ្នកចាត់ចែងតំបន់ឡូត៍នេសាទនោះទេ ដែលតែងតែទាមទារការបង់រំលោះនៃការវិនិយោគសម្ភារៈនេសាទ និងសំណង់ដល់សហគ្រាសឡូត៍នេសាទ។ ហេតុដូច្នេះ ពួកវៀតណាមក៏ដណ្តើមយកឡូត៍នេសាទរបស់ខ្លួនទៅ។

ដូច្នេះ របរនេសាទរបស់ប្រជារាស្ត្រខ្មែរ គឺជាការងារបន្ថែម។ ប្រជារាស្ត្រខ្មែរសម័យនោះ ធ្វើការនេសាទ នៅក្នុងត្រពាំង តាមបឹង តាមវាលស្រែចំការ និងតាមវាលទំនាបដែលមានទឹកជំនន់លិច នៅពេលដែលទឹកស្រក។ នៅឆ្នាំដែលសម្បូរត្រី គេឃើញមានប្រជារាស្ត្រ ដែលរស់នៅជួរមាត់ទន្លេសាប បានទុកចោលមុខរបរសិប្បកម្មទាំងអស់ ដើម្បីទៅធ្វើការនេសាទ ដូចជានៅក្នុងឆ្នាំ ១៩១៣ នៅក្នុងដែនដីខេត្តបាត់ដំបង ប្រជារាស្ត្រនៅតំបន់បាក់ព្រា និងនៅតាមតំបន់ជិតខាងដែលមានទម្លាប់រកស៊ីមុខរបរកាប់អុសលក់ បានទុកចោលការងារនេះ ដើម្បីទៅនេសាត្រី។ ប្រជារាស្ត្រដែលរស់នៅភាគខាងជើងនៃប្រទេស ក៏បានមកនេសាទដែរ ហើយពួកគេជាញឹកញយត្រូវបានចោរលួចឥវ៉ាន់នៅតាមផ្លូវធ្វើដំណើរមកកាន់ទន្លេសាប។

ហេតុនេះ សហគ្រាសនេសាទរបស់ថៅកែចិន វៀតណាម ឬថ្វា ទាំងអស់នេះ បានធ្វើការនេសាទជុំវិញតំបន់ភ្នំពេញ និងកំពង់ចាម ដែល មានវិធីសាស្ត្រប្លែកៗគ្នា។ ពួកវៀតណាម និងថ្វាធ្វើការនេសាទ នៅតាម បណ្តោយទន្លេមេគង្គ និងទន្លេបាសាក់ជាលក្ខណៈគ្រួសារ ជូនកាលពឹង ផ្អែកលើការ

ជួយពីមិត្តភ័ក្តិ និងអ្នកជិតខាង។ សហគ្រាសនេសាទធំបំផុត គឺស្ថិតនៅជុំវិញបឹងទន្លេសាប។ សហគ្រាសទាំងនោះ ជានិច្ចកាលដឹកនាំ ដោយថៅកែវៀតណាមម្នាក់ ហើយប្រើកូនឈ្នួលយួន និងខ្មែរមួយ ចំនួន ដែលត្រូវបានចិញ្ចឹម និងជួលតាមរដូវកាលនេសាទ ឬតាមខែ ដោយទទួលបានប្រាក់ពី ៨ ទៅ ១០ រៀល/ខែ។ កូនឈ្នួលទាំងនោះ ជ្រើសរើសយ៉ាងពិបាក ក្នុងស្ថានភាពនេះត្រូវអោយលុយមុនដើម្បីសង បំណុលដែលកូនឈ្នួលនោះបានជំពាក់គេមុនរដូវរកត្រី ដូច្នេះកូនឈ្នួល ទាំងនោះជាអ្នកជំពាក់បំណុលថៅកែ ហើយត្រូវស្ថិតនៅក្រោមអំណាចរបស់ថៅកែ ដែលតម្រូវអោយកូនឈ្នួលទាំងអស់នោះ ធ្វើការងារធ្ងន់ធ្ងរ ចៀសវាងការលួចរត់ ឬគេចខ្លួន។ ប្រធានឡូត៍នេសាទមានសិទ្ធិពេញក្នុងការកំណត់ការបើករដូវនេសាទ គឺពីថ្ងៃទី ១ ខែកញ្ញា ដល់ថ្ងៃទី ១៥ ខែមិថុនា ហើយការនេសាទធំៗត្រូវបានហាមឃាត់ពីពាក់កណ្តាលខែមិថុនា ដល់ខែកញ្ញា ដើម្បីទុកអោយត្រីពងនៅពេលទឹកឡើង។ ប៉ុន្តែសម្រាប់ការនេសាទជាគ្រួសារហាក់ដូចជាមិនមានការហាមឃាត់ទេ។ នៅតាមទន្លេមេគង្គ ការនេសាទត្រី គឺធ្វើឡើងចាប់តាំងពីខែ ធ្នូ ដល់ខែមេសា ហើយការហាមឃាត់មិនធ្វើការនេសាទ គឺចាប់ពីខែកញ្ញា ដល់ខែសីហា នៅតំបន់កំពង់ចាម និងពីខែឧសភា ដល់ខែសីហា នៅព្រៃវែង។ នៅបឹង

ទន្លេសាប រដូវឈប់នេសាទ គឺជាពេលដែលត្រូវរៀបចំឧបករណ៍នេសាទដូចជា មង អួន សំណាញ់ ដែលឧបករណ៍ទាំងនោះអាចមាន ប្រវែងពី ៤០០ ម ទៅ ៥ គ.ម និងដើម្បីកាប់មែកឈើធំតូចសម្រាប់ធ្វើ ផ្នស់ឡើងវិញ (សំរាស់) ដែលបិទដៃ ច្រក ឬផ្នែកនៃព្រែក ដើម្បីហ៊ុំត្រីអោយរស់នៅក្នុងនោះនារដូវទឹកសំរក។

កត្តាអាកាសធាតុ និងវិស័យជលសាស្ត្របានផ្តល់ផលល្អ និងអាក្រក់ ដូចជាបើមានទឹកជំនន់ច្រើន គឺជាមហន្តរាយសម្រាប់ស្រែចំការ តែផ្តល់ផលចំណេញចំពោះការនេសាទ។ ទឹកជំនន់ដែលបានធ្វើអោយមានការវិនាសយ៉ាងធំ ដល់វិស័យកសិកម្ម នៅឆ្នាំ ១៩០៥ តែផ្ទុយទៅ វិញរបរនេសាទបានផ្តល់ផលល្អបំផុត ពិសេសនៅក្នុងតំបន់មួយចំនួនដូចជា តាកែវ និងព្រៃវែង ដែលធ្វើអោយអ្នកស្រុកពោលថា មិនដែលឃើញត្រីសម្បូរដូចឆ្នាំនេះទេ។ ប៉ុន្តែក្នុងឆ្នាំ ១៩១០ ដល់ឆ្នាំ ១៩១២ ជា ឆ្នាំដែលមានទឹកតូច លទ្ធផលនៃការនេសាទត្រី គឺអាក្រក់បំផុត។

តាមឯកសាររបាយកាណ៍បារាំង គេបានប៉ាន់ស្មានថា លទ្ធផលនៃការនេសាទប្រចាំឆ្នាំ នៅប្រទេសកម្ពុជាសម័យនោះគឺប្រហែលជា ២០.០០០ តោន/ឆ្នាំ ក្នុងនោះត្រី ១២.០០០ ទៅ ១៤.០០០ តោនត្រូវបាន នាំចេញ (ក្នុងឆ្នាំនោះ គេបានបន្ថែមការនាំចេញខ្លាញ់ត្រីពី ១.០០០ តោន ទៅ ១.៥០០ តោន)។ ត្រី និងខ្លាញ់ត្រី ត្រូវបានដឹកទៅប្រទេសសឹង្ហបុរី ហុងកុង និងបាងកក ដោយកាត់តាមកំពង់ផែ ព្រៃនគរ។

លើសពីនេះទៀត ពួកអាណានិគមបានធ្វើអន្តរាគមន៍ទៅលើ សកម្មភាពអាជីវកម្មនេសាទទាំងនោះ ក្នុងនាមជាអ្នកគ្រប់គ្រងទូទៅ ពួកគេត្រួតពិនិត្យការងារពន្ធដារ និងយកពន្ធអាករលើឧបករណ៍នេសាទ ថែមទៀត។ ក្រៅពីនេះ ប្រាក់មួយចំណែកដែលបានពីការទារពន្ធ ត្រូវយកចេញពីប្រទេសកម្ពុជា ពីព្រោះនេះគឺជាលើកទីមួយដែលពន្ធគយ ត្រូវបានទារដោយគយ និងរដ្ឋាករ ដូចជាការលក់អំបិលស ត្រូវស្ថិតក្រោមការពិនិត្យរបស់រដ្ឋាករ ពីព្រោះអំបិលគឺជារបស់ដែលចាំបាច់បំផុត សម្រាប់ប្រឡាក់ត្រីទុក និងសម្រាប់ធ្វើប្រហុក និងទឹកត្រី។ ម៉្យាងវិញ ទៀតពួកគយបានទារពន្ធលើការនាំចេញដូចជានៅឆ្នាំ ១៨៩៨ ដល់ឆ្នាំ ១៩០៨ ឈ្មួញត្រូវបានបង់ពន្ធ ៣ហ្វ្រង់ ក្នុងត្រីធ្មើរត្រីក្រៀម ឬត្រីងៀត/១០០ គ.ក និងក្រោយមក ពន្ធអាករត្រូវបានបញ្ចុះតម្លៃមកត្រឹម តែ ២ ហ្វ្រង់/១០០ គ.ក នៅឆ្នាំ ១៩០៨។ ក្នុងឆ្នាំ ១៩១៥ ប្រាក់ដែលបាន ទទួលពីការបង់ពន្ធនាំចេញត្រីឡើងដល់ ១១០.០០០ រៀល និងពន្ធពីការលក់អំបិលគឺបាន៤៣.០០០រៀល ដែលជាប្រយោជន៍ដល់ថវិកាទូទៅរបស់បារាំង។

❖ អាជីវកម្មព្រៃឈើ

ជុំវិញការងារអាជីវកម្មព្រៃឈើនាសម័យកាលបារាំង យើងពុំមានឯកសារណាមួយ ដែលបានបញ្ជាក់ច្បាស់លាស់អំពីទំហំពិតប្រាកដនៃអាជីវកម្មនេះនោះទេ។ ប៉ុន្តែក្នុងឯកសាររបាយការណ៍បារាំងដែលយើងដកស្រង់នេះ គឺគ្រាន់តែបានបញ្ជាក់នូវទិន្នន័យសេដ្ឋកិច្ចខ្លះៗ តែប៉ុណ្ណោះ។ ដូចជានៅក្នុងអំឡុងឆ្នាំ ១៩១៣ ដល់១៩២០ ទំហំពាណិជ្ជកម្មអាជីវកម្មព្រៃឈើ មានចំនួនប្រហែល ៩% នៃថវិការដ្ឋ ដែលជាចំនួនមួយ អាចវាយតម្លៃបានថា សកម្មភាពអាជីវកម្មព្រៃឈើសម័យនោះ មានទំហំ និងវិសាលភាពសេដ្ឋកិច្ចធំធេង។ សម្រាប់ឆ្នាំ ១៩២០ ការនាំផលិតផលព្រៃឈើ ទៅលក់នូវកូសាំងស៊ីន

មានចំនួន ៨៧.០០០ តោន (ឈើកែច្នៃត្រូវបានគិតជាតោន) ដែលទំហំនេះ ជាផលិតផល ទី២បន្ទាប់ពីស្រូវក្នុងការនាំចេញ។ ក្នុងមួយឆ្នាំៗ បន្ទាប់ពីទឹកចាប់ផ្តើមស្រក ក្បូនឈើហ៊ុប និងឫស្សីជាច្រើន ត្រូវបានបណ្តែតតាមព្រែក ស្ទឹង និង តាមដងទន្លេមេគង្គ ឆ្ពោះទៅកាន់តំបន់កូសាំងស៊ីន។

នៅសម័យបារាំង មណ្ឌលដែលផលិតឈើគឺពិតជាតំបន់ដែលមានព្រៃឈើច្រើនបំផុត ប៉ុន្តែក៏ជាមណ្ឌលដែលមានភាពងាយស្រួលក្នុងការនាំឈើហ៊ុបធំៗចេញដែរ ព្រោះត្រាក់ទ័រមិនទាន់មាន ហើយក៏ជាមណ្ឌលដែលមានព្រែក ឫស្ទឹងធំៗហូរកាត់ដែលមានជារទឹកធំទូលាយដើម្បីនាំក្បូនឈើងាយស្រួលធ្វើអាជីវកម្មយ៉ាងខ្លាំង។ នៅខេត្តក្រចេះនៅភាគខាងត្បូងនៃខេត្តស្ទឹងត្រែង និងភាគខាងកើតនៃខេត្តកំពង់ចាមគឺជាតំបន់ផលិតឈើច្រើនជាងគេ បន្ទាប់ពីខេត្តកំពង់ធំដែលនាំឈើហ៊ុប តាមស្ទឹងជីនិត និងស្ទឹងសែន ចុះទៅកាន់ទន្លេសាប។ គ្រាន់តែខេត្តតាកែវ អាចផ្គត់ផ្គង់ឈើដល់ភាគខាងលិចនៃតំបន់កូសាំងស៊ីន ដែលឈើហ៊ុបទាំងនោះ ដឹកតាមរទេះនាំទៅកាន់តំបន់នានា ចេញពីស្រុក តានី និងទូកមាសរហូតទៅដល់ច្រកព្រំដែន ដែលជាកន្លែងឈើហ៊ុប ត្រូវដឹកតាមទូកប៉ុកចាយទៅប្រទេសវៀតណាម។ ខេត្តកោះកុង ក៏ជាចំណុចចេញដំណើរនៃពាណិជ្ជកម្មឈើ សម្រាប់ធ្វើជាអុសដុតផងដែរទៅប្រទេសសៀម។ ចំពោះតំបន់ព្រៃឈើដ៏ធំធេង នៅភាគឦសាន្ត និងភាគខាងជើង និងតំបន់ភ្នំក្រវាញហាក់ដូចជាគ្មានសកម្មភាពកាប់ឈើលក់ទេ ពីព្រោះបណ្តាលមកពីគ្មានហេដ្ឋារចនាសម្ព័ន្ធសម្រាប់ដឹកចេញ។

ការកាប់រំលំដើមឈើប្រើប្រាស់ច្រើនធ្វើឡើងដោយពួកជ្វា។ ឈើសម្រាប់ប្រើនិងពួកឈើមានតម្លៃ មិនមែនជារបស់តែមួយគត់សម្រាប់ធ្វើអាជីវកម្មនោះទេ។ មួយចំណែកធំនៃឈើសម្រាប់ការនាំចេញ គឺទាក់ទងនឹងពួកឈើលេខ២ ដែលត្រូវចៀកធ្វើជាឈើសម្រាប់ដុត និងសម្រាប់ប្រើប្រាស់។ ប្រសិនបើអ្នកស្រុកម្នាក់ៗ ត្រូវការព្រៃឈើសម្រាប់ សេចក្តីត្រូវការផ្ទាល់ខ្លួន ដូចជាផ្តៅ ឫស្សី ស្លឹកឈើ ការធ្វើអុស ប៉ុន្តែ នៅសម័យនោះ ព្រៃឈើក៏ត្រូវបានប្រើជាជំនួយផងដែរ ក្នុងការទាញយកអនុផលពីព្រៃឈើ ពេលមានគ្រោះទុរ្ភិក្ស ដូចជានៅខេត្តកណ្តាល ក្នុងឆ្នាំ ១៩១២ ជាដើម។

❖ ដំណាំកៅស៊ូ

ទាក់ទងទៅនឹងដំណាំឧស្សាហកម្ម ដោយផ្អែកលើទិន្នន័យនានាបានបញ្ជាក់ថា ដីសម្បទានមួយចំនួនជិត ៥០% ត្រូវបានប្រើប្រាស់ដើម្បីរៀបចំចំការដំណាំកៅស៊ូ។ នៅឆ្នាំ ១៩២១-១៩២២ មាន ការវាយសម្រុកធ្វើដំណាំកៅស៊ូ ចំការកៅស៊ូមានទំហំដីប្រមាណ១.២២៤ហិកតា។ លុះឆ្នាំ ១៩៤៥ ដំណាំកៅស៊ូបានគ្របដណ្តប់លើផ្ទៃដីរហូត ២៩.៩២២ ហិកតា។ ផ្ទៃដីសម្បទានប្រមាណជា ៥០%ទៀតត្រូវបានប្រើប្រាស់លើដំណាំផ្សេងៗដូចជា ពោត កាហ្វេ ម្រេច កប្បាស និងចិញ្ចឹមសត្វ។

គួរបញ្ជាក់ថា នៅមុនសម័យកាលសង្គ្រាមលោកលើកទី២ ដើមទុនរបស់ក្រុមហ៊ុនផ្តាច់មុខដែលបានចំណាយលើការអភិវឌ្ឍក្នុងវិស័យកសិកម្ម ក្នុងនោះគឺប្រមាណ ៦០% ត្រូវបានចំណាយសម្រាប់រៀបចំ ចំការកៅស៊ូ រីឯ ៤០% សម្រាប់អភិវឌ្ឍន៍លើគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់នៃប្រទេស។

តាមទិន្នន័យមួយចំនួនបានបញ្ជាក់ថា នៅឆ្នាំ ១៩៣០ បរិមាណ កម្មករដែលបម្រើការងារនៅក្នុងកសិដ្ឋានដំណាំចំការកៅស៊ូ មានប្រមាណពី ១០.០០០ ទៅ ១២.០០០នាក់ ដែលក្នុងនោះភាគច្រើនគឺជា កម្មករវៀតណាម ដែលបំពេញការងារតាមកិច្ចសន្យា។ នៅមុនសម័យសង្គ្រាមលោកលើកទី២ ចំនួនកម្មករទាំងអស់នៅក្នុងប្រទេសកម្ពុជា មានចំនួនពី ២០.០០០ ទៅ ២៥.០០០នាក់ ក្នុងនោះប្រមាណ ៥០% នៃ ចំនួនកម្មករ គឺបម្រើការនៅតាមកសិដ្ឋានចំការកៅស៊ូ។

រហូតមកដល់ចុងអាណត្តិគ្រប់គ្រងរបស់បារាំង យើងឃើញថាក្នុងចំណោមម្ចាស់កម្មសិទ្ធិដីចំនួន ៧២៧.០០០ នាក់ គឺមានប្រមាណជា ៥៥% (ឬម្ចាស់ដី ចំនួន ៤០២.០០០នាក់) ដែលតាំងលំនៅដ្ឋាន នៅភាគ កណ្តាលនៃប្រទេសកម្ពុជា ហើយដែលមានទំហំដី ប្រហែលតិចជាង១ហិកតាប៉ុណ្ណោះ។ ម្ចាស់ដីចំនួន ២៥% (ឬស្មើនឹង ១៨៣.០០០នាក់) ដែលមានទំហំដីពី ១ ទៅ ២ ហិកតា។ ម្ចាស់ដីចំនួន ១២% (ឬស្មើនឹង ៩០.០០០នាក់) ដែលមានទំហំដីពី ២ ទៅ ៥ហិកតា។ ម្ចាស់ដីចំនួន ៧% (ឬស្មើនឹង ៤៨,០០០នាក់) ដែលមានទំហំដីពី ៥ ទៅ ១០ហិកតា។ ម្ចាស់ដីចំនួនជិត ១% (ឬស្មើនឹង ៩.៣០០នាក់) ដែលមានទំហំដីពី ២០ ហិកតា ឡើងទៅ។ [101]

តាមទិន្នន័យបែបនេះ នៅសម័យកាលនៃអាណានិគមបារាំង ទោះបីជាបានបង្កើតទម្រង់ផលិតកម្ម តាមបែបមូលធននិយម (បង្កើត កសិដ្ឋានធំៗដែលមានម្ចាស់កម្មសិទ្ធិ) ក៏ដោយក៏ប្រទេសកម្ពុជា នៅតែ ស្ថិតនៅជាប្រទេសប្រកបដោយកសិដ្ឋានកសិកម្មធុនតូច និងធុនមធ្យម តែប៉ុណ្ណោះ។

## ៥.៣.២ វិស័យសិប្បកម្ម និងឧស្សាហកម្ម

នៅប្រទេសកម្ពុជានាសម័យអាណានិគមបារាំង មានសិប្បករ មួយចំនួនធំ ដែលក្នុងនោះមានជនជាតិខ្មែរ និងវៀតណាមផងដែរ។ ចំនួនសិប្បករទាំងអស់ដែលបំរើការក្នុងផលិតកម្មសិប្បកម្មនាសម័យ នោះ មានប្រមាណពី ៣០.០០០ ទៅ ៤០.០០០នាក់។ កម្មករ និង សិប្បករទាំងឡាយ មានការទាក់ទងជាមួយកិច្ចការស្រែចំការយ៉ាងជិត ស្និទ្ធ។

❖ វិស័យសិប្បកម្ម

វិស័យសិប្បកម្ម ពុំមាននៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជានោះទេ ស្ទើរតែគ្រប់កន្លែងសិប្បកម្មនិមួយៗ សិប្បករផលិតតែផលិតផលអ្វីដែលគេត្រូវការសម្រាប់ប្រើប្រាស់ក្នុងផ្ទះ សម្រាប់ ធ្វើការងារដូចជា នង្គ័ល រនាស់ ប្រដាប់ប្រដាររទេះគោ កញ្ច្រោង ល្អីគ្រប់ ប្រភេទទូក មងសំណាញ់ ឧបករណ៍នេសាទ។ ក្រៅពីនេះទៀត មានសំលៀកបំពាក់ (ក្រណាត់សំពត់និងថ្នាំពណ៌) របស់របរសម្រាប់បំភ្លឺ ដូចជា ក្រមួន និងចន្លុះ និងសម្រាប់ទទួលទានដំណេក ដូចជា កន្ទេល មុងជាដើម។

សិប្បកម្មតម្បាញសំពត់អំបោះគឺមានពាសពេញភូមិនៃតំបន់ជួរមាត់ទន្លេដែលមានដាំកប្បាស។ ជាទូទៅ មុននឹងត្បាញអំបោះ គេត្រូវជ្រលក់ពណ៌ដោយកិរិយារបស់កសិករដែលជាម្ចាស់ចំការត្រុំ។ តម្បាញ សំពត់អំបោះ មានទីតាំងនៅខេត្តកណ្តាល តំបន់គៀនស្វាយ ស្អាង និងកណ្តាលស្ទឹង ក្នុងស្រុកល្វាឯមដែរ។ នៅឆ្នាំ ១៩១៣ តម្បាញនេះ មានស្ទើរតែគ្រប់ក្រុមគ្រួសារទាំងអស់នៅខេត្តតាកែវ ជាពិសេស នៅភូមិបត់រការ។

យោងតាមរបាយការណ៍ឆ្នាំ ១៩១៥ សិប្បកម្មតម្បាញសំពត់អំបោះជាលក្ខណៈគ្រួសារ បានរលាយស្ទើរគ្មានសល់ ចាប់តាំងពីសំពត់អំបោះត្រូវបាននាំចូលពីក្រៅប្រទេសដែលមានតម្លៃថោកជាង និងមានច្រើនប្រភេទជាងផលិតផលក្នុងស្រុក។ ម្យ៉ាងទៀត ក្រណាត់សំពត់អំបោះដែលលក់នៅលើទីផ្សារក្នុងសម័យនោះ មានច្រើនប្រភេទ ច្រើនពណ៌ និងប្រហែលជាថោកជាង រួមផ្សំគ្នាជាមួយការជ្រៀតចូលនៃសំលៀកបំពាក់ពីបញ្ចឹមប្រទេសដែលមានលក់នៅទីក្រុងសម្រាប់សំលៀកបំពាក់របស់បុរស និងស្ត្រី ដែលជាប្រផ្នូលមិនល្អនៃការថយចុះរបស់វិស័យសិប្បកម្មតម្បាញខ្មែរនេះឯង។

សិប្បកម្មតម្បាញសូត្រ កើតមានឡើងក្នុងសភាពជាយថាហេតុ នៅទូទាំងប្រទេសក្នុងភូមិមួយចំនួននៅខេត្តកំពត រហូតដល់ស្រុកឆ្ងាយៗភាគខាងជើងនៃប្រទេស ដែលនៅទីនោះផ្ទះនិមួយៗមានដីដើមមន និងស្ត្រីម្នាក់ៗ បានធ្វើការត្បាញផលិតកម្មសូត្រប្រចាំគ្រួសារ។ ផលិតកម្មសូត្រត្រូវបានត្បាញក្នុងបរិមាណច្រើននៅលើទឹកដីនៃជួរទន្លេមេគង្គ ដែលនៅទីនោះគេដាំដើមមន ដូចជាដំណាំកសិកម្មធម្មតាដែរ និងមានកន្លែងស្រាវសូត្រដែលយើងបានរៀបរាប់ដូចខាងលើស្តីពីការសិក្សាលើដំណាំមន។

សិប្បកម្មកន្ទេលដែលហាក់ដូចជាល្បីឈ្មោះបំផុតនោះ មានត្បាញនៅខេត្តកណ្តាល តំបន់ល្វាឯម នឹងជាពិសេសនៅឃុំសេរីកោះកែវ និងនៅខេត្តកំពង់ឆ្នាំង ក្នុងមជ្ឈមណ្ឌលកំពង់ត្រលាចដែលមាន ជំនាញក្នុងការធ្វើកន្ទេលក្រហមពីដើមកក់។ នៅខេត្តកំពង់ចាម ភូមិមួយចំនួននៅក្នុងស្រុកស្រីសន្ធរ កំពង់សៀម និងជើងព្រៃ សិប្បករធ្វើកន្ទេល សម្រាប់ដោះដូរជាមួយនឹងផលិតផលផ្សេងៗទៀត។

សិប្បកម្មស្មូនឆ្នាំង ដែលល្បីល្បាញបំផុតរបស់ប្រទេសកម្ពុជាក្នុងសម័យបារាំងមាននៅមណ្ឌលខេត្តកំពង់ឆ្នាំង។ ផលិតកម្មស្មូនឆ្នាំងប្រៀបបានដូចជាឧស្សាហកម្មក្នុងស្រុកយ៉ាងសំខាន់មួយ ដែលល្បីឈ្មោះបំផុត ហើយផលិតផលក្អមឆ្នាំងនេះ ត្រូវបាននាំចេញទៅលក់រហូតដល់កូសាំងស៊ីន។ ក្នុងឆ្នាំ ១៩០៥ រ៉េស៊ីដង់បារាំង នៅខេត្តកំពង់ឆ្នាំងបានលើកឡើងអំពីការផលិតរបស់សិប្បកម្មនេះដែរ។ ក្នុងចង្វាក់ផលិតកម្ម បុរសទទួលបន្ទុកជាអ្នកជីករកដី ឯស្ត្រី និងអ្នកបម្រើ ជាអ្នករៀបចំ និងលាយល្បាយដីនឹងជើង មុននឹងសូនធ្វើជាភាជន៍។ ភាជន៍ទាំងនេះ ធ្វើនៅលើបន្ទះឈើមូល ដែលប្រើសម្រាប់ធ្វើជាភាជន៍ប្រភេទផ្សេងៗគ្នា។ ដើម្បីដុតភាជន៍ គេរៀបចំស្មៅ និងចំបើងស្ងួតដាក់ផ្ទាល់លើដីជាមួយមែក

ឈើតូចៗ ដែលនៅលើនោះ គេតម្រៀបក្អមឆ្នាំងដែលត្រូវដុតចំអិន ហើយគេគ្របដោយចំបើង ស្មៅស្ងួត និងមែកឈើតូចៗ ពីលើមួយជាន់ទៀត។ គេអាចរៀបចំក្អមឆ្នាំងជាពីរ ឬជាបីជួរតាមតម្រូវការ បន្ទាប់មកដុតក្នុងរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ការដុតចំអិនគឺត្រូវបានបញ្ចប់។ សមាជិកគ្រួសារនិមួយៗ មានជំនាញផ្សេងៗគ្នា ដូចជា ភាជន៍ ក្អម ចង្ក្រាន ឬជើង ហើយដែលទទួលបាននូវប្រាក់ចំណូលប្រចាំខែពី ១២ ទៅ ១៥ រៀល។

សិប្បកម្មការងារវាយថ្ម ជាជំនាញរបស់អ្នកភូមិបាជាយ នៅក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម។ អ្នកស្រុកធ្វើអាជីវកម្មថ្មសំលៀងពីភ្នំបាជាយ ហើយច្នៃថ្មទាំងនោះទៅជាត្បាល់បុកជើងសរសេរពុទ្ធបដិមា និង ជាសីមាសម្រាប់វត្ត។ កម្មករមួយចំនួន គឺធ្វើការរួមគ្នាជាសមាគម។ ម៉្យាងទៀត ទោះបីជាអាជីវកម្មធ្វើដោយសេរីក៏ដោយ ក៏មុខរបរចម្លាក់ថ្មនេះគឺជាកម្មសិទ្ធពីឪពុកតមកកូនសម្រាប់អ្នកដែលរក្សាទុកមុខរបរនេះ។ នៅពោធិសាត់អ្នកស្រុកមួយចំនួន ឆ្លាក់ថ្លើមថ្មពោធិសាត់ ដើម្បីធ្វើជាភាជន៍ និងធ្វើជាហិបស្លា ហើយសកម្មភាពនេះ មានការរីកចម្រើនជាបន្តបន្ទាប់ គួរអោយកត់សម្គាល់។

សិប្បកម្មជាងទង មានការរីកចម្រើនគួរកត់សម្គាល់គួរសមដែរ។ នៅភ្នំពេញជាងទងរបស់ព្រះមហាក្សត្រ បានរចនាជាពិសេសសម្រាប់ការប្រើប្រាស់ក្នុងព្រះបរមរាជវាំង ចំណែកឯហាងលក់គ្រឿងអលង្ការ គឺ ជាផលិតផលជាងទងមកពីវៀតណាម ចិន និងខ្មែរ។ នៅកោះសូទិនខេត្តកំពង់ចាម ជាងទងចំណានៗរបស់ខ្មែររស់នៅជាអ្នកកែច្នៃរចនា ម៉ូតពីលោហៈធាតុប្រាក់។ នៅតំបន់លលកស ក្នុងខេត្តពោធិសាត់ សិប្បករមួយចំនួនយកលោហៈធាតុដែកកែច្នៃធ្វើជាឧបករណ៍ប្រើប្រាស់ នានា និងជាអាវុធដែលស្វែងរកដោយអ្នករាជការជាន់ខ្ពស់ និងដោយភ្ញៀវទេសចរអឺរ៉ុប។

សិប្បកម្មកែច្នៃឈើ និងឫស្សី គឺពិតជាសិប្បកម្មដែលមានពាសពេញប្រទេស ពីព្រោះអ្នកស្រុកម្នាក់ៗជាអ្នកចេះធ្វើផ្ទះ និងចេះផលិតឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន។ នៅតំបន់មួយចំនួនប្រជាជនមានជំនាញផ្សេងៗគ្នា ដូចជានៅខេត្តតាកែវ គេចេះធ្វើត្រដោក និងចង្កង់ក្របីពីឈើ នៅខេត្តកំពង់ស្ពឺ ជាជាងចម្លាក់ឆ្លាក់ឈុតឆាកនៃរឿងព្រេងលើផ្ទាំងឈើ រីឯអ្នកស្រុកខេត្តព្រៃវែង គេចេះធ្វើរូបសត្វផ្សេងៗពីឈើ។

សិប្បកម្មធ្វើទូកអុំ និងទូកចែវ គឺមាននៅក្នុងស្រុក។ តំបន់ផលិតទូកសំខាន់បំផុតគឺនៅខេត្តស្ទឹងត្រែង ដែលជាកន្លែងអ្នកភ្នំធ្វើប្រវា និងខ្សែពួរពីសំបកដើមកន្ទេចអាលចិន។ រវាងឆ្នាំ១៩០៥ មានពាណិជ្ជករ ម៉ាឡេស៊ីប្រមាណជា៦០នាក់ ទទួលទិញ និងនាំចេញផលិតផលនេះ ទៅប្រទេសឡាវ ឬទៅភ្នំពេញ។ មានកន្លែងផលិតទូកធំៗផ្សេងទៀត នៅលង្វែក ក្នុងខេត្តកំពង់ឆ្នាំង ដូចជានៅភូមិកំពង់តាចេស និងនៅខេត្តកំពង់ឆ្នាំង ក្នុងភូមិកំពង់ត្រឡាច។ ម្ចាស់សហគ្រាសក្នុងស្រុកទាំងនោះគឺជាជនជាតិចិន ម៉ាឡៃ និងវៀតណាមមួយចំនួន។

សិប្បកម្មផ្សេងៗទៀត មាននៅតំបន់ដែលក្រីក្របំផុត និងនៅជិតតំបន់ព្រៃនៃភូមិសាស្ត្រទឹកដីកំពង់សោម និងខេត្តកំពត នៅជើងភ្នំក្រវាញ និងដងរែក អ្នកស្រុកធ្វើចន្លះពីជ័រឈើ ឬធ្វើក្រមួនពីផ្លិតឃ្មុំ។

នៅពេលទំនេរពីស្រែចំការ និងពេលមានគ្រោះទុរ្ភិក្ស អ្នកស្រុកកំពង់ស្ពឺចូលព្រៃភ្នំស្រួចដើម្បីធ្វើសកម្មភាពទាំងនោះសម្រាប់ទទួលបានកម្រៃបន្តិចបន្តួចបន្ថែម។ ក្រៅពីនេះអ្នកស្រុកនៅតំបន់កំពងលែង បានធ្វើកំបោរសម្រាប់ស្លាម្លូពីស្រទាប់សំបកខ្ចៅខ្យងដែលយកមកពីសំរោងជ័យ។ កំបោរមានធ្វើដោយអ្នកភ្នំគួលែន និងអ្នកស្រុកទូកមាស កំពង់ត្រាច ខេត្តកំពត។

❖ វិស័យឧស្សាហកម្ម

ទាក់ទងទៅនឹងវិស័យឧស្សាហកម្មនាសម័យអាណានិគម យើងសង្កេតឃើញថា ជាដំហានដំបូងនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដែលមានក្រុមហ៊ុនផ្តាច់មុខធំៗប្រមាណជិត ៣០ក្រុមហ៊ុនបានចូលរួមក្នុងការកសាងរោងចក្រ សហគ្រាស និងឧស្សាហកម្មធុនស្រាលជាពិសេស គឺរោងឧស្សាហកម្មកែច្នៃផលិតផលឧស្សាហកម្ម ដូចជារោងចក្រផលិតបារី រោងចក្រស្រា និងភេសជ្ជៈគ្មានជាតិអាល់កុល រោងចក្រស្ករស រោងចក្រវាយនភ័ណ្ឌ សហគ្រាសអារឈើ រោងចក្រម៉ាស៊ីនកិនស្រូវ និងសហគ្រាសផលិតសំពត់សូត្រ។ ក្រៅពីនេះក៏បានសាងសង់រោងចក្រតម្លើងយាន្តជំនិះ និងផលិតគ្រឿងសម្ភារៈសំណង់ទៀតផង។ នៅឆ្នាំ ១៩០២ នៅទីក្រុងភ្នំពេញ និងទីរួមខេត្តធំៗបានចាប់ផ្តើមសាងសង់ រោងចក្រអគ្គិសនី និងមានបម្រើបណ្តាញខ្សែទូរស័ព្ទ និងទូរលេខ។

យើងនឹងធ្វើការពិនិត្យមើលនូវដំណើរការ នៃការអភិវឌ្ឍវិស័យឧស្សាហកម្ម តាំងពីចុងសតវត្សទី១៩ រហូតដល់ដើមសតវត្សទី ២០ ដែលជាសម័យកាលមួយ នៃការចាប់ផ្តើមនូវពន្លកដំបូងៗ របស់វិស័យនេះ ទុកជាមូលដ្ឋានក្នុងការសិក្សា។

- រោងចក្រប្រឡះគ្រាប់កប្បាស

កិច្ចការឧស្សាហកម្មធំបំផុត ដែលបានបង្កើតឡើងដំបូងបង្អស់ ក្នុងសម័យកាលអាណានិគមបារាំង គឺទាក់ទងទៅនឹងការបង្កើតរោងចក្រ សម្រាប់ប្រឡេះគ្រាប់កប្បាសនៅខ្សាច់កណ្តាល ក្នុងខេត្តកណ្តាលនាឆ្នាំ ១៨៩២ ដោយលោក Prery។ ក្រោយមក រោងចក្រនេះត្រូវបាន លក់បន្តទៅអោយក្រុមហ៊ុនចិនឈ្មោះ ណាំហេ នៅឆ្នាំ ១៨៩៨។ ម្ចាស់ភាគហ៊ុនម្នាក់ក្នុងចំណោមម្ចាស់ភាគហ៊ុនសំខាន់ៗនៃក្រុមហ៊ុននេះ លោក លី ទុង ដែលមានសញ្ជាតិបារាំង និងជាប្រធានរោងចក្របានធ្វើ ការដឹកនាំអាជីវកម្មក្រុមហ៊ុននេះ អស់រយៈកាល១៥ឆ្នាំ គឺចន្លោះឆ្នាំ ១៨៩៨ ដល់ ថ្ងៃ ២៥ តុលា ឆ្នាំ១៩១៣ ដែលជាឆ្នាំចុងក្រោយនៃការក្ស័យធនរបស់រោងចក្រនេះ ហើយនៅទីបំផុតបានលក់បន្តទៅអោយធនាគារឥណ្ឌូចិន។

ខ្សែចង្វាក់ផលិតកម្មនៃរោងចក្រ ចែកចេញជាពីរសកម្មភាពគឺ សកម្មភាពទី១ ទាក់ទង់ទៅនឹងការចុះប្រមូលទិញផលកប្បាសទាំងអស់ដែលប្រព្រឹត្តទៅ ចាប់ពីខែមិនា ដល់ខែឧសភា ដែលខណៈនោះ រោងចក្របានដំណើរការពេញបន្ទុក ហើយការប្រើប្រាស់កម្មករបានកើនឡើងពី ១៨០ រហូតទៅដល់ ៤០០នាក់។ នៅរដូវមិនសូវមានសកម្មភាព គេប្រើប្រាស់កម្មករ ពី ៥០ ទៅ ៦០ នាក់ប៉ុណ្ណោះ គឺនៅក្នុងខែកក្កដា ដល់ខែតុលា។ សកម្មភាពទី២ ទាក់ទង់ទៅនឹងប្រតិបត្តិការប្រឡេះគ្រាប់កប្បាសដោយរោងចក្រធ្វើការញែកវត្ថុធាតុដើមកប្បាស អោយទៅជាសរសៃអំបោះ និងគ្រាប់កប្បាស ហើយ

ធ្វើការចំរាញ់បន្ត អោយទៅ កាកគ្រាប់ជាសាប៊ូប្រេងកប្បាស។ អនុភាពផលិតកម្មរបស់រោងចក្រ ខាងលើនេះ អាចផលិតបានទិន្នផលសរសៃអំបោះ ប្រហែលពាក់ជាកណ្តាលសំឡីកប្បាសដុលរបស់កម្ពុជាទាំងមូល ដែលពីមុនមកគេធ្លាប់បាននាំចេញវត្ថុធាតុដើមសំឡីកប្បាសនេះទៅលក់នៅទីផ្សារហុងកុង។

ក្នុងឆ្នាំ ១៩០៨ ចំនួនកម្មករសរុបក្នុងរោងចក្រខាងលើមានចំនួន ៤៥០នាក់ ដែលក្នុងនោះកម្មករខ្មែរមាន ៤០០នាក់ ដែលមានប្រាក់ខែ ០,៤៥ រៀល/ថ្ងៃ កម្មករចិនមានចំនួន ៣០នាក់ និងកម្មករវៀតណាម ចំនួន១០នាក់ ដែលមានប្រាក់ខែ ០,៨៨ រៀល/ថ្ងៃ ព្រោះកម្មករចិន និងវៀតណាមមានតួនាទីជាអ្នកគ្រប់គ្រង និងមានកម្មករស្ត្រីវៀតណាម ១០នាក់ទៀត បម្រើការនៅទីនោះ និងមានប្រាក់ខែ ០,២៥ រៀល/ថ្ងៃ។ ដោយសារតែអាជីវកម្មរបស់រោងចក្រ មិនបានទទួលផលចំណេញ ក្នុងឆ្នាំ ១៩១១-១៩១៣ ធ្វើអោយមានការរឹតបន្តឹងបញ្ជីបុគ្គលិក ហើយបាន កាត់បន្ថយចំនួនកម្មករប្រើប្រាស់ ក្នុងនោះកម្មករខ្មែរនៅសល់តែ ១២៣នាក់ អ្នកគ្រប់គ្រងចិននៅសល់២៥នាក់ និងតំណាងបុគ្គលិកជនជាតិ បារាំងសល់តែម្នាក់ប៉ុណ្ណោះ ។

មូលហេតុនៃការក្ស័យធន នៃរោងចក្រប្រឡះគ្រាប់កប្បាសនៅខ្សាច់កណ្តាល បណ្តាកមកពីការមិនយកចិត្តទុកដាក់របស់ឧស្សាហកម្មបារាំងចំពោះសំឡីកប្បាសខ្មែរ ក្រោមលេសមួយថាសរសៃសំឡីកប្បាសខ្មែរខ្លីពេក ភាគរយនៃកាកសំណល់ច្រើនពេក ការផ្តេចកប្បាស មិនបានត្រួតពិនិត្យត្រឹមត្រូវពីគ្រឿងយន្ត និងមានតម្លៃថ្លៃពេក។ ផ្ទុយទៅវិញ អ្នកជំនាញការម្នាក់របស់បារាំងគឺលោក ប៊េនីយេ បានផ្តល់អោយយើងនូវការធ្វើយុត្តិកម្មមួយថា សំឡីកប្បាសរបស់ខ្មែរ គឺធ្នារល្អណាស់ ហេតុនេះបានជាមានតម្លៃថ្លៃ ព្រោះជាប់ក្នុងលំដាប់លេខរៀង ល្អសម្រាប់ទីផ្សារបរទេស(ប៉ុន្តែក្រៅពីស្រុកបារាំង)។ មូលហេតុផ្សេងទៀត ដែលនាំអោយក្ស័យធន គឺទាក់ទងទៅនឹងទំនាស់ផលប្រយោជន៍ របស់មហាអំណាចបារាំង ជាមួយនឹងផលប្រយោជន៍របស់ដែនដីក្រោមអាណានិគម ដែលមានទីតាំងស្ថិតនៅតុងកឹង ដែលបានដាក់គំនាបមកលើឧស្សាហកម្មខ្មែរ ព្រោះរោងចក្រវាយណាភ័ណ្ឌនៅទីនោះ បានរៀបចំឡើងដោយបម្រើផលប្រយោជន៍ដល់ឧស្សាហកម្មបារាំងដ៏មានប្រសិទ្ធភាព។

- រោងចក្រផលិតស្រា

ទាក់ទងទៅនឹងរោងចក្រផលិតស្រាដោយយោងតាមឯកសាររបាយការណ៍របស់រ៉េស៊ីដង់បារាំង ក្នុងឆ្នាំ ១៩១៦ ប្រទេសកម្ពុជា មានរោងចក្រផលិតស្រាទាំងអស់១៧កន្លែង ដែលស្ថិតក្រោមការគ្រប់គ្រង យ៉ាងតឹងរឹងពីរដ្ឋបាលអាណានិគម ជាពិសេសគ្រប់គ្រងការងារពន្ធដារ និងរដ្ឋករ។ រោងចក្រផលិតស្រាទាំងនោះជារបស់ថៅកែចិន ដែលរោងចក្រនិមួយៗ ប្រើប្រាស់កម្មករពី ៣០ ទៅ ៥០ នាក់ ភាគច្រើនជាកម្មករចិនដូចគ្នា។ រដ្ឋបាលបារាំង បានកំណត់តម្លៃស្រា ក្នុង១ដប ស្មើនឹង ០,៤៥ រៀល និងអ្នកផលិតស្រាត្រូវបង់ពន្ធអាករចំនួន ០,១២ រៀល/ដប នៅក្នុងឆ្នាំដដែល។ ជាការលើទឹកចិត្តដល់អ្នកផលិតស្រាច្បាប់ពន្ធបារាំង បានធ្វើការលើកលែងមិនអោយបង់ពន្ធប៉ាតង់ប្រចាំឆ្នាំទេ។

នៅសម័យនោះ អ្នកផលិតស្រាមានការយោគយល់ និងមិនធ្វើការកម្រិតប្រាក់ចំណេញដល់អ្នកលក់ដូរតូចតាចនោះទេ ហូតដល់ពេលដែលអ្នកផលិតស្រា បានទទួលប្រាក់ចំណូលដុលរបស់ខ្លួន

លក់រាយរួចហើយ បន្ទាប់មកទើបម្ចាស់សហគ្រាសប្តូរយកសំបកដបពីអ្នកលក់រាយ ដោយអោយកម្រៃពី ០,២ ដល់ ០,២៥ រៀល/ដប ដើម្បីអោយអាជីវករតូចតាចទាំងនោះ អាចរកប្រាក់ចំណេញបាន។

- រោងចក្រវាយណាភ័ណ្ឌតម្បាញសំពត់សូត្រ

នៅឆ្នាំ ១៩១៦-១៩១៧ ដោយសារកំណើនដំណាំមនតាមរយៈការលើកទឹកចិត្ត និងចែកចាយដើមមនដោយឥតគិតថ្លៃដល់កសិករបានញ៉ាំងអោយបារាំងធ្វើការវិនិយោគលើរោងចក្រស្រាវជ្រាវសរសៃសូត្រ និងវាយណាភ័ណ្ឌតម្បាញសំពត់សូត្រ នៅចក្រអង្រៃតំបន់ភ្នំពេញ។ នៅឆ្នាំ ១៩១៩-១៩២០ នៅខេត្តកំពង់ចាម បានបង្កើតរោងចក្រមួយទៀតគឺ គ្រឹះស្ថានឧស្សាហកម្មសំឡីកប្បាស (Comptoir de l' industrie Colonniere) និងក្រោយមកទៀត បានពង្រីកសាខារបស់ខ្លួនមួយទៀតដើម្បីផ្តេចកប្បាស ប៉ុន្តែអ្វីៗក្នុងសម័យនោះដំណើរការឡើងមិនបិតថេរនោះទេ ព្រោះដំណាំកៅស៊ូកំពុងប្រជេញ ដំណាំកប្បាស។

- ផលិតកម្មឥដ្ឋ និងក្បឿង

នៅសម័យបារាំង ផលិតកម្មឥដ្ឋ ក្បឿង គឺជាឧស្សាហកម្មមួយ។ នៅជុំវិញមជ្ឈមណ្ឌលផលិតកម្មសំខាន់ៗមួយចំនួន គេឃើញមានឡឥដ្ឋ ដែលផ្គត់ផ្គង់ឥដ្ឋ និងក្បឿង ចាំបាច់ការសាងសង់សាលា វត្តអារាម និង អគាររដ្ឋបាលនានា។ ឡឥដ្ឋទាំងនោះគឺជាកម្មសិទ្ធរបស់ថៅកែចិន ក៏ដូចជា រោងចក្រអារឈើដែលមាននៅតាមដងមាត់ទន្លេ នៅតំបន់ភ្នំពេញ និងតំបន់បាណាម ឬរោងម៉ាស៊ីនកិនស្រូវដែលមានចំនួនយ៉ាងច្រើន ក្នុងឆ្នាំ ១៩១៨-១៩២០។

ជាមួយនឹងការសាងសង់ផ្លូវ និងការអនុវត្តបទបញ្ញាការងារក្នុង ខែមករា១៩១៦ សហគ្រាសសាធារណៈការ ធ្វើផ្លូវថ្នល់ ត្រូវបានបង្កើតឡើង ចំនួន ៣៥ សហគ្រាស នៅកំឡុងពេលត្រីមាសទីមួយ ឆ្នាំ១៩១៦ ដែលផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់ការដ្ឋាននោះ ជាពិសេសនៅក្នុងអាជីវកម្មវាយថ្ម ដូចជា នៅភ្នំសំពៅ នៅបាត់ដំបង និងនៅក្នុងការដឹកជញ្ជូនគ្រួស និងថ្ម។ ក្រោយពីផ្លូវទាំងឡាយបានធ្វើហើយ រថយន្តអាច បើកបរបានធ្វើអោយមធ្យោបាយដឹកជញ្ជូនតាមរថយន្តនានា ក៏ចាប់ផ្តើមកើតមានឡើង។

- ឧស្សាហកម្មរ៉ែត្បូង

ក្រៅពីឧស្សាហកម្មឡឥដ្ឋ និងគ្រឿង នៅសម័យបារាំង ទាក់ទងទៅនឹងសកម្មភាព នៃការស្រាវជ្រាវរករ៉ែត្បូងមានតម្លៃ នៅតំបន់ប៉ៃលិន ក្នុងខេត្តបាត់ដំបង ដែលបានកើតឡើងរវាង ឆ្នាំ ១៩០០-១៩០៥ គឺមាន ប្រជាជនរស់នៅប្រមាណជា ១២.០០០នាក់ ជាមួយនឹងការប្រគល់ខេត្តបាត់ដំបងមកអោយខ្មែរវិញ។ ក្នុងឆ្នាំ ១៩០៨ អ្នកជីកត្បូងស្រុកប៉ៃលិន មានមេគ្រួសារជាជនជាតិភូមា ដែលមានចំនួន ៦៩៥ នាក់ គ្រប់គ្រងដោយមេភូមិម្នាក់ឈ្មោះ ម៉ាងសៃ ជនជាតិភូមា និងមានគ្រួសារលាវ ខ្មែរ ចិន និងសៀមចំនួនរាប់ពាន់គ្រួសារ។ សម័យនោះក្រុមហ៊ុនអង់គ្លេស ឈ្មោះ The Siam Syndicate Limited ដែលមានទីស្នាក់ការនៅបាងកក អ្នកទិញត្បូង និងបង់ពន្ធអាករតាមបទបញ្ញត្តិពន្ធគយ ចំពោះអាជ្ញាធរបារាំង។ ក្នុងឆ្នាំ ១៩១០ ត្បូងថ្មនៅប៉ៃលិន មិនសូវមានទីផ្សារលក់ទេ ដូច្នេះក្រុមហ៊ុននេះបានបដិសេធ បន្តកិច្ចសន្យាជាមួយរដ្ឋបាលបារាំង ហើយប្រគល់អាជីវកម្មត្បូងថ្មអោយទៅអោយលោក ម៉ាងសៃ រហូតដល់ខែធ្នូ ឆ្នាំ ១៩១៥។ ក្រោយមក ដោយសារការលក់ត្បូងថ្មមានតម្លៃ

មិនសូវជាប់នៅទីផ្សារថៃ អ្នកជីកត្បូងបរទេសជាច្រើននាក់ ដូចជា ភូមា សៀម បានត្រលប់ទៅប្រទេសខ្លួនវិញ។ ក្រោយឆ្នាំ ១៥១៦ សកម្មភាពជីកត្បូងនៅប៉ៃលិនស្ទើរតែមិនមានការចុះកំណត់ត្រាក្នុងរបាយការណ៍នានា ។ សកម្មភាពនេះបន្តរហូតដល់ស្ទើរតែរលត់។

### ៥.៣.៣. វិស័យសេវាកម្ម

❖ ស្ថានភាពទូទៅនៃវិស័យពាណិជ្ជកម្ម

ក្រៅពីសកម្មភាពលក់ដូរ និងការធ្វើជំនួញតូចតាចតាមលក្ខណៈ ជាប្រពៃណី ដូចជាការលក់ដូរផលិតផលសិប្បកម្ម គ្រឿងបរិភោគ គ្រឿងចានឆ្នាំង គ្រឿងចម្លាក់ពីភ្លុកដំរី និងលោហៈ មានតម្លៃ គេសង្កេត ឃើញមានការលក់ដូរនូវផលិតផលឧស្សាហកម្មជាច្រើនទៀតដូចជា គ្រឿងភេសជ្ជៈ បារីស្ករស ទោចក្រយានយន្ត និងគ្រឿងសំណង់ ព្រមទាំងទំនិញដែលបាននាំចូលពីបរទេស។ ក្រុមហ៊ុនជំនួញធំៗភាគច្រើន ជាជនជាតិវៀតណាម និងចិន ដែលបានដើរតួនាទីជាឈ្មួញកណ្តាល ដែលមានភារកិច្ចជាអ្នកចែកចាយទំនិញរវាងក្រុមហ៊ុនផ្តាច់មុខបារាំង និងទីផ្សារនានា។ ក្រៅពីមុខរបរជំនួញ ក្រុមហ៊ុនឈ្មួញកណ្តាលទាំងនោះ ក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកឧស្សាហកម្មធុនស្រាល នៅក្នុងប្រទេស។

នៅក្នុងល័ក្ខខ័ណ្ឌ នៃរបបគ្រប់គ្រងរបស់អាណាព្យាបាលបារាំង មុខរបរអាជីវកម្មជួញដូរបានរីកលូតលាស់ដោយសង្វាក់យ៉ាងឆាប់រហ័ស និងផលចំណេញ។ ក៏ប៉ុន្តែ ក៏មានអាជីវកម្មមួយប្រភេទទៀតដែលមានការអភិវឌ្ឍអាស្រ័យដោយការគៀបសង្កត់ទៅលើកសិករ ពោលគឺប្រភេទអាជីវកម្មចងការប្រាក់។ គួបញ្ជាក់ថា នៅក្នុងសម័យអាណានិគមនិយមបារាំងការប្រើប្រាស់មូលធនសម្រាប់ការបណ្តាក់ទុនក្នុងការចងការប្រាក់ គឺបានទាក់ទាញកសិដ្ឋានកសិកររហូត ដល់ ៨០% ទៅ ៨៥% ដើម្បីអោយកសិដ្ឋានកសិកម្មនេះស្ថិតនៅក្នុងរង្វង់ ឥទ្ធិពលរបស់ពាណិជ្ជករក្នុងតម្លៃការប្រាក់ពី ១០០ ទៅ ១៥០% ជួនកាលត្រូវសងបំណុលក្នុងតម្លៃ ២០០ក៏មាន។ ក្នុងស្ថានភាពបែបនេះ កសិករមួយចំនួនពិបាកនឹងរំដោះខ្លួនចេញពីទម្ងន់នៃប្រាក់បំណុលនោះណាស់។ កសិករជាច្រើនបានជាប់បំណុលនឹងឈ្មួញកណ្តាល រីឯឈ្មួញទាំងនោះ ភាគច្រើនជាជនជាតិបារាំង ឥណ្ឌា វៀតណាម ដែលរស់នៅស្រុកស្រែចំការ និងនៅទីក្រុង។

ក. សមាភាពនៃដៃគូរពាណិជ្ជកម្ម

ក្នុងឆ្នាំ ១៩០៨ នៅទីក្រុងភ្នំពេញ ដែលជាកន្លែងប្រមូលផ្តុំនូវពួកពាណិជ្ជករចំរុះជាតិសាសន៍ និងជាមជ្ឈមណ្ឌលពាណិជ្ជកម្មកណ្តាល ដែលសំខាន់ជាងគេរបស់ប្រទេស ត្រូវបានរកឃើញថាមានក្រុមហ៊ុន ពាណិជ្ជកម្មឯកទេស និងស្វយ័តជាជនជាតិអាស៊ី សរុបចំនួន ៦២ នាក់ ក្នុងនោះ ម្ចាស់សហគ្រាសបានបង់ពន្ធប៉ាតង់ថ្នាក់លេខ១ លេខ២ និងថ្នាក់លេខ៣ ជូនដល់រដ្ឋបាលអាណានិគម។ ក្នុងចំណោមម្ចាស់សហគ្រាសទាំងអស់នោះ រួមមានជនជាតិចិន ៤២នាក់ ឥណ្ឌា ១៦នាក់ វៀតណាម ៣នាក់ និងខ្មែរ ១ នាក់។ ជាទូទៅអាជីវករជនជាតិចិន មានបរិមាណគ្រប់ដណ្តប់ និងមានទីតាំងនៅ

គ្រប់ទីកន្លែងនៃតំបន់សេដ្ឋកិច្ចសំខាន់ៗនៃប្រទេស។ គេអាចចែកចេញសហគ្រាសរបស់ចិនជា ២ក្រុម ទៅតាមប្រភេទនៃរចនាសម្ព័ន្ធអាជីវកម្ម និងទៅតាមលក្ខណៈ សេវាកម្មផ្សេងៗ ដែលជាសេចក្ដីត្រូវការលើទីផ្សារ។

ជាទូទៅ ក្រុមពាណិជ្ជករឯកទេស និងស្វយ័តភាគច្រើនធ្វើការ រកស៊ីប្រមូលផ្ដុំគ្នានៅទីក្រុងភ្នំពេញ មួយចំនួនទៀតបានឈរជើងនៅតាមបណ្ដាមណ្ឌលពាណិជ្ជកម្មនានានៃទីប្រជុំជន ដែលក្រុមពាណិជ្ជករទាំងនោះបានកាន់កាប់មុខរបរទាំងអស់។ ម្យ៉ាងវិញទៀត បណ្ដាញពាណិជ្ជកម្មគ្រប់ទីកន្លែងហាក់ដូចជា ត្រូវបានរៀបចំចាត់ចែងរួចជាស្រេចនូវយន្តការសេដ្ឋកិច្ចសរុបមួយក្នុងជំនាញឯកទេសដោយឡែក។ ដូចជា ម្ចាស់ភោជនីយដ្ឋាន អ្នកលក់គ្រឿងអលង្ការ ឱសថការី អ្នកលក់ សំលៀកបំពាក់ អ្នកលក់នាឡិការ អ្នកលក់នំ ជាងកាត់ដេរ ជាងកាត់សក់ អ្នកដេរស្បែកជើង។ល។

ខ. មជ្ឈមណ្ឌលពាណិជ្ជកម្ម

មជ្ឈមណ្ឌលទាំងឡាយ ដែលប្រមូលផ្ដុំសកម្មភាពពាណិជ្ជកម្ម របស់តំបន់មួយ ឬរបស់ភូមិភាគណាមួយ អាចមិនស្ថិតនៅជាមួយនឹងមជ្ឈមណ្ឌលរដ្ឋបាលនោះទេ។ ដូចជាទីក្រុងព្រៃវែង ជាទីក្រុងរដ្ឋបាលមួយដែលគ្មានផ្លូវទឹកសម្រាប់ការធ្វើគមនាគមន៍ ដូច្នេះមជ្ឈមណ្ឌលពាណិជ្ជកម្មពិតប្រាកដគឺស្ថិតនៅលើទន្លេមេគង្គ ហើយនិងមាត់ទន្លេពាម ទន្លេតូច នៅកំពង់ត្របែក ដែលភ្ជាប់ទៅបាណាម និងទៅកូសាំងស៊ីន តាមព្រែកត្របែក។ ដូចគ្នានេះដែរ ក្នុងខេត្តកណ្ដាល ដែលជា មជ្ឈមណ្ឌលពាណិជ្ជកម្មពិតប្រាកដរបស់ខេត្តនេះ គឺតំបន់កំពង់ហ្លួង។

មណ្ឌលពាណិជ្ជកម្មធំៗ មានមណ្ឌលរណប ៤ ឬ៥ ដែលស្ថិត នៅតាមបណ្ដោយដងទន្លេ ដូចជានៅខេត្តកំពង់ចាម ជាឧទាហរណ៍ ក្រៅពីទីរួមខេត្ត គឺមានស្រុកក្រូចឆ្មារ ពាមជីលាំង ជីហែ។ ដូចជាករណីជីហែនេះ សម័យនោះបានលេចឡើងដូចជាទីក្រុងដ៏សំខាន់បំផុតរបស់មណ្ឌលកំពង់ចាម ហើយជាមជ្ឈមណ្ឌលពាណិជ្ជកម្មយ៉ាងធំសម្បើមមួយរបស់ប្រទេសកម្ពុជា ដែលមានប្រជាជនរស់នៅកុះករ។ ក្នុងឆ្នាំ ១៩០០ ដល់ឆ្នាំ ១៩១០ ខេត្តស្វាយរៀង ដូចជាកំពង់ថ្មី កំពង់ចាស់ និងប្រសូត គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មរណប។ ចំនួនភូមិធំៗទាំងនេះ ចែកចេញជាបន្ថមកទៀតដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្មអ៊ីអរខ្លាំង។ នេះមានន័យថា មានការរីកចម្រើននូវការប្រមូលផ្ដុំសកម្មភាពសេដ្ឋកិច្ចពាណិជ្ជកម្មនៅជុំវិញតំបន់នានារបស់ខេត្ត បានតាំងនៅឆ្ងាយៗពីគ្នា ដែលមានហេដ្ឋារចនាសម្ព័ន្ធផ្លូវដ៏ប្រសើរ និងទាន់សម័យ។

រីឯមជ្ឈមណ្ឌលសេដ្ឋកិច្ចធំៗពិតប្រាកដរបស់ប្រទេសកម្ពុជា គឺស្ថិតនៅរាជធានីភ្នំពេញ ដែលជាទីក្រុងមានដៃទន្លេបួនមុខប្រសព្វគ្នា គឺទន្លេមេគង្គលើ ទន្លេសាប ទន្លេមេគង្គក្រោម និងទន្លេបាសាក់ ដែលជា ចំណុចសំខាន់មួយសម្រាប់ត្រួតពិនិត្យ និងប្រមូលផ្ដុំពាណិជ្ជកម្មទាំងអស់ ដែលដំណើរការឡើងនៅភាគខាងជើងនៃរាជធានី។ ប៉ុន្តែ មណ្ឌល នៅភាគខាងត្បូង ដូចជាខេត្តព្រៃវែង ស្វាយរៀង តាកែវ កំពត ក្នុងវិធាន ការទូទៅ គឺរួចផុតពីទំនាក់ទំនងសកម្មភាពសេដ្ឋកិច្ច របស់ទីក្រុង ភ្នំពេញ។ អ្នកជើងសារជំនួញ ដែលប្រតិបត្តិការនៅទីនេះ មិនសូវចេញដើមទុនប៉ុន្មានទេ ព្រោះគ្រឹះស្ថានជំនួញនៅភ្នំពេញ ត្រូវបានចេញដោយ ផ្ទាល់ពីគ្រឹះស្ថានជំនួញនៅព្រៃនគរ ចំណែកឯជំនួញ គឺធ្វើឡើងដោយ

ផ្ទាល់ជាមួយនឹង ទីក្រុងព្រៃនគរ តាមផ្លូវសមុទ្រ តាមទន្លេមេគង្គ ឬតាម ស្ទឹង និងព្រែកនៅក្នុងប្រទេស។

ទោះបីជាទំនិញទាំងឡាយឆ្លងកាត់ទីក្រុងភ្នំពេញ ឬមិនឆ្លងកាត់ ប៉ុន្តែជាចុងក្រោយ ភាពដែលមានឯកសិទ្ធិលើប្រទេសកម្ពុជាពិតប្រាកដ គឺមណ្ឌលពាណិជ្ជកម្មព្រៃនគរ ដោយហេតុថាទីក្រុងព្រៃនគរស្ថិតនៅជា មជ្ឈមណ្ឌលសេដ្ឋកិច្ចដ៏ពិតប្រាកដនៃតំបន់ឥណ្ឌូចិន គឺនៅព្រៃនគរនេះ ហើយ ដែលត្រូវចេញសេចក្តីសម្រេចលើហាងឆេងទំនិញ ហើយជា កន្លែងតែមួយគត់នៃការរាប់ផលិតផលរបស់ខ្មែរទាំងអស់នៅទីបញ្ចប់។

លើសពីនេះទៅទៀត វត្តមានរបស់បារាំងបានសង្កត់ធ្ងន់ទៅលើបញ្ហានេះទៀត ដោយការកំណត់បន្ថែមនូវបទបញ្ញាពន្ធគយ ហើយដែលមិនបានបង្កើតនូវចំណុចបង្អែកណាមួយនៅលើផ្ទៃសមុទ្ររបស់ខ្មែរឡើយ។ ក្រុមហ៊ុនរបស់ចិនទាំងឡាយគ្មានលទ្ធភាព និងផលប្រយោជន៍ ណាមួយក្នុងការកែប្រែស្ថានភាពនៃទង្វើនេះឡើយ ពីព្រោះក្រុមហ៊ុនទាំងអស់នោះ គឺបានរកឃើញនូវមធ្យោបាយសមស្របសម្រាប់ផ្តល់នូវលក្ខខណ្ឌគ្រប់គ្រាន់ ដល់ក្រុមហ៊ុនដឹកជញ្ជូនរបស់ខ្លួនតាមរយៈការទិញផលិតផលកសិកម្មក្នុងតម្លៃថោកពីកសិករខ្មែរ។ ដូច្នេះទីក្រុង និងមជ្ឈមណ្ឌលពាណិជ្ជកម្មរបស់ខ្មែរត្រូវបន្ទាបខ្លួនជាអ្នកបន្តភ្ជាប់នូវទំនាក់ ទំនងជាមួយនឹងទីស្នាក់ការសាខាពាណិជ្ជកម្មរបស់កូសាំងស៊ីន។

ឧទាហរណ៍ ដូចជាកំពង់ផែកំពត នៅមុនឆ្នាំ ១៨៧០ គឺជាមជ្ឈមណ្ឌលសកម្មភាពសេដ្ឋកិច្ចពាណិជ្ជកម្មទាំងមូល របស់ប្រទេសខ្មែរ និងជាទីតាំងសកម្មភាពជំនួញខ្លាំងក្លាគួរសមជាមួយបរទេស និងជា កំពង់ផែអន្តរជាតិ ដែលក្រោយមក ក្នុងសម័យបារាំង កំពង់ផែនេះ មិនមានការរីកចម្រើននោះទេ ហើយបានក្លាយទៅជាទីតាំងធម្មតានៃ ការសំចតនៃកប៉ាល់តូចៗរបស់សៀម កោះកុង ហាទៀង កោះត្រល់ និងព្រៃនគរ ទៅវិញ។

គ. ខ្សែបណ្តាញ និងយន្តការសេដ្ឋកិច្ច

នៅសម័យបារាំង បណ្តាញពាណិជ្ជកម្មអាជីវកម្មបោះដុំ គឺមាន ភាពស្មុគស្មាញច្រើន។ ពេលខ្លះបណ្តាញនេះ មានលក្ខណៈជាអន្តរជាតិ និងបានរៀបចំយ៉ាងឈ្លាសវៃ និងជួនកាលមានរចនាសម្ព័ន្ធទន់ភ្លន់។ ទីស្នាក់ការទាំងឡាយរបស់ក្រុមហ៊ុន ស្ថិតនៅហុងកុង ឬសឹង្ហបុរី (អ្នកទិញសំឡីកប្បាសធំៗទាំងឡាយមានទីស្នាក់ការនៅហុងកុង) ជួនកាល នៅភ្នំពេញ ឬជាញឹកញាប់នៅព្រៃនគរ ហើយនៅភ្នំពេញគ្រាន់តែជាទីស្នាក់ ការរបស់សាខាពាណិជ្ជកម្មទាំងអស់នោះតែប៉ុណ្ណោះ។

ការជ្រៀតចូលទៅក្នុងបណ្តាញពាណិជ្ជកម្ម អាជីវកម្មបោះដុំ ដែលបោះទីតាំងនៅគ្រប់មណ្ឌលពាណិជ្ជកម្មទាំងអស់ គឺកើតឡើងជា ពីរប្រភេទ។ ប្រភេទទីមួយ គឺការលក់ជាអចិន្ត្រៃយ៍សម្រាប់ជនជាតិចិន ដែលរស់នៅឆ្ងាយពីគេ ឬដែលគោចរ ហើយត្រូវបានទំនាក់ទំនងគ្នា និង ត្រូវឆ្លងកាត់ការបញ្ជាទិញរបស់អាជីវករនៃមណ្ឌលក្នុងស្រុក ដែលទទួល បន្ទុកការផ្គត់ផ្គង់ទំនិញបន្តពីភ្នំពេញ ឬពីឃ្លាំងរបស់ខ្លួនអោយបានដល់ អាជីវករជនជាតិចិនទាំងនោះ។ ប្រភេទទីពីរ គឺទាក់ទងនឹងការទិញ គេហដ្ឋានរបស់អាជីវករចិនទាំងនោះ ធ្វើជាឃ្លាំងស្តុក ដើម្បីដណ្តើមការប្រមូលផលកសិកម្មយ៉ាងឆាប់រហ័សបំផុត

ធ្វើទៅបាន និងដើម្បីធ្វើអោយការប្រកួតប្រជែងរបស់ខ្លួនប្រព្រឹត្តទៅបានមុនគេ។ ហេតុដូច្នេះហើយ ក្រោយពីការច្រូតកាត់ និងការប្រមូលផលរួច ក្រុមហ៊ុនសម្ងាន់ៗបានបញ្ជូនភ្នាក់ងាររបស់ខ្លួន ដោយធ្វើដំណើរតាមទូក ឬដោយរទេះ រហូតដល់ភូមិស្រុក ដែលនៅដាច់ស្រយាលពីគេ។ ភ្នាក់ងារទាំងនោះបានរៀបចំចាត់ចែង ធ្វើការដោះដូរផលិតផលរបស់ខ្លួនជាមួយនឹងកសិករ មានដូចជា ប្រេងកាត ក្រណាត់ សំពត់គ្រឿងដែក របស់ក្មេងលេង ជួនកាលទិញជាលុយ។ ភ្នាក់ងារទាំងនោះ អាចផ្តត់ផ្គង់ នូវប្រាក់បុរេប្រទាន(ប្រាក់កក់) ដែលអាចសងវិញដោយផលិតផលនៅពេលអនាគត។ ចំពោះអ្នកជួយដើរស្វែងរកអ្នកទិញទាំងនោះ ទទួលបានដាយថាហេតុនូវប្រាក់លើស (កម្រៃជើងសារ) និងការផ្គត់ផ្គង់ស្បៀងពីភ្នាក់ងារចម្លង ដែលបានបង្កើតនៅក្នុងមណ្ឌលទាំងនោះ។ អំណាចរបស់ក្រុមហ៊ុនចិនមានការរីកដុះដាលយ៉ាងខ្លាំងក្លា តាមរយៈវិធានការនានា ដែលក្រុមហ៊ុនទាំងនោះបានរៀបចំអោយដូចជាមធ្យោបាយដឹកជញ្ជូនតាមទូកប៉ុកចាយ កប៉ាល់ ។ល។ ក្នុងឆ្នាំ ១៩១១ ស្រូវពីខេត្តបាត់ដំបងត្រូវប្រគល់អោយរោងចក្រឈ្មោះ ចូឡុង (នៅខេត្តកំពង់ឆ្នាំង) ដែលធ្វើការសណ្តោងតាមទូកប៉ុកចាយរហូតដល់កន្លែងកំណត់។

ជាងនេះទៀត ជនជាតិចិនរស់នៅពាសពេញប្រទេស ជួនកាល ធ្វើដំណើរដោយទូក ឬដោយរទេះ ជួនកាលតាំងទីលំនៅនៅក្នុងភូមិតូចបំផុត។ ក្នុងឆ្នាំ ១៩១៤ នៅក្នុងមណ្ឌលខេត្តកណ្តាល គ្មានភូមិណាមួយ ដែលជនជាតិចិនមិនមានផ្ទះស្បូវនោះទេ ( ផ្ទះស្បូវនាសម័យនោះថ្លៃថ្នូរ បង្គួរ)។ នៅខេត្តពោធិសាត់ ក្នុងភូមិសាស្ត្រនៃតំបន់លាច គឺជាចំណុចស្រេចស្រាវនៃសកម្មភាពពាណិជ្ជកម្មនៅតំបន់ជើងភ្នំក្រវាញ មានផ្ទះលក់ទំនិញរបស់ចិនជាច្រើន ដែលជាទីកន្លែងផ្គត់ផ្គង់ អង្ករ ស្រា និងអំបិលដល់អ្នកស្រុកនៃភូមិតូចៗ ដែលនៅឆ្ងាយបំផុតរហូតដល់ស្រុកសៀម។

និយាយជារួម ពាណិជ្ជកម្មទាំងអស់របស់ប្រទេសកម្ពុជា គឺស្ថិតនៅក្នុងដៃរបស់ជនជាតិចិន ហើយអ្នកនាំចេញជាជនជាតិអឺរ៉ុបទាំងអស់ មិនអាចធ្វើពាណិជ្ជកម្មបានដោយគ្មានជនជាតិចិនធ្វើជាឈ្មួញកណ្តាល នោះបានទេ។ ជនជាតិចិនទាំងនោះ មានទីលំនៅនៅគ្រប់មណ្ឌលពាណិជ្ជកម្ម និងកសិកម្មរបស់ប្រទេស ហើយបានប្រាស្រ័យទាក់ទង ដោយផ្ទាល់ និងយ៉ាងខ្ជាប់ខ្លួន ជាមួយនឹងអ្នកស្រុក ជានិច្ចកាលជនជាតិចិនបានចូលឡូកឡំគ្នាជាមួយអ្នកស្រុកទាំងនោះ ដើម្បីបង្កើតបានជាភូមិដែលផលប្រយោជន៍របស់ខ្លួនធំជាងគេទាំងអស់។ ជនជាតិចិនទាំងនោះមិនមែនរកស៊ីតែម្នាក់ឯងនៅក្នុងខេត្តនានា ដោយធ្វើជាអ្នកជើងសារជំនួញ ឬជាឈ្មួញកណ្តាលទាំងអស់នោះទេ ពីព្រោះថាទាក់ទងនឹងរឿង ចិញ្ចឹមសត្វ ឬកិច្ចការព្រៃឈើ គឺពួកម៉ាឡេជាអ្នកទទួលបន្ទុក ពាណិជ្ជកម្មសត្វ ថ្នាំជក់ និងព្រៃឈើ បន្ទាប់ពីពួកគេបានបង្កើតក្រុមហ៊ុនពាណិជ្ជ ម្មតូចៗជាបណ្តោះអាសន្ន ដោយយកដើមទុនមកយ៉ាង
ច្រើន។ មានពាណិជ្ជករ ឥណ្ឌា សៀម និងចិនមួយចំនួនដែរ ដែលមកពីក្រុងបាងកក ឬមកពីប្រាជិនមកធ្វើអាជីវកម្ម នៅតាមបណ្តោយព្រំដែនខាងជើងនៃប្រទេសកម្ពុជាពីតំបន់ចុងកាល់ មកបាក់ព្រាព្រែកគ្រប់ ដោយដោះដូរសំឡី គ្រាប់ធញ្ញជាតិជាមួយនឹងត្រី។

❖ ពាណិជ្ជកម្មក្នុងស្រុក

ក. សកម្មភាពពាណិជ្ជកម្មក្នុងស្រុក

សកម្មភាពពាណិជ្ជកម្មក្នុងស្រុក ក្នុងសម័យឆ្នាំ ១៩០០ ដល់ឆ្នាំ ១៩១៨ គឺមានសកម្មភាពរស់រវើក និងគ្រប់ទីកន្លែងប្រៀបដូចជាចរន្តសរសៃឈាមដែលមានពាសពេញក្នុងអង្គប្រាណមនុស្ស។ ក្នុងឆ្នាំ ១៩០៧ ហាងលក់ទំនិញ ដែលភាគច្រើនលើសលប់ជារបស់ជនជាតិចិន ដែលជាអ្នកលក់ផលិតផលគ្រប់ប្រភេទ និងសេវាកម្ម គ្រប់មុខទៅអោយអតិថិជនខ្មែរនោះ គឺមានតាំងនៅគ្រប់ទីផ្សារតូចធំទាំង អស់ទូទាំងប្រទេស។ តៀមលក់ទំនិញទាំងនោះ គឺជាឃ្លាំងដែលផ្ទុកទៅ ដោយរបស់របរលាយឡំគ្នា ដែលជាផលិតផល ផលិតក្នុងស្រុក និងនាំចូលពីបរទេស។ ចំពោះផលិតផលទំនិញក្នុងស្រុក ដែលមានដាក់លក់ ក្នុងសម័យកាលនោះមានដូចជា ថ្នាំជក់ អំបិល ទឹកត្រី ត្រីងៀត ប្រហុក ជ្រូកសៀង ទឹកស៊ីអ៊ីវ ផ្លែឈើ បន្លែ ស្រូវ អង្ករ និងរបស់របរប្រើប្រាស់ ដែលធ្វើពីវត្ថុធាតុដីដុត កូនដបថ្នាំចិន គ្រឿងចានព័រស៊ឺឡែន ឈើគូស របស់របរធ្វើពីឈើ និងឫស្សី ផ្លែឈើក្រៀម ឬដំណាប់ផ្លែឈើដែលនាំចូលពី
ហុងកុង អំបោះ ក្រណាត់សំពត់ធ្វើពីសំឡីគ្រប់ប្រភេទ គ្រឿងដែក និងចង្កៀងបារាំង ស្លាម្ពូរបស់កូសាំងស៊ីន សំពត់សៀម សាប៊ូ ស្ករ បារី របស់ឥណ្ឌា ដោយមិនរាប់បញ្ចូលនូវគ្រឿងប្រដាប់ក្មេងលេង និងរបស់ តូចៗ ធ្វើពីគ្រីស្តាល់។ នៅខេត្តបាត់ដំបង នៅក្នុងស្រុកមង្គលបុរី មានហាងចិនជាច្រើន ដែលបានដាក់តាំងបង្ហាញនូវផលិតផលរបស់ប្រទេសលោកខាងលិច ដែលអាចរកទិញបាននូវស្រាមានតម្លៃដូចជា ស្រាបៀរបារាំង ស្រារបស់អង់គ្លេស ស្រាស ស្រាអាកុល និងត្រីខប្រអប់ ស្ពៃជូរ សណ្តែកបាយ និង
សណ្តែកបារាំងកំប៉ុងតូចៗ និងផ្សេងៗទៀត។

ខ. តម្លៃទំនិញទីផ្សារ

តម្លៃរូបិយវត្ថុ គឺជាខ្នាត ឬជាមធ្យោបាយសម្រាប់វាស់វែងនូវតម្លៃផលិតផលនិមួយៗ ស្របតាមលក្ខណៈធម្មជាតិនៃកត្តាផលិតកម្មរបស់វា។ ផលិតផលទំនិញ អាចមានតម្លៃខុសៗគ្នា អាស្រ័យដោយភាពស្មុគស្មាញនៃបច្ចេកវិទ្យាផលិតកម្ម យន្តការទីផ្សារ ទីតាំង និងពេលវេលា តម្រូវការទំនិញ ព្រមទាំងនយោបាយសេដ្ឋកិច្ច-សង្គម។

ក្នុងការសិក្សារបស់យើង យើងពិនិត្យមើលតែទៅលើមុខទំនិញ សំខាន់ៗមួយចំនួនប៉ុណ្ណោះ ដែលជាមុខទំនិញ ជាសេចក្តីត្រូវការចាំបាច់របស់ប្រជាជនខ្មែរ និងមុខទំនិញសម្រាប់នាំចេញក្នុងសម័យកាលនោះ ពោលគឺ តម្លៃស្រូវ អង្ករ ត្រីងៀត សាច់ ថ្នាំជក់ ម្រេច និងសំឡីកប្បាស នៅតាមបណ្តាឆ្នាំខុសៗគ្នា ដែលមានអត្ថន័យដូចខាងក្រោម៖

- តម្លៃផលិតផលស្រូវ

តម្លៃស្រូវ នៅឆ្នាំ ១៨៩៧ ដល់ឆ្នាំ ១៩០០ មានតម្លៃថោកសមរម្យ គឺ ប្រហែលជា ៣០ គ.ក/១ រៀល ទៅ ១៥ គ.ក/១រៀល។ តម្លៃស្រូវមានការកើនឡើងខ្ពស់បំផុតនៅឆ្នាំ ១៩១២ ដែលមានតម្លៃរហូតដល់ទៅ ៧ គ.ក/១រៀល ដោយសារគ្រោះធម្មជាតិ។

- តម្លៃអង្ករ

តម្លៃអង្ករ នៅចន្លោះឆ្នាំ ១៨៩៧ ដល់ ១៩០០ មានតម្លៃប្រហែល ៩,៥ គ.ក/១រៀល ហើយមានការកើនឡើងថ្លៃជាបន្តបន្ទាប់ រហូតដល់ទ្វេរដង ក្នុងចន្លោះឆ្នាំ ១៩១១ ទៅឆ្នាំ ១៩១២ តម្លៃរបស់វាកើនដល់ ៤ គ.ក/១រៀល។

- តម្លៃត្រីងៀត

តម្លៃត្រីទៀត (ងៀតត្រីប្រា) នៅឆ្នាំ ១៩០០ ដល់ឆ្នាំ ១៩០៧ មាន តម្លៃប្រមាណជា ៣,៧ គ.ក/១រៀល ។ តម្លៃនេះ បានបន្តកើនឡើង ប្រមាណ ៣០% នៅឆ្នាំ ១៩១១ និងបន្តកើនឡើងខ្ពស់បំផុត (កើនឡើង ១០០%) ក្នុងឆ្នាំ ១៩១៣ ពិសេសនៅតំបន់កំពង់ចាម កំពត និង ព្រៃវែង ព្រោះមាន ទឹកតូច។

- តម្លៃសាច់ជ្រូក

តម្លៃសាច់ជ្រូក នៅឆ្នាំ១៩០៥ នៅតំបន់កំពង់ចាម មានតម្លៃ ចន្លោះពី ៣,៧ គ.ក/១រៀល ទៅ ២,៨ គ.ក/១រៀល ហើយតម្លៃនេះ បានកើនឡើងខ្ពស់រហូតដល់ ១,៨ គ.ក/១រៀល ទៅ ១,៦ គ.ក/១រៀល ក្នុងឆ្នាំ ១៩១៤ (នៅតំបន់ខេត្តព្រៃវែង សាច់ជ្រូកមានតម្លៃរហូតដល់ ១,២ គ.ក/១រៀល)។ ប៉ុន្តែតម្លៃសាច់ជ្រូក បានធ្លាក់ចុះមកវិញ ក្នុងឆ្នាំ ១៩១៩ មកនៅត្រឹមតម្លៃតែ ៣,៧ គ.ក/១រៀល គឺប្រហែលគ្នាទៅនឹងតម្លៃក្នុងឆ្នាំ ១៩០៥។

- តម្លៃថ្នាំជក់

ចំពោះតម្លៃថ្នាំជក់វិញ មុនឆ្នាំ ១៨៩៧ មានតម្លៃប្រហែលជា ៤,៧ គ.ក/១រៀល ទៅ ៣,៣គ.ក/១រៀល។ ដោយសារផលិតផលថ្នាំជក់ ស្ថិតក្រោមឥទ្ធិពលនៃអំណាចពន្ធអាករ ហេតុដូចនេះហើយចាប់តាំងពី ឆ្នាំ ១៩០០ មក តម្លៃថ្នាំជក់បានកើនឡើងយ៉ាងគំហុក រហូតដល់ ១,៦ គ.ក/១រៀល ទៅ ០,៨ គ.ក/១រៀល ក្នុងឆ្នាំ១៩០៥ ដែលធ្វើអោយកសិករត្អូញត្អែរជាខ្លាំង អំពីបន្ទុកពន្ធអាករលើចរាចរថ្នាំជក់ ដែលនាំ អោយផលិតផលថ្នាំជក់បានចុះថោក។

- តម្លៃម្រេច

ទាក់ទងទៅនឹងដំណាំម្រេច គឺមានប្រវត្តិពិសេសរបស់វា ដែល យើងធ្លាប់បានដឹងរួចមកហើយពោលគឺការវិវត្តិនៃតម្លៃម្រេច ជាប់ទាក់ ទងនឹងវិបត្តិដែលកើតឡើងក្នុងការដាំដុះ បញ្ហាពន្ធគយ និងទីផ្សារនាំ ចេញ។ ចន្លោះឆ្នាំ ១៨៧៧ ដល់ឆ្នាំ ១៩០២ តម្លៃកើនឡើងខ្ពស់រហូត ដល់ ១ គ.ក/១រៀល ប៉ុន្តែក្រោយឆ្នាំ ១៩០២ ដោយសារហេតុផលខាង លើ តម្លៃម្រេចបានធ្លាក់ចុះជាបន្តបន្ទាប់ ដែលមានតម្លៃទាបបំផុតនៅ ឆ្នាំ ១៩០៨ ដល់ឆ្នាំ១៩០៩ គឺមានតម្លៃប្រហែល៣គ.ក/១រៀល។ ក្រោយមក តម្លៃម្រេចបានកើនឡើងវិញជាបណ្តើរៗ គឺកើនរហូតដល់ ១,១ គ.ក/១រៀល ចន្លោះឆ្នាំ ១៩១៦-១៩១៧។

- តម្លៃសត្វពាហនៈ

ចំពោះតម្លៃសត្វគោ ឬក្របីដែលរស់មានតម្លៃប្រហែលជា ៥០ រៀល/១ក្បាល។ សរុបមក យើងអាចពិនិត្យមើល បម្រែបម្រួលតម្លៃទំនិញ (ស្រូវ អង្ករ និងសំឡីកប្បាស) តាមបណ្តាឆ្នាំខុសៗគ្នា ដែលមាននៅក្នុងតារាង ខាងក្រោមនេះ ៖

| បរិយាយ | ស្រូវ | អង្ករ | សំឡីកប្បាស |
|---|---|---|---|

| | | | |
|---|---|---|---|
| **១៨៩៧-១៩០០ តម្លៃទាប និងថេរ** | ១-២,៥ | ៣-៤ | ៥ |
| **១៩០៤-១៩០៦ តម្លៃកើនឡើង** | ២-៣ | ៣,៥-៤,៥ | ៦-៨ |
| **១៩០៧-១៩១០ តម្លៃបន្តកើនឡើង** | ២,៥-៤ | ៣,៥-៦ | ៧-៨ |
| **១៩១១-១៩១៤ តម្លៃកើនឡើងខ្ពស់** | ៣-៥ | ៥-៨,៥ | ៩-១១ |
| **១៩១៣-១៩១៨ តម្លៃធ្លាក់ចុះ** | ២-៣ | ៤-៥ | ៦-៨ |
| **១៩១៥-១៩១៨ តម្លៃបន្តធ្លាក់ចុះ** | ១,៥-២,៥ | ៣-៤ | ៤-៦ |
| **១៩១៨-១៩១៩ តម្លៃកើនឡើងខ្ពស់** | ៣-៤ | ៥-៨ | ៨ |

*តារាងតម្លៃស្រូវ អង្ករ និងសំឡីកប្បាសចន្លោះឆ្នាំ ១៨៧៩-១៩១៩*
*(តម្លៃគិតជារៀល/Picul ឬ ១ការ៉ុង = ៣៣,៣៣ គ.ក)*

កំណត់ចំណាំៈ

តម្លៃផលិតផលសម័យនោះ ក្នុងឯកសារកំណត់ត្រារបស់បារាំង ត្រូវបានវាស់វែងដោយខ្នាតគិតជា Picul ដែលមួយ Picul មានទម្ងន់ ស្មើនឹងមួយការ៉ុងតូច ដែលទម្ងន់របស់វាប្រហែល ៣៣,៣៣ គ.ក ដែល ក្នុង ៣ Pical ស្មើនឹង ១០០ គ.ក។

គួរបញ្ជាក់ដែរថា តម្លៃផលិតផលកសិកម្មរបស់ខ្មែរ ក្នុងសម័យនោះ មានការប្រែប្រួលតម្លៃជាខ្លាំង ពីមួយឆ្នាំទៅមួយឆ្នាំ ដែលមូលហេតុចំបង ទាក់ទងនឹងកត្តា៣យ៉ាង គឺនយោបាយពន្ធអាកររបស់រដ្ឋបាលបារាំង បញ្ហាកត្តាអាកាសធាតុ និងជលសាស្ត្រ និងបរិមាណផលិតផលសម្រាប់ទីផ្សារក្នុងស្រុក និងទីផ្សារបរទេស។ ប៉ុន្តែស្ទើរតែមិនពាក់ព័ន្ធទៅនឹងនយោបាយរូបិយវត្ថុនោះទេ ព្រោះពេលដែលអត្រាប្តូរប្រាក់ រៀលធ្លាក់ចុះ (មានអតិផរណា) ឬពេលដែលប្រាក់រៀលឡើងថ្លៃវិញធៀប នឹងប្រាក់ហ្វ្រង់ គេនៅតែពិនិត្យឃើញថា ទំហំទិន្នន័យពាណិជ្ជកម្ម នាំចេញពីប្រទេសខ្មែរ នៅតែមានសកម្មភាព និងសន្ទុះខ្លាំងក្លាដដែល នេះបើតាមការបញ្ជាក់អះអាងពីឯកសារដើមនៃរបាយការណ៍បារាំង។

❖ ពាណិជ្ជកម្មអន្តរជាតិ

ក. ការនាំចេញ

នៅដើមសតវត្សទី២០ ក្នុងរបបអាណាព្យាបាល ជាពិសេសចន្លោះឆ្នាំ ១៩០០ ដល់ ១៩២០ ការនាំចេញនូវផលិតផលកសិកម្មរបស់ប្រទេសកម្ពុជា បានដំណើរការឡើងយ៉ាងសស្រាក់សស្រាំគួរអោយកត់សម្គាល់។ សម័យនោះទំនិញកសិកម្មសំខាន់ៗ ដែលបានធ្វើការនាំចេញមានដូចជាស្រូវ ម្រេច កប្បាស ត្រីងៀត សត្វពាហនៈ ឈើក្រវាញ ជ័រវង្គ ល័ក បង្កងធ្មើរ ពោត សណ្តែកដី សណ្តែកសៀង លូ ស្បែកសត្វ ក្រមួន ចន្លា និងល្ហុងខ្មែរ ដែលមានបរិមាណរាប់រយតោន។ ខាងក្រោមនេះ យើងនឹងធ្វើការពិនិត្យមើលប្រភេទមុខទំនិញចាំបាច់មួយចំនួន ដែលបានធ្វើការនាំចេញពីប្រទេសកម្ពុជា។

ក.១ ការនាំចេញផលិតផលស្រូវ និងអង្ករ

បើពិនិត្យតាមការអះអាងរបស់អភិបាលខេត្តបាត់ដំបង ដែលគ្រប់គ្រងនៅតំបន់អាណាខេត្តភាគខាងជើងរបស់ប្រទេសកម្ពុជា ក្រោយពីបានបញ្ចូលជាឧបសម្ព័ន្ធមកអោយខ្មែរវិញ បានបញ្ជាក់ថាការនាំចេញ ផលិតផលស្រូវរបស់កម្ពុជា គឺមានទំហំធំធេងណាស់ ហើយប្រហែលជា ១៥០.០០០ តោន/១ឆ្នាំឬស្មើនឹង ១/៣ ឬ ១/៤ នៃផលិតកម្មដំណាំស្រូវនៅទូទាំងប្រទេសកម្ពុជា ដែលចំនួននេះសមមូលទៅនឹង ១/១០ នៃ ការនាំចេញទំនិញទាំងអស់របស់ឥណ្ឌូចិន (គឺប្រហែលជា ១.៥៧០.០០០ តោន/ឆ្នាំ សម្រាប់រយៈពេលពីឆ្នាំ ១៩០៩-១៩១៦)។

យោងតាមកំណត់ត្រារបស់លោក G. Dauphinot ក្នុងឆ្នាំ ១៩០២ លើកឡើងថា គ្រាន់តែការនាំចេញស្រូវ និងត្រីងៀតពីខេត្តបាត់ដំបងមួយតែប៉ុណ្ណោះ ឆ្ពោះទៅភ្នំពេញរួចបន្តទៅកូសាំងស៊ីន ទីក្រុងព្រៃនគរ គឺអាចទទួលបានរូបិយប័ណ្ណប្រមាណជា ១២.០០០.០០០ ហ្វ្រង់។ ទិន្នន័យនាំចេញពីខេត្តនេះ បន្តកើនឡើងរហូតជាពិសេសនៅឆ្នាំ ១៩០៧ ដល់ ១៩០៨។ ជាងនេះទៅទៀត ខេត្តបាត់ដំបងបានផ្គត់ផ្គង់ ប្រហែល ១/៣ នៃការនាំចេញផលិតផលស្រូវទាំងអស់របស់ប្រទេសខ្មែរ ដែលស្មើនឹង ៥២.០០០ តោន គិតជាមធ្យម/១ឆ្នាំៗ ពិសេសនៅចន្លោះឆ្នាំ ១៩០៩ ដល់ឆ្នាំ ១៩១៦។

បើយើងពិនិត្យមើលបន្ថែមទៅលើទំហំពាណិជ្ជកម្មនាំចេញរបស់ឥណ្ឌូចិន ចន្លោះឆ្នាំ ១៩០៩-១៩១៦ គឺមានចំនួន ១.៥៧០.០០០ តោន (ក្នុងនោះគ្រាន់តែការនាំចេញស្រូវ ពីបណ្តាខេត្តភាគពាយ័ព្យនៃប្រទេសកម្ពុជាស្មើ ១/១០ នៃការនាំចេញសរុបរបស់ឥណ្ឌូចិនទាំងមូល)។ ក្រៅពីការនាំចេញស្រូវ និងអង្ករបស់កម្ពុជា យើងក៏បាននាំចេញនូវផលិតផលម្រេច និងសំឡីកប្បាសដែលមិនទាន់ប្រឡេះគ្រាប់ សត្វពាហនៈ ត្រីងៀត ត្រីឆ្អើរ ក្រវាញ ដែលផលិតផលទាំងនោះ បានកាន់កាប់លំដាប់លេខរៀងសំខាន់ៗ ក្នុងទិន្នន័យពាណិជ្ជកម្មនាំចេញរបស់ឥណ្ឌូចិន។

ក.២ ការនាំចេញសំឡីកប្បាស

ការនាំចេញផលិតផលសំឡីកប្បាស ដែលមិនទាន់ប្រឡេះគ្រាប់ និងប្រឡេះគ្រាប់ហើយ ស្ទើរតែទាំងអស់មកពីតំបន់ជួរមាត់ទន្លេមេគង្គគឺ ៣.៥៧៤ តោន/៤.២៥៦ តោន ដែលបាននាំចេញក្នុងឆ្នាំ ១៩០៤ និង ៥.៥៨៦ តោន/៦.៤៦០ តោន បាននាំចេញក្នុងឆ្នាំ ១៩១៣។ លើកលែង ទីផ្សារឥណ្ឌូចិនចេញ ទីផ្សារនាំចេញរបស់ខ្មែរសម្ងន់ៗចំពោះផលិតផល សំឡីកប្បាសខាងលើរួមមាន ហុងកុង (ស្ថិតក្រោមការគ្រប់គ្រងរបស់អង់គ្លេស) បានទិញ ៣.៥៧៤ តោនក្នុងឆ្នាំ ១៩០៤ និងទីផ្សារជប៉ុន បាន ទិញកប្បាសចំនួន ៥.៥៨៦ តោនក្នុងឆ្នាំ ១៩១៣។ ជាងនេះទៀត បើប្រៀបធៀបនឹងការនាំចេញពីឥណ្ឌូចិន កប្បាសខ្មែរជាប់លំដាប់ថ្នាក់លេខ៧ ក្នុងឆ្នាំ ១៩១៤ (ក្នុងចំណោមមុខទំនិញកសិកម្មនាំចេញសរុប)។

ក.៣ ការនាំចេញម្រេច និងត្រីងៀត

ចំពោះផលិតផលម្រេច និងត្រីងៀត ដែលនេសាទនៅបឹងទន្លេសាប និងទន្លេមេគង្គ នៅឆ្នាំ ១៩០៩ បាននាំចេញចំនួន ១១.៥០០ តោន និងឆ្នាំ ១៩១២យើងបាននាំចេញ ១២.៦៤០ តោន (ក្នុងឆ្នាំនោះ ២០.៨០០ តោន នាំចេញពីប្រទេសឥណ្ឌូចិន)។ គួរបញ្ជាក់ថា បើប្រៀបធៀបនឹងការនាំ

ចេញពីឥណ្ឌូចិនចំពោះផលិតផលដូចគ្នាយើងឃើញថា ផលិតផលម្រេចទទួលបានចំណាត់ថ្នាក់ល្អសម្រាប់ឆ្នាំ ១៩០១ និងឆ្នាំ ១៩១៤។

ទីផ្សារម្រេចសំខាន់ៗរបស់ខ្មែរនាសម័យនោះ រួមមាន ប្រទេសសឹង្ហបុរី សៀម (ម្រេច ត្រី ជ្រូក) និងប្រទេសបារាំងដែលបានទិញម្រេចមួយភាគធំរបស់ខេត្តកំពត។ ប្រទេសសៀម និងសឹង្ហបុរី បានទិញទំនិញកសិកម្មរបស់ខ្មែរក្នុងចំនួនកំណត់ច្បាស់លាស់ណាស់ រីឯបារាំងក៏ដូចគ្នាដែរ ដែលធ្វើអោយផលិតផលកសិកម្មខ្មែរ តែងតែមានការព្រួយបារម្ភ។ ជាក់ស្តែង ក្នុងឆ្នាំ ១៩០៣ ប្រទេសកូសាំងស៊ីនត្រូវបានធ្វើការនាំម្រេចចេញទៅស្រុកបារាំងប្រមាណ ៣.៣០៧ តោន ទល់នឹង ១០៦ តោន ចំពោះកម្ពុជា ហើយក្នុងឆ្នាំ ១៩០៤ ប្រទេសកូសាំងស៊ីនបាននាំចេញ ម្រេចចំនួន ៥.៣៣៧ តោន ទៅស្រុកបារាំង ទល់នឹង ៥ តោន ចំពោះកម្ពុជា។ នៅពេលដែលកម្ពុជា ត្រូវបាននាំចេញម្រេចចំនួន ៣.៧៧១ តោន ពីតំបន់កំពត ទៅទីក្រុងព្រៃនគរ និងមានតែ ៨៨៤ តោនប៉ុណ្ណោះ ដែលនាំចេញពីហាទៀង (ដែលជាកន្លែងដាំម្រេចរបស់កូសាំងស៊ីន) ទៅទីក្រុងព្រៃនគរដូចគ្នា។ នេះជាទង្វើដ៏អាក្រក់មួយ និងអយុត្តិធម៌របស់រដ្ឋបាលអាណានិគម ក្នុងកិច្ចការនយោបាយសេដ្ឋកិច្ចចំពោះប្រជាជនខ្មែរក្រោមដំបូលអាណានិគម។

ក.៤ ការនាំចេញបសុសត្វ

ចំពោះការនាំចេញបសុសត្វ (គោ និងក្របី) ក្នុងសម័យអាណាព្យាបាលបារាំងបានប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ចាប់តាំងពីឆ្នាំ ១៨៩៧ ដល់ឆ្នាំ ១៩២១។ ចំនួនគោ ក្របីដែលបាននាំចេញពីកម្ពុជាមានចំនួនខុសៗគ្នាទៅតាមបណ្តាឆ្នាំផ្សេងៗគ្នា ហើយឆ្នាំដែលល្អសម្រាប់ការនាំចេញនោះគឺមានឆ្នាំ ១៩០៨ ទៅ ១៩១១ និងឆ្នាំ ១៩១៩ ទៅ ១៩២១ ដែលក្នុងពេលនោះការនាំចេញសត្វពាហនៈខាងលើមានចំនួនគិតជាមធ្យម ពី ១៥.០០០ ក្បាល ទៅ ៦០,០០០ ក្បាល ក្នុងមួយឆ្នាំៗ។ ឆ្នាំដែលនាំចេញតិចគឺ ឆ្នាំ ១៩១២ និងឆ្នាំ ១៩១៧ ដោយមូលហេតុមាន បញ្ហាជំងឺរាតត្បាតដែលធ្វើអោយទីផ្សារគោលដៅទាមទារនូវលក្ខខណ្ឌស្តង់ដា បសុព្យាបាលសត្វពាហនៈ និងធ្វើពហិការចំពោះការទិញសត្វពាហនៈពីកម្ពុជា។

ទីផ្សារគោលដៅសំខាន់បំផុតរបស់យើងសម័យនោះ គឺប្រទេស ហ្វីលីពីន កូសាំងស៊ីន និងផ្សេងៗទៀត។ នៅឆ្នាំ ១៩១០ គ្រាន់តែនៅក្នុងត្រីមាសទី២ ប្រទេសកម្ពុជា បាននាំចេញសត្វពាហនៈចេញទៅក្រៅប្រទេសក្នុងបរិមាណយ៉ាងច្រើនដូចជាករណី ៖

- នាំចេញទៅប្រទេសហ្វីលីពីន មានប្រមាណជា ៩.២៣៤ ក្បាល ក្នុងនោះនាំចេញពីខេត្តកណ្តាល ៥.៤៤៨ ក្បាល ពីខេត្តកំពង់ធំ ៣៤៤ ក្បាល ពីខេត្តកំពង់ចាម ២.៩៣៧ ក្បាល ពីខេត្តព្រៃវែង និងកំពត ៥០៥ ក្បាល។
- ទៅកូសាំងស៊ីន ប្រមាណ ៧.០១៦ ក្បាល ក្នុងនោះមាន ៦.៦៨២ ក្បាលនាំចេញពីខេត្តកណ្តាល ១២៥ ក្បាល ពីខេត្តកំពង់ចាម ៩២ ក្បាល ពីក្រុងភ្នំពេញ ៦០ ក្បាល មកពីខេត្តតាកែវ និងកំពត។
- ទៅសឹង្ហបុរី ចំនួន ៩០០០ ក្បាល។

- ទីផ្សារសម្រាប់នាំសត្វពាហនៈចេញផ្សេងទៀតដូចជាបាងកក និងហុងកុង គឺគ្រាន់តែជាទីផ្សារនាំចេញម្តងម្កាល និងតិចតួចប៉ុណ្ណោះ។

អ្នកធ្វើជំនួញសត្វពាហនៈជំនាន់នោះមានជនជាតិចាម ជ្វា ហ្វីលីពីន និងចិន។ ជនជាតិចាម និងជ្វា ដែលរស់នៅស្ទើរគ្រប់ទីកន្លែង សំខាន់ៗនោះ បានធ្វើជាឈ្មួញកណ្តាលដ៏សំខាន់ នៃពាណិជ្ជកម្មបសុសត្វ ។ តែសង្កេតឃើញពួកឈ្មួញទាំងនេះធ្វើការរកស៊ីជួញដូរសត្វ គោ ក្របី នៅតាមតំបន់នានាក្នុងខេត្តកំពង់ចាម ដូចជានៅស្រុក ស្រីសន្ធរ កងមាស ឬនៅតំបន់នានាក្នុងខេត្តកំពង់ធំ ដែលធ្វើអោឈ្មួញកណ្តាល របស់ថៅកចាមនៅភ្នំពេញ។ ជនជាតិនេះជាអ្នកឯកទេសខាងពាណិជ្ជ កម្មនាំចេញទៅហ្វីលីពីន និងទៅកូសាំងស៊ីន និងប្រកួតប្រជែងគ្នាយ៉ាង ខ្លាំង ជាមួយនឹងជនជាតិចិន ដែលរកស៊ីនៅខេត្តកណ្តាល តាកែវ និង ព្រៃវែង ។ គេ ឃើញមានជនជាតិហ្វីលីពីន បានបញ្ជូនភ្នាក់ងាររបស់ខ្លួនមួយចំនួន អោយមកទំនាក់ទំនងទិញសត្វពាហនៈ នៅនឹងមូលដ្ឋានជន បទផ្ទាល់តែម្តង ។ ពួកអ្នកស្រែកម៉ានីលហ្វីលីពីន) ធ្វើដំណើរជាប្រចាំ ក្នុងខេត្តកំពង់ចាម ដើម្បីជ្រើសរើសសត្វ និងត្រួវពិនិត្យលើប្រតិបត្តិការ លើកដាក់សត្វពាហនៈចុះក្នុងកប៉ាល(អាជីវកម្មនេះ មានសកម្មភាពមមា ញឹកបំផុតក្នុងឆ្នាំ ១៩០៨-១៩១១)។

ក.៥ ការនាំចេញព្រៃឈើ អនុផលព្រៃឈើ និងផលិតផលកសិកម្មផ្សេងៗទៀត

ក្រៅពីការនាំចេញនូវផលិតផលកសិកម្មសំខាន់ៗ ដូចបានរៀបរាប់ខាងលើ នៅសម័យបារាំងប្រទេសកម្ពុជា ក៏បាននាំផលិតផលព្រៃឈើមួយចំនួន ទៅកាន់ប្រទេសឥណ្ឌូចិន សៀម និងសឹង្ហបុរី ដែលក្នុងឆ្នាំ ១៩២០ មានប្រហែល ៨៧ តោន និងនាំចេញនូវជ័រវង្គ ល័ក ស្នែងសត្វ ក្រមួន ចន្លុះ។ ក្រៅពីនេះ ផលិតផលវត្ថុធាតុដើមកសិកម្មកែច្នៃ និងមិនទាន់កែច្នៃជាច្រើនទៀតចំនួនរាប់រយតោន ដែលបានធ្វើការនាំចេញ ដូចជាផលិតផលល្ហុងខ្មែរ ដែលបានដាំក្នុងឆ្នាំ ១៩១៧ និងឆ្នាំ ១៩១៨ ត្រូវបាននាំចេញទៅព្រៃនគរ (គ្រាប់មិនទាន់ស្ល)រួចបន្តទៅប្រទេសបារាំង (ក្នុងឆ្នាំ ១៩១៨ កសិករទទួលផលពីដំណាំនេះប្រមាណជា ១.១៩៥ តោន) និងបាននាំចេញជ័រវង្គ ទៅប្រទេសអឺរ៉ុបកាត់តាមទីក្រុងបាងកក។ ការនាំចេញរុក្ខជាតិថ្នាំបុរាណក្រវាញ ដែលមានចំនួន ៦ ទៅ ១០ តោន ក្នុងឆ្នាំ ១៩០៤ និង ១៩០៧ ហើយឆ្នាំ ១៩១៤ ការនាំចេញក្រវាញ គឺទទួលបានចំណាត់ថ្នាក់ល្អបង្គួរ ក្នុងការនាំចេញពីឥណ្ឌូចិន។ លើសពីនេះទៀត យើងបាននាំចេញថ្នាំជក់ ស្ករត្នោត ផលិតផលត្រី សាច់កែច្នៃ ពោតសណ្តែក ល្ង និងផ្សេងៗទៀត ដែលមិនអាចកំណត់បរិមាណបាន។

៣.៣.៤ ជញ្ជីងពាណិជ្ជកម្មអន្តរជាតិ មុនឆ្នាំ ១៩២០

ជញ្ជីងពាណិជ្ជកម្ម គឺជាខ្នាតវាស់វែងពីប្រសិទ្ធភាពនៃការអនុវត្តនូវទំនាក់ទំនងសេដ្ឋកិច្ចពាណិជ្ជកម្ម រវាងប្រទេសមួយធៀបនឹងប្រទេស ក្រៅដើម្បីជាមូលដ្ឋានសម្រាប់វាយតម្លៃ ពីកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច នៃប្រទេសនោះ។

នៅឆ្នាំទីមួយនៃការបញ្ចូលបណ្តាខេត្តនានាភាគខាងជើងរបស់ប្រទេសកម្ពុជា ជាឧបសម្ព័ន្ធ (កាត់ពីសៀមមកអោយខ្មែរ) ពេលនោះប្រទេសកម្ពុជាបានកាត់បន្ថយអតុល្យភាពសាច់ប្រាក់ ៧.០០០.០០០ ហ្វង់ លើពាណិជ្ជកម្មសរុបនៅខែកក្កដា ឆ្នាំ ១៩០៧ ដល់ខែកក្កដា ឆ្នាំ ១៩០៨។ ដូច

ជា នៅចន្លោះខែមិថុនា ឆ្នាំ ១៩០៦ ដល់ខែមិថុនា ឆ្នាំ ១៩០៧ ប្រទេសកម្ពុជាបាននាំចេញផលិតផលសរុប គិតជារូបិយប័ណ្ណ ចំនួន ៩.៩៤២.២៥៧ ហ្វ្រង់ ទល់នឹង ២.៩៧៩.៤៤៧ ហ្វ្រង់នៃការនាំចូល។ សារៈសំខាន់នៃការបញ្ចូលបណ្តាខេត្តភាគខាងជើង ជាពិសេសខេត្តបាត់ដំបង ព្រោះជាជង្រុកស្រូវ និងត្រី គឺបានស្តែងអោយឃើញកាន់តែច្បាស់អំពីអនុភាពអត្ថប្រយោជន៍សេដ្ឋកិច្ចបន្ថែមរបស់ខ្មែរ ចំពោះមុខនៃអំណាចសេដ្ឋកិច្ចរបស់ឥណ្ឌូចិន។

ប៉ុន្តែបើយើងក្រឡេកមើលទៅលើទំនាក់ទំនងទ្វេរភាគី នៅក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ តាមរយៈឯកសារលម្អិតនៃវិស័យនាំចេញ និងនាំចូលរបស់ប្រទេសបារាំង ក្នុងសម័យកាលឆ្នាំ ១៩០៧ ដល់ ១៩១៧ យើងអាចវាយតម្លៃបានថា វាមានវិសមភាពយ៉ាងខ្លាំង ជាមួយនឹងជញ្ជីងពាណិជ្ជកម្មរបស់យើង ព្រោះនៅក្នុងឆ្នាំ ១៩០៧ កម្ពុជាបានធ្វើការនាំចេញទៅបារាំង គិតជាសាច់ប្រាក់ប្រមាណតែ ៩៣៩.៨៥៧ហ្វ្រង់ ទល់នឹងការនាំចូលទំនិញពីប្រទេសបារាំងមកកម្ពុជាដែលមានតម្លៃស្មើនឹង ៤.៥០០.០០០ ហ្វ្រង់ឯណោះ ឬស្មើនឹង ១០% នៃការនាំចេញសរុប។ ដូចគ្នាដែរ នៅឆ្នាំ ១៩១៧ ការនាំចេញរបស់កម្ពុជាទៅបារាំងមានតម្លៃ ទឹកប្រាក់តែ ១.៨០០.០០០ ហ្វ្រង់ ប៉ុណ្ណោះ ដែលការនាំចូលពីបារាំង មកខ្មែរមានតម្លៃកើនឡើងរហូតដល់ ៩.៧០០.០០០ ហ្វ្រង់។ គួរបញ្ជាក់ថា ក្រោយឆ្នាំ ១៩១៧ រាល់ករណីទាំងអស់ នៃសកម្មភាពនាំចេញផលិតផលរបស់ខ្មែរទៅប្រទេសបារាំង បានធ្លាក់ចុះស្ទើរស្មើសូន្យ ក្នុងពេលដែលសកម្មភាពនាំចូលផលិតផលសម្រេចពីបារាំងមកខ្មែរបន្តការកើនឡើងបើទោះបីជាមានឧបសគ្គច្រើនយ៉ាងណាក៏ដោយ។

ជាសរុបមក យើងគប្បីមានការប្រុងប្រយត្ន័ ចំពោះការធ្វើសេចក្តីសន្និដ្ឋានបែបណាមួយ អំពីអត្ថប្រយោជន៍នៃវិស័យពាណិជ្ជកម្មអន្តរជាតិរបស់ខ្មែរក្នុងសម័យនោះ ហើយជារួមអ្វីដែលយើងអាចសំយោគជាសន្និដ្ឋានបានគឺ ទីមួយយើងបានទទួលជោគជ័យដ៏មហិមា ដោយការនាំចេញច្រើនជាងការនាំចូលរហូតដល់ ៣,៣ ដង (ក្នុងឆ្នាំ ១៩១៧)។ ប៉ុន្តែទីពីរៈ ការនាំចេញច្រើនមិនមានន័យថា កសិករខ្មែរអាចទទួលបានផលប្រយោជន៍ពីការងារនេះទេ។ ព្រោះប្រាក់ចំណេញទាំងអស់ បានគ្រប់គ្រងដោយឈ្មួញកណ្តាលផ្តាច់មុខក្នុងការទិញ-លក់ និងដឹកជញ្ជូន ហើយដោយសារអត្រានៃការចងការប្រាក់មានតម្លៃខ្ពស់ ធ្វើអោយកសិករប្រឈមមុខនឹងការជំពាក់បំណុលគេពុំរ៉ែ ប្រឈមមុខនឹងការរឹបអូសផលិតផលប្រឈមមុខនឹងការបន្ទាបតម្លៃផលិតផលរបស់ខ្លួន ដែលមិនអាចរំដោះពីភាពក្រីក្របាន។ ចំពោះពួកឈ្មួញកណ្តាលបាន ទាញយកផលប្រយោជន៍សេដ្ឋកិច្ចពីការធ្វើជំនួញដែលធ្វើអោយមាន សិទ្ធិអំណាចធំ ហើយឈ្មួញកណ្តាលទាំងនោះមិនខ្វាចអ្វីទាល់តែសោះ ចំពោះភាពទន់ខ្សោយនិងភាពក្រីក្រក្នុងការរស់នៅរបស់កសិករខ្មែរ ក្នុងទីជនបទនោះទេ ហើយពួកឈ្មួញទាំងនោះព្រួយបារម្ភតែម្យ៉ាងគត់ គឺបរិមាណប្រមូលផលកសិកម្មមិនបានល្អ ហើយមិនមែនសម្រាប់លក់ បើទោះជាមានគ្រោះទុក្សក៏ដោយ ប៉ុន្តែគឺសម្រាប់តែការនាំចេញប៉ុណ្ណោះ។

និយាយជារួម ការរីកចម្រើននៃវិស័យសេដ្ឋកិច្ចពាណិជ្ជកម្មរបស់ប្រទេសខ្មែរ ក្នុងសម័យឆ្នាំ ១៩០០ ដល់ឆ្នាំ ១៩២០ បាននាំមកនូវការ ផ្លាស់ប្តូរបន្តិចបន្តួចនូវដំណើរការសេដ្ឋកិច្ចរបស់កសិករខ្មែរ តែប៉ុណ្ណោះ យ៉ាងណាមិញបន្ទាប់ពីបានផលិត និងលក់ផលិតផលសម្រេចរបស់ខ្លួន ក្នុងស្ថានការណ៍

នៃការគាបសង្កត់តម្លៃ ឬលក់ខ្សែឡុង) កសិករខ្មែរត្រូវបង្ខំចិត្ត ចំពោះការចំណាយឡើងវិញ ក្នុងការដោះស្រាយជីវភាព ដើម្បីការរស់រានបន្ត មិនមែនដើម្បីសន្សំទុកនោះទេ។

៣. ៣.៥ ស្ថានភាពពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ១៩២៩-១៩៣៣

វិបត្តិសេដ្ឋកិច្ចពិភពលោកនាឆ្នាំ ១៩២៩-១៩៣៣ បានជះឥទ្ធិពលអាក្រក់មកលើវិស័យសេដ្ឋកិច្ចអន្តរជាតិរបស់ប្រទេសកម្ពុជា ដោយហេតុថាឥទ្ធិពលទាំងនេះបានទាញអោយមានការបញ្ចុះតម្លៃទំនិញនាំចេញពីក្នុងប្រទេស និងមានការដាក់កម្រិតពាណិជ្ជកម្មក្រៅប្រទេស ក៏ដូចជាផលិតកម្មកសិ-ឧស្សាហកម្មក្នុងស្រុក។ វិបត្តិសេដ្ឋកិច្ចបានផ្តល់ លទ្ធភាពអោយមានការប្រមូលផ្តុំមូលធន តែនៅក្នុងកណ្តាប់ដៃរបស់ក្រុមហ៊ុនពាណិជ្ជកម្មអន្តរជាតិផ្តាច់មុខធំៗតែប៉ុណ្ណោះ។

ប៉ុន្តែចាប់តាំងពីសម័យកាលនៃពាក់កណ្តាលទសវត្សទី៣០ រហូតដល់សម័យកាលនៃការចាប់ផ្តើមសង្គ្រាមលោកលើកទី២ សេដ្ឋកិច្ចប្រទេសកម្ពុជាបានរីកលូតលាស់យ៉ាងខ្លាំងក្លា។ ក្នុងស្ថានភាពនៃការរៀបចំសង្គ្រាមលោកបែបនេះ ប្រទេសកម្ពុជាបាននាំចេញនូវផលិតផល កសិកម្មសំខាន់ៗជាច្រើន។

ជាទូទៅជារៀងរាល់ឆ្នាំជាមធ្យម ប្រទេសកម្ពុជាមានការនាំចេញស្រូវទៅបរទេសប្រមាណពី ១៥០.០០០ ទៅ ២៥០.០០០តោន/ឆ្នាំ។ ប៉ុន្តែនៅឆ្នាំ ១៩៣៧ ប្រទេសកម្ពុជាបាននាំចេញនូវផលិតផលកសិកម្ម ដូចជា ស្រូវ ៤០០.០០០តោន (ឬស្មើនឹង ៣៧១នៃផលិតផលស្រូវសរុប) ពោតរហូតដល់ ៣០០.០០០ ទៅ ៤០០.០០០តោន និងម្រេចប្រមាណ ៣.២០០ តោន។ នៅក្នុងឆ្នាំខាងលើនេះ ការនាំចេញកៅស៊ូរបស់ខ្មែរមាន ចំនួន ១២.០០០តោន ទៅក្រៅប្រទេស។ ក្រៅពីដំណាំកសិ-ឧស្សាហកម្ម នាសម័យអាណាព្យាបាលបារាំង ក៏បាននាំចេញនូវគ្រឿងសិប្បកម្ម ចម្លាក់ជាច្រើនទៀន (ចម្លាក់លើភ្លុកដំរី គ្រឿងមាសប្រាក់ និងសំរិទ្ធ ...។

គួរបញ្ជាក់ថា កិច្ចការសេដ្ឋកិច្ចនៃប្រទេសនានានៅឥណ្ឌូចិន មានទាំងសេដ្ឋកិច្ចប្រទេសកម្ពុជាជាដើម បានត្រូវដាក់អោយនៅក្នុងការបម្រើផលប្រយោជន៍ចក្រពត្តិនិយមបារាំង ហើយជាពិសេស នៅសម័យមុន សង្គ្រាមលោកលើកទី ២ ប្រទេសនៅឥណ្ឌូចិន បានប្រែក្លាយទៅជា ប្រទេសផលិតករនូវផលិតផលកសិកម្ម និងវត្ថុធាតុដើម សម្រាប់ប្រទេសបារាំង ដូច្នេះហើយបានជានៅសម័យដើមនៃសង្គ្រាមលោក លើកទី២ ទំនិញដែលនាំចេញពីបណ្តាប្រទេសឥណ្ឌូចិនទៅកាន់ប្រទេស បារាំង មានតម្លៃរហូតដល់ ១១លាន ហ្វ្រង់ (ជារូបិយប័ណ្ណ)។

ចំពោះទំនិញនាំចូល ក្នុងរបបគ្រប់គ្រងនៃអាណាព្យាបាលបារាំង បានបង្កើតជាឧបសគ្គដល់ការលូតលាស់នៃផលិតកម្មជាតិ នៅប្រទេស កម្ពុជា ដោយហេតុថា ទីផ្សារក្នុងប្រទេសត្រូវបានបើកចំហដល់ការនាំចូលដោយសេរី (គឺមិនត្រូវបានយកពន្ធគយ) នូវគ្រឿងឧស្សាហកម្មពី ប្រទេសបារាំង។

## ៥.៤. វិស័យហិរញ្ញវត្ថុ និងធនាគារ

នៅសម័យអាណាព្យាបាលបារាំងជីវភាពខាងសេដ្ឋកិច្ច ទាំងមូលនៃប្រទេសឥណ្ឌូចិន មានទាំងប្រទេសកម្ពុជាផងដែរ បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារឥណ្ឌូចិន។

ប្រភពដ៏សំខាន់នៃប្រាក់ចំណូលដល់ថវិកាជាតិ បានមកពីប្រាក់ចំណូលនៃពន្ធដារដោយផ្ទាល់ និងដោយប្រយោល។ នៅសម័យបារាំង អ្នកស្រុកបានបង់ពន្ធដារគ្រប់ជំពូកទាំងអស់ តាំងពីពន្ធលើមនុស្ស ដែលជាសមាជិកដីធ្លី ពន្ធលើលំនៅដ្ឋាន ពន្ធសត្វពាហនៈ ពន្ធលើយានជំនិះ មានទូកជាដើម និងពន្ធរបរអាជីវកម្ម។ល។

### ៥.៤.១ ការយកពន្ធលើមនុស្ស

ផ្អែកលើទិន្នន័យមួយចំនួន បានសរសេរថា ៥០% នៃប្រាក់ចំណូលថវិកាប្រទេសកម្ពុជា បានមកពីការទារពន្ធដារដោយផ្ទាល់ លើប្រភេទពន្ធខាងលើ ដែលក្នុងនោះពន្ធដ៏សំខាន់ បានមកពីពន្ធលើមនុស្ស ជាសមាជិកគ្រួសារ និងពន្ធដីធ្លី។ បុគ្គលជាប់ពន្ធ គឺជាមនុស្សដែលមាន អាយុពី ២១ឆ្នាំ ដល់ ៥០ឆ្នាំ ដែលត្រូវបង់ពន្ធផ្ទាល់ខ្លួនប្រមាណ ២,៥០ រៀលក្នុងមួយឆ្នាំ មនុស្សដែលមានអាយុពី ៥១ឆ្នាំ ដល់ ៦០ឆ្នាំត្រូវបង់ពន្ធ ផ្ទាល់ខ្លួន ០,៨រៀល។ លើសពីនេះទៅទៀត បុគ្គលជាប់ពន្ធត្រូវបង់ប្រាក់បន្ថែមប្រមាណ ០,១រៀល ក្នុងមួយថ្ងៃសម្រាប់រយៈពេល ២០ថ្ងៃ បើសិនជាចង់រំដោះខ្លួនពីការចូលរួមក្នុងការងារសាធារណៈ។ សម្រាប់ពេលដ៏ទៃទៀតប្រចាំឆ្នាំ រដ្ឋអាចកោះហៅអ្នកស្រុកអោយជួយបំពេញការងារ ជួសជុលទំនប់ទឹក ប្រព័ន្ធប្រឡាយបង្ហូរទឹក ឬធ្វើសំណង់អគារសាធារណៈ។ល។ (យើងនឹងបញ្ជាក់អំពីការងារនេះ បន្ថែទៀតនៅទំព័រខាងក្រោយ)។

ថវិកាមួយភាគធំ ដែលរដ្ឋការអាណាព្យាបាលបារាំងប្រមូលបាន ពីការបង់ពន្ធ ត្រូវបានចំណាយទៅលើការធ្វើសង្គ្រាមដើម្បីកាន់កាប់ទឹកដី ចំណាយលើការផ្គត់ផ្គង់រដ្ឋការអាណានិគម ចំណាយលើការងារស្រាវជ្រាវដែនដីថ្មី និងការសាងសង់ទីក្រុង សាងសង់ប្រឡាយទំនប់។ល។

### ៥.៤.២ វិស័យពន្ធដារលើផ្នែកកសិកម្ម

យើងនឹងពិនិត្យមើលលម្អិតទៅលើដំណើរការប្រមូលពន្ធអាករ របស់រដ្ឋបាលអាណានិគម ចន្លោះឆ្នាំ ១៩០០ ដល់ឆ្នាំ ១៩២១ ដែល មានខ្លឹមសារពិស្តារដូចខាងក្រោម៖.

- ពន្ធអាករលើដីស្រែ និងចំការ

នៅសម័យនោះ ដីស្រែចំការទាំងអស់ដែលស្ថិតនៅក្រោមការ ប្រើប្រាស់របស់កសិករខ្មែរ បានស្ថិតក្រោមកម្មវត្ថុនៃការជាប់ពន្ធ ដែល បើគិតជាតម្លៃស្មើនឹង ១០% នៃតម្លៃផលិតផលដែលដាំដុះនៅលើដីស្រែ ចំការនោះ។ ចំពោះដំណាំស្រូវ រាល់រដូវប្រចូតកាត់គេត្រូវបង់ពន្ធជារូបិយ វត្ថុ ប្រមាណជា ១/១០ នៃតម្លៃស្រូវជូនដល់រាជរតនាគារ។ ជាក់ស្តែង នៅឆ្នាំ ១៩១៧-១៩២១ ប្រជាកសិករខ្មែរទាំងអស់ក្នុងមួយខេត្តកំពង់ចាម បានបង់ពន្ធលើដីស្រែចំការគិតជាមធ្យម ១៤៧.០០០ រៀល/១ឆ្នាំៗ នៅ ខេត្តកណ្តាល បានបង់ពន្ធប្រមាណ ៣៤.០០០រៀល/១ឆ្នាំៗ និង មណ្ឌលផ្សេងៗទៀត ក្នុងទំហំខុសៗគ្នា។

- ពន្ធអាករលើម្រេច

អាជ្ញាធរបារាំង បានចេញសេចក្តីប្រកាសកំណត់អត្រាពន្ធគយ ចំពោះផលិតផលសម្រេចប្រមាណជា ១០៤ ហ្វ្រង់/១០០ គ.ក សម្រាប់ ការនាំចេញទៅប្រទេសបារាំង ហើយបារាំងអនុញ្ញាត

អោយនាំចូល ២.១០០ តោន/ឆ្នាំ។ ប៉ុន្តែតម្លៃអត្រាពន្ធចំពោះផលិតផលម្រេច មិនស្ថិត ស្ថេរទេ ពេលខ្លះបារាំងតម្លើងអត្រាពន្ធភ្លាមៗ ពេលខ្លះបញ្ចុះមកវិញ បត់បែនទៅតាមទំនោរនៃអត្ថប្រយោជន៍របស់បារាំង។

- ពន្ធលើសំឡីកប្បាស

នៅក្នុង ឆ្នាំ ១៩៩១ ២ តម្លៃពន្ធគយសំឡីកប្បាសរបស់ខ្មែរ ត្រូវបានបង់ពន្ធក្នុងតម្លៃ ២ ហ្វ្រង់/១០០គ.ក សម្រាប់សំឡីដុលមិនទាន់ប្រឡេះគ្រាប់ និងត្រូវបង់ ៣ហ្វ្រង់/១០០គ.ក សម្រាប់សំឡីប្រឡេះគ្រាប់ហើយ ដែលអត្រាពន្ធគយនេះ មានតម្លៃស្មើនឹង ១/១២ នៃតម្លៃមធ្យមរបស់សំឡីកប្បាស។

- ពន្ធអាករលើថ្នាំជក់

យោងតាមឯកសារស្រាវជ្រាវនៅខែកក្កដា ឆ្នាំ ១៩០៦ ថ្នាំជក់ ត្រូវបានលក់អោយឈ្មួញកណ្តាល ក្នុងតម្លៃ ៨ រៀល/១ Picul (ដែលពីមុនមានតម្លៃ ៣៥ រៀល/១ Picul) គឺសមមូលទៅនឹងតម្លៃ ៤,១ គ.ក/១រៀល (ឬ ០,២៥ រៀល/១ គ.ក)។ រីឯតម្លៃពន្ធអាករ នៃចរាចរថ្នាំ ជក់លើទីផ្សារ ត្រូវបង់ពន្ធស្មើនឹង ១៥ រៀល/១ Picul ដែលសមមូលទៅ នឹង ០,៤៥ គ.ក/១រៀល (ឬ ២ រៀល/០,៩ គ.ក) ដែលបន្ទុករបស់តម្លៃ ន្ធ គឺមានតម្លៃថ្លៃជាងពីរដង នៃតម្លៃថ្នាំជក់ ដែលបានចរាចរ។

- ពន្ធលើសត្វពាហនៈ

ពួកអាណានិគមបារាំង ជានិច្ចកាលជំទាស់ចំពោះការនាំសត្វពាហនៈចេញពីតំបន់ឥណ្ឌូចិន ហើយបានចាត់ទុកថា ការនាំសត្វចេញនេះជាការខ្វាក់ភ្នែករបស់រដ្ឋបាលបារាំង ព្រោះមុននឹងក្រោយនឹងធ្វើអោយចុះខ្សោយដល់ការចិញ្ចឹមសត្វនៅតំបន់ឥណ្ឌូចិន។

នៅក្នុងឆ្នាំ ១៩០៧ ចំពោះតម្លៃបង់ពន្ធគយ មានតម្លៃ ៥ ហ្វ្រង់ សម្រាប់គោមួយក្បាល និង ២០ ហ្វ្រង់ សម្រាប់ក្របីមួយក្បាល សម្រាប់ការនាំចេញ។ អត្រាតម្លៃពន្ធអាករនេះ មានការប្រែប្រួលឥតឈប់ឈរ ក្នុងគោលបំណងទប់ស្កាត់ ការនាំចេញសត្វពាហនៈទៅក្រៅប្រទេសក្រៅពីតំបន់ឥណ្ឌូចិន។ ដូចជាក្នុងឆ្នាំ ១៩២០ អត្រាពន្ធគយនាំចេញត្រូវបានតម្លើងថ្លៃជាថ្មីទៀត គឺពី ៥ ទៅ ១៥ ហ្វ្រង់ ចំពោះគោមួយក្បាល និង ពី ២០ ទៅ ៣០ ហ្វ្រង់ ចំពោះក្របីមួយក្បាល។ ក្រៅពីការបង់បន្ទុកពន្ធ អាករខាងលើនេះ ពួកអាណានិគមបារាំងបានចេញវិធានការមួយចំនួនទៀត ក្នុងគោលបំណងទប់ស្កាត់ការនាំចេញសត្វពាហនៈដូចជា ៖

- ឆ្នាំ ១៩០៩ ហាមឃាត់ការលក់គោញី ដែលមានអាយុតិចជាង ៧ឆ្នាំ។
- ឆ្នាំ ១៩១១ ហាមឃាត់ការលក់គោញី ដែលមានអាយុតិចជាង ៩ឆ្នាំ។
- ឆ្នាំ ១៩១៧ ហាមឃាត់ការលក់គោញីទាំងអស់។

វិធានការខាងលើនេះ បើអនុវត្តក្នុងរយៈពេលយូរអង្វែង វាអាចបំផ្លាញដល់ការរីកចម្រើននៃវិស័យចិញ្ចឹមសត្វពាហនៈរបស់ខ្មែរតែម្តង។ ជាតុពិត វិធានការនេះ ជាយថាហេតុអាចជាប្រភពមួយនៃនយោបាយ ផ្គត់ផ្គង់សាច់សត្វ ចំពោះប្រទេសបារាំងក្នុងសង្គ្រាមលោកលើកទី ១។

- ចំពោះការបង់ពន្ធដារ បារាំងគិតជាសាច់ប្រាក់ ដូចជាការបង់ ពន្ធលើដីធ្លី មានទំហំ ១០% ពីទិន្នផលស្រូវ ដែលជាប្រព័ន្ធពីមុនរបស់ព្រះមហាក្សត្រ ប៉ុន្តែត្រូវបង់ពន្ធជារូបិយវត្ថុ។ ការងារប្រមូលពន្ធនៅតាម ខេត្ត-ក្រុង បំពេញដោយរដ្ឋអំណាចមូលដ្ឋានផ្ទាល់ ពេលប្រមូលពន្ធដារបានហើយ ត្រូវតែយកទៅប្រគល់អោយរ៉េស៊ីដង់បារាំង នៅតាមមូលដ្ឋានរបស់ខ្លួន។ នៅសម័យនោះ ប្រជាពលរដ្ឋគ្រប់រូបត្រូវតែបង់ពន្ធពីរប្រភេទគឺ ពន្ធដារលើខ្លួន និងពន្ធដារលើដីធ្លី។ ចំពោះអ្នកដែលត្រូវរួចពន្ធ មានតែសមាជិករាជវង្ស ព្រះសង្ឃ និងមេដឹកនាំស្ថាប័នជា ខ្ពស់ហើយក៏មានប្រជាជន ជាពួកកុលសម្ព័ន្ធ មួយចំនួនដែរ។ [110]

## ៥.៤.៣ ការប្រើប្រាស់រូបិយវត្ថុ

នៅសម័យអាណានិគមនិយមបារាំង ប្រទេសដែលស្ថិតក្នុងសហភាពឥណ្ឌូចិនទាំងអស់ គឺត្រូវបានប្រើប្រាស់រូបិយវត្ថុរួមគ្នា ដែលនៅក្នុងក្រដាសរូបិយវត្ថុទាំងនោះបញ្ជាក់អំពី ខ្នាតតម្លៃដូចគ្នា ប៉ុន្តែហៅឈ្មោះទៅតាមការទម្លាប់របស់រូបិយវត្ថុក្នុងស្រុករៀងៗខ្លួន។ ក្រៅពីនោះគេក៏មានរូបិយប័ណ្ណរបស់បារាំង( លុយហ្វ្រង់ )ផងដែរនៅក្នុងចរាចរសេដ្ឋកិច្ចទូទៅ។ ចំពោះរូបិយវត្ថុខាងលើនេះឈ្មោះថា piastre ដែល នៅក្នុងក្រដាសប្រាក់នោះ បានកំណត់ខ្នាតតម្លៃដូចគ្នា( សមមូលគ្នា ខុសតែឈ្មោះដែលត្រូវហៅតាមប្រទេសនិមួយៗតែប៉ុណ្ណោះគឺៈ

១ piastre = ១ រៀល = ១ ដុង = ១ រូបិយវត្ថុរបស់ឡាវ ១ piastre = ៤,៥៤ ហ្វ្រង ។

## ៥.៥. វិស័យគមនាគមន៍សាធារណៈ

នៅឆ្នាំ ១៩១៦ ក្នុងខែមករា សហគ្រាសសាធារណៈការ ត្រូវបានបង្កើតឡើងជាច្រើន ហើយក្នុងពេលតែមួយត្រីមាសតែប៉ុណ្ណោះ ចំនួនសហគ្រាសកើនដល់ ៣៥។ កិច្ចការសំខាន់របស់សហគ្រាសទាំងនេះ ទាក់ទងនឹងការចាប់ផ្តើមឡើងនៅកម្ពុជា ក្នុងចលនាស្ថាបនានូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន ប្រឡាយទឹក ដែលជាមធ្យោបាយសម្រួល គឺដល់ការធ្វើចរាចរដឹកជញ្ជូនផលិតផលកសិកម្ម និងធ្វើកសិកម្ម។

ម្យ៉ាងទៀត នាសតវត្សទី ២០ ទាក់ទងទៅនឹងវិស័យគមនាគមន៍ និងដឹកជញ្ជូន យើងសង្កេតឃើញថា មធ្យោបាយធ្វើដំណើរគ្រប់ប្រភេទ ក្នុងប្រទេសកម្ពុជាបានចាប់ផ្តើមមានការប្រើប្រាស់យានជំនិះផ្សេងៗ ក្នុងការធ្វើដំណើរ ដែលសុទ្ធសឹងជាផលិតផលនាំចូល។

## ៥.៦. វិស័យសិក្សាធិការជាតិ

នៅសម័យនោះមានការសាងសង់គ្រឹះស្ថានសិក្សានានាជាច្រើន និងបានសាងសង់សាលាបច្ចេកទេសទៀតផង។ នៅឆ្នាំ ១៩១១ មជ្ឈ មណ្ឌលបឋមសិក្សានៅកម្ពុជាទាំងមូលមានប្រមាណ ៣០ខ្នង ប៉ុណ្ណោះ ដែលមានកុមារចូលរៀនចាប់ពីអាយុ ៨ឆ្នាំឡើងទៅ ក្នុងនោះមានការសិក្សារៀនអាន

ជាភាសាខ្មែរ រៀនលេខ និងរៀនភាសាបារាំង។ ក្រៅពីនេះ ការសិក្សារបស់កុមារបានប្រព្រឹត្តទៅនៅតាមបណ្តាវត្តនានា។

នាសម័យអាណានិគម យុវជន យុវតីខ្មែរ អាចទទួលការអប់រំមុខ ជំនាញនៃមុខរបរខាងសិប្បកម្ម និងសិល្បៈ។ នៅក្នុងឆ្នាំ ១៩១៧ នៅ សាលារចនា នាទីក្រុងភ្នំពេញ ត្រូវបានបើកទ្វារដើម្បីទទួលយុវជន យុវនារីខ្មែរ អោយហាត់រៀនលើមុខជំនាញសិប្បកម្ម ដូចជា សិប្បកម្មចម្លាក់ សិប្បកម្មធ្វើគ្រឿងមាសប្រាក់ និងជាងស្មូនឆ្នាំង។ នៅឆ្នាំ ១៩៣៧ នៅសាលារចនា បានទទួលសិស្សានុសិស្សខ្មែរប្រមាណ ១៣៥នាក់ ដើម្បីបង្ហាត់បង្រៀននូវជំនាញសិប្បកម្មខាងលើ។

នៅឆ្នាំ ១៩២៤ កម្មវិធីសិក្សានៅក្នុងសាលារៀន ត្រូវបានត្រួតពិនិត្យរៀបចំសារជាថ្មី ដើម្បីសម្របទៅតាមសេចក្តីត្រូវការនៃបច្ចុប្បន្នភាពហើយត្រូវបានដាក់ក្រោមការត្រួតត្រារបស់រដ្ឋការបារាំង។ លុះដល់ ឆ្នាំ១៩៣៧នៅប្រទេសកម្ពុជាយើង បានសាងសង់សាលាបឋមសិក្សាប្រមាណ ៨១៣ខ្នង ដែលបានទទួលសិស្សានុសិស្សអោយចូលរៀនចំនួន ៣៤.០០០នាក់។ សិស្សានុសិស្សដែលរៀននៅតាមវត្តអារាម ក៏ដូចជារៀននៅសាលាបឋមសិក្សានានាខាងលើដែលចេះអានសរសេរ ជាភាសាខ្មែរ ហើយអាចចូលរៀននៅសាលាបឋមសិក្សាបារាំង ដោយការសិក្សាបានប្រព្រឹត្តទៅជាភាសាបារាំង ហើយកម្មវិធីសិក្សាបានត្រូវរៀបចំឡើងប្រហាក់ប្រហែលនឹងកម្មវិធី នៅសាលាបឋមសិក្សាប្រទេសបារាំង។ នៅឆ្នាំ ១៩៣៧ ដដែល សាលាបឋមសិក្សាតាមរបៀបបារាំង មានចំនួនដល់ ១១៧ ខ្នង ដែលក្នុងនោះមានសិស្សានុសិស្សប្រមាណជាង ១១.០០០នាក់រៀននៅសាលាទាំងនោះ។ តាមធម្មតាសាលាទាំង នោះ បានត្រូវកសាងឡើងនៅទីក្រុងសំខាន់ៗនៃប្រទេស។

នៅក្នុងឆ្នាំ១៩៣៥ អនុវិទ្យាល័យស៊ីសុវត្ថិដែលបានបង្កើតឡើង តាំងពីឆ្នាំ ១៩១១) ត្រូវបានប្រែក្លាយជាវិទ្យាល័យស៊ីសុវត្ថិវិញ ហើយនៅពេលនោះក៏មានការបណ្តុះបណ្តាលគ្រូបង្រៀន សម្រាប់សាលាបឋមសិក្សា និងបណ្តុះបណ្តាលការងាររដ្ឋបាលដល់មន្ត្រីរាជការទៀតផង។ នៅទីក្រុងភ្នំពេញ តាំងពីឆ្នាំ ១៩០៣ មានការបង្កើតសាលាអប់រំវិជ្ជាជីវៈ កម្មករ ដែលនៅក្នុងអំឡុងឆ្នាំ ១៩២៣ សាលានេះ បានត្រូវកែប្រែទៅជា អនុវិទ្យាល័យបច្ចេកទេសសម្រាប់ការអប់រំក្រេបខណ្ឌមធ្យមបច្ចេកទេស ក្នុងវិស័យបច្ចេកទេសផ្សេងៗ។ ឆ្នាំ១៩៣៧នៅអនុវិទ្យាល័យបច្ចេកទេស ខាងលើនេះ មានសិស្សានុសិស្សចូលរៀនចំនួន ១០០នាក់។[111]

ដើម្បីទៅបន្តការសិក្សានៅគ្រឹះស្ថានជាន់ខ្ពស់ និស្សិតត្រូវទៅបន្ត ការសិក្សានៅទីក្រុងហាណូយ នាសាកលវិទ្យាល័យឥណ្ឌូចិន ឬនៅទី ក្រុងប៉ារីស។ប៉ុន្តែនៅក្នុងប្រទេស ក៏មានគ្រឹះស្ថានសិក្សាពីរ ដែលបានបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការបណ្តុះបណ្តាលក្របខណ្ឌបញ្ញវន្តជាតិ គឺសាលាបាលីជាន់ខ្ពស់ និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត។ សាលាបាលីជាន់ត្រូវខ្ពស់ គឺបានបង្កើតឡើងនៅឆ្នាំ ១៩២៣ ដែលនៅឆ្នាំ ១៩៣៧ សាលានេះមាននិស្សិតជាព្រះសង្ឃចូលរៀនចំនួន ១៨០ អង្គ ។ ចំពោះវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត បានចាប់ផ្តើមបើកនៅឆ្នាំ ១៩៣០ ហើយនៅទីនោះមានការសិក្សាស្រាវជ្រាវអំពីគម្ពីរពុទ្ធសាសនាផ្សេងៗ។

## ៥.៧. សេចក្តីសន្និដ្ឋាន

សរុបមក ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា នាសម័យអាណានិគមបារាំង ជាពិសេស គឺចាប់តាំងពីពួកបារាំងបានចូលមគ្រប់គ្រងប្រទេសកម្ពុជា នាឆ្នាំ ១៨៦៣ រហូតដល់ដើមទសវត្សទី ២០ (នៃសតវត្សទី ២០) យើងសង្កេតឃើញថា ស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ហាក់ដូចជាមិនមានការរីកចម្រើនលើវិស័យណាមួយដែលគួរអោយកត់សម្គាល់នោះឡើយ។ ក៏ប៉ុន្តែចាប់តាំងពីទសវត្សទី ២០ រហូត ដល់មុនពេលសង្គ្រាមលោកលើកទី២ យើងពិនិត្យឃើញថា ស្ថានភាពសេដ្ឋកិច្ចមានការប្រែប្រួលជាវិជ្ជមាន។ ទ្រង់ទ្រាយនៃរបបសេដ្ឋកិច្ច បានដំណើរការឡើងតាមលក្ខណៈមូលធននិយម។

ចំពោះវិស័យកសិកម្មវិញ ទន្ទឹមនឹងការដាំដុះដំណាំជាប្រពៃណី ក៏មានការដាំដុះនូវដំណាំ កសិ-ឧស្សាហកម្មជាច្រើនទៀតដែរ ( កៅស៊ូ កប្បាស កាហ្វេ ថ្នាំជក់ ម្រេច )។

វិស័យដំណាំ កសិ-ពាណិជ្ជកម្ម ផលចំណេញក្រោមរបបអាណាព្យាបាលមិនបានស្តែងឡើងជាក់ស្តែងទេ។ គ្មានដំណាំកសិ-ពាណិជ្ជកម្ម ណាមួយត្រូវបានពង្រីកនោះទេ (យ៉ាងហោចណាស់ក៏អោយមានភាពសមរម្យ មនុស្សធម៌ដែរ) ពោលគឺគ្មានដំណាំណាមួយត្រូវបានធានាថានឹងរកអោយបាន ទីផ្សារពិតប្រាកដនោះទេ ហើយគ្មានទីផ្សារណាដែល កើតមានហើយត្រូវបានពង្រីកនោះដែរ។ ក្រោយពីមានការពង្រីកការដាំដុះមួយចំនួន សន្ទុះនៃដំណាំទាំងនេះ ក៏នៅតែជាប់គាំងនិងបានកាត់បន្ថយ ធ្វើអោយប៉ះពាល់ដល់ការបំបាត់ចោលចំពោះអាជីវករដែលទន់ខ្សោយ។ ដូចជាករណីដំណាំម្រេច នៅខេត្តកំពតជាដើម នៅក្នុងឆ្នាំ ១៨៩៧-១៩១០ កសិករជួបប្រទះនូវការក្ស័យធនយ៉ាងធ្ងន់ធ្ងរ។

ចំពោះអាជ្ញាធរបារាំងដែលទាក់ទងនឹងដំណាំនេះ បានធ្វើការ តាមដានដោយទាញយកតែផលប្រយោជន៍សម្រាប់ការអភិវឌ្ឍដំណាំ ពាណិជ្ជកម្ម ដែលការលក់ និងការនាំចេញដំណាំនោះ គ្រាន់តែបង្កើតនូវ យុត្តិកម្ម និងកិត្តិនាមដល់វត្តមានរបស់អាណាព្យាបាលបារាំង តែ ប៉ុណ្ណោះ។ ប៉ុន្តែ សកម្មភាព

[111] ឡុង សៀម, ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា, ឆ្នាំ ១៩៨៤

ពិតរបស់អាណាព្យាបាលបារាំង គឺមានកម្រិតទាប គិតតែពីការបង់ពន្ធ និងការលើកទឹកចិត្តទៀងពេល ដូចជា ការលើកទឹកចិត្ត ចំពោះសំឡីគរ សណ្តែកសៀង និងមន ជាឧទាហរណ៍ គឺមានរយៈពេលខ្លី ការបញ្ចូលដំណាំថ្មីៗ ដូចជាល្ហុង ខ្មែរ បង្កើតនូវតម្លៃ នៃការរំដើបរំជួលមួយជាទំលាប់នៃការដាំដំណាំ និងស្ថិតជាដំណាំកាលៈទេសៈ។ ជាទីបញ្ចប់ ក្រៅពីវិស័យកសិកម្ម ក្រុមភ្នាក់ងារពន្ធដារ និងរដ្ឋាករ បានអនុវត្តន៍ការយកពន្ធពិតៗលើប្រតិបត្តិការពាណិជ្ជកម្ម ដោយការបង់ពន្ធលើការនាំចេញ និងការចរាចរផលិតផល និងសម្រាប់គណនីរបស់ថវិកាទូទៅ។

មួយវិញទៀត ប្រទេសកម្ពុជានៅតែស្ថិតនៅជាប្រទេសកសិកម្ម ពីព្រោះប្រជាជនកម្ពុជា មិនមានការងារអ្វីក្រៅពីកសិកម្មទេ ព្រោះដោយសារតែពួកអាណានិគម មិនបានបញ្ចូលមូលដ្ឋានគ្រឹះនៃការកែប្រែណាមួយ ឬការធ្វើកំណែទម្រង់សេដ្ឋកិច្ច ឬការបណ្តាក់ជាក់ស្តែងនោះទេ ហើយពួកអាណានិគម ក៏មិនបានផ្តួចផ្តើមអ្វីដល់ប្រទេសកម្ពុជាក្រៅពីកសិកម្មនោះឡើយ។

ក្នុងវិស័យឧស្សាហកម្ម មានការសាងសង់រោងចក្រ សហគ្រាស ជាច្រើនដែលផលិតនូវទំនិញជាគ្រឿងភេសជ្ជៈ ចំណីអាហារ ដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការក្នុងស្រុក។

តាមការស្រាវជ្រាវ ចន្លោះឆ្នាំ១៨៩៧ ដល់ ១៩២០ គ្មានសកម្មភាពសិប្បកម្មណាមួយ ដែលហួសពីក្របខ័ណ្ឌសកម្មភាពជាបណ្តោះអាសន្ន និងក្របខ័ណ្ឌជំនួយនោះទេ ហើយក៏គ្មានឧស្សាហកម្មណាមួយ ដែលបានទទួលជោគជ័យផ្សេងពីឧស្សាហកម្មគ្រួសារនោះដែរ ក្រៅពីឧស្សាហកម្មបិតស្រានានា ដែលបានការពារដោយក្រុមការងាររដ្ឋាករ។ ចំពោះកិច្ចការដែលទាក់ទងនឹងឧស្សាហកម្មតូចតាច រដ្ឋបាល បារាំងបានតាមដាន និងបង្កើតឧស្សាហកម្មនេះ ដោយសមាណចិត្តខ្លះដែរ ព្រោះឧស្សាហកម្មទាំងនេះ ធ្វើអោយមានឥទ្ធិពលសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ជាមួយកិត្តិស័ព្ទ ក៏ប៉ុន្តែជាមួយគ្នានេះ អ្នកដឹកនាំបារាំង យល់ច្បាស់ថាកិច្ចការទាំងនេះ គឺជាកិច្ចការរបស់ផលិតករ និងអ្នកជំនួញចិន ហេតុនេះវាសនា និងផលប្រយោជន៍របស់បារាំងកម្រមានឥទ្ធិពល ពិតប្រាកដលើជីវិតរបស់ប្រទេសខ្មែរណាស់។

ទោះបីមានការនាំចូលនូវទំនិញគ្រប់មុខ ពីបណ្តាប្រទេសអឺរ៉ុប យ៉ាងណាក្តី ក៍ពុំបានធ្វើអោយចុះខ្សោយដល់របរសិប្បកម្ម នៅក្នុងប្រទេសខ្មែរណាស់ណានោះទេ ពោលគឺមានតែវិស័យសិប្បកម្មមួយចំនួន តែប៉ុណ្ណោះដែលបានចុះខ្សោយ ដូចជាសិប្បកម្មតម្បាញក្រណាត់សំពត់ ត្បាញក្រមា បិតស្រាអំបិល និងគ្រឿងភេសជ្ជៈជាដើម។ ដោយឡែកវិស័យដ៏ទៃទៀត ដូចជាវិស័យគ្រឿងបរិភោគ (ទឹកត្រីត្រីងៀត គ្រឿងទេស...) គ្រឿងចានឆ្នាំង គ្រឿងចម្លាក់លើក្លកដំរី គ្រឿងចម្លាក់ លើលោហៈ លើមាសប្រាក់ និងសំរិទ្ធ របរទាំងអស់នេះ គឺមានដំណើរ ការដូចប្រក្រតី មិនតែប៉ុណ្ណោះ ថែមទាំងមានការនាំគ្រឿងផលិតផល ទាំងនេះទៅបរទេសទៀតផង។ ប្រភពនៃដំណើរការដ៏ប្រសើរនៅក្នុង វិស័យសិប្បកម្មបានកើតមានឡើងដោយសារតែទំនាក់ទំនងល្អរវាង សិប្បករទាំងឡាយ និងស្រុកស្រែចំការដែលជាស្រុកកំណើតរបស់ខ្លួន។ នៅពេលណាមានការខាតបង់ក្នុងរបរសិប្បកម្ម ពួកគេអាចប្រែក្លាយទៅ ជាកសិករវិញបានយ៉ាងឆាប់រហ័ស។

វិស័យសេវាកម្មនាំចេញ ក៏បានដំណើរការឡើងគួរជាទីមោទនៈ ពោលគឺបាននាំចេញកៅស៊ូពោត ស្រូវ ក្នុងអត្រាកម្រិតខ្ពស់ (៣៧% នៃ ផលិតផលស្រវបាននាំចេញ )។ ហេតុនេះ ជារួមយើងឃើញថា ជីវភាពសេដ្ឋកិច្ចមានដំណើរការល្អប្រសើរ ប៉ុន្តែប្រជាកសិករហាក់ដូចជារស់នៅ ក្រោមទម្ងន់ពន្ធដារ និង ៨០% ត្រូវសង់ការប្រាក់ដល់ម្ចាស់បំណុលក្នុង តម្លៃអត្រាការប្រាក់ខ្ពស់។

រដ្ឋបាលអាណានិគមបារាំង បានដាក់អោយកសិករខ្មែរ ស្ថិតនៅក្រោមភាពមិនពិតប្រាកដ ដោយការបិទច្រកទីផ្សារនាំចេញផលិត និងការកេងយកប្រាក់ចំណេញជាប្រចាំតាមរយៈការបង់ពន្ធ និងការទម្លាក់កំហុសទៅលើផលិតករ នូវគ្រប់ភាពមិនទៀងទាត់របស់ទីផ្សារ ហើយចង់បានចំណេញហួសហេតុ ក្រោមនយោបាយសេដ្ឋកិច្ចរបស់ខ្លួន និងមានការប្រុងប្រយ័ត្នជានិច្ចចំពោះផលប្រយោជន៍។ ពួកបារាំង តែងតែដណ្តើមសិទ្ធិលើរាល់គំនិតផ្តួចផ្តើមធ្វើសេដ្ឋកិច្ច ដោយគ្មានការយល់ព្រមពីដៃគូរខ្មែរជាអ្នកផលិតក្នុងបាតុភូតនេះ គ្មានអ្វីសម្រាប់ជាការលើកទឹកចិត្តដល់ផលិតករដែលជាអ្នកមានឯកទេសរួចហើយនោះទេ។ ប៉ុន្តែយ៉ាងហោចណាស់ ប្រវត្តិសាស្ត្រដ៏ជូរចត់នេះ ក៏អាចចាត់ទុកថាជាបទពិសោធន៍ល្អសម្រាប់យើងជាអ្នកសិក្សា ដែលល្អជាងអត់ដែរ។

សរុបសេចក្តីមក ការសិក្សាលម្អិតអំពីប្រវត្តិសេដ្ឋកិច្ចសរុបរបស់ ប្រទេសកម្ពុជាយើង តាំងពីចុងសតវត្សទី១៩ និងដើមសតវត្សទី ២០មក បានអនុញ្ញាតអោយយើងយល់បានអំពីហេតុផលនៃបញ្ហាដែលមិនបាន នាំអោយមានការរីកចម្រើនទាំងអស់នោះ។

ជាតុពិត ផលិតកម្មកសិកម្មរបស់ខ្មែរយើង អាចនាំចេញទៅកាន់ទីផ្សារធំៗបាន ព្រោះទីផ្សារនោះបានប្រមូលផ្តុំនូវផលិតផលអាស៊ីប៉ូព៌ាទាំងអស់ ហើយនឹងគ្រប់គ្រងដោយបណ្តាញពាណិជ្ជកម្មសំខាន់ៗ នៃអ្នកមានតម្រូវការ និងឈ្មួញកណ្តាលបរទេស។ ប៉ុន្តែអាណាព្យាបាល បារាំងគ្រាន់តែចាត់ទុកថា សេដ្ឋកិច្ចកម្ពុជា ជាសកម្មភាពសេដ្ឋកិច្ចរដ្ឋ ហើយរដ្ឋត្រូវក្លាយជាអ្នកកាន់កាប់ និងជួយអន្តរាគមន៍ក្នុងការគ្រប់គ្រង សេដ្ឋកិច្ចដើម្បីទាញយកផលតែប៉ុណ្ណោះ។ ហើយប្រសិនបើប្រទេសនេះ មានការចាប់អារម្មណ៍ចំពោះបារាំងពិតមែននោះ គឺមូលធនរបស់ពួកបារាំង ដែលបានសន្យាយ៉ាងច្រើននៅក្នុងឥណ្ឌូចិន នឹងយកមកប្រើប្រាស់ ពិតប្រាកដក្នុងសេដ្ឋកិច្ចខ្មែរទៅហើយ។ ម៉្យាងទៀតផលិតផលមិនត្រូវបានបញ្ចូលក្នុងប្រព័ន្ធជំរុញក្នុងចលនាសេដ្ឋកិច្ចជាតិ និងពិតពលោកគួរជាទីពេញចិត្តនោះទេ លើកលែងតែម្រេចចេញ ពេលខ្លះទីផ្សាររបស់បារាំងមិនបានបង្កើតច្រកចូល ពេលខ្លះទៀត បើមានអត្ថិភាពប្រកួតប្រជែង ផលិតផលដែលជាផលប្រយោជន៍ខ្មែរ ដូចជាសំឡីកប្បាស គឺរដ្ឋបាលណានិគម មិនបានធ្វើអ្វីសោះ ដើម្បីពង្រឹងស្ថានភាពពាណិជ្ជកម្មរបស់ ប្រទេសដែលនៅក្រោមអាណាព្យាបាលរបស់ខ្លួន។ ហើយពួកអាណានិគម គឺចូលចិត្តតែធ្វើអ្វីៗ អោយគេឃើញតែសម្បកក្រៅ ដើម្បីភាពល្បីល្បាញរបស់ខ្លួននៅពេលដែលមានវត្តមាននៅលើទឹកដីអាណានិគមតែប៉ុណ្ណោះ។

ដូច្នេះវត្តមានរបស់ពួកអាណានិគមបារាំង គឺស្ថិតនៅក្រៅរង្វង់សេដ្ឋកិច្ចនៃសកម្មភាពពាណិជ្ជកម្មទាំងស្រុង ប្រៀបដូចជាវល្លិនៅលើមែកឈើ ឬអាចនិយាយបានថា វត្តមានបារាំងគ្រាន់តែមកបន្ថែមពីលើ សកម្មភាពដែលកើតមានស្រាប់ ហើយដើម្បីកាត់យកផលិតផលលើសពីសេចក្តីត្រូវការ តាមរយៈសម្ពាធសារពើពន្ធ ដែលអនុវត្តយ៉ាងតឹងរឹង លើសកម្មភាពសេដ្ឋកិច្ចរបស់កម្ពុជា តាមរយៈពន្ធអាករពន្ធនាំចេញ និង ពន្ធលើចរាចរទំនិញ។ យើងបានឃើញស្ថានភាពតែមួយគក់ដូចជា សេដ្ឋកិច្ចក្នុងស្រុកត្រូវបង់ពន្ធយ៉ាងធ្ងន់ធ្ងរ និងធ្វើអោយចុះខ្សោយដោយសារលេសដែលត្រូវបង់ពន្ធដារទាំងអស់នេះ ហើយបង្កើតជាមធ្យោបាយ ដើម្បីរៀបចំផ្លូវ និងកន្លែងធ្វើសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មដែលស្ទើរតែគ្មាននៅក្នុងប្រទេសហើយតែងតែដាក់កំហុសដល់អ្នកផលិតនិងកំហុសដល់ការវិនិយោគរបស់កសិករ។

ជាលទ្ធផលចុងក្រោយ សេដ្ឋកិច្ចខ្មែរនៅតែជាសេដ្ឋកិច្ចជនបទ ជាសារវ័ន្ត ហើយការធ្វើអន្តរាគមន៍ ដែលត្រូវបានបញ្ចេញអោយឃើញ នោះ គឺស្ថិតនៅក្រោមទម្រង់ការនៃ ការកេងប្រវ័ញ្ចយកវិញ តាមរបៀបពីរយ៉ាងគឺ ទីមួយ ការដេកហូតសារពើពន្ធរបស់អាណានិគម និងទីពី ការដេកហូតពាណិជ្ជកម្មផ្តាច់មុខ ដែលនៅទីបំផុតធ្វើអោយមានការហិនហោចដល់អានុភាពសេដ្ឋកិច្ចរបស់ប្រទេសខ្មែរ ហើយដើម្បីគ្រាន់តែជាការទាញយកផលប្រយោជន៍ទៅតាមវិធីផ្សេងៗ (ដោយរៀបចំការកេងប្រវ័ញ្ចស្របច្បាប់) ដើម្បីអោយបានផលចំណេញជាអតិបរមា។

# ជំពូកទី ៦
# ប្រវត្តិសេដ្ឋកិច្ចប្រទេសកម្ពុជា សម័យសង្គមរាស្ត្រនិយម
# ឆ្នាំ ១៩៥៣ - ១៩៧០

## ៦.១. ស្ថានភាពនយោបាយ

### ៦.១.១ ស្ថានភាពនយោបាយមុនឆ្នាំ ១៩៥៣

ស្ថានភាពនយោបាយប្រទេសកម្ពុជា មុនឆ្នាំ ១៩៥៣ គឺមានការ ទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងព្រះរាជសកម្មភាពរបស់ព្រះមហាក្សត្រ ខ្មែរ ក្នុងចលនាតស៊ូប្រកបដោយការលំបាក និងគ្រោះថ្នាក់ជាទីបំផុតដើម្បីដណ្តើមឯករាជ្យពីពួកអាណានិគមនិយមបារាំង ពោលគឺ ព្រះបាទ នរោត្តម សីហនុ ដែលបានឡើងគ្រងរាជ្យសម្បត្តិនៅឆ្នាំ ១៩៤១ ក្នុងព្រះ ជន្មាយុ ១៩ ព្រះវស្សា ដែលកាលនោះព្រះអង្គកំពុងបំពេញវិជ្ជា នៅឯ ទីក្រុងព្រៃនគរ ទឹកដីដែលបារាំងកំពុងគ្រប់គ្រង។[112] ហើយចំពោះព្រះរាជ្យសកម្មភាពសំខាន់ៗ របស់ព្រះអង្គ គឺបានកើតមានឡើងជាបន្តបន្ទាប់ ដូចខាងក្រោមនេះ ៖

- តាមរយៈការចរចាយ៉ាងលំបាកលំបិនរវាង បារាំង-ខ្មែរ ទីបំផុត ឆ្នាំ ១៩៤៩ បារាំងបានយល់ព្រមព្រះចុះហត្ថលេខាលើសន្ធិសញ្ញា បារាំង-ខ្មែរ នៅទីក្រុងប៉ារីស (បន្ថែមលើសន្ធិសញ្ញា ឆ្នាំ ១៩៤៦) ដោយព្រមប្រគល់ឯករាជ្យមកអោយខ្មែរវិញ ក៏ប៉ុន្តែកម្ពុជាត្រូវតែស្ថិតនៅក្នុងសហភាពបារាំង ដែលជាឯករាជ្យមិនពេញលេញ។
- នៅក្នុង ខែកុម្ភៈ ឆ្នាំ ១៩៥៣ ព្រះអង្គបានទៅប្រទេសបារាំង ដើម្បីចរចាទាមទារឯករាជ្យភាពពីបារាំង ប៉ុន្តែពុំសម្រេចតាមព្រះរាជ្យបំណងនោះឡើយ។
- ថ្ងៃទី ១១ ខែមេសា ឆ្នាំ ១៩៥៣ ព្រះអង្គក៏បានយាងទៅប្រទេសកាណាដា និងសហរដ្ឋអាមេរិក ដើម្បីថ្លែងការទៅកាន់អ្នកសារពត៌មាន ដែលសង្កត់ធ្ងន់ទៅលើការទាមទារឯករាជ្យពីបារាំង។ ព្រះអង្គបាន បញ្ជាក់ប្រាប់អ្នកសារពត៌មានអន្តរជាតិលើបញ្ហា ២យ៉ាង។ បញ្ហាទី១ ៖ គឺទាក់ទងទៅនឹងការប្រយុទ្ធប្រឆាំងនឹងពួកកុំម្មុយនីស្តនៅលើទឹកដីខ្មែរ ។ ឯបញ្ហាទី២៖ គឺបញ្ហាឯករាជ្យភាពបរិបូរណ៍សម្រាប់ប្រទេសកម្ពុជា។ ព្រះអង្គ បានបញ្ជាក់ថា ប្រទេសខ្មែរពុំត្រូវការរបបកុម្មុយនីស្តទេ ព្រោះប្រជារាស្ត្រខ្មែរម្នាក់ៗ សុទ្ធតែមានកម្មសិទ្ធដីធ្លីសម្រាប់បង្កបង្កើនផល។ ហើយបញ្ហាធំដែលគេចង់បាននោះ គឺឯករាជ្យភាពបរិបូរណ៍សម្រាប់ប្រទេសគេ ។
- លុះព្រះអង្គយាងចូលដល់សហរដ្ឋអាមេរិក ព្រះអង្គក៏បានលើកយកប្រធានបទដដែលនេះ មកបកស្រាយ ដែលត្រូវបានសារពត៌មានដ៏ធំមួយឈ្មោះ New York Time ចុះផ្សាយក្នុងទំព័រទី១ នាថ្ងៃទី១៩ ខែ មេសា ឆ្នាំ១៩៥៣ ដែលធ្វើអោយពិភពលោកទាំងមូល មានការភ្ញាក់ផ្អើល។ ជាពិសេស ព្រះរាជសាសន៍ដែលធ្វើអោយគេភ្ញាក់ផ្អើលនោះគឺ បើបារាំងមិនយល់ព្រមប្រគល់ឯករាជ្យអោយប្រទេសកម្ពុជាទេ គ្រោះថ្នាក់មួយនឹងមានពិតប្រាកដ គឺប្រជារាស្ត្រខ្មែរនឹងក្រោកឡើងប្រឆាំងបារាំងហើយគេនឹងងាកទៅរកចលនាយៀកមិញដែលដឹកនាំដោយពួកកុំម្មុយនីស្ត។

ជាងនេះទៀត ព្រះអង្គបានបញ្ជាក់បន្ថែមទៀតថា ពួកបារាំងទាំងអស់ដែលនៅក្នុងស្រុកខ្មែរ នឹងត្រូវឡោមព័ទ្ធហើយជីវិតចុងក្រោយនឹងមកដល់។ [113]

គួរបញ្ជាក់ថា ព្រះរាជសាសន៍ប្រកបដោយព្រះបញ្ញាញាណនេះ ធ្វើអោយមតិសាកលលោក ពិសេសលោកខាងលិច ជម្រុញអោយរដ្ឋាភិបាលបារាំងយល់ព្រមចូលរួមក្នុងតុចរចាជាមួយនឹងតំណាងរដ្ឋាភិបាលកម្ពុជា ស្តីអំពីឯករាជ្យភាពបរិបូរណ៍នៃព្រះរាជាណាចក្រនេះ។

- ថ្ងៃទី២៣ ខែមេសា ឆ្នាំ ១៩៥៣ ការចរចាដោយយកចិត្តទុកដាក់រវាងរដ្ឋាភិបាលបារាំង-ខ្មែរ ស្តីអំពីឯករាជ្យភាពបានចាប់ផ្តើមឡើងនៅទីក្រុងប៉ារីស ប៉ុន្តែភាគីទាំងពីរបានឯកភាពគ្នាលើលក្ខន្តិកៈខ្លះៗប៉ុណ្ណោះ ដោយបានចុះហត្ថលេខា នាថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៥៣។
- នៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៥៣ ព្រះអង្គទ្រង់បញ្ជាអោយរៀបចំពង្រឹងមូលដ្ឋានទ័ពនៅបាត់ដំបង (ក្នុងដំណើរការទាមទារឯករាជ្យ ព្រះអង្គមិនគង់ក្នុងរាជធានីភ្នំពេញទេ គឺគង់នៅខេត្តសៀមរាប បាត់ដំបង និងកំពង់ធំ ដែលជាតំបន់ស្វយ័តភាពយោធា ដែលទាមទារពីបារាំងនៅឆ្នាំ ១៩៤៦ ហើយលុះឆ្នាំ ១៩៤៩ ទើបបារាំងយល់ព្រមចុះហត្ថលេខា) និងរៀបចំកងកម្លាំងជីវពលនារីក្លាហាន។

ការរៀបចំកម្លាំងជីវពលនេះនៅគ្រប់ខេត្តទាំងអស់ ប្រជារាស្ត្រខ្មែរទាំងប្រុស ស្រី ស្ម័គ្រចូលបម្រើក្នុងទឹកចិត្តពុះកញ្ជ្រោល។ មកដល់ខែសីហា ឆ្នាំ១៩៥៣ ចំនួនកងជីវពលបានកើនឡើងដល់ ៤០០.០០០ នាក់។ នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ ១៩៥៣ នៅខេត្តបាត់ដំបងបានប្រារព្ធពិធីមហាព្យុះហយាត្រាមួយ នៅចំពោះមុខព្រះភ័ក្ត្រព្រះមហាក្សត្រ ដែលមានការចូលរួមពីកងជីវពលប្រមាណ ៨០.០០០នាក់។

- ក្រោយពីមានការដង្ហែក្បួនព្យុហយាត្រារួមមក នៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៥៣ រដ្ឋាភិបាលបារាំង យល់ព្រមចុះហត្ថលេខាប្រគល់ អំណាចតុលាការ និងប៉ូលីសមកអោយរដ្ឋាភិបាលខ្មែរ។
- ថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៥៣ បារាំងយល់ព្រមចុះហត្ថលេខា ប្រគល់អធិបតេយ្យភាពយោធាទូទាំងប្រទេសមកអោយកម្ពុជា។
- ក្រោយមកមុនថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ បារាំងក៏យល់ព្រមចុះហត្ថលេខាប្រគល់ឯករាជ្យលើគ្រប់វិស័យដែលនៅសេសសល់។
- នៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ នៅមុខព្រះបរមរាជវាំងមានប្រារព្ធពិធី ស្តីពីការដកអំណាចពីបារាំងចេញពីកម្ពុជា ហើយតាំងពីពេលនោះមកព្រះរាជាណាចក្រកម្ពុជាជារដ្ឋមួយមានឯករាជ្យពិតប្រាកដ និងបរិបូរណ៍។
- អាស្រ័យកិត្យានុភាពដ៏ត្រចះត្រចង់ នៃព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋមួយប្រកបដោយឯករាជ្យ សន្តិភាព និងមានអធិបតេយ្យភាពពេញលេញបរិបូរណ៍ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ១៩៥៥ ប្រទេសកម្ពុជា ត្រូវបានចូលជាសមាជិកពេញសិទ្ធិរបស់អង្គការសហប្រជាជាតិ។ [115]

## ៦.១.២ ស្ថានភាពនយោបាយ ឆ្នាំ ១៩៥៣-១៩៧០

ទោះបីជា អំណាចបារាំងត្រូវបានបញ្ចប់នៅលើទឹកដីខ្មែរក៏ ដោយ ប៉ុន្តែបញ្ហានយោបាយផ្សេងៗទៀត នៅមិនទាន់ដោះស្រាយបានទេ ជាពិសេសការឈ្លានពានរបស់ប្រទេសជិតខាង។

នៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ កងទ័ពវៀតមិញ (ពួកកុំម្មុយនីស្ត) មិនព្រមដកចេញពីទឹកដីខ្មែរទេ ជាពិសេសនៅខេត្តបាត់ដំបង។ ខណៈនោះ ក្នុងនាមព្រះអង្គជាអគ្គមេបញ្ជាការកងខេមរភូមិន្ទ ទ្រង់បាន បញ្ជាអោយរៀបចំប្រតិបត្តិការសឹកប្រយុទ្ធជាមួយពួកបរទេសឈ្លានពាន ដែលបានប្រព្រឹត្តិនៅថ្ងៃទី ១៧ ដល់ ៣០ខែធ្នូ ឆ្នាំ១៩៥៣។

ហើយបានបណ្តេញពួកវៀតមិញអស់ពី ពួកនេះបានលបចូលមកតាំងមូលដ្ឋានទ័ព តាំងពីឆ្នាំ ១៩៤៩ មកម្ល៉េះ។ នៅខែមេសា ឆ្នាំ ១៩៥៥ ពួកវៀតមិញ បានចូលមកម្តងទៀតក្នុងខេត្ត ស្ទឹងត្រែង និងខេត្តក្រចេះ។ ក្នុងស្ថានការណ៍នេះ កងទ័ពខ្មែរ ដែលបាន ដឹកនាំផ្ទាល់ដោយព្រះអង្គបានទៅវាយប្រយុទ្ធនឹងពួកបរទេសឈ្លានពាននៅត្រង់ច្រកចូលនៃខេត្តក្រចេះ(តំបន់ស្រែជេស)។ នៅខែកក្កដា ឆ្នាំ ១៩៥៤ នៅក្នុងសន្និសិទ្ធិ ទីក្រុងសឺណែវ ស្តីពីបញ្ហាឥណ្ឌូចិន ពេលនោះក្រោមការដឹកនាំរបស់ឯកឧត្តម ទេព ផន និងអនុវត្តតាមព្រះរាជតម្រិះរបស់ព្រះអង្គធ្វើអោយយើងទទួលបានលទ្ធផលដ៏ត្រចះត្រចង់ គឺកិច្ចព្រមព្រៀង ក្រុងសឺណែវ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ១៩៥៤ ដែលក្នុងកិច្ចព្រមព្រៀងនោះតម្រូវអោយកងទ័ពវៀតមិញដកចេញពីប្រទេសកម្ពុជា។

គួរបញ្ជាក់ថា ដើម្បីគៀបសង្កត់មកលើប្រទេសកម្ពុជា អោយចូលខេត្តបាត់ដំបង ដែលទៅក្នុងប្លុកសេរី (ព្រោះពេលនោះ ប្រទេសកម្ពុជាប្រកាន់យកនូវនយោបាយអព្យាក្រឹត្យមិនចូលបក្សសម្ព័ន្ធ ដូច្នេះប្រទេសវៀតណាមខាងត្បូង និងថៃ (ប្រទេសទាំងពីរប្រកាន់ខ្ជាប់នូវលទ្ធិសេរីនិយម) តែងតែបង្កបញ្ហា ទំនាស់តាមព្រំដែន ដោយធ្វើការឈ្លានពានជាច្រើនលើកមកលើបូរណភាពទឹកដីខ្មែរ ដោយការទម្លាក់គ្រាប់បែក ការសម្លាប់ ការឆក់ប្លន់ទ្រព្យ សម្បត្តិនៅតាមព្រំដែន។ ឆ្នាំ ១៩៥៨ ការរំលោភពីសំណាក់វៀតណាមខាងត្បូង ចូលទឹកដីខ្មែរមានចំនួន ២៩ លើក និងពីសំណាក់កងទ័ពថៃ ចំនួន ៦ លើក។

ឆ្លើយតបនឹងហេតុការណ៍នយោបាយនេះ រាជរដ្ឋាភិបាលខ្មែរ បង្ខំចិត្តកាត់ផ្តាច់ទំនាក់ទំនងការទូត ជាបណ្តោះអាសន្នជាមួយប្រទេសថៃ នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៦១ និងជាមួយវៀតណាមខាងត្បូង នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៦៣ និងជាមួយសហរដ្ឋអាមេរិក នៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ១៩៦៥។

លើសពីនេះទៀត ស្នាព្រះហស្តដ៏ខ្ពង់ខ្ពស់មិនអាចកាត់ថ្លៃបានមួយទៀតរបស់ព្រះអង្គ គឺទាក់ទងទៅនឹងការទាមទារយកមកវិញនូវទឹកដី និងប្រាសាទព្រះវិហារដែលប្រទេសថៃបានទន្ទ្រានកាន់កាប់ខុសច្បាប់ ក្នុងឆ្នាំ ១៩៥៤ មកអោយកម្ពុជាវិញ នៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៦២ តាមរយៈតុលាការនៅទីក្រុងឡាអេ ។

ចំពោះសមិទ្ធិផលនយោបាយផ្សេងៗទៀតនៅក្នុងប្រទេសខ្មែរនាសម័យកាលនោះ មានការទាក់ទងទៅនឹងការបង្កើតចលនានិងការ បង្កើតជាវេទិកាជាតិ ដើម្បីផ្សារភ្ជាប់ការគ្រប់គ្រងនយោបាយ

ជាមួយនឹង ប្រជារាស្ត្រខ្មែរអោយកាន់តែមានភាពជិតស្និទ្ធ ដែលចលនានយោបាយ ទាំងនោះមានខ្លឹមសារដូចខាងក្រោម ៖

- នៅថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៥៥ ក្នុងព្រះរាជបំណងផ្សារភ្ជាប់ ព្រះមហាក្សត្រខ្មែរ ទៅនឹងប្រជារាស្ត្រអោយកាន់តែជិតស្និទ្ធ ព្រះបាទ នរោត្តម សីហនុ ព្រះអង្គបានដាក់រាជ្យសម្បត្តិដោយទុករាជ្យបល្ល័ង្ក អោយព្រះបិតា ព្រះបាទនរោត្តម សុរាម្រឹត ជាអ្នកគ្រងរាជ្យសម្បត្តិបន្ត។ បន្ទាប់មកព្រះអង្គបានបង្កើតចលនា ដ៏ទូលំទូលាយមួយ មានឈ្មោះថា សង្គមរាស្ត្រនិយម នៅថ្ងៃទី ២៤ ខែមិនា ឆ្នាំ ១៩៥៥។ ចលនាសង្គម រាស្ត្រនិយម មិនមែនជាគណបក្សនយោបាយទេ ប៉ុន្តែជាចលនាបង្រួបបង្រួមជាតិ ក្នុងគោលបំណងស្ថាបនាជាតិតាម លទ្ធិសង្គមនិយម សាសនាខ្មែរ ។ ចលនានេះ មានឥទ្ធិពលយ៉ាងខ្លាំងក្លាក្នុងវិស័យនយោបាយ និងក្នុងសង្គមខ្មែរទាំងមូល ដែលពេលនោះប្រជារាស្ត្រខ្មែរបានសម្តែងនូវឆន្ទៈគាំទ្រយ៉ាងខ្លាំងក្លា រហូតដល់ ៨៣% (ក្នុងការបោះឆ្នោត ជ្រើសរើសអំណាចនីតិបញ្ញត្តិ)។ ក្នុងបណ្តាគណបក្សនយោបាយនានា (គណបក្សរាជានិយម គណបក្សប្រជាធិបតេយ្យ និងគណបក្សឆ្វេងនិយម) ក៏បានរំលាយខ្លួនហើយចូលរួមក្នុងចលនាសង្គមរាស្ត្រនិយម។[118]
- ជាពិសេសទៅទៀត ក្នុងព្រះរាជបំណងធ្វើអោយចលនាសង្គមរាស្ត្រនិយម កាន់តែខិតជិតប្រជារាស្ត្រ និងមានលក្ខណៈសុក្រឹត្យយុត្តិធម៌ ហេតុនេះព្រះអង្គបានបង្កើតវេទិកាប្រជាធិបតេយ្យរបស់មហាជនយ៉ាងទូលំទូលាយមួយដែលហៅថា សមាជជាតិ ដែលដឹកនាំសកម្មភាពដោយព្រះអង្គផ្ទាល់។ បន្ទាប់មកទៀត ចលនាសមាជជាតិត្រូវបានអនុម័តក្នុងរដ្ឋធម្មនុញ្ញ ក្នុងខែធ្នូ ឆ្នាំ ១៩៥៧។ តាំងពីពេលនោះមក សមាជជាតិជាស្ថាប័ននយោបាយមួយរបស់រដ្ឋ។ តាមរយៈជាតិនេះ ប្រជារាស្ត្រទូទៅគ្រប់ស្រទាប់វណ្ណៈទូទាំងប្រទេសអាចចូលរួមសម្តែងមតិបញ្ចេញយោបល់ចំពោះសកម្មភាពដឹកនាំរបស់រាជរដ្ឋាភិបាល ចំពោះសកម្មភាពខុសច្បាប់ក្នុងសង្គមដូចជាបញ្ហាពុករលួយរបស់ តាមរយៈសមាជមន្ត្រីរាជការជាដើម។

## ៦.១.៣ សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ស្ថានភាពនយោបាយនាសម័យសង្គមរាស្ត្រ និយមយើងពិនិត្យឃើញថា ស្ថានភាពនយោបាយដែលបានកើតមានឡើងមុនឆ្នាំ១៩៥៣ គឺទាក់ទងទៅនឹងចលនាតស៊ូរបស់ព្រះបាទនរោត្តម សីហនុ ក្នុងការទាមទារឯករាជ្យភាពពីបារាំង។ ចលនាតស៊ូទាំងនេះ ធ្វើអោយប្រទេសខ្មែរយើងបានទទួលឯករាជ្យពេញលេញពីបារាំង ដែលដាក់អាណានិគមមកលើប្រទេសខ្មែរអស់រយៈកាល ៩០ឆ្នាំ។ ដោយសារសមិទ្ធិផលនយោបាយ ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះអង្គ បានធ្វើអោយប្រជារាស្ត្រខ្មែរទទួលស្វាគមន៍ និងដឹងគុណជាអតិបរមា ហើយឆ្លើយតបទៅនឹងសំណូមពររបស់ប្រជារាស្ត្រខ្មែរ រាជរដ្ឋាភិបាលសម័យ នោះបានចេញក្រឹត្យមួយចុះថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ថ្វាយព្រះនាមព្រះអង្គជាកិត្តិយសថា ព្រះមហាវីរបុរសជាតិ ។

ម៉្យាងវិញទៀតចំពោះស្ថានភាពនយោបាយរបស់ប្រទេសកម្ពុជា ក្រោយឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ យើងសង្កេតឃើញថា មានការទាក់ ទងទៅនឹងការប្រយុទ្ធប្រឆាំង ទៅនឹងអំពើឈ្លានពាន របស់បរទេស មក លើប្រទេសកម្ពុជា ពោលគឺ ការប្រឆាំងជាមួយនឹងប្រទេសវៀតណាម ខាងត្បូង និង ប្រទេសថៃ ដែលតែងតែធ្វើទុក្ខបុកម្នេញមកលើបូរណភាព ទឹកដី និងមកលើប្រជារាស្ត្រខ្មែរ ដែលរស់នៅតាមបណ្តោយព្រំដែន។ ផ្សេងពីនេះទៀត សមិទ្ធិផលនយោបាយដ៏ធំធេងដែលបានកើតមាន ឡើង នៅសម័យកាលនោះគឺទាក់ទងទៅនឹងការទាមទារមកវិញនូវទឹក ដី និងប្រាសាទព្រះវិហារ ដែល ប្រទេសថៃបានដណ្តើមយកដោយខុស ច្បាប់កាលពីឆ្នាំ ១៩៥៤។

ដោយឡែក ចំពោះការគ្រប់គ្រងនយោបាយក្នុងប្រទេសវិញ យើងពិនិត្យឃើញថាព្រះមហាក្សត្រខ្មែរក្នុងព្រះរាជបំណងផ្សារភ្ជាប់ ព្រះអង្គទៅនឹងប្រជារាស្ត្រ ព្រះអង្គបានដាក់រាជ្យសម្បត្តិ ហើយ បង្កើត ជាចលនាមហាជនមួយដែលហៅថា សង្គមរាស្ត្រនិយម ដើម្បីបង្រួបបង្រួមជាតិ ស្ថាបនាជាតិ តាមគន្លងលទ្ធិសង្គមនិយមព្រះពុទ្ធសាសនា។ លើសពីនេះទៅទៀត ព្រះអង្គក៏បានបង្កើតនូវចលនា វេទិកាប្រជាធិបតេយ្យរបស់មហាជនដែលហៅថាសមាជជាតិ ក្រោយមកចលនានេះក៏ក្លាយទៅជា ស្ថាប័ននយោបាយមួយរបស់រដ្ឋ។

រហូតដល់ថ្ងៃ១៨ ខែមិនា ឆ្នាំ១៩៧០ សម្តេចនរោត្តមសីហនុ ត្រូវបក្សពួកលោកសេនាប្រមុខ លន់ នល់ អ្នកអង្គម្ចាស់ស៊ីសុវត្ថិសិរីមតៈ និង លោក អ៊ិន តាំ ប្រកាសទំលាក់ព្រះអង្គពីតំណែងជាព្រះប្រមុខរដ្ឋ ដោយចោទប្រកាន់ថា ព្រះអង្គក្បត់ប្រទេសជាតិ ក្បត់មាតុភូមិ លក់ទឹកដីអោយ វៀតណាម ខាងជើង និងវៀតកុង។

## ៦.២. ទស្សនៈទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ច

ចាប់តាំងពីយុគសម័យដើមមកម្ល៉េះ ប្រទេសខ្មែរយើងជាប្រទេស ដែលប្រកបរបរកសិកម្មជាធំ ហើយផលិតផលដែលផលិតចេញពីដី គឺមានអានុភាពខ្លាំងក្លាណាស់ចំពោះសេដ្ឋកិច្ចជាតិ។ ដូចជានៅក្រោមរបប អាណាព្យាបាលបារាំងប្រទេសខ្មែរបានយកវិស័យកសិកម្មធ្វើជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច។ រីឯ វិស័យអាជីវកម្មផ្សេងៗទៀត គឺមានតិចតួច ស្តួចស្តើងណាស់ ដូចដែលយើបានសិក្សារួចមកហើយ ពោលគឺមានតែរបរសិប្បកម្មបន្តិចបន្តួច និងកម្មន្តសាលតូចតាចប៉ុណ្ណោះ ហើយវិស័យទាំងនោះស្ថិតនៅក្នុងកណ្តាប់ដៃជនបរទេស។ ដោយសារតែកង្វះខាតផ្នែកឧស្សាហកម្មនេះហើយ ទើបធ្វើអោយ វិស័យបច្ចេកទេស និងបច្ចេកវិទ្យានៅសម័យកាលនោះ ពុំមានការជឿនលឿន។ នៅខណៈពេលនោះ ប្រទេសយើងបានធ្វើការនាំចេញទៅក្រៅប្រទេសនូវភោគផលធម្មជាតិ ហើយនាំចូលមកវិញនូវ ផលិតផលឧស្សាហកម្ម សម្រាប់យកមកប្រើ ប្រាស់ក្នុងស្រុក។

ក្រោយពីបានទទួលឯករាជ្យមក រាជរដ្ឋាភិបាលខ្មែរបានជម្រុញអោយវិស័យសេដ្ឋកិច្ចគ្រប់ផ្នែក មានសន្ទុះកើន ឡើង ហើយរដ្ឋាភិបាល ក៏បានធ្វើការគ្រប់គ្រង និងកាន់កាប់យកផ្នែកសំខាន់ៗខ្លះ ដែលជាអាយុជីវិតនៃសេដ្ឋកិច្ចជាតិ។

ចំពោះគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជានាសម័យកាលនោះ រាជរដ្ឋាភិបាលបានកំណត់គោលដៅ ៣យ៉ាង គឺ

- កសាងសេដ្ឋកិច្ចថ្មី តាមរយៈការធ្វើជាតូបនីយកម្ម ផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងស្ថាប័នហិរញ្ញវត្ថុ ដោយប្រើប្រាស់ជំនួយបរទេស។
- ជៀតចូលជាសមាជិកភាពនៃស្ថាប័នធនាគារពិភពលោក ដូច ជា ADB, IMS និង IBRD។
- បង្កើតច្បាប់វិនិយោគអោយមានការទាក់ទាញ ដើម្បីអូសទាញទុនវិនិយោគពីបរទេស និងវិនិយោគក្នុងស្រុកតាមរយៈការធ្វើឯកជនភាវូបនីយកម្ម វិស័យពាណិជ្ជកម្ម ធនាគារ និងឧស្សាហកម្ម ។

ទាក់ទងទៅនឹងទស្សនៈទាននៃការអភិវឌ្ឍវិស័យកសិកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើគោលនយោបាយពង្រីកដីស្រែចំការថ្មី ការជ្រើសរើសពូជស្រូវ និងពូជដំណាំ ការប្រើប្រាស់ដីធម្មជាតិគួបផ្សំនឹងជីគីមី ការអភិវឌ្ឍនយោបាយទឹក និងការផ្តល់ឥណទានយ៉ាងច្រើនក្នុងវិស័យកសិកម្ម។

បើយើងពិនិត្យមើលអោយបានពិស្តារ ទៅលើកម្មវិធីលម្អិតនៃការអភិវឌ្ឍវិស័យកសិកម្មយើងឃើញថា រាជរដ្ឋាភិបាលសម័យនោះបានបែងចែកថវិការដ្ឋប្រមាណ ២៥% សម្រាប់ការវិនិយោគលើវិស័យកសិកម្ម (ជាលក្ខណៈឥណទាន និងមិនមែនឥណទាន) ជាពិសេសទៅលើដំណាំសំខាន់ៗជាមូលដ្ឋាន ដូចជា ដំណាំស្រូវ កៅស៊ូ ពោត កប្បាស ត្នោត តែ និងកាហ្វេ ព្រមទាំងបានវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ សម្រួលដល់ការធ្វើកសិកម្មច្រើនរដូវកាល។

ក្រៅពីនេះ រដ្ឋាភិបាលបានជម្រុញអោយកសិករខ្មែរចេះប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ចេះធ្វើទំនើបកម្មកសិកម្ម ដោយប្រើប្រាស់ត្រាក់ទ័រ និងបរិក្ខារកសិកម្មផ្សេងៗទៀត និងលើកលែងពន្ធនាំចូលលើ សម្ភារៈកសិកម្មទាំងនោះ។ សំខាន់ជាងនេះទៀត នៅក្នុងគោលនយោបាយអភិវឌ្ឍន៍កសិកម្មយើងពិនិត្យឃើញថា រដ្ឋាភិបាលបានផ្តល់ដី កសិកម្ម និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាកសិករ បានបង្កើតស្ថានីយ៍ ស្រាវជ្រាវកសិកម្ម និងជ្រើសរើសភូមិកសិកម្មគម្រូ ពិសេសទៀត រដ្ឋបានធ្វើការកំណត់តម្លៃផលិតផលកសិកម្ម ដើម្បីអោយកសិករអាចជ្រួតជ្រាបជាមុនអំពីតម្លៃទីផ្សារងាយស្រួលក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងផែនការផលិតកម្មរបស់ខ្លួន។

ចំពោះទស្សនៈទាននៃការអភិវឌ្ឍ វិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលបានជម្រុញការសាងសង់នូវរោងចក្រជាច្រើនដូចជា រោងចក្រ តម្លើង គ្រឿងយន្ត រោងចក្រចម្រាញ់ប្រេងកាត រោងចក្រស្រាបៀររោងចក្រវាយនភ័ណ្ឌ រោងចក្រស៊ីម៉ង់ត៍ រោងចក្រក្រដាស រោងចក្រផលិតកែវ រោងចក្រផលិតកង់រថយន្ត រោងចក្រផលិតឱសថ រោងចក្របារី ក្រចៅ រោងចក្រត្រីខកំប៉ុង រោងចក្រក្តារបន្ទះ និងផ្សេងៗទៀតនៅទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។

ផ្សេងពីនេះទៀត ទាក់ទងទៅនឹងវិស័យសេវាកម្ម យើងឃើញថា រាជរដ្ឋាភិបាលបានពង្រីកហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការសាងសង់កំពង់ផែសំខាន់ៗ ដើម្បីធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ជាមួយបណ្តាប្រទេសជាច្រើននៅលើពិភពលោក។ គួរបញ្ជាក់ថា ការធ្វើពាណិជ្ជកម្មក្រៅ

ប្រទេស គឺបានស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការរបស់រដ្ឋក្នុងភាគហ៊ុន ៦០% ជាដើមទុនរបស់រដ្ឋ និង ៤០ ជាដើមទុនរបស់ឯកជន។ ម្យ៉ាងទៀតរដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ច ពាណិជ្ជកម្ម ដោយបានបង្កើតក្រុមហ៊ុននាំចេញ-នាំចូលរបស់ជាតិ ក្នុងគោលបំណងគ្រប់គ្រងចរាចរលំហូរទំនិញចេញពីក្នុងស្រុក និងលំហូរចូលពីបរទេស ក្នុងទិសដៅធានាបាននូវតុល្យភាពជញ្ជីងពាណិជ្ជកម្ម និងទទួលបាននូវអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនេះដែរ រដ្ឋបានបង្កើតក្រុមហ៊ុនជាតិ ចែកចាយទំនិញក្នុងស្រុក ដើម្បីកាត់បន្ថយនូវគម្លាត និងអន្តរការីសេដ្ឋកិច្ច (ឈ្មួញកណ្ដាល) ពោលគឺធ្វើយ៉ាងណាអោយអ្នកផ្គត់ផ្គង់ទំនិញ និងអ្នកប្រើប្រាស់បានខិតជិតគ្នា។

ដោយឡែកចំពោះវិស័យសិក្សាធិការជាតិ និងសុខាភិបាលសាធារណៈវិញ ដែលជាវិស័យគន្លឹះនាសម័យកាលនោះ រាជរដ្ឋាភិបាលបានធ្វើការជម្រុញយ៉ាងខ្លាំងក្លា ដោយពង្រីកការបណ្ដុះបណ្ដាលធន ជានមនុស្សលើគ្រប់កម្រិតសិក្សា និងគ្រប់ជំនាញ ព្រមទាំងធ្វើការពង្រីកវិស័សុខាភិបាល និងវប្បធម៌ជាតិ ដែលនៅសម័យអាណានិគមពុំត្រូវបានយកចិត្តទុកដាក់។

## ៦.៣. ស្ថានភាព សេដ្ឋកិច្ចសម័យសង្គមរាស្ត្រ

### ៦.៣.១ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

នៅសម័យសង្គមរាស្ត្រនិយម យើងពិនិត្យឃើញថា ផលិតផលក្នុងស្រុកសរុប (ផ.ស.ស ឬ GDP ) នាឆ្នាំ១៩៦៨ មានទំហំប្រមាណជា ៣២.០០០ លាន រៀល ឬសមាមាត្រទៅនឹង ៩១៤ លាន ដុល្លារ អាមេរិក (តម្លៃអត្រាប្តូរប្រាក់ គឺ ៣៥ រៀល/១ដុល្លារ)។ ចំពោះអត្រាកំណើនសេដ្ឋ កិច្ចជាតិ (ផ.ស.ស) ប្រចាំឆ្នាំ មានចំនួន ៣,៧% គិតចាប់ពីឆ្នាំ១៩៦៣ ដល់ឆ្នាំ ១៩៦៦។ រីឯ អត្រាផលធៀបទំហំសេដ្ឋកិច្ចជាតិ សម្រាប់ពលរដ្ឋ ម្នាក់ៗ (GDP per capita) មានអត្រាតម្លៃប្រហែល ៥.០០០ រៀល/ម្នាក់ៗ ឬ ១៤០ ដុល្លារ/ម្នាក់ៗ ដែលអត្រាតម្លៃផលធៀបនេះ មានកម្រិតខ្ពស់ជាងបណ្ដាប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍យើងនេះក្នុងសម័យកាលនោះ។

ម្យ៉ាងទៀតបើយើងពិនិត្យមើលនៅក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិវិញ យើងឃើញថាវិស័យកសិកម្មបានដើរតួនាទីសម្ខាន់ជាងគេ ជាក់ស្តែងនៅឆ្នាំ១៩៦៨ វិស័យកសិកម្មមានទំហំ ៤១% នៃGDP វិស័យឧស្សាហកម្មមានទំហំ ១៩% នៃGDP និងវិស័យសេវាកម្មមានទំហំប្រមាណ៤០% នៃGDP។

### ៦.៣.២ វិស័យកសិកម្ម

តាមការស្រាវជ្រាវបង្ហាញថា នៅសម័យសង្គមរាស្ត្រនិយម ដីស្រែចំការចំនួន ២១,៦% នៃដីស្រែចំការរបស់ប្រទេសកម្ពុជា គឺជាកម្មសិទ្ធិរបស់ម្ចាស់ដីខ្នាតធំ និងខ្នាតមធ្យម។ នៅទសវត្សទី៦០ ដីស្រែ ចំការដែលកាន់កាប់ដោយម្ចាស់កម្មសិទ្ធិខ្នាតធំ (ដែលមានដីច្រើនជាង ២០ហិកតា) បានគ្របដណ្តប់លើផ្ទៃដីទំហំ ៥,៦% នៃផ្ទៃដីស្រែចំការរបស់ប្រទេស។ ក្រៅពីនោះ ដីស្រែចំការដែលកាន់កាប់ដោយម្ចាស់កម្មសិទ្ធិខ្នាតមធ្យម (ដែលមានផ្ទៃដីទំហំប្រមាណពី ១០ ទៅ ២០ ហិកតា) បានគ្រប

ដណ្តប់លើផ្ទៃដីចំនួន ១៦%។ ដីស្រែចំការដែលម្ចាស់កម្មសិទ្ធិខ្នាតតូច (ដែលមានផ្ទៃដីទំហំពី ៥ ទៅ ១០ ហិកតា) គឺមានចំនួន ២៤,៨% នៃដីស្រែចំការទូទាំងប្រទេស ។ រីឯកសិដ្ឋានតូចតាច (ដែលមានដីទំហំ ១ហិកតា) បានគ្របដណ្តប់លើដីស្រែចំការប្រមាណចំនួនតែ ៥,២% នៃមូលនិធិដីស្រែចំការរបស់ប្រទេស។ ក្រៅពីនេះទៀត ជាកម្មសិទ្ធិរបស់កសិករតូចតាចដែលមានដីស្រែចំការតិចជាងមួយហិកតា។

នៅសម័យនោះ ក្នុងចំណោមប្រជារាស្ត្រជាង ៦លាននាក់ គឺ មាន ២.៥ លាននាក់ (ប្រហែល ៤៤%នៃប្រជនជនសរុប) ជាប្រជាជនសកម្ម ដែលក្នុងនោះ ៨០% នៃប្រជាជនសកម្ម គឺជាកសិករ។ ក្នុងចំណោមកសិករទាំងអស់ ៨១% ជាអ្នកប្រកបរបរដាំដំណាំស្រូវ ១៦% ជាអ្នកប្រកបរបរកសិកម្មផ្សេងទៀត និង ៣% ជាអ្នកនេសាទ។ [120]

នៅឆ្នាំ១៩៥៦ នៅប្រទេសកម្ពុជាបានបង្កើតអង្គការសហករណ៍កសិកម្ម ដែលអង្គការនេះ មានសិទ្ធិទទួលប្រាក់ឥណទានពីធនាគារ កណ្តាលដើម្បីអភិវឌ្ឍន៍វិស័យកសិកម្ម។

គួរបញ្ជាក់ថា អង្គការសហករណ៍កសិកម្ម គឺជាសហគ្រាសកសិកម្ម ដែលមានកសិករជាច្រើនចូលរួមបង្កើត ដើម្បីសម្រេចបំណងរួម ដែលជាប្រយោជន៍ដល់ពួកគេគ្រប់ៗគ្នា លើការងារកសិកម្មនៅជនបទ ។ សហករណ៍កសិកម្ម មានច្រើនប្រភេទដូចជាសហករណ៍ឧបភោគបរិភោគ សហករណ៍កសិកម្ម កសិកម្មពហុការ សហករណ៍កម្មករ សហករណ៍សិល្បៈ និងពាណិជ្ជកម្ម សហករណ៍ចងការប្រាក់ (សហករណ៍ផ្តល់ទុនខេត្ត) សហករណ៍ផលិតផល សហភាពសហករណ៍ និងគ្រឹះស្ថានប្រជារាស្ត្រ ជាដើម។

នៅឆ្នាំ១៩៦៣ ចំនួនសហករណ៍ខាងលើនេះមានតែ ២៨១ ប៉ុណ្ណោះ លុះដល់ឆ្នាំ ១៩៦៩ បានកើនឡើងរហូតដល់ ៧៦០។ ទិន្នន័យនេះ បង្ហាញអំពីការរីកលូតលាស់ ក្នុងវិស័យសហគមន៍កសិកម្ម និងមិនមែនកសិកម្មនៅជនបទដែលបង្ហាញផងដែរ អំពីការចូលរួមរបស់ប្រជារាស្ត្រក្នុងការចងក្រងជាសហគមន៍ផលិតកម្ម ដោយមានការឧបត្ថម្ភ គាំទ្រពីរាជរដ្ឋាភិបាលសម័យនោះ និងដើម្បីកាត់បន្ថយការកេងប្រវ័ញ្ចពីឈ្មួញកណ្តាល។ ជាឧទាហរណ៍នៅសម័យអាណានិគមបារាំង រដ្ឋាភិបាលអាណានិគម មិនបានយកចិត្តទុកដាក់លើជីវភាពប្រជារាស្ត្រនៅជនបទនោះឡើយ ជាក់ស្តែង ចំពោះកសិករដែលដាំដំណាំស្រូវ ពួកគេ ទទួលបានចំណូលតែ ២៦%ប៉ុណ្ណោះ នៃតម្លៃស្រូវ ហើយ ៣៣.៦% ទៀត បានទៅឈ្មួញកណ្តាល ២១% បានទៅអ្នកដឹកជញ្ជូនផលិតផល ១៤.៤% បង់ពន្ធដារជូនរាជការអាណានិគម និង ៥% បានទៅថៅកែម៉ាស៊ីនស្រូវ។

ចំពោះបណ្តាកសិដ្ឋាននៅតាមទន្លេមេគង្គ គឺជាតំបន់ដីចំការដែលគេអាចដាំដំណាំបានគ្រប់មុខ និងដាំបានពីរដងក្នុងមួយឆ្នាំ។ តាមធម្មតា ម្ចាស់ដីស្រែចំការនៅតំបន់នោះ ដែលមានទំហំផ្ទៃដីពី ៥ទៅ ១០ ហិកតា ច្រើនតែប្រកបរបរកសិកម្មតាមលក្ខណៈប្រវាស់ដី ហើយបានទទួលផលចំណេញច្រើនជាងម្ចាស់ដី ដែលមានទំហំផ្ទៃដីចាប់ពី ១៥ ទៅ ២០ ហិកតា។ នៅតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជាយើង ម្ចាស់ដី ដែលបានជួលដីរបស់ខ្លួនអោយកសិករដទៃទៀត សម្រាប់ដាំដំណាំ បច្ចេកទេសលើដី

ល្បាប់ ក្នុងមួយហិកតាបានផ្តល់ទិន្នផល ឬប្រាក់ចំណូលប្រមាណ ២ ទៅ ៣ដង លើសដីស្រែសម្រាប់ដាំដំណាំស្រូវក្នុងមួយហិកតា។

ដោយសារតែប្រជាជនខ្មែរយើងភាគច្រើនបានពឹងផ្អែកលើរបរកសិកម្ម ដូចនេះរបៀបនៃការរស់នៅ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងធម្មជាតិហើយនឹងសណ្ឋានដី។ ពិតមែនតែលក្ខណៈភូមិសាស្ត្រ នៃប្រទេសកម្ពុជាបានញ៉ាំងអោយវិស័យកសិកម្មអាចរីកលូតលាស់បានក៏ដោយ ក៏ផ្ទៃដីសម្រាប់ធ្វើកសិកម្ម មានទំហំប្រហែលជា ១/៦ នៃផ្ទៃដីប្រទេសខ្មែរទាំងមូលប៉ុណ្ណោះ។ តាមស្ថិតិឆ្នាំ ១៩៥៨ ការប្រើប្រាស់ ដីកសិកម្មមានលក្ខណៈដូចខាងក្រោមនេះ ៖

- ដីសម្រាប់ដាំដំណាំស្មើនឹង ៣.០១៦.០០០ ហិចតា (១៧%)
- ដីគ្មានដំណាំស្មើនឹង ១.៨៦៧.០០០ ហិចតា (១០%)
- ដីព្រៃឈើស្មើនឹង ១៣.២២៧.០០០ ហិចតា (៧៣%)។

គួរបញ្ជាក់ថា ដីកសិកម្មនៅប្រទេសកម្ពុជាមានដំណើរការ និង មានលក្ខណៈសម្គាល់ដូចខាងក្រោមនេះ ៖

- ជាលក្ខណៈឯកវប្បកម្មនៃដំណាំស្រូវ
- ភាគច្រើនវាជីកម្មសិទ្ធិដែលមានទំហំតូច
- កសិកម្មគ្រួសារច្រើនតែប្រកបរបរកសិកម្មយថាផល
- កសិករភាគច្រើនខ្វះដើមទុន ព្រមទាំងខ្វះមធ្យោបាយផលិតកម្ម
- ជាទូទៅទទួលបានទិន្នផលទាប
- ផលទុនផលិតកម្មជាមធ្យមមានកម្រិតទាប ។

### ៣.២.១ ដំណាំជាស្បៀងអាហារ

ក. ដំណាំស្រូវ

ដំណាំស្រូវ គឺជាដំណាំយ៉ាងសំខាន់នៅប្រទេសខ្មែរយើង។ នៅសម័យសង្គមរាស្ត្រនិយម ដំណាំនេះ បានលាតសន្ធឹងលើផ្ទៃដីប្រមាណ ជា ២.៤២៧.២០០ ហិចតា។ ក្នុងឆ្នាំ ១៩៥៥ ផលិតផលស្រូវទទួលបាន ១.៤៨៤.០០០ តោន។ ចន្លោះឆ្នាំ១៩៦៧–១៩៦៨ ផលិតផលស្រូវកើនឡើងដល់ទៅ ៣.២ ៥២.០០០ តោន។

នៅឆ្នាំ១៩៧០ ទិន្នផលស្រូវបានកើនឡើងដល់ ៣.៨១៤.០០០ តោន ដែលគិតជាមធ្យមស្មើនឹង ២ ទៅ ២.៥តោន/ហិកតា។ បើគិតជាមធ្យមសម្រាប់ប្រជាពលរដ្ឋម្នាក់ៗ ត្រូវទទួលបាន ៥៦៨ គ.ក/ម្នាក់ ដែលសម័យនោះ យើងមានប្រជាពលរដ្ឋប្រមាណ ៦.៥ លាន នាក់។

កសិករខ្មែរ មិនទាន់ចេះប្រើប្រាស់នូវឧបករណ៍កសិកម្មទំនើបៗ នៅឡើយទេ។ ពួកគេច្រើនតែពុំសូវយកចិត្តទុកដាក់នឹងការប្រើជី ឬជ្រើសរើសពូជស្រូវនោះទេ។ ដូចនេះហើយ បានជាគេទទួលបានទិន្នផលមិនប្រសើរ។ ម្យ៉ាងទៀតកសិករភាគច្រើនដែលជាម្ចាស់ដី គេនិយមធ្វើកសិកម្មជាលក្ខណៈប្រវាស់ដីដៃរ។ រីឯកសិករស៊ីឈ្នួលពុំសូវមានទេ។ អ្នកទាំងនោះ ច្រើនជាអ្នកស៊ីឈ្នួលតាមរដូវកាល

ប៉ុណ្ណោះ។ ដំណាំស្រូវជាទូទៅ មានលក្ខណៈជាកសិកម្មគ្រួសារ លើផ្ទៃដីផ្ទាល់ខ្លួនតូចៗ។ ដោយឡែកមានតែខេត្តបាត់ដំបងទេដែលផ្ទៃដីស្រែចំការច្រើនតែមានទំហំធំៗហើយមានកសិករស៊ីឈ្នួលជាប្រចាំ។

នៅប្រទេសកម្ពុជា ការដាំដំណាំស្រូវចែកចេញជា ២ប្រភេទ គឺស្រូវវស្សា និងស្រូវប្រាំង។ ដំណាំស្រូវវស្សាសម្បូរជាងគេ ព្រោះស្រូវប្រភេទនេះ ជាដំណាំដែលដាំដុះយ៉ាងងាយស្រួលនៅលើផ្ទៃដីដែលមានទឹកលិចក្នុងរដូវវស្សា ហើយចំណែកឯស្រូវប្រាំងវិញ ត្រូវបានគេដាំដុះនៅតំបន់ណាដែលមានប្រភពទឹកនៅទីនោះ។ ពូជស្រូវដែលគេនិយមដាំដុះនាសម័យនោះ ចែកជា ៣ប្រភេទ ដោយគិតទៅតាមដំណើរលូតលាស់របស់វា គឺស្រូវស្រាល ដែលផ្តល់ទិន្នផលបានក្នុងរយៈពេលតែ ៣ខែ ប៉ុណ្ណោះ។ ស្រូវកណ្តាលផ្តល់ទិន្នផលក្នុងរយៈពេល ៦ខែ។ ស្រូវធ្ងន់ផ្តល់ទិន្នផលក្នុងរយៈពេល ៩ខែ។ ស្រូវមួយបែបទៀតដែលគេនិយមចូលចិត្តដាំនៅតំបន់ទឹកឡើងរហ័ស គឺស្រូវឡើងទឹក។

គេធ្វើស្រូវពង្រោះនៅខេត្តបាត់ដំបង និងក្នុងភូមិភាគជាប់នឹងបឹងទន្លេសាបនៃខេត្តកំពង់ឆ្នាំង ពោធិសាត់ សៀមរាប កំពង់ធំ។ ក្រៅពីនេះ គេប្រើវិធីដកស្ទូងតាមធម្មតា។ ក្នុងប្រតិបត្តិការដាំដុះគ្រប់យ៉ាង ធ្វើឡើងដោយដៃ គេពុំបានយកគ្រឿងចក្រមកប្រើប្រាស់ទេ។

មណ្ឌលដាំស្រូវសំខាន់ជាងគេគឺ ខេត្តបាត់ដំបង (គេអោយឈ្មោះថា ជង្រុកស្រូវ) កំពង់ចាម ស្វាយរៀង កណ្តាល ព្រៃវែង និងតាកែវ។ ជាទូទៅក្នុងឆ្នាំធម្មតា ប្រទេសខ្មែរអាចលក់ស្រូវចេញទៅបរទេសបានពី ៥០០ ០០០ តោន។ ក្នុងឆ្នាំខ្លះគេអាចលក់បានច្រើនជាងនេះទៀត ។

ខ. ដំណាំពោត

ពោត គឺជាដំណាំសំខាន់ទីពីរ បន្ទាប់ពីដំណាំស្រូវ។ ដំណាំពោតស (ពោតដំណើប) ភាគច្រើនត្រូវបានកសិករប្រើប្រាស់សម្រាប់បរិភោគជាអាហារបន្ថែប ហើយនៅពេលមានគ្រោះទុរ្ភិក្ស គេប្រើប្រាស់ ពោតជាអាហារចាំបាច់លាយជាមួយនឹងបាយៗ ចំពោះពោតក្រហមវិញ ត្រូវបានគេប្រើប្រាស់សម្រាប់លក់ចេញទៅកាន់ទីផ្សារបរទេស។

នៅមុនសង្គ្រាមលោកលើកទី២ ផលិតផលពោតក្នុងមួយឆ្នាំៗ ទទួលបានរហូតដល់ទៅ ៤០០.០០០តោន ប៉ុន្តែនៅសម័យឯករាជ្យ ផលិតផលនេះបានថយចុះមកនូវត្រឹមតែ ១០០.០០០ តោនទៅវិញ ព្រោះដោយសារមានការកាត់បន្ថយផ្ទៃដីដាំដុះដំណាំពោត។ មណ្ឌលពោតសំខាន់ជាងគេគឺកំពង់ចាម និងកណ្តាល ដែលផ្តល់ផលិតផលពោតច្រើនជាងគេ។

ជាងនេះទៀត ចំពោះផ្ទៃដីដាំដុះដំណាំពោតនៅឆ្នាំ ១៩៦៧ មានចំនួន ១០២.០០០ ហិកតា និងទទួលបានទិន្នផល ១៤៩.៩០០ តោន។ នៅឆ្នាំ ១៩៦៨ ទិន្នផលពោតបានកើនឡើងដល់ ១៥៤.០០០

តោន។

គ. ដំណាំផ្តល់ប្រេង

- ដំណាំសណ្តែកដីៈ ភាគច្រើនត្រូវបានកសិករខ្មែរដាំដុះនៅលើដីខ្សាច់តាមជួរមាត់ទន្លេ។ សណ្តែកដី ជាដំណាំដែលគេប្រើប្រាស់សម្រាប់បរិភោគក្នុងស្រុក និងសម្រាប់ស្លធ្វើជាប្រេង។

នៅក្នុងឆ្នាំ១៩៦៨ និងឆ្នាំ១៩៦៩ គេទាញយកផលសណ្តែកដីបាន ២៥.៧០០តោន ដោយបានដាំលើផ្ទៃដីចំនួន ២១.៦០០ ហិកតា។

- ដំណាំល្ង៖ ត្រូវបានកសិករខ្មែរដាំដុះជាប្រភេទល្ងស និងល្ងខ្មៅ សម្រាប់ប្រើប្រាស់ក្នុងស្រុក និងសម្រាប់លក់ចេញទៅបរទេស។ ដំណាំនេះ គេនិយមដាំនៅតាមបណ្តោយច្រាំងទន្លេ និងគ្រប់ទីទួលខ្ពស់មិនលិចទឹក។
- ដំណាំល្ហុងខ្មែរ៖ ត្រូវបានគេដាំនៅជួរមាត់ទន្លេក្នុង ខេត្តកណ្តាល និងកំពង់ចាម។ ផលិតផលនេះ គិតជាមធ្យម ចន្លោះឆ្នាំ ១៩៥៩ ដល់ ១៨៦៤ បានកើនឡើង ដល់ជាង ៣០០០ តោន។ បន្ទាប់មកចំនួននេះ បានថយចុះជាលំដាប់ ក្នុងឆ្នាំ ១៩៦៨ និង ១៩៦៩ ដែលនៅសល់តែ ១០០ តោន។ ហើយពីឆ្នាំ១៩៦៩ ដល់ ១៩៧០ ទើបកើនឡើង ដល់ ៣៥០ តោនវិញ។
- ដំណាំដូង៖ មានមុខងារដ៏សំខាន់ក្នុងការធ្វើម្ហូបអាហាររបស់ខ្មែរ គេយកខ្ទះដូងធ្វើជាបង្អែម យកផ្លែដូងទុំ ធ្វើជាវត្ថុធាតុដើម សម្រាប់ផលិតជាសាប៊ូ គេអាចបរិភោគ ទឹកដូង និងសាច់ដូងស្រស់ដែលមានឱជារស់ ព្រមទាំងមានអត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់សុខភាព។ គួរបញ្ជាក់ថា ផលិតផលដូង នៅក្នុងស្រុកខ្មែរយើង ពុំទាន់អាចបំពេញសេចក្តីត្រូវការបានឡើយ ជាពិសេសសម្រាប់រោងចក្រធ្វើសាប៊ូ ដែលត្រូវការប្រេងដូងធ្វើជាវត្ថុធាតុដើម។ នាសម័យកាលនោះ ទម្ងន់ដូងស្ងួតមានប្រហែលជា ៧.០០០តោន ប៉ុណ្ណោះក្នុងមួយឆ្នាំ ។

ឃ. ដំណាំផ្តល់ស្ករ

- ដំណាំអំពៅ៖ ដែលគេបានដាំដុះភាគច្រើនគឺជាអំពៅ សម្រាប់បរិភោគស្រស់។ ចំណែកឯអំពៅសម្រាប់ផលិតជាស្ករសវិញ ពុំសូវមានទេ តែគេកត់សម្គាល់ឃើញថា អំពៅយកស្ករនេះ មានសន្ទុះខ្លាំងក្លា ហើយរីកចម្រើនទៅតាមសកម្មភាពរបស់រោងចក្រចម្រាញ់ស្ករស។
- ដំណាំត្នោត៖ ដើមត្នោតដុះសឹងតែគ្រប់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា ហើយបានដុះនៅតាមភ្លឺស្រែ ឬតាមផ្លូវនៅទីជនបទ ក្នុងខេត្តតាកែវ កណ្តាល កំពត កំពង់ស្ពឺ កំពង់ចាម និងកំពង់ឆ្នាំង។ ត្នោតមួយដើមអាចផ្តល់ស្ករត្នោតគិតជាមធ្យមក្នុងមួយឆ្នាំ៦០ដល់៧០គ.ក។ នៅសម័យកាលនោះ ជារៀងរាល់ឆ្នាំ បើតាមការប៉ាន់ស្មាន ផលិតផលស្ករត្នោតអាចប្រែប្រួលពី ៤០.០០០ ទៅ ៥០.០០០ តោន។

ដើម្បីយកទឹកត្នោត កសិករខ្មែរបានគៀបផ្កា និងចិតផ្កានោះមួយចំណិតយ៉ាងស្តើង រៀងរាល់ពេលដែលគេឡើងយកទឹកត្នោត។ ទឹកត្នោតដែលបានចេញពីផ្កាត្នោតមក ត្រូវបានស្រក់ចូលក្នុងបំពង់ឫស្សី ឬបំពង់ស័ង្កសី។ គេចបរិភោគទឹកត្នោតស្រស់ ឬមួយជាទឹកត្នោតជូរ ឬប្រើប្រាស់ជាទឹកខ្មេះ។ តែភាគច្រើនគេទុកទឹកត្នោតសម្រាប់ធ្វើជាស្ករត្នោត។ កសិករខ្មែរចាប់ផ្តើមឡើងត្នោតតាំងពីដើមខែវិច្ឆិកា រហូតដល់ខែឧសភាទើបឈប់។ ក្នុងមួយថ្ងៃៗគេឡើងយកទឹកត្នោតពីរដង។ ទឹកត្នោតពេលយប់ស្រក់បានច្រើនជាងទឹកត្នោតស្រក់នៅពេលថ្ងៃ។

ង. ដំណាំម្រេច

កសិករខ្មែរ បានដាំម្រេចនៅខេត្តកំពត និងតាកែវ។ នៅសម័យនោះ គេបានពិសោធន៍ដាំម្រេចខ្លះៗហើយ នៅលើតំបន់ដីក្រហមក្នុងខេត្តកំពង់ចាម និងកំពត។ ក្នុងឆ្នាំ ១៩២៨ ផលិតផលម្រេចខ្មែរទទួលបានចំនួនដល់ទៅ ៦,០០០ តោន តែក្រោយមកក្នុងមួយឆ្នាំៗ ទិន្នផលម្រេច បានថយចុះមកនៅត្រឹមប្រហែល ២.៥០០ តោន ក្នុងឆ្នាំ ១៩៦៧ និងឆ្នាំ ១៩៦៨។

ច. ដំណាំអាហារផ្សេងៗទៀត

ក្រៅពីដំណាំសំខាន់ៗ ទាំងប៉ុន្មានខាងលើនេះ គេអាចរាប់បញ្ចូលនូវដំណាំផ្សេងទៀតដូចជាសណ្តែកបាយ (២០.០០០ តោនក្នុងមួយឆ្នាំ) សណ្តែកសៀង (១០.០០០តោនក្នុងមួយឆ្នាំ) ព្រមទាំងផ្លែឈើគ្រប់បែបយ៉ាងដូចជា ចេក ស្វាយ ក្រូច ម្នាស់ លុត មៀន ធូរេន ។ល។ បានផ្តល់លទ្ធភាពយ៉ាងទូលំទូលាយ ក្នុងការប្រើប្រាស់វត្ថុធាតុដើម ។ សម្រាប់ផលិតជាអាហារកំប៉ុង គេនិយមដាំបន្លែនៅជិតទីក្រុងធំៗ និងទីប្រជុំជន ហើយបានដាំនៅតាមមាត់ទន្លេមេគង្គ។ ចំពោះផ្លែឈើអស់ខាងលើនេះត្រូវបានដាំតាមគ្រប់បណ្តាខេត្ត ប៉ុន្តែខេត្តដែលបានដុះច្រើនជាងគេ មានខេត្តកំពង់ចាម កណ្តាល បាត់ដំបង និងកំពត។

### ៣.២.២ ដំណាំឧស្សាហកម្ម

ដំណាំសំខាន់ជាងគេក្នុងផ្នែកនេះ គឺដំណាំកៅស៊ូ ដែលបានផ្តល់ផលជារៀងរាល់ឆ្នាំសម្រាប់នាំចេញទៅលក់នៅលើទីផ្សារបរទេស។

ក. ដំណាំកៅស៊ូ

នៅសម័យកាលនោះ គេបានដាំកៅស៊ូនៅក្នុងចំការធំៗ នៃតំបន់ដីក្រហម។ ដំណាំនេះមាននៅក្នុងស្រុកខ្មែរដោយសារតែ ក្រុមហ៊ុនបារាំង បាននាំចូលមកកាលពីឆ្នាំ ១៩២១ ម្ល៉េះ។ នៅជំនាន់នោះ គេប្រើ កម្មករជនជាតិយួនតុងកឹង បន្ទាប់មកទើបមានកម្មករខ្មែរចូលធ្វើការជាមួយ។ ចំការកៅស៊ូ ច្រើនតែផ្តុំគ្នានៅខេត្តកំពង់ចាម និងក្រចេះ ដូចជា ជប់ ព្រែកកក់ ចំការអណ្តូង ចំការលើ ក្រែក មេមត់ ស្នួល ។ល។ ប៉ុន្តែ ក្រោយមក ចំការកៅស៊ូបានរីករាលដាលទៅដល់តំបន់កំពង់សោម និងខេត្តរតនៈគីរី។

នៅសម័យសង្គមរាស្ត្រនិយម អាជីវកម្មកៅស៊ូភាគច្រើនជាកម្ម សិទ្ធិរបស់ក្រុមហ៊ុនបារាំង ដែលក្រុមហ៊ុនសំខាន់ៗ មានចំនួនដូចខាង ក្រោមនេះ ៖

- ក្រុមហ៊ុនខ្មែរ (នៅជប់)
- ក្រុមហ៊ុនចំការកៅស៊ូមេមត់
- ក្រុមហ៊ុនចំការកៅស៊ូមេគង្គ (នៅព្រែកកក់)
- ក្រុមហ៊ុនចំការកៅស៊ូកំពង់ធំ (នៅចំការអណ្តូង)
- ក្រុមហ៊ុនចំការកៅស៊ូក្រចេះ (នៅស្នួល)។

ចំពោះក្រុមហ៊ុនរបស់រដ្ឋ មានចំនួន ០១ និងក្រុមហ៊ុនចម្រុះរដ្ឋ និងឯកជនមានចំនួន ០៤។ ក្រោយពេលទទួលបានឯករាជ្យមក ប្រទេសខ្មែរយើងបានខិតខំពង្រីកដំណាំចំការកៅស៊ូរបស់រដ្ឋជាបន្តបន្ទាប់ មានចំការកៅស៊ូរដ្ឋនៅ ឡាបានសៀក ខេត្តរតនៈគីរី ចំការអណ្តូង ខេត្តកំពង់ចាមជាដើម។ នៅក្បែរចំការធំៗរបស់ឯកជន ឬរបស់រដ្ឋ រដ្ឋាភិបាលខ្មែរបានជួយជ្រោមជ្រែងដោយផ្តល់ពូជជារ ដី និង

បច្ចេកទេស ដល់ចំការដំណាំគ្រួសារ ហើយនិងជួយទិញផលិតផលពីចំការទាំងនោះថែមទៀតផង។ ដើម្បី ទទួលបានលទ្ធផលល្អ ដំណាំកៅស៊ូត្រូវការបច្ចេកទេសដែលផ្អែកទៅ លើវិទ្យាសាស្ត្រទាំងស្រុង។ គេប្រើប្រាស់វិធីបំបៅពូជកៅស៊ូល្អៗនៅលើដើមដែលគេបានបណ្តុះក្នុងរណ្តៅដីជាជួរៗ ឃ្លាតពីគ្នាតាមក្បួនខ្នាត។ ពេលដើមដុះល្អហើយ គេថែរក្សាយ៉ាងហ្មត់ចត់ និងយកទៅដាំក្នុងចំការ ដែលបានរៀបចំដីរួចជាស្រេច និងធ្វើការថែទាំតាមបច្ចេកទេស រហូតដល់រយៈពេល ៧ឆ្នាំ ទើបដើមធំល្មមអាចយកជ័របាន។ កម្មករជៀរដើម កៅស៊ូដើម្បីបង្ហូរយកជ័រដោយចិតយកសំបកមួយចំណិតយ៉ាងស្តើងក្នុង មួយសប្តាហ៍ ៣ ឬ៤ដង។ ផលិតផលកៅស៊ូនៅឆ្នាំ ១៩៥៥ ទទួលបាន ២៥.០០០តោន ហើយចំនួននេះបានកើនឡើងរហូតដល់ ៥១.០០០ តោន នៅក្នុងឆ្នាំ ១៩៦៨។ ឆ្នាំ១៩៦៩ ផ្ទៃចំការកៅស៊ូបានកើនឡើងដល់ ៦៧ ០០០ ហិកតា ហើយបានផ្តល់ទិន្នផលជិត ៥២.០០០ តោន។ ពិតមែនតែឧស្សាហកម្មកៅស៊ូនេះ ពុំទាន់មានការរីកចម្រើនញលេញក៏ដោយ ក៏ដំណាំកៅស៊ូ នៅមានមុខងារសំខាន់ណាស់ក្នុងជីវភាពសេដ្ឋ កិច្ចរបស់ខ្មែរទាំងមូលនាសម័យកាលនោះ។

ខ. រុក្ខជាតិសរសៃត្បាញ

- ដំណាំកប្បាសៈ គឺជាដំណាំដែលបានដាំដុះភាគច្រើននៅតាម មាត់ទន្លេមេគង្គ។ តំបន់ដែលបានដាំដុះសំខាន់ជាងគេ គឺនៅខេត្តក្រចេះ បាត់ដំបង និងកំពង់ចាម។ នាសម័យនោះ ដំណាំកប្បាសត្រូវបានគេដាំ នៅលើដីខ្មៅដែលមានជីជាតិ។ ជារៀងរាល់ឆ្នាំ ផលិតផលកប្បាសមានប្រហែលជា ៦.០០០ តោន។ នៅក្នុងចំនួននោះ ២.០០០ តោន សម្រាប់ រោងចក្រវាយនភ័ណ្ឌក្នុងប្រទេស ក្រៅពីនោះសម្រាប់ការនាំចេញ។
- ដំណាំមនៈ ផ្តល់ស្លឹកសម្រាប់ចិញ្ចឹមដង្កូវនាង។ គេច្រើនដាំដើមមន នៅខេត្តកណ្តាល និងព្រៃវែង។ ផ្ទៃដីដាំដើមមន មានសភាពកាន់តែតិចទៅៗ ជាហេតុនាំអោយរាជរដ្ឋាភិបាលខ្មែរបានចាប់អារម្មណ៍ជាខ្លាំង ដូច្នេះហើយ ទើបគេចាប់ផ្តើមធ្វើគម្រោងមួយសម្រាប់ចិញ្ចឹមដង្កូវនាង។
- ដំណាំក្រចៅៈ មានដាំនៅមាត់ទន្លេមេគង្គ។ គេប្រើក្រចៅសម្រាប់ធ្វើជាចំណងបន្តិចបន្តួច។ ក្រោយមកដំណាំនេះ មានសន្ទុះយ៉ាងខ្លាំងក្លា ដោយសារមានរោងចក្រក្រចៅនៅខេត្តបាត់ដំបង។ ផលិតផលក្រចៅក្នុងឆ្នាំ ១៩៦៨ និងឆ្នាំ ១៩៦៩ បានកើនឡើងដល់ ៦.៣០០ តោន។
- ដំណាំថ្នាំជក់ៈ គេដាំតាមច្រាំងទន្លេរនៅពេលទឹកស្រក។ ខេត្តកំពង់ចាមបានផ្តល់ទិន្នផលចំនួន ២/៤ ហើយនៅខេត្តកណ្តាលមានចំនួន ១/៤ នៃផលិតផលសរុបក្នុងប្រទេស។ ក្នុងឆ្នាំ ១៩៦៩ និងឆ្នាំ ១៩៧០ ថ្នាំជក់របស់ខ្មែរយើង មានចំនួនដល់ទៅ ១៦.៣០០ តោន។ ពូជថ្នាំជក់ខ្មែរមានច្រើនប្រភេទណាស់។ ថ្នាំជក់ពណ៌ទង់ដែង ដែលគេនិយមប្រើសម័យនោះ ជាពូជមកពីបរទេស ដែលរីកដុះដាលចាប់តាំងពី ឆ្នាំ ១៩៤៩ មក។ គេដាំថ្នាំជក់ ដើម្បីកុំអោយខាតបង់រូបិយប័ណ្ណសម្រាប់ទិញថ្នាំជក់ដែលនាំចូលពីបរទេស។

- ដំណាំឧស្សាហកម្មផ្សេងៗទៀត មានដំណាំ តែ និងកាហ្វេ ដែលគេបានដាំក្នុងចំការធំៗ នៅតាមតំបន់មានអាកាសធាតុត្រជាក់ល្មម និងមានភ្លៀងច្រើនដូចជា បូកគោ គីរីរម្យ និងប៉ៃលិនជាដើម។

ក្រៅពីនេះ គេឃើញមានរុក្ខជាតិដើមគរ ដុះសឹងតែគ្រប់ទីកន្លែង ហើយនឹងដើមធ្នៃ ដែលគេប្រើប្រាស់សម្រាប់ធ្វើឧបករណ៍នេសាទ។

### ៣.២.៣ ការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វនៅប្រទេសកម្ពុជាយើង ភាគច្រើនជាការចិញ្ចឹមសត្វខ្នាតតូច ពោលគឺជាការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដែលមិនសូវមានចំនួនសត្វច្រើនប៉ុន្មានទេ។ ចំពោះការចិញ្ចឹមគោ និងក្របីវិញគេច្រើនតែចិញ្ចឹមយកទៅប្រើប្រាស់ជាកម្លាំងអូសទាញ នៅក្នុងវិស័យកសិកម្មធ្វើស្រែចំការ និងប្រើប្រាស់ក្នុងវិស័យគមនាគមន៍ ដឹកជញ្ជូន ហើយមិនមែនសម្រាប់យកទឹកដោះ ឬយកសាច់បរិភោគនោះទេ។

- សត្វគោះ បើធៀបទៅនឹងគោអឺរ៉ុបដែលមានទម្ងន់ពី ៨០០ គ.ក ទៅ ១.០០០ គ.ក គោខ្មែរមិនសូវជាធ្ងន់ប៉ុន្មានទេ គឺមានទម្ងន់ពី ៣៥០ ទៅ ៥៥០ គ.ក។ នៅសម័យនោះ គោទាំងអស់មានចំនួនប្រហែលជា ៣០០.០០០ក្បាល នៅឆ្នាំ ១៩៥៥ ហើយចំនួននេះកើនឡើងរហូតដល់

  ១.៩០០.០០០ ក្បាល នៅចន្លោះឆ្នាំ ១៩៦៨ និង១៩៦៩ ដែលគេច្រើន ចិញ្ចឹមនៅក្នុងខេត្តកណ្ដាល កំពង់ចាម និងបាត់ដំបង។ ក្នុងមួយឆ្នាំៗ គោសម្រាប់យកសាច់មានចំនួនប្រហែល ១.២០០ ក្បាល។ មានគោ ចំនួនប្រហែលជាជាង ៣០.០០០ ក្បាល ដែលត្រូវបានគេនាំចេញទៅ លក់នៅក្រៅប្រទេសក្នុងមួយឆ្នាំៗ។
- សត្វក្របីះ ត្រូវបានកសិករចិញ្ចឹមនៅតំបន់ណាដែលមានវាល ភក់ច្រើន។ ខេត្តដែលចិញ្ចឹមក្របីច្រើនជាងគេគឺខេត្តព្រៃវែង កំពង់ធំ និងកំពង់ឆ្នាំង។ ក្នុងចំណោមក្របី ៧០០.០០០ ក្បាល ដែលប្រទេសខ្មែរមាន ក្នុងសម័យនោះ មានក្របីចំនួន ២០.០០០ ក្បាល ដែលត្រូវបានគេនាំ ចេញទៅលក់នៅក្រៅប្រទេសក្នុងមួយឆ្នាំៗ។
- សត្វជ្រូកះ មានចំនួន ១.១៥១.០០០ ក្បាល។ គេច្រើនចិញ្ចឹមសត្វជ្រូកជាលក្ខណៈគ្រួសារនៅខេត្តកណ្ដាល ស្វាយរៀង តាកែវ និងកំពងចាម។ គេលកជ្រូកចេញទៅបរទេសក្នុងមួយឆ្នាំៗ ប្រហែលពី ១០០.០០០ ទៅ ១០.០០០ ក្បាល។ គេច្រើនយកជ្រូកទៅលកនៅហុងកុង និងវៀតណាម។
- បក្សីស្រុក ដែលកសិករយើងបានចិញ្ចឹម ភាគច្រើនមានដូចជា មាន់ ទា ក្ងាន។ ខេត្តដែលចិញ្ចឹមបក្សីស្រុកច្រើនជាងគេនោះ គឺខេត្តស្វាយរៀង កំពង់ចាម កណ្ដាល។ ចំនួនបក្សីទាំងអស់នៅឆ្នាំ ១៩៥៧ មានប្រហែលជា ៣.៧៣០.០០០ ក្បាល ហើយចំនួននេះបានកើនឡើងរហូតដល់ ៥.៧៥៥.០០០ ក្បាល នៅឆ្នាំ១៩៦៨ និង១៩៦៩។ ឯផលិតផលស៊ុតវិញមាន

គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការក្នុងស្រុក។ ក្នុងមួយឆ្នាំៗ គេបានលក់សត្វបក្សីស្រុកប្រហែលជាជាង ៦.០០០ក្បាល ចេញទៅប្រទេសវៀតណាម។

- សត្វដទៃទៀត ពោលគឺក្រៅពីសត្វស្រុកខាងលើទាំងប៉ុន្មាននេះ នៅមានសត្វចតុបាទ និងសត្វដំរីដែលកសិករខ្មែរបានចិញ្ចឹមមានដូចជា៖
  - សេះ ២.៦០០ ក្បាល
  - ចៀម ៥៤០ ក្បាល
  - ពពែ ១.០០០ ក្បាល
  - ដំរី ៤៣០ ក្បាល។

### ៣.២.៤ ធនធានធម្មជាតិនៃប្រទេសកម្ពុជា

ក. ផលិតផលព្រៃឈើ

ព្រៃឈើ ជាធនធានធម្មជាតិដ៏មានសារៈសំខាន់ដែលបំរើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដោយសារមានការព្រួយបារម្ភពីការរាំងស្ងួត ទើបរាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយម បានបង្កើតអោយមានរុក្ខទិវា នៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។

ព្រៃឈើនាសម័យនោះ បានគ្របដណ្តប់លើផ្ទៃដីចំនួន ១៣លានហិកតា ស្មើនឹង ៧៣% នៃផ្ទៃប្រទេស។ ខេត្តដែលសម្បូរព្រៃឈើជាងគេ គឺខេត្តស្ទឹងត្រែង ក្រចេះ រតនៈគីរី មណ្ឌលគីរី កំពង់ធំ ពោធិសាត់ និងកំពត។ រីឯ ខេត្តបាត់ដំបង កំពង់ចាម កំពង់ស្ពឺ សៀមរាប កំពង់ឆ្នាំង មានព្រៃជាមធ្យម។ ចំពោះខេត្តខ្លះទៀត ត្រូវបានគេកាប់ឆ្ការព្រៃ ដើម្បីយកដីធ្វើជាចំការដំណាំ។ នាសម័យនោះ ឈើជាប្រភពតែមួយគត់នៃវត្ថុ ធាតុសម្រាប់ដុតប្រើប្រាស់នៅក្នុងគ្រួសារ ឬក្នុងឧស្សាហកម្មមួយចំនួន ក្រៅពីនោះ គេប្រើប្រាស់ឈើសម្រាប់សំណង់លំនៅដ្ឋាន ឬធ្វើជាគ្រឿង សង្ហារឹមផ្សេងៗ។

ចំពោះអាជីវកម្មព្រៃឈើទាំងអស់នៅសម័យនោះ គឺធ្វើអាជីវកម្មក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម។ ច្បាប់អនុញ្ញាតអោយកាប់ព្រៃឈើ សុទ្ធតែធ្វើឡើងតាមរយៈការដេញថ្លៃជាសាធារណៈជារៀងរាល់ឆ្នាំ ប៉ុន្តែចំពោះព្រៃឈើដែលបានរៀបចំដាំដុះឡើងវិញ ឬព្រៃឈើបម្រុងទុក គេអាចអនុញ្ញាតអោយទាញយកផលសម្រាប់រយៈពេលច្រើនឆ្នាំបាន។ អាជីវកម្មលើអនុផលព្រៃឈើបន្ទាប់បន្សំទៀត ដូចជា ផ្តៅ ជ័រឈើ ច្រើនតែបើកអោយធ្វើអាជីវកម្មដោយមានច្បាប់អនុញ្ញាតពិសេស។ គេត្រូវតែបង់ពន្ធជូនរដ្ឋ លើផលិតផលទាញចេញពីព្រៃឈើ ។

ការរំលំដើមឈើ ច្រើនតែធ្វើឡើងដោយដៃ ឯការដឹកជញ្ជូនឈើហុបវិញ ភាគច្រើនប្រព្រឹត្តទៅតាមរថយន្ត។ ម្យ៉ាងទៀតគេដឹកនាំឈើហុបនេះទៅកន្លែងគោលដៅតាមរថភ្លើង ឬតាមផ្លូវទឹកដោយបណ្តែតជាក្បូន។

ផលិតផលឈើព្រៃ អាចបំពេញសេចក្តីត្រូវការក្នុងប្រទេសបានគ្រប់គ្រាន់ ហើយថែមទាំងនៅសល់ អាចនាំចេញទៅបរទេសទៀតផង។ ឈើដែលគេបានកាប់ចេញមកពីក្នុងព្រៃចែកចេញជា ៖

- ឈើប្រើប្រាស់ទូទៅដែលមាន ៣២.៧៩៥ ម៣ ជាឈើប្រណិត សម្រាប់ធ្វើជាគ្រឿងសង្ហារឹមមានដូចជា បេង ធ្នង់ កកោះ នាងនួន។ ឈើសំណង់ដែលជាប់បានយូរមាន គគីរ ធ្នឹក សុក្រំ។

ឈើសម្រាប់ធ្វើគុ ទូតាំងធម្មតាមានដូចជា ដូងចែម ស្រឡៅ និងឈើសំណង់ធម្មតា និងសម្រាប់ធ្វើក្តារបន្ទះនៅរោងចក្រ (ជីផង្ឍ) មានដូចជា ឈើទាល ថ្លុង ត្បែង និងត្រាច។

- ឈើឧស្សាហកម្មគេប្រើសម្រាប់ធ្វើជា កំណល់ផ្លូវរថភ្លើង ប្រអប់ហិប កេសសម្រាប់ដាក់ផលិតផល ឈើគូស និងម្សៅក្រដាស ស្ពហាល អួន និងមង (ខាងផ្នែកនេសាទ) ជន្លង់ម្រេច ជាដើម។
- ឈើសម្រាប់ដុត និងសម្រាប់ធ្វើធ្យូង រាល់ឆ្នាំគេកាប់ឈើសម្រាប់ដុតបាន ៣០៨.០០០ ម និងសម្រាប់ធ្យូងចំនួន ២៥.០០០ តោន។ ឈើជំពូកនេះប្រើសម្រាប់តែធ្វើអោយមានកំដៅ និងអោយមានថាមពលផ្សេងៗ។ ក្រៅពីនេះគេទាញយកអនុផលព្រៃឈើខ្លះទៀតដូចជា ឬស្សី ផ្តៅ ជ័រឈើ ក្រវាញ ស្លឹកត្នោត រំពាក់ ដក់ត្នោត។ល។ សម្រាប់ប្រើប្រាស់តាមតម្រូវការ។

**៣.២.៥ ផលិតផល**

ចាប់តាំងពីខែវិច្ឆិកា ដល់ខែឧសភា របរនេសាទជាសកម្មភាពសំខាន់របស់អ្នកស្រុកនៅតាមទន្លេមេគង្គ និងបឹងបួរនានា ហើយជា ពិសេស អ្នកដែលរស់នៅតាមដងទន្លេសាប។ នៅលើពិភពលោកយើងនេះ គឺមានតែបឹងទន្លេសាបទេ ដែលបានផ្តល់ទិន្នផលត្រីច្រើនជាងគេ។ ពោលគឺទិន្នផលត្រីមានរហូតដល់ទៅ ១០តោន/១គ.ម២ ដោយគិតលើផ្ទៃទឹកនារដូវវស្សា ។

របៀបនេសាទអាចចែកជាពីរយ៉ាង គឺនេសាទខ្នាតតូចដែលគេអាចនេសាទដោយដើរលុយទឹក ឬជិះទូក មិនបាច់ប្រើធនធានច្រើនទេ និងពុំមានកម្មករ ហើយប្រើប្រាស់ឧបករណ៍ងាយៗ ដូចជាដងសន្ទូច ស្នមានងៀង និងសំណាញ់។ ឯនេសាទខ្នាតធំវិញប្រើមូលធនច្រើន ឧបករណ៍ច្រើន ហើយមានតម្លៃថ្លៃ និងមានកម្មករច្រើនជួយធ្វើការងារផង។ វិធីចាប់ត្រីក៏ប្លែកពីនេសាទខ្នាតតូចដែរដូចជា ថ្នងធំ មង អញ្ចង អួនជាដើម។ល។

ជារៀងរាល់ឆ្នាំ ផលិតកម្មនេសាទផ្តល់ផលប្រហែល ១៥០.០០០ តោន។ ១/៣ នៃផលត្រីទាំងអស់ ត្រូវបានគេលក់ជាត្រីស្រស់សម្រាប់បរិភោគក្នុងស្រុក។ ផលត្រីដែលនៅសល់ គេធ្វើជាត្រីប្រឡាក់ ត្រីងៀត ត្រីឆ្អើរ ប្រហុក និងទឹកត្រី។ ក្នុងចំណោមផលិតផលនេសាទបន្ទាប់បន្សំ គេអាចរាប់បានដូចជា ខ្លាញ់ត្រី ម្សៅត្រី ដែលគេប្រើធ្វើជាជី ឬជាចំណី សម្រាប់ការចិញ្ចឹមបក្សីស្រុក ។

ក្រៅពីតម្រូវការក្នុងប្រទេស ផលិតផលត្រី អាចនាំចេញទៅលក់ នៅក្រៅប្រទេសបានប្រហែល ២៨.០០០ តោន (ត្រីងៀត ឬត្រីប្រឡាក់) ដែលកាលមុនសង្គ្រាមលោកលើកទី២។ ប្រជាជនខ្មែរយើងនៅសម័យកាលនោះ និយមចិញ្ចឹមត្រីតាម លក្ខណៈ ៣យ៉ាង គឺ ចិញ្ចឹមត្រីតាមបែបបណ្តែតទឹក ចិញ្ចឹមត្រីតាមស៊ង និងចិញ្ចឹមត្រីតាមស្រះ។

ចំពោះការនេសាទតាមសមុទ្រវិញ ក៏មានការរីកចម្រើនផងដែរ ដោយសារតែផលិតកម្មអាហារសមុទ្រ បានកើនឡើងដល់ ៤៥.០០០ តោន ក្នុងឆ្នាំ ១៩៦៨។ គេបាននេសាទជាហូរហែនៅតាមសមុទ្រខ្មែរ មជ្ឈមណ្ឌលនេសាទទឹកប្រៃដែលសំខាន់ជាងគេ គឺនៅក្នុងខេត្តកោះកុង តំបន់រាម កំពត និងកំពង់សោម។ នេសាទសមុទ្រ ទទួលបានទិន្នផលដូចខាងក្រោម ៖

| ឆ្នាំ | ទិន្នផលដែលទទួលបាន |
|---|---|

| | |
|---|---|
| ១៩៦១ | ២៨.០០០ តោន |
| ១៩៦២ | ៣០.០០០ តោន |
| ១៩៦៣ | ៣៥.០០០ តោន |
| ១៩៦៤ | ៣៩.០០០ តោន |
| ១៩៦៥ | ៤២.០០០ តោន |
| ១៩៦៦ | ៤៤.០០០ តោន |
| ១៩៦៧ | ? |
| ១៩៦៨ | ៤៥.០០០ តោន |

*ទិន្នផលនេសាទសមុទ្រឆ្នាំ ១៩៦១ ដល់ ១៩៦៦* [123]

## ៦.៣.៣ វិស័យឧស្សាហកម្ម និងភោគទ្រព្យរ៉ែ

### ភោគទ្រព្យរ៉ែ

ភោគទ្រព្យធម្មជាតិនៅក្នុងដីនៃប្រទេសខ្មែរយើង ពុំទាន់ត្រូវបានសិក្សាស្រាវជ្រាវអោយបានដិតដល់នៅឡើយ។ នាសម័យនោះរាជរដ្ឋាភិបាលបានខិតខំស្រាវជ្រាវ ដោយធ្វើសហប្រតិបត្តិការជាមួយនឹងរដ្ឋាភិបាលបារាំង ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងរួមគ្នាមួយ ដែលបានដំណើរការឡើងក្នុងឆ្នាំ ១៩៦២ ដោយរដ្ឋាភិបាលបារាំងផ្តល់ឥណទានចំនួន ១.២០០.០០០ រៀល។ គេអាចចែកមណ្ឌលរ៉ែនៅប្រទេសខ្មែរជា ៥ក្រុមសំខាន់ៗដូចជា ៖

- មណ្ឌលប៉ៃលិន គឺជាមណ្ឌលដែលសម្បូរទៅដោយរ៉ែត្បូង កន្លងមកត្រូវបានគេធ្វើអាជីវកម្មជីកត្បូង។ ជាយូរឆ្នាំមកហើយអាជីវកម្មក្នុងវិស័យត្បូងនេះ បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកភូមា។ ត្បូងមានតម្លៃមានដូចជា ត្បូងទទឹម និងត្បូងកណ្តៀង។
- មណ្ឌលបរកែវ (រតនៈគីរី) គឺជាមណ្ឌលដែលគេជីកយកត្បូង និងមាស។ តែត្បូងមណ្ឌលនេះច្រើនតែជាត្បូងពេជ្រខ្មែរយើង (Zircon) ដែលគេប្រើប្រាស់ជាគ្រឿងអលង្ការ។

ត្បូងនៅមណ្ឌលប៉ៃលិន និងបរកែវសុទ្ធសឹងតែជាត្បូង ដែលមានតម្លៃណាស់។ អាស្រ័យហេតុនេះហើយបានជារដ្ឋាភិបាលសម័យនោះ មានគំនិតផ្តួចផ្តើមក្នុងការធ្វើអាជីវកម្ម ពីព្រោះត្បូងធម្មជាតិមានតម្លៃថ្លៃ ហើយអាចលក់ចេញទៅបរទេស ដោយទទួលបានមកវិញនូវរូបិយប័ណ្ណយ៉ាងច្រើន។

- មណ្ឌលកំពង់ធំ គឺជាមណ្ឌលដែលមានទាំងរ៉ែដែក និងរ៉ែមាស។ រ៉ែដែកមាននៅភ្នំដែក ដែលមានបរិមាណប្រហែលជា ៥លាន តោន ហើយមានសារជាតិដែកយ៉ាងច្រើនគិតជាមធ្យមប្រហែល ៦០%។ ក្នុងខេត្តកំពង់ធំនេះ រដ្ឋាភិបាលខ្មែរសម័យនោះបានរៀបចំស្ថានាពេងចក្រស្លដែកមួយដែរ។ ផ្សេងពីនេះទៀត ចំពោះរ៉ែមាស គេបានជីកយកមាសដែលកប់នៅក្នុងដីល្បាប់ព័ទ្ធជុំវិញភ្នំជី និងភ្នំលឿង។
- មណ្ឌលកំពត ជាមណ្ឌលអាចផ្តល់ថ្មកំបោរ និងផូស្វាតជាដើម។ ដោយថ្មកំបោរនៅតំបន់នោះមានច្រើនប្រភេទ គេអាចយកវាប្រើសម្រាប់ធ្វើជាកំបោរ ធ្វើស៊ីម៉ង់ត៍ ឬធ្វើគ្រឿងសំណង់។ ឯថ្មផូស្វាត ប្រើសម្រាប់ធ្វើជាជីគីមីដែលអាចយកទៅប្រើប្រាស់ដាក់ក្នុងស្រែ និងចំការផូស្វាត ត្រូវបានគេជីក ដើម្បីធ្វើជាវត្ថុធាតុដើមក្នុងរោងចក្រនៅស្រុកទូកមាស។
- មណ្ឌលពោធិសាត់ ជាមណ្ឌលដែលមានថ្មមួយបែបនៅតំបន់តាសាយ ឈ្មោះថា ថ្មកែវសម្រាប់រចនាធ្វើជាវត្ថុសិល្បៈ។

យើងអាចពិនិត្យមើលប្រភេទរ៉ែលោហៈធម្មជាតិដែលមាននៅ ក្នុងប្រទេសកម្ពុជាយើងដូចខាងក្រោមនេះ ៖

រ៉ែលោហៈធាតុ និងរ៉ែធម្មជាតិ

| | |
|---|---|
| Ag រ៉ែប្រាក់ (argent natif) | Si ស៊ីលីស (silice) |
| Al បុតស៊ីត (bauxite) | Sn កាល់ស៊ីតេរីត (calsitérite) |
| As រ៉ែអាសឺនិច (arsenic) | W វ៉ុលប្រាមីត (wolframite) |

Au រ៉ែមាស (or natif)
Bi រ៉ែប៊ីស្មុត (bismuth)
C ធ្យូងថ្ម (charbon lignite)
Ca ថ្មកំបោរ (calcaire)
Cr រ៉ែក្រូម (chrome)
Cu រ៉ែទង់ដែង (cuivre)
F រ៉ែភ្លុយអរ (fluor)
Fe រ៉ែដែក (fer)
Mg រ៉ែដូឡូមីត (dolomite)
Mo ពីរ៉ូម៉ូលីបដែន (molybdéne)
P ហ្វូស្វាត (phosphate)
Zr ពេជ្រខ្មែរ ថ្មត្បូង និងថ្មលំអ (zircon)
L ថ្មថ្លើមអណ្តើក
M ថ្មម៉ាប
P ថ្មកែវ
Qa ក្វាតអាមេទិស
Qh ក្វាតអ៊ីយ៉ាឡាំង
F ថ្មត្បូង
Y ថ្មត្បូងកន្លៀង ត្បូងទទឹម
A ដីឥដ្ឋ និងរ៉ែផ្សេងៗទៀត

## វិស័យឧស្សាហកម្ម និងសិប្បកម្ម

បន្ទាប់ពីបានទទួលឯករាជ្យ និងពង្រឹងអធិប្បតេយ្យភាពជាតិនៅប្រទេសកម្ពុជាមក វិស័យឧស្សាហកម្មជាតិធុនស្រាល និងសិប្បកម្មត្រូវបានចាប់ផ្តើមរីកលូតលាស់ជាបណ្តើរៗ ក្នុងនោះមានរោងចក្រសហគ្រាសប្រមាណពី ១៨ ទៅ ២០ បានដើរតួនាទីដ៏សំខាន់ក្នុងដំណើរឧស្សាហកម្មផលិតកម្មជាតិ។ រោងចក្រមួយចំនួនរបស់រដ្ឋ ត្រូវបានសាងសង់ឡើងក្រោមកិច្ចសហការផ្នែកបច្ចេកទេស និងសេដ្ឋកិច្ចនៃប្រទេសសង្គមនិយមនានា។

តាមទិន្នន័យមួយចំនួនបញ្ជាក់ថា សម័យសង្គមរាស្ត្រនិយម ការរីកលូតលាស់វិស័យឧស្សាហកម្មផលិតកម្ម ហាក់ដូចជាស្ថិតក្នុងស្ថានភាពទន់ខ្សោយនៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសនានា នៅតំបន់អាស៊ីភាគអាគ្នេយ៍យើងនេះ។ ជាក់ស្តែងនៅឆ្នាំ ១៩៦៧ ក្នុងវិស័យឧស្សាហកម្មផលិតកម្មជាតិនៅកម្ពុជា គឺមានកម្រិតត្រឹមតែ ១២% នៃផលទុនជាតិសរុប (GNP) តែប៉ុណ្ណោះបានសេចក្តីថា នៅមានកម្រិតទាបជាងផលទុនជាតិរបស់ប្រទេសមួយចំនួនធំនៅអាស៊ីភាគអាគ្នេយ៍។

នៅពាក់កណ្តាលទសវត្សទី៥០ និងចុងទសវត្សទី៦០ យើងសង្កេតឃើញថា បរិមាណកម្មករដែលបម្រើការនៅក្នុងប្រទេសកម្ពុជា មានការកើនឡើងខ្ពស់ជាងសម័យអាណានិគមនិយមបារាំង។ ស្ថានភាពបែបនេះ បញ្ជាក់អំពីទម្រង់ឧស្សាហកម្មផលិតកម្មមានការអភិវឌ្ឍទៅមុខជាបន្តបន្ទាប់។ ដូចជានៅឆ្នាំ ១៩៥៥ ដល់ ១៩៥៨ តាមស្ថិតិនានាបានអះអាងថា ចំនួនកម្មករដែលបានបម្រើការ នៅតាមបណ្តារោងចក្រ សហគ្រាស និងនៅក្នុងវិស័យគមនាគមន៍ មានចំនួនប្រមាណ ៤០.០០០ ទៅ ៥៥.០០០ នាក់ ។ ក៏ប៉ុន្តែក្នុងរយៈពេលតែដប់ឆ្នាំប៉ុណ្ណោះ គឺនៅឆ្នាំ ១៩៦៨ ចំនួនកម្មករបានកើនឡើងរហូតដល់ជិតពីរដង ពោលគឺពី ៧៥.០០០ ទៅ ៨០.០០០ នាក់។ ហើយក្នុងនោះភាគច្រើនជាកម្មករ

វិស័យគមនាគមន៍ ការដ្ឋានសំណង់ និងចំការដំណាំឧស្សាហកម្ម។ បើបូករួមទាំង ចំនួនកម្មករនៅតាមបណ្តារោងចក្រ សហគ្រាសតូចតាច និងសិប្បករ ចំនួនកម្មករបានកើនឡើងពី ៩០.០០០ ទៅ

១០០.០០០នាក់។ មជ្ឈមណ្ឌលប្រមូលផ្តុំកម្មករដែលសំខាន់ជាងគេ នោះគឺចំការកៅស៊ូ ដែលមានកម្មករបម្រើការងារ មានចំនួនពី២៤.០០០ ទៅ ២៥.០០០ នាក់។ ចំណែកឯកម្មករការដ្ឋានសំណង់ និងគមនាគមន៍មានប្រមាណ ២០.០០០នាក់។ ក្រៅពីនោះជាប្រភេទកម្មករបម្រើការនៅតាម ជាងរោងចក្រសហគ្រាសនានា។

នៅអំឡុងឆ្នាំ ១៩៥៥ ដល់ ១៩៦៨ ប្រទេសកម្ពុជាមានរោងចក្ររដ្ឋ និងរោងចក្រឯកជន ខ្នាតមធ្យម និងខ្នាតតូចដូចខាងក្រោម៖

ចំនួនក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនរដ្ឋចម្រុះឯកជន និង ក្រុមហ៊ុនឯកជន [124]

| **បរិយាយ** | **១៩៥៥** | **១៩៦៨** |
|---|---|---|
| **រោងចក្ររដ្ឋ** | ០ | ២៨ |
| **រោងចក្ររដ្ឋចម្រុះឯកជន** | ០ | ២៩ |
| **រោងចក្រសហគ្រាសឯកជន ខ្នាតមធ្យម និងខ្នាតតូច** | ៦៥០ | ៣៧០០ |

គួរបញ្ជាក់ផងដែរថា ក្រោយសង្គ្រាមលោកលើកទី ២ ទីក្រុង ភ្នំពេញបានក្លាយទៅជាទីផ្សារកម្លាំងពលកម្មដ៏សំខាន់របស់ប្រទេស។ បាតុភូតនៃការធ្វើចំណាកស្រុករបស់ប្រជាកសិករនៅជនបទដើម្បីស្វែងរកការងារធ្វើនៅទីក្រុងភ្នំពេញ មានលក្ខណៈគួរអោយកត់សម្គាល់។ យ៉ាងណាមិញ នៅឆ្នាំ ១៩៣៩ នៅទីក្រុងភ្នំពេញមានប្រជាពលរដ្ឋរស់នៅតែ ១០០.០០០នាក់ ប៉ុណ្ណោះ។ លុះដល់ឆ្នាំ ១៩៥៦ ប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញបានកើនឡើងពី ៣០០.០០០ ទៅ ៣៥០.០០០ នាក់។ ដូច្នេះកំណើនប្រជាជនចំណូលថ្មី ដែលស្ថិតក្នុងសង្វាក់ខ្លាំងក្លាបែបនេះ គឺជាភស្តុតាងមួយបង្ហាញពីតម្រូវការនូវកម្លាំងកម្មករនៅទីក្រុងភ្នំពេញ ដែលជាសក្ខានុពលមួយបញ្ជាក់អំពីទំនោរនៃការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសេវាកម្មនាសម័យកាលនោះ។

បើពិនិត្យជារួមរហូតមកដល់សម័យសង្គមរាស្ត្រនិយម វិស័យឧស្សាហកម្មពុំទាន់មានមុខងារសំខាន់ប៉ុន្មានទេ ព្រោះប្រទេសខ្មែរយើង ច្រើនតែពឹងផ្អែកលើវិស័យកសិកម្មជាមូលដ្ឋាន។ លក្ខណៈនេះ មានជាយូរយារណាស់មកហើយ។ យ៉ាងណាមិញ នៅសម័យអាណាព្យាបាលបារាំង ដែលបានអនុវត្តសេដ្ឋកិច្ចបែបអាណានិគមនិយម ដោយបានចាត់ទុកប្រទេសខ្មែរយើងជាទីផ្សារសម្រាប់ទទួលយកផលិតផលសម្រេចពីបរទេស ជាពិសេសពីប្រទេសបារាំងតែម្តង និងជាទីផ្សារសម្រាប់ផ្គត់ផ្គង់នូវវត្ថុធាតុដើមទៅបរទេសវិញ ។

ក្រោយពេលទទួលបានឯករាជ្យ អ្នកដឹកនាំរដ្ឋបានខិតខំពង្រឹងជំហរសេដ្ឋកិច្ច ដោយជួយជម្រុញអោយវិស័យឧស្សាហកម្ម មានការរីកលូតលាស់ ដើម្បីការពាររូបិយប័ណ្ណកុំអោយហូរចេញក្រៅប្រទេសច្រើនពេក។ ទោះជាយ៉ាងនេះក៏ដោយ ក៏ឧស្សាហកម្មធុនធ្ងន់នៅតែពុំសូវមានសកម្មភាពខ្លាំងក្លាប៉ុន្មានទេ។ ចំណែកឧស្សាហកម្មធុនស្រាលដែលបែរឆ្ពោះទៅរកផលិតកម្មទំនិញប្រើប្រាស់ក្នុងស្រុក

ហាក់ដូចជាមានដំណើរការលូតលាស់គួរអោយមោទនៈ។ ម្យ៉ាងទៀត ផ្នែកនេះទើបតែកកើតនាពេលក្រោយៗទៀតប៉ុណ្ណោះ ។

ជាសរុប បរិមាណសហគ្រាសឧស្សាហកម្មទាំងតូចទាំងធំ មាន ប្រហែលជិត ៤.០០០ សហគ្រាស។ ពីព្រោះដើមទុនផ្នែកឯកជនក្នុង ស្រុកពុំសូវមាន ហើយម្យ៉ាងវិញទៀត អ្នកមានមូលធនពុំសូវចូលចិត្ត ដាក់ទុនវិនិយោគលើផ្នែកឧស្សាហកម្មនោះទេ។ ពិតមែនតែសេដ្ឋកិច្ច ឧស្សាហកម្មប្រទេសខ្មែរ ចែកជា ៣ទម្រង់ (ផ្នែករដ្ឋ ផ្នែកមូលធនចម្រុះ និងផ្នែកឯកជន) តម្រូវអោយធ្វើទៅតាមគោល

[124] photos - souveniers du CAMBODGE sangkum reastr niyum p1955-1969 p 78

នយោបាយក្នុងប្រទេស ក៏ដោយ ក៏ឧស្សាហកម្មនាសម័យនោះ កំពុងតែត្រូវការជាបន្ទាន់នូវការទ្រទ្រង់ផ្សេងៗទៀតពីសំណាក់រដ្ឋាភិបាល ដើម្បីអោយមានការអភិវឌ្ឍ។ សិប្បកម្មដែលជារបរប្រពៃណី ហើយដែលធ្វើនៅតាមគ្រួសារ បានផ្តល់ វត្ថុសិល្បៈសំខាន់ៗគួរអោយចាប់អារម្មណ៍ ។

## វិស័យថាមពល

ទោះបីជាការស្រាវជ្រាវខ្លះៗ ដែលបានធ្វើរួចមកហើយ ដោយបានបញ្ជាក់នូវសញ្ញាណខ្លះថាមានរ៉ែជាប្រភពថាមពលក៏ដោយ ក៏ប្រទេសខ្មែរ ពុំទាន់បានរកឃើញប្រេងកាត ឬធ្យូងថ្មនៅឡើយទេ។

ក. អុស និងធ្យូងឈើ

អុស និងធ្យូងឈើ គឺជាប្រភពថាមពលយ៉ាងសំខាន់ក្នុងប្រទេស សម្រាប់ប្រើប្រាស់ជាធាតុឆេះក្នុងការចំអិនម្ហូបអាហារ។ ក្នុងឧស្សាហកម្មថាមពល ចំហេះសម្រាប់ក្បាលរថភ្លើង និងកប៉ាល់ប្រើចំហាយ ត្រូវបានគេប្រើប្រាស់អុសជាប្រភពថាមពល (ឥឡូវនេះគេបោះបង់ចោល មធ្យោបាយនេះទៅហើយ)។ ផលិតកម្មធ្យូងឈើមានដល់ទៅ ២៥.០០០ តោន រៀងរាល់ឆ្នាំ ឯអុសវិញមានដល់ ៣០៨.០០០ ស្ទែ។

ខ. ផលិតផលប្រេងកាត

ផលិតផលប្រេងកាតទាំងអស់ សុទ្ធតែជារបស់នាំចូលមករយៈក្រុមហ៊ុនបរទេស។ គួរកត់សម្គាល់ថា កាលពីមុនពេលសាងសង់រោងចក្រចម្រាញ់ប្រេងកាតនៅក្រុងកំពង់សោម ប្រេងឥន្ធនៈសម្រាប់ប្រើប្រាស់ក្នុងស្រុក ត្រូវបាននាំចូលពីបរទេសទាំងស្រុង។ បន្ទាប់ពីបានសាងសង់រោងចក្រចម្រាញ់ប្រេងកាតរួចមក ប្រទេសខ្មែរយើងបានទិញតែប្រេងកាតឆៅ ដើម្បីយកមកចម្រាញ់។ សមត្ថភាពក្នុងការចម្រាញ់ ប្រេងឆៅមានក្នុងកម្រិត ៦០០.០០០ តោនក្នុងមួយឆ្នាំ។[125] ប៉ុន្តែនៅសម័យ នោះយើងបានផលិតជាផលិតផលសម្រេច នៅក្រុងកំពង់សោមបានតែ ៤០០.០០០ តោន ក្នុង
មួយឆ្នាំ។

គ. ធ្យូងថ្ម

ធ្យូងថ្ម ត្រូវបានគេប្រើប្រាស់សម្រាប់កិច្ចការផលិតកម្ម នៅក្នុងរោងជាងដែក ឬឡរំលាយដែក។ ធ្យូងថ្ម ក៏ត្រូវបានគេនាំចូលមកក្នុងប្រទេសខ្មែរ ដែលមួយឆ្នាំៗប្រហែលជា ៣០ តោនដែរ។

ឃ. រោងចក្រអគ្គិសនី

គួរបញ្ជាក់ថា កាលពីសម័យមុនៗ នៅតាមរាជធានី និងតាមទីក្រុងផ្សេងៗ ឬតាមទីប្រជុំជននានា ផលិតកម្មអគ្គិសនីសម្រាប់បំភ្លឺផ្លូវថ្នល់ និងប្រើប្រាស់ក្នុងគេហដ្ឋាន គឺពុំទាន់មានលក្ខណៈជាអគ្គិសនីដែលផលិតចេញពីរោងចក្រឧស្សាហកម្មឡើយ។ ចាប់តាំងពីឆ្នាំ ១៩៤៥ ដល់ ១៩៦០ ផលិតកម្មថាមពលអគ្គិសនីបានកើន ១ ជា ១២ដង (ពី៥លាន kWh ទៅ៥៨លាន kWh ) ហើយមកដល់ឆ្នាំ១៩៦៣មាន៨៧លាន kWh ហើយនៅក្នុងឆ្នាំ១៩៦៨ បានឡើងដល់ទៅ ១២៨ លាន kWh។

ង. ថាមពលអគ្គិសនីថ្មីទៀត

អ្វីដែលគួរអោយយើងមានសង្ឃឹមទៅថ្ងៃក្រោយ គឺថាមពលវារីអគ្គិសនី។ រោងចក្រវារីអគ្គិសនីគិរីរម្យ ជារោងចក្រទីមួយដែលបានផ្តល់អគ្គិសនីដល់ទីក្រុងភ្នំពេញនាសម័យនោះ។ ឯទំនប់ព្រែកត្នោតត្រូវបានស្ថាបនាដោយមានកិច្ចសហប្រតិបត្តិការ និងជំនួយពីអង្គការសហប្រជាជាតិ។

❖ ឧស្សាហកម្មអាហារ

ទាក់ទងទៅនឹងឧស្សាហកម្មអាហារ យើងឃើញថាមានការជឿនលឿនជាងគេទាំងអស់នាសម័យសង្គមរាស្ត្រនិយម។

ក.ម៉ាស៊ីនកិនស្រូវ

ម៉ាស៊ីនកិនស្រូវបានផ្តល់អង្ករ ចុងអង្ករ និងកន្ទក់សម្រាប់ការប្រើប្រាស់នៅក្នុងប្រទេស និងការនាំចេញទៅបរទេស។ ផ្នែកនេះមានវឌ្ឍនភាពយ៉ាងខ្លាំងក្លាចាប់តាំងពីឆ្នាំ ១៩៥១ មកក្នុងគ្រាដែលក្រសួងពាណិជ្ជកម្ម បានអនុញ្ញាតអោយនាំស្រូវចេញទៅបរទេស។ ចំនួនរោងម៉ាស៊ីនកិនស្រូវបានកើនឡើងពី ៤៧ ក្នុងឆ្នាំ ១៩៥១ ដល់ទៅជាង ៧០០ ក្នុងឆ្នាំ ១៩៧០។ រោងម៉ាស៊ីនកិនស្រូវសំខាន់ៗហើយច្រើនជាងគេមាននៅរាជធានីភ្នំពេញ បាត់ដំបង កំពង់ចាម និងព្រៃវែង ។

នៅស្វាយអាត់ (ជិតទីក្រុងពោធិសាត់) មានម៉ាស៊ីនរោងចក្រកិន ស្រូវមួយរបស់រដ្ឋ ដែលជាជំនួយសហប្រតិបត្តិការជប៉ុន។ រោងចក្រនេះស្ថិតនៅត្រង់ចន្លោះផ្លូវរថភ្លើង និងផ្លូវរថយន្ត ពីភ្នំពេញទៅបាត់ដំបង ម៉ាស៊ីនកិនស្រូវម៉ាកជប៉ុន អាចកិនស្រូវបានក្នុងមួយម៉ោងពី ១.២ តោន ទៅ ១.៤ តោន។

ខ. សហគ្រាសបិតស្រា

សហគ្រាសបិតស្រា បានប្រើវត្ថុធាតុដើមដូចជា ពោត ស្ករពាង (ឬទឹកស្ករ) ហើយជាពិសេសចុងអង្ករ ដើម្បីផលិតជាស្រា។ សហគ្រាសបិតស្រាដែលធំជាងគេ គឺមាននៅឬស្សីកែវ (ភ្នំពេញ) ឯកន្លែងសំខាន់ផ្សេងៗទៀត មាននៅក្រុងបាត់ដំបង លលកស (ពោធិសាត់) បាណាម (ព្រៃវែង) កំពង់ត្រាំ (កំពង់ស្ពឺ) ជីហែ និងសួង (កំពង់ចាម)។

គ. រោងចក្រផលិតភេសជ្ជៈ

នៅរាជធានីភ្នំពេញរោងចក្រផលិតភេសជ្ជៈប្រចាំឆ្នាំបានផលិត ក្នុងបរិមាណ ២៤.០០០.០០០ ដប ដែលមានចំណុះ ២៨៤ ម.ល/ដប។

ឃ. រោងចក្រផលិតស្រាបៀ

រោងចក្រស្រាបៀរក្រុមហ៊ុនសុរាគារខ្មែរ នៅទីក្រុងព្រះសីហនុ បានផលិតស្រាបៀរប្រចាំឆ្នាំចំនួន ១០០.០០០ កេស[127] និងកេសជ្ជៈមានឧស្ម័ន និងទឹកកកផង។ ឯរោងចក្រផ្សេងទៀតដែលផលិតកេសជ្ជៈមានឧស្ម័ន (ទឹកក្រូច) ទឹកស៊ីរ៉ូ ទឹកសូដា ទឹកផ្លែឈើដប និងទឹកកក ច្រើនតែផលិតនៅភ្នំពេញ
និងទីរួមខេត្តនានា។ ខេត្តបាត់ដំបងជាតំបន់ ពិសេសដែលផ្តល់ផលិតកេសជ្ជៈមានឧស្ម័នច្រើនជាងខេត្តនានា នៅក្នុងប្រទេសកម្ពុជា ។

ង. ផលិតកម្មអំបិល

នៅខេត្តកំពតមានផ្ទៃដីសម្រាប់ធ្វើស្រែអំបិលប្រមាណ ៥.០០០ ហិកតា ដែលផលិតអំបិលបានចំនួន ៥.០០០ តោនក្នុងមួយឆ្នាំៗ ដែល អាចបំពេញសេចក្តីត្រូវការក្នុងប្រទេសបានគ្រប់គ្រាន់ ។

ច. រោងចក្រចម្រាញ់ស្ករ

រោងចក្រចម្រាញ់ស្ករ ត្រូវបានចែកចេញជាពីរសណ្ឋានដោយរោងចក្រម្យ៉ាងជារោងចក្រតូចៗដែលមាននៅគ្រប់តំបន់ដែលផលិតស្ករត្នោត។ រោងចក្រនេះ ចម្រាញ់ស្ករពាងអោយទៅជាស្ករដើមមួយប្រភេទ ដែលគេពុំសូវបរិភោគផ្ទាល់ទេ ដោយគេច្រើនយកស្ករដើមនេះទៅដាក់ផ្សំក្នុងគ្រឿងបរិភោគខ្លះដែលត្រូវការជាតិផ្អែម ដូចជាទឹកស៊ីអ៊ីវ សៀង។ល។ ឬប្រើសម្រាប់បិតស្រា ឯរោងចក្រឧស្សាហកម្មផលិតស្ករសសម្រាប់បិរភោគផ្ទាល់ ឬធ្វើនំចំណី។ យើងមានរោងចក្រប្រភេទនេះពីរកន្លែង គឺនៅកំពង់ត្រាំ (កំពង់ស្ពឺ) និងកំពង់គល់(បាត់ដំបង) ដែលអាចផលិតស្ករសបានជាង ១៣.០០០ តោន ក្នុងមួយ
ឆ្នាំៗ[128] ។

ឆ. រោងចក្រឧស្សាហកម្មអាហារផ្សេងទៀត

នៅសម័យនោះមានរោងចក្រឧស្សាហកម្ម ដែលផលិតប្រេងសណ្តែកដី ប្រេងកន្ទក ទឹកត្រី ទឹកស៊ីអ៊ីវ សៀង គ្រឿងបរិភោគកំប៉ុង ត្រីខប្រអប់។ល។ រោងចក្រទាំងនោះច្រើនតែនៅទីក្រុងភ្នំពេញ។ រីឯខេត្តកោះកុងក៏មានរោងចក្រផលិតត្រីខប្រអប់ ម្សៅត្រី និងទឹកកកដែលផលិតប្រចាំឆ្នាំ ក្នុងនោះ ត្រីខប្រអប់ផលិតបាន ៥០០ តោន ម្សៅត្រីផលិតបាន ១.០០០ តោន និងទឹកកក ១.៥០០ តោន។

❖ ឧស្សាហកម្មវាយនភ័ណ្ឌ

តាំងពីបូរាណមក ប្រជាជនខ្មែរយើងត្បាញសំពត់អំបោះ និងសំពតសូត្រសម្រាប់ប្រើប្រាស់ជាតម្រូវការរៀងៗខ្លួន។ នៅសម័យនោះ ប្រជាជនខ្មែរបានបោះបង់ចោលសកម្មភាពនោះស្ទើរតែអស់ទៅហើយ ដោយគេនិយមទិញក្រណាត់ដែលបានផលិតចេញពីរោងចក្រមកប្រើប្រាស់ជំនួសវិញ។

សិប្បកម្មសំឡីកប្បាសផ្តល់កាងារដល់ប្រជាពលរដ្ឋខ្មែរជាច្រើនតំបន់។ គេធ្វើអំបោះត្បាញ ធ្វើក្រមា មុង ភួយ។ល។ ដែលជាតម្បាញប្រើកីត្បាញដោយដៃ។

សម័យនោះ យើងមានរោងចក្រវាយនភ័ណ្ឌរបស់រដ្ឋពីរ មួយនៅ កំពង់ចាម មួយទៀតនៅបាត់ដំបង។ ក្នុងឆ្នាំ ១៩៦៨ រោងចក្រទាំងពីរ ផលិតអំបោះត្បាញបាន ១.១៥៥ តោន និងក្រណាត់សំពត់ជាង ៩៥លានម៉ែត។[129] រោងចក្រតម្បាញតូចៗខ្លះទៀត ដូចជារោងចក្រដីបតុង សេងថៃ (នៅ

ភ្នំពេញ និងនៅតាមខេត្តខ្លះទៀត) បានទិញអំបោះត្បាញ យកមកត្បាញជាក្រណាត់សំពត់សាច់លាត ឬមានផ្កា ដូចជា សារុងពុម្ព ជាដើម ។

នៅបាត់ដំបងរដ្ឋយើងបានបង្កើតរោងចក្រក្រចៅមួយនៅដូនទាវ ដែលអាចផលិតបាវក្រចៅ ចំនួន ៤លានបាវ ក្នុងមួយឆ្នាំ និងរោងចក្រផ្តេចកប្បាសមួយនៅ អណ្តើកហែប ដែលផលិតសំឡី កប្បាសបាន ចំនួន ២.០០០ តោនក្នុងមួយឆ្នាំ។

នៅសម័យសង្គមរាស្ត្រនិយម ប្រជាជនខ្មែរនិយមប្រើប្រាស់ សំពត់សូត្រសម្រាប់ពិធីនានាដែរ។ ក្នុងឆ្នាំ ១៩៦៩ មានសិប្បករតម្បាញសូត្រចំនួនជាង ២០០នាក់ និងរោងតម្បាញចំនួន១៣ ដោយមានកីយន្តចំនួន ២៧០។ សសៃសូត្របានមកពីផលិតផលក្នុងស្រុកប្រហែលជាង ២០ តោន និងការនាំចូលពីបរទេសចំនួន ពី ៥០ ទៅ ៩០តោន ត្រូវបានសិប្បករខ្មែរយើងត្បាញធ្វើជាសារុង ហូល ផាមួង។ ឯរោងជាងតម្បាញ ដោយគ្រឿងយន្តច្រើនធ្វើសំពត់ព្រៃ។ ផលិតផលសរុបនៃសំពត់សូត្រ មានប្រហែល ១លានម៉ែត។

❖ រោងចក្រផលិតក្រដាសនៅឆ្លូង

នៅសម័យសង្គមរាស្ត្រនិមយើងមានរោងចក្រផលិតក្រដាសនៅឆ្លូង ដែលមានលទ្ធភាពអាចផលិតប្រភេទក្រដាសប្រើប្រាស់ដូចជា ក្រដាសសរសេរ ក្រដាសសបិទប្រកាស ក្រដាសផ្តិត ក្រដាសកាតុង ក្រដាស Duplex ក្រដាសស្តើង ក្រដាសសំណៅ ក្រដាសវេចខ្ចប់ ក្រដាស offset ក្រដាសក្របសៀវភៅ ដែលការផលិតក្រដាសប្រចាំឆ្នាំគ្រប់មុខមានចំនួន ៤.៣២០តោន នាឆ្នាំ១៩៦៦។

❖ ឧស្សាហកម្មគ្រឿងយន្ត

ចំពោះឧស្សាហកម្មគ្រឿងយន្តនេះ ពុំទាន់មានការលូតលាស់ នៅឡើយទេ ហើយយើងនៅមានកង្វះខាតច្រើន។ ប្រទេសខ្មែរជានិច្ចកាល គឺតែងតែធ្វើការជាវទិញគ្រឿងយន្តពីបរទេសមកប្រើប្រាស់ ទោះបីជាខ្មែរយើងចេះរំលាយដែកតាំងពីយូរយារណាស់មកហើយក៏ដោយ។ នៅខេត្តកំពង់ធំ មានតែពួកកួយទេ ដែលប៉ិនប្រសព្វខាងជីកយករ៉ែដែក មករំលាយតាមមធ្យោបាយខ្សត់ខ្សោយរបស់ខ្លួន។ នៅត្រាំខ្នារ (តាកែវ) និងឧដុង្គ គេរំលាយទង់ដែងដើម្បីធ្វើផ្ទាំង ផ្តិល ឬគ្រឿងសិល្បៈ។

ក. រោងចក្រដំឡើងត្រាក់ទ័រ និងរថយន្តដឹកទំនិញ

នៅសម័យសង្គមរាស្ត្រនិយម រោងចក្រតម្លើងគ្រឿងយន្ត មានទីតាំងនៅក្រុងកំពង់សោម ហើយកាន់កាប់ដោយក្រុមហ៊ុនជាតិ តម្លើងត្រាក់ទ័រ និងរថយន្តឈ្មោះថា SONATRAC ។ រោងចក្រនេះតម្លើងបានត្រាក់ទ័រចំនួន ៣០០ គ្រឿង មានម៉ាក់ សេទ័រ (Zétor) និង ម៉ូឡូតូវ (Molotov) និងរថយន្តដឹកទំនិញ ៤០០គ្រឿង ទាំងតូចទាំងធំម៉ាក ប៊ែល្យ សាវៀម (Berliet Saviem) រថយន្តដែលតម្លើងហើយមានម៉ាកអង្គរ។

❖ រោងជាងកងយោធាខេមរជាតិ

នៅសម័យនោះ ប្រទេសកម្ពុជាយើង បានស្ថាបនារោងជាងសម្រាប់ជួសជុលគ្រឿងសព្វាវុធ ជួសជុលគ្រឿងម៉ាស៊ីនទូទៅ និងធ្វើសម្ភារៈកីឡាដែលមានទីតាំងផ្សេងៗគ្នា ហើយការគ្រប់គ្រងអង្គភាពទាំងនោះ ដោយកងយោធាខេមរជាតិ ដែលមានដូចខាងក្រោមនេះ ៖

- រោងជាងនៅបន្ទាយលង្វែក មានតួនាទីសម្រាប់រំលាយដែកធ្វើជាដែកគោល និងគ្រឿងបន្លាស់ ដើម្បីយកទៅប្រើប្រាស់ក្នុងការជួសជុល ម៉ាស៊ីននានា និងសម្រាប់ធ្វើគ្រឿងម៉ាស៊ីនខ្លះៗ [131]
- រោងជាងសម្រាប់ជួសជុលម៉ាស៊ីនមាននៅចោមចៅ
- រោងចក្រតូចៗផលិតថ្មពិលមាននៅអង្គស្នួល និងចាក់អង្រែ
- រោងជាងជួសជុលគ្រឿងសព្វាវុធ
- រោងជាងធ្វើម៉ាស៊ីនទូទៅ
- រោងចក្រផលិតរថយន្តហ្ស៊ីប
- និងរោងជាងធ្វើសម្ភារៈកីឡានៅគិរីរម្យ។

❖ រោងចក្រផលិតថ្មពិល

នៅសម័យនោះ ចំពោះផលិតផលឧស្សាហកម្មថ្មពិលយើងមាន រោងចក្រផលិតថ្មពិលនៅចាក់អង្រែ ដែលមានសមត្ថភាពអាចផលិតថ្មពិលប្រចាំឆ្នាំប្រភេទ UMI បានចំនួន ១.៦៥០.០០០ឡូ។

❖ សហគ្រាសស្វ័យរិន

សហគ្រាសស្វ័យរិននៅចាក់អង្រែអាចផលិតដែកគោល ខ្សែលួសបន្លា និងខ្សែនីឡុង ដែលសមត្ថភាពផលិតប្រចាំឆ្នាំមានដូចខាង ក្រោមនេះ ៖

| ផលិតផលប្រចាំឆ្នាំ | គិតជាគីឡូក្រាម |
|---|---|
| **ផលិតផលដែកគោល** | ៣.៦០០.០០០ |
| **ផលិតផលខ្សែលួសបន្លា** | ៩០០.០០០ |
| **ផលិតផលខ្សែនីឡុង** | ៨០.០០០ |

*ប្រភេទ និងបរិមាណផលិតផលទំនិញឧស្សាហកម្ម (គិតក្នុងមួយឆ្នាំ)*

❖ រោងជាងផ្នែកកិច្ចការបច្ចេកទេស

នៅសម័យនោះសម្បូរទៅដោយរោងជាងជួសជុលរថយន្ត និង គ្រឿងអគ្គិសនី រោងជាងផលិតគ្រឿងប្រដាប់ផ្ទះបាយ ផលិតវត្ថុផ្សេងៗ ពីដែក រោងចក្រផលិតយានយន្តកង់បី ទោចក្រយាន និងម៉ូតូជាដើម។ [132] នៅតាមច្រាំងទន្លេវិញ គេឃើញមានការរដ្ឋានសំណង់ និងរោងជាង ជួសជុលកាណូត និងកប៉ាល់តូចៗ។

❖ ឧស្សាហកម្មគីមី

សម័យនោះឧស្សាហកម្មគីមី ទើបតែមានការរីកលូតលាស់នៅឡើយ ហើយប្រើប្រាស់វត្ថុធាតុដើម ដែលនាំចូលពីបរទេស ដោយភាគច្រើនមានដូចជា៖

- ឱសថខ្លះត្រូវបានផ្សំ និង ទិញយកមកច្រកដប បំពង់ ប្រអប់ ឬអំពូល សម្រាប់លាប សម្រាប់លាប ឬចាក់ តាមតម្រូវការក្នុងស្រុក។ មានអង្គការ និងសហគ្រាសមួយចំនួន បានទទួលភារៈធ្វើកិច្ចការនេះទាំងស្រុងដូចជា សហគ្រាសជាតិខាងផលិតឱសថ។
- រោងចក្ររដ្ឋចម្រាញ់ប្រេងកាត នៅក្រុងព្រះសីហនុ បានផលិតប្រេងកាត ដែលបានបំពេញមុខងារខ្លះ ព្រមទាំងអាចប្រើប្រាស់បានជិតគ្រប់គ្រាន់ក្នុងប្រទេស។

- រោងចក្រស៊ីម៉ងត៍របស់រដ្ឋ នៅចក្រីទីង (កំពត) ផលិតស៊ីម៉ងត៍ ប្រកបទៅដោយគុណភាពខ្ពស់ និងប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ផលិតបានចំនួន ៧០.០០០ តោនក្នុងមួយឆ្នាំ។
- រោងចក្រជីផូស្វាតនៅទូកមាស (កំពត) ផលិតជីផូស្វាតបាន ចំនួន ៣.៥៨០ តោន ក្នុងឆ្នាំ ១៩៦៧ និង ៤.៥០០ តោន ក្នុងឆ្នាំ១៩៦៨។
- រោងចក្រកែវនៅជើងឯក ស្រុកដង្កោ (កណ្តាល) បានផលិតនូវផលិតផលកែវគ្រប់ប្រភេទ ចំនួន ២.៦៨០.០០០ ក្នុងឆ្នាំ ១៩៦៨ និងផលិតដបបានចំនួន ៦.៥៤៣.៥០០ ក្នុងមួយឆ្នាំៗ។
- ក្រៅពីរោងចក្រកែវនៅជើងឯកយើងមានរោងចក្រឯកជនផ្សេងទៀត ដែលបានផលិតនៅផលិតផល ប្រភេទខាងលើនេះដូចជាផលិត កែវ ចូផ្កា ផើងផ្កា និងចានស៊ីរ៉ាមីក ក្នុងបរិមាណយ៉ាងច្រើនប្រកបដោយក្បាច់រចនាយ៉ាងប្រណិត ដែលជាទីគាប់ចិត្តរបស់អតិថិជន។
- រោងចក្រស្លកៅស៊ូរដ្ឋ និងឯកជនខ្លះទៀត មានតាំងនៅចំការកៅស៊ូធំៗ ដូចជារោងចក្រកៅស៊ូក្រែប នៅក្នុងចំការកៅស៊ូជប់ (កំពង់ចាម)។ ជារៀងរាល់ឆ្នាំ គេលក់ផលិតផលកៅស៊ូក្រែបមួយចំនួន ទៅអោយសហគ្រាសនៅក្នុងប្រទេស ជាពិសេសសហគ្រាសតូចៗ ចំនួនជាង ២០ ដែលផលិតស្បែកជើង កំណាត់កៅស៊ូសម្រាប់ធ្វើពួក។ល។ គេលក់ ផលិតផលភាគច្រើនទៅបរទេស។ រោងចក្រស្លកៅស៊ូទាំងនោះ ផលិតចេញជាបន្ទះកៅស៊ូផ្អើរ (Feuilles Fumées) ជាកៅស៊ូចិញ្ច្រាំ (Granules) និងជាជ័រកៅស៊ូហួតទឹក (Latex centrifuge)។
- រោងចក្រកៅស៊ូកង់ឡាន កង់ទោចក្រយានយន្ត ស្ពតទៃ (រោងចក្រស្ទឹសង្កម គីម ឆៃហាង) ផលិតសំបកទោចក្រយាន (កង់) បានផលិតនៅតាខ្មៅ (កណ្តាល) និងនៅទីក្រុងភ្នំពេញ ក្បែរគល់ស្ពានជ្រោយចង្វារ។
- ក្រៅពីនោះ មានសហគ្រាសឧស្សាហកម្មគីមីមួយចំនួនទៀតដូចជា កៅស៊ូកម្មន្តសាល ស្បែកជើងផ្ទាត់ សហគ្រាសធ្វើសាប៊ូ ទៀន ដែលយកវត្ថុធាតុដើមពីប្រេងសណ្តែកដី ប្រេងដូងខ្លាញ់គោ។ល។ សហគ្រាសសម្លាប់ស្បែក ធ្វើប្រដាប់ប្រដាពីប្លាស្ទិច កម្មន្តសាលធ្វើបារី រោងចក្រធ្វើឈើគូស ។

❖ ឧស្សាហកម្មឈើ

នៅសម័យនោះ ម៉ាស៊ីនអារឈើមានចំនួនជាង ២០០ និងកន្លែងអារឈើដោយដៃជាច្រើនទៀតដែលបានផលិតឈើអារ សម្រាប់លក់ក្នុងស្រុក និងនាំចេញទៅបរទេស។ ម៉ាស៊ីនអារឈើធំៗមាននៅក្រុងភ្នំពេញ និងខេត្តបាត់ដំបង។ រីឯម៉ាស៊ីនអារឈើ ៦កន្លែងទៀត នៅភ្នំពេញដែលលក់ឈើទៅបរទេស អាចអារឈើក្នុងមួយថ្ងៃបានពី ២០ ទៅ ៦០ ម$^{៣}$ ។

រោងចក្រអារឈើរបស់រដ្ឋ ២កន្លែងផ្សេងទៀត បានផលិតឈើយ៉ាងច្រើន គឺរោងចក្រអារឈើនៅ បល្ល័ង្គ (កំពង់ធំ) និងនៅត្រពាំង ក្រឡឹង (កំពង់ស្ពឺ)។ រោងចក្រ បល្ល័ង្គ ផលិតបានឈើអារ១០០ ម$^{៣}$ ក្នុង១ខែ។

រោងចក្រក្ដារបន្ទះរបស់រដ្ឋនៅជីឥដ្ឋ (កណ្ដាល) ដែលផលិតក្ដារបន្ទះសម្រាប់លក់ក្នុងប្រទេស បានផលិតក្ដារបន្ទះក្នុងឆ្នាំ ១៩៦៨ ចំនួន៨៤៧.០០០ ម២ និងនៅឆ្នាំ ១៩៦៩ ផលិតបាន ៩០០.០០០ ម២ ។

❖ ឧស្សាហកម្មផ្សេងៗទៀត

ក្រៅពីឧស្សាហកម្មខាងលើនេះ គេឃើញមានឧស្សាហកម្មសំខាន់ៗខ្លះទៀតដូចជា ៖

- ឡកំបោរមានជាង ៥០កន្លែង ដែលមានទីតាំងនៅខេត្តកំពត និងបាត់ដំបង ដែលគេដុតថ្មកំបោរអោយទៅជាកំបោរ ផលិតបានប្រហែលពី ៥ ទៅ ៦ ពាន់តោន ក្នុងមួយឆ្នាំ។
- ឡឥដ្ឋធំៗ និងក្បឿង មានចំនួន ១៤០កន្លែង ធ្វើឥដ្ឋតាន់ និងឥដ្ឋប្រហោងបាន ១២៥ លានដុំ។ ឡឥដ្ឋទាំងនោះភាគច្រើនមានទីតាំង នៅក្នុងខេត្តកណ្ដាល កំពង់ចាម ពោធិសាត់ បាត់ដំបង។ រោងជាងខ្លះផលិតឥដ្ឋពណ៌ ក្បឿង និងឥដ្ឋធម្មតាធ្វើពីស៊ីម៉ង់ត៍។

❖ វិស័យសិប្បកម្ម

នៅសម័យសង្គមរាស្ត្រនិយម វិស័យសិប្បកម្ម គឺជាសកម្មភាពចាំបាច់មួយរបស់ប្រជាជនខ្មែរយើង តាំងពីច្រើនសតវត្សមកម្ល៉េះ ហើយគេតែងតែនិយមរាប់អានសរសើរស្នាដៃសិល្បៈ ដែលបានផលិតចេញពីវិស័យសិប្បកម្មនេះណាស់។

កសិករខ្មែរច្រើនតែធ្វើរបស់ប្រើប្រាស់រៀងៗខ្លួន សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារដូចជា ចេះសង់ផ្ទះ ឆ្លាក់ឈើ ត្បាញឫស្សី ផ្ដៅ ធ្វើជាប្រដាប់ប្រើប្រាស់ ឬតុបតែងគេហដ្ឋាន។ អ្នកខ្លះទៀតចេះធ្វើក្អម ឆ្នាំង ឪទិន ជើងក្រាន ដូចជានៅខេត្តកំពង់ឆ្នាំង។ បន្ទាប់មកខេត្តកណ្ដាល តាកែវ សិប្បករប្រហែល ២.០០០នាក់ មានមុខរបរធ្វើក្អម ឆ្នាំង ជើងក្រាន ។ល។ ហើយបាននាំយកទៅលក់នៅពាសពេញប្រទេស ដោយរទេះគោ និងទូក។ គេអាចចាត់ទុកខេត្តសៀមរាប ជាតំបន់ល្បីល្បាញខាងការឆ្លាក់ ឬដាប់លើស្បែក ធ្វើជារូបតុបតែងផ្ទះ របាំងចង្កៀង ។ល។ រូបស្បែកដាប់នេះ មានសមត្ថភាពរហូតដល់ទៅបង្កើតជាសិល្បៈណាំង ដែលជា សិល្បៈកំរមួយក្នុពិភពលោក។

សិប្បកម្មប្រពៃណីមួយទៀត ដែលគេឃើញមាននៅពាសពេញទេ គឺការត្បាញកន្ទេលកក់ ស្លឹករំចេក ស្លឹកត្នោត ស្លឹកចាក ឬផ្ដៅ ។ល។ ធ្វើខ្សែជក់ដូង ជក់ត្នោត ក្រចៅ ឬធ្វើជាសំណាញ់សម្រាប់ការនេសាទ។

ក្រៅពីសិប្បកម្មទាំងនោះ គេឃើញមានសិប្បកម្មកែច្នៃត្បូង មានរចនាម៉ូតគ្រប់បែបយ៉ាងនៅតំបន់ប៉ៃលិន (ខេត្តបាត់ដំបង) និងបរកែវ (ខេត្តរតនៈគីរី)។ សកម្មភាពនេះ អាចផ្ដល់ជារូបិយប័ណ្ណយ៉ាងច្រើន ដល់ប្រទេសខ្មែរ ប្រសិនបើយើងធ្វើពាណិជ្ជកម្មអោយបានម៉ត់ចត់។

យើងគួរអោយតម្លៃទៅលើសិប្បកម្មម្យ៉ាង ដែលសិល្បៈករជាច្រើននិយមចូលចិត្តប្រើប្រាស់ជាគ្រឿងសម្អាង គឺផលិតផលសិប្បកម្មដែលឆ្លាក់ ឬច្នៃពីមាស ប្រាក់ ស្ពាន់ ទង់ដែង សំរិទ្ធិ ដែលមិនគ្រាន់តែជាផលិតផលអាចទាក់ទាញចិត្តភ្ញៀវទេសចរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើអោយប្រជាជនខ្មែរយើងគ្រប់ស្រទាប់វណ្ណៈ បានពេញចិត្តគ្រប់ៗគ្នាទៀតផង។

សិប្បកម្មធ្វើ តុ ទូ មានទីតាំងនៅគ្រប់ខេត្ត ជាពិសេសនៅភ្នំពេញ ក្រចេះ បាត់ដំបង ដែលបានផលិតគ្រឿងសង្ហារឹម ឬគ្រឿងតុបតែងលម្អ នៅក្នុងគេហដ្ឋាន និងរបស់របរប្រើប្រាស់ធម្មតា។

សិប្បកម្មគ្រឿងប្រដាប់ប្រដាធ្វើអំពីផ្ដៅ ក៏មានសភាពលូតលាស់ជានិច្ច ព្រោះសម្ភារៈធ្វើពីផ្ដៅមានរាងសម ហើយជារបស់ស្រាលងាយស្រួលប្រើប្រាស់ និងងាយធ្វើការបំលាស់ទី។ នៅកន្លែងខ្លះទៀតក៏មានរោងជាងធ្វើ ទូកអំពីឈើ តូច ធំ និងធ្វើចន្លុះ។

## ៦.៣.៤ វិស័យសេវាកម្ម

❖ គមនាគមន៍ និងការដឹកជញ្ជូន

សម្តេចនរោត្តមសីហនុ ទ្រង់បានដឹកនាំប្រជាពលរដ្ឋដោយផ្ទាល់អោយធ្វើការងារហត្ថកម្មរួមគ្នាទាំងការកសាងផ្លូវថ្នល់ ផ្លូវរថភ្លើង និងការស្ថានាហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗទៀត។ ដូចជានៅឆ្នាំ ១៩៥៤ មានការពង្រីកកំពង់ផែភ្នំពេញ និង ការកសាងកំពង់ផែសមុទ្រ នៅក្រុងព្រះសីហនុ ដើម្បីធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ហើយកំពង់ផែ នេះ ត្រូវបានពង្រីកថែមទៀតនៅឆ្នាំ ១៩៦៤។

នៅឆ្នាំ ១៩៥៦ មានការកសាងផ្លូវជាតិលេខ ៤ ដែលតភ្ជាប់ពីទីក្រុងភ្នំពេញទៅក្រុងព្រះសីហនុមានប្រវែង ២២៦ គ.ម ហើយអាកាសយានដ្ឋានពោធិចិនតុង ក៏បានពង្រីកអោយក្លាយទៅជាអាកាសយាន ដ្ឋានអន្តរជាតិ ដែលមានប្រវែងផ្លូវប្រមាណ ២៤០០ ម៉ែត្រ និងទីលានសម្រាប់យន្តហោះចុះចតទំហំ ១២០មx១១០ម ។ អាកាសយានដ្ឋាននេះ បានបើកអោយប្រើប្រាស់នៅក្នុងឆ្នាំ ១៩៥៨។ នៅឆ្នាំ ១៩៥៩ មានការកសាងអាកាសយានដ្ឋានខ្នាតអន្តរជាតិមួយទៀត សម្រាប់ពង្រីកវិស័យទេសចរណ៍នៅខេត្តសៀមរាប។

នៅឆ្នាំ ១៩៦០ មានការស្ថាបនាផ្លូវរថភ្លើងមួយខ្សែតភ្ជាប់ពីទីក្រុងភ្នំពេញ ទៅទីក្រុងព្រះសីហនុដែលមានប្រវែង ២៧០គ.ម ហើយនៅឆ្នាំនោះដែរ ក៏មានការកសាងស្ពានដ៏ទំនើបមួយឆ្លងកាត់ទន្លេសាប គឺស្ពានជ្រោយចង្វារ។

នៅឆ្នាំ១៩៦១ ព្រះរាជាណាចក្រកម្ពុជា បានពង្រីកទំនាក់ទំនងជាអន្តរជាតិដោយភ្ជាប់ខ្សែទូរស័ព្ទជាមួយក្រុងតូក្យូ និងសង់ហ្វ្រង់ស៊ីស្កូ។

ក. វិស័យគមនាគមន៍ផ្លូវទឹក

បើគេក្រឡេកមើលផែនទីប្រទេសកម្ពុជា គេនឹងយល់ភ្លាមថា សណ្ឋានដីនេះបានសម្រួលដល់បណ្តាញផ្លូវទឹក សម្រាប់ការទាក់ទងគ្នាបានគ្រប់ទីកន្លែង។ នៅផ្នែកកណ្តាលនៃផ្ទៃប្រទេស មានទន្លេសាប និងទន្លេមេគង្គ ដែលមានដៃទន្លេជាច្រើនបានកាត់ផ្ទៃដីប្រទេស រហូតដល់ទីជនបទដាច់ស្រយាល។

កន្លែងណាមានទឹកទៅដល់ជាអចិន្ត្រៃយ៍ កន្លែងនោះ បានហុចផលប្រយោជន៍ច្រើនយ៉ាង។ ផ្លូវទឹកដែលធំជាងគេ គឺទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ។

- ទន្លេមេគង្គ គេអាចធ្វើចរាចរណ៍បានគ្រប់រដូវកាល តាំងពីខេត្តក្រចេះរហូតដល់សមុទ្រ។ ពីភ្នំពេញទៅក្រចេះ ទូកតូចធំ កប៉ាល់តូច និងកាណូតអាចទៅមកបាន។ រីឯកប៉ាល់សមុទ្រ អាចឡើងមកបានត្រឹម តែកំពង់ផែភ្នំពេញប៉ុណ្ណោះ ហើយបានចំពោះតែកប៉ាល់មានជម្រៅបាតតិចជាង ៤.៥ ម។ នាវាសមុទ្រ ដែលចេញចូលមកកាន់រាជធានី ដឹកនាំទំនិញគ្រប់យ៉ាង។ ឯទូកឬនាវា បើកបរតាមផ្លូវទឹកនានាទៀត ច្រើនតែដឹកត្រីឆ្អើរ ត្រីងៀត ស្រូវ ឈើសំណង់ ពោត ថ្នាំជក់ ។ល។

- ទន្លេសាប និងទន្លេបាសាក់ ផ្លូវទឹកទាំងពីរនេះគេអាចអោយធ្វើចរាចរណ៍បានរហូតដល់បឹងទន្លេសាប។ ពេលទឹកស្រក ការធ្វើទំនាក់ ទំនងរវាងភ្នំពេញ និងបឹងទន្លេសាប ពុំអាចប្រព្រឹត្តទៅបានទេ ពីព្រោះទឹកដៃ ទន្លេសាប នៅតំបន់ច្រកផ្នុកទ្រូមានជម្រៅរាក់ពេក។
- ដៃទន្លេ គេអាចធ្វើចរាចរណ៍បានខ្លះ តាមដៃទន្លេសាប នៅពេលទឹកឡើង។ ឯតាមដៃទន្លេមេគង្គវិញ ការធ្វើចរាចរណ៍ពុំអាចប្រព្រឹត្តទៅបានឡើយ ពីព្រោះដៃទន្លេទាំងនោះមានទឹកហូរខ្លាំងពេកពិបាកនឹងធ្វើដំណើរ។ ក៏ប៉ុន្តែដៃទន្លេទាំងនោះមានប្រយោជន៍ណាស់ដែរ ព្រោះគេប្រើប្រាស់សម្រាប់បណ្តែតក្បូនឬស្សីមកកាន់តំបន់ពាណិជ្ជកម្ម។
- តាមស្ទឹង ព្រៃវែង និង តាកែវ គេអាចធ្វើចរាចរណ៍បាន លុះត្រាតែគេកៀរសម្អាតបាតស្ទឹងអោយបានញឹកញាប់ ។

ខ. បណ្តាញផ្លូវថ្នល់

ផ្លូវថ្នល់សម័យនោះពុំសូវស្អាតទេ។ នៅរដូវទឹកជំនន់ម្តងៗ ផ្លូវស្រុតសឹងតែគ្រប់ទីកន្លែង ជាហេតុតម្រូវអោយមានការជួសជុលជារៀងរាល់ឆ្នាំ។ ផ្លូវស្រុត ផ្លូវខ្ទងអណ្តើក ផ្លូវចង្អៀត ឬស្ពានតូច និងទ្រុឌទ្រោម សុទ្ធតែជារបស់ដែលត្រូវជួសជុលអោយបានល្អឡើងវិញ ដើម្បីតម្រូវអោយសមស្រមតាមការប្រើប្រាស់ក្នុងការធ្វើចរាចរណ៍។ ផ្លូវពីភ្នំពេញ ទៅក្រុងព្រះសីហនុ កាត់តាមកំពង់ស្ពឺ និងផ្លូវពីភ្នំពេញទៅកំពតកាត់តាមអង្គតាសោម មានសភាពល្អជាង ផ្លូវដទៃទៀតច្រើន។

- ផ្លូវថ្នល់សម្ខាន់ៗ មានបណ្តាញផ្លូវថ្នល់នៅតំបន់ទំនាបកណ្តាល ដែលមានការលូតលាស់ជាងគេ។ ផ្លូវទាំងនោះចែកជា ផ្លូវជាតិប្រវែង ២.៨០០ គ.ម ផ្លូវខេត្តប្រវែង ១.២០០ គ.ម និងផ្លូវរុក្ខបាលប្រវែង ២.០០០ គ.ម គ្រាន់តែក្រាលថ្ម ឬដីក្រហម។ ឯផ្លូវផ្សេងពីនេះ ច្រើនជាផ្លូវលំ និង ផ្លូវដីលើក។

គួរបញ្ជាក់ថា ជាការពិតក្នុងប្រវត្តិសាស្ត្រ ហើយដែលយើងមិន អាចប្រកែកបាន ដែលជាសមិទ្ធិរបស់សម័យសង្គមរាស្ត្រនិយមនោះ គឺទាក់ទងទៅនឹងការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបន្តែផ្លូវ ក្នុងចំនួនច្រើន ដែលនៅសម័យបារាំងមិនបានធ្វើឡើយ។ ទិន្និន័យដែលបានអះអាង ទៅលើពត៌មានខាងលើនេះ មានបញ្ជាក់ដូចខាងក្រោមនេះ ៖ [133]

- ការស្ថាបនាផ្លូវរថភ្លើង មានប្រវែង ៣៨៦ គ.ម នៅឆ្នាំ ១៩៥៥ និងមានប្រវែងសរុប ៦៦៥ គ.ម នៅឆ្នាំ ១៩៦៨
- ផ្លូវក្រាលកៅស៊ូ មានប្រវែង ១.៦០០គ.ម នៅឆ្នាំ ១៩៥៥ និង មានប្រវែង ២.៦០០ គ.ម នៅឆ្នាំ ១៩៦៨
- ផ្លូវក្រាលថ្ម មានប្រវែង ១.៦០៣ គ.ម នៅឆ្នាំ ១៩៥៥ និងមានប្រវែង២.១៤៥ គ.ម នៅឆ្នាំ ១៩៦៨
- ផ្លូវដីលើក មានប្រវែង 0 គ.ម នៅឆ្នាំ ១៩៥៥ និងមានប្រវែង ១.៣៥២ គ.ម នៅឆ្នាំ ១៩៦៨
- ផ្លូវលំដែលអាចបើកបររថយន្តបាន មានប្រវែង ១.០៦០ គ.ម នៅឆ្នាំ ១៩៥៥ និងមានប្រវែង ១០.៨២៦ គ.ម នៅឆ្នាំ ១៩៦៨

ប្រវែងទាំងអស់នៃផ្លូវថ្នល់ និងផ្លូវលំដែលអាចបើកបររថយន្តបាន មានប្រវែង ៤.៨០៥ គ.ម នៅឆ្នាំ ១៩៥៥ និងមានប្រវែង ១៦.៣៨១ គ.ម នៅឆ្នាំ ១៩៦៨

- ស្ពានឈើ មានប្រវែង ១.១០០ ម នៅឆ្នាំ ១៩៥៥ និងមានប្រវែង ១.៨៥៨ ម នៅឆ្នាំ ១៩៦៨
- ស្ពានបេតុង មានប្រវែង ៨៧៥ ម នៅឆ្នាំ ១៩៥៥ និងមានប្រវែង ១.០០៥ ម នៅឆ្នាំ ១៩៦៨
- ស្ពានដែក មានប្រវែង ១២០ ម នៅឆ្នាំ ១៩៥៥ និងមានប្រវែង១៦៥ ម នៅឆ្នាំ ១៩៦៨។

គ. ទិន្នន័យចំនួនរថយន្តគ្រប់ប្រភេទ

នៅសម័យសង្គមរាស្ត្រនិយម ចំនួនរថយន្តគ្រប់ប្រភេទបានកើនច្រើនឡើងៗ ក្នុងនោះរថយន្តដឹកទំនិញ រថយន្តទេសចរណ៍ និងទោចក្រយានយន្តធុនតូច បានកើនឡើងខ្លាំងជាងគេ។ ខាងក្រោមនេះ គឺជាទិន្នន័យ ចំនួនរថយន្តគ្រប់ប្រភេទ ពីឆ្នាំ ១៩៦៣ ដល់ឆ្នាំ ១៩៦៨។

| បរិយាយ | ១៩៦៣ | ១៩៦៥ | ១៩៦៦ | ១៩៦៧ | ១៩៦៨ |
|---|---|---|---|---|---|
| រថយន្តទេសចរណ៍ | ១៥.២៦០ | ១៨.០៥៧ | ១៩.៣៣០ | ២១.៦៨៥ | ២៣.៧៧០ |
| រថយន្តដឹកទំនិញតូច និងធំ | ៧.៦២៧ | ៨.៥១៩ | ៨.៨៥៥ | ៩.១២៨ | ៩.៤០២ |
| រថយន្តដឹកមនុស្សតូច និងធំ | ១.២៩៤ | ១.៣២២ | ១.៣៣២ | ១.៣៤៣ | ១.៣៥៣ |
| ទោចក្រក្រយានយន្ត និងស្កុតទែ | ១០.៨៦៤ | ១១.៦៩១ | ១១.៨៦៣ | ១២.៣២០ | ១៤.៩១៥ |
| ត្រីចក្រយានយន្ត | ១.០៣០ | ១.៨២៣ | ២.០១២ | ២.១០៣ | ២.១១៧ |
| ទោចក្រយានផុនតូច | ៣៨.៣៧៣ | ៥១.៦៨៤ | ៦០.៧៦១ | ៦៤.៥៦៦ | ៧៨.៦២៥ |

*តារាងទិន្នន័យរថយន្តគ្រប់ប្រភេទឆ្នាំ ១៩៦៣ ដល់ ១៩៦៨*

[133] ទស្សនាវដ្តីត្រីមត្រូវបារាំងមួយឈ្មោះ អឺរ៉ុប-ហ្វ្រង្ស-អ៊ូត្រមើរ លេខ ៤៦៥ ខែតុលា ១៩៦៨ ទំព័រ៩៤

ឃ. ផ្លូវអយស្ម័យយាន

ប្រទេសខ្មែរយើងមានផ្លូវដែកតិចណាស់ ពោលគឺមានចំនួនតែ ២ខ្សែប៉ុណ្ណោះ។ ផ្លូវដែកទីមួយពីភ្នំពេញទៅអូរជ្រៅមានប្រវែង ៣៨៥ គ.ម ហើយបានបន្តដំណើរដោយផ្លូវដែកក្នុងប្រទេសថៃ រហូតដល់ទីក្រុងបាងកក។ ផ្លូវនេះប្រើប្រាស់សម្រាប់ការដឹកជញ្ជូនអ្នកដំណើរ ទំនិញឧស្សាហកម្ម ផលិតផលកសិកម្ម និងព្រៃឈើពីតំបន់ខាងលិចប្រទេស មកកាន់រាជធានីភ្នំពេញ និងត្រឡប់ទៅទីតាំងដើមវិញ។ ឯទំនិញនាំចូល ពីអូរជ្រៅមកភ្នំពេញ ច្រើនជាងពីភ្នំពេញទៅអូរជ្រៅ ៧ដង។ ហេតុនេះហើយបានជាអាជីវកម្មផ្លូវដែក ទី១នេះមានការលំបាកយ៉ាងខ្លាំង ព្រោះការដឹកជញ្ជូន បានផ្តល់ផលតែម្ខាង ពោលគឺពីអូរជ្រៅមកភ្នំពេញ ដោយសកម្មភាពពាណិជ្ជកម្មបានកើនឡើងពី ២៦ លានតោន នៅឆ្នាំ ១៩៦៧ ទៅដល់ ៧១ លានតោន នៅឆ្នាំ ១៩៦៨ ។

ចាប់ពីដើមឆ្នាំ១៩៦០ ក្រោមការដឹកនាំរបស់សម្តេចព្រះប្រមុខរដ្ឋ អយស្ម័យយានកម្ពុជា បានចាប់ផ្តើមកសាងផ្លូវរថភ្លើងមួយទៀត ពីភ្នំពេញទៅក្រុងព្រះសីហនុដែលមានចំងាយ ២៧០គ.ម។ សម្តេចព្រះប្រមុខរដ្ឋទ្រង់បានសម្ពោធការដ្ឋានហត្ថកម្ម ដើម្បីកសាងផ្លូវដែកនេះនៅ ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៦០។ ផ្លូវដែកថ្មីនេះ ចេញពីភ្នំពេញទៅក្រុងព្រះសីហនុដោយឆ្លងកាត់ស្ទឹងតូចក្នុងខេត្តតាកែវ។ ថ្ងៃទី២ ខែមករា ឆ្នាំ ១៩៦៦ សម្តេចព្រះប្រមុខរដ្ឋ ទ្រង់បានសម្ពោធស្ថានីយ៍អយស្ម័យយានទី១ នៃផ្លូវរថភ្លើងថ្មីភ្នំពេញ-ក្រុងព្រះសីហនុ នៅប្រទះឡាង។ ស្ថានីយ៍នេះបានចាប់ផ្តើមកសាងនៅ ខែសីហា ឆ្នាំ ១៩៦០។ កាលនោះ សម្តេចព្រះប្រមុខរដ្ឋព្រះអង្គទ្រង់បានបើកការដ្ឋានហត្ថកម្មដោយព្រះអង្គផ្ទាល់។ ការកសាងផ្លូវរថភ្លើងថ្មីនេះ ជាវិភាគទានមួយដ៏សំខាន់ របស់ប្រជារាស្ត្រ ខ្មែរ ដែលបានធ្វើការងារដោយមិនយកកម្រៃ ៦០ នៃការស្ថាបនានេះ។ ព្រះសង្ឃ កសិករ មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ និងយុវជន រាជសង្គមនិយម បានរួមកម្លាំងគ្នាជាធ្លុងមួយ ដើម្បីធ្វើការងារនេះរួមគ្នា។ ស្ថានីយ៍អយស្ម័យយាននៅប្រទះឡាង និងនៅព្រៃទទឹង បានសាងសង់ឡើងមួយផ្នែកធំដោយប្រជារាស្ត្រនៅខេត្តកណ្តាល។ ក្បាលរថភ្លើង ក្នុងចំណោមក្បាលរថភ្លើងចំនួន១៣ ជាម៉ាស៊ីនប្រើដោយប្រេងម៉ាស៊ូត និងក្នុងកម្លាំងម៉ាស៊ីន ២.០០០សេះ ម៉ាក អាល់ស្តុម របស់ប្រទេសបារាំង ដាក់អោយដំណើរការនៅលើផ្លូវ

រថភ្លើងថ្មី គឺភ្នំពេញទៅក្រុងព្រះសីហនុ។ ដោយឡែកស្ថានីយ៍អយស្ម័យយានកែបវិញ សម្តេចព្រះប្រមុខរដ្ឋទ្រង់បានសម្ពោធនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៦០ ដែលជាសមិទ្ធិរបស់ប្រជារាស្ត្រនៃក្រុងកែប។ ប្រជារាស្ត្រក្នុងក្រុងកែប បានចេញវិភាគទានផ្ទាល់ខ្លួន ដើម្បីស្ថាបនាស្ថានីយ៍នេះ ដែលស្ថិតនៅចំងាយ ១៥០គ.ម ពីរាជធានីភ្នំពេញ អោយទៅជាស្ថានីយ៍ដ៏ល្អស្រស់ប្រិមប្រិយជាងគេ ក្នុងចំណោមស្ថានីយ៍ទាំងអស់ នៅតាមផ្លូវរថភ្លើងនេះ។ មានប្រជារាស្ត្រ ចំនួន ៦៧៥ នាក់ បានជួយឧបត្ថម្ភដោយជូនដីរបស់គេទាំងឡាយ ដល់រាជអយស្ម័យយានកម្ពុជា ដោយមិនមានយកកម្រៃអ្វីទាំងអស់។ មានប្រជារាស្ត្រខ្មែរមួយចំនួនទៀត បានផ្តល់នូវកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីចូលរួមចំណែកក្នុងការងារស្ថាបនាផ្លូវអយស្ម័យយាន និងអគារទាំងអស់។

ង. វិស័យគមនាគមន៍ដឹកជញ្ជូនតាមផ្លូវអាកាស

នៅសម័យនោះ ប្រទេសកម្ពុជាយើង មានចំណតអាកាសយាន ដ្ឋានចំនួន ៤ គឺអាកាសយានដ្ឋានភ្នំពេញ-ពោធិចិតុង សៀមរាប-អង្គរ រាម-ក្រុងព្រះសីហនុ និង បាត់ដំបង-ប៉ៃកចាន។ ដោយឡែកនៅខេត្ត ស្ទឹងត្រែង ស្ថានីយ៍អាកាស យានដ្ឋានក៏បានសង់រួចហើយដែរដែលអា កាសយានដ្ឋាននោះមានផ្លូវយន្តហោះខ្នាតអន្តរជាតិនិងអាកាសយាន ដ្ឋានទី៦ បានសាងសង់ឡើងនៅក្រុងខេមរភូមិន្ទ (ខេត្តកោះកុង) សព្វ ថ្ងៃនេះ។

សកម្មភាពដឹកជញ្ជូនតាមរយៈផ្លូវអាកាស មានសភាពរីកចម្រើន ដោយសារយើងមានអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ដែលមាន ចម្ងាយ ១០ គ.ម ពីទីក្រុងភ្នំពេញ និងអាកាសយានដ្ឋានសៀមរាប។ អាកាសយានដ្ឋានពោធិចិនតុង មានផ្លូវយន្តហោះមួយប្រវែង ៣.០០០ ម ទទឹង ៤០ម អាចទទួលទម្ងន់កង់យន្តហោះម្ខាងបាន ៣០តោន ក្រុមហ៊ុន អាកាសចរណ៍ជាច្រើនបានមកធ្វើអាជីវកម្មដឹកជញ្ជូនតាមផ្លូវអាកាស របស់យើងទាំងពីរនេះ ដើម្បីតភ្ជាប់គមនាគមន៍ ពីភ្នំពេញ ឬ ពីសៀមរាបទៅកាន់ទីក្រុងនានា នៅតំបន់អាស៊ី និងអឺរ៉ុប។ ម៉្យាងទៀត អាកាសយានដ្ឋាននៅរាម-ក្រុងព្រះសីហនុ មានផ្លូវយន្តហោះមួយប្រវែង១២០០ម និងត្រូវពង្រីកបន្តរហូតដល់ ១៨០០ ម ក្រោយមកបានពង្រីកបន្តទៀត រហូតដល់ ២០០០ ម។ [134]

ច. វិស័យគមនាគមន៍(កំពង់ផែ)តាមទន្លេ និងតាមសមុទ្រ

សកម្មភាពដឹកជញ្ជូនតាមដងទន្លេ និងតាមសមុទ្រមានលក្ខណៈខ្លាំងក្លា នៅតំបន់ភ្នំពេញ និងក្រុងព្រះសីហនុ។ ក្រៅពីនោះមានកំពង់ផែ ផ្សេងៗទៀត ដែលបានរៀបចំតែបន្តិចបន្តួច សម្រាប់ការដឹកទំនិញចេញចូលក្នុងតំបន់របស់ខ្លួនជាពិសេស សម្រាប់ការដឹកជញ្ជូនផលិតផល កសិកម្មទៅកាន់កំពង់ផែធំៗ។

- កំពង់ផែភ្នំពេញ និងសកម្មភាពដឹកជញ្ជូន

កំពង់ផែភ្នំពេញ ជាកំពង់ផែទន្លេផង និងជាកំពង់ផែសមុទ្រផង។ ទីក្រុងភ្នំពេញ គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់ជាងគេបង្អស់របស់ប្រទេស ព្រោះជាកន្លែងដែលមានទន្លេធំៗហូរមកប្រសព្វគ្នា ដែលជាភូមិសាស្ត្រមួយ បង្កលក្ខណៈអោយកំពង់ផែនេះមានលទ្ធភាពដ៏ប្រពៃក្នុងការទាក់ទងជាមួយនឹងខេត្តនានានៅភាគឦសាននៃប្រទេស លើសពីនេះទៅទៀត ក៏បានផ្តល់លទ្ធភាព

អាចទំនាក់ទំនងជាមួយនឹងបណ្តាខេត្តនានាជុំវិញបឹងទន្លេសាប និងជាមួយប្រទេសវៀតណាមខាងត្បូង បានទៀតផង ។ ដូចនេះហើយ បានជាកំពង់ផែនេះនៅតែមានការរីក ចម្រើនតាំងពីសម័យដើមមក ទោះបីជាមានផ្លូវថ្នល់ខ្វាត់ខ្វែងពាសពេញប្រទេស ឬផ្លូវដែកក៏ដោយ។ ចាប់តាំងពីខែ មីនា ឆ្នាំ ១៩៤៨ មកពេលដែលមាន កប៉ាល់ធ្វើដំណើរចូលមកដល់កំពង់ផែភ្នំពេញ កំពង់ផែ នេះក៏បានក្លាយទៅជាកំពង់ផែអន្តរជាតិ។

134 អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជាសង្គមរាស្ត្រនិយមសាធារណការ ទំព័រ ១៨៥

| បរិយាយ | ចំនួនកប៉ាល | ការនាំចូល (គិតជាតោន) | ការនាំចេញ (គិតជាតោន) | ចំនួនសរុប |
|---|---|---|---|---|
| **១៩៦៤** | ៤៩០ | ៣២៥.៦០០ | ៣៨២.២០០ | ៧០៧.៨០០ |
| **១៩៦៥** | ៣៩១ | ២៨២.៣០០ | ៣១៣.១០០ | ៥៩៥.១០០ |
| **១៩៦៦** | ៣៣៥ | ២៩៧.៥៥៦ | ២១៩.៥២៨ | ៥១៧.០៨៤ |
| **១៩៦៧** | ៣៣២ | ៣៤៣.៨០៧ | ១៩១.៤៣៣ | ៥៣៥.២៤០ |
| **១៩៦៨** | ២៧៩ | ៣០៨.៥៧៦ | ១៤៤.៥១៣ | ៤៥៣.១១៩ |

*សកម្មភាពនៃការដឹកជញ្ជូនតាមផ្លូវទឹកនៅកំពង់ផែភ្នំពេញ*

យើងឃើញថា ចំនួនកប៉ាល់ដែលធ្វើចរាចរចេញ-ចូល កាត់តាម កំពង់ផែក្រុងភ្នំពេញ មានការថយចុះជាលំដាប់ ដែលទន្ទឹមនឹងនោះ ទំនិញនាំចូល និងទំនិញនាំចេញ ក៏មានការថយចុះស្របគ្នាដែរ។ បញ្ហា ធ្លាក់ចុះរបស់សកម្មភាពពាណិជ្ជកម្ម នៃកំពង់ផែក្រុងភ្នំពេញ បណ្តាលមកពីបញ្ហានយោបាយរបស់ប្រទេសវៀតណាមខាងត្បូង ជាមួយនឹងប្រទេសខ្មែរយើង និងការតម្លើងថ្លៃពន្ធក្នុងការដឹកទំនិញឆ្លងកាត់តាមផ្លូវទឹករបស់វៀតណាម។ ហើយសកម្មភាពនាំចេញ-ចូលបានងាកទៅរកកំពង់ផែអន្តរជាតិក្រុងព្រះសីហនុវិញ ព្រោះវាមានលក្ខណៈអំណោយផលផ្នែកសេដ្ឋកិច្ច និងមានភាពងាយស្រួលជាង។

- កំពង់ផែកំពង់ចាម

កំពង់ផែកំពង់ចាម ជាក្រុងព្រះសីហនុទីពីរ បន្ទាប់ពីកំពង់ផែភ្នំពេញ។ កំពង់ផែនេះ មានទីតាំងនៅត្រើយខាងស្តាំនៃទន្លេមេគង្គ តា ច្រាំងទន្លេប្រហែលជា ១គ.ម។ ពិតមែនតែជាកំពង់ផែតូច ប៉ុន្តែគេបានរៀបចំជាបន្តបន្ទាប់ទៀត អោយស្របទៅតាមការរីកលូតលាស់នៃទីក្រុងកំពង់ចាម។ កំពង់ផែកំពង់ចាម ជាកំពង់ផែចុងក្រោយបង្អស់សម្រាប់ការធ្វើទំនាក់ទំនងជាមួយនឹងទន្លេសាបពេលទឹកស្រក។

- កំពង់ផែសមុទ្រ ក្រុងព្រះសីហនុ

កំពង់ផែសមុទ្រក្រុងព្រះសីហនុ មានជម្រៅទឹកជ្រៅជាងគេហើយបានសម្ពោធដាក់អោយប្រើប្រាស់នៅខែមេសា ឆ្នាំ១៩៦០។ តាំងពីពេលនោះមកសកម្មភាពដឹកជញ្ជូនរបស់កំពង់ផែនេះ មានដំណើរការកើនឡើងហួសពីការស្មាន។ នៅឆ្នាំ ១៩៦៧ តាមទិន្នន័យរបស់សកម្មភាពដឹកជញ្ជូនបាន

បង្ហាញថា មានការកើនឡើងនូវបរិមាណទំនិញរហូតដល់ ៥៤៥.១៩៧ តោន។ ដូច្នេះការពង្រីកកំពង់ផែក៏បានចាប់ផ្តើមធ្វើផែចំណូតកប៉ាល់ចំលង និងកំពង់ចំណតប្រវែង ៣៥០ម សម្រាប់នាវាធ្វើដំណើរមកពីផ្លូវឆ្ងាយចំណុះ ១២.០០០ តោនអាចចតបាន ២ គ្រឿង ព្រមទាំងអាចទទួលនាវាសមុទ្រធំៗផ្សេងទៀតបាន ។

សកម្មភាពដឹកជញ្ជូនក្នុងឆ្នាំ ១៩៦៨ មានការរីកចម្រើនជាងឆ្នាំ ១៩៦៧ ដោយសារមានកប៉ាល់ ៨០ គ្រឿង លើសឆ្នាំ១៩៦៧។

| បរិយាយ | ចំនួនកប៉ាល | ការនាំចូល (គិតជាតោន) | ការនាំចេញ (គិតជាតោន) | ចំនួនសរុប |
|---|---|---|---|---|
| **១៩៦៤** | ២៥០ | ១៨៦.៨៣៥ | ៥២៧.៩៩៩ | ៧១៤.៨៣៣ |
| **១៩៦៥** | ២៦៦ | ២៦៥.០៩៦ | ៤៨៩.៤៦៥ | ៧៥៤.៥៦០ |
| **១៩៦៦** | ២៥៨ | ២៧៤.៧៥០ | ២៧៣.៧៧៦ | ៥៤៨.៥២៦ |
| **១៩៦៧** | ២៤៥ | ២៥១.២៤៨ | ២៩៣.៩៤៧ | ៥៤៥.១៩៧ |
| **១៩៦៨** | ៣២៥ | ៣៨៩.៧៦៧ | ៣៨៥.០៨១ | ៧៤៧.៨៤៨ |

*សកម្មភាពដឹកទំនិញនៅកំពង់ផែសមុទ្រក្រុងព្រះសីហនុ*

- កំពង់ផែសមុទ្ររាម

ក្រៅពីកំពង់ផែភ្នំពេញ កំពង់ចាម និងក្រុងព្រះសីហនុ យើងនៅមានកំពង់ផែសមុទ្ររាម ដែលកំពង់ផែនេះ ពុំសូវមានសកម្មភាពពាណិជ្ជកម្មប៉ុន្មាននោះទេ ដោយសារតែទឹកមានជម្រៅរាក់ពេកពោលគឺមាន ជម្រៅតែ ៦ ម ហើយអាចទទួលបានតែនាវាដែលមានចំណុះប្រហែល ២.០០០ តោនប៉ុណ្ណោះ។ ដូចនេះហើយបានជារដ្ឋាភិបាលយកចិត្តទុក ដាក់ពង្រីកកំពង់ផែក្រុងព្រះសីហនុវិញ។

❖ វិស័យពាណិជ្ជកម្ម

យើងឃើញថា នៅសម័យសង្គមរាស្ត្រនិយម មិនត្រឹមតែនៅក្នុង ទីក្រុងធំៗប៉ុណ្ណោះទេ សូម្បីតែនៅតាមទីជនបទស្រែចំការ ក៏សកម្មភាពអាជីវកម្មគ្រប់ប្រភេទ មានដំណើរការគួរអោយកត់សម្គាល់ផងដែរ។

ក. ពាណិជ្ជកម្មក្នុងប្រទេស

ក.១ ពាណិជ្ជកម្មជនបទ និងអាជីវកម្មចងការប្រាក់

បើតាមទិន្នន័យខ្លះកំណត់ថា នៅឆ្នាំ ១៩៥៤ នៅតំបន់ស្រុកស្រែចំការ មានអ្នកជំនួញជួញដូរប្រមាណរហូតដល់ ៣៤.០០០ នាក់ ដែលជាអ្នកមានតៀមលក់ដូរទំនិញគ្រប់មុខ និងធ្វើអាជីវកម្មចងការប្រាក់។ ប្រភេទអាជីវកម្មចងការប្រាក់ បានបន្តប្រពៃណីរបស់ខ្លួន តាំងពីសម័យអាណាព្យាបាលបារាំងមកម្ល៉េះ។ តាមស្ថិតិឆ្នាំ ១៩៥២ កសិដ្ឋានប្រមាណ ៧៥% បានប្រើប្រាស់ឥណទានចងការប្រាក់សម្រាប់អភិវឌ្ឍវិស័យ កសិកម្មរបស់ខ្លួន (ភាគច្រើនជាកសិដ្ឋាន ធុនមធ្យម និងធុនតូច) ។ តាមធម្មតា

ក្នុងចំណោមពី ១៨ ទៅ ២០ កសិដ្ឋានកសិកម្ម គឺមានអាជីវករចងការប្រាក់ម្នាក់។ ជាទូទៅបរិមាណប្រាក់ឥណទានរបស់ម្ចាស់បំណុល ដែលបានផ្តល់អោយកសិករ (តាមលក្ខណៈចងការប្រាក់) បានកើនដល់ ២០% នៃផលទុនវិនិយោគទូទៅ ក្នុងវិស័យកសិកម្មរបស់ប្រទេសជាតិ ។

ក.២ ពាណិជ្ជកម្ម

មុនពេលមានកំណែទម្រង់សេដ្ឋកិច្ច នៅឆ្នាំ ១៩៦៣ ស្នាក់ការនាំចេញ និងនាំចូលជាច្រើនយកន្លែង បានប្រមូលទិញផលិតផលក្នុងស្រុកដោយផ្ទាល់ ឬតាមឈ្មួញកណ្តាល យកទៅលក់នៅបរទេស រួចនាំទំនិញជាផលិតផលសម្រេចពីបរទេស ឬជាវត្ថុធាតុដើម សម្រាប់បម្រើអោយឧស្សាហកម្មក្នុងស្រុក ដោយចែកចាយទៅអោយតាមរយៈឈ្មួញលក់ដុំ និងបន្តទៅអោយឈ្មួញលក់រាយ ជាច្រើនតំណទៀត។ សកម្មភាពនេះ កើតឡើងជារៀងរហូតគ្មានទីបញ្ចប់សម្រាប់វដ្តពាណិជ្ជកម្មក្នុងស្រុកនាសម័យនោះ។ ការកេងកម្រៃពីឈ្មួញគ្រប់ដំណាក់កាល បណ្តាលអោយជីវភាពប្រជារាស្ត្រខ្មែរយើងចុះដុនដាប និងធ្វើអោយ អ្នកគ្រប់គ្រងរបស់រដ្ឋ បានរៀបចំធ្វើកំណែទម្រង់សេដ្ឋកិច្ចនេះ។ កំណែទម្រង់សេដ្ឋកិច្ចរដ្ឋសំខាន់ៗនាសម័យនោះ គឺរដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនជាតិនាំចេញ-នាំចូល និងក្រុមហ៊ុនចែកចាយក្នុងស្រុកដើម្បីធ្វើទំនាក់ទំនងពាណិជ្ជកម្មដោយផ្ទាល់ជាមួយអ្នកចែកចាយក្នុងស្រុក និងកសិករដែលជាអ្នកផលិត និងជាអ្នកប្រើប្រាស់ ធ្វើយ៉ាងណាកាត់បន្ថយគម្លាត ពោលគឺកាត់បន្ថយការកេងចំណេញច្រើនដំណាពេកពីសំណាក់ឈ្មួញកណ្តាល ដើម្បីអោយប្រជារាស្ត្រទូទៅដែលជាអ្នកប្រើប្រាស់ និងជាអ្នកផលិតវត្ថុធាតុដើមកសិកម្ម អាចចូលរួមក្នុងចរន្តសេដ្ឋកិច្ចជាតិ និងអាចទទួលបានផលប្រយោជន៍ទាំងសងខាង។ ក្រុមហ៊ុនរដ្ឋទាំងនោះមានដូចជា ៖

- ក្រុមហ៊ុនជាតិនាំចេញ នាំចូល(SONEXIM)

គឺមានមុខងារក្នុងការប្រមូលទិញផលិតផលទាំងអស់សម្រាប់ ធ្វើការនាំចេញទៅក្រៅប្រទេស និងនាំចូលទំនិញពីបរទេស មកលក់ផ្ទាល់តាមស្នាក់ការចែកចាយរបស់ខ្លួន ឬចែកទៅអោយក្រុមហ៊ុនជាតិ ចែកចាយទំនិញនាំចូលដែលហៅថា រដ្ឋភណ្ឌាគារ និងស្នាក់ការលក់រាយរបស់រដ្ឋ។

- ក្រុមហ៊ុនជាតិចែកចាយទំនិញនាំចូល (SONAPRIM)

ក្រុមហ៊ុនរដ្ឋខាងលើនេះ មានតួនាទីសម្រាប់តែទទួលទំនិញនាំចូលពីក្រុមហ៊ុនជាតិនាំចេញ និងនាំចូល ដើម្បីយកទៅលក់ផ្ទាល់តាមបណ្តាសាខា ឬក៏លក់ទៅអោយឈ្មួញឯកជន លក់រាយជាបន្តទៀត។ ក្រុមហ៊ុននេះ ក៏បានទទួលទំនិញក្នុងស្រុក ដែលបានផលិតចេញពី សហគ្រាសរដ្ឋមកលក់បន្តដូចជាទំនិញនាំចូលពីបរទេសដែរ។

រដ្ឋភណ្ឌាគារ និងស្នាក់ការលក់រាយ មានមុខងារដូចគ្នា គឺលក់ទំនិញផលិតក្នុងស្រុក និងនាំមកពីបរទេស ទៅអោយប្រជារាស្ត្រទូទៅ ដែលមានតម្រូវការប្រើប្រាស់។

ក្រៅពីក្រុមហ៊ុនរដ្ឋខាងលើនេះ មានអង្គការជាច្រើនទៀត ដូចជាសហករណ៍ និងឈ្មួញនានាដែលមានមុខងារប្រមូល ឬលក់ផលិតផលគ្រប់យ៉ាងដែលបានប្រកួតប្រជែងជាមួយសហគ្រាសរដ្ឋ។

កំណែទម្រង់សេដ្ឋកិច្ច ក៏នៅមានវិបត្តិច្រើនដែរ ជាហេតុនាំអោយអ្នកដឹកនាំរដ្ឋនាសម័យនោះ បានចាត់វិធានការថ្មីៗជាច្រើនទៀត ពោលគឺរដ្ឋផ្អាកធ្វើពាណិជ្ជកម្មចែកចាយទាំងស្រុង ដោយបើក

អោយមានសេរីភាវូបនីយកម្មសេដ្ឋកិច្ច ហើយលុបចោលអង្គការខ្លះដូចជា ក្រុមហ៊ុនជាតិចែកចាយទំនិញនាំចូល រដ្ឋភណ្ឌាគារ។

ខ. វិស័យពាណិជ្ជកម្មក្រៅប្រទេស

ខ.១ ការនាំចេញ (Exportation)

ទំនិញសម្រាប់នាំចេញទៅបរទេស ច្រើនតែជាផលិតផលវត្ថុធាតុដើមកសិកម្ម និងភោគទ្រព្យធម្មជាតិកើតពីដី ព្រមទាំងពីក្នុងព្រៃ (សត្វព្រៃ)។ ផលិតផលនាំចេញសំខាន់ៗ ពុំមែនចេះតែកើនឡើង និង មានតម្លៃកើនឡើងជារៀងរាល់ឆ្នាំនោះទេ។ ស្ថិតិឆ្នាំ ១៩៦៧ និងឆ្នាំ ១៩៦៨ អាចបញ្ជាក់ប្រាប់យើងបានខ្លះដូចជា ប្រាក់ដែលយើងបានមកពី ការនាំចេញផលិតផលកៅស៊ូ និងស្បែកសម្លាប់ ថ្នាំជក់ និងម្រេចចេញទៅបរទេស គឺបានតិចជាងរូបិយប័ណ្ណ ដែលយើងទទួលបានក្នុងឆ្នាំ ១៩៦៧។

| បរិយាយ | ១៩៦៧ | | ១៩៦៨ | |
|---|---|---|---|---|
| | ពាន់តោន | លានរៀល | ពាន់តោន | លានរៀល |
| អង្ករ, ផលិតផលចេញពីអង្ករ | ២១៩ | ១.២៩៤ | ២៣០ | ១.៣០៥ |
| កៅស៊ូ | ៥០ | ៧១៦ | ៤៧ | ៦៥៧ |
| ផលិតផលផ្សេងៗ | ៣៣ | ២៩៤ | ៣៤ | ៣៩២ |
| ពោត | ៦៥ | ១៤៧ | ៨៨ | ១៥៦ |
| សណ្តែកបាយ | ៦ | ៤៣ | ១៨ | ១១០ |
| ផលិផលបសុសត្វ | ១១ | ៩០ | ១៦ | ១១០ |
| ឈើសំណង់ | ៩៨ ម៣ | ៧០ | ១១៧ ម៣ | ៨៤ |
| សំឡីគ | ៤ | ៤៥ | ៦ | ៦៣ |
| ល្ង | ៧ | ៦៣ | ១០ | ៦៦ |
| ម្រេច | ២ | ៥៣ | ២ | ៤៩ |
| សណ្តែកសៀង | ? | ? | ៦ | ២៦ |
| ប្រេងឈើ | ១ | ៤ | ១ | ១៧ |
| គ្រាប់ឪឡឹក | ១ | ៨ | ១ | ១៦ |
| ថ្នាំជក់ | ១ | ១៧ | ? | ១២ |
| ស្បែក និងស្បែកសម្លាប់ | ១ | ១៩ | ១ | ១០ |

*ទិន្នន័យទំនិញនាំចេញ ឆ្នាំ ១៩៦៧ និងឆ្នាំ ១៩៦៨*

ចំពោះការនាំចេញទំនិញក្នុងឆ្នាំ១៩៦៨ មានតម្លៃសរុប ៣.០៩៨៨ លានរៀល។ យើងឃើញថា អង្ករ និងកៅស៊ូ មានតម្លៃស្មើនឹង ៣/៥ នៃតម្លៃផលិតផលនាំចេញទាំងអស់។ ប្រទេសទទួលទិញទំនិញដែល នាំចេញពីប្រទេសកម្ពុជារួមមាន ប្រទេសបារាំង (កៅស៊ូ ពោត ម្រេច) ប្រទេសនៅអាស៊ីមានដូចជា ហុងកុង ម៉ាឡេស៊ី ជប៉ុន ចិន លាវ និងប្រទេសផ្សេងៗទៀតដូចជា ហូឡង់ អាឡឺម៉ង់ អង់គ្លេស ហ្វាំងឡង់ ស៊ុយអែដ អេហ្ស៊ីប និងដាណឺម៉ាក។

ខ.២ ការនាំចូល (Importation)

នៅសម័យនោះ ប្រទេសខ្មែរយើងបាននាំចូលនូវផលិតផល ផលិតសម្រេចដូចជាទំនិញមានទម្ងន់ស្រាលតែមានតម្លៃខ្ពស់ ភាគខ្លះជាវត្ថុធាតុដើមសម្រាប់សហគ្រាសនានា។ ការនាំចូលក្នុងឆ្នាំ

១៩៦៨ មានចំនួនរហូតដល់ទៅ ៤.០៤៨ លានរៀល លើសពីឆ្នាំ ១៩៦៧ គឺប្រមាណជា ២០.១% ដែលមានត្រឹមតែ ៣.៣៦៥ លានរៀលតែប៉ុណ្ណោះ។ បើយើងគិតជាតម្លៃមធ្យម ពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ ១៩៦៣ ការនាំចូលទំនិញក្នុងឆ្នាំ ១៩៦៨ ចំនួនកើនឡើង ៤៦%។ ផលិតផលនានាដែលនាំចូលមកមានដូចជា ផលិតផលកសិកម្មបសុសត្វ និងគ្រឿងបរិភោគ ៦% ផលិតផលរ៉ែ ១០% ផលិតផលវាយនភណ្ឌ ផលិតផលលោហៈ និងផលិតផលចេញពីលោហៈ ៤៣% និងផលិតផលផ្សេងៗ ៣១.៥%។

ប្រទេសដែលបានលក់ផលិតផលមកអោយប្រទេសកម្ពុជា គឺ ច្រើនតែប្រទេសដែលបានទិញផលិតផលរបស់យើង។ ម្យ៉ាងទៀត បើយើងពិនិត្យមើលទៅលើជញ្ជីងពាណិជ្ជកម្មអន្តរជាតិ ក្នុងឆ្នាំ ១៩៦៨ យើងឃើញថា ប្រទេសកម្ពុជាមានឱនភាពពាណិជ្ជ កម្មអន្តរជាតិចំនួន ៩៤៦ លានរៀល ច្រើនជាងឆ្នាំ ១៩៦៧ ទៅទៀត ដែលមានឱនភាពតែ ១៥៨ លានរៀលតែប៉ុណ្ណោះ។

ទាក់ទងនឹងវិស័យពាណិជ្ជកម្មអន្តរជាតិ យើងសង្កេតឃើញថា តាំងពីយុគសម័យមុនៗមក ក្រុមហ៊ុនផ្តាច់មុខធំៗរបស់បារាំង បានដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេសជាតិ។ ក្រុមហ៊ុនបារាំងមានជាអាទិ៍គឺ ក្រុមហ៊ុនពាណិជ្ជកម្មកម្ពុជា ក្រុមហ៊ុនឌុយម៉ារ៉េស្ត ក្រុមហ៊ុនដឺនីសហ្វ្រេ ក្រុមហ៊ុនឡាអារ៉េរ៉ែស។ល។ បានធ្វើអាជីវកម្មផ្តាច់ មុខក្នុងការនាំចេញនូវទំនិញសំខាន់ពីប្រទេសកម្ពុជា ដូចជា កៅស៊ូ អង្ករ ម្រេច និងទំនិញមួយចំនួនធំទៀត។ តាមស្ថិតិនាឆ្នាំ ១៩៦២ មូលធន (Capital) បារាំងបានកាន់កាប់ស្ថានភាពរហូតដល់ ១/៣ នៃមូលធនក្រុមហ៊ុនពាណិជ្ជកម្មនាំចេញទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ទិដ្ឋភាពដែលគួរអោយកត់សម្គាល់ម្យ៉ាងទៀតគឺនៅក្រោមរបបអាណាព្យាបាលបារាំង ពួកអាជីវករចងការប្រាក់មិនរវល់យកចិត្តទុក ដាក់ដល់ការទិញដីធ្លី ដើម្បីធ្វើជាកម្មសិទ្ធិរបស់ខ្លួនទេ។ ប៉ុន្តែបន្ទាប់ពីប្រទេសទទួលបានឯករាជ្យមក ស្ថានភាពបែបនេះ ត្រូវបានផ្លាស់ប្តូរ ដោយហេតុថាពួកមូលធនក្នុងស្រុកមានឱកាសចូលរួមក្នុងវិស័យពាណិជ្ជកម្មនាំចេញ ជាពិសេសផលិតផលស្រូវ និងពោត។ មូលធនពាណិជ្ជកម្មកម្ពុជា បានចាប់ផ្តើមពង្រីកកិច្ចសហប្រតិបត្តិការរបស់ខ្លួន ទៅលើផលិតកម្មនៃដំណាំសំខាន់ៗសម្រាប់នាំចេញទៅលក់ឯបរទេស។ ស្ថានភាពបែបនេះ បានជម្រុញអោយមានការចំណាយដើមទុនរបស់ អាជីវករមួយភាគធំទៅលើរបរកសិកម្ម និងបង្កើតអោយមានការប្រមូល ទិញដីធ្លីកសិកម្មក្នុងទិសដៅអភិវឌ្ឍន៍ ដំណាំកសិកម្មសម្រាប់នាំចេញ។

គួរបញ្ជាក់ថា ចាប់តាំងពីឆ្នាំ ១៩៥៦ វង្វង់នៃការប្រើប្រាស់ឥណទានខាងវិស័យពាណិជ្ជកម្មក្រៅប្រទេសនៅប្រទេសកម្ពុជា បានក្លាយជាមូលដ្ឋាននៃការប្រកួតប្រជែងគ្នាដ៏ស្វិតស្វាញ រវាងមូលធនបារាំង សហរដ្ឋអាមេរិក អង់គ្លេស និងជប៉ុន។ ការហូរចូលមកនូវមូលធនហិរញ្ញវត្ថុ និងទំនាក់ទំនងពាណិជ្ជកម្ម មានការទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងការអនុវត្តនូវកម្មវិធីជំនួយខាងសេដ្ឋកិច្ច និងយោធារបស់សហរដ្ឋអាមេរិក។

នៅឆ្នាំ ១៩៥៥ ក្រៅពីក្រុមហ៊ុនពាណិជ្ជកម្មធំៗរបស់បារាំង គេសង្កេតឃើញមានសាខានៃក្រុមហ៊ុនពាណិជ្ជកម្ម និងក្រុមហ៊ុនធានារ៉ាប់រងអាមេរិកផងដែរ ដែលបានដំណើរការនៅទីក្រុងភ្នំពេញ ក្នុងនោះមាន ក្រុមហ៊ុនអន្តរជាតិរបស់អាមេរិក ឈ្មោះ Esso និង Caltex ដែលទទួល បានសិទ្ធិនាំចូល

ប្រេងឥន្ធនៈចំនួន ៣៥% ក្នុងនោះក៏មានក្រុមហ៊ុនជាដៃគូរប្រកួតប្រជែងគឺមានក្រុមហ៊ុនប្រេងកាត អង់គ្លេស-ហូឡង់ឈ្មោះ Shell ដែលទទួលបន្ទុកក្នុងការនាំចូលប្រេង ៦០% ដែរ ។

បន្ទាប់ពីបានកកើតក្រុមហ៊ុនពាណិជ្ជកម្មអង់គ្លេស ក៏មានការកកើតក្រុមហ៊ុនពាណិជ្ជកម្មជប៉ុន ដែលធ្វើការនាំចូលគ្រឿងតម្បាញ។ សកម្មភាពរបស់ក្រុមហ៊ុនអង់គ្លេស និងជប៉ុន បានរីកសាយទៅលើបម្រើបម្រាស់ឥណទានសម្រាប់ពាណិជ្ជកម្ម ដោយមានការបង្កើតធនាគារ អង់គ្លេសពីរគឺ ធនាគារ ឆារទែរ៉េត ធនាគារ ហុងកុង-សៀងហៃ និងធនាគារជប៉ុនមួយឈ្មោះ តូក្យូ។ ការនាំចូលទុនឯកជនរបស់សហរដ្ឋអាមេរិក អង់គ្លេស និងជប៉ុនមកក្នុងវិស័យឧស្សាហកម្មកម្ពុជាមានតិចតួចស្ដួចស្ដើងបំផុត រហូតដល់ឆ្នាំ ១៩៦៤។

នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ មជ្ឈដ្ឋានអ្នកដឹកនាំប្រទេសកម្ពុជាបាន ធ្វើសេចក្ដីសម្រេចមួយ ដើម្បីបញ្ឈប់កម្មវិធីជំនួយសេដ្ឋកិច្ចរបស់បណ្ដាប្រទេសខាងលើ ដោយបានអនុវត្តការកែប្រែនូវប្រព័ន្ធធនាគារ និង ពាណិជ្ជកម្មអន្តរជាតិ។ ការកែប្រែនេះសំដៅលើការហាមឃាត់ដល់សកម្មភាពរបស់ក្រុមហ៊ុនពាណិជ្ជកម្មឯកជនក្រៅប្រទេស និងធនាគារ ពាណិជ្ជកម្មឯកជនមួយចំនួននៅប្រទេសកម្ពុជា។

ហេតុនេះមុខងារផ្នែកពាណិជ្ជកម្ម អាហារ័ណ-នីហារ័ណ ដែលពីមុនមក បានបំពេញដោយក្រុមហ៊ុនបរទេស ក្រោយមកត្រូវបានប្រគល់តួនាទីដល់ក្រុមហ៊ុនពាណិជ្ជកម្មជាតិ ដែលទើបតែបង្កើតថ្មី។ ក្រុមហ៊ុន ពាណិជ្ជកម្មអន្តរជាតិថ្មីនេះមានឈ្មោះថា ក្រុមហ៊ុនអាហារ័ណ-នីហារ័ណជាតិ ដោយសរសេរអក្សរកាត់ថាសូណិចស៊ីម (SONEXIM) ក្រុមហ៊ុនថ្មី នេះមានមូលនិធិប្រមាណ ២៤០លានរៀល ដែលក្នុងនោះ មូលនិធិ ៦០% ជាដើមទុនរបស់រដ្ឋ ហើយ ៤០% ទៀត ជាដើមទុនរបស់ឯកជនក្នុងស្រុក។ ប្រភពធនធានឥណទាន ដែលពីមុនៗមកបានបំពេញដោយ ធនាគារបរទេសនានា ក្រោយពេលកែប្រែរបបប្រព័ន្ធធនាគារត្រូវបានផ្ដល់ដោយធនាគារពាណិជ្ជកម្មរដ្ឋវិញឈ្មោះ ឥណទានជាតិ។

នៅឆ្នាំ ១៩៦៤ នៅកម្ពុជាមានការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋ និងឯកជនពីរទៀតគឺ ក្រុមហ៊ុនឯកជនខ្មែរ ដែលមានតួនាទីជាអ្នកទិញតាមរយៈ ផលិតផលកសិកម្ម (សរសេរកាត់ថា ស្វ៉ាប៉ា និងក្រុមហ៊ុនជាតិដែលមានតួនាទីជាអ្នកចែកចាយនូវទំនិញនាំចូលមកពីបរទេស ក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋ សរសេរកាត់ថា សូណាព្រីម (SONAPRIM)។ ភារកិច្ចដ៏សំខាន់របស់ក្រុមហ៊ុនទាំងពីរនេះ គឺជួយសម្របសម្រួល និងឧបត្ថម្ភដល់ក្រុមហ៊ុនសូណិចស៊ីម ក្នុងការរៀបចំទំនិញដោយផ្ទាល់ពីអង្គការសហករណ៍កសិកម្មនានាសម្រាប់ការនាំចេញ និងជួយចែកចាយទំនិញនាំចូល។ នៅឆ្នាំ ១៩៦៥ រដ្ឋាភិបាលកម្ពុជាបានអនុញ្ញាត អោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសមួយចំនួន បន្តសកម្មភាពរបស់ខ្លួនឡើងវិញ។ ជាពិសេសគឺក្រុមហ៊ុនធំៗ ដែលធ្វើអាជីវកម្មលើការនាំប្រេង ឥន្ធនៈចូលមកក្នុងប្រទេសមានជាអាទិ៍គឺក្រុមហ៊ុនរបស់អង់គ្លេសហូល្លង់ឈ្មោះ Shell និងក្រុមហ៊ុនអាមេរិកឈ្មោះ Esso និង Caltex។ ម្ដងនេះក្រុមហ៊ុនរដ្ឋ (សូណិចស៊ីម) បានកាន់កាប់របរពាណិជ្ជកម្មអន្តរ ជាតិសំខាន់ៗលើវិស័យដទៃ

ទៀត។

គួរបញ្ជាក់ថា ក្រុមហ៊ុនអាមេរិកខាងលើ គឺជាសាខានៃក្រុមហ៊ុន ពាណិជ្ជកម្ម និងក្រុមហ៊ុនជានារ៉ាប់រងអាមេរិក ដែលបានបង្កើតបណ្តាញ សាខារបស់ខ្លួននៅប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៥៥ ហើយមានតួនាទី យ៉ាងសម្ខាន់ក្នុងការនាំប្រេងឥន្ទនៈចូលមកក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៥៥ រហូតដល់ ៣៥% នៃបរិមាណសរុប។ ចំណែកឯក្រុមហ៊ុន ប្រេង របស់អង់គ្លេស-ហូល្លង់ឈ្មោះ Shell ទទួលបន្ទុកលើការនាំប្រេងចូល ច្រើនជាងគេ គឺស្មើនឹង ៦០% នៃចំនួននាំចូលសរុប។ ក្រៅពីនោះ ក៏មានកកើតក្រុមហ៊ុនពាណិជ្ជកម្មរបស់ជប៉ុន ដែលបានត្រួតពិនិត្យកាន់កាប់លើទីផ្សារនាំចូលគ្រឿងតម្បាញគ្រប់យ៉ាង ។

រហូតមកដល់សម័យសង្គមរាស្ត្រនិយម ប្រទេសខ្មែរជាប្រទេសមួយដែលទិញផលិតផលផលិតសម្រេចពីបរទេស។ នៅសម័យនោះដែរ សហគ្រាសឧស្សាហកម្មរបស់យើងបានកែច្នៃវត្ថុធាតុដើមក្នុងប្រទេស អោយទៅជាផលិតផលសម្រេច រួចចែកចាយប្រើប្រាស់ក្នុងប្រទេស ឬ នាំចេញទៅក្រៅប្រទេសបានមួយចំនួនទៀតផង។ ទោះបីជាយ៉ាងនេះ ហើយក៏ដោយ ក៏ស្ថានភាពសេដ្ឋកិច្ចប្រទេសខ្មែរនៅពឹងផ្អែកលើបរទេស យ៉ាងខ្លាំងក្លា។ ជាពិសេស ផលិតផលកសិកម្មដែលត្រូវនាំចេញទៅកាន់ ទីផ្សារអន្តរជាតិ ហើយនឹងតម្រូវការនាំចូលនូវផលិតផល ដែលជាការចាំ បាច់នោះ ក៏ត្រូវពឹងផ្អែកទាំងស្រុងទៅលើទំនាក់ទំនងក្រៅប្រទេសដែរ។

ហេតុដូចច្នេះពាណិជ្ជកម្មក្រៅប្រទេស គឺជាវិស័យគន្លឹះមួយយ៉ាងចាំបាច់ សម្រាប់អាយុជីវិតប្រទេសកម្ពុជា។ លក្ខណៈបែបនេះ ពុំបានធ្វើអោយពាណិជ្ជកម្មក្រៅប្រទេសអាចប្រព្រឹត្តទៅដោយរលូននោះឡើយ។ ព្រោះថាផលិតកម្មខ្មែរយើងទទួលបានកម្រៃយ៉ាងតិចបំផុត ហើយទំនិញនាំចូលគឺមានតម្លៃហួសប្រមាណ។

❖ វិស័យធនាគារ និងហិរញ្ញវត្ថុ

នៅសម័យសង្គមរាស្ត្រនិយម វិស័យធនាគារបានដើរតួនាទីយ៉ាងសំខាន់ក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេស។ ធនាគាររបស់រដ្ឋ ដែលសំខាន់ជាងគេគឺ ធនាគារឥណទានជាតិ ដែលជាធនាគារពាណិជ្ជ កម្មរដ្ឋដោយមានភារកិច្ចផ្តល់ឥណទានដល់ក្រុមហ៊ុន អាហារណែនិហាវណែជាតិ ប្រមាណ ១៥៤ លានរៀល នៅឆ្នាំ១៩៦៣ និងផ្តល់ឥណទានសម្រាប់សហករណ៍កសិកម្ម ប្រមាណ ៤០០លានរៀល នៅ ចន្លោះឆ្នាំ ១៩៦៧–១៩៦៨។

វិស័យធនាគារ នៅសម័យនោះគឺមានធនាគារជាតិនៃកម្ពុជា ដែលបានកើតឡើងនៅឆ្នាំ ១៩៥៤ ក្រោយពេលទទួលបានឯករាជ្យពីបារាំង ហើយមានបុព្វសិទ្ធិបោះពុម្ពក្រដាសប្រាក់ដោយខ្លួនឯង។ ធនាគារជាតិ នៃកម្ពុជា គឺជាធនាគារកណ្តាលមួយ ដែលមានទំនាក់ទំនងជាមួយក្រសួងហិរញ្ញវត្ថុក្នុងការកំណត់គោលនយោបាយរូបិយវត្ថុរបស់ប្រទេស និងមានទំនាក់ទំនងប្រតិបត្តិការជាមួយធនាគារពាណិជ្ជកម្មផងដែរ ក្នុងការត្រួតពិនិត្យអត្រាប្តូរប្រាក់បរទេស និងការអនុវត្តគោលនយោបាយផ្សេងៗ។ នៅថ្ងៃទី ១ ខែកក្កដា ឆ្នាំ ១៩៦៤ រាជរដ្ឋាភិបាលបានធ្វើជាតូបនីយកម្មធនាគារជាង១០ ដើម្បីគ្រប់គ្រងធនាគារពាណិជ្ជកម្មឯកជនទាំងនោះ។ រាជរដ្ឋាភិបាលបានបង្កើតអោយមានធនាគាររដ្ឋ ២ គឺ

ធនាគារ ខ្មែរសម្រាប់ពាណិជ្ជកម្ម និងធនាគារឥណទានជាតិ ដើម្បីគ្រប់គ្រងលើធនាគារឯកជនខាងលើនេះ។[135]

ក្រៅពីនោះ មានសាខាធនាគារបរទេសជាច្រើនទៀត ដែលបានសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានាសម័យនោះ។ ពោលគឺចាប់តាំងពីឆ្នាំ ១៩៥៦ មកម្ល៉េះ ការប្រើប្រាស់ប្រាក់ឥណទានសម្រាប់ដំណើរការលើវិស័យពាណិជ្ជកម្មអន្តរជាតិនៅប្រទេសកម្ពុជា ក្នុងនោះមានធនាគាររបស់បារាំង អាមេរិក អង់គ្លេស និងជប៉ុន។

ចំពោះប្រតិបត្តិការ អាហរណ៍-នីហរណ៍ របស់ក្រុមហ៊ុនពាណិជ្ជកម្មបារាំង បានប្រព្រឹត្តទៅតាមរយៈធនាគារបារាំងចំនួនបីពោលគឺធនាគារនៃឥណ្ឌូចិន ធនាគារបារាំង-ចិន និងធនាគារដើម្បីពាណិជ្ជកម្ម និងឧស្សាហកម្ម ដែលធនាគារទាំងអស់នេះហើយ បានផ្តល់ឥណទាន ពាណិជ្ជកម្មយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជា។

ក្រៅពីនោះ មានធនាគារអង់គ្លេសចំនួនពីរគឺ ធនាគារ ឆាវទែរ៉េត ធនាគារ ហុងកុង-សៀងហៃ ព្រមទាំងធនាគារជប៉ុនមួយឈ្មោះ តូក្យូ។ ធនាគារទាំងអស់នេះ ក៏បានចូលរួមផ្តល់ឥណទានសម្រាប់វិស័យពាណិជ្ជកម្មអន្តរជាតិរបស់ប្រទេសកម្ពុជាផងដែរ។

តាមសារពត៌មានដែលបានចុះផ្សាយ ដោយកាសែតបរទេស បានអះអាងថា ការនាំចូលទុនឯកជនរបស់សហរដ្ឋអាមេរិក អង់គ្លេស និងជប៉ុន សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅប្រទេសកម្ពុជា គឺមានសភាពស្ងួតស្ងើងណាស់។ យើងសង្កេតឃើញថា រហូតមកដល់ឆ្នាំ ១៩៦៤ ក្របខ័ណ្ឌនៃការផ្តល់ទុនសម្រាប់វិស័យឯកជនពីបរទេស បានស្ថិតនៅតែក្នុងរង្វង់នៃសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស និងក្នុងប្រព័ន្ធការផ្តល់ប្រាក់ឥណទានដល់ប្រទេសកម្ពុជាតែប៉ុណ្ណោះ។

ម្យ៉ាងទៀត លក្ខណៈពិសេសនៃការផ្តល់មូលធនបរទេសនៅប្រទេសកម្ពុជា នាសម័យសង្គមរាស្ត្រនិយម ក៏បានបង្ហាញអំពីលក្ខណៈប្រយោជន៍នយោបាយផ្សេងៗ របស់បណ្តាប្រទេសម្ចាស់ឥណទានដែរ។ ដូចជានៅឆ្នាំ ១៩៥៥ ដល់ ១៩៦៣ រដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលបារាំងបានផ្តល់ប្រាក់ឥណទាន ក្រោមរូបភាពជំនួយឥតសំណង ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីជំនួយសេដ្ឋកិច្ច និងជាជំនួយយោធារបស់ខ្លួន។ ក្នុងនោះ រដ្ឋាភិបាលប្រទេសអាល្លឺម៉ង់ខាងលិច អូស្ត្រាលី និងជប៉ុន ក៏បានចូលរួមក្នុងការអនុវត្តកម្មវិធីជំនួយសេដ្ឋកិច្ចនេះដែរ។

គួរបញ្ជាក់ថា ការចុះហត្ថលេខាលើការផ្តល់ជំនួយរបស់សហរដ្ឋ អាមេរិក ចាប់តាំងពីឆ្នាំ ១៩៥៥ រហូតដល់ឆ្នាំ ១៩៦៣ សម្រាប់ជួយលើ ផ្នែកសេដ្ឋកិច្ច និងយោធា ដែលមានលក្ខណៈគួរអោយកត់សម្គាល់ដូចខាងក្រោមនេះ ៖

- ឆ្នាំ ១៩៥៥ ជំនួយសរុបទាំងអស់ចំនួន ៤៥.៩០០.០០០ ដុល្លារ ដែលក្នុងនោះមានទឹកប្រាក់ចំនួន ២១.៣០០.០០០ ដុល្លារ ផ្តល់ដល់ផ្នែកយោធា និងទឹកប្រាក់ចំនួន ២៤.៦០០.០០០ ដុល្លារទៀត បានផ្តល់សម្រាប់ផ្នែកសេដ្ឋកិច្ច ។

- ឆ្នាំ ១៩៥៦ ជំនួយសរុបមាន ៤៥.៨០០.០០០ដុល្លារ ក្នុងនោះមានទឹកប្រាក់ចំនួន ២២.០០០.០០០ដុល្លារ ផ្តល់ដល់ផ្នែកយោធា និង១៣.២០០.០០០ដុល្លារ ទៀតផ្តល់ដល់ផ្នែកសេដ្ឋកិច្ច។
- ឆ្នាំ ១៩៥៧ ជំនួយសរុបមាន ៣៤.៦០០.០០០ដុល្លារ ក្នុងនោះមានទឹកប្រាក់ចំនួន ១៥.៥០០.០០០ដុល្លារ ផ្តល់ដល់ផ្នែកយោធា និង១៩.១០០.០០០ដុល្លារ ទៀតផ្តល់ដល់ផ្នែកសេដ្ឋកិច្ច។
- ឆ្នាំ ១៩៥៨ ជំនួយសរុបមាន ២៨.៦០០.០០០ដុល្លារ ក្នុងនោះ មានទឹកប្រាក់ចំនួន ១៥.៤០០.០០០ដុល្លារ ផ្តល់ដល់ផ្នែកយោធា និង១៣.២០០.០០០ដុល្លារ ទៀតផ្តល់ដល់ផ្នែកសេដ្ឋកិច្ច។
- ឆ្នាំ ១៩៥៩ ជំនួយសរុបមាន ២៥.៦០០.០០០ដុល្លារ ក្នុងនោះ មានទឹកប្រាក់ចំនួន ១៣.១០០.០០០ដុល្លារ ផ្តល់ដល់ផ្នែកយោធា និង ១២.៥០០.០០០ដុល្លារ ទៀតផ្តល់ដល់ផ្នែកសេដ្ឋកិច្ច។

- ឆ្នាំ ១៩៦០ ជំនួយសរុបមាន ២២.៧០០.០០០ដុល្លារ ក្នុងនោះមានទឹកប្រាក់ចំនួន ១២.០០០.០០០ដុល្លារ ផ្តល់ដល់ផ្នែកយោធា និង ១០.៧០០.០០០ដុល្លារ ទៀតផ្តល់ដល់ផ្នែកសេដ្ឋកិច្ច។
- ឆ្នាំ ១៩៦១ ជំនួយសរុបមាន ២៦.៦៦៤.៧៥៨ដុល្លារ ក្នុងនោះ មានទឹកប្រាក់ចំនួន ១២.០០០.០០០ដុល្លារ ផ្តល់ដល់ផ្នែកយោធា និង ១០.៧០០.០០០ដុល្លារ ទៀតផ្តល់ដល់ផ្នែកសេដ្ឋកិច្ច។
- ឆ្នាំ ១៩៦២ ជំនួយសរុបមាន ២៣.៩០០.០០០ដុល្លារ ក្នុងនោះ មានទឹកប្រាក់ចំនួន ៥២.២% ត្រូវបានផ្តល់ដល់ផ្នែកយោធា និងប៉ូលីស។ ឆ្នាំ ១៩៦៣ ជំនួយសរុបមាន ១៩.៣០០.០០០ដុល្លារ ក្នុងនោះ មានទឹកប្រាក់ចំនួន ៥៧% ត្រូវបានផ្តល់ដល់ផ្នែកយោធា និងសន្តិសុខ ផ្ទៃក្នុងប្រទេស។

បើយើងពិនិត្យ តាមទិន្នន័យនៃជំនួយដែលបង្ហាញខាងលើនេះ យើងឃើញថា ជំនួយសហរដ្ឋអាមេរិក ដែលបានផ្តល់អោយប្រទេសកម្ពុជា មានចំនួនរាប់សិបលានដុល្លារក្នុងមួយឆ្នាំៗ ដែលអាចអនុញ្ញាត អោយកម្ពុជាមានលទ្ធភាពក្នុងការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិបាន មិនត្រឹមតែប៉ុណ្ណោះ ជំនួយនេះអាចធ្វើអោយប្រទេសកម្ពុជារក្សាការពារនូវបូរណភាពទឹកដី និងឯករាជ្យជាតិបានទៀតផង ។

ប៉ុន្តែការផ្តល់ឥណទានរដ្ឋ ដល់ប្រទេសកម្ពុជាដោយប្រទេសខាងលើ មានគោលបំណងច្បាស់លាស់ គឺដើម្បីបម្រើផលប្រយោជន៍ និងមហិច្ឆតានយោបាយរបស់បណ្តាប្រទេសសេរីនិយមខាងលើតែប៉ុណ្ណោះ ក្នុងទិសដៅទប់ស្កាត់ប្រទេសកម្ពុជា អោយស្ថិតនៅក្នុងរង្វង់ព្រំដែននៃឥទ្ធិពលនយោបាយរបស់ប្រទេសទាំងអស់នោះ ជាពិសេសចង់អោយកម្ពុជាក្លាយទៅជាមូលដ្ឋានគាំទ្រមួយដ៏

សំខាន់នៅឥណ្ឌូចិន។ ដូច្នេះ តាមខ្លឹមសារខាងលើ ប្រភពចំណូលមួយចំណែកនៃថវិការដ្ឋ គឺបានមកពីជំនួយឥតសំណងពីបរទេស។ រីឯប្រាក់ចំណូលរបស់រដ្ឋមួយផ្នែកធំទៀត គឺបានមកពីការនាំចេញនូវទំនិញកសិកម្មជាច្រើនទៀត តាមរយៈក្រុមហ៊ុនអាហារ័ណ-នីហារ័ណ (SONEXIM) និងការបង់ពន្ធក្នុងស្រុក ព្រមទាំងពន្ធគយ ។

ទាក់ទងទៅនឹងការចំណាយនានារបស់ថវិការដ្ឋ នៅសម័យសង្គមរាស្ត្រនិយម យើងសង្កេតឃើញថា រដ្ឋាភិបាលបានចំណាយ ថវិកាជាច្រើនសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ក្នុងនោះមានការផ្តល់ ជាប្រាក់ឥណទានដល់សហករណ៍កសិកម្ម (នៅក្នុងឆ្នាំ ១៩៦៧-១៩៦៨ មានប្រមាណ ៤០០ លានរៀល) និងចំណាយក្នុងដំណើរការពាណិជ្ជកម្ម អន្តរជាតិ (ដែលមានប្រមាណ ៦០% នៃភាគហ៊ុនរបស់រដ្ឋ)។ ក្រៅពីនោះ ថវិការដ្ឋបានចំណាយលើការទ្រទ្រង់មន្ត្រីរាជការ ការកសាងសំណង់សាធារណៈ និងផ្សេងៗទៀត។ ដោយសារតែការចំណាយថវិការដ្ឋមានលក្ខណៈមិនសមស្រប នៅឆ្នាំ ១៩៦៦ ប្រទេសកម្ពុជាបានជួបប្រទះនូវឱនភាពថវិការដ្ឋ ក្នុងកម្រិតវិសមមាត្រប្រមាណ ៣០% លើសប្រាក់ចំណូលសរុប។

សរុបសេចក្តីមក បើយើងពិនិត្យមើលបន្ថែមទៀតទៅលើប្រាក់ចំណូលថវិការដ្ឋ (គឺតែផ្នែកចំណូលចរន្តរួមមានដូចជា ចំណូលពន្ធ ប្រាក់ចំណេញពីសហគ្រាសរដ្ឋ ការផាកពិន័យ ។ល។) នៅឆ្នាំ ១៩៦៧ មានចំនួន ៥.៦០២ លាន រៀល និងឆ្នាំ ១៩៦៩ មានចំនួន ៥.៩៩៦ លាន រៀល ដែលចំនួននេះ មិនអាចធានាបានចំពោះការចំណាយចរន្តនោះទេ។ នៅសម័យនោះ ឱនភាពថវិការដ្ឋ នៅក្នុងឆ្នាំ ១៩៦៧ មានចំនួន ១.០៥៦ លាន រៀល និងឆ្នាំ ១៩៦៩ មាន ចំនួន ១.០០៤ លានរៀល។ ដើម្បីដោះស្រាយបញ្ហាអតុល្យភាពថវិការដ្ឋ រដ្ឋាភិបាលបានអនុវត្តគោលនយោបាយថវិកា ដូចជាករណីឆ្នាំ ១៩៦៩ ដោយស្វែងរកកម្ចីពីបរទេស ៧០០ លានរៀល យកឥណទានពីធនាគារកណ្តាល ចំនួន ៣៥០ លានរៀល និងយកពីរតនាគារជាតិ ចំនួន ១៨៤ លានរៀល (សរុបទាំងអស់ ១.២៣៤លានរៀល) ដែលចំណូលទាំងអស់នេះ ត្រូវបានប្រើប្រាស់ សម្រាប់ការទ្រទ្រង់នូវឱនភាពថវិការដ្ឋ នៅក្នុងឆ្នាំនោះ។

ចំពោះអត្រាប្តូរប្រាក់ មុនថ្ងៃទី ១៨ ខែសីហា ឆ្នាំ ១៩៦៩ លុយ រៀលមានតម្លៃដូចខាងក្រោមនេះ ៖

- ៣៥ រៀល = ១ ដុល្លារ អាមេរិក
- ៨៤ រៀល = ១តោន
- ១០ រៀល = ១ ហ្វ្រង់បារាំង
- ១ រៀល = ២៥.៣៩០៥ មីលីក្រាមមាសសុទ្ធ។

### វិស័យឧស្សាហកម្មទេសចរណ៍

ការរីកលូតលាស់នៃវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ គឺមានការទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងការរីកចម្រើន ខាងផ្លូវគមនាគមន៍។ តំបន់ទំនាប ដែលបានរីកចម្រើនជាយូរមកហើយនោះ គឺមានផ្លូវថ្នល់ ផ្លូវទឹក និងផ្លូវដែកច្រើនគួរសម។ ឯតំបន់ខ្ពស់វិញ គេពុំសូវបានទៅ

ដល់នោះទេព្រោះកន្លែងខ្លះ មានតែផ្លូវដើសម្រាប់ទាក់ទងគ្នាតែប៉ុណ្ណោះ ដែលជាបញ្ហាប្រឈមចំពោះវិស័យទេសចរណ៍។ នៅសម័យនោះ មានភ្ញៀវទេសចរអន្តរជាតិបានចូលមកទស្សនា នៅកម្ពុជារាប់ពាន់នាក់ក្នុងមួយឆ្នាំៗ ជាពិសេសនៅ តំបន់ប្រាសាទអង្គរវត្ត។ សម្រាប់ការស្នាក់នៅ យើងមានផ្ទះសំណាក់នៅគ្រប់ខេត្ត-ក្រុង នៅទូទាំងប្រទេស ចំណែកឯសណ្ឋាគារវិញ ក៏បានសាងសង់ឡើងច្រើនគួរសមដែរ ដែលមាននៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្ត-ក្រុងធំៗ ប៉ុណ្ណោះ។ យើងពុំមានឯកសារគ្រប់គ្រាន់ដែលបញ្ជាក់អំពីចំនួនភ្ញៀវទេសចរអន្តរជាតិដែលបានមកទស្សនាកំសាន្តនៅក្នុងប្រទេសកម្ពុជាឡើយ។

## ៦.៤. វិស័យសិក្សាធិការជាតិ

នៅសម័យអាណានិគមនិយមបារាំង ពេលដែលសម្តេចប្រមុខរដ្ឋ នរោត្តម សីហនុ បានឡើងសោយរាជ្យសម្បត្តិ នាឆ្នាំ ១៩៤១ ប្រទេសកម្ពុជាយើង មានសាលាមធ្យមសិក្សាតែមួយគត់គឺ វិទ្យាល័យព្រះស៊ីសុវត្ថិនៅភ្នំពេញ។ [137]

ដោយឡែកអនុវិទ្យាល័យបាត់ដំបង ត្រូវបានសៀមបិទចោល តាំងពីសម័យសៀមបានកាន់កាប់ ក្នុងដំណាក់កាលសង្គ្រាមលោកលើក ទី ២ ដោយមានជំនួយពីពួកជប៉ុន។ តែសំណាងល្អ ដែនដីនេះ ត្រូវបានវិលត្រលប់មកជារបស់កម្ពុជាយើងវិញនៅក្នុងរជ្ជកាលសម្តេចព្រះប្រមុខរដ្ឋនរោត្តម សីហនុ ឆ្នាំ ១៩៤៧។

នៅឆ្នាំ១៩៤២ បារាំងបានផ្តល់ជូននូវថវិកាដល់សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ នូវទឹកប្រាក់មួយចំនួន ដើម្បីថ្វាយព្រះអង្គ សម្រាប់ស្ថានា ព្រះរាជដំណាក់មួយនៅភ្នំបូកគោ មានទាំងអាងហែលទឹកផងដែរ។ ប៉ុន្តែសម្តេចព្រះប្រមុខរដ្ឋបានសម្រេចយកទឹកប្រាក់ទាំងអស់នោះទៅសាងសង់វិទ្យាល័យមួយជូនមាតុភូមិយើងនៅខេត្តកំពង់ចាម។ ទន្ទឹមនឹងនោះ នៅក្នុងសម័យអាណាព្យាបាលបារាំង យើងមានវិទ្យាល័យទី ២ មួយទៀត ដែលជាស្នាដៃរបស់សម្តេចព្រះប្រមុខរដ្ឋ ហើយវិទ្យាល័យនោះមានឈ្មោះថា សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ។[138]

ក្រោយពីទទួលបានឯករាជ្យរាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយម បានយកចិត្តទុកដាក់ជាចម្បងទៅលើវិស័យសិក្សាធិការជាតិមុន គេបង្អស់។ ជាពិសេស រាជរដ្ឋាភិបាលបានធ្វើការស្ថាបនានូវអគារសិក្សា តាំងពីថ្នាក់បឋមសិក្សា រហូតដល់សាកលវិទ្យាល័យ ដើម្បីបង្កើនលទ្ធភាពអោយមានការសិក្សានៅគ្រប់តំបន់នានា ក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងតំបន់ព្រៃភ្នំនៃខេត្តមួយចំនួនផង ដូចជាខេត្តកំពង់ស្ពឺ មណ្ឌលគីរី រតនៈគីរី ស្ទឹងត្រែង និងឧត្តរមានជ័យ ជាដើម។ វិស័យសិក្សាធិការអប់រំជាតិសាធារណៈ មានការរីកចម្រើនលូតលាស់យ៉ាងខ្លាំងក្លា ចន្លោះឆ្នាំ ១៩៥៥ ដល់ ១៩៦៩ ពោលគឺសម័យ សង្គមរាស្ត្រនិយម។ ទិន្នន័យខាងក្រោមនេះ បានបញ្ជាក់នូវភាពរីកចម្រើនដែលជាស្នាដៃរបស់ប្រជា
រាស្ត្រខ្មែរ របស់ព្រះសង្ឃ និងរបស់រដ្ឋាភិបាលខ្មែរជំនាន់នោះ ដែលលោកបានចំណាយថវិកាជាតិយ៉ាងច្រើន សន្ធឹកសន្ធាប់ សម្រាប់វិស័យសិក្សាធិការជាតិ ដែលមានទំហំច្រើនជាង ថវិកាក្នុងវិស័យការពារប្រទេសទៅទៀត។ មាគ៌ានយោបាយពង្រីកការ សិក្សាអប់រំជាតិបែបនេះ គឺជាករណីដ៏ពិសេសមួយ នៅលើពិភពលោក នេះ។

ឆ្លើយតបទៅនឹងពត៌មាន ជុំវិញវិស័យសិក្សាធិការជាតិ យើងមានមូលដ្ឋានទិន្នន័យមួយចំនួនដែលជាភស្តុតាងបញ្ជាក់អំពី ការរីកចម្រើនលូតលាស់របស់វិស័យនេះ តាមរយៈតារាងដែលយើង ខាងក្រោម។

| បរិយាយ | ឆ្នាំ ១៩៥៥ | ឆ្នាំ ១៩៦៨ |
|---|---|---|
| ចំនួនសាលាបឋមសិក្សា | ២.៧៣១ | ៥.៨៥៧ |

| | | |
|---|---|---|
| **ចំនួនសិស្ស** | ៣១១.០០០ នាក់ | ១.០២៥.០០០ នាក់ |
| **ចំនួនអនុវិទ្យាល័យ វិទ្យាល័យ** | ១២ | ១៨០ |
| **ចំនួនសិស្ស** | ៥.៣០០ នាក់ | ១១៧.០០០ នាក់ |
| **ចំនួនសាលាបច្ចេកទេស** | ៥ | ៩៩ |
| **ចំនួនសិស្ស** | ៣៣៤ នាក់ | ៧.៤០០ នាក់ |
| **ចំនួនសាកលវិទ្យាល័យ** | ០ | ៩ |
| **ចំនួនមហាវិទ្យាល័យ** | ២ | ៤៨ |
| **ចំនួននិស្សិត** | ៣៤៧ នាក់ | ១០.៨០០ នាក់ |

*ទិន្នន័យគ្រឹះស្ថានសិក្សាជាតិ និងចំនួនសិស្ស និស្សិត*

នៅឆ្នាំ ១៩៦៩ យើងមានសាកលវិទ្យាល័យចំនួន ៩ គឺ ៖

- សាកលវិទ្យាល័យភូមិន្ទ
- សាកលវិទ្យាល័យសង្គមរាស្ត្រនិយម
- សាកលវិទ្យាល័យបច្ចេកទេសភូមិន្ទ(មិត្តភាពខ្មែរ-សូវៀត)
- សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- សាកលវិទ្យាល័យភូមិន្ទកេត្យវិទ្យា
- សាកលវិទ្យាល័យប្រជារាស្ត្រ និងពុទ្ធិកសាកលវិទ្យាល័យ
- សាកលវិទ្យាល័យភូមិន្ទបាត់ដំបង សាកលវិទ្យាល័យភូមិន្ទកំពង់ចាម
- សាកលវិទ្យាល័យកំពត-តាកែវ (ក្បែរភ្នំនរាយណ៍)។

សាកលវិទ្យាល័យសង្គមរាស្ត្រនិយមមាន៣មហាវិទ្យាល័យគឺ៖

- មហាវិទ្យាល័យអក្សរសាស្ត្រ និងវិទ្យាសាស្ត្រមនុស្សជាតិ
- មហាវិទ្យាល័យវិទ្យាសាស្ត្រពិត
- មហាវិទ្យាល័យឱសថសាស្ត្រ។

សាលកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានស្ថាបនាឡើងនៅឆ្នាំ ១៩៦៥ មាន ៥ មហាវិទ្យាល័យ គឺ[1]

- មហាវិទ្យាល័យសិល្បៈ និងបុរាណវត្ថុ
- មហាវិទ្យាល័យស្ថាបត្យកម្ម និងនគរូបនីយកម្ម
- មហាវិទ្យាល័យសិល្បៈ ចំលាក់គំនូរ
- មហាវិទ្យាល័យសិល្បៈនៃវិនាដកម្ម និងរបាំ

139 អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជាសង្គមរាស្ត្រនិយម សិក្សាធិការទំព័រ ១៩២

- មហាវិទ្យាល័យតន្ត្រី

សាកលវិទ្យាល័យក្សេត្រសាស្ត្រភូមិន្ទមាន ៦មហាវិទ្យាល័យគឺ

- មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម
- មហាវិទ្យាល័យវិទ្យាសាស្ត្ររុក្ខកម្ម (ព្រៃឈើ)
- មហាវិទ្យាល័យវិទ្យាសាស្ត្របសិកម្ម (បសុព្យាបាល)
- មហាវិទ្យាល័យវិទ្យាសាស្ត្រមច្ឆវប្បកម្ម
- មហាវិទ្យាល័យជនបទស្ថាបនា
- មហាវិទ្យាល័យសង្គមវិទ្យា និងសេដ្ឋកិច្ចជនបទ។

សាកលវិទ្យាល័យភូមិន្ទកំពង់ចាមបានសម្ភោធនៅឆ្នាំ ១៩៦៥ មាន ៣ មហាវិទ្យាល័យគឺ

- មហាវិទ្យាល័យមេកានិក
- មហាវិទ្យាល័យកសិកម្មប្រទេសក្តៅ
- មហាវិទ្យាល័យវិទ្យាសាស្ត្ររូបនិយម - គណិតសាស្ត្រ។

សាកលវិទ្យាល័យភូមិន្ទបាត់ដំបងមាន ៣ មហាវិទ្យាល័យគឺ

- មហាវិទ្យាល័យឧស្សាហកម្ម - កសិកម្ម និងម្ហូបអាហារ
- មហាវិទ្យាល័យភូតព្ភសាស្ត្រអនុវត្ត និងស្រាវជ្រាវអណ្តូងរ៉ែ
- មហាវិទ្យាល័យស្ថាបនាយន្តសាស្ត្រ។

សាកលវិទ្យាល័ប្រជារាស្ត្រមាន៦មហាវិទ្យាល័យគឺ

- មហាវិទ្យាល័យបេតុងអាមេ
- មហាវិទ្យាល័យសំណង់បាយអរ
- មហាវិទ្យាល័យអគ្គិសនី
- មហាវិទ្យាល័យកិច្ចការជាងសំណ និងដែកបន្ទះ
- មហាវិទ្យាល័យគ្រឿងយន្តការដ្ឋាន
- មហាវិទ្យាល័យយន្តកម្ម និងមានសាកលវិទ្យាល័យចំនួន ០៣ ទៀតដែលយើងមិនបានរៀបរាប់បន្ថែមអោយបានពិស្តារ។

នៅក្នុងសកម្មភាពសិក្សា យើងមានកម្មសិក្សា (ហាត់ការ) បង្កើនចំណេះដឹងផ្នែកការអនុវត្តបន្ថែមទៀត សម្រាប់កម្មករមកពីសហគ្រាសរដ្ឋ ឬឯកជនក្នុងរយៈពេលពី ២ ទៅ ៨ ខែ។ កម្មសិក្សានេះធ្វើឡើងគឺដើម្បីអោយកម្មករខ្លះទទួលបាននូវបទពិសោធន៍ជាក់ស្តែងក្នុងការងារ ហើយអាចនឹងបន្តការបណ្តុះបណ្តាលវិជ្ជាជាន់ខ្ពស់បានថែមទៀត ។

នៅសម័យសង្គមរាស្ត្រនិយមទទួលបានជោគជ័យយ៉ាងខ្លាំង ទាំងផ្នែកបរិមាណ និងគុណភាពអប់រំជាពិសេស គុណភាពនៃការ បង្ហាត់បង្រៀន និងឧបករណ៍សិក្សាផ្សេងទៀត គុណភាពនៃការជ្រើសរើស និងអប់រំហ្វឹកហ្វឺនគ្រូបង្រៀន និងសាស្ត្រាចារ្យខ្មែរជាមួយនឹង ការយកចិត្តទុកដាក់ផ្តល់ប្រាក់បៀវត្សខ្ពស់ ប្រាក់បំណាច់ និងការឧបត្ថម្ភជាសម្ភារៈផ្សេងៗទៀត។ ទន្ទឹមនឹងនេះ យើងក៏បានអញ្ជើញអ្នកជំនាញការបរទេស (ជាពិសេសជំនាញការបារាំង) ជាសាស្ត្រាចារ្យ ឬជាមេប្រយោគ ដើម្បីជួយ

លើកកម្ពស់គុណភាពប្រពន្ធ័អប់រំជាតិយើង អោយបានប្រហាក់ប្រហែលទៅនឹងថ្នាក់អន្តរជាតិ។ ហើយគុណភាពសញ្ញាបត្រ ឧត្តមសិក្សាសម្រាប់ថ្នាក់បណ្ឌិតវិទ្យាសាស្ត្រជាដើម អោយមានតម្លៃស្មើគ្នានឹងសញ្ញាបត្រឧត្តមសិក្សា នៃសាកលវិទ្យាល័យនៅប្រទេសបារាំង។

ក្នុងការតស៊ូកំចាត់អនក្ខរកម្ម យើងបានធ្វើអោយចំនួនអនក្ខរជនមជ្ឈិមវ័យ បានចុះថយមកត្រឹមតែ ២០% នៃប្រជារាស្ត្រកម្ពុជាទាំងមូល។ ហើយនៅជំនាន់នោះមាតុភូមិយើងបានទទួលពីអង្គការយូណេស្កូ នូវពានរង្វាន់ពី ព្រះចៅអៀរ៉ង់ ដែលជាពានរង្វាន់សម្រាប់ប្រគល់ជូនចំពោះប្រទេសណាដែលបានខិតខំប្រឹងប្រែងលុបបំបាត់អនក្ខរកម្ម ក្នុងបណ្តាប្រជានុរាស្ត្ររបស់ខ្លួន ។

ចំពោះវិស័យកីឡានិងអត្តពលកម្មវិញ នាសម័យសង្គមរាស្ត្រនិយមក៏ទទួលបានជោគជ័យគួរអោយកត់សម្គាល់ផងដែរជាពិសេស ក្នុងកំឡុងឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៦៩ ដោយបានលើកទង់ជាតិរបស់កម្ពុជា អោយឡើងស្មើនឹងបណ្តាប្រទេសនានា ដែលល្បីឈ្មោះខាងកីឡា និងអត្តពលកម្ម នៅភូមិភាគអាស៊ីអាគ្នេយ៍ និងក្នុងតតិយលោក។

យើងបានសាងសង់នៅរាជធានីភ្នំពេញនូវពហុកីឡាដ្ឋានជាតិ ដ៏ល្អប្រណិតមួយ ដែលធ្វើអោយប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនធំ ក្នុងទសវត្សទី៦០ ប៉ងប្រាថ្នាចង់បានដូចយើងដែរ។ ហើយពហុកីឡាដ្ឋានជាតិនេះ អាចទទួលកីឡាករបាន ៦០.០០០នាក់ និងទទួលអ្នកទស្សនាបានជាង ៨០.០០០នាក់ វេទិកាកិត្តិយសដែលមានចំណុះ ៤.០០០នាក់ និងវិមានកីឡាដែលមានចំណុះ ៦.០០០នាក់ ដែលមានទំហំ ៧២ ម៉ែត្របួនជ្រុង។ [140] ក្រៅពីនេះ នៅមានអាងហែលទឹកអូឡាំពិចមួយទៀត ដែល មានវេទិកាចំណុះ ៤.០០០នាក់ មានគ្រឹះស្ថានសម្រាប់ហាត់ហ្វឹកហ្វឺន មានទីលានតេនីសទីលានបាល់បោះ និងទីលានបាល់ទះទៀតផង។

មិនតែប៉ុណ្ណោះ យើងបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំការប្រកួតជាអន្តរជាតិ ដែលហៅថាកីឡាហ្គាណេហ្វូអាស៊ី លើកទី១ នៅថ្ងៃទី ២៦ វិច្ឆិកា ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៦៦ ហើយក៏បានរៀបចំនិងសាងសង់ ឡើងនូវភូមិកីឡាអន្តរជាតិសម្រាប់ទទួលគណៈប្រតិភូចំនួន ១.០០០ នាក់ ក្នុងការស្នាក់អាស្រ័យ ពេលប្រកួតកីឡា កីឡាហ្គាណេហ្វូអាស៊ីលើកទី១ ផងដែរ។

ខាងក្រោមនេះ គឺជាទិន្នន័យសំខាន់ៗ ទាក់ទងនឹងមណ្ឌលកីឡា និងកន្លែងហាត់កីឡា និងកន្លែងប្រកួតកីឡា ដែលបានស្ថាបនាឡើងចន្លោះឆ្នាំ ១៩៥៥ ដល់ឆ្នាំ១៩៦៨។

| កីឡា | ឆ្នាំ ១៩៥៥ | ឆ្នាំ ១៩៦៨ |
|---|---|---|
| ពហុកីឡាដ្ឋាន ថ្នាក់អន្តរជាតិ | ០ | ១ |
| បូរីកីឡាថ្នាក់អន្តរជាតិ | ០ | ១ |
| កីឡាដ្ឋាន | ១ | ៤០ |
| ទីលានបាល់ទាត់ | ១៥ | ៥១៤ |
| ទីលានបាល់បោះ | ២០ | ៥៨៥ |
| ទីលានបាល់ទះ | ១០ | ១.២៣៦ |
| ទីលានវាយសី | ០ | ២៩៦ |

| | | |
|---|---|---|
| ទីលានតេននីស | ៩ | ៦០ |
| ក្លឹមវាយកូនឃ្លីលើតុ(ប៉េងប៉ុង) | ១២ | ៣១០ |
| សៃវានប្រដាល់ | ១ | ៩ |
| សាលចំបាប់ហ្វឺដូ | ១ | ១៣ |
| ទីលានបាញ់ប្រកួត | ០ | ២ |
| ក្លឹបហែលទឹក | ០ | ១១ |
| អាងសម្រាប់ហែលប្រណាំង | ២ | ៥ |

*ទិន្នន័យនៃការរីកចម្រើនកីឡាដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា*

រីឯលទ្ធផលនៃការចូលរួមប្រកួតប្រជែងផ្នែកកីឡា និងអត្តពលកម្មរបស់កម្ពុជាលើឆាកអន្តរជាតិ កីឡាករកម្ពុជាយើងសម័យនោះ ត្រូវបានបណ្តាប្រទេសនៅភូមិភាគអាស៊ីអាគ្នេយ៍ចាត់ទុកថា ជាប្រទេសខ្លាំងពូកែ និងជាគូប្រជែងដ៏គួរអោយស្ញប់ស្ញែង។ ការប្រកួតកីឡានៃបណ្តាប្រទេសនៅភូមិភាគអាស៊ីអាគ្នេយ៍ និងក្នុងតំបន់ប៉ាស៊ីហ្វិក កម្ពុជាយើងក្នុងប្រទេសតតិយលោកដូចគ្នា ដណ្តើមបានមេដាយមាស មេដាយប្រាក់ និងមេដាយសំរិទ្ធិ បានយ៉ាងសន្ធឹកសន្ធាប់នៅរាល់ពេលដែលមានការប្រកួត ជាពិសេស ខាងកីឡា តេននីស កីឡាហែលទឹក កីឡាប្រដាល់ និងអត្តពលកម្ម។ នៅក្នុ ពេលប្រកួតកីឡាអន្តរជាតិ សម្រាប់បណ្តាប្រទេសដែលជាកម្លាំងថ្មី កីឡាករកម្ពុជាយើងបានទទួលមេដាយមាសចំនួន ១៣ និងជាប់ចំណាត់ថ្នាក់លេខ ៣ បន្ទាប់ពីសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ហើយបានឈ្នះលើប្រទេស ២៦ ទៀត។

## ៦.៥. វិស័យសុខាភិបាលសាធារណៈ

នៅសម័យសង្គមរាស្ត្រនិយម រាជរដ្ឋាភិបាលបានខិតខំយ៉ាងខ្លាំងក្នុងការអនុវត្តនូវមាគ៌ានយោបាយរាស្ត្រនិយម តាមគម្រូនៃព្រះបាទជ័យវរ្ម័នទី៧ ដែលជាព្រះមហាក្សត្រមួយអង្គ និយមព្រះពុទ្ធសាសនា។ មាគ៌ានយោបាយនេះហើយដែលធ្វើអោយមានការរីកចម្រើននូវវិស័យ សុខាភិបាលសាធារណៈ វិស័យសិក្សាធិការជាតិ វិស័យគមនាគមន៍ និងនយោបាយទឹក (ការបញ្ចូលទឹកក្នុងស្រែ-ចម្ការ)។

141 អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជាសង្គមរាស្ត្រនិយម សិក្សាធិការទំព័រ ១២

វិស័យសុខាភិបាលសាធារណៈ គឺជាសុខុមាលភាពរបស់ជាតិរបស់ប្រជារាស្ត្រ និងរបស់ប្រជាជាតិខ្មែរទាំងមូល។ នៅគ្រប់មជ្ឈដ្ឋានទាំងអស់ រដ្ឋាភិបាលបានសាងសង់មន្ទីរពេទ្យ មណ្ឌលសុខភាព និង បណ្តុះបណ្តាលគ្រូពេទ្យ វេជ្ជបណ្ឌិតគ្រប់ជំនាញ ដើម្បីបម្រើការងារជូនប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈដោយគ្មានការរើសអើង។ ទោះបីជា នៅតាមទីជនបទដាច់ស្រយាលក៏មានគ្រូពេទ្យ បានចុះទៅពិនិត្យព្យាបាល អ្នកជម្ងឺដល់មនុស្សក្មេង ចាស់ គ្រប់វ័យទៀតផង។

មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត គឺជាមន្ទីរពេទ្យដែលធំជាងគេនៅអាស៊ីអាគ្នេយ៍ ដែលមានគ្រែសម្រាប់អ្នកជម្ងឺ ចំនួន ៥០០ គ្រែ។

| បរិយាយ | ឆ្នាំ ១៩៥៥ | ឆ្នាំ ១៩៦៨ |
|---|---|---|
| មន្ទីរពេទ្យ និងមណ្ឌលសុខភាព | ១៦ | ៥៩ |
| គិលានដ្ឋាន ឱសថកាល័យ មន្ទីរគ្លីនិក មន្ទីរសម្ភព | ១០៣ | ៥៥៣ |
| ចំនួនគ្រែ សម្រាប់អ្នកជម្ងឺ | ២.៤៤៥ | ៦.៥២៥ |
| មន្ទីរសម្ភពនៅតាមជនបទ | ៦០ | ៧៦៨ |
| ឱសថស្ថាន និងឱសថកាល័យ | ២៤ | ៣៨៥ |
| វេជ្ជបណ្ឌិត និងមន្ត្រីសុខាភិបាល | ៧៧ | ៤៤០ |
| ឱសថការី | ៤ | ៧៧ |
| ពេទ្យធ្មេញ | ៣ | ៤០ |
| ពេទ្យធ្មប | ១២៥ | ១.១០៥ |
| អធិការសុខាភិបាល | ០ | ៤៤២ |

*ទិន្នន័យនៃការរីកចម្រើនវិស័យសុខាភិបាលនៅកម្ពុជា*[142]

នៅឆ្នាំ ១៩៥៥ ចំនួនគ្រូពេទ្យមានប្រមាណជា ៧៧នាក់ និងពេទ្យធ្មេញ ៣នាក់ សម្រាប់ប្រជាជនទូទាំងប្រទេស។ រយៈពេល ១៣ឆ្នាំ ក្រោយមក គឺនៅឆ្នាំ១៩៦៨ ចំនួនគ្រូពេទ្យបានកើនឡើងដល់ ៤៤០នាក់ ឱសថការី ៧៧ នាក់ និង ពេទ្យធ្មេញ ៤០ នាក់ ហើយបានបំពេញ ការងារនៅតាមបណ្ដាខេត្តនានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងមូល។ ចំនួនគិលានុបដ្ឋាក គិលានុបដ្ឋាយិការ ធ្មប និងអ្នកជំនួយការនានា ព្រមទាំងមន្ទីរពេទ្យ និងឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត សម្រាប់មន្ទីរពេទ្យក៏បានកើនឡើងយ៉ាងច្រើនផងដែរ។

មិនតែប៉ុណ្ណោះក៏មានមន្ទីរពិសោធន៍ ការផលិតថ្នាំពេទ្យរបស់កងខេមរភូមិន្ទដែរ ហើយមន្ទីរពិសោធន៍នេះ ស្ថិតនៅក្នុងមន្ទីរពេទ្យឃោជាព្រះបាទមុនីវង្ស។ ក្រៅពីនេះវិទ្យាស្ថានប៉ាស្ទ័រនៃកម្ពុជាបានផលិតថ្នាំបង្ការរោគសម្រាប់មនុស្ស និងសត្វនៅទូទាំងប្រទេស ហើយវិទ្យាស្ថាននេះអាចផលិតថ្នាំបង្ការរោគរាតត្បាតសម្រាប់មនុស្ស ២០០.០០០នាក់ក្នុងមួយថ្ងៃ។ ថ្នាំទាំងនោះត្រូវបានរក្សាទុកនៅក្នុងទូត្លាសេមួយលានដូសជាប្រចាំ សម្រាប់បង្ការជម្ងឺអាសន្នរោគ ដែលអាចយកមកប្រើបានភ្លាមៗ នៅពេលមានគ្រាអាសន្ន។ ជាពិសេសទៅទៀតនោះ ចំនួនគិលានុបដ្ឋាន បានពង្រីកស្ទើរតែគ្រប់ ឃុំ សង្កាត់

[142] អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជាសង្គមរាស្ត្រនិយម សុខាភិបាលទំព័រ ៣

ទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។ ហើយប្រជារាស្ត្រទូទៅ ដែលត្រូវសំរាលកូន ត្រូវបានទទួលសម្រាកព្យាបាលដោយឥតគិតថ្លៃ នៅក្នុងមជ្ឈមណ្ឌលសុខភាព ឬនៅក្នុងគិលានុបដ្ឋាន។

បុគ្គលិកសុខាភិបាល ក៏ដូចជាមន្ត្រីរាជការទូទាំងប្រទេសដែរ បានយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវភាពថ្លៃថ្នូរជានិច្ច ហើយខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដោយបានចែកគ្នាជាក្រុមចុះទៅតាមភូមិ ឃុំ និងនៅតាមសាលារៀនដើម្បី ចាក់ថ្នាំការពារជម្ងឺឆ្លងគ្រប់ប្រភេទ។ ពេលចុះពិនិត្យ បើគេសង្ស័យថា ពលរដ្ឋណាមួយមានជម្ងឺរបេង ក្រុមបុគ្គលិកពេទ្យទាំងនោះ បានបញ្ជូន អ្នកជម្ងឺមកពិនិត្យសួតតាមវិទ្យុសកម្មនៅតាមមន្ទីរពេទ្យខេត្តក្រុងភ្លាមៗ។

រីឯ ឱសថស្ថាន និងការផ្គត់ផ្គង់ឱសថវិញ គេឃើញមានការផលិតសេរ៉ូមផ្អែម និងប្រៃ ព្រមទាំងផលិតថ្នាំលេប ថ្នាំលាបជាច្រើនប្រភេទ ហើយការផលិតនេះ ភាគច្រើនបានប្រើប្រាស់វត្ថុធាតុដើមនៅក្នុងស្រុក។ ហើយផលិតផលឱសថបានកើនឡើងជាបន្តបន្ទាប់ ជាក់ស្តែងនៅឆ្នាំ ១៩៦៤ ផលិតបានថ្នាំចាក់ចំនួន ១.៥០០.០០០ អំពូល ឆ្នាំ ១៩៦៥ ផលិតបាន ២.០០០.០០០ អំពូល និងនៅឆ្នាំ ១៩៦៦ យើងផលិតបានចំនួន ៤.០០០.០០០ អំពូល។

ចំណែកឯសេរ៉ូមវិញ នៅឆ្នាំ១៩៦៤ ផលិតបាន ២០.០០០ ដប នៅឆ្នាំ ១៩៦៥ ផលិតបាន ២៣.០០០ ដប ហើយនៅឆ្នាំ១៩៦៦ ផលិត បាន ២៨.០០០ ដប ដែលបរិមាណទាំងនេះអាចបម្រើសេចក្តីត្រូវការរបស់មន្ទីរពេទ្យទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ការរីកចម្រើនផ្នែកឱសថស្ថានបានផ្គត់ផ្គង់ថ្នាំពេទ្យ នៃព្រះរាជាណាចក្រកម្ពុជាកម្ពុជា សមស្របទៅនឹង ការរីកចម្រើនលូតលាស់ទូទាំងប្រទេស ហើយការរីកចម្រើននេះបានរួមវិភាគទានយ៉ាងធំធេងដល់ការបង្កើនកម្លាំង និងធនជានមនុស្សនៅកម្ពុជា ដែលជាកត្តាសំខាន់បំផុតនៃការអភិវឌ្ឍប្រទេស
ជាតិ។

## ៦.៦. វិស័យសង្គមកិច្ច

នៅសម័យសង្គមរាស្ត្រនិយម ក្នុងក្រមខណ្ឌនយោបាយជួយសង្គ្រោះជនក្រីក្រ ជនពិកាពីកំណើត កុមារដែលជួបប្រទះនឹងវិបត្តិខាងផ្លូវចិត្ត កុមារដែលគេបោះបង់ចោល កុមារកំព្រាឪពុកម្តាយ សម្តេចព្រះប្រមុខរដ្ឋ បានសង់សមិទ្ធិផលសង្គម ជួយសង្គ្រោះកុមារទាំងនោះយ៉ាងច្រើន។ ក្នុងសមិទ្ធិផលទាំងនេះមាន មជ្ឈមណ្ឌលកុមារសង្គ្រោះព្រះសីហនុ កំបូលនៅចំងាយ ២០ គ.ម ពីភ្នំពេញស្ថិតជាប់ផ្លូវជាតិលេខ៥ ដែលសម្តេចព្រះប្រមុខរដ្ឋបានសម្ពោធ នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៦១ និងសង្គមមណ្ឌលព្រះសីហនុ ដែលស្ថិតនៅមហាវិថីព្រះមុន្នីវង្ស សង្កាត់ចំការមន ជាមជ្ឈមណ្ឌលទទួលកុមារកំព្រារ និងមនុស្សពិការខ្វាក់ខ្វិន មនុស្សចាស់ជរាក្រីក្រគ្មានទីលំនៅ ដែលបានសម្ពោធ នៅថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៦៩។

សម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ទ្រង់សព្វព្រះរាជហឫទ័យ ជួយប្រជារាស្ត្រទូទៅផ្នែកសង្គមកិច្ចផងដែរ ជាក់ស្តែងសម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ទ្រង់សព្វព្រះរាជហឫទ័យសង់ផ្ទះចំនួន ៥ខ្នង ប្រទានប្រជារាស្ត្រក្រីក្រជាងគេនៅភូមិ វ៉ែស ក្នុងខេត្តកំពង់ស្ពឺ។

លើសពីនេះទៅទៀត សម្តេចព្រះប្រមុខរដ្ឋទ្រង់សព្វព្រះហឫទ័យ ប្រទានមណ្ឌលកុមារសង្គ្រោះនៅកោះទន្សាយ និងនៅសិតបូ។ ហើយទ្រង់សព្វព្រះរាជហឫទ័យ ក៏មានកសាងភូមិមួយនៅខេត្តស្វាយរៀង សម្រាប់ប្រជារាស្ត្រ ដែលរងគ្រោះដោយសង្គ្រាម។ ក្រៅពីនេះ នៅតាមក្រសួងមន្ទីរមួយចំនួន ក៏មានមណ្ឌលសម្រាប់សម្រាកលំហែរកាយដែរ ដូចជាមណ្ឌលសម្រាកលំហែរកាយរបស់បុគ្គលិកធនាគារជាតិ កម្ពុជាដើម្បីសម្រាកលំហែរកាយ។

មិនតែប៉ុណ្ណោះ នៅសម័យនោះ ក៏បានសង់ផ្ទះសំណាក់សម្រាប់ មន្ត្រីរាជការចាស់ៗដែលមានធនធានតិចតួចអាចមកសម្រាកកាយជាលក្ខណៈគ្រួសារបានម្តងម្នាក់ៗ នៅស្ថានីយ៍សំណាក់លើភ្នំគីរីរម្យក្នុងព្រៃ ដ៏ស្រស់ប្រកបដោយខ្យល់អាកាសល្អ ដែលការសាងសង់នេះ គឺបានចំណាយថវិកាអស់ជិត៤លានរៀល ដែលមានផ្ទះ ៣២ខ្នងដូចៗគ្នាមាន គ្រឿងតុ ទូ គ្រែ មាន ទឹក ភ្លើងអគ្គិសនី សម្រាប់អ្នកចូលនិវត្តន៍ទាំងឡាយណា ដែលមានបំណងចង់មកលំហែរកាយដោយរីករាយ។ គ្រួសារនីមួយៗអាចឈប់សម្រាប់នៅទីនោះបាន ២សប្តាហ៍ដោយឥតគិតថ្លៃ។ អធិការនៃក្រសួងសង្គមកិច្ចជាអ្នកសម្រេច និងអនុញ្ញាតអោយមកឈប់សម្រាកនៅក្នុងមណ្ឌលនេះបាន ក្រោយពីគ្រូពេទ្យធ្វើការអង្កេតសុខភាព និងសម្រេច។

## ៦.៧. សេចក្តីសន្និដ្ឋាន

ការសិក្សាអំពីប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា នាសម័យសង្គមរាស្ត្រនិយម នាឆ្នាំ ១៩៥៣ ដល់ ១៩៧០ យើងអាចធ្វើសេចក្តីសន្និដ្ឋាន ទៅលើសមិទ្ធិផលនានា ដែលស្ថាបនាឡើងក្នុងវិស័យសេដ្ឋកិច្ច-សង្គម សំខាន់ៗទាំងអស់ ដែលមានដូចខាងក្រោមនេះ ៖

សម័យនោះ ក្នុងការអភិវឌ្ឍវិស័យកសិកម្ម ប្រទេសកម្ពុជា យើងបានបង្កើតអង្គការ សហករណ៍កសិកម្ម ដែលមានការចូលរួមប្រជាកសិករគ្រប់ស្រទាប់វណ្ណៈនៅជនបទ ហើយអង្គការនេះមានសិទ្ធិទទួលបាននូវប្រាក់ឥណទានពីធនាគារកណ្តាលរបស់រដ្ឋ (៤០០ លានរៀល) នៅឆ្នាំ ១៩៦៨។ ចំពោះដំណាំសំខាន់ៗ ដែលបានដាំដុះនៅសម័យនោះ គឺមានដំណាំស្រូវ ដែលបានដាំដុះលើផ្ទៃដីប្រមាណជា ២,៤ លានហិកតា ហើយទទួលបានទិន្នផលរហូតដល់ ៣,២ លានតោន ដែលគិតជាមធ្យមគឺ ១,៣ តោន/ហិកតា (ប្រហែល ៤៥៧ គ.ក/ម្នាក់)។ ក្រៅពីនោះ យើងមានដំណាំពោត (១០០.០០០ តោន) សណ្តែកដី (២៥.៧០០ តោន) ល្ហុងខ្មែរ (៣.០០០ តោន) ដំណាំដូង(ទម្ងន់ដូងស្ងួត ៧.០០០តោន) សណ្តែកសៀង (១០.០០០ តោន) ស្ករត្នោត (៥០.០០០ តោន) ម្រេច (៦.០០០ តោន)

សណ្តែកបាយ (២០.០០០ តោន) កៅស៊ូ (៥២.០០០ តោន) កប្បាស (៦.០០០ តោន) ក្រចៅ (៦.៣០០ តោន) ថ្នាំជក់ (១៦.៣០០ តោន) និងដំណាំជាបន្លែបង្កាជាច្រើនទៀត។

ចំពោះការចិញ្ចឹមសត្វស្រុក នៅសម័យនោះ យើងឃើញមាន សត្វគោ (ចំនួន ១.៩០០.០០០ ក្បាល) ក្របី (៧០០.០០០ ក្បាល) ជ្រូក (១.១៥១.០០០ ក្បាល) បក្សី (៣.៧៣០.០០០ ក្បាល។ ក្រៅពីនោះមាន សត្វសេះ ចៀម ពពែ ដំរី ជាច្រើនពាន់ក្បាលទៀត។ រីឯអាជីវកម្មព្រៃឈើ (ផលិតផលឈើហ៊ុប ឈើកែច្នៃ អុស ធ្យូង) និងវិស័យនេសាទ (នេសាទទឹកសាប ១៥០.០០០ តោន និងនេសាទសមុទ្រ ៤៥.០០០ តោន) ក៏មានការរីកចម្រើនខ្លាំងក្លាណាស់ដែរ។

- វិស័យឧស្សាហកម្ម និងសិប្បកម្ម នៅសម័យនោះក៏មានការរីក ចម្រើនគួរអោយកត់សម្គាល់ផងដែរ។ យើងពិនិត្យឃើញថា ការស្ថាបនា រោងចក្រ សហគ្រាសគ្រប់ប្រភេទ មានដូចជាឧស្សាហកម្មអាហារ ឧស្សាហកម្មគីមី ឧស្សាហកម្មគ្រឿងយន្ត វិស័យថាមពលអគ្គិសនី

ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មឥដ្ឋ-ក្បឿង។ល។ នៅគ្រប់ទីកន្លែងនៃប្រទេសកម្ពុជាយើង។ នៅសម័យនោះយើងមានរោងចក្ររបស់រដ្ឋប្រមាណ ២៨ រោងចក្រចម្រុះ (រដ្ឋ-ឯកជន) ២៩ និងសហគ្រាស ឯកជនខ្នាតតូច និងខ្នាតមធ្យម មានរហូតដល់ ៣.៧០០ សហគ្រាស។ ចំនួនកម្មករបានកើនឡើងពី ៤០.០០០ នាក់ដល់ ៨០.០០០នាក់ ចន្លោះឆ្នាំ ១៩៥៨-១៩៦៨។

ក្រៅពីការអភិវឌ្ឍវិស័យឧស្សាហកម្មខាងលើនេះ យើងឃើញ មានការអភិវឌ្ឍវិស័យសិប្បកម្មជាច្រើនប្រភេទ ជាពិសេស សិប្បកម្ម តម្បាញសូត្រ ចម្លាក់ ត្បាញកន្ទេល ត្បាញឫស្សី ផ្តៅ ធ្វើក្អម-ឆ្នាំង។ល។ ដែលចំនួនសិប្បករគ្រាន់តែក្នុងខេត្តកណ្តាល និងតាកែវមានប្រមាណជា ២.០០០ នាក់។

- ចំពោះវិស័យសេដ្ឋកិច្ចសេវាកម្ម នៅសម័យនោះ មានការអភិវឌ្ឍខ្លាំងក្លា ជាពិសេស វិស័យគមនាគមន៍ វិស័យពាណិជ្ជកម្ម។ ទាក់ទងនឹងវិស័យគមនាគមន៍ យើងពិនិត្យឃើញថា បានសាងសង់ផ្លូវជាតិលេខ ៤ (ឆ្នាំ ១៩៥៦) ប្រវែង ២២៦ គ.ម បានស្ថាបនាផ្លូវដែក (ឆ្នាំ ១៩៦០) ពីភ្នំពេញទៅក្រុងព្រះសីហនុ កាត់តាមខេត្តកំពង់ស្ពឺ តាកែវ និងកំពត មានប្រវែង ២៧០ គ.ម បានកសាងព្រលានយន្តហោះខ្នាតអន្តរជាតិនៅខេត្តសៀមរាប (ឆ្នាំ ១៩៥៩) និងពង្រីកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (ឆ្នាំ ១៩៥៨) អោយមានទំហំខ្នាតធំជាងមុន និងងាយស្រួលចុះចត។ ក្រៅពីនោះ ក៏បានស្ថាបនាបន្ថែមទៀត នូវព្រលានយន្តហោះ វាមក្រុងព្រះសីហនុ និងបាត់ដំបង-ប៉ៃកចាន។ រីឯ សកម្មភាពដឹកជញ្ជូន តាមផ្លូវទឹកនៅកំពង់ផែភ្នំពេញ និងនៅកំពង់ផែសមុទ្ររបស់រដ្ឋ នៅក្រុងព្រះសីហនុ ក៏មានដំណើរការយ៉ាងផុសផុលផងដែរ។ នៅឆ្នាំ ១៩៦៨ កំពង់ផែអន្តរជាតិក្រុងព្រះសីហនុមានចំនួនកប៉ាល់ចេញ-ចូល បានកើនឡើងរហូតដល់ ៣២៥ គ្រឿង និងការលើកដាក់ទំនិញសរុប កើនដល់ ៧៤៧.៨៤៨ តោន។

ដោយឡែក វិស័យពាណិជ្ជកម្មវិញ ក៏មានដំណើរការលូតលាស់ខ្លាំងណាស់ដែរ។ នៅសម័យនោះ រដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ច (ឆ្នាំ១៩៦៣) ដោយបង្កើតអោយមានក្រុមហ៊ុនរដ្ឋចំនួន ២ គឺក្រុមហ៊ុនជាតិ នាំចេញ-នាំចូល (SONEXIM) និងក្រុមហ៊ុនចែកចាយទំនិញនាំចូល (SONAPRIM) ដើម្បីសម្របសម្រួលដល់វិស័យពាណិជ្ជកម្មនេះអោយកាន់តែមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ជាងមុនសម្រាប់គ្រប់ភាគីពាក់ព័ន្ធ។

- ម្យ៉ាងទៀត វិស័យសិក្សាធិការជាតិ និងវិស័យសុខាភិបាល យើងសង្កេតឃើញថា មានការរីកលូតលាស់យ៉ាងខ្លាំងក្លា ព្រោះបើយើងធ្វើ ការសិក្សាប្រៀបធៀបជាមួយនឹងសម័យអាណានិគមបារាំង យើងឃើញថា ប្រទេសកម្ពុជាយើងមានវិទ្យាល័យតែមួយប៉ុណ្ណោះ គឺវិទ្យាល័យ ព្រះស៊ីសុវត្ថិភ្នំពេញ។ ប៉ុន្តែក្រោយទទួលបានឯករាជ្យ ក្រោមការដឹក នាំរបស់ព្រះវរៈរាជព្រះបិតាឯករាជ្យ ព្រះបាទ នរោត្តម សីហនុ ប្រទេសកម្ពុជា បានកសាងនូវសាលារៀនជាច្រើន ដូចជាឆ្នាំ ១៩៥៥ យើងមានអនុវិទ្យាល័យ និងវិទ្យាល័យប្រមាណ ១២ និងនៅឆ្នាំ ១៩៦៨ បានកើនឡើងរហូតដល់ ១៨០ និងមានចំនួនសិស្សានុសិស្សចូលសិក្សា រហូតដល់ ១១៧.០០០ នាក់

ដែលនៅឆ្នាំ ១៩៥៥ មានតែ ៤.៣០០ នាក់ ប៉ុណ្ណោះ។ ជាងនេះទៅទៀត យើងមានសាលាបច្ចេកទេសចំនួន ៩៩ មានសិស្សចូលរៀន ៧.៤០០ នាក់ និងមានសាកលវិទ្យាល័យចំនួន ៩ (មាន ៤៨ មហាវិទ្យាល័យ) មាននិស្សិតចូលសិក្សាប្រមាណ ១០.៨០០ នាក់ ដែលនៅឆ្នាំ ១៩៥៥ មានសាកលវិទ្យាល័យតែ ២ប៉ុណ្ណោះ និងមាននិស្សិតតែ ៣៤៧ នាក់។ រដ្ឋបានយកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន ដោយបានផ្តល់ប្រាក់បៀវត្សយ៉ាងច្រើន។

ចំពោះវិស័យកីឡា និងអត្តពលកម្មវិញ ក៏បានទទួលជោគជ័យ គួរអោយកត់សម្គាល់ផងដែរ ជាក់ស្តែងនៅក្នុងការប្រកួតកីឡាអន្តរជាតិសម្រាប់ប្រទេសតតិយលោក កម្ពុជាយើងទទួលបានមេដាយមាស ១៣ និងជាប់ចំណាត់ថ្នាក់លេខ៣ (បន្ទាប់ពីចិន និងកូរ៉េ) និងទទួលបានជ័យជំនះយ៉ាងត្រចះត្រចង់លើប្រទេសចំនួន ២៦។

- ផ្សេងពីនេះទៀត វិស័យសុខាភិបាលសាធារណៈ ក៏មានការរីកលូតលាស់ណាស់ដែរ ព្រោះមន្ទីរពេទ្យ មណ្ឌលសុខភាព និងចំនួនវេជ្ជបណ្ឌិត ទន្តបណ្ឌិត ឱសថការី គិលានុបដ្ឋាក និងគិលានុបដ្ឋាយិការ បានកើនឡើងយ៉ាងឆាប់រហ័ស ទាំងនៅទីក្រុង រហូតដល់ទីជនបទដាច់ស្រយាល។

សរុបសេចក្តីមក យោងតាមការសិក្សាស្រាវជ្រាវជុំវិញស្ថានភាពសេដ្ឋកិច្ច និងសង្គម របស់ប្រទេសកម្ពុជា នាសម័យសង្គមរាស្ត្រនិយម យើងអាចវាយតម្លៃបានថា នៅសម័យនោះប្រទេសកម្ពុជាយើងបានកសាងឡើងនូវមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច លើគ្រប់វិស័យទាំងអស់ ដែលពីសម័យមុនៗមក (សម័យក្រោយអង្គរ និងសម័យបារាំង) មិនធ្លាប់មាន។ ពោលគឺ ការអភិវឌ្ឍសេដ្ឋកិច្ច នាសម័យសង្គមរាស្ត្រនិយម គឺជាអរិយធម៌ថ្មីទី២ ដែលបន្ថែមពីលើអរិយធម៌អង្គរដ៏រុងរឿង។

# ជំពូកទី ៧
# សេដ្ឋកិច្ចប្រទេសកម្ពុជាសម័យសាធារណៈរដ្ឋខ្មែរ ឆ្នាំ ១៩៧០ - ១៩៧៥

## ៧.១. ស្ថានភាពនយោបាយ

ព្រឹត្តិការណ៍នយោបាយដ៏សំខាន់បំផុត ដែលបានកើតមានឡើង ក្នុងសម័យសាធារណៈរដ្ឋខ្មែរ គឺទាក់ទងទៅនឹងការធ្វើរដ្ឋប្រហារទម្លាក់ ព្រះបាទសម្តេច នរោត្តម សីហនុ ពីតំណែងព្រះប្រមុខរដ្ឋ ខណៈពេលដែលព្រះអង្គ បានយាងចេញទៅបំពេញព្រះរាជកិច្ច ទស្សនៈកិច្ចជាផ្លូវរដ្ឋនៅទីក្រុងម៉ូស្គូ (រដ្ឋធានីអតីតសហភាពសូវៀត)។ ហើយព្រឹត្តិការណ៍ សំខាន់មួយទៀតគឺទាក់ទងទៅនឹងការផ្លាស់ប្តូររបបគ្រប់គ្រងនយោបាយរបស់ប្រទេសកម្ពុជា ពីការគ្រប់គ្រងបែបរាជានិយមទៅជាការគ្រប់គ្រងបែបសេរីនិយម ក្នុងទម្រង់ជារបបសាធារណៈរដ្ឋបែបសហរដ្ឋអាមេរិក)។ ព្រឹត្តិការណ៍នយោបាយទាំងអស់ខាងលើនេះ បាននាំមកនូវព្យុះសង្ឃរាដ៏កំណាច ដល់វាសនាអនាគតនៃប្រទេសកម្ពុជា ពោលគឺធ្វើអោយកើតមានបញ្ហាសង្គ្រាមស៊ីវិល ដែលបានអូសបន្លាយអស់រយៈកាលជិត ៣ ទសវត្ស។

តាមការស្រាវជ្រាវបង្ហាញថា ក្រោយពីការប្រកាសទម្លាក់សម្តេច នរោត្តម សីហនុ ពីតំណែងព្រះប្រមុខរដ្ឋ នៅថ្ងៃទី ១៨ ខែមិនា ឆ្នាំ ១៩៧០ ដោយបក្សពួកលោកសេនាប្រមុខ លន់ នល់ អ្នកអង្គម្ចាស់ស៊ី សុវត្ថិសិរីមតៈ និងលោក អ៊ិន តាំ យើងពិនិត្យឃើញថា ស្ថានការណ៍ទូទៅ នៅប្រទេសកម្ពុជាទាំងមូលមានភាពរំជើបរំជួល និងវឹកវរស្ទើរគ្រប់ទីកន្លែង។ នៅ ថ្ងៃទី ៩ ខែតុលា ឆ្នាំ ១៩៧០ វិទ្យុជាតិបានប្រកាសប្រទេសកម្ពុជា ជាសាធារណៈរដ្ឋ ហើយរដ្ឋាភិបាលបណ្តោះអាសន្ន បានរៀបចំបង្កើតស្ថាប័នដឹកនាំរដ្ឋ។ [145]

នាសម័យនោះ នៅរាជធានីភ្នំពេញក្រុមគាំទ្ររបបសាធារណៈរដ្ឋ បានបង្កើតបក្សនយោបាយ ៣ គឺ បក្សសាធារណៈរដ្ឋ ដឹកនាំដោយ ទ្រង់សិរីមតៈ បក្សប្រជាធិបតេយ្យ ដឹកនាំដោយលោក អ៊ិន តាំ និង បក្ស សង្គមសាធារណៈរដ្ឋ ដែលមានលោកសេនាប្រមុខ លន់ នល់ ជាអ្នកដឹកនាំ។ នៅខែមិនា ឆ្នាំ ១៩៧២ លោកសេនាប្រមុខ លន់ នល់ បានរំលាយរដ្ឋសភា និងរដ្ឋាភិបាល ហើយបានប្រកាសខ្លួនឯងជាប្រធានាធិបតី នៃរបបសាធារណៈរដ្ឋខ្មែរ។ ហើយក្នុងការប្រកួតប្រជែងដណ្តើមអាសនៈតំណាងរាស្ត្រសម្រាប់រដ្ឋសភារបស់គណបក្សទាំង៣ នាថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៧២ គឺគណបក្សសង្គមសាធារណៈរដ្ឋ ដែលដឹកនាំ ដោយលោកសេនាប្រមុខ លន់ នល់ បានទទួលជ័យជំនះ ពោលគឺ ទទួលបានអាសនៈទាំងអស់ ១២៦ កៅអី ដែលបើកច្រកក្នុងការចូលរួម បោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា នាថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ១៩៧២។

រដ្ឋាភិបាលថ្មីបានប្តេជ្ញាថា ជម្រុញអោយវប្បធម៌ជាតិរីកសាយ ប្រកបដោយឆន្ទៈមួយថ្មី ដោយប្រកាន់ខ្ជាប់នូវគោលការណ៍សិទ្ធិមនុស្ស ជម្រុញអោយប្រទេសឈានដល់លទ្ធិប្រជាធិបតេយ្យផ្នែកនយោបាយ និង ប្រជាធិបតេយ្យផ្នែកសង្គម បំបាត់អោយអស់នូវអំពើជិះជាន់សង្កត់សង្កិន និងអំពើខ្វះអធ្យាស្រ័យ ដើម្បីឆ្ពោះទៅរកសេចក្តីសុខ សុភមង្គលសាធារណៈរដ្ឋប្រឆាំងនឹងរបបរាជានិយមមិន

អោយរស់ឡើងវិញ ហើយប្រឆាំងនឹងរបបបុគ្គលនិយម ធ្វើយ៉ាងណារក្សាការពារបូរណៈភាពទឹកដីខ្មែរ

[145] ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ. ឆ្នាំ ២០១២, ទំព័រ ៣២១-៣២២

អោយមានឯករាជ្យ និងឯកភាពជាតិ ស្របតាមបាវចនា សេរីភាព សមភាព ភាតរភាព វឌ្ឍនភាព និងសុភមង្គល។

ប៉ុន្តែជាក់ស្តែងរបបសាធារណៈរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ គឺជារបបមួយដែលគ្មានស្ថេរភាពនយោបាយ និងសេដ្ឋកិច្ច ព្រោះជារបបដែលពោរពេញទៅដោយអំពើពុករលួយ ហើយរបបនេះ មានជីវិតបានដោយសារតែជំនួយគ្រប់ផ្នែកពីសហរដ្ឋអាមេរិក។ របបនេះអាចគ្រប់គ្រងបានតែផ្នែករដ្ឋបាលនៅរាជធានីភ្នំពេញ និងទីក្រុងធំៗ មួយចំនួនប៉ុណ្ណោះ ហើយប្រជាពលរដ្ឋភៀសសឹក បានប្រមូលផ្តុំគ្នាមក រស់នៅតាមទីក្រុង។ ការរស់នៅរបស់ពួកគេ ខ្វះខាតជីវភាពសព្វបែបយ៉ាង ហើយទំនិញចាំបាច់ប្រចាំថ្ងៃបានឡើងថ្លៃជាលំដាប់។ វិបត្តិសង្គម អតិផរណា ភាពឥតការងារធ្វើ និងអំពើពុករលួយមានកម្រិតកាន់តែខ្ពស់ ដោយសារសង្គ្រាមរវាងខ្មែរទាំងសងខាង ដែលចាត់ទុកគ្នាឯងជាសត្រូវ។

## ៧.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច

ផ្ទុយពីសម័យសង្គមរាស្ត្រនិយម យុទ្ធសាស្ត្រសំខាន់ៗ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នាសម័យសាធារណៈរដ្ឋខ្មែរ គឺជាការទទួលយកនូវប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចជាតិ តាមរូបភាព សេដ្ឋកិច្ចទីផ្សារ
សេរី។ នៅសម័យនោះ ប្រព័ន្ធសេដ្ឋកិច្ចជាតិទាំងមូលត្រូវបានរៀបចំឡើង ដោយថតចម្លងនូវក្បួនខ្នាតនៃការធ្វើសេដ្ឋកិច្ចទីផ្សារសេរីរបស់សហរដ្ឋអាមេរិក យកមកអនុវត្តផ្ទាល់នៅក្នុងប្រទេសកម្ពុជា ដោយដំណើរការសេដ្ឋកិច្ចជាតិទាំងមូល ពឹងផ្អែកទាំងស្រុងលើវិស័យឯកជន ហើយរដ្ឋដើរតួជាអ្នកសម្របសម្រួល និងធ្វើនិយ័តកម្មក្នុងយន្តការសេដ្ឋកិច្ច ។ ជាលទ្ធផល មូលដ្ឋានសេដ្ឋកិច្ចសំខាន់ៗ ត្រូវបានផ្ទេរទៅអោយ ផ្នែកឯកជនជាអ្នកគ្រប់គ្រង ជាពិសេសវិស័យពាណិជ្ជកម្ម ដែលជាវិស័យគន្លឹះនាសម័យនោះ។ [146]

## ៧.៣. ស្ថានភាពសេដ្ឋកិច្ច

### ៧.៣.១ វិស័យកសិកម្ម

សេដ្ឋកិច្ចខ្មែរ គឺពឹងផ្អែកទៅលើវិស័យកសិកម្មជាសំខាន់។ ប្រជាកសិករខ្មែរមានជិត ៨០% ក្នុងចំណោមប្រជាពលរដ្ឋខ្មែរទាំងមូល ប្រកបរបរកសិកម្ម (ស្រូវ បន្លែគ្រប់មុខ កៅស៊ូ ពោត ម្រេច ផ្លែឈើ ឈើ និងការចិញ្ចឹមសត្វ) ដែលពីមុនៗមកផលិតផលកសិកម្មធ្លាប់បាននាំ ចេញទៅក្រៅប្រទេសជាង ៩០%។ ដូច្នេះបើប្រៀបធៀបនឹងសកម្មភាព សេដ្ឋកិច្ចផ្សេងៗទៀត សកម្មភាពផ្នែកកសិកម្ម និងព្រៃ

ឈើ បានដើរតួនាទីយ៉ាងសំខាន់មួយក្នុងជីវភាពសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងមូល នាសម័យកាលមុនៗ។

សម័យសាធារណៈរដ្ឋខ្មែរ វិស័យកសិកម្មត្រូវបានរងនូវការប៉ះ ពាល់ខ្លាំងជាងគេ ដោយសារតែបញ្ហាសឹកសង្គ្រាមតាំងពីដំបូងមកម្ល៉េះ។ ចាប់តាំងពីដើមឆ្នាំ១៩៧០ កើតមានការទម្លាក់គ្រាប់បែកមកលើលំនៅ ដ្ឋានប្រជាពលរដ្ឋនៅតំបន់ភូមិភាគខាងកើតទន្លេមេគង្គ ក៏បានបង្ខំអោយ កសិកររាប់ម៉ឺននាក់ភៀសខ្លួនចេញពីកសិដ្ឋានរបស់ពួកគេ ក៏ព្រោះតែផ្ទះសម្បែងរបស់ពួកគេត្រូវបានបំផ្លិចបំផ្លាញ ហើយសត្វពាហនៈក៏ត្រូវបានសម្លាប់។ ក្នុងពេលជាមួយគ្នានោះដែរ កសិករដទៃទៀតក៏បានភៀសខ្លួន ចេញពី

146 ឈុន ហុ, ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា(មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ១-២

ក្រោមការត្រួតត្រារបស់ពួកខ្មែរក្រហម ដែលកាន់តែរីកឡើងៗនោះ។ មានន័យថា ពួកគេបានគេចខ្លួនចេញពីតំបន់ដែលប្រើប្រាស់រូបភាពជាកសិកម្មសមូហភាព (ហៅថា សហករណ៍) ដែលរៀបចំឡើងដោយពួកខ្មែរក្រហម។ ប្រជាកសិករខ្លះទៀត បានធ្វើចំណាកស្រុក ចេញពីតំបន់ជនបទនានាដែលជាសមរភូមិប្រយុទ្ធយ៉ាងក្តៅគគុក ហើយបានរត់មករស់នៅពពាក់ពពូននៅតាមទីក្រុងធំៗជាច្រើន។ ប្រជាជន នៅទីក្រុងភ្នំពេញដែលនៅ ខែមីនា ឆ្នាំ ១៩៧០ មានចំនួនតែ ៦៥០.០០០ នាក់ បានកើនឡើងរហូតដល់ ៩០០.០០០ នាក់ នៅក្នុងខែកញ្ញា ឆ្នាំ ១៩៧០។ នៅដើមឆ្នាំ១៩៧៥ ចំនួននេះ ក៏បានកើនឡើងរហូតដល់ ៣.០០០.០០០ នាក់ ក្នុងចំនួនប្រជាជន ៧.០០០.០០០ នាក់។ ការចាកចោលស្រុកយ៉ាងច្រើនបែបនេះ បានសម្តែងអោយឃើញនូវការបោះបង់ចោលនូវដី ស្រែចំការ និងមុខរបរកសិកម្មយ៉ាងពិតប្រាកដ។ ផ្ទៃដី ដាំដុះ និងផលិតផលកសិកម្ម ដំណាំស្រូវ បានថយចុះឥតឈប់ឈរ ដូចមានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ៖

| បរិយាយ | ផ្ទៃក្រឡា (ហ.ត) | ផលិតផលស្រូវ (តោន) |
|---|---|---|
| **១៩៦៩-១៩៧០** | ២.៤៥៨.៣៨៩ | ៣.៨១៣.៨១៣ |
| **១៩៧០-១៩៧១** | ១.៨៨០.០០០ | ២.៧៣២.០០០ |
| **១៩៧១-១៩៧២** | ១.៥៤៨.០០០ | ២.១៣៧.៨៤០ |

*ផ្ទៃដីដាំដុះ និងផលិតកម្មស្រូវ ឆ្នាំ ១៩៧០-១៩៧២* [147]

ដូច្នេះយើងពិនិត្យឃើញថា ផ្ទៃដីដាំដុះដំណាំស្រូវនៅសម័យនោះ បានថយចុះប្រមាណ ៤០% គ្រាន់តែចន្លោះឆ្នាំ ១៩៧០-១៩៧២ ប៉ុណ្ណោះ ហើយផ្ទៃដីនេះ បានថយចុះជាបន្តបន្ទាប់រហូតដល់ឆ្នាំ ១៩៧៥ ដែលធ្វើអោយប្រទេសកម្ពុជា មានការខ្វះខាតស្បៀងអាហារ និងមានគ្រោះទុរ្ភិក្សស្ទើរតែពេញមួយសម័យកាលនៃរបបសាធារណៈរដ្ឋខ្មែរ។

ទាក់ទងទៅនឹងការចិញ្ចឹមសត្វ រដ្ឋាភិបាលសម័យនោះ បានជម្រុញអោយប្រជាពលរដ្ឋចិញ្ចឹមសត្វពាហនៈ ជ្រូក មាន់ ទា សម្រាប់លក់អោយទីផ្សារផង និងសម្រាប់បរិភោគខ្លួនឯងផង ក្នុងបំណងកាត់ បន្ថយអំពើចោរកម្ម។ ប៉ុន្តែគោលនយោបាយនេះ ត្រូវបានជួបនឹងការលំបាក ព្រោះការចំណាយទៅលើចំណីអាហារសត្វខ្ពស់ជាងលទ្ធផល ដែលត្រូវទទួលបានពីការចិញ្ចឹមសត្វ។ [148]

ដោយឡែកចំពោះដំណាំកៅស៊ូវិញ ក៏មានវាសនាមិនខុសគ្នាពីដំណាំស្រូវនោះដែរ ព្រោះមិនត្រឹមតែមិនបានដាំដុះថ្មីនោះទេ ថែមទាំងដើមកៅស៊ូដែលបានដាំដុះរួចហើយ និងកំពុងផ្តល់ផលនោះគិតជា ចំនួនប្រមាណជាង ២/៣ ត្រូវបានបោះបង់ចោល ព្រោះនៅសម័យនោះ ចំការកៅស៊ូស្ទើរតែទាំងអស់ ត្រូវបានពួកកងទ័ពខ្មែរក្រហមយកមកធ្វើ ជាជម្រកលាក់ខ្លួន និងជាមូលដ្ឋានបង្កទ័ព។

វិស័យព្រៃឈើនាសម័យសាធារណៈរដ្ឋខ្មែរ ត្រូវបានរងការប៉ះពាល់ខ្លាំងជាងគេ។ ព្រៃឈើមួយចំនួនធំ ត្រូវបានឆេះដោយសារតែទីនោះ គឺជាសមរភូមិប្រយុទ្ធហើយកន្លែងខ្លះទៀត ត្រូវបានគ្រប់គ្រងដោយរដ្ឋបាលខ្មែរក្រហម។

ចំណែកការនេសាទវិញ ត្រីគឺជាអាហារមូលដ្ឋានមួយទៀតរបស់ប្រជាជនកម្ពុជា ដែលគេនេសាទជាទម្លាប់ នៅតាមបណ្តោយដងទន្លេ នៅបឹងទន្លេសាប នៅតាមព្រែក ឬនៅតាមឆ្នេរសមុទ្រនោះ ក៏ត្រូវរងផលប៉ះពាល់ដោយសង្គ្រាម និងអសន្តិសុខដែរ។ ជាងនេះទៀត ផលិតផលត្រីដែលបាននេសាទដោយអន្លើនៅតាមតំបន់ខាងលើនេះ មិនអាចបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានឡើយ។

ក្នុងកាលៈទេសៈនោះ ផលិតផលកសិកម្មពុំអាចបំពេញអោយសេចក្តីត្រូវការជាក់ស្តែងបានឡើយ។ ទោះបីជាប្រព័ន្ធផលិតកម្មកសិកម្ម នៅតែដំណើរការក៏ដោយ ក៏ប៉ុន្តែសរុបសេចក្តីមក ពុំអាចរៀបចំផ្គត់ផ្គង់ ផលិតផលស្បៀងអាហារអោយបានគ្រប់គ្រាន់បាននោះទេ ព្រោះថាស្ថានភាពសង្គ្រាម និងភាពមិនអាចគ្រប់គ្រងបាននូវបរិមាណដីកសិកម្ម ដែលចេះតែរួមតូចទៅៗ ដោយពាក់ព័ន្ធនឹងស្ថានភាពដ៏លំបាកដែល កំពុងកើតមានឡើងជាប្រចាំ មានន័យថាពួកខ្មែរក្រហមកាន់តែវាយលុកចូលមកគៀកទីក្រុងជាបន្តបន្ទាប់ជារៀងរាល់ថ្ងៃ។ ហេតុដូច្នេះហើយ គ្រប់សកម្មភាពសេដ្ឋកិច្ចកសិកម្មទាំងឡាយ ដែលប្រទេសជាតិនឹងត្រូវបានបំពេញនោះ ត្រូវបានអសកម្ម ហើយនឹងមិនអាចធ្វើផែនការផលិតកម្មទុកជាមុនបានឡើយ។

### ៧.៣.២ វិស័យឧស្សាហកម្ម

លទ្ធផលនៃសង្គ្រាម រោងចក្ររបស់រដ្ឋ ក៏ដូចជាឯកជនទាំងអស់ ដែលស្ថិតនៅតាមបណ្តាខេត្តនានា (ដូចជា រោងចក្រតម្បាញនៅខេត្តកំពង់ចាម រោងចក្រក្រដាសនៅឆ្លូង (ខេត្តក្រចេះ) រោងចក្រស៊ីម៉ង់ត៍នៅ ចក្រីទីងខេត្តកំពត រោងចក្រដីហ្វូស្វាតនៅទូកមាសខេត្តកំពត រោងចក្រ ក្តារបន្ទះនៅជីផដ្ឋ ខេត្តកណ្តាល។ល។ ត្រូវបានបញ្ឈប់សកម្មភាពរបស់ខ្លួនទាំងស្រុង។ ពិសេសទៅទៀត រោងចក្រឧស្សាហកម្ម ប្រមាណជា ៤/៥ ត្រូវបានបំផ្លាញដោយសារតែសង្គ្រាម។ [149]

ចំពោះស្ថានីយ៍ស្រាវជ្រាវព្រែកត្នោត រួមជាមួយអ្នកជំនួយការ បច្ចេកទេសជនជាតិ អ៊ីស្រាអែលបានបន្តដំណើរការរបស់ខ្លួនរហូតដល់ ឆ្នាំ ១៩៧២-១៩៧៣។ ក្នុងពេលនោះដែរ ខ្មែរក្រហមចេះតែកើនឡើង និងធ្វើការកាន់កាប់ត្រួតត្រាលើតំបន់មួយចំនួន នៅតាមជនបទដាច់ ស្រយាលកាន់តែច្រើនឡើងៗ ហើយពួកគេក៏បានរៀបចំនូវអង្គការរចនា សម្ព័ន្ធគ្រប់គ្រងបែបសេដ្ឋកិច្ចផែនការអន្តរកាល នៅក្នុងសង្គមជនបទភ្លាមដែរ។

## ៧.៣.៣ វិស័យសេវាកម្ម

❖ វិស័យគមនាគមន៍

នៅឆ្នាំ ១៩៧០ បញ្ហាអសន្តិសុខនៅតាមបណ្តាញផ្លូវគមនាគមន៍ ធំៗនៅពុំទាន់ចោទមានជាឧបសគ្គនៅឡើយទេ ប៉ុន្តែនៅឆ្នាំបន្ទាប់មកទៀត បញ្ហាអសន្តិសុខបានរីករាលដាលទៅដល់ខេត្តនានាជាច្រើនទៀត ហើយបានឈានទៅគ្របដណ្តប់លើភូមិសាស្ត្រនៃផ្ទៃប្រទេសទាំងមូល។ ផ្លូវអោយស្វ័យយានរវាងទីក្រុងភ្នំពេញ និងខេត្តបាត់ដំបង ដែលគេចាត់ទុកថា ជាតំបន់ជង្រុកស្រូវរបស់ប្រទេស និងផ្លូវរថ
ភ្លើងរវាងទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រអន្តរជាតិដ៏សំខាន់បំផុតនោះ ត្រូវបានកាត់ផ្តាច់ទាំងស្រុង។

ដូចគ្នាដែរ ភាគច្រើននៃផ្លូវជាតិដែលតភ្ជាប់ពីទីក្រុងភ្នំពេញ ទៅកាន់ខេត្តនានាក៏ត្រូវបានកាត់ផ្តាច់ដូចគ្នា។ ពោលគឺមានតែផ្លូវជាតិពីរខ្សែប៉ុណ្ណោះ ដែលគេអាចធ្វើចរាចរទៅមកបានយូរគួសមជាងគេ គឺផ្លូវជាតិ លេខ៤ រវាង ទីក្រុងភ្នំពេញ និងក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៥ រវាងទីក្រុងភ្នំពេញ និងខេត្តបាត់ដំបង។ ក៏ប៉ុន្តែនៅ ខែមិនា ឆ្នាំ ១៩៧៥ ការធ្វើគមនាគមន៍តាមផ្លូវគោកទាំងអស់ត្រូវបានកាត់ផ្តាច់ជាស្ថាពរដោយកងទ័ពកុម្មុយនីស្តខ្មែរក្រហម។

ក្រោយពីផ្លូវគោកត្រូវបានកាត់ផ្តាច់ទាំងស្រុងនៅចុងឆ្នាំ ១៩៧៤ មកផ្លូវទាក់ទងតែមួយគត់ដែលអាចប្រើប្រាស់បានសម្រាប់ការដឹកជញ្ជូនផ្សេងៗ គឺមានតែផ្លូវទឹកតាមដងទន្លេមេគង្គ និងផ្លូវអាកាស តាមអាកាសយានដ្ឋានពោធិចិនតុងតែប៉ុណ្ណោះ។ ប៉ុន្តែចាប់តាំងពីដើមឆ្នាំ ១៩៧៥ មក ពួកកងទ័ពខ្មែរក្រហម បានចាប់ផ្តើមកាត់ផ្តាច់ផ្លូវទឹកទន្លេ មេគង្គទាំងស្រុង ដែលធ្វើអោយស្ថានភាពកាន់តែធ្ងន់ធ្ងរ។ [150]

ដោយប្រព័ន្ធគមនាគមន៍ផ្លូវទឹក និងផ្លូវគោក ដែលត្រូវបានពួក ខ្មែរក្រហមគ្រប់គ្រងហើយនោះជាលទ្ធផលផ្លូវដែលអាចដឹកជញ្ជូនទំនិញ និងធ្វើដំណើរបាន មានតែចរាចរតាមផ្លូវអាកាសតែមួយប៉ុណ្ណោះ (នៅក្នុងពេលនោះ ប្រទេសកម្ពុជាមានក្រុមហ៊ុនអាកាសចរណ៍ប្រមាណ ពី ១៤ ទៅ ១៧) ដែលកំពុងដំណើរការពីភ្នំពេញទៅបណ្តាខេត្តនានា។ ប៉ុន្តែ នៅដើមឆ្នាំ ១៩៧៥ ដោយសារការបាញ់ផ្តក់មកលើចំណតអាកាស យានដ្ឋានពោធិចិនតុង ដែលជាបណ្តាញគមនាគមន៍សំខាន់ចុងក្រោយបង្អស់របស់របបសាធារណៈរដ្ឋខ្មែរ និងពិភពលោកខាងក្រៅ ក៏ត្រូវបានស្ទះដំណើរការដឹកជញ្ជូន។

❖ វិស័យពាណិជ្ជកម្ម

ចំពោះវិស័យពាណិជ្ជកម្ម នៅសម័យសាធារណៈរដ្ឋខ្មែរ ដែលកាលពីដើមមកធ្លាប់តែនាំអង្ករចេញជិត ៣០០.០០០ តោន ក្នុង១ឆ្នាំៗ ឥឡូវត្រូវនាំអង្ករចូលពីបរទេសមកវិញ ជាពិសេសពីសហរដ្ឋអាមេរិក។ នៅឆ្នាំ ១៩៧២ សហរដ្ឋអាមេរិក បានផ្តល់អង្ករអោយប្រទេសកម្ពុជា ចំនួន ៧០.០០០ តោន និងបន្ទាប់មក សម្រាប់ឆមាសទី១ នាឆ្នាំ ១៩៧៣ បានផ្តល់អង្ករប្រមាណ ២៨.០០០ តោន។ រហូតដល់ទីបញ្ចប់នៃរបបសាធារណៈរដ្ឋខ្មែរ សហរដ្ឋអាមេរិកនៅតែជាប្រទេសមួយដ៏សំខាន់ ក្នុងការនាំចេញ

[150] សារព័ត៌មាន រាស្ត្រសច្ចៈ, ការខ្វះខាតអង្ករ និងទំនិញឡើងថ្លៃ ពិបាករកទិញទទួលទានអាហារនៅទីក្រុងភ្នំពេញ ចេញផ្សាយថ្ងៃ ទី១៣ ខែកញ្ញា លេខ ៨៩៣

អង្ករមកកាន់ប្រទេសកម្ពុជានាសម័យនោះ។

រីឯសកម្មភាពពាណិជ្ជកម្មក្នុងស្រុក គេសង្កេតឃើញថា ពុំមានសកម្មភាពណាមួយ ដែលមានទ្រង់ទ្រាយសេដ្ឋកិច្ចធំដុំនោះទេ និយាយជារួម ការធ្វើជំនួញដ៏សំខាន់គឺ ការជួញដូរអង្ករ និងការលក់ដូរទូទៅ សម្រាប់តែដោះស្រាយបញ្ហាជីវភាពមួយគ្រាៗប៉ុណ្ណោះ។

ចំពោះតម្លៃទំនិញភាគច្រើន បានឡើងថ្លៃប្រហែលជា ៤០០% ចន្លោះឆ្នាំ ១៩៧២ ដល់ឆ្នាំ ១៩៧៤ ហើយបានបន្តឡើងថ្លៃរហូតដល់ ១០០០% នៅឆ្នាំ ១៩៧៥។ ប្រជាជនខ្មែរភាគច្រើនពុំមានលទ្ធភាពទទួលទានសាច់ជ្រូក សាច់គោ មាន់ ទា នោះទេ។ ហើយបន្លែដែលមានតម្លៃ ថោកជាងគេ និងមានការពេញនិយមបំផុតនោះគឺ ត្រកួន។ [151]

❖ វិស័យហិរញ្ញវត្ថុ និងធនាគារ

នៅសម័យសាធារណៈរដ្ឋខ្មែរ ភាគច្រើននៃប្រជាជនបានរស់នៅ ក្រោមកម្រិតនៃភាពក្រីក្រទៅទៀត។ ជាការប្រឈមមុខនឹង សភាពការណ៍នយោបាយបែបនេះ ខេត្តបាត់ដំបងនៅតែជាតំបន់មួយដែលស្ថិត នៅក្នុងសភាពស្ងប់ស្ងាត់ និងបានបន្តតួនាទីដ៏ធំជាអ្នកផ្គត់ផ្គង់អង្ករ និងចំណីអាហារដល់ប្រជាជនទូទាំងប្រទេស។ ចំពោះតំបន់ទីក្រុងវិញ ការរស់នៅរបស់ប្រជាពលរដ្ឋ គឺអាស្រ័យទៅនឹងអង្កររបស់សហរដ្ឋអាមេរិក ដែលបានបញ្ជូនមក ដូចជាជំនួយចំណីអាហារជាដើម នៅពេលនោះហើយដែលវិបត្តិសេដ្ឋកិច្ច-សង្គមមានការកើនឡើងកាន់តែខ្លាំងទៅៗ។ នៅឆ្នាំ ១៩៧៣ មន្ត្រីរាជការដែលទទួលបានប្រាក់បៀវត្ស ក្នុងមួយខែ ចន្លោះពី ៤.០០០ ទៅ ៨.០០០ រៀល (ឬស្មើនឹង ៦០ ទៅ ១២០ ហ្វ្រង់) បានចាត់ទុកថា ជាអ្នកមានចំណូលបង្គួរ។ មានន័យថា បើយើងពិនិត្យមើលទៅលើតម្លៃអង្ករនៅលើទីផ្សារ ដែលពីមុនៗធ្លាប់តែលក់ក្នុងតម្លៃ ១៨០០រៀល/១០០គ.ក ក្រោយមកកើនឡើងរហូតដល់តម្លៃ ៧.០០០ រៀលឯណោះ។ ត្រីមួយគីឡូក្រាមមានតម្លៃ ២៥០រៀល សាច់ជ្រូក មួយគីឡូក្រាមមានតម្លៃ ៣០០រៀល។ តម្លៃទាំងនេះ បានឡើងថ្លៃជា បន្តបន្ទាប់រហូតដល់ដើមឆ្នាំ ១៩៧៥ ក្នុងកម្រិត ១០០០% គិតជាមធ្យម។ រីឯប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិលបានកើនឡើងតែ ៣០០% ប៉ុណ្ណោះ នៅចន្លោះឆ្នាំ ១៩៧០ ដល់ ១៩៧៥ ។ ពេលនោះហើយដែលប្រទេសកម្ពុជាបានបង្ខំអោយមានការទំនាក់ទំនងយ៉ាងខ្លាំង ជាមួយអង្គការអន្តរជាតិមួយចំនួន ដូចជា UNDP, ILO, WHO និងសប្បុរសជនជាច្រើនទៀត មាន ជប៉ុន អឺរ៉ុប និងបារាំង។

ដើម្បីទ្រទ្រង់សេដ្ឋកិច្ចសង្គមនាសម័យនោះ ប្រទេសកម្ពុជាត្រូវបានទទួលប្រាក់កម្ចីពីបរទេស និងជំនួយនានាពីបណ្តាប្រទេសសេរី។ តាមឯកសារខ្លះបានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាបានខ្ចីប្រាក់ពីសហរដ្ឋអាមេរិក ប្រមាណ ១២០ លានដុល្លា ប៉ុន្តែតាមប្រភពខ្លះទៀត បានអះអាងថា មានចំនួនរហូតដល់ទៅ ៣០០ លានដុល្លាអាមេរិក។ រីឯតាម ប្រភពមួយទៀតបានលើកឡើងថានៅថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៩៧៥ លោកប្រធានាធិបតីសហរដ្ឋអាមេរិក បានស្នើសុំអោយរដ្ឋសភាសហរដ្ឋអាមេរិកលុបចោលកំហិតចំណាយនៅត្រឹមតែ ២០០លានដុល្លា សម្រាប់ជំនួយលើវិស័យយោធា និងសេដ្ឋកិច្ច ហើយនឹងសុំបន្ថែមចំនួន ២២២ លានដុល្លា ទៀតសម្រាប់ជំនួយទូទៅដល់ប្រទេសកម្ពុជា។

[151] សារពត៌មាន រាស្ត្រសច្ចៈ, ការខ្វះខាតអង្ករ និងទំនិញឡើងថ្លៃ ពិបាករកទិញទទួលទានអាហារនៅទីក្រុងភ្នំពេញ ចេញផ្សាយថ្ងៃទី១៣ ខែកញ្ញា លេខ ៨៩៣

❖ វិស័យសំណង់

ចំពោះវិស័យសំណង់ ជាពិសេសសំណង់កំពង់ផែ កំពង់ចម្លង សំណង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវស្ពាន សំណង់សាធារណៈ និងគ្រឹះស្ថាន សិក្សា ត្រូវបានរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរ ដោយសារសង្គ្រាមស៊ីវិល ពោលគឺ ខូចខាតអស់ប្រមាណពី ៨០% ទៅ ៩០%។ ដូចជាករណី ស្ពាន ជ្រោយចង្វារ ត្រូវបានបំផ្ទុះគ្រាប់បែកបំផ្លាញចោលតែម្តង។

## ៧.៤. សេចក្តីសន្និដ្ឋាន

សរុបមក ស្ថានភាពសេដ្ឋកិច្ច និងសង្គមប្រទេសកម្ពុជានាសម័យសាធារណៈរដ្ឋខ្មែរ ឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ គឺជាស្ថានភាពសេដ្ឋកិច្ចមួយ ដែលស្ថិតនៅក្នុងសភាពវិបត្តិដ៏ធ្ងន់ធ្ងរបំផុត និងមាន
លក្ខណៈរីករៃ ហើយឆ្ពោះទៅរកការរលាយសាបសូន្យលើគ្រប់មូលដ្ឋានគ្រឹះនៃវិស័យ សេដ្ឋកិច្ចជាតិទាំងមូល។ ជាក់ស្តែង វិស័យឧស្សាហកម្មផលិតកម្មត្រូវបានផ្អាកស្ទើរតែទាំងស្រុង វិស័យកសិកម្ម ក៏មិនអាចដំណើរការបាន និងវិស័យសេវាកម្ម ពាណិជ្ជកម្ម ក៏ដំណើរការបានតែក្នុងទីក្រុង និងទីប្រជុំជនធំៗតែប៉ុណ្ណោះ។ ជាលទ្ធផលសង្គ្រាមរយៈពេល ៥ ឆ្នាំ និង ១ខែ ធ្វើអោយរោងចក្រឧស្សាហកម្ម ៤/៥ ត្រូវបានបំផ្លិចបំផ្លាញ ចំការដំណាំកៅស៊ូ ២/៣ ត្រូវបានបាត់បង់ ផ្លូវថ្នល់ និងផ្លូវដែកពី ៧០% ទៅ ៨០ ត្រូវបានខូចខាត កំពង់ផែ និងកំពង់ចម្លង ត្រូវបានខ្ទេចខ្ទាំ សំណង់សាធារណៈតាមទីប្រជុំជន និងគ្រឹះស្ថានសិក្សាបានរងនូវការខូចខាតយ៉ាងធ្ងន់ធ្ងរពី ៨០ ទៅ ៩០%។

ពិសេសជាងនេះទៅទៀត ភាគីខ្មែរទាំងសងខាងប្រមាណជាង ១លាននាក់ បានស្លាប់ និងរងរបួស អ្នកនៅរស់ក្លាយជាអ្នកទោស ខ្វះជម្រក ខ្វះស្បៀងអាហារ មនុស្សចាស់ និងកុមារភាគច្រើនស្លាប់ដោយសារភាពអត់ឃ្លាន។

និយាយរួមមូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិទាំងមូល ដែលបានកសាងអស់រយៈពេលជាច្រើនទសវត្សកន្លងមកនេះ ត្រូវបានបំផ្លាញចោលខ្ទេចខ្ទីស្ទើរគ្មានសល់ ដោយសារតែលទ្ធផលនៃសង្គ្រាមស៊ីវិលរវាងខ្មែរគ្នាឯង តាមរយៈថ្នាំបំពុលនៃមនោគមវិជ្ជាលោកលន់ វាទីនិយមរបស់បរទេសក្នុងមហិច្ឆិតា ដែលយើងទាំងអស់គ្នាមិនអាចបំភ្លេចបានជាប្រវត្តិសាស្ត្រ។

# ជំពូកទី ៨
# សេដ្ឋកិច្ចប្រទេសកម្ពុជា សម័យកម្ពុជាប្រជាធិបតេយ្យ
# ឆ្នាំ ១៩៧៥-១៩៧៩

## ៨.១. ស្ថានភាពនយោបាយ

ដោយសារតែលទ្ធផល នៃជម្លោះនយោបាយរបស់បរទេសនៃមនោគមវិជ្ជាពីរផ្សេងគ្នា បានធ្វើអោយប្រទេសកម្ពុជាយើង ក្លាយទៅជាមជ្ឈមណ្ឌលនៃមន្ទីរពិសោធន៍នយោបាយរវាងប្លុកសេរី និងកុម្មុយនីស្ត និងជាកន្លែងទីលានប្រយុទ្ធគ្នារវាងខ្មែរ និងខ្មែរអស់រយៈកាល៥ឆ្នាំ (១៩៧០-១៩៧៥) ហើយក្រោយមកបានក្លាយជាប្រទេសសម្រាប់កប់ខ្មោចប្រជាពលរដ្ឋខ្មែរខ្លួនឯងរាប់លាននាក់ ដែលជាអំពើសោកនាដកម្ម ប្រល័យពូជសាសន៍ ដ៏សែនឃោរឃៅព្រៃផ្សៃជាទីបំផុតមិនអាចបំភ្លេចបាន គឺបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះឯង។ គួររំលឹកថា របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេប្រកាសជាផ្លូវការក្នុងប្រទេសកម្ពុជា ក្រោយពីបានអនុម័តរដ្ឋធម្មនុញ្ញនៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៧៥ ហើយរដ្ឋធម្មនុញ្ញនេះ បានចូលជាធរមាន នៅថ្ងៃទី ០៥ ខែមករា ឆ្នាំ ១៩៧៦។ នៅសម័យកាលនោះ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្ត មានសិទ្ធិចូលរួមក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋផងដែរដូចជា ៖

- លោក ខៀវ សំផន ជាប្រមុខរដ្ឋ ដែលគេហៅថា ប្រធានគណៈប្រធានរដ្ឋ
- លោក ប៉ុល ពត ជាប្រមុខរដ្ឋាភិបាល គឺ ជានាយករដ្ឋមន្ត្រី
- លោក នួន ជា ជាប្រធានសភាតំណាងប្រជាជនកម្ពុជា

ក្រោយពេលដែលរបបខាងលើនេះ បានចូលមកដល់នយោបាយស្មើភាពគ្នា ក្នុងប្រទេសខ្មែរត្រូវបានបង្កើតឡើង ដែលតាមរយៈគោលនយោបាយនេះ ប្រជាជនខ្មែរត្រូវបានជម្លៀសចេញពីទីក្រុង និងទីប្រជុំជនទៅកាន់ទីជនបទ ដោយបង្ខំអោយបំបាត់ចោលនូវកម្មសិទ្ធិឯកជន ហើយងាកមកទទួលយករបបអាហាររួម និងធ្វើការងាររួម ដោយលះបង់នូវជីវិតផ្ទាល់ខ្លួនមកបម្រើអង្គការ។

តាមរយៈរដ្ឋធម្មនុញ្ញ កម្ពុជាប្រជាធិបតេយ្យបានបង្កើតជាអង្គការគ្រប់គ្រង និងដឹកនាំរដ្ឋ មានអង្គការនីតិប្រតិបត្តិ អង្គការនីតិបញ្ញត្តិ និងស្ថាប័នតុលាការ។ ក៏ប៉ុន្តែក្រោយមកស្ថាប័នទាំង ៣ នេះ គឺមិនបាន ប្រតិបត្តិតាមតួនាទីរបស់ខ្លួនឡើយពោលគឺ សកម្មភាពដឹកនាំរដ្ឋបាន ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់បក្សកុម្មុយនីស្ត ហើយស្ថាប័នដឹកនាំរដ្ឋ ត្រូវបានគេស្គាល់ថាជា អង្គការ ។ អង្គការ បានធ្វើសកម្មភាពក្នុងនាមបក្សកុំម្មុយនីស្ត ហើយទទួលបញ្ជាពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុំម្មុយនីស្ត។

តាមគោលនយោបាយរបស់គណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា គឺបានយកទស្សនៈមហាជន និងមាគ៌ាមហាជនជាធំ។ តាមរយៈគោលនយោបាយនេះ បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យបានជឿ ព្រមទាំងពឹងផ្អែកទៅលើកម្លាំង និងសមត្ថភាពរបស់មហាជន ជាពិសេសកម្មករ កសិករក្រីក្រ ក្នុងការធ្វើបដិវត្តន៍កែប្រែ និងកសាងសង្គមជាតិ។ បដិវត្តន៍នេះ បានបោះបង់ចោលនូវគ្រឿងចក្រទំនើប

ហើយប្រមូលកៀងគរមហាជនអោយធ្វើការទាំងយប់ទាំងថ្ងៃនៅតាម វាលស្រែចំការ កសិដ្ឋាន និងតាមការដ្ឋានសំណង់នានា។ ជាទូទៅ ទស្សនៈនេះគោរពតាមសំណូមពររបស់មហាជន ប៉ុន្តែបើ សំណូមពរជាលក្ខណៈប្រយោជន៍ផ្ទាល់ខ្លួន អ្នកសំណូមពរនោះ ត្រូវបានយកទៅរៀនសូត្រ (គឺសម្លាប់ចោល)។ ចំពោះស្ថានភាពនយោបាយក្នុងប្រទេសកម្ពុជានាសម័យនោះ ពុំមានស្ថានភាពយូរអង្វែងឡើយ ដោយសារតែជារបបដែលខ្មៅងងឹត និងជាឋាននរកលោកីយ៍ សម្រាប់មនុស្សជាតិ។ ជាក់ស្តែង លោក ហ៊ូ យន់ បានចេញមុខប្រឆាំងទៅនឹងគម្រោងការរបស់បក្ស ក្នុងការដែលមិនអនុញ្ញាតអោយប្រជាជនទីក្រុង បានវិលត្រឡប់មកកាន់ផ្ទះសំបែងរបស់ពួកគេវិញ (កិច្ចពិភាក្សាក្នុងគណៈមជ្ឈិមបក្ស ដើមឆ្នាំ ១៩៧៥ ) ក្រោយមក ត្រូវបានគេយកគាត់ទៅសម្លាប់ចោល។ នៅខែមករា ឆ្នាំ ១៩៧៦ លោក ហ៊ូ នឹម ដែលជារដ្ឋមន្ត្រីក្រសួងឃោសនាការរបស់កម្ពុជាប្រជាធិបតេយ្យ ក៏បានចេញមុខប្រឆាំងទៅនឹងនិន្នាការផ្តាច់ការរបស់ ប៉ុល ពត ដែរ។

ជាក់ស្តែង នៅក្នុងកិច្ចពិភាក្សាគ្នាជាសម្ងាត់រវាង លោក ហ៊ូ នឹម ជាមួយនឹងលោក មូល សម្បត្តិ (ប្រធានភូមិភាគពាយ័ព្យ) បានអោយដឹងថា "យើងមិនអាចបំពេញទៅតាមផែនការបក្សទាមទារអោយ យើង បំពេញផែនការស្រូវគឺ ៣តោន/ហិកតា បានទេ ព្រោះយើងគ្មានគ្រឿង យន្តកសិកម្ម និងគ្មានប្រេងផង ក្នុងស្ថានភាពបែបនេះមិនមែនជាកំហុសរបស់យើងទេ នេះជាកំហុសរបស់មជ្ឈិមបក្ស"។[155] ទីបំផុត អ្នកទាំងពីរ ត្រូវបានចាប់បញ្ជូនមកមន្ទីរឃុំឃាំង គុកទួលស្លែង(ស-២១) ធ្វើទារុណកម្ម និងសម្លាប់ចោល។ចំពោះលោក សោ ភឹម ដែលជាប្រធានភូមិភាគ បូព៌ា ក៏បានជំទាស់ទៅនឹងបទបញ្ជាពីមជ្ឈិមបក្ស ដែលបានដាក់ចុះមក សម្រាប់បំពេញផែនការសេដ្ឋកិច្ចនេះដែរ។ ទីបំផុតនៅខែ ឧសភា ឆ្នាំ ១៩៧៧ ត្រូវបានពួក ប៉ុល ពត សម្លាប់ចោល។ ក្រោយមក នៅភូមិភាគ បូព៌ា ក៏មានការផ្ទុះឡើងនូវការប៉ះបោរយ៉ាងខ្លាំងក្លា។

នៅខែមិនា ឆ្នាំ១៩៧៦ ប្រជាជននៅ ចំការលូង និងនៅខេត្តសៀមរាបបានទាមទារអោយតម្លើងកម្រិតជីវភាព និងអោយគ្រួសារបានរស់នៅជួបជុំគ្នា។ នៅដើមខែមករា ឆ្នាំ១៩៧៨ ប្រជាជននៅខេត្ត សៀមរាបភាគខាងជើង និងនៅខេត្តបាត់ដំបងបានក្រោកឈរឡើង បង្កើតជាចលនាបះបោរប្រឆាំងនឹងពួកប៉ុល ពត។ ហើយនៅខែមិនា និងមេសា ឆ្នាំ១៩៧៧ ប្រជាជននៅខេត្តកំពង់ធំ មណ្ឌលគីរី និង កំពង់ឆ្នាំង ក៏បានបង្កើតចលនាតស៊ូប្រឆាំងនឹងពួក ប៉ុល ពត ដែរ។ នៅឆ្នាំដដែលនេះ នៅខេត្តកំពង់ចាម ក្នុងស្រុកក្រូចឆ្មារ នៅឃុំស្វាយឃ្លាំង តំបន់ព្រែកចាម(ក្បែរកោះផល) ត្រូវបានប្រជាជន ខ្មែរ-អ៊ីស្លាម បានងើបបះបោរប្រឆាំងនឹងរដ្ឋអំណាចរបស់ប៉ុលពត។ ប៉ុន្តែយើងឃើញថា រាល់ចលនាតស៊ូទាំងនោះ ពុំសម្រេចបានជោគជ័យនោះទេ ផ្ទុយទៅវិញ បានធ្វើអោយអង្គការដឹកនាំ(អាជ្ញាធរ)របស់ពួក ប៉ុល ពត បានចាប់ផ្តើមធ្វើការកាប់សម្លាប់ប្រជាជនឯងយ៉ាងសាហាវព្រៃផ្សៃជាងមុនទៅទៀត ជាពិសេសនៅភូមិភាគ និរតី ឧត្តរ និងភូមិភាគបូព៌ា។

ក្រៅពីនយោបាយក្នុងប្រទេស ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យបានធ្វើទំនាក់ទំនងនយោបាយក្រៅប្រទេសដែរដូចជា ជាមួយប្រទេសសាធារណៈរដ្ឋប្រជាមានិតចិន កូរ៉េខាងជើង ឡាវ

គុយបា រ៉ូម៉ានី យូហ្គោស្លាវី អាល់បានី និងប្រទេសអេហ្ស៊ីប ជាពិសេស ប្រទេសវៀតណាម។[158] ប៉ុន្តែមន្ត្រីស្ថានទូតទាំងនោះ ត្រូវស្ថិតនៅតែក្នុងស្ថានទូត របស់ខ្លួនតែប៉ុណ្ណោះ មានតែមន្ត្រីស្ថានទូត ចិន កូរ៉េខាងជើង និងឡាវទេ ដែលអាចដើរហើរបានខ្លះ។ លុះក្រោយមក ដោយសារមានការរំលោភអធិបតេយ្យភាព និង បូរណភាពទឹកដីខ្មែរ ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ បានធ្វើលិខិតព្រមានទៅក្រសួងការបរទេសនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមអោយ ៖

ទី១៖ គឺបញ្ឈប់ការវាយប្រហារឈ្លានពានលុកលុយ និងសកម្មភាពរំលោភបំពានលើដែនគោក ដែនទឹក និងដែនអាកាស។

ទី ២៖ គឺប្រទេសវៀតណាម ត្រូវបញ្ឈប់ការបញ្ជូនគិញមកស៊ើបការណ៍ និងការប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាលកម្ពុជា។

ទី៣៖ គឺប្រទេសវៀតណាម ត្រូវបោះបង់ចោលនូវយុទ្ធសាស្ត្រដាក់កម្ពុជា អោយនៅក្រោមសហព័ន្ធឥណ្ឌូចិនតាមគោលការណ៍បក្សមួយប្រទេសមួយប្រជាជាតិមួយនៅឥណ្ឌូចិនរបស់វៀតណាម។

សរុបមក ដោយសារការកាប់សម្លាប់ប្រជាជនឯងកាន់តែខ្លាំងឡើងៗ ធ្វើអោយចលនាតស៊ូរបស់ប្រជាជនខ្មែរកាន់តែរីកធំទៅៗ ដូចជាករណីនៅស្រុកត្បូងឃ្មុំ (ខេត្តកំពង់ចាម) និងស្រុកសៀមប៉ាង (ខេត្ត ស្ទឹងត្រែង) នៅស្រុកបកែវ (ខេត្តរតនៈគិរី) បានងើបឡើងក្រោម ការដឹកនាំរបស់លោក ហេង សំរិន មេបញ្ជាការកងពលលេខ ៤ ។ ចលនាតស៊ូនេះ គឺបានអំពាវនាវអោយប្រជាជនខ្មែរនៅទូទាំងប្រទេស ក្រោកឈរឡើង សាមគ្គីគ្នាប្រឆាំងនឹងរបបឃោរឃៅ ផ្តាច់ការ ហើយចូលរួមចំណែកក្នុងការកសាងប្រទេសកម្ពុជាឡើងវិញ ប្រកបដោយឯករាជ្យ សន្តិភាព សេរីភាព និងសុភមង្គល។

នៅថ្ងៃទី ០២ ខែធ្នូ ឆ្នាំ១៩៧៨ ក្រោមការដឹកនាំរបស់អ្នកស្នេហាជាតិ បានបើកសម័យប្រជុំមហាសន្និបាទតំណាងកម្លាំងរំដោះជាតិ គ្រប់តំបន់ទូទាំងប្រទេស ហើយជាលទ្ធផល បានសម្រេចជាឯកច្ឆន្ទបង្កើតជារណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលមានសមាជិក ១៤រូប ក្នុងនោះមានលោក ហេង សំរិន ជាប្រធាន[159] ហើយដោយមានជំនួយពីកងទ័ពវៀតណាមកងកម្លាំងរណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក៏បានវាយប្រយុទ្ធប្រឆាំងនឹងពួក ប៉ុល ពត រំដោះប្រជាជនខ្មែរ និងទឹកដី រហូតដល់ទទួលបានជោគជ័យ នៅថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩។

## ៨.២. ស្ថានភាពវិស័យសេដ្ឋកិច្ច

### ៨.២.១ វិស័យកសិកម្ម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានឈរលើទស្សនៈវិស័យថា មានស្រូវគឺមានអ្វីៗទាំងអស់។ ដូច្នេះ ក្នុងរបប ប៉ុល ពត ពួកគេបានបង្ខំប្រជាជនអោយទៅរស់នៅតាមទីជនបទ ហើយបង្ខំអោយធ្វើស្រែចំការយ៉ាងធ្ងន់ធ្ងរ។កសិករទាំងអស់ បានធ្វើការងារជាសមូហភាព ដោយបង្ខំ ដូចសត្វធាតុ ។

នៅសម័យកម្ពុជាប្រជាធិបតេយ្យ ប្រជាពលរដ្ឋស្ទើរតែ ១០០% ត្រូវបានពួកអង្គការបង្ខំអោយធ្វើការងាររួមគ្នា ប្រកបរបរកសិកម្មយ៉ាងធ្ងន់ធ្ងរជាទីបំផុត ទាំងយប់ទាំងថ្ងៃមិនថាឈឺឬជានោះទេ ពោលគឺ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្មែរក្រហម គឺការពង្រឹងវិស័យកសិកម្ម សម្រាប់ការផ្គត់ផ្គង់វិស័យសេដ្ឋកិច្ចទាំងមូល។[161] ដោយពឹងផ្អែកលើវិស័យកសិកម្មនេះ ប្រទេសកម្ពុជាបានត្រូវធ្វើសមូហភាវូបនីយកម្ម និង ជាតូបនីយកម្ម លើគ្រប់វិស័យនៃខឿនសេដ្ឋកិច្ចជាតិទាំងមូល។ ជាមួយនេះផងដែរ ពួកថ្នាក់ដឹកនាំរបស់អង្គការ បានបង្កើតនយោបាយ ខ្លួនទីពឹងខ្លួន ដោយរដ្ឋាភិបាលគ្រប់គ្រងលើកម្លាំងពលកម្មទាំងអស់ អោយដាំដំណាំស្រូវ និងធ្វើការងារជីកប្រឡាយ លើកទំនប់ទឹកជីកស្រះ និងបំពេញការងារយ៉ាងធ្ងន់ធ្ងរផ្សេងៗទៀត ព្រោះពួកគេបានមើល ឃើញពីបទពិសោធន៍នៃភាពរីកចម្រើនដ៏ខ្លាំងក្លានៅសម័យអង្គរ ដោយសារតែប្រព័ន្ធធារាសាស្ត្រនេះ។

ថ្វីត្បិតតែប្រទេសកម្ពុជានាសម័កាលនោះ បានទទួលយកឯកទេសកម្មខាងការផលិតស្រូវក៏ដោយ ក៏ប៉ុន្តែប្រជាជនខ្មែរពុំមានអាហារបរិភោគគ្រប់គ្រាន់នោះទេ ពីព្រោះផលិតផលអស់ទាំងនោះត្រូវផ្តល់ ជាជំនួយអោយទៅប្រទេសចិន។[162] ជាទូទៅក្នុងមួយថ្ងៃៗ ប្រជាជនខ្មែរសម័យនោះ គេអោយហូបតែបបររាវ ២ពេល ប៉ុណ្ណោះក្នុងមួយថ្ងៃ។

ក្នុងការប្រកបរបរកសិកម្ម ប្រជាជនខ្មែរត្រូវបានរៀបចំជាសហករណ៍ សម្រាប់បង្កបង្កើនផលដោយមានការរៀបចំជាក្រុមសាមគ្គីតូចៗ នៅតាមបណ្តាភូមិនិមួយៗនៃទីជនបទ ស្រែចំការ ដែលភាគច្រើនជ្រើសរើស យកកម្លាំងយុវជន (កងចល័ត) ធ្វើជាកម្លាំងស្នូល ដើម្បីអនុវត្តអោយបានតាមផែនការបង្កបង្កើនផលទាំងយប់ទាំងថ្ងៃ (ក្រោមពាក្យស្លោកថា ផលិតស្រូវគឺ ៣ តោន/ហិកតា)។[163] ប្រព័ន្ធធារាសាស្ត្រ បានបន្សល់ទុក រហូតដល់បច្ចុប្បន្ននេះ។ ចំណែកឯធនធានធម្មជាតិ ក្នុងសម័យនោះ ត្រូវបានប្រើប្រាស់អស់លទ្ធភាព ហើយសូម្បីតែកំប្លោកក៏ត្រូវអូសយក មកកាប់ចិញ្ច្រាំធ្វើជាជីសម្រាប់ដាក់ស្រែអស់ដែរ។ [164]

ក្រៅពីដំណាំស្រូវ ការដាំបន្លែ ផ្លែឈើ ថ្នាំជក់ ចិញ្ចឹមសត្វ និងនេសាទវិញ បក្សកុម្មុយនីស្តបានអោយប្រជាពលរដ្ឋ ដែលមានវ័យចាប់ពីអាយុ ៥០ឆ្នាំ ឡើងទៅ និងអ្នកទោសកម្រិតស្រាល ទទួលយកភារកិច្ចទាំងនោះ។ [165] ផ្ទៃដីបង្កបង្កើនផលអាចមានដល់ទៅ ២.៤ លាន ហិកតា រួមទាំងដីទំនាបខ្ពង់រាបដីល្បាប់ដីមានជីជាតិ និងដីហិលមួយចំនួនទៀត។ ប៉ុន្តែការអនុវត្តកន្លងមក កម្ពុជាប្រជាធិបតេយ្យ ធ្វើបានតែ ៥៨% នៃផ្ទៃដីដាំដុះតែប៉ុណ្ណោះ។ ដូច្នេះហើយ អ្នកសេដ្ឋកិច្ចសម័យនោះ បានបង្កើតផែនការសម្រាប់ពង្រីកផ្ទៃដីដាំដុះ និងផែនការពង្រីកការដាំ ដុះស្រូវរយៈពេល៤ឆ្នាំ។ ចំពោះទិន្នផលស្រូ

វល្អបំផុតនៅសម័យនោះ អាចទទួលបានប្រហែលជា ២ តោន ទៅ ២,៣តោនប៉ុណ្ណោះក្នុងមួយហិកតា។

ប៉ុន្តែអ្វីដែលគួរអោយកត់សម្គាល់នោះ ប្រជាជនខ្មែរក្នុងរបប ប៉ុល ពត គឺរកតែបបរពរហូបក៏មិនបានឆ្អែតផង។ តាមឯកសារខ្លះបង្ហាញថា នៅឆ្នាំ ១៩៧៧ ភូមិភាគពាយ័ព្យអាចប្រមូលផលស្រូវបានប្រហែលតែ ពី ៧០០.០០០ ទៅ ៩០០.០០០ តោន ប៉ុណ្ណោះ ប៉ុន្តែជាលទ្ធផលក្នុងឆ្នាំ ១៩៧៨ ភូមិភាគនេះ គឺបានខ្វះស្រូវពី ៧០០.០០០ ទៅ ៨០០.០០០តោន ដែលនាំអោយកើតមានគ្រោះទុរ្ភិក្សព្រោះស្រូវទាំងនោះ ត្រូវបានមជ្ឈិមបក្សនាំចេញទៅបរទេស។ បើយោងតាមឯកសារបក្ស នៅឆ្នាំ ១៩៧៧ គឺបានដាក់បទបញ្ជាអោយភូមិភាគ នេះត្រូវតែផលិតស្រូវអោយបាន ១.៦២០.០០០ តោន ដែលមួយភាគធំ សម្រាប់ធ្វើការនាំចេញទៅលក់នៅបរទេស។

ដោយឡែកនៅឆ្នាំ ១៩៧៦ ស្រូវភាគច្រើនគឺមជ្ឈិមបក្សបាន ទទួលពីភូមិភាគបូព៌ាទៅវិញ ប៉ុន្តែលុះដល់ឆ្នាំ ១៩៧៧-១៩៧៨ មជ្ឈមបក្សលែងទទួលបានស្រូវពីភូមិភាគនេះហើយ ព្រោះការដឹកនាំក្នុងតំបន់នេះ បានយកចិត្តទុកដាក់លើកម្រិតជីវភាពប្រជាជនប្រសើរជាងតំបន់ដ៏ទៃទៀតក្នុងប្រទេសខ្មែរ ដែលជាមូលហេតុនៃការចាប់ផ្តើងឡើងនូវទំនាស់ផ្នែកនយោបាយ និងការស្លាប់របស់លោក សោ ភឹម។

## ៨.២.២ វិស័យឧស្សាហកម្ម និងសិប្បកម្ម

ក្នុងរបបដិវត្តន៍កុំម្មុយនីស្តកម្ពុជា បានផ្លាស់ប្តូរទីតាំងរោងចក្រពីទីក្រុង ទៅជនបទវិញ។ [168] ពួកអង្គការបានកែច្នៃម៉ាស៊ីនយានយន្តមួយចំនួន តាមរយៈការស្លម៉ាស៊ីនទាំងនោះ រួចចាក់ជាផ្ទាំងបាស ខ្លះ

ជាដើម។ ចំពោះផលិតកម្មឧស្សាហកម្ម ដែលប្រទេសកម្ពុជាធ្លាប់មានពីមុនមកដូចជា រោងចក្រសហគ្រាស មធ្យោបាយដឹកជញ្ជូន និងផ្លូវគមនាគមន៍ ត្រូវបានកំទេចចោលទាំងស្រុង។[169] ចំពោះវិស័យសិប្បកម្ម គឺពុំមានអ្វីជាដុំកំភួននោះទេ ព្រោះប្រជាពលរដ្ឋគ្មានពេលសម្រាប់ចាក់ជាម្ជុកស្លឹកត្នោត និង

ស្នូនផ្ទាំងសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនទេ (ព្រោះជាកម្មសិទ្ធិរួម ប្រជាជនមានកម្មសិទ្ធិតែស្លាបព្រាមួយ និងកំប៉ុងទឹកដោះគោមួយប៉ុណ្ណោះ សម្រាប់ដាក់ទឹកបរិភោគ)។ ហើយអ្វីដែលពួកអង្គការបង្ខំ អោយធ្វើនៅតាមភូមិនិមួយៗនោះគឺធ្វើ បង្គី ចប និង កណ្តៀវច្រូតស្រូវ ដែលជាឧបករណ៍ផលិតកម្មកសិកម្មសំខាន់បំផុតក្នុងសម័យ ប៉ុល ពត។

## ៨.២.៣ វិស័យសេវាកម្ម

### ❖ ៨.២.៣.១ វិស័យពាណិជ្ជកម្ម

វិស័ពាណិជ្ជកម្ម ត្រូវបានបំបាត់ចោលទាំងស្រុង ព្រោះជាសេដ្ឋ កិច្ចក្នុងទ្រង់ទ្រាយ និងទម្រង់អន់ថយ ជាសេដ្ឋកិច្ចបែបសម័យបុរេប្រវត្តិ ព្រោះគេបានបំបាត់ក្រដាសប្រាក់ ទីផ្សារ និងទំនាក់ទំនងដោះដូរ។

ប៉ុន្តែដោយសារតែភាពអត់ឃ្លានរបស់ប្រជាពលរដ្ឋបានបង្ខំ អោយមានការដោះដូរស្រូវអង្ករដោយលួចលាក់ជាមួយរបស់របរដែល ពួកប្រជាជនមូលដ្ឋានចាស់(ជាម្ចាស់ស្រុកមុនរបបខ្មែរក្រហម) មានតម្រូវការដូចជា នាឡិការ ឬគ្រឿងអលង្កាផ្សេងៗពីព្រោះសម័យនោះគឺគ្មានការចរាចរជារូបិយវត្ថុ នោះទេ។

ចំពោះពាណិជ្ជកម្មក្រៅប្រទេសត្រូវបានផ្អាក ប៉ុន្តែបានដំណើរការឡើងវិញ នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ ១៩៧៧ ជាមួយប្រទេសចិន ដែលជាដៃគូរពាណិជ្ជកម្មដ៏សំខាន់។ បើតាមផែនការរបស់ពួកខ្មែរក្រហម គឺនៅឆ្នាំ ១៩៧៨ គេមានគម្រោងនាំស្រូវអង្ករចេញ ចំនួន ១.៦២៩.០០០ តោន ។ នៅក្នុងផែនការ៤ឆ្នាំរបស់ ប៉ុល ពត គេមានគម្រោងនាំចេញអង្ករ អោយបានជិត ៤ដង ដោយសង្ឃឹមថាទទួលបានរូបិយប័ណ្ណប្រមាណ ១.៣ ពាន់លានដុល្លា។ [171]

ថ្វីត្បិតតែយើងឃើញមាន ការដោះដូររវាងកម្ពុជា និងចិន លើផលិតផលស្រូវ និងសព្វាវុធ ប៉ុន្តែមិនមែនជាពាណិជ្ជកម្មនោះទេ គឺជាជំនួយទៅវិញទៅមក។ ចំពោះទំហំពាណិជ្ជកម្មមានក្នុងតម្លៃត្រឹមតែ ៣ ឬ ៤លាន ដុល្លារប៉ុណ្ណោះ។ ក្រោយមកក៏បានទំនាក់ទំនងជាមួយប្រទេស បារាំង អង់គ្លេស និងសហរដ្ឋអាមេរិក ដោយឆ្លងកាត់តាមហុងកុង។

### ❖ ៨.២.៣.២ វិស័យគមនាគមន៍

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានផ្លូវដែក ផ្លូវទឹក និងផ្លូវថ្នល់។ ហើយនៅលើដី គឺមានរទេះគោ និងនៅលើទឹកមានទូក។ ដោយសារតែគោលនយោបាយនាំប្រជាជនឆ្ពោះទៅរកម្ហូបអាហារ (ព្រោះពិបាកដឹក សៀងអាហារយកទៅផ្គត់ផ្គង់ដល់ប្រជាជននៅទីក្រុង) ដូច្នេះ រថភ្លើង និងរថយន្តត្រូវបានផ្អាកការប្រើប្រាស់ ហើយគេប្រើប្រាស់រទេះគោ ទូក និងធ្វើរជើងជំនួសវិញ។

### ❖ ៨.២.៣.៣ វិស័យហិរញ្ញវត្ថុ

ក្រោយពីបានវាយរំលំរដ្ឋាភិបាល លន់ នល់ មកពួកខ្មែរក្រហម បានឡើងកាន់អំណាច ហើយធ្វើការបិទមិនអោយមានការចាយលុយ និងមិនអោយមានការដោះដូរទៀតទេ។ ប៉ុន្តែ បក្សកុំមុយនីស្តកម្ពុជា សម័យនោះ គេបានបោះពុម្ពក្រដាសប្រាក់ដែរ។ ហើយរូបិយវត្ថុទាំងនេះ បានបោះពុម្ពនៅក្នុងឆ្នាំ ១៩៧៥ និងគ្រប់គ្រងដោយធនាគារកម្ពុជា។ ការបោះពុម្ពសាច់ប្រាក់នេះ មានគោលបំណង៣យ៉ាងគឺ៖

- ជានិមិត្តរូបដើម្បីបំភ័ន្តភ្នែកសកលលោក
- សម្រាប់ទូទាត់ពាណិជ្ជកម្មជាមួយបរទេស (ចិនជាដើម)

– ទុកបើកប្រាក់បៀវត្សដល់កម្មាភិបាលរបស់ពួកគេ។

ប៉ុន្តែយើងពិនិត្យឃើញថា ជាក់ស្តែង រូបិយវត្ថុទាំងអស់នោះ ពេញមួយសម័យកាលនៃរបប ប៉ុល ពត ពុំបានចរាចរនោះឡើយ។

## ៨.៣. វិស័យសិក្សាធិការជាតិ

ក្នុងរបបខ្មែរក្រហម វិស័យសិក្សាធិការជាតិ ដែលពីមុនៗមក មានការរីកចម្រើន ក៏ត្រូវបានបិទទ្វារគ្រប់ភូមិសិក្សា។ សាលារៀនបាន ប្រែក្លាយទៅជាឃ្លាំងសព្វាវុធ ក្លាយជាក្រោលគោ ជាមន្ទីរឃុំឃាំង និង ជាកន្លែងផ្ទុកសម្ភារៈគ្មានតម្លៃផ្សេងៗ។

មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ បានអនុវត្តន៍ការសម្លាប់យ៉ាងរង្គាលមកលើ បញ្ញវ័ន្តខ្មែរ សាស្ត្រាចារ្យ ស្ទើរតែគ្មានសល់។ ហើយសាលារៀនទាំងអស់ គឺត្រូវបានបិទទ្វារ។ តាមរបាយការណ៍របស់សូវៀត បានអោយដឹងថា គ្រូបង្រៀន ៩០% ត្រូវបានសម្លាប់ដោយខ្មែរក្រហម។ ចំនួនគ្រូបង្រៀនគឺបានថយចុះពី នៅក្នុងឆ្នាំ ១៩៧០ មកនៅត្រឹមតែ ៥.០០០ នាក់ ក្នុងឆ្នាំ ១៩៨០ ក្នុងនោះ សាស្ត្រាចារ្យ សាកលវិទ្យាល័យ នៅសល់តែ ៥០ នាក់ ដែលនៅឆ្នាំ១៩៧០ មានចំនួន ៧២៥ នាក់។ គ្រូមធ្យមសិក្សានៅសល់តែ ២០៧ នាក់ ដែលពីមុន មកមានចំនួន ២.៧១៧ នាក់ និង គ្រូបឋមសិក្សានៅសល់តែ ២.៧១៧ ដែលនៅឆ្នាំ ១៩៧០ មានចំនួន ២១.៣១១នាក់។ វិស័យអប់រំស្ថិត ក្រោមការគ្រប់គ្រង់របស់បដិវត្តន៍ ហើយក្មេងជំទង់ និងកុមារត្រូវបាន ពង្វក់ក្នុងការងារ។ ដូច្នេះ អនក្ខរភាពបានគ្របដណ្តប់ស្ទើរតែទាំងស្រុង ហើយកុមារដែលមានអាយុ ១៤ឆ្នាំ ស្ទើរតែទាំងអស់ បានបាត់បង់មូលដ្ឋាននៃការសិក្សារបស់ខ្លួន។

## ៨.៤. វិស័យសុខាភិបាលសាធារណៈ

ចំពោះការថែទាំសុខភាពវិញ អង្គការមិនជឿទុកចិត្តចំពោះអ្នក ដែលបានទទួលការសិក្សាពីសាលាវណ្ណៈដិះជាន់នោះទេ។ អង្គការបាន លើកស្ទួយនារីកសិករក្មេងៗ ដែលមិនបានរៀនសូត្រ ព្រោះជាប់រវល់លះបង់ពេលវេលាបម្រើបដិវត្តន៍អោយធ្វើជាគ្រូពេទ្យ។ ពេទ្យនារី តែងតែត្រូវបានធ្វើការផ្លាស់ប្តូរសមាសភាពជាញឹកញាប់។[176] ពួកក្រុមគ្រូពេទ្យបដិវត្តន៍នេះ ខ្លះបានរៀនសូត្ររយៈពេលតែមួយម៉ោងប៉ុណ្ណោះ រួចចេញមកអនុវត្តការព្យាបាលភ្លាម។

នៅក្នុងមន្ទីរពេទ្យអង្គការបានបែងចែកជា ៥ផ្នែក មានដូចជា ធ្មប ជម្ងឺទូទៅ ស្លថ្នាំ ដាំបាយ និង បង្កបង្កើនផល។ ចំពោះផ្នែកស្ល៍ចែកចេញជា ២ទៀត គឺថ្នាំបុរាណ និងថ្នាំសម័យ។ ចំពោះអ្នកជម្ងឺវិញត្រូវចែកជាអ្នកជម្ងឺ ១៧មេសា (ប្រជាជនជម្លៀសពីទីក្រុង) និងអ្នកជម្ងឺប្រជាជនមូលដ្ឋាន។ ដោយក្តីស្រេកឃ្លាន ប្រជនជនបានបរិភោគផ្តេសផ្តាស រួមទាំងធ្វើការហួសកម្លាំងបណ្តាលអោយរាងកាយចុះទន់ខ្សោយ ហើយទទួលរងនូវជម្ងឺរាតត្បាតផ្សេងៗ ដូចជាកើតជាជម្ងឺហើម។ ជម្ងឺនេះត្រូវបានគេស្តីបន្ទោសថា ពួកអាមេរិក បាចម្សៅគីមីពុល។ ការកំណត់អាហារ ធ្វើអោយស្ត្រីទើបតែសម្រាលកូនរួចងាយនឹងរងជម្ងឺគ្រប់ប្រភេទ ជាពិសេសជម្ងឺខ្វះទឹកដោះ។

នៅក្នុងស្រុកត្រាំកក់ ប្រជាជន១៧មេសា ស្លាប់ក្នុងមួយថ្ងៃៗ ពី ៥ ទៅ ២០ នាក់ ដោយអត្រាស្លាប់នេះ មិនបានគិតពីចំនួនអ្នកស្លាប់ក្នុងពេទ្យឃុំ តាមការដ្ឋាននានា និងតាមផ្ទះផងទេ។ ផ្ទុយទៅវិញ បក្សកុំម្មុយនីស្តនៃរបបកម្ពុជាប្រជាធិបតេយ្យ បានផ្សព្វផ្សាយតាមវិទ្យុ និងចុះទស្សនាវដ្តីថា សុខភាពប្រជាពលរដ្ឋល្អ បរិបូរណ៍ បានកម្ចាត់ជម្ងឺគ្រុនចាញ់ និងជម្ងឺសង្គមផ្សេងៗ។ បន្ថែមពីលើនេះ អត្រាកំណើតមានដល់ ៥០% ព្រោះទារកបានកើតនៅឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ មានចំនួនដល់ ៣៩២.០០០ នាក់ ក្នុងចំនួនមនុស្ស ៧.៨០០.០០០ នាក់។ ឯចំនួនអត្រាស្លាប់មិនដល់ ១៣ ភាគពាន់ទេ។[177] ប៉ុន្តែជាក់ស្តែង ផ្នែកវេជ្ជសាស្ត្រនៅសម័យនោះ ពុំមានគ្រូពេទ្យណាម្នាក់យល់សោះ ហើយគេចេះតែអោយថ្នាំ ចាក់ថ្នាំ និងវិភាគជម្ងឺស្មានៗ ព្រមទាំងព្យាបាលជម្ងឺដោយថ្នាំបុរាណ ឬហៅថា ថ្នាំអាចម៍ទន្សាយ។

## ៨.៥. វិស័យសង្គមកិច្ច

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេបានបំបែកប្រជាជន ដូចជា ប្តី និងប្រពន្ធ កូន និងឪពុកម្តាយអោយរស់នៅដោយឡែកៗពីគ្នា មានលក្ខណៈជាក្រុម។ ឪពុកម្តាយគ្មានសិទ្ធិលើកូន (ព្រោះជាកូនរបស់អង្គការរដ្ឋ)។ ប្រជាជនទាំងអស់គ្មានសិទ្ធិប្រឆាំងនឹងអង្គការនោះទេ ព្រោះអង្គការអាចសម្លាប់ចោល

ភ្លាមៗ។ ពួកវាមិនត្រឹមតែសម្លាប់មន្ត្រីរាជការ ទាហាន ប៉ូលីស គ្រូបង្រៀន ប៉ុណ្ណោះទេ ប៉ុន្តែវាសម្លាប់ប្រជាជនទូទៅ ដែលមិនទទួលស្គាល់ ឬជំទាស់នឹងលទ្ធិកម្ពុជាប្រជាធិបតេយ្យ។ គេផ្សឹក ឬធ្វើគុតព្រះសង្ឃ បំបាត់ជំនឿ សាសនា និងទំនៀមទំលាប់ប្រពៃណីផ្សេងៗចោលទាំងស្រុង។ គេតម្រូវអោយរៀបអាពាហ៍ពិពាហ៍ ខុសពីប្រពៃណីជាតិ ម្តងពី ២០ ទៅ ៣០ គូ ដោយគ្រាន់តែអោយផ្លូវផ្តង់គ្នា ហើយអង្គការជាអ្នកសម្រេច និងទទួលស្គាល់ ។

## ៨.៦.សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ ទៅលើប្រវត្តិសេដ្ឋកិច្ច នៃរបបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ រួចមក យើងអាចធ្វើសេចក្តីសន្និដ្ឋានបានដូចខាងក្រោមនេះ ៖

- ក្រោយពីពួកអង្គការខ្មែរក្រហមទទួលបានជ័យជំនះនាថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ លើរបបសាធារណៈរដ្ឋខ្មែររបស់លោក លន់ នល់ ពួកខ្មែរក្រហមបានជម្លៀសប្រជាជនខ្មែរយ៉ាងទាន់ហន់ចេញពីទីក្រុង ភ្នំពេញ និងទីប្រជុំជននានា ក្នុងរយៈពេលតែ ៣ថ្ងៃ ប៉ុណ្ណោះ ដោយយកលេសថា ពួកអាមេរិកអាចនឹងមកទម្លាក់គ្រាប់បែកសងសឹកវិញ។
- បន្ទាប់មក ពួកអង្គការខ្មែរក្រហមផ្តាច់ការ បានចាប់ផ្តើមអនុវត្តន៍ នូវលទ្ធិកុម្មុយនីស្តនិយមបែបចិននិយម ដែលមិនធ្លាប់មាននៅលើលោក បើទោះបីជាប្រទេសចិនខ្លួនឯង ឬក៏អតីតសហភាពសូវៀតក៏ដោយក៏មិនដែលបានអនុវត្តន៍នូវលទ្ធិបែបព្រៃផ្សៃ យង់ឃ្នង់ អមនុស្សធម៌ បែបនេះ នោះដែរ។

- នៅសម័យនោះ បញ្ញវ័ន្ត វិស្វករ គ្រូបង្រៀន វេជ្ជបណ្ឌិត ទាហាន ប៉ូលីស មន្ត្រីរាជការ និងអ្នកមានទ្រព្យធន គឺអ្នកទាំងអស់នោះ ទោះបីជាមិនបានប្រព្រឹត្តអ្វីខុសឆ្គងចំពោះអង្គការក៏ដោយ ក៏ប៉ុន្តែពួកគេ ត្រូវបានអង្គការកំណត់ថា ជាសត្រូវរបស់បដិវត្តន៍នៃរបបខ្មែរក្រហមរួចទៅហើយ ហើយក៏ជាមុខសញ្ញា ដែលត្រូវគេសម្រាប់យកទៅកម្ទេចដែរ (គឺសម្លាប់ចោល)។ ចំពោះមនុស្សដែលនៅរស់ គឺត្រូវគេបង្ខំអោយធ្វើការងារអោយអង្គការបដិវត្តន៍ ហើយត្រូវរស់នៅក្នុងសភាពគរ ថ្លង់ ភ័យ ព្រួយគ្រប់វិនាទី ហើយម្នាក់ៗទន្ទឹងរង់ចាំតែថ្ងៃមរណាតែប៉ុណ្ណោះ។
- ចំពោះគោលនយោបាយសេដ្ឋកិច្ចនៃរបបខ្មែរក្រហម គឺគ្មានអ្វីដែលប្រសើរនោះទេ ថ្វីត្បិតតែពួកមេដឹកនាំអង្គការសម័យនោះ បានអួតអាងថា នឹងដឹកនាំប្រទេសអោយមានការរីកចម្រើនជឿនលឿន មហាអស្ចារ្យ មហាលោតផ្លោះ ហើយក្នុងរយៈពេលតែ ២ ឬ ៣ ឆ្នាំ ប៉ុណ្ណោះ គេនឹងទទួលបាននូវការអភិវឌ្ឍ ដោយមិនពឹងផ្អែកលើបច្ចេកទេសអ្វីទាំងអស់ ពោលគឺ ឈរលើទស្សនៈខ្លួនទីពឹងខ្លួន។
- ជាតុពិត នៃទស្សនៈទានសេដ្ឋកិច្ច និងការអនុវត្តនូវគោលនយោបាយសេដ្ឋកិច្ចរបស់អង្គការខ្មែរក្រហម គឺឈរលើគោលចំហរសមូហភាវូបនីយកម្ម ពង្រឹងសមូហភាពកែលម្អសមូហភាពជាប់ជានិច្ច ហើយប្រឆាំងទៅនឹងកម្មសិទ្ធិឯកជន ប្រឆាំងនឹងទីផ្សារ ប្រឆាំងនឹងការអបរ ហើយមិនទទួលស្គាល់នូវបច្ចេកទេស បច្ចេកវិទ្យា និងភាពទំនើបកម្មណាមួយឡើយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។
- ពួកអង្គការខ្មែរក្រហម ទទួលស្គាល់តែវិស័យកសិកម្មបែបអន់ថយតែប៉ុណ្ណោះ ហើយប្រើប្រាស់កម្លាំងមនុស្ស សត្វ រួមផ្សំជាមួយនឹងធនធានធម្មជាតិ ដើម្បីសម្រេចគោលដៅ គឺទទួលបានទិន្នផលស្រូវ ៣តោន/ហិកតា។ ប៉ុន្តែជាក់ស្តែង ពួកគេមិនដែលបានសម្រេចបំណង ម្តងណាឡើយ។
- ដើម្បីអនុវត្តន៍ផែនការ នៃការកសាងវិស័យកសិកម្មបែបបុរេប្រវត្តិសាស្រ្តរបស់គេ ពួកអង្គការអាវខ្មៅ បានបង្ខំអោយប្រជាពលរដ្ឋស្លាបនាហេង្ការចនាសម្ព័ន្ធធារាសាស្រ្តពោលគឺ ជីកប្រឡាយលើកទំនប់ទឹក ជីកអាងស្តុកទឹក ស្ទើរតែគ្រប់ទីកន្លែងនៃផ្ទៃប្រទេស ដោយសង្ឃឹមថា សមិទ្ធិផលទាំងនោះ អាចជួយដល់ការកសាងសេដ្ឋកិច្ចកសិកម្ម។
- ដោយឡែក ចំពោះវិស័យឧស្សាហកម្ម និងសិប្បកម្ម នាសម័យនោះ ត្រូវបានផ្អាកសកម្មភាពទាំងស្រុង។ អ្វីដែលនៅសេសសល់នោះ គឺវិស័យសិប្បកម្មផលិតបរិក្ខារកសិកម្មអន់ថយដូចជាធ្វើ បង្គី ចប កណ្តៀវ នង្គ័ល រនាស់ ស្នាចបាច់ទឹក រហាត់ទឹក ខ្សែគោ ដងរែក ល្អី ដែលជាសម្ភារៈសាមញ្ញ បម្រើអោយវិស័យកសិកម្មបែបបុរាណតែប៉ុណ្ណោះ។
- ទោះបីជាពួកអង្គការ បានបង្ខំអោយប្រជាពលរដ្ឋខ្មែរទាំងអស់ ធ្វើការងារច្រើនលើសលប់ ធ្វើការទាំងយប់ទាំងថ្ងៃក៏ដោយ ប៉ុន្តែផ្ទុយទៅ វិញ ពួកគេមិនដែលបានផ្តល់របបអាហារគ្រប់គ្រាន់ដល់ប្រជាជនខ្មែរ ខ្លួនឯងនោះទេ ដែលធ្វើអោយប្រជាជនម្នាក់ៗ មានរូបរាងស្គមស្គាំងស្បែកដ

ណ្តាប់ធ្មឹង គ្មានកម្លាំងកំហែងនិងមានជម្ងឺជាប្រចាំ ហើយត្រូវបានស្លាប់ជាបន្តបន្ទាប់ជារៀងរាល់ថ្ងៃ។

- ក្រៅពីបញ្ហាជីវភាពដែលរស់ក្នុងរបបអាហារខ្វះខាត និងហូបតែបបរាវ (លាយជាមួយគ្រាប់ពោត ឬដំឡូងមី ឬលាយជាមួយគល់ចេក) ហើយហូបរួមគ្នាក្នុងរបបរតែ ២ចាន/ម្នាក់ ហើយចំនួន ២ល/ថ្ងៃ គឺប្រជារាស្ត្រខ្មែរគ្មានកម្មសិទ្ធិអ្វីទាំងអស់លើជីវិតផ្ទាល់ខ្លួន ព្រោះពួកគេគឺជាមនុស្សរបស់អង្គការបដិវត្តន៍ ហើយអ្វីដែលប្រជាជនខ្មែរមានជាកម្មសិទ្ធិនោះ គឺស្លាបព្រាមួយ ចានមួយ ខោអាវពណ៌ខ្មៅ ២កំប្លេ ក្រម៉ាមួយ ហើយគ្មានទាំងស្បែកជើងពាក់ផង។

ដោយយោងលើស្ថានភាពដូចបានរៀបរាប់ខាងលើនេះហើយ បានជាតែក្នុងរយៈពេល ៣ឆ្នាំ ៨ខែ ២០ថ្ងៃ តែប៉ុណ្ណោះ របបកម្ពុជាប្រជាធិបតេយ្យ បានសម្លាប់ប្រជាជនខ្មែរស្លូតត្រង់អស់ជាង៣លាននាក់ ហើយនៅក្នុងប្រទេសខ្មែរទាំងមូល ពុំមានគ្រួសារណាមួយ អាចគេចផុត ពីការធ្វើបាបយ៉ាងព្រៃផ្សៃ និងការកាប់សម្លាប់នោះឡើយ។ ពិសេសទៅទៀត ដែលជាទីអវសាននោះ របបខ្មែរក្រហមខ្លួនឯងត្រូវបានរលាយសាបសូន្យ ដោយសារតែការងើបតស៊ូប៉ះបោរប្រឆាំងនឹងពួកគេវិញ ពីសំណាក់ប្រជារាស្ត្រខ្មែរខ្លួនឯង។

# ជំពូកទី ៩
# សេដ្ឋកិច្ចកម្ពុជា សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា
# ឆ្នាំ ១៩៧៩ - ១៩៨៨

## ៩.១. ស្ថានភាពនយោបាយ

ព្រឹត្តិការណ៍ ថ្ងៃទី ៧ មករា ឆ្នាំ១៩៧៩ គឺជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានសហការជាមួយកងទ័ពវៀតណាម ធ្វើការវាយលុកចូលមកដល់ទីក្រុងភ្នំពេញ។ បន្ទាប់មកនៅថ្ងៃទី១៤ ខែមិនា ឆ្នាំ១៩៧៩ នៅរាជធានីភ្នំពេញ រណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបើកសម័យប្រជុំសន្និបាតថ្នាក់ជាតិទូទាំងប្រទេសលើកទី១ ដែលបានទទួលភារកិច្ចស្តារស្ថានភាពសេដ្ឋកិច្ច ដែលបានធ្លាក់ក្នុងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរកន្លងមកក្នុងរបប ប៉ុល ពត។ មហាសន្និបាតបានកំណត់ថាជាការចាំបាច់ប្រទេសកម្ពុជា ត្រូវតែពន្លឿនសង្វាក់នៃការស្តារស្ថានភាពជីវភាពប្រជាជន តាមរយៈការជួយឧបត្ថម្ភគ្រប់បែបយ៉ាងដល់ប្រជាពលរដ្ឋ ដែលបានវិលត្រឡប់មកកាន់ ស្រុកកំណើតវិញ និងតាមរយៈការបង្កើតអោយមានលក្ខខណ្ឌប្រសើរ ក្នុងការរៀបចំសេដ្ឋកិច្ចជាតិឡើងវិញ។

បន្ទាប់មក ថ្ងៃទី ២៩-៣០ ខែកញ្ញា ឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញ បានបើកសម័យប្រជុំនៃមហាសន្និបាតលើកទី២ របស់រណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលនៅក្នុងនោះមានការចូលរួមពីសំណាក់ប្រតិភូ ចំនួន ៥០០ រូប ដែលជាតំណាងខេត្ត-ក្រុងទាំងអស់របស់ប្រទេស។ អង្គប្រជុំនៃមហាសន្និបាត បានធ្វើសេចក្តីរាយការណ៍បូកសរុបអំពីសកម្មភាពការងាររបស់រណៈសិរ្ស និងក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជានៅក្នុងការតស៊ូលុបបំបាត់នូវផលវិបាកដ៏ធ្ងន់ធ្ងរនៃរបបត្រួតត្រាដ៏ឃោរឃៅ និងផ្តាច់ការរបស់ ប៉ុល ពត ហើយបានអនុម័តលើសេចក្តីសម្រេច ដែលទាក់ទងទៅនឹងកិច្ចការស្តារ និង
កសាងសេដ្ឋកិច្ច-សង្គម ព្រមទាំងបានបញ្ជាក់អំពីគោលដៅសំខាន់ៗ ក្នុងការស្តាបនាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច ក៏ដូចជាក្នុងវិស័យនយោបាយ។

ប្រតិភូទាំងឡាយរបស់មហាសន្និបាត បានអនុម័តលើលក្ខន្តិកៈបណ្តោះអាសន្នដោយបញ្ជាក់ថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺជាអង្គការមហាជនរបស់ប្រជាជនកម្ពុជា ដែលបានធ្វើការប្រយុទ្ធប្រឆាំងនឹងរបប ប៉ុល ពត ប្រឆាំងនឹងពួកចក្រពត្តិ និងពួកប្រតិកិរិយាទាំងអស់។ អង្គការនេះ ធ្វើការតស៊ូដើម្បីឯករាជ្យភាព ការសង្គ្រោះជាតិ ការស្តារ និងស្ថាបនាកម្ពុជា តាមមាគ៌ាឆ្ពោះទៅកាន់សង្គមនិយម ក្នុងការពង្រឹងសន្តិភាព និងស្ថេរភាពនៅតំបន់អាស៊ី-អាគ្នេយ៍ និងនៅលើពិភពលោក។

នៅក្នុងដំណោះស្រាយបញ្ហាសេដ្ឋកិច្ច ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជាបានយកចិត្តទុកដាក់ពិសេសទៅលើបញ្ហា ដែលទាក់ទង ទៅនឹងការស្តារស្ថានភាពខាងផលិតកម្ម កសិកម្ម និងឧស្សាហកម្មឡើងវិញ។ ភារកិច្ចជាបន្ទាន់បំផុតបានចោទមានឡើងចំពោះសង្គមជាតិនាសម័យនោះគឺសេចក្តីអត់

ឃ្លាន ការខ្វះខាតស្បៀងអាហារខ្វះថ្នាំព្យាបាល។ល។ ដែលក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ត្រូវតែស៊ូជំនះអោយខាងតែបាន។

## ៩.២. ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច - សង្គម

បន្ទាប់ពីបានទទួលជ័យជំនះភ្លាម រដ្ឋាភិបាលសម័យនោះបានចាប់ផ្តើមបំពេញការងារព្យាបាលនូវដំបៅដ៏ធ្ងន់ធ្ងរ ដែលបានកើតមានឡើងចំពោះប្រទេសកម្ពុជា។ រដ្ឋបានធ្វើសេចក្តីប្រកាសស្តីអំពីការបដិសេធន៍ចោលនូវច្បាប់ដែលប្រឆាំងនឹងប្រជាជនរបស់ពួក ប៉ុល ពត ដែលជាសេចក្តីប្រកាស ស្តីអំពីការធានាដល់សេរីភាពប្រជាធិបតេយ្យ ដល់សេរីភាពក្នុងជំនឿសាសនា ដល់សិទ្ធិសេរីភាពចំពោះការងារ ការឈប់សម្រាក ការសិក្សារៀនសូត្រ សមភាពសង្គម និងការគោរពចំពោះបុគ្គលិកលក្ខណៈមនុស្សជាតិ ដែលរបបប៉ុល ពត ពុំបានអនុវត្ត។ ក្រោយថ្ងៃរំដោះ នៅគ្រប់ទិសទីទាំង ទីក្រុង និងជនបទស្រែ

ចំការ គេបានបង្កើតគណៈកម្មាធិការប្រជាជនបដិវត្តន៍ស្វ័យតនានា ដែលទទួលភារកិច្ចអនុវត្តការរៀបចំសង្គមជាតិ តាមរបៀបបដិវត្តន៍សង្គមនិយម ទទួលភារកិច្ចផ្តល់ជំនួយដល់ជនជាតិកម្ពុជា ទាំងអស់ ដែលបានវិលត្រលប់មក កាន់ស្រុកកំណើតរបស់ខ្លួនវិញ និងបានចូលមករួមរស់ជាមួយសង្គមគ្រួសារ។

ការស្តារស្ថានភាពសេដ្ឋកិច្ចជាតិឡើងវិញ បានចាប់ផ្តើមប្រព្រឹត្តទៅនៅក្នុងស្ថានភាពដ៏លំបាកលំបិនយ៉ាងក្រៃលែង ព្រោះក្នុងរបប ប៉ុល ពត បានបំផ្លាញខ្ទេចខ្ទីគ្មានសល់នូវមូលដ្ឋានរចនាសម្ព័ន្ធសង្គមទាំងអស់របស់ប្រទេស ហើយមិនតែប៉ុណ្ណោះ ពួកវាបានធ្វើអោយមានវិនាសកម្ម និងមហន្តរាយដល់សេដ្ឋកិច្ចជាតិ ដែលទើបតែចាប់ផ្តើមរីកលូតលាស់បាន ២ ទសវត្ស ប៉ុណ្ណោះ(១៩៥០-១៩៧០)។ ជាពិសេសក្នុងរបប ប៉ុល ពត បានធ្វើអោយមានអន្តរាយដ៏ធ្ងន់ធ្ងរដល់វិស័យឧស្សាហកម្ម បរិក្ខាកសិកម្ម គមនាគមន៍ និងទូគមនាគមន៍របស់ប្រទេសជាតិទាំងមូល។

វិស័យកសិកម្មបានស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរបំផុត។ ការប្រហារជីវិតប្រជាជនគ្រប់វណ្ណៈអស់រាប់លាននាក់ បានបណ្តាលអោយ មានផលវិបាកយ៉ាងខ្លាំងក្លា ព្រោះចំនួនប្រជាជននៅទីជនបទបានចុះថយ។ ជីវភាពប្រជាជននៅតាមស្រុកស្រែចំការ មានលក្ខណៈខ្វះខាត នូវពូជដំណាំ ខ្វះខាតសត្វពាហនៈ ដែលជាកម្លាំងអូសទាញ ខ្វះខាត គ្រឿងសម្ភារៈបរិក្ខាកសិកម្ម។ កិច្ចការស្តារស្ថានភាពសង្គមអោយមានជីវភាពធម្មតាឡើងវិញ គឺជាបញ្ហាស្មុគស្មាញបំផុត ហើយប្រព្រឹត្តទៅយ៉ាងលំបាក។

ទាក់ទងទៅនឹងធនធានមនុស្ស ក្រោមរបប ប៉ុល ពត ពួកគេបានប្រហារជីវិតអ្នករដ្ឋការអស់ប្រមាណ ៨០% ក្នុងនោះមានមន្ត្រីរាជការស៊ីវិលនៅតាមបណ្តាក្រសួងនានា វិស្វករ អ្នកបច្ចេកទេស អ្នកជំនាញ ក្នុងវិស័យសេដ្ឋកិច្ចជាតិ គ្រូពេទ្យ គ្រូបង្រៀន សាស្ត្រាចារ្យ ត្រូវបានស្លាប់យ៉ាងវេទនា។ ស្របតាមឯកសារយោងបោះពុម្ពផ្សាយនៅទីក្រុងភ្នំពេញ បានបង្ហាញថា ក្នុងបណ្តាសាស្ត្រាចារ្យឧត្តមសិក្សាចំនួន ៧២០ នាក់ នៅ សល់តែ៥០ នាក់ ប៉ុណ្ណោះដែលរស់នៅ ក្នុងចំណោមគ្រូពេទ្យ ៤៨៧ នាក់ នៅសល់តែ ៥៤ នាក់ ក្នុងបណ្តាឱសថការីចំនួន ១៩៦នាក់ នៅ សល់តែ ១៥ នាក់ ក្នុងបណ្តាប

ញាវន្តដែលបានសិក្សានៅបរទេសចំនួន ១.០០០ នាក់ នៅសល់តែ ៨៥ នាក់ក្នុងចំណោមគ្រូបង្រៀនអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ២.៣០០នាក់ នៅសល់តែ ២០៧ ក្នុងចំណោមគ្រូបង្រៀនកម្រិតបឋមសិក្សាចំនួន ២១.៣១១ នៅសល់តែ ២.៧១៧ នាក់ ក្នុងចំណោមបណ្ឌិតនិស្សិតថ្នាក់ឧត្តមសិក្សាចំនួន ១.១០០ នាក់ នៅសល់តែ៤៥០ នាក់ ក្នុងចំណោមសិល្បៈករ ១.២៤១ នាក់ នៅសល់តែ ១២១ នាក់ ប៉ុណ្ណោះ។

ដូច្នេះតាមទិន្នន័យខាងលើយើងឃើញថា ក្រោយថ្ងៃរំដោះប្រទេស កម្ពុជា បានបាត់បង់ហេដ្ឋារចនាសម្ព័ន្ធសង្គមស្ទើរតែទាំងស្រុង ដែលជាបញ្ហាលំបាកក្នុងការស្តារស្ថានភាពសេដ្ឋកិច្ច-សង្គមឡើងវិញ។

## ៩.៣. ផលវិបាកនៃការបាត់បង់ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច - សង្គម

ក្រោយថ្ងៃរំដោះភ្លាម គេសង្កេតឃើញថា រោងចក្រ សហគ្រាស នៅគ្រប់ទីកន្លែងទូទាំងប្រទេសបានបិទទ្វារ ឬបានបំផ្លាញដោយរបប ប៉ុល ពត។ រូបិយវត្ថុត្រូវបានបោះបង់ចោលលែងប្រើការប្រទេសជាតិ គ្មានចរាចរទំនិញគ្មានទីផ្សារ គ្មានការផ្លាស់ប្តូរមុខទំនិញ ជារួមអាច និយាយបានថាទាក់ទងនឹងវិស័យផលិតកម្មគ្រប់ប្រភេទ ពេលនោះដែលពួក ប៉ុល ពត បានបន្សល់ទុក គឺការអត់ឃ្លាន ដោយគំរាមកំហែងជីវិតប្រជាជន មិនមែនតែក្នុងគ្រួសារមួយ ឬក្នុងភូមិមួយ ឬខេត្តមួយ ប៉ុណ្ណោះទេ គឺទូទាំងប្រទេសទាំងមូល។ ក្រោយពេលរំដោះរួច ប្រជាជន បាននាំគ្នាបោះបង់ចោលនូវរបបធ្វើពលកម្មប្រមូលផ្តុំ ការហូបបាយរួម ដោយគេនាំគ្នាបែងចែកមធ្យោបាយផលិតកម្ម ចែកសម្ភារៈប្រើប្រាស់ ចែកស្បៀងអាហារដែលនៅសល់បន្តិចបន្តួចក្រោយពីរបប ប៉ុល ពត សម្រាប់ជាវិធីនៃការរស់រានបន្តទៀត។

បញ្ហាដ៏ធ្ងន់ធ្ងរនេះ ត្រូវធ្លាក់មកលើស្មានៃរដ្ឋាភិបាលថ្មីជាអ្នកដោះស្រាយ រដ្ឋាភិបាលបានទទួលថ្មបាក់ ពីរបបមួយដែលគ្មានបន្សល់ទុកអ្វីក្រៅពីផលវិបាករាប់មិនអស់ប៉ុណ្ណោះទេ ដោយឡែក ស្បៀងអាហារ ដែលកងទ័ពរណៈសិរ្សសាមគ្គីសង្គ្រោះជាតិ វាយដណ្តើមបាន គឺមានចំនួនតិចតួចណាស់ បើប្រៀបធៀបទៅនឹងតម្រូវការរបស់ជាជន ដែលកំពុងជួបប្រទះនូវគ្រោះអត់ឃ្លាន។ ក្នុងសភាពការណ៍ដ៏តានតឹងនេះ ប្រទេសកម្ពុជា ត្រូវបានការជួយឧបត្ថម្ភពីបណ្តាប្រទេស មួយចំនួនដូចជា សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលបានជួយជាបន្ទាន់ដល់ប្រជាជន ដែលរស់នៅតំបន់ជាប់ព្រំដែនឡាវ ជាស្បៀងអាហារ និងសម្ភារៈប្រើប្រាស់។ ក្រៅពីនេះ គឺមានប្រទេសអតីតសហភាពសូវៀត បណ្តាអតីតប្រទេសសង្គមនិយមនៅអឺរ៉ុបខាងកើត ក៏បានចាប់ផ្តើមផ្តល់ជាបន្ទាន់នូវស្បៀងអាហារ ថ្នាំសង្កូវ សម្ភារៈប្រើប្រាស់ ឧបករណ៍ផលិតកម្ម វត្ថុធាតុដើម ដែលជាជំនួយអាចអោយយើង បានចាប់ផ្តើមនូវសកម្មភាពផលិតកម្មឧស្សាហកម្ម សិប្បកម្ម កសិកម្ម ដែលជាជំហានដំបូងនៃជីវិតសេដ្ឋកិច្ចសង្គម។ [180]

ចូលដល់ឆ្នាំ ១៩៨០ ប្រទេសមួយចំនួនទៀតមានទាំងប្រទេសឥណ្ឌាផង អង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល ក៏បានចាប់ផ្តើមផ្តល់ជាជំនួយជាបន្តបន្ទាប់អោយប្រទេសកម្ពុជាដែរ។ បញ្ហាគ្រប់គ្រងសេដ្ឋកិច្ច គឺជាបញ្ហាដ៏ថ្មីមួយសម្រាប់ថ្នាក់ដឹកនាំរដ្ឋដែលទើបនឹងកាន់អំណាច។ ហើយ

បានចាប់ផ្តើមស្តារ និងកសាងសង្គមមួយដែលគ្មានហេដ្ឋារចនាសម្ព័ន្ធខាងសេដ្ឋកិច្ច និងគ្មានហេដ្ឋារចនាសម្ព័ន្ធសង្គមទាំងមូល។

## ៩.៤. ទស្សនៈទាននៃការស្តារ និងការកសាងសេដ្ឋកិច្ច - សង្គម

ដោយសារតែនៅសម័យកាលនោះ ប្រទេសកម្ពុជាបានកំណត់យកមាគ៌ានយោបាយ ឆ្ពោះទៅរកការអនុវត្តលទ្ធិសង្គមនិយម ដូច្នេះនិន្នាការសេដ្ឋកិច្ច គឺ ជាប្រភេទសេដ្ឋកិច្ចផែនការ សេដ្ឋកិច្ចផែនការអន្តរកាល ឆ្ពោះទៅរកសេដ្ឋកិច្ចផែនការពេញលេញ។

ជាជំហានដំបូងនោះ ទស្សនៈវិស័យចំពោះការកសាងសេដ្ឋកិច្ច ជាតិស្ថិតនៅក្នុងលក្ខណៈខុសៗគ្នា មានមតិមួយចំនួនបានលើកឡើងថា យើងអាចកសាងសេដ្ឋកិច្ចសង្គម តាមបែបផែនសង្គមនិយមតែម្តង ដោយអនុញ្ញាតិអោយមានតែទ្រង់ទ្រាយសេដ្ឋកិច្ចរដ្ឋ និងសេដ្ឋកិច្ចសមូហភាពប៉ុណ្ណោះ។ រីឯសេដ្ឋកិច្ចគ្រួសារវិញ គឺស្ថិតនៅក្នុងសមាស ភាពបន្ទាប់បន្សំតូចតាចប៉ុណ្ណោះ ហើយមិនចាំបាច់អោយមានសេដ្ឋកិច្ច ឯកជនទេ ព្រោះទ្រង់ទ្រាយសេដ្ឋកិច្ចឯកជនបានស្លាប់ក្នុងរបប ប៉ុល ពត អស់ទៅហើយ។ ការជំទាស់មិនអោយមានសេដ្ឋកិច្ចឯកជន បានអូសបន្លាយអស់រយៈពេលយ៉ាងយូរបើទោះបីជាលើស្ថានភាពជាក់ស្តែង សេដ្ឋកិច្ចឯកជនបានកកើតឡើងវិញតាំងពីជំហានដំបូងម្ល៉េះ ហើយបានរីកដុះដាលជាបណ្តើរៗ នៅក្នុងវិស័យកសិកម្ម ពាណិជ្ជកម្ម វិស័យសិប្បកម្ម និងសេវាកម្មដឹកជញ្ជូន។ល។ ទស្សនៈនេះ បានអូសបន្លាយ រហូតដល់ចុងឆ្នាំ ១៩៨៤ ទើបរដ្ឋាភិបាល បានចេញសច្ចាប័នទទួលស្គាល់ទម្រង់សេដ្ឋកិច្ចឯកជន នៅក្នុងឱកាសមហាសន្និបាតរបស់ថ្នាក់ ដឹកនាំទូទាំងប្រទេស នាថ្ងៃទី ២ ដល់ ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៤ ។

ក្រៅពីទស្សនៈទានខាងលើនេះ ក៏មានទស្សនៈចង់បើកអោយ សេដ្ឋកិច្ចឯកជនជាចំណែកដ៏សំខាន់មួយ ក្នុងការជម្រុញការស្តារ និងអភិវឌ្ឍន៍ ផលិតកម្មសង្គម ដែលអាចបម្រើសេចក្តីត្រូវការរបស់ប្រជាជនបានគ្រប់គ្រាន់ ហើយគេមានបំណងប្រើប្រាស់អោយអស់នូវប្រភពដើមទុនឯកជន បច្ចេកទេស និងកម្លាំងពលកម្មសង្គមអោយបានប្រសើរ។

នៅសម័យនោះ ជុំវិញទស្សនៈស្តីពីការកសាងសេដ្ឋកិច្ចត្រូវបាន ថ្នាក់ដឹកនាំរដ្ឋ លើកយកមកពិភាក្សាជាប្រចាំ នៅក្នុងឱកាសប្រជុំធំៗ។ រីឯការដឹកនាំចាត់ចែងគ្រប់គ្រងសេដ្ឋកិច្ច ក៏ស្ថិតក្នុងការលំបាកដែរ ដោយរោងចក្រ សហគ្រាស ឬមូលដ្ឋានសេដ្ឋកិច្ចរដ្ឋផ្សេងៗទៀត គឺសុទ្ធតែដំណើរការឡើងតាមប្រព័ន្ធគ្រប់គ្រងចំណាយគ្រប់ចំណូលគ្រប់ ហើយការចំណេញ ឬខាត គឺជាបញ្ហារបស់រដ្ឋ ដែលជាអ្នកទទួលខុសត្រូវ។

## ៩.៥. ស្ថានភាព សេដ្ឋកិច្ច - សង្គម ឆ្នាំ ១៩៧៩ ដល់ ១៩៨៨

គួរបញ្ជាក់ថាទិន្នន័យស្ថិតិសេដ្ឋកិច្ចជាតិដែលផ្អែកលើប្រព័ន្ធស្ថិតិរបស់ជាតិ និងរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជា គឺគេពុំអាចរកបានចាប់តាំងពីឆ្នាំ ១៩៦៨ មកម្ល៉េះ។ ក្នុងនោះដែរ សម្រាប់ ដំណាក់កាលឆ្នាំ១៩៧៩ ដល់ឆ្នាំ ១៩៨៤ ទិន្នន័យស្ថិតិជាតិលើគ្រប់វិស័យសេដ្ឋកិច្ច-សង្គម ក៏ពុំទាន់មានការប្រមូលរៀបចំបាននៅឡើយទេ ព្រោះគេពិបាកនឹងធ្វើការស្រាវជ្រាវរុករក អំពីពត៌មានសេដ្ឋកិច្ចសំខាន់ៗ នាសម័យនោះណាស់។ ចំពោះដំណាក់កាលឆ្នាំ ១៩៨៤ ដល់ ១៩៨៩

យើងសង្កេតឃើញថា តួលេខស្ថិតិគណនេយ្យជាតិដែលផ្អែកលើប្រព័ន្ធ ផលិតកម្មសម្ភារៈទំនិញ ត្រូវបានរៀបចំឡើងវិញ។

### ៩.៥.១ វិស័យកសិកម្ម

តាមការសិក្សាស្រាវជ្រាវ បានអោយយើងដឹងថា ក្នុងរយៈពេល ១០ឆ្នាំ (១៩៧៩-១៩៨៩) គឺជាដំណាក់កាលថ្មីមួយសម្រាប់ប្រទេស កម្ពុជា ក្នុងការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឡើងវិញ។ រដ្ឋាភិបាលសម័យនោះ បានកំណត់នូវចំនួនមុខព្រួញសេដ្ឋកិច្ចសំខាន់ៗ នៅក្នុងវិស័សេដ្ឋកិច្ចកសិកម្មចំនួន ៤មុខព្រួញ គឺមានស្បៀង កៅស៊ូ ជលផល និងរុក្ខកម្ម។

**ផ្ទៃដី កម្លាំងអូសទាញ និងកម្លាំងពលកម្ម**

ចាប់តាំងពីឆ្នាំ ១៩៧៩ ដល់ ១៩៨៩ ផ្ទៃដីកសិកម្មនៅកម្ពុជា មានផ្ទៃក្រឡាប្រមាណជា ២ លាន ហិកតា ក្នុងនោះផ្ទៃដីស្បុងមានជិត ២លាន ហិកតា ត្រូវបានស្តារ និងដាក់អោយបង្កបង្កើនផល។ គោ ក្របី បានកើនឡើងពី ៧៦៨.០០០ ក្បាល នៅឆ្នាំ ១៩៧៩ ដល់ ១.៤៩៥.៦០០ ក្បាល នៅឆ្នាំ ១៩៨៨។ នៅឆ្នាំ ១៩៨៨ ត្រាក់ទ័រសម្រាប់ភ្ជួររាស់ បានកើនដល់ ១.៦៤៥ គ្រឿង។ កម្លាំងពលកម្មប្រមាណ ៨០% នៃកម្លាំងពលកម្មសង្គមបានបម្រើការនៅក្នុងវិស័យកសិកម្ម។

**ដំណាំស្រូវ**

ជារួមចាប់តាំងពីឆ្នាំ ១៩៧៩ មករហូតមកដល់ឆ្នាំ ១៩៨៨ ផលិតផលស្រូវពុំមានលក្ខណៈស្ថេរភាពឡើយ ទាំងផ្ទៃដី និងទាំងបរិមាណផលិតផល បញ្ហានេះបណ្តាលមកពីភាពរាំងស្ងួត និង ទឹកជំនន់។ ឆ្នាំដែលផលិតផលស្រូវ ទទួលបានទិន្នផលខ្ពស់មានឆ្នាំ ១៩៨៣ ដែលសម្រេចបានប្រមាណ ២.០២លានតោន នៅឆ្នាំ១៩៨៦ ប្រមាណ ២.០៩លានតោន និងឆ្នាំ ១៩៨៨ ទទួលបានប្រមាណ ២.៦លានតោន។ គិតជាមធ្យមទិន្នផលស្រូវប្រាំង បានកើនឡើងជាមធ្យមប្រមាណ ៣%។ យើងអាចពិនិត្យមើលទិន្នន័យទិន្នផលស្រូវ ចន្លោះឆ្នាំ ១៩៨០ រហូតដល់ឆ្នាំ ១៩៨៨ តាមរយៈតារាងខាងក្រោមនេះ ៖

| បរិយាយ | ទិន្នផលស្រូវ | បម្រែបម្រួល(%) |
|---|---|---|
| ១៩៨០ | ១.៧១៥.១៣០ | - |
| ១៩៨១ | ១.៤៨៩.២០០ | -១៥% |
| ១៩៨២ | ១.៨៩៩.២០០ | ២៦% |
| ១៩៨៣ | ២.០៣៩.១៩០ | ២,៥% |
| ១៩៨៤ | ២.២៥៨.២៥០ | ១០% |
| ១៩៨៥ | ១.៧៣៨.៤៩០ | -២៦% |
| ១៩៨៦ | ២.០៨៩.០៨០ | ១៦% |
| ១៩៨៧ | ១.៨១៣.៣៥០ | -១៥% |
| ១៩៨៨ | ២.៧០០.០០០ | ៣៣% |

*តារាងទិន្នផលស្រូវឆ្នាំ ១៩៨០ - ១៩៨៨(គិតជាតោន)* [182]

[182] ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២, ទំព័រ ៣៨៣ – ៣៨៤

សរុបមកចាប់តាំងពីឆ្នាំ ១៩៧៩ ដល់ ១៩៨៨ ប្រទេសកម្ពុជាបានស្តារផលិតផលស្រូវបាន យ៉ាងឆាប់រហ័ស ហើយតែក្នុងរយៈពេល ៣ ទៅ ៤ ឆ្នាំដំបូងក្រោយថ្ងៃរំដោះប្រទេសកម្ពុជាបានដោះស្រាយបញ្ហាគ្រោះទុរ្ភិក្សក្នុងទូទាំងប្រទេសបាន។ នាពេលបន្ទាប់មកទៀត និន្នាការឈានទៅរកការធ្វើកសិកម្មតាមលក្ខណៈប្រពលវប្បកម្ម បានរីកចម្រើនយ៉ាងខ្លាំងក្លាក្នុងមជ្ឈដ្ឋានប្រជាជន។ ប៉ុន្តែបើប្រៀបធៀបទៅនឹងសម័យមុនសង្គ្រាម យើងឃើញថា ផ្ទៃដីស្តារបានគឺនៅមានកម្រិតទាប ព្រោះនៅមានដីទំនេរច្រើន ជាពិសេសនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងតំបន់ផ្ទៃដីស្រូវឡើងទឹក។ លទ្ធភាពស្រោចស្រពដីស្រែទើបតែសម្រេចបានប្រមាណលើផ្ទៃដី ៣៧៨.០០០ ហិកតា ដែលត្រូវនឹង ២០% នៃផ្ទៃដីសរុបនៅឆ្នាំ ១៩៨៨។

**ដំណាំរួមផ្សំ**

ដំណាំផ្សេងៗទៀត កំពុងមានទំនោរកើនឡើង ទាំងផ្ទៃដី ទាំងបរិមាណផលិតផលជាពិសេសដំណាំឧស្សាហកម្មរយៈពេលខ្លី ហើយបានរក្សាតួនាទីដ៏សំខាន់ក្នុងការផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់បម្រើវិស័យ ឧស្សាហកម្ម និងបម្រើការនាំចេញ។ ដោយឡែកដំណាំពោត ដោយភូមិសាស្ត្រផ្ទៃដីប្រែប្រួល ដោយការចាត់តាំងប្រមូលទិញ និងគោលនយោបាយតម្លៃពុំទាន់បានសមស្របផ្ទៃដី និងបរិមាណផលិតផលមានទំនោរថយចុះចាប់តាំងពីឆ្នាំ ១៩៨១ រហូតមកដល់ឆ្នាំ ១៩៨៧។ ប៉ុន្តែ ចាប់តាំងពីឆ្នាំ ១៩៨៨ មក ដំណាំពោតមានទំនោររីកចម្រើនឡើងវិញ។

**ការចិញ្ចឹមសត្វ**

ក្នុងរយៈពេល ១០ឆ្នាំ ទាក់ទងទៅនឹងការចិញ្ចឹមគោ ក្របី ត្រូវ បានស្តារឡើងវិញ និងមានសន្ទុះរីកចម្រើនគួរសម ស្មើនឹងសម័យមុនសង្គ្រាម។ គោ ក្របី សរុបមានប្រមាណ ២.៥៩៨.០០០ ក្បាល នៅឆ្នាំ ១៩៨៨។ ប៉ុន្តែចំនួននេះពុំបានរាយស្មើគ្នាគ្រប់ទីកន្លែងនោះទេ ដែលជាហេតុនាំអោយតំបន់ខ្លះមានបរិមាណគោច្រើន តំបន់ខ្លះទៀតមានបរិមាណគោតិច ដែលជាមូលហេតុកើតមានបញ្ហាកង្វះខាតកម្លាំងអូសទាញ។ ទន្ទឹមនឹងនេះ ការចិញ្ចឹមសត្វនៅតាមមជ្ឈមណ្ឌលរដ្ឋនៅមានកម្រិតទាប ដោយសារខ្វះខាតបណ្តាញពង្រីកពូជគោ និងខ្វះខាតការផ្សព្វផ្សាយ។ ជារួមការចិញ្ចឹមសត្វពាហនៈនាសម័យនោះ មានលក្ខណៈទន់ខ្សោយនៅឡើយ មូលហេតុទាំងនេះបណ្តាលមកពី៖

- វិធានការលើផ្នែកបសុព្យាបាលពុំមានប្រសិទ្ធភាពខ្ពស់ ដោយខ្វះថ្នាំចាក់ការពារ និងពុំទាន់មានបច្ចេកទេសព្យាបាលជម្ងឺ
- ការផលិតចំណីសត្វ ពុំទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ
- មូលដ្ឋានសម្ភារៈបច្ចេកទេសនៃការចិញ្ចឹមសត្វ ពុំទាន់ទំនើប។

**ដំណាំកៅស៊ូ**

ចាប់តាំងពីឆ្នាំ ១៩៨០ វិស័យកៅស៊ូត្រូវបានរៀបចំឡើងវិញ។ មកដល់ឆ្នាំ ១៩៨៨ ផ្ទៃដីចៀរជ័រស្តារបាន ៤៣.៤៨០ ហិកតា ក្នុងនោះអគ្គនាយកដ្ឋានចំការកៅស៊ូអាចស្តារបាន ៤១.៥០០ ហិកតា

ដែលឆ្នាំ ១៩៨០ មានតែប្រមាណ ៥.០០០ ហិកតា ប៉ុណ្ណោះ។ បរិមាណជ័រកៅស៊ូស្ងួតនៅឆ្នាំ ១៩៨៨ ទទួលបាន ៣៣.០០០ តោន ដែលឆ្នាំ ១៩៨០ សម្រេចបានតែ ១.៣០០ តោន ប៉ុណ្ណោះ។ យើងអាចពិនិត្យមើលទៅ លើទិន្នផលជ័រកៅស៊ូដែលទទួលបាន ចន្លោះឆ្នាំ ១៩៨០-១៩៨៨ ដែល មានខ្លឹមសារលម្អិតដូចខាងក្រោម ៖

| បរិយាយ | ទិន្នផលជ័រកៅស៊ូ(តោន) | បម្រែបម្រួល(%) |
|---|---|---|
| ១៩៨០ | ១.៣០០ | - |
| ១៩៨១ | ៤.០០០ | ២០៧% |
| ១៩៨២ | ៧.០០០ | ៧៥% |
| ១៩៨៣ | ៩.០០០ | ២៨% |
| ១៩៨៤ | ១៣.៤០០ | ៤៤% |
| ១៩៨៥ | ១៧.៦៤០ | ៣០% |
| ១៩៨៦ | ២៤.៥០០ | ២៣% |
| ១៩៨៧ | ២៥.០០០ | ៤% |
| ១៩៨៨ | ៣២.០០០ | ២៨% |

*តារាងទិន្នផលជ័រកៅស៊ូ ឆ្នាំ ១៩៨០-១៩៨៨(គិតជាតោន)* [183]

រហូតដល់ឆ្នាំ ១៩៨៨ មូលដ្ឋានកែច្នៃជ័រ មន្ទីរពេទ្យ សាលារៀន លំនៅដ្ឋានរបស់កម្មករចំការកៅស៊ូ ត្រូវបានស្តារ និងសាងសង់បន្ថែម មួយចំនួនទៀត។ ពេលគឺផ្ទះកម្មករគ្រប់ប្រភេទបានស្ថាបនាប្រមាណ ជា ៣០០០ ខ្នង។

ទន្ទឹមនឹងការស្តារផ្ទៃដីកៅស៊ូឡើងវិញ ការដាំកៅស៊ូថ្មី ក៏បានដំណើរការយ៉ាងសកម្ម ហើយកាបណ្តុះបណ្តាល និងការដាំកូនកៅស៊ូ ត្រូវបានកែលម្អដោយប្រើប្រាស់បច្ចេកទេសថ្មី។ សរុបផ្ទៃដីដាំកៅស៊ូ សម្រេចបាន ៣.៧០០ ហិកតា បន្ថែមទៀត។ នៅសម័យនោះ បញ្ហាលំបាកជុំវិញការស្តារដំណាំកៅស៊ូ មានលក្ខណៈដូចខាងក្រោម៖

- ទិន្នផលកៅស៊ូទាប ព្រោះតែការជៀរជ័រមិនអស់ពីដើម ព្រោះនៅតាមតំបន់ខ្លះ ខ្វះខាតកម្លាំងពលកម្ម
- ការដោះស្រាយបញ្ហាជីវភាពកម្មករ និងការចាត់ចែងគ្រប់គ្រង ពុំទាន់បានល្អនៅឡើយ
- គុណភាពកៅស៊ូកែច្នៃនៅទាប ដោយសារតែបច្ចេកវិទ្យាសម្រាប់កែច្នៃពុំទាន់ស្តារបានត្រឹមត្រូវ និងកម្រិតជំនាញរបស់កម្មករ បុគ្គលិក នៅមានកម្រិតទាប។

**វិស័យរុក្ខកម្ម**

ស្ថាប័នអាជីវកម្មព្រៃឈើ មានស្ថាប័នរដ្ឋ និងមានក្រុមសាមគ្គី អាជីវកម្មរបស់ខេត្ត-ក្រុង បានចាប់ដំណើរការពីឆ្នាំ ១៩៨១។ នៅសម័យនោះ ការគ្រប់គ្រងពុំទាន់មានសណ្តាប់ធ្នាប់នៅឡើយទេ ហើយខ្វះខាត មធ្យោបាយសម្រាប់ធ្វើអាជីវកម្ម។ ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំ លទ្ធផលអាជីវកម្មព្រៃឈើមានការ

រីកចម្រើនជាលំដាប់ ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ក្នុងប្រទេស និងការនាំចេញទៀតផង។

[183] ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២, ទំព័រ ៣៤៣ – ៣៤៤

ពីឆ្នាំ ១៩៨៧ ប្រទេសកម្ពុជាបានដំណើរការ រុក្ខដ្ឋានរដ្ឋចំនួន ៤កន្លែង និងរុក្ខដ្ឋានឯក ជនចំនួន ១កន្លែងទៀត ក្នុងខេត្តកំពង់ធំដែលអនុវត្តតាមរូបភាពម៉ៅការ។ ទន្ទឹមនឹងនេះ សហគ្រាសកែច្នៃឈើរបស់ក្រសួងកសិកម្ម មានចំនួន ៦កន្លែង និងរបស់បណ្ដាខេត្តក្រុង កំពុងដំណើរការយ៉ាងសកម្ម។ នៅឆ្នាំ ១៩៨៨ អាជីវកម្មឈើមូលអាចសម្រេចបាន ២៨២.០០០ ម$^3$ ក្នុងនោះ សម្រាប់ប្រើប្រាស់ក្នុងស្រុកចំនួន ២២០.០០០ ម$^3$ ហើយឈើមូលនាំចេញមានចំនួន ១០៦.០០០ ម$^3$ ។ ចំពោះខ្លឹមសារលម្អិតដែលទាក់ទងនឹងផលិតកម្មព្រៃឈើ យើងអាចពិនិត្យមើលតាមរយៈតារាងដូចខាងក្រោមនេះ៖

| **បរិយាយ** | **១៩៨១** | **១៩៨២** | **១៩៨៣** | **១៩៨៤** |
|---|---|---|---|---|
| **ឈើមូល** | ១១.០៣០ | ៦៧.៧០០ | ៩០.០០០ | ៧៣.២៨០ |
| **ឈើកែច្នៃ** | ១.៤៤០ | ២.៩៩០ | ៣.៤១០ | ៤.៦៣០ |
| **ការនាំចេញ (ឈើមូល)** | 0 | ១.៧៥០ | ១៥.១៦០ | ១៥.១៧០ |

*តារាងផលិតកម្មព្រៃឈើឆ្នាំ ១៩៨១-១៩៨៤(គិតជា ម$^3$ )* [184]

| **បរិយាយ** | **១៩៨៥** | **១៩៨៦** | **១៩៨៧** | **១៩៨៨** |
|---|---|---|---|---|
| **ឈើមូល** | ៩៦.៥៣០ | ២១៣.៥៥០ | ៣០៦.១៦០ | ២៨២.៩៥០ |
| **ឈើកែច្នៃ** | ៨.៥៨០ | ៩.៩៩០ | ១១.៧៨០ | ១២.៧៥០ |
| **ការនាំចេញ (ឈើមូល)** | ២៥.១២០ | ២៥.៤៧០ | ៨៤.៦៨០ | ១០៦.៥៩០ |

*តារាងផលិតកម្មព្រៃឈើឆ្នាំ ១៩៨៥-១៩៨៨(គិតជា ម$^3$ )*

បញ្ជាក់ ៖ បើយើងសិក្សាប្រៀបធៀប អំពីផលិតកម្មអាជីវកម្មព្រៃឈើ ជាមួយនឹងសម័យមុនសង្គ្រាម យើងឃើញថានៅឆ្នាំ ១៩៨៨ ផលិតកម្មព្រៃឈើនៅមានកម្រិតទាបជាងនៅឡើយ។ ជាក់ស្ដែងឆ្នាំ ១៩៦៦-១៩៦៨ ប្រទេសកម្ពុជាផលិតឈើមូលបាន ៣៤៧.៩០០ម$^3$ ច្រើនជាងផលិតកម្មនៅឆ្នាំ ១៩៨៨ ដែលមានតែ ២៨២.៩៥០ ម$^3$។

ទន្ទឹមនឹងការធ្វើអាជីវកម្មព្រៃឈើ ការពារបរិស្ថាន ក៏ដូចជាការថែរក្សាព្រៃឈើ នៅទន់ខ្សោយនៅឡើយ ព្រោះការកាប់អុស និងការកាប់ឈើបានឈានដល់ដំណាក់កាលបំផ្លាញព្រៃឈើ។ រហូតមកដល់ឆ្នាំ ១៩៨៩ បណ្ដាស្ថាប័នរដ្ឋ មិនទាន់កំណត់បែងចែកតំបន់ព្រៃឈើដែលត្រូវការពារ ឬត្រៀមបម្រុង និងសម្រាប់ធ្វើអាជីវកម្មនៅឡើយទេ។ ចំណុចដែលគួរចាប់អារម្មណ៍ គឺលទ្ធភាពកែច្នៃឈើរបស់រដ្ឋនៅមានកម្រិតទាប ហើយពុំទាន់សមស្របនឹងការធ្វើអាជីវកម្ម ដោយនៅតែបន្តដដែល។

### វិស័យជលផល

ក. ការនេសាទទឹកសាប និងវារីវប្បកម្ម

ការធ្វើអាជីវកម្មឡូត៍នេសាទភាគច្រើនជាក្រុមសាមគ្គី។ ពីមួយ ឆ្នាំទៅមួយឆ្នាំ បរិមាណត្រីដែលចាប់បាន គឺមានកំណើនយឺត។ នៅឆ្នាំ ១៩៨៦ បរិមាណត្រីស្រស់សម្រេចបាន ៧៥.០០០តោន ឆ្នាំ ១៩៨៧ ទទួលបាន ៧៦.៦០០តោន និងឆ្នាំ ១៩៨៨ ទទួលបាន ៨៥.៨០០ តោន។ យើងអាចពិនិត្យមើលទៅលើ ទិន្នន័យលម្អិតក្នុងវិស័យជលផលតាមបណ្តាឆ្នាំនានា ដូចខាងក្រោមនេះ៖

| បរិយាយ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ |
|---|---|---|---|---|
| នេសាទ ទឹកសាប | ៥០.៧៨០ | ៦៥.៧០០ | ៥៨.៦៨១ | ៥៥.០៩៣ |
| វារីវប្បកម្ម | ០ | ០ | ០ | ១.៦១០ |
| នេសាទសមុទ្រ | ៨១៤ | ៣.០១៥ | ៩.៤៤៤ | ៧.៧២១ |
| សរុប | ៥១.៥៩៤ | ៦៨.៧១៥ | ៦៨.១២៥ | ៦៤.៤២៤ |

*តារាងផលិតកម្មជលផល ឆ្នាំ ១៩៨១-១៩៨៤ (គិតជាតោន)* [185]

| បរិយាយ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | ១៩៨៨ |
|---|---|---|---|---|
| នេសាទ ទឹកសាប | ៥៦.៤០០ | ៦៤.១៨១ | ៦២.១៥៤ | ៦១.២០០ |
| វារីវប្បកម្ម | ៣.០០០ | ២.២០០ | ២.៥០០ | ៤.៦០០ |
| នេសាទសមុទ្រ | ១១.៥៧៨ | ៧.២៤៧ | ១៧.៤១៧ | ២១.០០០ |
| សរុប | ៧០.៥៧៨ | ៧៣.៦២៨ | ១៧.៤១៧ | ៨៦.៨០០ |

*តារាងផលិតកម្មជលផល ឆ្នាំ ១៩៨៥-១៩៨៨ (គិតជាតោន)*

បញ្ជាក់ ៖ ចំពោះនេសាទទឹកសាប ខេត្តច្រើនជាងគេ ក្នុងសម័យឆ្នាំ ១៩៨០ ដល់ ១៩៨៨ រួមមាន ខេត្តកំពង់ចាម ក្រចេះ កណ្តាល កំពង់ធំ និងពោធិសាត់។ រីឯនេសាទសមុទ្រ រួមមាន ខេត្តកំពត កំពង់សោម និងកោះកុង។

ទន្ទឹមនឹងនេះ បទល្មើសក្នុងការនេសាទ នាសម័យនោះមានលក្ខណៈធ្ងន់ធ្ងរដូចជានេសាទនៅរដូវហាមឃាត់ ការប្រើប្រាស់ ឧបករណ៍ខុសច្បាប់។ល។ ដែលជាហេតុនាំអោយបាត់បង់ពូជត្រីមួយចំនួន។ ជារួមបរិមាណត្រីមានការថយចុះដោយបរិស្ថានដែលត្រីរស់នៅ មានការប្រែប្រួលជាអវិជ្ជមាន។

លទ្ធផលនៃការចិញ្ចឹមត្រីនៅមានកម្រិតទាបដោយបច្ចេកទេសចិញ្ចឹមពុំទាន់បានល្អប្រជាពលរដ្ឋពុំទាន់មានទម្លាប់ក្នុងការចិញ្ចឹមត្រី។ ការងារពង្រឹងក្រុមសាមគ្គីអាជីវកម្មនេសាទ ក៏ដូចជាការបែងចែកឡូត៍នេសាទនៅមានចំណុចអសកម្ម។

ខ. ការនេសាទសមុទ្រ

ចំពោះផលិតផលនេសាទសមុទ្រវិញ យើងពិបាកនឹងរុករកពត៌មានអោយបានច្បាស់លាស់ណាស់។ បើតាមការប៉ាន់ស្មានក្នុងឆ្នាំ ១៩៨៨ ផលិតផលនេសាទសមុទ្រមានដំណើរការល្អប្រសើរ ហើយបានសម្រេចបាន ២១.០០០ តោន។

### ៩.៥.២ វិស័យឧស្សាហកម្ម-សិប្បកម្ម

❖ **ឧស្សាហកម្មមជ្ឈមណ្ឌល**

ឧស្សាហកម្មមជ្ឈឹម ជាឧស្សាហកម្មថ្នាក់ជាតិរបស់រដ្ឋ ដែលត្រូវ បានជម្រុញយ៉ាងខ្លាំងក្លា ក្នុងនោះសហគ្រាសចំនួន ៦៩កន្លែង ក្នុង ចំណោមសហគ្រាសទាំងអស់ ៧៩ ដែលមានពីមុនមក ត្រូវបានស្តារ សមត្ថភាពផលិតកម្មជាថ្មី។ តម្លៃសរុបបរិមាណផលិតផលកើនឡើងជា ឮមប្រមាណ ១៥% ក្នុងចន្លោះឆ្នាំ ១៩៨០-១៩៨៥ និង ១០% ចាប់ពីឆ្នាំ ១៩៨៦-១៩៨៨។ ក្នុងឆ្នាំ ១៩៨៨ តម្លៃសរុបនៃបរិមាណផលិតផលសម្រេចបាន ២.៨៩៤លានរៀល។ បរិមាណផលិតផលសំខាន់ៗនាសម័យនោះរួមមាន៖

- ថាមពលអគ្គិសនីផលិតបាន ១៧៨លាន kwh
- សំបកកង់រថយន្តផលិតបាន ៣០.០០០ គ្រាប់
- ដីហ្វូស្វាតផលិតបាន ៦០០០ តោន
- បារីគ្រប់ប្រភេទ ផលិតបាន ១២០លានកញ្ចប់
- ក្រណាត់គ្រប់ប្រភេទ ផលិតបាន ៤.៣៧០.០០០ ម៉ែត្រ
- សារ៉ុងផលិតបាន ៣.៩០០.០០០ ម៉ែត្រ។ [186]

ចាប់តាំងពីឆ្នាំ ១៩៨៧ មក រដ្ឋាភិបាលបានប្រកាស អំពីនយោបាយផ្តល់ប្រាក់បៀវត្សតាមបរិមាណផលិតផល ប៉ុន្តែចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៨៨ មក ទើបរោងចក្រសហគ្រាសមួយចំនួនបានអនុវត្តការផ្តល់ប្រាក់បៀវត្សតាមបរិមាណផលិតផល ម្ចាស់ការដោះស្រាយបញ្ហាវត្ថុធាតុដើម និងឈានចូលដល់ការអនុវត្តរបបស្វ័យាភិបាលសេដ្ឋកិច្ច។ វិធានការជម្រុញផលិតកម្មគ្រប់មុខត្រូវបានកែលម្អយ៉ាងញឹកញាប់ និងទាន់ពេលវេលា។

ទោះបីជាមានការរីកចម្រើនជាវិជ្ជមានក៏ដោយ ប៉ុន្តែឧស្សាកម្មមជ្ឈឹម បានជួបប្រទះនូវការលំបាកដូចខាងក្រោម៖

- ការរៀបចំចាត់ចែងគ្រប់គ្រងផលិតកម្ម និងបែងចែកជំនាញផលិតកម្មឡើងវិញ ទើបអនុវត្តបានពីឆ្នាំ ១៩៨៦ ប៉ុណ្ណោះ ដូច្នេះដំណើរ ការនេះពុំទាន់មានប្រសិទ្ធភាពសេដ្ឋកិច្ចសមស្របនៅឡើយទេ។
- ការប្រើប្រាស់សមត្ថភាពផលិតកម្មពុំទាន់បាន ១០០% នោះទេ លើកលែងតែផ្នែកយន្តសាស្ត្រ។
- ការផលិតមុខទំនិញប្រើប្រាស់សម្ងាន់ៗ ពុំទាន់បានគ្រប់គ្រាន់ តាមសេចក្តីត្រូវការ ទាំងបរិមាណទំនិញ ទាំងគុណភាពទំនិញ។
- ការប្រគល់មុខទំនិញមួយចំនួននៅជួបប្រទះការលំបាកច្រើន។
- វត្ថុធាតុដើមមួយចំនួនដែលបានផលិតនៅក្នុងប្រទេស មានលទ្ធភាពច្រើនសម្រាប់ផ្គត់ផ្គង់រោងចក្រក្នុងស្រុក ប៉ុន្តែការផ្គត់ផ្គង់គឺមានភាពស្មុគស្មាញ និងមិនគ្រប់គ្រាន់ ធ្វើអោយរោងចក្រខ្លះផ្អាកសកម្មភាព ផលិតដូចជា រោងចក្រប្រេងកន្ទក់ រោងចក្រសាប៊ូ និងរោងចក្រស្ករស។
- ការផ្គត់ផ្គង់ថាមពលអគ្គិសនីនាសម័យនោះ ក៏នៅមានការខ្វះខាតច្រើនសម្រាប់រោងចក្រសហគ្រាស។

### ❖ ឧស្សាហកម្មមូលដ្ឋាន និងសិប្បកម្ម

ផ្នែកនេះក៏ត្រូវបានស្តារឡើងវិញដែរ និងមានការរីកចម្រើនគួរ អោយកត់សម្គាល់ ជាពិសេសលើមុខទំនិញមួយចំនួនដែលប្រើប្រាស់វត្ថុធាតុដើមមានស្រាប់ក្នុងស្រុក។ ឧស្សាហកម្មមូលដ្ឋាន និងសិប្បកម្ម រាជធានីភ្នំពេញ កំពុងវិវត្តិក្នុងជំហានថ្មី ប្រកបដោយចរិកសកម្មភាពក្នុង ផលិតកម្ម បម្រើអោយមុខព្រួញសេដ្ឋកិច្ចទាំងបួន និងបម្រើអោយ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានមួយចំនួនធំ។ នៅឆ្នាំ ១៩៨៨ តម្លៃសរុបនៃផលិតកម្មឧស្សាហកម្មមូលដ្ឋាន និងសិប្បកម្ម សម្រេចបាន ១.៤៦២ លានរៀល។ មុខទំនិញសំខាន់ៗមួយចំនួនដូចជា ផាល ផលិតបាន ៩៧.០០០ផ្លែ បាវក្រចៅ ផលិតបាន៣.០០០.០០០ សំបកបាវ ជីហ្វូស្វាត ផលិតបានជាង ៤.០០០ តោន សាប៊ូ ផលិតបាន ១១៦ តោនក្រដាស ផលិតបាន ៩៦ តោន សន្លឹកថ្នាំជក់ទទួលបាន ៦.០០០ តោន និងក្រណាត់គ្រប់ប្រភេទ ផលិតបានជាង ១.០០០.០០០ ម៉ែត្រ។ [187]

ទន្ទឹមនឹងនេះ គោលនយោបាយរបស់រដ្ឋស្តីពីការងារសិប្បកម្ម ដូចជាគោលនយោបាយស្តីពីការអោយខ្ចីទុន ការផ្គត់ផ្គង់វត្ថុធាតុដើម ការអនុគ្រោះពន្ធ តម្លៃប្រមូលទិញផលិតផល គេសង្កេតឃើញថាពុំ ទាន់មានឥទ្ធិពលខ្លាំងក្លាដល់វិស័យសិប្បកម្មនៅឡើយទេ។ ពិនិត្យជារួម វិស័យសិប្បកម្មនាសម័យនោះបានរីកចម្រើនផុសផុលនៅតែរាជធានី ភ្នំពេញប៉ុណ្ណោះ ប៉ុន្តែមិនទាន់បានបើកទូលាយក្នុងប្រទេសនៅឡើយ។

### ❖ វិស័យសេវាកម្ម

#### គមនាគមន៍ដឹកជញ្ជូន និងប្រៃសណីយ៍

វិស័យគមនាគមន៍ គឺជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិ។ ចាប់តាំងពីឆ្នាំ ១៩៧៩-១៩៨៨ បណ្តាញគមនាគមន៍ប្រវែងប្រមាណ ១.៧០០ គ.ម ត្រូវបានជួសជុល និងដាក់អោយដំណើរការជាប្រក្រតី។ ផ្លូវជាតិសំខាន់ៗមួយចំនួនបានស្តារ និងជួសជុលឡើងវិញដូចជា ផ្លូវជាតិលេខ ១ ផ្លូវជាតិលេខ១៩ ផ្លូវជាតិលេខ ៥ និងផ្លូវខ្លះទៀតក្នុងរាជធានីភ្នំពេញ និងបណ្តាញផ្លូវជាតិមួយចំនួនទៀតកំពុងស្ថិតក្នុងដំណាក់កាលកែលម្អគុណភាព។ ការស្តារ និងការជួសជុលផ្លូវជាតិ បានផ្សារភ្ជាប់ទៅនឹងការ

[187] ឈុន ពហុ, ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ៨

ការពារក្នុងពេលដែលខ្មាំងព្យាយាមបំផ្លាញ (សម័យនោះកងកម្លាំងខ្មែរក្រហមនៅមានសកម្មភាពនៅឡើយ)។ ចំពោះបណ្តាញផ្លូវដែកទាំងពីរខ្សែ ត្រូវបានថែរក្សា និងជួសជុលបានល្អជាប្រចាំ។

រីឯការដឹកជញ្ជូនតាមរថយន្ត ស្របយកសមាមាត្រពី ៤៥-៥០% នៃបរិមាណដឹកជញ្ជូនទំនិញតាមផ្លូវដែក ហើយបរិមាណទំនិញដឹកជញ្ជូនមានកំណើនជាមធ្យមប្រមាណជា ១០% ក្នុងមួយឆ្នាំ។ ការលើកដាក់ទំនិញចេញពីកំពង់ផែ កើនឡើងប្រមាណ ២០% ជាមធ្យមក្នុងមួយឆ្នាំ។ ការស្តារសមត្ថភាពកំពង់ផែសំខាន់ៗមានជាអាទិ៍ កំពង់ផែកំពង់សោម និងកំពង់ផែភ្នំពេញត្រូវបានយកចិត្តទុកដាក់។

ការងារប្រៃសណីយ៍របស់ប្រទេសកម្ពុជានាសម័យកាលនោះ គឺបានស្តារឡើងវិញនូវប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍សម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានទាន់ពេលវេលា។ ទំនាក់ទំនងជាមួយអន្តរជាតិ មានភាពងាយស្រួលច្រើន ដោយយើងមានស្ថានីយ៍ផ្កាយរណប។ ចំពោះបញ្ហាខ្វះខាតក្នុងការស្តារឡើងវិញជុំវិញវិស័យគមនាគមន៍ដឹកជញ្ជូន និងប្រៃសណីយ៍នាចន្លោះឆ្នាំ ១៩៨០ ដល់ ១៩៨៨ មានដូចខាងក្រោម ៖

- បរិមាណដឹកជញ្ជូនពុំទាន់សមស្របទៅនឹងលទ្ធភាព នៃមធ្យោបាយដឹកជញ្ជូនទាំងផ្លូវដែក ផ្លូវគោក និងផ្លូវទឹក
- ប្រព័ន្ធគ្រប់គ្រងមធ្យោបាយដឹកជញ្ជូន និងសុវត្ថិភាពដឹកទំនិញ ក៏ដូចជាសុវត្ថិភាពដឹកជញ្ជូនអ្នកដំណើរពុំទាន់រៀបចំបានល្អនៅឡើយ
- មធ្យោបាយតាមកំពង់ចម្លង មិនទាន់បានពង្រីកអោយបានសមស្របនោះទេ
- ការរៀបចំប្រគល់ និងទទួលទំនិញ អនុវត្តពុំទាន់បានល្អនាំអោយមានបញ្ហាទំនិញកកស្ទះក្រោមទ្រង់ទ្រាយធំជាញឹកញាប់
- ការចាត់តាំងលើកទំនិញតាមកំពង់ផែអនុវត្តមិនសូវល្អ ទាំងការប្រើប្រាស់គ្រឿងចក្រ ទាំងការប្រើប្រាស់កម្លាំងកម្មករ បើទោះបីជាបរិមាណទំនិញឆ្លងកាត់ពុំទាន់ស្មើនឹងសមត្ថភាពក៏ដោយ
- ទាក់ទងទៅនឹងការបញ្ជូនព័ត៌មានក្នុងប្រទេស និងក្រៅប្រទេស យើងឃើញថា អនុវត្តពុំបានល្អនោះទេ

**វិស័យពាណិជ្ជកម្ម**

ក. ពាណិជ្ជកម្មក្នុងប្រទេស

យើងដឹងហើយថា ក្រោមរបប ប៉ុល ពត ឆ្នាំ១៩៧៥-១៩៧៩ នៅ ក្នុងប្រទេសកម្ពុជាទាំងមូលគ្មានទីផ្សារទេ។ ក្រោយឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាក៏បានចាប់ផ្តើមអនុវត្តគោលនយោបាយ ពាណិជ្ជកម្ម តាមរូបភាព សេដ្ឋកិច្ចផែនការដោយរដ្ឋជាអ្នកកំណត់តម្លៃមុខទំនិញ។ រដ្ឋាភិបាល បានបង្កើតនៅប្រព័ន្ធតម្លៃទំនិញជាបីប្រភេទ គឺតម្លៃប្រមូលទិញផលិត ផលកសិកម្ម តម្លៃលក់ដុំនូវឧបករណ៍បរិក្ខាររបស់រដ្ឋសម្រាប់បម្រើអោយវិស័យកសិកម្មផលិតកម្ម និងតម្លៃលក់រាយ ដោយជារៀងរាល់ឆ្នាំ រដ្ឋបានធ្វើការកែសម្រួលតម្លៃបំពេញបន្ថែមស្របតាមលក្ខណៈចាំបាច់របស់ទំនិញ។

ចំពោះតម្លៃប្រមូលទិញផលិតផលកសិកម្មពីកសិករ រដ្ឋាភិបាល បានពិនិត្យ និងកែសម្រួលជារៀងរាល់ឆ្នាំ គឺចាប់តាំងពីឆ្នាំ ១៩៨០ មកហើយត្រូវបានប្រជាពលរដ្ឋអបអរសាទរ និងជម្រុញការផលិត និងការលក់ផលិតផលរបស់ខ្លួនបានយ៉ាងច្រើន។ ជាក់ស្តែង តម្លៃទំនិញស្រូវ ក៏ដូចជាតម្លៃកសិផលដ៏ទៃទៀតក្នុងឆ្នាំ ១៩៨៨-១៩៨៩ បានកើនឡើងពី ៥ ទៅ ៦ ដង បើប្រៀបធៀបទៅនឹងឆ្នាំ ១៩៨០ និងកើនឡើងប្រមាណ ២ ដង បើប្រៀបធៀបទៅនឹងឆ្នាំ ១៩៨៥។

រីឯតម្លៃលក់ដុំវិញ រដ្ឋាភិបាលបានអនុវត្ត និងគិតគូរតាមតម្លៃ អត្រាទាបគឺ ១០ រៀល ក្នុង ១ រូប្លិ (រូបិយប័ណ្ណសហភាពសូវៀត) និង ៨ រៀល ក្នុង ១ដុល្លា ក្នុងរយៈពេលយូរបង្គួរហួតមកដល់ឆ្នាំ ១៩៨៦។ លក្ខណៈបែបនេះ បានជះឥទ្ធិពលដល់ថវិការដ្ឋ និងការសន្សំសំចៃរបស់អង្គភាពផលិតកម្ម

អាជីវកម្ម។ ផ្តើមចេញពីសភាពការណ៍នេះ រដ្ឋបានកែសម្រួល និងកំណត់អត្រាតម្លៃប្រាក់រៀល ដែលមានតម្លៃ ១០ រៀល ស្មើ នឹង ១រូប្ល និង ៨ រៀល ស្មើនឹង ១ដុល្លា។ ក្រោយមកអត្រាតម្លៃប្រាក់ រៀលបានកើនឡើងរហូតដល់ ៣៥រៀល ក្នុង ១រូប្ល និង ៤០រៀល ក្នុង ដុល្លា ដោយកំណត់អត្រាជាក់ស្តែងតាមប្រភេទទំនិញនាំចូលនិមួយៗ។

ទាក់ទងទៅនឹងតម្លៃលក់រាយវិញ រដ្ឋាភិបាលបានធ្វើការសម្របសម្រួលតម្លៃទាំងឡាយដែលពុំទាន់សមស្រប និងបានតម្លើងអត្រាតម្លៃ គោលការណ៍ជាក់ស្តែង ដោយរដ្ឋមិនបំពេញខាត មិនបង្កភាពប្របូកប្របល់ក្នុងផលិតកម្ម និងមិនតម្លើងតម្លៃដើមចំពោះផលិតផល ទំនិញ អោយខ្ពស់ហួសពីសមត្ថភាពរបស់អ្នកប្រើប្រាស់ឡើយ។ របបតម្លៃប្រើប្រាស់ត្រូវបានគេចែកចេញជាពីរលក្ខណៈពោលគឺតម្លៃលក់រាយសម្រាប់ផ្គត់ផ្គង់ទំនិញប្រមាណជា ៩ មុខ តាមបរិមាណកំណត់ជូនដល់កម្មករ បុគ្គលិកកម្មាភិបាល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងតម្លៃលក់រាយ មួយប្រភេទទៀត សម្រាប់លក់ជូនមហាជនទូទៅ។ ទន្ទឹមនឹងនេះរដ្ឋបាន បែងចែកឋានុក្រមគ្រប់គ្រងតម្លៃ ក្នុងគោលបំណងកាត់បន្ថយការបាត់បង់ពេលវេលា និងបង្កើនការទទួលខុសត្រូវមួយកម្រិតទៀត ចំពោះបណ្តាអង្គភាពមូលដ្ឋានក្នុងទិសដៅអនុវត្តការងារគ្រប់គ្រងតម្លៃទំនិញ។

ជុំវិញយន្តការដោះដូរទំនិញរដ្ឋបានបង្កើតមូលដ្ឋានពាណិជ្ជកម្ម រដ្ឋរហូតដល់ថ្នាក់ស្រុក។ ហើយនៅតាមថ្នាក់ឃុំ និងភូមិ ក៏មានទីស្នាក់ការប្រមូលទិញ ឬមានក្រុមចល័តដែរ។ ស្នាដៃដ៏សំខាន់នាសម័យនោះ គឺរដ្ឋបានប្រមូលទិញស្រូវពីកសិករ សម្រាប់បម្រើសេចក្តីត្រូវការក្នុងក្របខណ្ឌរដ្ឋ។ ឆ្នាំដែលសម្រេចបានខ្ពស់ជាងគេក្នុងការទិញផលិតផលស្រូវគឺឆ្នាំ ១៩៨៤ ដោយប្រមូលទិញបានប្រមាណ ៤៤៤.០០០ តោន និងនៅឆ្នាំ១៩៨៨ ប្រមូលទិញបានប្រមាណ ៣៣៥.០០០ ការប្រមូលទិញ

កសិផល រដ្ឋប្រើប្រាស់សម្រាប់ជាវត្ថុធាតុដើមមួយចំនួន បម្រើអោយវិស័យឧស្សាហកម្ម និងសម្រាប់ការនាំចេញ។

ខ. ពាណិជ្ជកម្មអន្តរជាតិ

ការនាំចេញក៏ដូចជាការផ្លាស់ប្តូរទំនិញនៅលើទីផ្សារ គឺបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៨០ ប្រទេសកម្ពុជាបានធ្វើការនាំចេញលើមុខទំនិញ កសិ-ឧស្សាហកម្មមួយចំនួន។ រដ្ឋបាននាំចេញនូវទំនិញ កៅស៊ូ សំឡីគរ និងទំនិញកសិកម្មជាច្រើនទៀត។ បរិមាណតម្លៃនាំចេញបានកើនឡើង ពីមួយឆ្នាំទៅមួយឆ្នាំ ហើយសម្រេចបាន ១២៣,៨៧ លាន រូប្ល បើគិតពី ឆ្នាំ ១៩៨០-១៩៨៨។ ដោយឡែកនៅក្នុងឆ្នាំ ១៩៨៨ ការនាំចេញសម្រេចបានប្រមាណ ៣៥,៥ លាន រូប្ល។

ចំពោះការនាំចេញ នូវផលិតផលកសិ-ឧស្សាហកម្មមិនទាន់កែច្នៃ ក្នុងនោះមុខទំនិញនាំចេញសំខាន់ជាងគេគឺ កៅស៊ូ ដោយទទួលបាននូវចំណូលប្រមាណពី ៦០% ទៅ ៧០% នៃតម្លៃនាំចេញសរុបប្រចាំឆ្នាំនិមួយៗ។ ចាប់តាំងពីឆ្នាំ ១៩៨៤ ផលិតផលកៅស៊ូបាននាំចេញស្ទើរតែ ទាំងស្រុង (៩០)លើកលែងតែឆ្នាំ១៩៨៥ ដែលថយចុះមកត្រឹម ៧៨%។ ចំពោះបរិមាណឈើនាំចេញ គឺមានប្រមាណ ២០% នៃបរិមាណដែលធ្វើអាជីវកម្មសរុប។

បើពិនិត្យមើលទៅលើលទ្ធផល នៃការនាំចេញសម័យនោះ តម្លៃសរុបនៃការនាំចេញទំនិញគឺពុំទាន់មានលក្ខណៈសមស្របទៅនឹង លទ្ធភាពដែលប្រទេសកម្ពុជាមាននៅឡើយទេ។ ព្រោះបើសិនជាមាន ការចាត់តាំងការងារផលិតកម្មចាត់តាំងការងារប្រមូលផល ព្រមទាំងមានគោលនយោបាយតម្លៃត្រឹមត្រូវនោះ ប្រទេសកម្ពុជាមានលទ្ធភាព ច្រើនក្នុងការបង្កើនការនាំចេញ។

ទាក់ទងនឹងការនាំចូលវិញ ដោយសារលទ្ធភាពផលិតកម្មក្នុង ប្រទេសមានកម្រិតទាប និងសេចក្ដីត្រូវការប្រើប្រាស់ក្នុងស្រុកកាន់តែមានកម្រិតខ្ពស់ ហេតុនេះបរិមាណទំនិញនាំចូលគឺមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ តម្លៃសរុបនៃការនាំចូលចាប់គិតពីឆ្នាំ ១៩៨០ ដល់ ១៩៨៨ មានប្រមាណ ៦៦៥,៦៦ លានរូប្ល។ សម័យកាលនោះរដ្ឋ ពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាពាណិជ្ជកម្មអន្តរជាតិនោះឡើយ។ [188]

សរុបមកក្នុងរយៈពេល ១០ឆ្នាំ គឺឆ្នាំ ១៩៧៩-១៩៨៨ តម្លៃទំនិញ ការនាំចេញទទួលបានតែប្រមាណ ១៨,៦% នៃតម្លៃសរុបទំនិញនាំចូលប៉ុណ្ណោះ។ ជញ្ជីងពាណិជ្ជកម្មអន្តរជាតិ ជានិច្ចកាល គឺបានជួបប្រទះនូវឱនភាពជារៀងរាល់ឆ្នាំ។

**វិស័យហិរញ្ញវត្ថុ និងធនាគារ**

ចាប់តាំងពីឆ្នាំ ១៩៧៩-១៩៨៨ មកថវិការដ្ឋទទួលបានមកពី ប្រជាជនជាច្រើនដែលប្រើប្រាស់ទៅវិញសម្រាប់អនុវត្តលើការងារស្ដារសេដ្ឋកិច្ច-សង្គម និងការពារជាតិ។ ប្រភពចំណូលខ្លះ បានមកពីការលក់ ផលិតផលកសិកម្ម ដែលកសិករបានបង់វិភាគទានជូនរដ្ឋ ក្រោមពាក្យ ស្លោកថា បង់ពន្ធជូនរដ្ឋ គឺស្នេហាជាតិ ។ ប្រភពខ្លះទៀត បានមកពីអាជីវកម្មរបស់សហគ្រាសរដ្ឋ និងការបង់ពន្ធភាសីពីអាជីវករ។ល។

ចំពោះចំណូលថវិការដ្ឋវិញ គឺមានកំណើនជាមធ្យមប្រមាណ ២៣,៧% ក្នុងមួយឆ្នាំ។ ក្នុងចំនួននោះ ចំណូលក្នុងស្រុកស្រូបយកសមាមាត្រ ២% ប៉ុណ្ណោះ នៅចន្លោះឆ្នាំ ១៩៧៩ ដល់ ១៩៨២ និងមានកំណើនពី ១២ ទៅ ១៣% ចាប់ពីឆ្នាំ ១៩៨៣ រហូតដល់ឆ្នាំ ១៩៨៨។ ដូច្នេះសម័យនោះយើងសង្កេតឃើញថា ចំណូលពីក្រៅប្រទេស បានដើរតួនាទីដ៏សំខាន់បំផុត សម្រាប់ទ្រទ្រង់ថវិការដ្ឋ ក៏ដូចជា សម្រាប់ការស្ដារសេដ្ឋកិច្ច-សង្គមឡើងវិញ។

រីឯការចំណាយថវិការដ្ឋ មានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ២៣%។ នៅក្នុងចន្លោះឆ្នាំ ១៩៧៩ ដល់ ១៩៨៤ ការចំណាយថវិការដ្ឋ ច្រើនផ្ដល់អាទិភាពទៅលើការសង្គ្រោះប្រជាពលរដ្ឋ អោយរួចផុតពី គ្រោះទុរ្ភិក្ស និងប្រមូលផ្ដុំទៅលើការស្ដារមូលដ្ឋានសេដ្ឋកិច្ចសង្គម។ ចាប់តាំងពីឆ្នាំ ១៩៨៤ រហូតដល់ឆ្នាំ ១៩៨៩ ការចំណាយបានផ្ដល់អាទិភាព ទៅលើមុខព្រួញសេដ្ឋកិច្ចទាំងបួនវិញ (ស្បៀង កៅស៊ូ ព្រៃឈើ និងជលផល)។ ជារួម រចនាសម្ព័ន្ធលើមុខចំណាយថវិការដ្ឋ នាចន្លោះឆ្នាំ ១៩៨៤ ដល់ ១៩៨៨ មានស្ថានភាពដូចខាងក្រោម៖

- ការចំណាយសន្សំទុកស្របយកសមាមាត្រពី ៣៥ ទៅ ៤៥% លើ ចំណាយសរុប។

- ការចំណាយសម្រាប់ប្រើប្រាស់ ក្នុងការស្តារសេដ្ឋកិច្ច-សង្គម ស្របយកសមាមាត្រពី ៣៥ ទៅ ៤៥%។ ការចំណាយលើវិស័យការពារជាតិ និងសន្តិសុខសង្គមស្រូបយកសមាមាត្រពី ២០ ទៅ ២៥% ។

នៅសម័យនោះជារៀងរាល់ឆ្នាំថវិការដ្ឋ តែងតែបាត់បង់តុល្យ ភាពដោយចំណាយច្រើនជាងការរកចំណូល។ នៅឆ្នាំ ១៩៨៦-១៩៨៧ ឱនភាពថវិការដ្ឋមានកម្រិតខ្ពស់ជាងបណ្ដាឆ្នាំនានា អាស្រ័យដោយមានការកែទម្រង់តម្លៃ នៃការទិញផលិតផលកសិកម្ម។

ការបោះពុម្ពសាច់ប្រាក់បន្ថែម គិតជាមធ្យមប្រចាំឆ្នាំ នាសម័យ នោះស្មើនឹង ៥,៤។ ដោយឡែកនៅឆ្នាំ ១៩៨៨ ការបោះពុម្ពសាច់ប្រាក់ បន្ថែមកើនឡើងរហូតដល់ ៨,៣%។ បើសរុបចំណូលសាច់ប្រាក់ ក្នុងរយៈពេល ១០ឆ្នាំ គឺមានចំនួន ២៣.៣៩៦ លានរៀល។ ក្នុងចំនួននេះឆ្នាំ ១៩៨៥ កើនលើសឆ្នាំ ១៩៨០ ប្រមាណ ៣២,៥ ដង និងឆ្នាំ ១៩៨៨ កើនលើសឆ្នាំ ១៩៨៥ ចំនួន ២,៦ ដង។ ចំណាយសរុប ក្នុងរយៈពេល ១០ឆ្នាំ មានទំហំស្មើនឹង ២៩.២៦៦ លានរៀល ក្នុងនោះការចំណាយក្នុងឆ្នាំ១៩៨៥ កើនលើសការចំណាយនៅឆ្នាំ ១៩៨០ ប្រមាណ ១១,៣ ដង និងឆ្នាំ ១៩៨៨ ការចំណាយកើនលើសឆ្នាំ ១៩៨៥ ប្រមាណចំនួន ២,៥ ដង។ [189]

ដូច្នេះយើងឃើញថា ដោយសារតែស្ថានភាពសេដ្ឋកិច្ចសង្គម និងស្ថានភាពសន្តិសុខ ស្ថិតក្នុងលក្ខណៈសង្គ្រាមផង និងគ្មានសង្គ្រាមផង (នៅប៉ែកខាងលិច ផ្នែកពាយ័ព្យ និងផ្នែកខាងជើងនៃប្រទេសតែងតែមានការវាយប្រហារគ្នារវាងកងទ័ពរដ្ឋាភិបាល និងពួកខ្មែរក្រហម) ហេតុនេះឱនភាពថវិការដ្ឋ គឺបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាលំដាប់។ ឱនភាពសាច់ប្រាក់នាឆ្នាំ ១៩៨៨ បានកើនឡើងចំនួន ៧ដង បើប្រៀបធៀបទៅនឹងឆ្នាំ ១៩៨០ និងកើនឡើងចំនួន ២,២ ដង ចាប់ពីឆ្នាំ ១៩៨៥ មក។ នៅឆ្នាំ ១៩៨៨ ចំណូលរូបិយប័ណ្ណមានសន្ទុះកើនឡើងគួរអោយកត់សម្គាល់ គឺយើងទទួលបានប្រមាណ ១៧លានដុល្លា។ ល្បឿននៃកំណើននេះ គឺអាស្រ័យដោយរដ្ឋមានគោលនយោបាយអោយខ្ចីចងការប្រាក់បង្វិល និងការផ្តល់ភាគរយលើកទឹកចិត្តលើប្រាក់ចំណេញ ព្រមទាំងកំណត់អត្រាប្តូរប្រាក់បានសមស្រប។ ដូច្នេះការចំណាយលើ រូបិយប័ណ្ណសម្រាប់កិច្ចការរដ្ឋវិញ គឺបានស្ថិតក្នុងស្ថានភាពល្អប្រសើរ សម្រាប់សម័យកាលនោះ គឺ ១៨ លានដុល្លា។

## ៩.៦. ការវិនិយោគសាធារណៈ

ក្នុងដំណាក់កាលនៃការស្តារសេដ្ឋកិច្ចជាតិនាមស័យនោះ ប្រទេសកម្ពុជាបានយកចិត្តទុកដាក់សំខាន់ទៅលើការសាងសង់សំណង់ មូលដ្ឋានទាំងឡាយណាដែលប្រើទុនវិនិយោគក្នុងប្រទេស ដូចជាការ វិនិយោគក្នុងវិស័យគមនាគមន៍កសិកម្ម សុខាភិបាល សិក្សាអប់រំ និងកសាងស្ថាប័នការពារជាតិ។ នៅសម័យនោះ រដ្ឋបានយកចិត្តទុកដាក់ ខ្ពស់លើការសាងសំណង់ ដែលជាកិច្ចសហប្រតិបត្តិការណ៍ជាមួយបរទេស ជាពិសេសបណ្តាប្រទេសសង្គមនិយម។ ប៉ុន្តែបញ្ហាសំខាន់ ដែលចោទឡើងក្នុងវិស័យសំណង់នោះ គឺការខ្វះខាតសម្ភារៈសំណង់ និងការងារគ្រប់គ្រងបច្ចេកទេសដែលមានលក្ខណៈទន់ខ្សោយ។

ជារួមទុនវិនិយោគសំណង់មូលដ្ឋានក្នុងរយៈពេល ១០ឆ្នាំ នាសម័យកាលនោះបានស្របយក សមាមាត្រប្រមាណពី ១២ ទៅ ១៤% ចាប់ពីឆ្នាំ ១៩៨២ រហូតដល់ឆ្នាំ ១៩៨៦ និង ១៧% ចាប់ពីឆ្នាំ ១៩៨៧ ដល់ឆ្នាំ១៩៨៨ នៃថវិការដ្ឋ។ ចាប់ពីឆ្នាំ ១៩៨៦ មក ទុនវិនិយោគ សំណង់មូលដ្ឋាន បានផ្ដល់អាទិភាពខ្ពស់លើផ្នែកកសិកម្មធារាសាស្ត្រ ការដាំកៅស៊ូ និងផ្នែកគមនាគមន៍សំខាន់ៗ។ រីឯចាប់ពីឆ្នាំ ១៩៨៨ មកទុនវិនិយោគបានផ្ដល់បរិមាណខ្ពស់បង្គួរ បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ប៉ុន្តែទំហំការងារ និងចំនួនការដ្ឋានសំណង់ ពុំសូវកើនឡើងប៉ុន្មានទេ ព្រោះសម្ភារៈសំណង់ និងថ្លៃឈ្នួលកម្មករបានកើនឡើងឥតឈប់ឈរ។ ចំពោះការដ្ឋានសំខាន់ៗមួយចំនួន បានសាងសង់រួចជាស្ថាពរនៅចុងឆ្នាំ ១៩៨៨ ក្នុងនោះមានប្រឡាយទឹកលេខ១៥ ក្នុងខេត្តតាកែវ ប្រព័ន្ធធារាសាស្ត្រ ខេត្តពោធិសាត់ ខេត្តព្រៃវែង ខេត្តកំពង់ឆ្នាំង។ ដាំដើមឈើបាន ៦៦៣ ហិកតា ដាំកៅស៊ូថ្មីបាន ១.៤២៥ ហិកតា ជួសជុលផ្លូវបានប្រវែង ២១៣ គ.ម ជួសជុល និងសាងសង់ស្ពានបានប្រវែង ៥០៤ ម៉ែត្រ សាងសង់ឃ្លាំងផ្ទុកទំនិញបានទំហំ ១២.០០០ ម៉ែត្រក្រឡា និងសាងសង់ មន្ទីរពេទ្យសម្រាប់ព្យាបាលកម្មករ គឺនៅមន្ទីរពេទ្យបជិវត្តន៍ បានមួយកន្លែង។ ចំពោះបញ្ហាលំបាកជុំវិញការវិនិយោគនាជំណាក់កាលនោះ មានស្ថានភាពដូចខាង

ក្រោមនេះ៖

- ការផ្ដល់ទុនទៅលើសំណង់ការដ្ឋានធំៗមួយចំនួន មិនបានសម ស្របតាមតម្រូវការ
- ការដ្ឋានដែលត្រូវសាងសង់មានច្រើនពេក ដែលជាបញ្ហាលំបាក ក្នុងការបែងចែកទុនវិនិយោគ។
- ការដ្ឋានគមនាគមន៍ ច្រើនតែជួសជុលដាក់អោយប្រើប្រាស់ជា បណ្ដោះអាសន្នប៉ុណ្ណោះ ហើយត្រូវជួសជុលឡើងវិញស្ទើររាល់ឆ្នាំ។
- ការគ្រប់គ្រងនៅតាមការដ្ឋានសំណង់ទាំងអស់ មានភាពធូរលុង កម្មករខ្វះវិន័យ ការសាងសង់ពុំមានគុណភាពល្អ និងប្រើប្រាស់ពេល វេលាវែងអន្លាយ។ល។ [190]

## ៩.៧. ការខារសហប្រតិបត្តិការ សេដ្ឋកិច្ចលើពិភពលោក

ចំពោះទំនាក់ទំនងសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ និងផ្លាស់ប្ដូរទំនិញ យើងសង្កេតឃើញថា ក្នុងអំឡុងពេល ១០ឆ្នាំ (១៩៧៩ ដល់ ១៩៨៨) កន្លងមក ប្រទេសកម្ពុជាបានសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយបណ្ដាប្រទេសមួយចំនួនលើពិភពលោក។

[190] ឈុន ពហុ, ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ២៤

- ក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិទ្យាសាស្ត្រ បច្ចេកទេស ប្រទេសកម្ពុជាបានបង្កើតទំនាក់ទំនងជាមួយប្រទេសវៀតណាម ឡាវ អតីតសហភាពសូវៀត បណ្ដាប្រទេសសង្គមនិយមនៅអឺរ៉ុប ខាងកើត និងប្រទេសគុយបា។ នាសម័យនោះ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចបានក្លាយទៅជាតួនាទីមួយដ៏សំខាន់ ក្នុងការស្ដារ និងកសាងសេដ្ឋកិច្ចកម្ពុជា។ ភាគីបរទេសបានផ្ដល់ជំនួយឥតសំណង និងជំនួយថវិកា ជាសម្ភារៈ បរិក្ខា និងជាទំនិញសំខាន់ៗ

ខ្លះទៀត សម្រាប់ជួយស្ពារ ឬជួយកសាងសំណង់មួយចំនួន និងជួយបណ្តុះបណ្តាលមន្ត្រីរាជការ បុគ្គលិក កម្មករ ជាក្រុបខណ្ឌរដ្ឋ។

- កិច្ចសហប្រតិបត្តិការ តាមការផ្តល់ឥណទានពីអតីតសហភាពសូវៀត គឺសម្រាប់ផលិតកម្មកៅស៊ូធម្មជាតិ លើផ្ទៃដីសរុប ៤០.០០០ ហិកតា ក្នុងនោះ ២០.០០០ ហិកតា ជាផ្ទៃដីមានកៅស៊ូស្រាប់ និង ២០.០០០ ហិកតា គឺជាផ្ទៃដីដាំថ្មី។ ទន្ទឹមនឹងកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្មនេះ ប្រទេសកម្ពុជាក៏បានសហការជាមួយសាធារណៈរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ និងសាធារណៈរដ្ឋប្រជាមានិតប៉ុលហ្គារី ក្នុងទិសដៅស្ពារ និងអភិវឌ្ឍន៍កសិកម្មផងដែរ។
- បណ្តាអង្គការជាតិ ដែលស្ថិតនៅក្នុងបណ្តាញអង្គការសហប្រជាជាតិ និងបណ្តាអង្គការមនុស្សធម៌ពិភពលោក ក៏បានផ្តល់ជំនួយច្រើនបង្គួរដែរដល់ប្រទេសកម្ពុជា ក្នុងនោះស្បៀងអាហារ មធ្យោបាយដឹកជញ្ជូន មធ្យោបាយផលិតកម្មគីមី និងរបស់ប្រើប្រាស់។ ប៉ុន្តែទំហំជំនួយនេះបានថយចុះជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ ១៩៨២ មកម្ល៉េះ។ [191]
- បៀពិនិត្យជារួម រយៈពេល ១០ ឆ្នាំ ដែលជាដំណាក់កាលស្តារ សេដ្ឋកិច្ចជាតិប្រទេសកម្ពុជាបានបង្កើតទំនាក់ទំនងសហប្រតិបត្តិការ អន្តរជាតិយ៉ាងទូលំទូលាយ លើផ្នែកពាណិជ្ជកម្ម វប្បធម៌ ការបរទេស ជាមួយបណ្តាប្រទេសជាច្រើននៅលើពិភពលោក ប៉ុន្តែ ភាគច្រើនតែក្នុងសហគមន៍នៃបណ្តាប្រទេសសង្គមនិយមតែប៉ុណ្ណោះ។

## ៩.៨. វិស័យសិក្សាធិការជាតិ សុខាភិបាល និងវប្បធម៌សង្គម

### ៩.៨.១ វិស័យការសិក្សាអប់រំ

ក្រោយឆ្នាំ ១៩៧៩ វិស័យសិក្សាអប់រំ ត្រូវបានរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា។ រដ្ឋបានរៀបចំឡើងវិញនូវប្រព័ន្ធអប់រំយ៉ាង ទូលំទូលាយ ពីទីក្រុងរហូតដល់ជនបទដាច់ស្រយាល។ នៅឆ្នាំ ១៩៨២ ដល់ឆ្នាំ ១៩៨៣ យើងពិនិត្យឃើញថា ចំនួនសិស្សថ្នាក់មតេយ្យសិក្សា និងបឋមសិក្សា មានចំនួនប្រមាណ ១.៥០០.០០០ នាក់ សិស្សថ្នាក់អនុវិទ្យាល័យមានចំនួនប្រហែល ៥០.០០០ នាក់ និងសិស្សថ្នាក់វិទ្យាល័យ មានចំនួនប្រហែល ២.០០០ នាក់។ គ្រូបង្រៀនសម្រាប់ភូមិសិក្សាខាង លើនេះមានចំនួនប្រហែល ៤០,០០០ នាក់។ សាលាថ្នាក់ឧត្តមសិក្សា និងមធ្យមសិក្សាបច្ចេកទេស ក៏បានបើកទ្វារទទួលនិស្សិតអោយចូលរៀនជាច្រើនអ្នកផងដែរ ដូចជាសាលាគរុវិជ្ជាជាន់ខ្ពស់ វិទ្យាស្ថានបច្ចេក ទេសជាន់ខ្ពស់ មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ និងផ្សេងៗទៀត។ [192]

[191] ឈុន ពហុ, ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ១៤

[192] ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២, ទំព័រ ៣៦២

វិស័យអប់រំនៅសម័យនោះ មានសន្ទុះរីកចម្រើនយ៉ាងខ្លាំងក្លា ពីមួយឆ្នាំទៅមួយឆ្នាំ ទាំងចំណេះទូទៅ ទាំងឧត្តមសិក្សា និងទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំនួនសិស្សានុសិស្សដែលបានចូលរៀនមាន កម្រិតខ្ពស់ជាងសម័យមុនៗ។ ក្នុងឆ្នាំសិក្សា ១៩៨៨-១៩៨៩ សិស្សានុសិស្សចំណេះទូទៅមានចំនួន រហូតដល់ ១.៧១២.៤៤០ នាក់។ ប្រព័ន្ធអប់រំចំណេះទូទៅ ត្រូវបានកែលម្អឡើងវិញ។ ការរៀន

សូត្រតាមសាលាបំពេញវិជ្ជា និងក្រៅម៉ោងធ្វើការ ត្រូវបានរដ្ឋយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងទិសដៅលើកកំពស់កម្រិតវប្បធម៌ជូនមន្ត្រីរាជការ បុគ្គលិកកម្មករ និងកងទ័ព។ ការរៀនសូត្ររបស់ជនជាតិភាគតិចនៅភូមិភាគឦសាន្ត ក៏ត្រូវបានរដ្ឋយកចិត្តទុកដាក់ដែរ។ ភាពអនក្ខរកម្មបានធ្លងផុតជាស្ថាពរ។

គ្រឹះស្ថានឧត្តមសិក្សា មធ្យមសិក្សាបច្ចេកទេស មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានស្តារឡើងវិញ ហើយការទទួលសិស្ស អោយចូលរៀន បានចំនួន ២៩.១០០ នាក់ នៅក្នុងឆ្នាំ ១៩៨៨-១៩៨៩។ ការបណ្តុះបណ្តាលគ្រូបង្រៀនក៏ត្រូវបានពង្រីកទាំងបរិមាណ និងគុណ ភាពនៅគ្រប់សាលាគរុកោសល្យ នៅទូទាំងប្រទេស។ ការបណ្តុះ បណ្តាលក្របខណ្ឌបច្ចេកទេស ក្នុងនោះមានការបែងចែកលើមុខជំនាញ ឯកទេសមួយចំនួន សម្រាប់បណ្តាក្រសួង ខេត្ត-ក្រុង ក៏ត្រូវបានដំណើរ ការជាជំហានៗ។ ការបញ្ជូនសិស្ស និស្សិតនៅក្នុងប្រទេស អោយទៅ សិក្សានៅបរទេស ក៏បានដំណើរការល្អ។ ក្នុងរយៈពេល ១០ឆ្នាំ កន្លងមក ប្រទេសកម្ពុជាបានបណ្តុះបណ្តាលនិស្សិតថ្នាក់ឧត្តមបានចំនួនប្រមាណ ៨.៩៧០ នាក់ ក្នុងនោះ ការបណ្តុះបណ្តាលក្នុងប្រទេសបាន ប្រមាណ ៦.៦៤០ នាក់ និងទៅសិក្សានៅបរទេសបានប្រមាណ ២.៣ ៣០ នាក់។ តាមការស្រាវជ្រាវបង្ហាញថា ទន្ទឹមនឹងការស្តារឡើងវិញយ៉ាងចាប់រហ័សលើវិស័យអប់រំ ការបណ្តុះបណ្តាលធនធានមនុស្ស នាសម័យនោះបានជួបប្រទះនូវការលំបាកជាច្រើនដូចខាងក្រោម៖

- ការវិនិយោគទុនក្នុងវិស័យអប់រំមានកម្រិតស្តួចស្តើងៗ
- ការពង្រីកផ្នែកបរិមាណ និងគុណភាពពុំទាន់បានសមស្រប។
- កម្រិតយល់ដឹងលើមុខជំនាញរបស់គ្រូបង្រៀន និងមន្ត្រីរាជការ គឺនៅមិនទាន់ឆ្លើយតបទៅនឹងសំណូមពរអប់រំរបស់ប្រទេសជាតិឡើយ។
- របបគោលនយោបាយចំពោះបុគ្គលិកសិក្សា ពុំទាន់ធានាបានជីវភាពសមរម្យ និងពុំទាន់អាចអូសទាញសិស្សពូកែៗ អោយចូលធ្វើជា គ្រូបង្រៀនឡើយ។

### ៩.៨.២ វិស័យសុខាភិបាលសាធារណៈ

មូលដ្ឋានសេវាកម្មសុខាភិបាល ក៏ត្រូវបានស្តារឡើងវិញយ៉ាងឆាប់រហ័ស។ មណ្ឌលសុខភាពបានពង្រីករហូតដល់ថ្នាក់ស្រុក និងឃុំ។ រដ្ឋបានបំផុសចលនាអនាម័យការពារជម្ងឺរាតត្បាត និងជម្ងឺឆ្លងការចាត់ តាំងពិនិត្យព្យាបាលជម្ងឺបានរីករាលដាលរហូតដល់ជនបទ ដោយធ្វើអោយអត្រាឈឺស្លាប់របស់ប្រជាពលរដ្ឋ បានថយចុះជាបន្តបន្ទាប់ បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម និង ឱសថការី មានការកើនឡើងជារៀងរាល់ឆ្នាំ។ គ្រូពេទ្យ និងឱសថការី បានបញ្ជូនទៅដល់បណ្តាខេត្តឆ្ងាយៗ និងខេត្តដែលនៅមានសង្គ្រាម។

### ៩.៨.៣ វិស័យសង្គមកិច្ច

ទន្ទឹមនឹងនោះ ការងារសង្គមកិច្ចក៏បានចាប់បដិសន្ធិឡើងយ៉ាង ទាន់ពេលវេលា ដោយបានរួមចំណែកយ៉ាងសកម្ម សម្រួលដល់ការរស់ នៅរបស់កុមារកំព្រា ជនពិការ ព្រមទាំងដោះស្រាយការងារជូនគ្រួសារ កងទ័ពដែលបានបាត់បង់ជីវិតក្នុងសមរភូមិ ក៏ដូចជាដោះស្រាយការងារ ជូនជនពិការ ស្រប

តាមសមត្ថភាព និងលទ្ធភាពជាក់ស្តែង។ រដ្ឋក៏បាន រៀបចំគោលនយោបាយ សម្រាប់សម្រួលដល់ជនចូលនិវត្តន៍ផងដែរ។

## ៩.៩. ក្របខណ្ឌការងារពលកម្មសង្គម

ក្រោយថ្ងៃរំដោះ ដោយសំណូមពរតម្រូវអោយមានការកសាង បង្កើតស្ថាប័នគ្រប់គ្រងរដ្ឋ ដូច្នេះការជ្រើសរើសបុគ្គលិកធ្វើការនៅគ្រាដំបូង គឺមានលក្ខណៈប្រញាប់ប្រញាល់។ បន្ទាប់មកចាប់ពីឆ្នាំ ១៩៨៦ រដ្ឋាភិបាលបានកម្រិតជាអប្បរមានូវក្រុបខណ្ឌផ្នែករដ្ឋបាល ផ្តល់អាទិភាពដល់ការជ្រើសរើស ការសម្រេច និងការផ្ទេរក្របខណ្ឌទៅផ្នែកផលិតកម្មវិញ។ ទន្ទឹមនឹងនេះសម័យកាលនោះរដ្ឋមានគោលការណ៍ បើកអោយទូលាយ ក្នុងការប្រើប្រាស់កម្លាំងពលកម្មអណ្តែត សម្រាប់ប្រភេទការងារសាមញ្ញ ឬការងារដែលមានលក្ខណៈជារដូវកាល។

ក្នុងរយៈពេល ១០ឆ្នាំ កន្លងមកនេះ (១៩៧៩-១៩៨៨) រដ្ឋាភិបាល បានព្យាយាមកែលម្អរបបឧបត្ថម្ភ សម្រាប់ជីវភាពបុគ្គលិក មន្ត្រីរាជការ បានចំនួន ៣ ដង។ ពោលគឺចាប់ពីឆ្នាំ ១៩៨៦ មករដ្ឋបានផ្តល់ប្រាក់បៀវត្សរ៍តាមរបៀបថ្មី ដោយផ្អែកលើបរិមាណផលិតកម្មនៅក្នុងរោងចក្រសហគ្រាសមួយចំនួន។ ក្នុងលក្ខណៈនេះ រដ្ឋបានបង្កើតលំដាប់ ថ្នាក់បច្ចេកទេសកម្មករ និងបទដ្ឋានពលកម្មក្នុងផ្នែក
ចំការកៅស៊ូ ផ្នែកគ្រឿងយន្ត ត្រាក់ទ័រ ផ្នែកតម្បាញទៅតាមបណ្តារោងចក្រ សហគ្រាស រដ្ឋប្រកបដោយលទ្ធផលល្អប្រសើរ។

ទន្ទឹមនឹងនេះ រដ្ឋបានចាប់ផ្តើមអនុវត្តការងារជានាាប់រងសង្គម ការពារពលកម្ម និងសុវត្ថិភាពពលកម្ម តាមរយៈការបង្កើត និងផ្សព្វផ្សាយនូវគោលនយោបាយមួយចំនួនរបស់ខ្លួន។ ។[194]

សរុបមក ទោះបីជាមានការផ្សព្វផ្សាយ និងអនុវត្តគោលនយោ បាយថ្មីហើយក៏ដោយ ក៏ការងារពលកម្ម និងប្រាក់បៀវត្ស គឺមានកម្រិតទាប។ រូបភាពប្រមូលផ្តុំកម្លាំងពលកម្មសង្គមក្នុងប្រទេស និងការប្រើប្រាស់កម្លាំងពលកម្មមិនទាន់បាន។ ការជ្រើសរើស និងការប្រើប្រាស់ បុគ្គលិកអណ្តែតនៅតាមកន្លែងខ្លះៗ អនុវត្តពុំបានត្រឹមត្រូវ ស្របតាមគោលការណ៍បច្ចេកទេស។ ជាទូទៅរដ្ឋបានជួបប្រទះនូវការខ្វះខាតមន្ត្រី បុគ្គលិកជំនាញ និងអ្នកបច្ចេកទេសវិទ្យាសាស្ត្រ។ ចំពោះប្រាក់បៀវត្ស សម្រាប់មន្ត្រីរាជការ កម្មករ បុគ្គលិក កងកម្លាំងប្រដាប់អាវុធ គឺនៅមានកម្រិតទាបនៅឡើយ។

194 ឈុន ពហុ, ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៨, ទំព័រ ៣០

## ៩.១០.សេចក្តីសន្និដ្ឋាន

តាមការស្រាវជ្រាវកន្លងមក ជុំវិញប្រវត្តិសេដ្ឋកិច្ច-សង្គម របស់ប្រទេសកម្ពុជា នាសម័យកាលនោះ (ឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨៩) យើងសង្កេតឃើញថា ប្រទេសកម្ពុជា បានស្ថិតនៅក្នុងដំណាក់កាលនៃការស្តារប្រទេសជាតិឡើងវិញ ក្រោយពីរបប ប៉ុល ពត យ៉ាងលំបាកវេទនា និងកសាងឡើងដោយបាតដៃទទេ។ ក្នុងរយៈពេល ១០ ឆ្នាំនេះ ប្រទេសកម្ពុជាយើងបានរៀបចំស្តារឡើងវិញលើគ្រប់

ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច-សង្គម អោយមានដំណើរការជាប្រក្រតី។ នៅក្នុងដំណាក់កាលនោះ ប្រទេសកម្ពុជា គឺបានកសាងសេដ្ឋកិច្ច-សង្គម ដោយទទួលបាននូវលទ្ធផលគួរជាទីមោទនៈដែរ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បញ្ហាលំបាកសព្វយ៉ាងបានចោទមានឡើងចំពោះមុខប្រទេសជាតិវាពិតជានាំមកនូវឧបសគ្គក្នុងការស្តារ និងការកសាងប្រទេសឡើងវិញចៀសមិនរួច។ ហើយដើម្បីជំនះរាល់ឧបសគ្គទាំងនោះបើតាមទស្សនៈរបស់អ្នកគ្រប់គ្រងរដ្ឋនាសម័យនោះ បានកំណត់ថា ត្រូវតែមានការកែទម្រង់ទៅលើចំណុចសម្ខាន់ៗមួយចំនួនដូចខាងក្រោមៈ

- ដោយខឿនសេដ្ឋកិច្ចជាតិផ្អែកលើវិស័យកសិកម្ម ហើយវិស័យនេះពឹងផ្អែកលើធម្មជាតិ ដូច្នេះទិន្នផលកសិកម្មដែលយើងទទួលបាន គឺសម្រាប់តែបម្រើជីវភាពប៉ុណ្ណោះ។ ម៉្យាងវិញទៀត ដីកសិកម្មដែល ធ្លាប់បានប្រើប្រាស់ពីសម័យមុនមក គឺនៅសល់ប្រមាណ ១.០០០.០០០ ហិកតា ដោយពុំបានស្តារ។ ហើយដីកសិកម្មដែលធ្លាប់បានប្រកបអាជីវកម្ម ប្រមាណជិត ១០០ ឆ្នាំ កន្លងមកហើយនោះ ភាគច្រើនបានក្លាយទៅជាដីខ្សោះគ្មានជីជាតិ។ តំបន់ថ្មីដែលបានរុករកសម្រាប់បម្រើវិស័យកសិកម្ម គឺបានជួបនូវការលំបាកច្រើន។ ហេតុដូច្នេះ ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ គួរតែប្រើប្រាស់បច្ចេកវិទ្យាទំនើបប្រើពូជល្អៗ ប្រើប្រាស់ជី និងជម្រុញការស្រាវជ្រាវកសិកម្មជាការចាំបាច់។
- ផលិតកម្មឧស្សាហកម្ម សិប្បកម្មក៏បានស្តារឡើងវិញជាបណ្តើរៗ ដោយបានចាប់ផ្តើមដំណើរការជាមួយមធ្យោបាយផលិតកម្មដែលសេសសល់ចាស់ៗ ពីសម័យមុនៗ។ ឈរលើលក្ខណៈបែបនេះ ស្ថេរភាពផលិតកម្មពុំទាន់បានត្រូវជានា និងប្រសិទ្ធភាពសេដ្ឋកិច្ចក៏ស្ថិតក្នុងកម្រិតទាប។ វិស័យឧស្សាហកម្មនាសម័យនោះ បានជួបនូវការលំបាកធំៗជាច្រើន ដូចជា កង្វះខាតវត្ថុធាតុដើម ខ្វះខាតប្រេងឥន្ធនៈ ខ្វះថាមពល អគ្គិសនី ដែលជាហេតុនាំអោយជះឥទ្ធិពល ជាអវិជ្ជមានដល់តម្លៃផលិតទំនិញ។ ដូច្នេះ បើសិនជាដោះស្រាយបញ្ហាលំបាកទាំងនេះបាន វិស័យ ឧស្សាហកម្មនឹងដំណើរការបានល្អប្រសើរ។
- ប្រព័ន្ធគមនាគមន៍មានលក្ខណៈងាយស្រួល ដោយសារប្រទេសកម្ពុជាមានបណ្តាញផ្លូវគោក ផ្លូវទឹក ផ្លូវដែក ដែលតភ្ជាប់រាជធានីភ្នំពេញ ទៅកាន់តំបន់សេដ្ឋកិច្ចសំខាន់ៗទូទាំងប្រទេស ប៉ុន្តែការជួសជុលហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដែលបានខូចខាតខ្ទេចខ្ទាំដោយសារសង្គ្រាមនៅមានកម្រិតទាបនៅឡើយ។ ដើម្បីជានាការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ប្រទេសកម្ពុជាយើង ត្រូវតែប្រមូលផ្តុំកម្លាំងធនធានសម្រាប់ការកសាង និងស្តារបណ្តាញផ្លូវជាយុទ្ធសាស្ត្រសំខាន់ៗ។
- ជញ្ជីងពាណិជ្ជកម្មអន្តរជាតិ បានជួបប្រទះនូវឱនភាពជាប្រចាំ។ ការខ្វះខាតទាំងនេះ គឺត្រូវបានបំពេញបន្ថែម ដោយជំនួយឧបត្ថម្ភពីក្រៅប្រទេសក្នុងក្របខណ្ឌជាជំនួយឥតសំណង និងជំនួយឥណទាន។ ដើម្បីកាត់បន្ថយការបាត់បង់តុល្យភាពអវិជ្ជមាន ជុំវិញការនាំចេញ និងការនាំចូល ជាការចាំបាច់ត្រូវតែជម្រុញគោលនយោបាយនាំចេញអោយបានច្រើន។

- ចំពោះវិស័យអប់រំ សុខាភិបាល វប្បធម៌ សង្គមកិច្ច ក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ ថ្វីត្បិតតែមានការស្តារឡើងវិញ និងមានការរីកចម្រើន ហើយមានផ្នែកខ្លះបានឈានដល់កម្រិតខ្ពស់ជាងមុនៗ ក៏ដោយក៏យើងមើលឃើញថា សង្វាក់នៃការរីកលូតលាស់នៅមិនទាន់បម្រើសេចក្តីត្រូវការរបស់ប្រទេសជាតិបាននោះឡើយ។

សរុបសេចក្តីមក សមិទ្ធិផលសេដ្ឋកិច្ចសង្គមសំខាន់ៗដែលបានស្តារ និងកសាងឡើងចន្លោះឆ្នាំ ១៩៧៩ ដល់ ១៩៨៨ យើងពិនិត្យឃើញថា នៅមានសភាពទន់ខ្សោយនៅឡើយ បើប្រៀបធៀបទៅនឹងសម័យមុនសង្គ្រាម។ ប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ការគ្រប់គ្រងបច្ចេកទេសក្នុងផលិតកម្ម វិធានការបណ្តុះបណ្តាលវិស័យធនធានមនុស្ស ការគ្រប់គ្រងសេដ្ឋកិច្ចផលិតកម្ម និងអាជីវកម្មក្នុងស្រុក ក៏ដូចជាការនាំចេញនាំចូល គឺពុំទាន់បានឆ្លើយតបបានទៅនឹងសេចក្តីត្រូវការរបស់សង្គមជាតិនោះឡើយ។

# ជំពូកទី ១០
# សេដ្ឋកិច្ចប្រទេសកម្ពុជា នាសម័យរដ្ឋកម្ពុជា ឆ្នាំ ១៩៨៩-១៩៩៣

## ១០.១. ព្រឹត្តិការណ៍នយោបាយ

ក្រោមព្រះរាជកិច្ចដឹកនាំដ៏ឈ្លាសវៃរបស់ព្រះមហាក្សត្រខ្មែរ ព្រះវររាជបិតាជាតិ ព្រះបាទសម្តេច នរោត្តម សីហនុ ព្រមទាំង ដោយមានការឧបត្ថម្ភគាំទ្រ ពីសំណាក់អង្គការសហប្រជាជាតិ ក៏ដូចជាសហគមន៍ អន្តរជាតិ និងក្រោមកិច្ចខិតខំប្រឹងប្រែង របស់ប្រជាពលរដ្ឋខ្មែរ ក្នុងគោលបំណងស្វែងរកសុខសន្តិភាពជូនសង្គមជាតិយើង បានធ្វើអោយសម្រេចជោគជ័យមួយដ៏ធំធេង ជាប្រវត្តិសាស្ត្រនៅចុងឆ្នាំ ១៩៩៣ ជាពិសេសសមិទ្ធិផលនយោបាយ នេះបានផ្តល់ឱកាស និងជាលក្ខខណ្ឌអំណោយ ដល់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស ក្នុងការស្តារសេដ្ឋផលដ៏ល្អប្រសើរ កិច្ច-សង្គមកិច្ច បន្តទៅទៀត ដែលធ្លាប់ត្រូវបានរងនូវការបំផ្លិចបំផ្លាញ ក្នុងអំឡុងពេលជិត ៣ ទសវត្សកន្លងមកនេះ។

សមិទ្ធិផលនយោបាយជាផ្លែផ្កា នៃការបង្រួបបង្រួមជាតិខ្មែរនាសម័យនោះបាននាំមកនូវសុខសន្តិភាពពិតប្រាកដមួយជូនដល់ប្រទេសជាតិ និងបានបង្កលក្ខខណ្ឌចាំបាច់ដែលពុំអាចខ្វះខាតបានសម្រាប់ប្រជាពលរដ្ឋខ្មែរ ក្នុងការលុបបំបាត់ស្លាកស្នាមរបួសដែលបន្សល់ទុកដោយសង្គ្រាម ក្រោមគំនាបមនោគមវិជ្ជានយោបាយបរទេស និងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ក្នុងស្ថានភាពចំពោះមុខ និងយូរអង្វែង ក្រោមកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ដើម្បីជួយស្តារ និងអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ។

ព្រឹត្តិការណ៍នយោបាយដែលបានកើតមានឡើងគួរអោយកត់ សម្គាល់នាពេលនោះ គឺទាក់ទងទៅនឹងការរៀបចំអោយមានកិច្ចប្រជុំលើកទី១ នាដើមខែកញ្ញា ឆ្នាំ១៩៩៣ របស់គណៈកម្មការអន្តរជាតិ សម្រាប់ការស្តារប្រទេសកម្ពុជា ដែលបានឆ្លុះបញ្ចាំងអំពីការគាំទ្រទាំងស្រុងរបស់សហគមន៍អន្តរជាតិ ក្នុងការស្តារប្រទេសជាតិឡើងវិញ ដោយបានសន្យាផ្តល់ជាទឹកប្រាក់យ៉ាងច្រើនបន្ថែមពីលើការសន្យានៅទីក្រុង តូក្យូ ឆ្នាំ ១៩៩២។

ព្រឹត្តការណ៍នយោបាយសំខាន់ជាងគេនាសម័យកាលនោះ គឺទាក់ទងនឹងការបោះឆ្នោតជាសាកលនៅចុងឆ្នាំ ១៩៩៣ ដែលមានការចូលរួមពីប្រជាពលរដ្ឋប្រមាណជា ៩០% និងមានការចូលរួមពីសំណាក់គណបក្សនយោបាយចំនួន ៣៨ គណបក្ស។

នៅសម័យរដ្ឋកម្ពុជា បើយើងពិនិត្យទៅលើស្ថានភាពនយោបាយជារួម យើងពិនិត្យឃើញថាដោយសារផលវិបាកទាំងឡាយដែលបន្សល់ទុកពីវិនាសកម្មអតីតកាល បានធ្វើអោយសង្គមកម្ពុជា នៅតែបន្ត ប្រឈមមុខនឹងបញ្ហាជាច្រើននៅឡើយ។ ក្នុងវិស័យសង្គមកិច្ច បានជួបប្រទះនូវចំណោទបញ្ហាធំៗជាច្រើនយ៉ាង ដូចជាបញ្ហាជនពិការ ស្ត្រីមេម៉ាយ កុមារកំព្រា។ល។ ទាំងនេះជាបន្ទុកដ៏ធំមួយសម្រាប់រាជរដ្ឋាភិបាល ដែលត្រូវដោះស្រាយជាបន្ទាន់។ បន្ថែមពីលើបន្ទុកនេះ ការធ្វើមាតុភូមិនិវត្តន៍នៃជនភៀសខ្លួន បានធ្វើអោយគ្រាកំណើនប្រជារាស្ត្រ កើនឡើង ប្រមាណ ៥% ក្នុងឆ្នាំ ១៩៩២-

១៩៩៣ និងបានបង្កើនបន្ទុកដល់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហា ជម្រកស្នាក់នៅ បញ្ហាស្បៀងអាហារ ជីផ្លីសម្រាប់បង្កបង្កើនផល ការងារសុខាភិបាល សេវាសិក្សាអប់រំជាដើម។ល។

ទន្ទឹមនឹងនេះ ទោះបីជាមានវត្តមាននៃអាជ្ញាធរបណ្តោះអាសន្ន អន្តរជាតិ(អ៊ុនតាក់) នៅកម្ពុជានាសម័យកាលនោះ ដែលបានផ្តល់ការ ងារជាច្រើនដល់ប្រជាពលរដ្ឋនៅក្នុងទីក្រុង និងជនបទធំៗមួយចំនួនក៏ដោយ ប៉ុន្តែឱកាសនេះបានបាត់បង់ទៅវិញ បន្ទាប់ពីការដកចេញនូវកងកម្លាំងអ៊ុនតាក់ពីប្រទេសកម្ពុជានាចុងឆ្នាំ ១៩៩៣ ។ [195]

## ១០.២. ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច - សង្គម

តាមការសិក្សាស្រាវជ្រាវ បង្ហាញថា នៅសម័យនោះសេដ្ឋកិច្ច កម្ពុជា ជាសេដ្ឋកិច្ចមួយ ស្ថិតនៅក្នុងចំណោមសេដ្ឋកិច្ចនៃបណ្តាប្រទេស ដែលមានសេដ្ឋកិច្ចទន់ខ្សោយជាងគេនៅលើពិភពលោក ព្រោះសេដ្ឋកិច្ច នេះត្រូវបានទទួលរងនូវការបំផ្លិចបំផ្លាញដោយសង្គ្រាម។ បើយើងពិនិត្យ លើផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ៗ (GDP per capita) តាមការប៉ាន់ស្មានគឺស្មើនឹង ១៨០ដុល្លាអាមេរិក (ឆ្នាំ១៩៩១)។ ទន្ទឹមនឹងនេះ ក្នុងដំណាក់កាលនោះ ភាពខ្វះចន្លោះក្នុងការរៀបចំនូវស្ថាប័នរដ្ឋ មួយដែលមានប្រសិទ្ធភាព និងភាពខ្វះខាតនូវលិខិតបទដ្ឋានគតិយុត្តិ ចាំបាច់សម្រាប់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ បានជះឥទ្ធិពលជាអវិជ្ជមានទៅលើផលប្រយោជន៍ជាតិទាំងមូល ដែលយើងទទួលបានពីការស្តារ និងការ កសាងសេដ្ឋកិច្ច-សង្គមកិច្ចរបស់កម្ពុជា។

ក្នុងដំណាក់កាលដំបូងនៃសម័យកាលនោះ ចំពោះកិច្ចការដែល ជាទស្សនៈទានដ៏សំខាន់បំផុតសម្រាប់បន្តការកសាង និងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាបន្តទៅទៀតនោះ គឺទាក់ទងទៅនឹងការគិតគួរពិចារណា លើបញ្ហាការធ្វើកំណែទម្រង់សេដ្ឋកិច្ចជាតិ ជាលើកដំបូង (ដំណាក់កាល ទី១ នៃការធ្វើកំណែទម្រង់សេដ្ឋកិច្ច) ក្នុងលក្ខណៈស៊ីជម្រៅ។ ប៉ុន្តែការស្រាវជ្រាវ គំនិតផ្តួចផ្តើមរៀបចំ និងការកែទម្រង់ការគ្រប់គ្រង សេដ្ឋកិច្ច ពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំមកជាសេដ្ឋកិច្ចទីផ្សារសេរីនៅកម្ពុជា គឺបានចាប់ផ្តើមឡើងតាំងពីពាក់កណ្តាលទសវត្សទី ៨០ មកម្ល៉េះ ដែលបានធ្វើអោយស្ថានភាពសេដ្ឋកិច្ចកម្ពុជា មានការរីកចម្រើនជាបណ្តើរៗរួចមកហើយ។

ចំពោះខ្លឹមសារជាមូលដ្ឋានជុំវិញកិច្ចការធ្វើកំណែទម្រង់សេដ្ឋកិច្ច ក្នុងសម័យកាលនោះ បានទាក់ទងនឹងវិស័យសេដ្ឋកិច្ចសំខាន់ៗទាំងអស់ ក្នុងនោះមានការធ្វើកំណែទម្រង់ក្នុងវិស័យកសិកម្មដែលផ្តោតលើការធ្វើកំណែទម្រង់ដីធ្លី ការធ្វើកំណែទម្រង់ក្នុងវិស័យឧស្សាហកម្មដោយផ្តោត លើការធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ និងការធ្វើកំណែទម្រង់ ក្នុងវិស័យសេវាកម្ម ដោយផ្តោតជាសំខាន់លើវិស័យធនាគារ។ យើងអាចពិនិត្យមើលលម្អិត អំពីខ្លឹមសាររួមនៃការធ្វើកំណែទម្រងសេដ្ឋកិច្ច កម្ពុជាក្នុងដំណាក់កាលទី១ ពីឆ្នាំ ១៩៨៩-១៩៩៣ ដូចខាងក្រោមនេះ ៖

### ១០.២.១ ការធ្វើកំណែទម្រង់ក្នុងវិស័យកសិកម្ម

ចំពោះចក្ខុវិស័យនៃការធ្វើកំណែទម្រង់សេដ្ឋកិច្ច នៅក្នុងវិស័យកសិកម្ម គឺជាការងារដែលរដ្ឋាភិបាលបានយកចិត្តទុកដាក់ដោះស្រាយមុនគេ និងបានចាប់ផ្តើមអនុវត្តជាផ្លូវការ គិតចាប់តាំងពីឆ្នាំ ១៩៨៩ដែលទាក់ទងទៅនឹងការធ្វើកែទម្រង់ដីធ្លី។ គួរបញ្ជាក់ថានៅដើមឆ្នាំ១៩៨៩សភាជាតិនប្រទេស

[195] ឈុន ពហុ. ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ១-២

កម្ពុជា បានធ្វើការកែទម្រង់យ៉ាងទូលំទូលាយក្នុងរដ្ឋធម្មនុញ្ញ ដើម្បីអោយមានរបបកម្មសិទ្ធិលើដីធ្លីៗផ្អែកលើខ្លឹមសារនៃ រដ្ឋធម្មនុញ្ញនាសម័យនោះ បានកំណត់ថាការកាន់កាប់ដីធ្លីរបស់ប្រពើ ពលរដ្ឋត្រូវបានបែងចែកជា ៣ ប្រភេទដូចខាងក្រោម៖

- ដីកម្មសិទ្ធិឯកជន
- ដីភោគ
- ដីសម្បទាន។

ទន្ទឹមនឹងកម្មសិទ្ធិដីធ្លីដែលបានទទួលស្គាល់ជាផ្លូវការ នៅក្នុងឆ្នាំ ១៩៨៩ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ក៏បានកែប្រែខ្លឹមសារជុំវិញការអនុវត្ត វិធានការចរាចរផលិតផលកសិកម្ម ដោយសេរីក្នុងទូទាំងប្រទេស ដែលប្រជាកសិករខ្មែរ អាចធ្វើសេចក្តីសម្រេចចិត្តក្នុងការផលិត និងកំណត់តម្លៃផលិតផលរបស់ខ្លួន ដោយយោងទៅតាមតម្លៃទីផ្សារ និងគ្មានការ អន្តរាគមន៍ពីសំណាក់រដ្ឋាភិបាលឡើយ។ ជារួមការទទួលស្គាល់កម្មសិទ្ធិ ដីធ្លីឯកជន បានជះឥទ្ធិពលជាវិជ្ជមានទាំងផ្នែកសេដ្ឋកិច្ច សង្គម និងផ្នែកនយោបាយ ដោយប្រជាកសិករខ្មែរមានជំនឿទុកចិត្តលើគោលនយោ បាយ និងខិតខំកែលម្អដីធ្លីរបស់ខ្លួន។ ម្យ៉ាងទៀត គោលនយោបាយ ចរាចរផលិតផលកសិកម្មដោយសេរី និងគោលនយោបាយសារពើពន្ធ ក្នុងវិស័យកសិកម្មក៏បានរួមវិភាគទានយ៉ាងសំខាន់ ក្នុងកិច្ចការអភិវឌ្ឍន៍វិស័យនេះផងដែរ។[196]

### ១០.២.២ កំណែទម្រង់ឧស្សាហកម្ម

ចំពោះការធ្វើកំណែទម្រង់ក្នុងវិស័យឧស្សាហកម្មវិញ ចាប់តាំងពី ឆ្នាំ ១៩៨៩ មក ក្នុងអំឡុងពេលរដ្ឋាភិបាល បានបើកទូលាយនូវយន្តការសេដ្ឋកិច្ចទីផ្សារក្នុងផ្នែកកសិកម្ម រដ្ឋក៏បានខិតខំប្រឹងប្រែងធ្វើឯកជន ភាវូបនីយកម្មសហគ្រាសរដ្ឋដែរ។ នេះគឺជាទិសដៅដ៏សំខាន់ក្នុងដំណើរការកែទម្រង់សេដ្ឋកិច្ចជាតិក្នុងវិស័យឧស្សាហកម្ម។ បើយោងទៅតាមកាលៈទេសៈជាក់ស្តែងវិធីសាស្ត្រកែទម្រង់ការគ្រប់គ្រងសហគ្រាសរដ្ឋ មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតហើយផលវិបាក និងការជះឥទ្ធិពលទៅលើសេដ្ឋកិច្ចទាំងមូលក៏មានភាពខុសគ្នាដែរ។ គោលដៅនៃការធ្វើកំណែទម្រង់សហគ្រាសរដ្ឋ គឺមានអត្ថប្រយោជន៍សំខាន់ៗដូចខាងក្រោមនេះ ៖

- បង្កលក្ខណៈដល់សកម្មភាពសហគ្រាសរដ្ឋអោយកាន់តែមាន ប្រសិទ្ធភាពក្នុងវិស័យផលិតកម្ម ដើម្បីមានលទ្ធភាពធ្វើការប្រកួតប្រជែងនៅលើទីផ្សារ ដែលនាំមកនូវផលប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ។

- កាត់បន្ថយបន្ទុកថវិកាជាតិ ដែលធ្លាប់បានផ្តល់ទៅអោយសហគ្រាសរដ្ឋ តាមរយៈរូបភាពឧបត្ថម្ភធនផ្សេងៗ។

ចំពោះការធ្វើកំណែទម្រង់សហគ្រាសរដ្ឋ នាសម័យកាលនោះ ដែលបានចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ១៩៨៩ ត្រូវបានបែងចែកជា ២ ជំហាន ដូចខាងក្រោមនេះ ៖

- ស្វ័យភិបាលសេដ្ឋកិច្ចក្នុងផលិតកម្ម និងស្វ័យាភិបាលសេដ្ឋកិច្ច ក្នុងសេវាកម្ម ។
- ឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ ។

196 ឈុន ពហុ, ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ២-៣

២.២.១ ជំហានទី១ នៃកំណែទម្រង់វិស័យឧស្សាហកម្ម

ចំពោះការធ្វើកំណែទម្រង់ឧស្សាហកម្ម សម្រាប់ជំហានទី១ ក្នុងសម័យនោះមានពីរលក្ខណៈ គឺការធ្វើអោយមាន ស្វ័យាភិបាលសេដ្ឋកិច្ច ក្នុងផលិតកម្ម និងស្វ័យាបាលសេដ្ឋកិច្ចក្នុងសេវាកម្ម ដែលមានសារដូចខាងក្រោមនេះ ៖

- ស្វ័យាភិបាលសេដ្ឋកិច្ចក្នុងផលិតកម្ម

នៅចុងឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩០ រដ្ឋាភិបាលបានបញ្ឈប់ការលូកដៃចូលក្នុងដំណើរការផលិតកម្ម អាជីវកម្មរបស់សហគ្រាសរដ្ឋ បន្ទាប់ពីមានការអនុវត្តរបបស្វ័យាភិបាលសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះដែរ សហគ្រាសរដ្ឋទាំងឡាយ អាចរក្សាទុកនៅខ្ទង់ចំណាយទាំងឡាយ បន្ទាប់ពីបានធ្វើការបង់ពន្ធចូលថវិការដ្ឋ និងចំនួនទឹកប្រាក់ពាក់កណ្តាល នៃរំលស់ទុនអចលនៈទ្រព្យ។ ប៉ុន្តែការអនុវត្តរបបស្វ័យាភិបាលសេដ្ឋកិច្ច គឺបានជួបប្រទះនូវការលំបាក ដោយសាររដ្ឋនៅតែធ្វើការត្រួតពិនិត្យ លើការវិនិយោគ ការកំណត់ថ្លៃទំនិញ និងការចំណាយរូបិយប័ណ្ណ ហើយរដ្ឋត្រូវដកយកទុនចល័តពីសហគ្រាសរដ្ឋ ដើម្បីយកមកបំពេញឱនភាពថវិកាជាតិ។

- ស្វ័យាភិបាលសេដ្ឋកិច្ចក្នុងសេវាកម្មចរាចរទំនិញ

នាសម័យនោះ របបស្វ័យាភិបាលសេដ្ឋកិច្ចក្នុងសេវាកម្ម ក៏មិនអាចអនុវត្តបានជោគជ័យដែរ ដោយសារសកម្មភាពផ្លាស់ប្តូរទំនិញជា មួយអតីតបណ្តាប្រទេសអឺរ៉ុបខាងកើតត្រូវបានបញ្ចប់។ ទន្ទឹមនឹងនេះដែរក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋ បានជួបការលំបាក ដោយសារការបាត់បង់ ទំនិញ ដែលធ្លាប់បានផ្តល់អោយស្ទើរតែទាំងស្រុងដោយប្រទេសសង្គមនិយមនិងខ្វះដើមទុនក្នុងការធ្វើពាណិជ្ជកម្ម។ ម្យ៉ាងវិញទៀតរបបស្វ័យាភិបាលសេដ្ឋកិច្ចទីផ្សារ ពុំទាន់មានភាពច្បាស់លាស់ ហើយនឹងកង្វះខាតនូវប្រព័ន្ធច្បាប់ចាំបាច់ ដើម្បីសម្រួលដល់ដំណើរការអនុវត្តរបប ស្វ័យាភិបាលសេដ្ឋកិច្ច អោយស្របតាមស្តង់ដារសេដ្ឋកិច្ចទីផ្សារ។ [197]

២.២.២ ជំហានទី២ នៃកំណែទម្រង់វិស័យឧស្សាហកម្ម

ចំពោះជំហានទី២ នៃការធ្វើកំណែទម្រង់វិស័យឧស្សាហកម្ម គឺទាក់ទងទៅនឹងការបម្លែងកម្មសិទ្ធិគ្រប់គ្រងដោយរដ្ឋ ទៅអោយឯកជន នូវសហគ្រាសសាធារណៈ ដែលហៅថា ឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ។

ផ្អែកតាមបទពិសោធន៍ពិភពលោកបានបង្ហាញថា ការធ្វើកំណែ ទម្រង់សហគ្រាសសាធារណៈ ជាពិសេស ការធ្វើឯកជនភាវូបនីយកម្ម សហគ្រាសរដ្ឋ គឺជានយោបាយសេដ្ឋកិច្ចមួយដ៏សំខាន់បំផុតរបស់រដ្ឋ ផ្នែកសេដ្ឋកិច្ច ដែលរដ្ឋបានយកចិត្តទុកដាក់នៅពេលដែលប្រទេសជាតិ បានសម្រេចផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ច ពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំទៅ ជាសេដ្ឋកិច្ចទីផ្សារសេរី។ ម៉្យាងទៀតបញ្ហាចំបងពាក់ព័ន្ធនឹងការធ្វើកំណែទម្រង់សហគ្រាសរដ្ឋ គឺបណ្តាលមកពីមូលហេតុច្រើនយ៉ាង ប៉ុន្តែមូល ហេតុសំខាន់ជាងគេនោះគឺ ភាពទន់ខ្សោយក្នុងការធ្វើអាជីវកម្មរបស់សហគ្រាសរដ្ឋតែម្តង។

ជារួម កត្តាដែលធ្វើអោយដំណើរការផលិតកម្មរបស់សហគ្រាសរដ្ឋ មានភាពទន់ខ្សោយជាងសហគ្រាសឯកជន គឺបណ្តាលមកពីហេតុផលសំខាន់ៗ បីយ៉ាងដូចជា ៖

- ភាពគ្មានការប្រកួតប្រជែង

កត្តាចម្បងគឺ សហគ្រាសរដ្ឋមានសិទ្ធិផ្តាច់មុខលើទីផ្សារក្នុងការ ផ្គត់ផ្គង់ទំនិញ ភាពផ្តាច់មុខនេះ ធ្វើអោយសហគ្រាសរដ្ឋយកចិត្តទុកដាក់ទៅលើតែផលិតកម្មតាមផែនការដែលបានកំណត់ ហើយមិនបាន ពិចារណាលម្អិតទៅលើតម្រូវការរបស់អ្នកប្រើប្រាស់ ឬការប្រែប្រួលនៃតម្រូវការលើទីផ្សារ ហើយមិនអាចជម្រុញអោយបច្ចេកវិទ្យា មានភាពជឿនលឿនទៅមុខដោយសារទីផ្សាររបស់សហគ្រាសរដ្ឋ ជាប្រភេទទីផ្សារផ្តាច់មុខ។

- ខ្វះការលើកទឹកចិត្ត

ជាទូទៅអ្នកដឹកនាំ និងកម្មករដែលបម្រើការនៅក្នុងសហគ្រាសរដ្ឋ ពុំបានទទួលប្រាក់កម្រៃអោយបានសមស្របទេ ទោះបីជាអ្នកទាំងនោះធ្វើការល្អ ឬធ្វើអោយមានទិន្នផលផលិតកម្មខ្ពស់ក៏ដោយ។ ការបង្កើនប្រាក់ចំណូលរបស់សហគ្រាសរដ្ឋ គឺគ្រាន់តែបានចូលរួមចំណែកបង្កើនចំណូលថវិការដ្ឋប៉ុណ្ណោះ។ និយោជក និងកម្មករនៃសហគ្រាសទាំងនោះ ពុំបានទទួលផលអ្វីក្រៅពីប្រាក់បៀវត្សរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ ឱនភាពថវិការបស់សហគ្រាសរដ្ឋ ត្រូវបានបំពេញដោយថវិកាជាតិដដែល។ ដូច្នេះ គេមិនរំពឹងទុកថា អ្នកគ្រប់គ្រង និងកម្មករនៅក្នុង សហគ្រាសរដ្ឋប្រឹងប្រែងបង្កើនប្រសិទ្ធភាពអាជីវកម្មរបស់ខ្លួនឡើយ។ ក្នុងករណីខ្លះទៀត តម្លៃផលិតផលទំនិញរបស់សហគ្រាសរដ្ឋជាទូទៅ ត្រូវបានបញ្ចុះតម្លៃទាបជាងតម្លៃពិតរបស់វា ដើម្បីធានានូវជីវភាពរបស់ប្រជាពលរដ្ឋ។ នេះគឺជាកត្តាមួយផ្សេងទៀត ដែលកាត់បន្ថយការលើក ទឹកចិត្តកម្មកររបស់សហគ្រាសរដ្ឋ។

- កង្វះខាតក្នុងការគ្រប់គ្រង

ភាគច្រើននៃអាជីវកម្មរបស់សហគ្រាសរដ្ឋ រមែងតែងតែទទួល ការធ្វើអន្តរាគមន៍ ឬ ការណែនាំពីរដ្ឋាភិបាលក្នុងការធ្វើសេចក្តីសម្រេច ផ្សេងៗរបស់សហគ្រាស។ រដ្ឋាភិបាលតែងតែធ្វើសេចក្តីសម្រេចលើសហគ្រាសរដ្ឋដោយឈរលើមូលដ្ឋានទស្សនៈនយោបាយធំជាង ទស្សនៈសេដ្ឋកិច្ច ។ បញ្ហានេះ ធ្វើអោយប្រធានសហគ្រាសពុំមានសិទ្ធិសម្រេច ឬសិទ្ធិស្វ័យគ្រប់គ្រងពេញលេញនោះឡើយ។

លក្ខណៈពិសេសនៃដំណើរការសេដ្ឋកិច្ចនៅកម្ពុជានាសម័យនោះ គឺការអភិវឌ្ឍដោយបើកទូលាយ ឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលក្នុងនោះឯកជនភាវូបនីយកម្ម គឺជាការងារស្នូលនៃ កំណែទម្រង់។ ក្នុងអំឡុងពេលអន្តរកាល ពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំ ឆ្ពោះទៅរកសេដ្ឋកិច្ច

ទីផ្សារ គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋាភិបាល គឺធ្វើយ៉ាងណាអោយមានការទាក់ទាញអ្នកវិនិយោគិនបរទេស ដែលអាចចូលមកបណ្តាក់ទុនវិនិយោគ និងអាចផ្តល់ចំណេះដឹងចាំបាច់ដែល ជាមធ្យោបាយយ៉ាងសំខាន់ ដើម្បីស្តារសេដ្ឋកិច្ចជាតិ។ ហេតុនេះ ការធ្វើឯកជនភាវូបនីយកម្ម ត្រូវបានលើកទឹកចិត្ត ដោយផ្អែកលើមូលដ្ឋាន ច្បាប់ជាចម្បងសម្រាប់ដំណើរការនេះ (ច្បាប់វិនិយោគដែលបានអនុម័តនៅឆ្នាំ ១៩៨៩) និងអនុក្រឹត្យរបស់រដ្ឋាភិបាល ដែលក្នុងនោះបានចែងពីវិស័យអទិភាពមួយចំនួន។ យើងអាចពិនិត្យមើល ច្បាប់វិនិយោគដែលមានចែងពីវិស័យអទិភាពចំនួន ៥ ដូចខាងក្រោម៖

- ផលិតកម្មដែលប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក
- ការផលិតទំនិញសម្រាប់ការនាំចេញ និងទំនិញដែលអាចជំនួសទំនិញនាំចូលសំខាន់ៗ
- សេវាកម្មដែលបង្កើនចំណូលរូបិយប័ណ្ណបរទេស
- ការកសាងហេដ្ឋារចនាសម្ព័ន្ធសម្ខាន់ៗដូចជា រោងចក្រអគ្គិសនី ស្ថានីយ៍វារីអគ្គិសនី ផ្លូវ ស្ពាន កំពង់ផែ និងព្រលានយន្តហោះ
- កសិកម្ម និងការចិញ្ចឹមសត្វ

ក្នុងដំណាក់កាលទី១ អាជ្ញាធរបានលក់ និងជួលសហគ្រាសរដ្ឋ ដើម្បីទាក់ទាញអ្នកវិនិយោគបរទេស ហើយរក្សាអោយបាននូវពលករ ដែលធ្លាប់បានបម្រើការងារជាអទិភាព។ សរុបមក សហគ្រាសរដ្ឋមានចំនួន ១៥២ ក្នុងនោះ ៥០ សហគ្រាសរដ្ឋ បានលក់ និង ៥២ ទៀតបាន ជួល ក្នុងនោះជា
សហគ្រាសដែលមានផលិតកម្មខ្នាតតូច។ រីឯ សហគ្រាសខ្នាតមធ្យម និងខ្នាតធំ ក៏រដ្ឋចង់ជួលអោយអ្នកវិនិយោគបរទេសដែរ។ លក្ខខណ្ឌនៃការលក់ និងជួល កំណត់ថា សហគ្រាសថ្មីត្រូវតែរក្សា ការងារអោយពលករដែលមានស្រាប់។ សហគ្រាសអាចដកកម្មករចេញខ្លះ បើមិនត្រូវជំនាញ តែត្រូវទូទាត់ប្រាក់បៀវត្សប្រចាំឆ្នាំអោយពលករយ៉ាងតិចបំផុតប្រាក់បៀវត្ស បីខែ និងច្រើនបំផុតដប់ខែ។

ជាក់ស្តែងក្នុងចំណោមរូបភាពនៃ ឯកជនភាវូបនីយកម្ម ការជួលរោងចក្រសហគ្រាសរដ្ឋមានចំនួនច្រើនជាងពាក់កណ្តាលនៃគម្រោង វិនិយោគឯកជនសរុប។ ជាធម្មតាអចលនៈទ្រព្យរបស់សហគ្រាសរដ្ឋ ត្រូវបានជួលសម្រាប់អំឡុងពេលពី ១០ ទៅ ២៥ឆ្នាំ ខ្លះទៀតរហូតដល់ ៧០ឆ្នាំ ដោយពិនិត្យស្ថានភាពឡើងវិញប្រាំឆ្នាំម្តង។ នៅក្នុងឆ្នាំ ១៩៩០ ការវិនិយោគទុនបរទេស ជាពិសេសផ្នែកសណ្ឋាគារ ទេសចរណ៍ និងឧស្សាហកម្មកែច្នៃតាមការប៉ាន់ស្មានមានប្រហែល ១០លានដុល្លាអាមេរិក។ រដ្ឋក៏បានលើកទឹកចិត្តចំពោះការវិនិយោគទុនឯកជន លើផ្នែកថាមពល និងរ៉ែផងដែរ។ ការអភិវឌ្ឍវិស័យនេះ ត្រូវបានគ្រប់គ្រងតាមរយៈច្បាប់ស្តីពីការរុករកប្រេងកាត ដែលបានអនុម័តនៅខែកញ្ញា ១៩៩១។

ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ នៅសម័យនោះ បានបន្ថយបន្ទុករដ្ឋក្នុងការបំពេញខាតអោយសហគ្រាស ប៉ុន្តែការធ្វើឯកជន តាមរបៀបមួយដែលពុំទាន់មានផែនការច្បាស់លាស់ ក៏បានជះឥទ្ធិពល ពុំសូវល្អដោយសារការខ្វះខាតលិខិតបទដ្ឋានគតិយុត្តិ និងការត្រួតពិនិត្យត្រឹមត្រូវ។

ចំពោះបញ្ហាប្រឈម ដែលបានកើតមានឡើង ក្នុងការធ្វើកំណែទម្រង់សេដ្ឋកិច្ចកម្ពុជានាឆ្នាំ ១៩៨៩ - ១៩៩៣ យើងឃើញថា ទាក់ទងនឹងស្ថានភាពនយោបាយ និងសេដ្ឋកិច្ច បញ្ហាលំបាកដ៏ធំបំផុតនោះដែលបានចោទឡើងចំពោះអ្នកវិនិយោគឯកជនគឺការធានាអោយបានគ្រប់គ្រាន់ពីរដ្ឋាភិបាលដែលកំពុងប្រឹងប្រែងអនុវត្តយន្តការសេដ្ឋកិច្ចទីផ្សារ។ តាមការស្រាវជ្រាវបង្ហាញថា បញ្ហាប្រឈមសំខាន់ៗមាន ២ យ៉ាងគឺ ៖

ទី១៖ អ្នកវិនិយោគឯកជនមានការប្រុងប្រយ័ត្ន ចំពោះភាពដែលអាចធ្វើអោយក្ស័យធនរបស់គេ។ ហេតុនេះ ការបង្កើតច្បាប់ និងលិខិតបទដ្ឋាន អាចពុំទាន់ធានាបានគ្រប់គ្រាន់តាមនិន្នាការរីកចម្រើននៃសកម្មភាពរបស់ផ្នែកឯកជននៅឡើយទេ។ ប្រការនេះ ទាមទារនូវពេលវេលា ការសិក្សាស្រាវជ្រាវ និងការខិតខំប្រឹងប្រែងជាច្រើនទៀត របស់រដ្ឋាភិបាល ដើម្បីធានាភាពកក់ក្ដៅដល់អ្នកវិនិយោគឯកជន។

ទី ២៖ បញ្ហាសំខាន់មួយផ្សេងទៀតដែលគួរយកមកពិនិត្យ គឺការបង្កលក្ខណៈងាយស្រួលខាងហិរញ្ញវត្ថុ។ ក្នុងនោះមានបញ្ហាសំខាន់ ៣យ៉ាង ក្នុងការអនុវត្តកំណែទម្រង់របស់សហគ្រាសរដ្ឋនាសម័យនោះ។ បញ្ហាសំខាន់ទាំងនោះរួមមាន ការដឹកនាំដែលមានសមត្ថភាព បច្ចេកវិទ្យាគ្រប់គ្រាន់ និងអាជីវកម្មមានចំណេញ។ ដោយសារដើមទុនដ៏ខ្សត់ខ្សោយរបស់ផ្នែកឯកជន និងការប្រុងប្រយ័ត្នរបស់អ្នកវិនិយោគគិន បរទេស រដ្ឋាភិបាលបានបង្កើតភាពងាយស្រួលខាងហិរញ្ញវត្ថុ (តាមការធ្វើកំណែទម្រង់ធនាគារ) ដើម្បីប្រើប្រាស់នូវប្រភពធនធានហិរញ្ញវត្ថុនេះ អោយមានប្រសិទ្ធភាពខ្ពស់ និងបង្កើនស្ថេរភាពសេដ្ឋកិច្ចអោយបានល្អប្រសើរ ដើម្បីជំរុញការលើកទឹកចិត្តអ្នកវិនិយោគឯកជន។

គួរបញ្ជាក់ថា ការធ្វើកំណែទម្រង់សហគ្រាសរដ្ឋនាសម័យនោះជាកិច្ចការមួយដ៏លំបាក ព្រោះស្ថិតនៅក្នុងដំណាក់កាលសេដ្ឋកិច្ចអន្តរកាល ដែលផ្នែកឯកជនមិនទាន់មានការរីកចម្រើន ហើយពុំទាន់សម្បូរ អ្នកដែលមានលទ្ធភាពក្នុងការវិនិយោគ និងភាពជាសហគ្រិនប្រកបដោយសមត្ថភាពព្រមទាំងអ្នកគ្រប់គ្រងដែលមានបទពិសោធន៍។ ចំពោះការលំបាកផ្សេងៗទៀតជុំវិញដំណើរការវិនិយោគរបស់ប្រទេសកម្ពុជា នាដំណាក់កាលនោះ មានដូចខាងក្រោមនេះ ៖

- បញ្ហាប្រព័ន្ធច្បាប់

រាល់សកម្មភាពរបស់សេដ្ឋកិច្ចទីផ្សារ ដាច់ខាតទាមទារអោយមានវត្តមាននៃប្រព័ន្ធច្បាប់គ្រប់គ្រាន់។ បើប្រព័ន្ធច្បាប់មិនទាន់គ្រប់គ្រាន់បានធ្វើអោយអ្នកវិនិយោគឯកជនទាំងក្នុងស្រុក ក៏ដូចជាអ្នកវិនិយោគ បរទេស មានការរារែកក្នុងការសម្រេចចិត្ត។

- បញ្ហាសុវត្ថិភាពផ្នែកសង្គម

នៅបណ្ដាប្រទេសជាច្រើនបញ្ហាសម្ខាន់បំផុតរបស់សហគ្រាស គឺការប្រើប្រាស់បុគ្គលិកលើសពីតម្រូវការ ដើម្បីបង្កើនផលិតភាពរបស់សហគ្រាស ហេតុនេះ នៅពេលដែលរដ្ឋាភិបាលរៀបចំដំណើរការធ្វើ កំណែទម្រង់សហគ្រាសរដ្ឋចាំបាច់ត្រូវរៀបចំអោយបានស្រេចជាមុន ពិសេសទាក់ទងទៅនឹង

សុវត្ថិភាពផ្នែកសង្គម ក្នុងនោះត្រូវដោះស្រាយ បញ្ហានិកម្មភាព(ភាពអត់ការងារធ្វើ) ក៏ដូចជាការបណ្តុះបណ្តាលធនធាន មនុស្ស អោយត្រូវតាមតម្រូវការទីផ្សារ និងប្រាក់បៀវត្សសមរម្យ។

នៅដំណាក់កាលទី២នៃការធ្វើកំណែទម្រង់វិស័យឧស្សាហកម្ម (ក្រោយខែមេសា ឆ្នាំ ១៩៩៥) មានភាពទន់ភ្លន់ជាង គឺសហគ្រាសខ្នាត តូច អាចវាយតម្លៃរួមគ្នាជាមួយក្រសួងសាមី និងមន្ត្រីផ្លូវការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយសហគ្រាសជាច្រើន ក៏ត្រូវបានវាយតម្លៃ ដោយភាគីខាងក្រៅប្រទេសផងដែរ។ ទាំងការលក់ និងជួលសហគ្រាស ត្រូវបានយល់ព្រមដោយគណៈកម្មការឯកជនភាវូបនីយកម្ម។

ជាលទ្ធផលនៃការធ្វើកំណែទម្រង់វិស័យឧស្សាហកម្មយើង ពិនិត្យឃើញថា ២/៣ នៃសហគ្រាសរដ្ឋ ពោលគឺចំនួន ៤២ បានផ្ទេរទៅ អោយផ្នែកឯកជនរួចហើយក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

ចាប់តាំងពីឆ្នាំ ១៩៩៣ មក មានការកើនឡើងយ៉ាងខ្លាំង នៃការ វិនិយោគបរទេសផ្ទាល់នៅកម្ពុជា (Foreign direct investment)។ ហេតុដូចម្តេច បានជាប្រទេសកម្ពុជាអាចទាក់ទាញវិនិយោគបរទេស តាំងពីពេលនោះមក គឺបណ្តាលមកពីមូលហេតុដូចខាងក្រោម ៖

- ថ្លៃដើមពលកម្មថោកប្រហែល ៤០ ដុល្លាអាមេរិកក្នុងមួយខែ និង ៤០ ម៉ោងការងារក្នុងមួយសប្តាហ៍។
- ប្រព័ន្ធអនុគ្រោះពន្ធ (General system of Prefercene) ជាលក្ខន្តិកៈផ្តល់អោយកម្ពុជាពីប្រទេសចំនួន ២៨។
- ទីតាំងកម្ពុជាស្ថិតនៅអនុតំបន់ទន្លេមេគង្គ
- រដ្ឋាភិបាលផ្តល់ភាពងាយស្រួលយ៉ាងទូលាយដល់អ្នកវិនិយោគ
- ការិយាធិបតេយ្យ មានកម្រិតទាបជាងនៅប្រទេសវៀតណាម
- និងអចលនវត្ថុអាចជួលបានដល់ទៅ៧០ឆ្នាំ តែមិនអាចទិញបាននោះទេ។ [199]

គណនេយ្យករនៃក្រុមប្រឹក្សាវិនិយោគ បានយល់ព្រមអោយអ្នកវិនិយោគក្នុងស្រុក និងបរទេសធ្វើការវិនិយោគរាប់រយគម្រោងតាំងពីឆ្នាំ ១៩៩៤ មក។ ភាគច្រើននៃអ្នកវិនិយោគ គឺមកពីប្រទេសក្នុងតំបន់ដូចជា ម៉ាឡេស៊ី សឹង្ហបុរី តៃវ៉ាន់ និងថៃ ហើយអ្នកវិនិយោគមួយចំនួនទៀត មកពីសហរដ្ឋអាមេរិក អង់គ្លេស និងបារាំង។ ផ្នែកដែលមានការវិនិយោគភាគច្រើន គឺវិស័យវាយណភ័ណ្ឌ វិស័យសេវាកម្ម សំណង់អគារ ថាមពល ប្រេងឥន្ទនៈ និងផលិតកម្មព្រៃឈើ។

ហេតុដូច្នេះ ជុំវិញដំណើរការនៃការធ្វើឯកជនភាវូបនីយកម្ម ក្នុងសម័យរដ្ឋកម្ពុជា បានដំណើរការឡើងតែ មួយដំណាក់កាល ប៉ុណ្ណោះ គឺចាប់ពីឆ្នាំ ១៩៩១ ដល់ពាក់កណ្តាលឆ្នាំ ១៩៩៣ ។ ចំពោះដំណាក់កាល ទី២ បានធ្វើបន្តទៀត ចាប់ពីក្រោយខែមេសា ឆ្នាំ ១៩៩៥ នៅពេលដែល មានការសម្របសម្រួលថ្មីមួយត្រូវបានបង្កើតឡើង។

### ១០.២.៣ កំណែទម្រង់វិស័យសេវាកម្ម

ទាក់ទងទៅនឹងការកែទម្រង់ជាចម្បងនៅក្នុងវិស័យសេវាកម្ម នា សម័យកាលនោះ គឺបានផ្តោតជាពិសេសទៅលើវិស័យសេវាកម្មធនាគារ ដែលបានដំណើរការឡើងចាប់តាំងពីឆ្នាំ ១៩៨៩។ កំណែទម្រង់សំខាន់ ក្នុងវិស័យធនាគារ គឺត្រូវបានទទួលច្បាប់អនុញ្ញាតអោយបង្កើតធនាគារ ចម្រុះ និងអនុញ្ញាតអោយមានសាខាធនាគារបរទេសជាច្រើន ប៉ុន្តែ ធនាគារមួយចំនួនតូចប៉ុណ្ណោះដែលអាចដំណើរការបាន។ ភាគច្រើននៃ ធនាគារចម្រុះទាំងនោះ មានប្រភពមកពី ប្រទេសថៃ ម៉ាឡេស៊ី ហុងកុង និងបារាំង។ ថ្វីត្បិតតែ មានការរីកចម្រើនខាងផ្នែកឯកជនក៏ដោយ ប៉ុន្តែសកម្មភាពរបស់ធនាគារកន្លងមក ពុំបានយកចិត្តទុកដាក់ជំរុញអោយ វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ក្នុងប្រទេសអាចដំណើរការផលិតកម្មរបស់ខ្លួនបាននោះទេ។ ជាក់ស្តែង សកម្មភាពទាំងនោះ បានបម្រើតែមួយផ្នែកនៃការងារសេវាកម្មប៉ុណ្ណោះ ពោលគឺការទូទាត់ពាណិជ្ជកម្មក្រៅប្រទេសនិងផ្តល់សេវាកម្មផ្ទេរប្រាក់ដល់ជនបរទេស ជាពិសេស បុគ្គលិកអ៊ុនតាក់។

## ១០.៣. ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

ដោយសារវត្តមាននៃអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ (អ៊ុនតាក់) ការបញ្ចប់សង្គ្រាមស៊ីវិល និងការធ្វើកំណែទម្រង់សេដ្ឋកិច្ច ដែលជាលទ្ធផលនៃការចុះហត្ថលេខាលើកិច្ចព្រមព្រៀង សន្តិភាពទីក្រុងប៉ារីសនាឆ្នាំ ១៩៩១ បានធ្វើអោយស្ថានភាពសេដ្ឋកិច្ច នៃប្រទេសកម្ពុជាមានការអភិវឌ្ឍជាងដំណាក់កាលមុនៗមួយកម្រិត។ បើយើងពិនិត្យមើល ទៅលើផលិតផលក្នុងស្រុកសរុប(GDP) និងការបែងចែកផ្នែកសេដ្ឋកិច្ចយើងសង្កេតឃើញថា ផលិតផលក្នុងស្រុកសរុប គិតតាមតម្លៃស្ថេរភាពឆ្នាំ ១៩៨៩ បានកើនឡើងប្រមាណ ៧,៦% នៅឆ្នាំ ១៩៩១ ហើយកើនឡើង ៧% នៅក្នុងឆ្នាំ ១៩៩២ និងកើនឡើងប្រហែល ៥,៥% នៅក្នុងឆ្នាំ ១៩៩៣។ អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃផលិតផលក្នុងស្រុកសរុប សម្រាប់ដំណាក់កាលឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩៣ មាន ប្រហែល ៦,៧%។ ទោះបីជាក្នុងកាលៈទេសៈដែលប្រទេសកម្ពុជាបាន ស្ថិតនៅក្នុងសភាពលំបាកខាងផ្នែកនយោបាយ និងបាត់បង់ជំនួយពីបរទេសស្ទើរតែទាំងស្រុងក៏ដោយ ក៏ការរីកចម្រើនក្នុងស័យសេដ្ឋកិច្ចក្នុងល្បឿនដូចពោលខាងលើ គឺជាការរីកចម្រើនមួយគួរអោយមោទនៈភាព ហើយល្បឿននេះមានកម្រិតប្រហាក់ប្រហែលគ្នានឹងបណ្តាប្រទេសក្នុងតំបន់។

### ១០.៣.១ ទំហំផលិតកម្មកសិកម្មក្នុង GDP

ក្នុងផ្នែកកសិកម្មវិញយើងសង្កេតឃើញថា ក្នុងចន្លោះឆ្នាំ ១៩៩០ ដល់ ១៩៩៣ ទំហំរបស់វានៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) មាន ការប្រែប្រួលថយចុះពី ៥១,៨ មកនៅត្រឹម ៤៩%។ បើប្រៀបធៀបអត្រា កំណើនគិតជាមធ្យមប្រចាំឆ្នាំផ្នែកកសិកម្ម ក្នុងចន្លោះឆ្នាំ១៩៩០-១៩៩៣ គឺមានការកើនឡើងយឺតជាងផ្នែកឧស្សាហកម្ម និងសេវាកម្មដោយអត្រា កំណើនប្រចាំឆ្នាំ ផ្នែកកសិកម្មមានចំនួនស្មើនឹង៤,៤% ប៉ុណ្ណោះ។ នៅក្នុងផ្នែកសិកម្មក្នុងន័យទូលាយ ផលិតផលស្រូវ គឺជាផ្នែកដែល

សំខាន់ជាងគេ ក៏មានការថយចុះពី ៣៥% នៅឆ្នាំ ១៩៩១ មកនៅត្រឹម ៣៣% នៅឆ្នាំ១៩៩៣ នៃផ្នែកកសិកម្មនៅក្នុងផលិតផលក្នុងស្រុកសរុប។ ការថយចុះ នៃផលិតផលស្រូវ គឺបណ្តាលមកពីកត្តាគ្រោះធម្មជាតិ និងកត្តាអសន្តិសុខក្នុងតំបន់ផលិតកម្ម។

### ១០.៣.២ ទំហំវិស័យឧស្សាហកម្មក្នុង GDP

ចំពោះវិស័យឧស្សាហកម្ម (មានដូចជា សហគ្រាសផលិតទំនិញ ផលិតកម្មទឹកស្អាតថាមពលអគ្គិសនី និងសំណង់) ក៏បានស្រូបយក សមាមាត្រក្នុងផលិតផលក្នុងស្រុកសរុប (GDP) គិតជាមធ្យមប្រចាំឆ្នាំ ក្នុងដំណាក់កាលឆ្នាំ ១៩៩១-១៩៩៣ មានកំណើនប្រមាណ ១៥% ក្នុងមួយឆ្នាំ។ យើងសង្កេតឃើញថា វិស័យសំណង់កើនឡើងពី ៤៤,៦% រហូត ដល់ ៥៣,៣% នៅឆ្នាំ១៩៩៣។ វិស័យសំណង់ដែលមានសន្ទុះកើនឡើងលឿនយ៉ាងដូច្នេះគឺដោយសារការពាក់ព័ន្ធទៅនឹងវត្តមានរបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ(អ៊ុនតាក់) និងភាពល្អប្រសើរ ជុំវិញបរិយាកាសនយោបាយ ក្នុងដំណោះស្រាយស្វែងរកសុខសន្តិភាព ជូនប្រទេសកម្ពុជា។ ប៉ុន្តែផ្នែកសហគ្រាសផលិតទំនិញ មានការថយចុះ ដែលបណ្តាលមកពីរោងចក្រសហគ្រាសរដ្ឋដែលបានដាក់ជួលអោយ អ្នកវិនិយោគឯកជនរួចមកហើយនោះ នៅពុំទាន់បានដំណើរការពេញ លេញ ឬពុំទាន់បានចាប់ផ្តើមដំណើរការនៅឡើយ។

### ១០.៣.៣ ទំហំវិស័យសេវាកម្មក្នុង GDP

ទាក់ទងទៅនឹងសមាមាត្ររបស់ផ្នែកសេវាកម្ម នៅក្នុងផលិតផលក្នុងស្រុកសរុប (GDP) គឺមានការកើនឡើងគួរអោយកត់សម្គាល់។ តាមការស្រាវជ្រាវបញ្ជាក់ថា ទំហំចំណែកវិស័យសេវាកម្មនៅក្នុង GDP នាសម័យនោះ បានកើនឡើងប្រមាណ ៣៣% ក្នុងឆ្នាំ ១៩៩១ ហើយកើនឡើង ៣៣,៤% ក្នុងឆ្នាំ ១៩៩២ និងកើនឡើង ៣៥% ក្នុងឆ្នាំ ១៩៩៣។ ផ្នែកពាណិជ្ជកម្ម គឺជាផ្នែកដែលមានសមាមាត្រធំជាងគេ នៅក្នុងវិស័យសេវាកម្ម បានកើនឡើងដល់ ៣៩,៦% នៅឆ្នាំ១៩៩៣ ក្នុងភាគបំណែករបស់វា។ ចំពោះសេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋាន ទោះបីជាមាន សមាមាត្រតូចនៅក្នុងភាគបំណែករបស់វាក៏ដោយ ប៉ុន្តែផ្នែកនេះ មានកំណើនខ្ពស់គួរអោយចាប់អារម្មណ៍ គឺកើន ៣៥,៧% នៅក្នុងឆ្នាំ ១៩៩១ និងកើនឡើង ៣០% នៅក្នុងឆ្នាំ ១៩៩២ និងកើនឡើង ៣១% នៅក្នុងឆ្នាំ ១៩៩៣។ ផ្នែកសេវាកម្ម បើគិតជាអត្រាកំនើនជាមធ្យម ក្នុងចន្លោះឆ្នាំ ១៩៩០-១៩៩៣ មានប្រមាណជា១០%។ គួរបញ្ជាក់ថា ចាប់តាំងពីការធ្វើកំណែទម្រង់សេដ្ឋកិច្ច(ឆ្នាំ១៩៨៩) ផ្នែកសេវាកម្ម គឺមានសន្ទុះរីកចម្រើន យ៉ាងលឿន ជាពិសេសផ្នែកសេវាកម្មសណ្ឋាគារទេសចរណ៍ និងផ្នែកភោជនីយដ្ឋាន។ [201]

ចំពោះទំហំផលិតផលក្នុងស្រុកសរុប (GDP) និងការបែងចែង តាមផ្នែកនិមួយៗ អត្រាកំណើន ព្រមទាំងចំណែករបស់វិស័យនិមួយៗ ក្នុងផលិតផលក្នុងស្រុកសរុប យើងបានបកស្រាយដូចមានក្នុងតារាងខាងក្រោមនេះ ៖

| វិស័យ, ឆ្នាំ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ |
|---|---|---|---|---|
| GDP | ២៤៣,៧ | ២៦២,២ | ២៨០,៦ | ២៦៩ |
| កសិកម្ម | ១២៧,៤ | ១៣៥,៩ | ១៣៨,៥ | ១៤៤,៨ |
| ឧស្សាហកម្ម | ៣៦,៣ | ៣៩,៥ | ៤៥,៧ | ៥២,៤ |
| សេវាកម្ម | ៨០ | ៨៦,៧ | ៩៦,៣ | ៩៨,៨ |

*ផលិតផលក្នុងស្រុកសរុបតាមវិស័យសេដ្ឋកិច្ច*
*ចន្លោះឆ្នាំ១៩៩០ - ១៩៩៣ (គិតជា ពាន់លានរៀល)*

- គិតតម្លៃឆ្នាំគោល ឆ្នាំ ១៩៨៩

| វិស័យ, ឆ្នាំ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ |
|---|---|---|---|---|
| GDP | ១,២ | ៧,៦ | ៧ | ៥,៥ |
| កសិកម្ម | ១,៦ | ៧,១ | ១,៩ | ៤,៥ |
| ឧស្សាហកម្ម | -២ | ៨,៩ | ១៥,៦ | ១៤,៧ |
| សេវាកម្ម | ២,៦ | ៨,៣ | ១១,២ | ២,៦ |

*អត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP) គិតជា (%)*

| វិស័យ, ឆ្នាំ | ១៩៩០ | ១៩៩១ | ១៩៩២ | ១៩៩៣ |
|---|---|---|---|---|
| GDP | ១០០ | ១០០ | ១០០ | ១០០ |
| កសិកម្ម | ៥២,២ | ៥១,៨ | ៤៩,៤ | ៤៨,៩ |
| ឧស្សាហកម្ម | ១៥ | ១៥,១ | ១៦,៣ | ១៧,៧ |
| សេវាកម្ម | ៣២,៨ | ៣៣,១ | ៣៤,៤ | ៣៣,៣ |

*ទំហំចំណែកនៃវិស័យនិមួយៗ ក្នុង GDP (គិតជា %)*

## ១០.៤. ស្ថានភាពសេដ្ឋកិច្ច-សង្គម

### ១០.៤.១ វិស័យកសិកម្ម

#### ការផលិតស្បៀងអាហារ

បើយើងក្រឡេកមើលទៅលើ វិស័យផលិតកម្មស្បៀងអាហារ នាសម័យកាលនោះ យើងឃើញថា បានជួប្រទះនូវការលំបាកដោយសារវិស័យកសិកម្មនៅប្រទេសកម្ពុជា គឺនៅតែរណបស្ទើរតែទាំងស្រុង ទៅនឹងធម្មជាតិ។ ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលនោះ ប្រជាកសិករបានពេញចិត្តពេញថ្លើមយ៉ាងខ្លាំង ក្នុងការប្រកបការងាររបស់ខ្លួន ព្រោះដោយពួកគេអាចទទួលសិទ្ធិកាន់កាប់ដីធ្លី ព្រមទាំងបានទទួលការអនុញ្ញាតជាផ្លូវការ ក្នុងការធ្វើចរាចរកសិផលដោយសេរីក្នុងប្រទេស។ ប្រជាកសិករមានសិទ្ធិគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងមធ្យោបាយផលិតកម្ម និងទំនាក់ទំនងទីផ្សារតាមសមត្ថភាពដែលអាចដំណើរការទៅបាន។ ទន្ទឹមនឹងនេះ តាមរយៈនយោបាយពន្ធដារ រដ្ឋាភិបាលបានបើកទូលាយអោយក្រុមហ៊ុនឯកជន ធ្វើការនាំចូលនូវឧបករណ៍សម្ភារៈកសិកម្ម និងលើកទឹកចិត្តសម្រួលដល់ការវិនិយោគ ពីសំណាក់ក្រុមហ៊ុនឯកជនក្នុងស្រុក ក៏ដូចជាក្រុមហ៊ុនបរទេសដែលមានលទ្ធភាព ហើយមានគោលបំណងជំរុញការអភិវឌ្ឍដំណាំកសិកម្ម ការចិញ្ចឹមសត្វ ជាលក្ខណៈឧស្សាហកម្ម ដើម្បីធានាអោយបាននូវតម្រូវការក្នុងស្រុក និងការនាំចេញ។ លទ្ធផលជាក់ស្តែង គឺនៅឆ្នាំ១៩៩១ ផ្ទៃដីដាំដុះសរុប សម្រេចបាន ២.០៩៦.២៤០ ហិកតា ឆ្នាំ ១៩៩២ ផ្ទៃដីដាំដុះសរុបសម្រេច បាន ២.០២៨.៨៧០ ហិកតា និងឆ្នាំ ១៩៩៣ ផ្ទៃដីដាំដុះសម្រេចបាន ២.១៤២.៤០០ ហិកតា។ ចំពោះស្ថានភាពស្បៀងអាហារក៏មានការកើនឡើងជាលំដាប់ ហើយដូចមានបញ្ជាក់នៅខាងក្រោមនេះ។

- ដំណាំស្រូវ

ពេលគឺដំណាំស្រូវទូទាំងឆ្នាំ ១៩៩១ សម្រេចបាន ១.៩១០.០០០ ហិកតា និងទទួលបានលទ្ធផល ២.៤០០.០០០តោន ហើយនៅឆ្នាំ ១៩៩៣ ដំណាំស្រូវសម្រេចបាន ២.២៦០.០០០ ហិកតា និងទទួលបាន លទ្ធផល ៣.៣០០.០០០ តោន (ក្នុងនោះទាំងផលិតកម្មស្រូវប្រាំង និង ស្រូវវស្សា)។

- ដំណាំរួមផ្សំ

ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មនាដំណាក់កាលនោះ កំពុង តែមានទំនោរឈានទៅរកការអភិវឌ្ឍ ទាំងការពង្រីកផ្ទៃដីដាំដុះទាំង បរិមាណទិន្នផល ដោយបានរក្សាតួនាទីយ៉ាងសម្ខាន់ ក្នុងការផ្គត់ផ្គង់វត្ថុ ធាតុដើមសម្រាប់បម្រើវិស័យឧស្សាហកម្ម សិប្បកម្មក្នុងស្រុក និងការនាំ ចេញ។

- ការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វពាហនៈក្នុងមជ្ឈដ្ឋានប្រជាកសិករ ក៏កំពុងតែមាន សន្ទុះរីកចម្រើនប្រហាក់ប្រហែលគ្នានឹងសម័យសង្គមរាស្ត្រនិយម។ ប៉ុន្តែ ការចិញ្ចឹមសត្វនៅតាមកសិដ្ឋានរដ្ឋ និងគោល

នយោបាយលើការផ្សព្វ ផ្សាយពូជសត្វពាហនៈនៅមានកម្រិតទាប ព្រោះដោយខ្វះបណ្តាញចែក ចាយ និងផលិតកម្មពូជសត្វ។ [202]

### វិស័យរុក្ខកម្ម

ចំពោះការធ្វើអាជីវកម្មព្រៃឈើ ដោយឈរលើយន្តការសេដ្ឋកិច្ច ទីផ្សារសេរី ពោលគឺឈរលើគោលការណ៍ធ្វើអាជីវកម្មតាមរូបភាពដេញថ្លៃព្រៃគុប និងតាមវិធានការណ៍តឹងរឹង រដ្ឋាភិបាលបានបើកទូលាយ ជុំវិញការធ្វើវិនិយោគទុនបរទេសលើវិស័យព្រៃឈើ។ នៅឆ្នាំ ១៩៩១ ឈើមូលសម្រេចបាន ២៨០.០០០ម៣ នៅឆ្នាំ១៩៩២ សម្រេចបាន ១១៩.៨០៨ម៣ និងឆ្នាំ ១៩៩៣ សម្រេចបាន ៣២.៨៨៣ ម៣។ ការដាំកូន ឈើនៅឆ្នាំ ១៩៩១ ដាំបាន ២១០ ហិកតា ឆ្នាំ ១៩៩២ ដាំបាន ៧៤៤ ហិកតា ប៉ុន្តែក្នុងឆ្នាំ ១៩៩៣ រដ្ឋាភិបាលពុំបានផ្តល់ទុនដល់ការដាំកូនឈើទេ។ យើងអាចពិនិត្យមើលទៅលើទិន្នផលអាជីវកម្មព្រៃឈើ ដែលបានផលិតនៅឆ្នាំ ១៩៨៩ រហូតដល់ឆ្នាំ ១៩៩៣ ដូចខាងក្រោមនេះ ៖

| បរិយាយ | ឈើមូល | ឈើកែច្នៃ | ការនាំចូលឈើមូល | ការនាំចេញឈើកែច្នៃ |
|---|---|---|---|---|
| **១៩៨៩** | ២២៤.៨៣០ | ១៦.៣៧០ | ៧៨.៧២០ | ៩៣០ |
| **១៩៩០** | ២៥៧.៣៥០ | ១៥.៧១០ | ៩៣.៧៥០ | ៥.៥២០ |
| **១៩៩១** | ២៨០.០០០ | - | ១៣១.៧៩០ | ៥.៣៣០ |
| **១៩៩២** | ១១៩.៨០៨ | - | - | - |
| **១៩៩៣** | ៣២.៨៨៣ | - | - | - |

*តារាងផលិតកម្មព្រៃឈើ ឆ្នាំ ១៩៨៩ - ១៩៩៣ ( គិតជាម៣ )*

*ប្រភព ៖ នាយកដ្ឋានរុក្ខប្រមាញ់ និងនេសាទ*

ទន្ទឹមនឹងនេះ រដ្ឋបានបង្កើតរុក្ខទិវា ដើម្បីជំរុញការដាំកូនឈើ អោយក្លាយទៅជាប្រពៃណីមួយរបស់ជាតិ និងរួមចំណែកក្នុងការ ការពារបរិស្ថានធម្មជាតិ។ រដ្ឋបានផ្ទេរការធ្វើអាជីវកម្មព្រៃឈើទៅអោយផ្នែកឯកជន ហើយធ្វើការគ្រប់គ្រងបច្ចេកទេសព្រៃឈើ ការយកពន្ធ អាជីវកម្ម និងផលរបរវិញ។ ក្នុងលក្ខណៈបែបនេះ យើងសង្កេតឃើញថាកើតមានភាពអនាធិបតេយ្យក្នុងការធ្វើអាជីវកម្មព្រៃឈើជាពិសេសនៅ តាមបណ្តាខេត្តជាប់ព្រំដែន។

### វិស័យជលផល

ការប្រកបអាជីវកម្មឡូត៍នេសាទ នៅសម័យកាលនោះ បានជះ ឥទ្ធិពលយ៉ាងស្មុគស្មាញដល់ការគ្រប់គ្រងក្នុងវិស័យនេះ ដោយសារតែ សភាពការណ៍ប្រទេសជាតិកំពុងមានការវិវត្តន៍ទាំងផ្នែកនយោបាយ និងផ្នែកសេដ្ឋកិច្ច។

នៅឆ្នាំ ១៩៨៩ បរិមាណត្រីស្រស់ទទួលបាន ៨២.០៨៨ តោន ក្នុងនោះត្រីទឹកសាបទទួលបាន ៥០.៥០០ តោន ត្រីសមុទ្រ ២៦.០៥០ តោន និងត្រីចិញ្ចឹម ៥.៥៣៨ តោន។ នៅឆ្នាំ ១៩៩០

បរិមាណត្រីស្រស់ ទទួលបាន ១១១.៤០០ តោន ក្នុងនោះត្រីទឹកសាបទទួលបាន ៦៥.១០០ តោន ត្រីសមុទ្រ ៣៩.៩០០ តោន និងត្រីចិញ្ចឹម ៦.៤០០ តោន។ នៅឆ្នាំ ១៩៩១ បរិមាណត្រីស្រស់ទទួលបាន ១១៧.៨០០ តោន ក្នុងនោះត្រីទឹក សាបទទួលបាន ៧៤.០០០ តោន ត្រីសមុទ្រ ៣៦.៤០០ តោន និងត្រី ចិញ្ចឹម ៦.៤០០តោន។ ឆ្នាំ ១៩៩២ បរិមាណត្រីស្រស់សម្រេចបាន ១១១.១៥០តោន ក្នុងនោះត្រីទឹកសាបទទួលបាន ៦៨.៩០០ តោន ត្រីសមុទ្រ ៣៣.៧០០ តោន និងត្រីចិញ្ចឹម ៨.៥៥០ តោន។ ឆ្នាំ ១៩៩៣ បរិមាណត្រីស្រស់សម្រេចបាន ៩១.២២៧ តោន ក្នុងនោះត្រីទឹកសាប ទទួលបាន ៦៧.០០០ តោន ត្រីសមុទ្រ ១៧.៧៧៥ តោន និងត្រីចិញ្ចឹម ៥.៥៥ ២ តោន។

ចំពោះស្ថានភាពដែលគួរអោយមោទនៈបែបនេះ រដ្ឋាភិបាលបានខិតខំប្រឹងប្រែងចាត់វិធានការណ៍ការពារព្រៃលិចទឹក ដែលជាជម្រកត្រីពង និងបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ នូវលក្ខណៈបច្ចេកទេសនៃការនេសាទ។ ទោះបីជាមានការប្រព្រឹត្តបទល្មើសក្នុងវិស័យជលផលយ៉ាងណាក៏ដោយ ប៉ុន្តែសម័យនោះ រដ្ឋបានការពារឡូត៍នេសាទបម្រុងរបស់រដ្ឋបានល្អ ហើយបានធ្វើការស្រាវជ្រាវ ជៀសវាងផលប៉ះពាល់ដល់ប្រភពធនធានជលផល ហើយការវិនិយោគទុន និងការកែច្នៃផលិតផលត្រី ត្រូវបានបើកទូលាយ។

**ដំណាំកៅស៊ូ**

សម័យរដ្ឋកម្ពុជា ដំណើរការអាជីវកម្ម ផលិតកម្មកៅស៊ូ បានជួបប្រទះនូវភាពស្មុគស្មាញដែលគួរអោយព្រួយបារម្ភ ព្រោះដើមកៅស៊ូកាន់ តែចាស់ទ្រុឌទ្រោម បញ្ហាសណ្តាប់ធ្នាប់នៅក្នុង និងជុំវិញតំបន់ចំការកៅស៊ូ និងបញ្ហាជម្ងឺរាតត្បាត ជាពិសេសជម្ងឺគ្រុនចាញ់ ដែលចោទឡើងជាបញ្ហាធ្ងន់ធ្ងរសម្រាប់សម័យកាលនោះ។ សកម្មភាពលួចជៀរជ័រកៅស៊ូ លួចកាប់ដើមកៅស៊ូ និងចរាចរផលិតផលជ័រកៅស៊ូខុសច្បាប់តាមគ្រប់រូបភាព បានកើតមានឡើងយ៉ាងខ្លាំងក្លា។ របៀបទូទាត់ថ្លៃកៅស៊ូ រវាងស្ថាប័នពាក់ព័ន្ធ បានបណ្តាលអោយអង្គភាពចំការកៅស៊ូរដ្ឋធ្លាក់ចុះ ក្នុងសភាពលំបាកលំបិនផ្នែកហិរញ្ញវត្ថុ។

បើយើងសិក្សាទៅលើបរិមាណផលិតកម្មជ័រកៅស៊ូគិតជាជ័រស្ងួត សម្រេចបាននាឆ្នាំ ១៩៩១ ចំនួន ៣៥.០០០ តោន ឆ្នាំ ១៩៩២ សម្រេចបាន ៣០.០០០ តោន និងឆ្នាំ ១៩៩៣ សម្រេចបាន ៣២.០០០ តោន ។ មូលដ្ឋានសម្ភារៈបច្ចេកទេសផ្នែកផលិតកម្មកែច្នៃ និងត្រួតពិនិត្យគុណភាពកៅស៊ូពុំទាន់មានលទ្ធភាពរៀបចំបានល្អ ជាហេតុនាំអោយការលក់ជ័រកៅស៊ូ និងការនាំចេញកៅស៊ូក្រែប ពុំទាន់អនុវត្តបានសមស្របទៅតាមបទដ្ឋានស្តង់ដារអន្តរជាតិនៅឡើយ ជាហេតុនាំអោយតម្លៃជ័រកៅស៊ូស្ងួត មានតម្លៃទាបជាងតម្លៃទីផ្សារពិភពលោកប្រមាណពី ១០% ទៅ ២០%។

នៅសម័យនោះ យើងសង្កេតឃើញថា ចំពោះការថែទាំដើម កៅស៊ូដែលបានដាំហើយ ក៏ដូចជាការដាំដើមកៅស៊ូថ្មីបន្ថែម គឺជាការលំបាកដែលបណ្តាលមកពីកង្វះខាតដើមទុន។ ពីព្រោះថា សម្រាប់ដំណាំកៅស៊ូ នាសម័យកាលនោះ ពុំទាន់បានទទួលនូវការវិនិយោគទុន ពីផ្នែកឯកជនក្នុងស្រុក និងក្រុមហ៊ុនបរទេសនៅឡើយនោះទេ ដោយសារតែការវិនិយោគទុនលើវិស័យកៅស៊ូនេះ តម្រូវអោយប្រើប្រាស់រយៈពេលវែង ទើបប្រមូលចំណូលបានមកវិញ និងដោយសារប្រទេសយើង ពុំមានលទ្ធភាពរៀបចំមូលដ្ឋានច្បាប់អោយបានគ្រប់គ្រាន់។

### វិស័យឧស្សាហកម្ម និងសិប្បកម្ម

នៅចន្លោះឆ្នាំ ១៩៨៩-១៩៩៣ វិស័យឧស្សាហកម្មប្រទេសកម្ពុជា បានដំណើរការក្នុងស្ថានភាពទន់ខ្សោយ។ រដ្ឋាភិបាលបានចាប់ផ្ដើមធ្វើការកែលម្អលើការគ្រប់គ្រងវិស័យឧស្សាហកម្មជាបន្តបន្ទាប់ ដោយអនុលោមទៅតាមសភាពការណ៍ជាក់ស្ដែងរបស់ប្រទេសជាតិ និងស្របតាមនិន្នាការរួមក្នុងពិភពលោក និងតាមក្រឹត្យក្រមអភិវឌ្ឍន៍សង្គម។ ការកែទម្រង់ការគ្រប់គ្រងសេដ្ឋកិច្ចក្នុងអង្គភាពផលិតកម្ម បានប្រព្រឹត្តទៅជាច្រើនដំណាក់កាលដែលមានខ្លឹមសារដូចខាងក្រោមនេះ ៖

- ក្រោយពីប្ដូររូបភាពគ្រប់គ្រងតាមបែបសេដ្ឋកិច្ចផែនការ ទៅជារូបភាពម្ចាស់ការហិរញ្ញវត្ថុ និងស្វ័យភិបាលសេដ្ឋកិច្ច នៅដំហានដំបូង ហាក់ដូចជាដំណើរការមានសន្ទុះល្អ ពីព្រោះលក្ខណៈធម្មជាតិស្របទៅនឹងចំណង់ចំណូលចិត្តរបស់សហគ្រាសមួយចំនួន។ ប៉ុន្តែមិនយូរប៉ុន្មានស្ថានភាពនេះ ក៏ឈានទៅរកភាពទ័លច្រក ដែលបណ្ដាលមកពីខ្វះលិខិតបទដ្ឋានលម្អិត សម្រាប់ណែនាំការអនុវត្ត។ ម្យ៉ាងទៀត សហគ្រាសគ្មានដើមទុន និងសិទ្ធិគ្រប់គ្រាន់ក្នុងការងារគ្រប់គ្រងអាជីវកម្ម ក៏ដូចជាដំណើរការផលិតកម្ម។ ក្នុងដំណាក់កាលនោះ សហគ្រាសមួយចំនួនតម្រូវអោយមានស្វ័យគ្រប់គ្រង ព្រមទាំងបុគ្គលិក កម្មករ អាចផ្អាកការងារជាបណ្ដោះអាសន្នមួយរយៈ ដោយគ្មានប្រាក់បៀវត្ស ដើម្បីរង់ចាំលទ្ធភាពដំណើរការវិញ។ ម៉្យាងទៀត ភាពចាស់ទ្រុឌទ្រោមនៃគ្រឿងចក្រ កង្វះខាតគ្រឿងបន្លាស់ កង្វះខាតវត្ថុធាតុដើម ធ្វើអោយផលិតកម្មនៃវិស័យនេះ អាចដោះស្រាយកង្វះខាតថាមពល បានធ្វើអោយផលិតកម្មនៃវិស័យនេះ អាចដោះស្រាយបានតែមួយផ្នែកប៉ុណ្ណោះលើទីផ្សារ។
- ដើម្បីផ្លាស់ប្ដូរបច្ចេកទេសថ្មី និងបង្កើនប្រសិទ្ធភាពក្នុងផលិតកម្ម រដ្ឋាភិបាលចាប់ផ្ដើមផ្ទេរជាបណ្ដើរៗ នូវការផលិតរបស់ខ្លួនទៅជាការអនុវត្តតាមគោលការណ៍ឯកជនភាវូបនីយកម្ម។ រដ្ឋបានពិនិត្យលទ្ធភាព ដោយរក្សាទុកតែផ្នែកដែលបម្រើសេវាកម្មចាំបាច់សម្រាប់ផលិតកម្មឧស្សាហកម្មប៉ុណ្ណោះ។
- ចំពោះការងារភូគព្ភសាស្ត្រ និងការស្រាវជ្រាវរ៉ែ ក៏ចាប់ផ្ដើមមានសកម្មភាពរីកចម្រើន។ ក្រោយពីមានការអនុញ្ញាតពីរដ្ឋាភិបាល ក្រសួង ឧស្សាហកម្ម ក៏បានធ្វើការរៀបចំចងក្រងឯកសារបែងចែកឡូត៍ប្រេងកាត និងធ្វើការផ្សព្វផ្សាយលក់ឯកសារឡូត៍ប្រេងកាត ដល់ក្រុមហ៊ុនចំនួន៥៦។ ក្នុងនោះ ទឹកប្រាក់ដែលទទួលបានពីការលក់ឯកសារមានចំនួន ៤៦០.០០០ ដុល្លាអាមេរិក។
- ទន្ទឹមនឹងនេះដែរ ការបង្កើតសហគ្រាសឧស្សាហកម្មតូចៗ និងសិប្បកម្មឯកជន ត្រូវបានរដ្ឋទទួលស្គាល់ និងយកចិត្តទុកដាក់ជំរុញយ៉ាងខ្លាំងក្លា។ ការទទួលស្គាល់ និងលើកទឹកចិត្តបែបនេះ បានធ្វើអោយឧស្សាហកម្មធុនតូច និងសិប្បកម្មឯកជន មានការរីកចម្រើនគួរអោយ កត់សម្គាល់។

សរុបមក ក្នុងចន្លោះឆ្នាំ ១៩៨៩-១៩៩៣ យើងសង្កេតឃើញថាផលិតកម្មឧស្សាហកម្មរដ្ឋមានការថយចុះ និងជួបប្រទះនូវការលំបាកច្រើនបើប្រៀបធៀបទៅនឹងដំណាក់កាលមុនៗ។ ការប្រកួត

ប្រជែង រវាងមុខទំនិញនាំចូលបានធ្វើអោយទំនិញដែលផលិតដោយឧស្សាហកម្មក្នុងស្រុក មានការកក ស្ទះ។ រីឯ សហគ្រាសដែលបានដួលតាមរូបភាពឯកជនភាវូបនីយកម្ម បានដំណើរការផលិតទំនិញតែ មួយចំនួនតូចប៉ុណ្ណោះ ហើយពុំទាន់បានរួមចំណែកល្អ ដល់ការផ្គត់ផ្គង់ក្នុងស្រុក ក៏ដូចជាការនាំចេញ។ សហគ្រាសមួយចំនួនទៀត ដែលបានដួលក្នុងគោលបំណងពង្រីកឧស្សាហកម្មក្នុងស្រុក ផ្ទុយទៅវិញ មិនត្រឹមតែមិនបានធ្វើអោយផលិតកម្មគ្មានការរីកចម្រើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានបិទទ្វារ ឬ ផ្អាកសកម្មភាពផលិតកម្ម និងធ្វើការនាំចូលទំនិញទាំងស្រុងតែម្តង។ ប៉ុន្តែចំពោះសហគ្រាសផលិតកម្ម តូចៗ និងសិប្បកម្ម ហាក់ដូចជា មានការចាប់ផ្តើម និងមាននិន្នាការជាវិជ្ជមាន។

## ១០.៤.២ វិស័យសេវាកម្មឯកជន និងសាធារណៈ

### ពាណិជ្ជកម្ម

ក្នុងស្រុក នៅសម័យរដ្ឋកម្ពុជា (១៩៨៩-១៩៩៣) យើងសង្កេតឃើញថា ចរាចរពាណិជ្ជកម្ម ក្នុងស្រុក បានដំណើរការឡើងតាមរូបភាពសេដ្ឋកិច្ចទីផ្សារ ដោយផ្នែកឯកជនកំពុងរួមចំណែកយ៉ាង សកម្មក្នុងការបំពេញកង្វះខាតទំនិញនៅលើទីផ្សារ។ ចំពោះសកម្មភាពពាណិជ្ជកម្មក្នុងស្រុកជាបណ្តើរៗ កំពុងធ្វើការប្រកួតប្រជែងគ្នាលើទីផ្សារ ហើយសហគ្រាសរដ្ឋដែលធ្លាប់បានផលិតទំនិញគ្រប់យ៉ាង បាន បាត់បង់តួនាទីរបស់ខ្លួន ហើយត្រូវបានផ្ទេរទៅអោយឯកជន ក្នុងការផលិតទំនិញឧស្សាហកម្ម។ រហូត មកដល់ចុងឆ្នាំ១៩៩៣ ការផលិតទំនិញឧស្សាហកម្ម ក៏ដូចជាចរាចរទំនិញទូទៅ បានធ្លាក់មកលើផ្នែក ឯកជនជាអ្នកបំពេញ។

### ពាណិជ្ជកម្មអន្តរជាតិ

ចាប់តាំងពីឆ្នាំ ១៩៨៩ ឱនភាពជញ្ជីងពាណិជ្ជកម្មក្រៅប្រទេស មានការកើនឡើងយ៉ាងខ្លាំងក្លា ដែលបណ្តាលមកពីការបាត់បង់ស្ទើរតែ ទាំងស្រុងនៃប្រភពទំនិញ ដែលនាំចូលមកពីអតីតសហភាព សូវៀត និងអតីតប្រទេសសង្គមនិយមអឺរ៉ុបខាងកើត ហើយក្នុងពេលជាមួយគ្នានោះ ប្រភពទំនិញដែល នាំចូលពីប្រទេសសេរីផ្សេងៗទៀតទើបតែចាប់ផ្តើមនាំចូលបន្តិចបន្តួច។ ទន្ទឹមនឹងនេះ យើងកត់ សម្គាល់ឃើញថា មុខទំនិញដែលធ្លាប់នាំចេញនៅក្នុងទសវត្សទី ៨០ ពុំទាន់មានការផ្លាស់ប្តូរទាំង បរិមាណ ក៏ដូចជាចំនួនមុខទំនិញថ្មីដែរ គឺច្រើនប្រមូលផ្តុំតែទៅលើទំនិញ ៤-៥ មុខប៉ុណ្ណោះ ពិសេស ទៅទៀត ទំនិញនាំចេញសម័យកាល នោះសុទ្ធសឹងជាទំនិញដែលពុំទាន់បានកែច្នៃដូចជាផលផល ឈើមូល ជ័រកៅស៊ូស្ងួត សណ្តែងសៀង ពោតក្រហម។ បញ្ហានេះបានឆ្លុះបញ្ចាំងអោយឃើញថា កម្រិត នៃការលូតលាស់នៃផ្នែកឧស្សាហកម្ម ពោលគឺ ឧស្សាកម្មកែច្នៃនៅកម្ពុជានាសម័យនោះ មានកម្រិត ទាបបំផុត។ ជាងនេះទៀត មុខទំនិញចាំបាច់សំខាន់ៗ សម្រាប់បម្រើជីវភាពប្រចាំថ្ងៃ រួម ទាំងមុខ ទំនិញប្រណិត និងទំនិញយុទ្ធសាស្ត្រសម្រាប់ជីវភាព និងមុខទំនិញផ្សេងៗទៀត ក្នុងនោះមានប្រេង ឥន្ធនៈ និងវត្ថុធាតុដើម សម្រាប់ ឧស្សាហកម្ម គឺត្រូវបានធ្វើការនាំចូលទាំងស្រុង។ ចំពោះស្ថានភាព ជញ្ជីងពាណិជ្ជកម្មក្រៅប្រទេសនាសម័យកាលនោះ គឺមានបង្ហាញក្នុងតារាងខាងក្រោម ៖

| បរិយាយ | ការនាំចេញ | ការនាំចូល | តុល្យភាព |
|---|---|---|---|
| ១៩៨៩ | ៤៤,២០ | ១៣៥,០០ | -៩០,៨០ |
| ១៩៩០ | ៣៤,៧០ | ១១៥,៣០ | -៨០,៣០ |
| ១៩៩១ | ៦៧,៣០ | ២០៩,១០ | -១៤១,៨០ |
| ១៩៩២ | ៧០,០០ | ៣៦០,០០ | -២៩០,០០ |
| ១៩៩៣ | ២១,០០ | ២២២,១០ | -២១០,១០ |

*តុល្យភាពពាណិជ្ជកម្មក្រៅប្រទេស (គិតជា លានដុល្លាអាមេរិក)*

❖ ជាទិន្នន័យអនុវត្តមកត្រឹម ខែសីហា ឆ្នាំ ១៩៩៣
❖ ប្រភពព័ត៌មាន ៖ ក្រសួងព័ត៌មាន

តារាងខាងលើបានបង្ហាញថា ក្នុងឆ្នាំ ១៩៨៩-១៩៩៣ វិស័យពាណិជ្ជកម្មអន្តរជាតិប្រទេសកម្ពុជា បានជួបប្រទះនូវឱនភាពជាប្រចាំ។ ពីមួយឆ្នាំទៅមួយឆ្នាំ តម្លៃនៃការនាំចូលទំនិញ មានការកើនឡើងជាលំដាប់ក្នុងកម្រិតខ្ពស់ ក៏ប៉ុន្តែផ្ទុយទៅវិញ ការនាំចេញនូវផលិតផលកសិកម្មពីប្រទេសកម្ពុជាហាក់ដូចជាមិនជានាបាននូវកំណើនដែលគួរអោយសង្ឃឹមទុកនោះឡើយ ព្រោះបណ្តាលមកពីមូលហេតុផ្សេងៗ។

**វិស័យសាធារណៈការ ប្រៃសណីយ៍ និងទូរគមនាគមន៍**

ក. វិស័យសាធារណៈការ

ដឹកជញ្ជូននៅសម័យនោះ រដ្ឋបានធ្វើការគ្រប់គ្រងផ្ទាល់លើមធ្យោបាយ ដឹកជញ្ជូនគ្រប់ប្រភេទ។ យុទ្ធនាការជួសជុល និងស្តារប្រព័ន្ធបណ្តាញផ្លូវ គមនាគមន៍ និងស្ពាន តាមបណ្តោយផ្លូវជាតិ ក៏ដូចជាផ្លូវខេត្ត-ក្រុង ជាពិសេសនៅរាជធានីភ្នំពេញ បានដំណើរការយ៉ាងផុលផុស។ ទន្ទឹមនឹងនេះ នៅតាម

បណ្តាកំពង់ផែសំខាន់ៗ (ភ្នំពេញ ក្រុងព្រះសីហនុ) ត្រូវបានបំពាក់គ្រឿងចក្រ និងឧបករណ៍ ស្ទូចទំនិញយ៉ាងទំនើប។ សកម្មភាព ការងារនៅតាមកំពង់ចម្លងត្រូវបានកែលម្អ និងយកចិត្តទុកដាក់គួរអោយកត់សម្គាល់ពីសំណាក់រដ្ឋាភិបាល។

នៅក្នុងឆ្នាំ ១៩៩១ វិស័យសេវាកម្មដឹកជញ្ជូនទំនិញរបស់ក្រសួងគមនាគមន៍ បានបម្រើសេវាដឹកជញ្ជូនទំនិញ សម្រេចបាន ២៦៨.៥០០ តោន និងដឹកជញ្ជូនអ្នកដំណើរ សម្រេចបានប្រមាណ ១.០០០.០០០០ នាក់។ បរិមាណទំនិញឆ្លងកាត់កំពង់ផែរាជធានីភ្នំពេញ គឺសម្រេចបាន ១៦៦.៨៦០ តោន និងទំនិញដែលឆ្លងកាត់ក្រុងព្រះសីហនុ សម្រេចបានប្រមាណ ២១៧.០០០ តោន។ ឆ្នាំ ១៩៩២ ការដឹកជញ្ជូនទំនិញ សម្រេចបាន ១៦០.៦៤០តោន និងការដឹកជញ្ជូនអ្នកដំណើរ គឺសម្រេចបាន

ប្រមាណ ១.២៩០.០០០ នាក់ រីឯបរិមាណទំនិញឆ្លងកាត់កំពង់ផែភ្នំពេញ សម្រេចបាន ៣១០.០០០ តោន និងកំពង់ផែក្រុងព្រះសីហនុ សម្រេចបាន ២១៧.០០០ តោន។ ឆ្នាំ ១៩៩៣ ការដឹកជញ្ជូនទំនិញ តាមការប៉ាន់ស្មានសម្រេចបាន ១១៨.១៤០ តោន ដឹកជញ្ជូនអ្នកដំណើរសម្រេចបាន ១.២

៤២.០០០នាក់ បរិមាណទំនិញឆ្លងកាត់កំពង់ផែរាជធានីភ្នំពេញ តាមការប៉ាន់ស្មានសម្រេចបាន ១៧០.០០០តោន និងកំពង់ផែក្រុងព្រះសីហនុ សម្រេចបាន ៣១០.០០០ តោន។

ចំពោះបញ្ហាប្រឈមជុំវិញវិស័យសាធារណៈការ និងដឹកជញ្ជូននាសម័យនោះ គឺបានជួបប្រទះនូវការលំបាកដូចខាងក្រោមនេះ ៖

- ទោះបីជាមានការជួសជុលជាប្រចាំទៅលើផ្លូវថ្នល់ និងស្ពានយ៉ាងណាក៏ដោយ ប៉ុន្តែអំណាចនៃទឹកភ្លៀងរដូវវស្សា បានធ្វើអោយដក់ទឹកនៅលើដងផ្លូវ ជាហេតុនាំអោយបាក់ច្រោះ និងក្លាយទៅជាប្លុកសំបុកមាន់ដោយអន្លើ។
- ដោយសារតែការដឹកទំនិញដោយរថយន្តធំក្នុងបរិមាណហួសចំណុះ បានធ្វើអោយផ្លូវជាតិ និងស្ពានមួយចំនួនត្រូវបានខូចខាតឥតឈប់ឈរ។
- វត្ថុធាតុដើម និងសម្ភារៈសំណង់ស្ពានថ្នល់នាសម័យកាលនោះ ពុំទាន់ធានាបាននូវគុណភាពក្នុងការជួសជុលស្ពាន ថ្នល់ ស្របតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវនៅឡើយទេ។

ខ. ប្រៃសណីយ៍ និងទូរគមនាគមន៍

ក្រោយពីបានបើកទូលាយអោយមានការវិនិយោគទុនលើវិស័យសេវាកម្មនេះ យើងឃើញថាសេវាកម្មប្រៃសណីយ៍ ក៏ដូចជាសេវាកម្ម ទូរគមនាគមន៍ មានការរីកចម្រើនយ៉ាងឆាប់រហ័ស ជាពិសេសវិស័យទូរគមនាគមន៍ក្នុង និងក្រៅប្រទេស។ នៅដំណាក់កាលនោះ ចំនួនអ្នកជាវទូរស័ព្ទសរុបមាន ៧.៣១១ នាក់ ក្នុងនោះចំនួន ៥.២៩០ នាក់នៅទីក្រុងភ្នំពេញ និង ១,២៩០ នាក់ នៅតាមបណ្ដាខេត្ត-ក្រុង។ មានន័យថា ក្នុងចំណោមប្រជាជន ១០,០០០ នាក់ គឺមានប្រជាជន ៨នាក់ ហើយ ដែលមានទូរស័ព្ទប្រើប្រាស់។ សម្រាប់ទំនាក់ទំនងក្រៅប្រទេសយើង មានហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍សំខាន់ៗដូចជា ៖

- ស្ថានីយ៍ផ្កាយរណប Intersputnick ដែលមាន ៦ Channals
- ស្ថានីយ៍ផ្កាយរណប Intersat Visa ដែលមាន ៨ Channals (អាចមានលទ្ធភាពពង្រីកដល់ ៦០ Channals) ដែលអាចទាក់ទងផ្ទាល់ ទៅក្រៅប្រទេសបាន និងមានលទ្ធភាពទទួលអ្នកជាវ បានរហូតដល់ ១.៣០០ នាក់
- ស្ថានីយ៍ផ្កាយរណប Standard A ដែលអាចពង្រីក Channals បានរហូតដល់ ១២០ ព្រមទាំងពង្រីកបន្ថែមនូវខ្សែទូរស័ព្ទបានរហូតដល់ ៥.០០០ ខ្សែ
- និងស្ថានីយ៍វិទ្យុលេកផ្សាយសម្លេងខ្ពស់ FM ។

ទន្ទឹមនឹងនេះ នៅពេលដែលអ៊ុនតាក់បានបំពេញបេសកកម្មនៅកម្ពុជា ក៏បានស្ថាបនាប្រព័ន្ធទូរគមនាគមន៍របស់ខ្លួន គឺនៅឆ្នាំ ១៩៩២។ ប្រព័ន្ធនេះ បានដាក់ពង្រាយទូទាំងប្រទេសកម្ពុជាសម្រាប់អ្នកប្រើប្រាស់ប្រមាណ ៣.៧៦០ នាក់។ លុះក្រោយមក ក៏បានប្រគល់ជូនរដ្ឋាភិបាល កម្ពុជាដែលមានចំនួនរហូតដល់ ១៩ ស្ថានីយ៍។

ក្រៅពីនេះទៀត សេវាកម្មផ្នែកប្រៃសណីយ៍ក៏បានពង្រឹង និងពង្រីកទាំងក្នុងនិងក្រៅប្រទេស។ នៅតាមបណ្ដាទីរួមខេត្ត-ក្រុងទាំង ២១ គឺមានបម្រើសេវាកម្មផ្នែកប្រៃសណីយ៍ទាំងអស់។ ផ្នែក

ប្រៃសណីយ៍នៅ តាមបណ្ដាស្រុកចំនួន ១៥១ និងឃុំមួយចំនួនដែរ ក៏មានបម្រើសេវាកម្មប្រៃសណីយ៍បានត្រឹមត្រូវ ។ គឺនៅខ្វះតែ ១៥ ស្រុកទៀត និង ១.៤០០ឃុំ ដែលពុំទាន់មានលទ្ធភាពបម្រើសេវាកម្មប្រៃសណីយ៍។ ចំពោះវិស័យសេវាកម្ម និងប្រៃសណីយ៍ក្រៅប្រទេស ជាមួយនឹងទ្វីបអឺរ៉ុប អាមេរិក និងបណ្ដាប្រទេសអាហ្វ្រិក គឺបានប្រព្រឹត្តទៅ តាមរយៈមធ្យោបាយផ្លូវអាកាសតែប៉ុណ្ណោះ។

បើគិតអំពីប្រាក់ចំណូលដែលរដ្ឋបានទទួលពីការធ្វើអាជីវកម្ម សេវាកម្មក្នុងវិស័យខាងលើនេះ ដោយគិតពីថ្ងៃទី ០១ មករា ដល់ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៩៣ គឺទទួលបានប្រមាណ ២០.០៩១.៩០៣ ដុល្លាអាមេរិក និង ១.៧ ៥៤.៥២០.០០០ រៀល។ [204]

## ១០.៥. ការងារវិនិយោគ

តាមឯកសារស្រាវជ្រាវ នៅសម័យនោះ ការវិនិយោគសរុបស្រប យកសមាមាត្រប្រមាណ ១០% នៃផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ ១៩៩២។ ក្នុងការសិក្សារបស់យើង យើងបែងចែកការងារវិនិយោគ ជាពីរសណ្ឋានគឺ វិនិយោគសាធារណៈ និងឯកជន។

### ១០.៥.១ វិនិយោគសាធារណៈ

កម្រិតនៃការ វិនិយោគរបស់ផ្នែកសាធារណៈនាសម័យកាលនោះមានការថយចុះខ្លាំង បន្ទាប់ពីមានការបាត់បង់ជំនួយលើគម្រោងអភិវឌ្ឍន៍នានា និងការគាំទ្រដល់ថវិកាជាតិពីអតីតសហភាពសូវៀត។ ទន្ទឹមនឹងនេះការវិនិយោគរបស់ផ្នែកសាធារណៈមានការរាំងស្ទះដែល បណ្ដាលមកពីចំណោទបញ្ហាលើផ្នែកថវិការដ្ឋ ដែលជួបប្រទះនូវការលំបាក និងការហូរចូលដ៏ស្ដួចស្ដើងនៃជំនួយពីបណ្ដាបច្ចឹមប្រទេស។ ផ្ទុយទៅវិញ នៅពេលដែលការសន្សំរបស់ផ្នែកឯកជន មានការកើនឡើងយ៉ាងឆាប់រហ័ស ការសន្សំរបស់ផ្នែកសាធារណៈមានការថយចុះ ចាប់ពី ឆ្នាំ ១៩៨៨-១៩៩៣។ ក្នុងរយៈពេលដូចគ្នានេះ
ការវិនិយោគផ្នែកឯកជន បានស្រូបយកសមាមាត្រប្រមាណ ៩០% ជាពិសេសការវិនិយោគលើការងារសំណង់ស៊ីវិល។

### ១០.៥.២ វិនិយោគឯកជន

ចាប់តាំងពីមានច្បាប់វិនិយោគបរទេសត្រូវបានអនុម័ត និងដាក់ អោយប្រើប្រាស់នាឆ្នាំ ១៩៨៩ មក សកម្មភាពវិនិយោគទុនរបស់ផ្នែក ឯកជនទាំងក្នុង និងក្រៅប្រទេស ក៏មានសន្ទុះរីកចម្រើន គួរអោយកត់ សម្គាល់។ យើងសង្កេតឃើញថា ក្រុមហ៊ុនទាំងអស់ដែលគណៈកម្មា ធិការជាតិវិនិយោគបានឯកភាពជាគោលការណ៍ មានចំនួន ៤៨៧ ក្រុមហ៊ុន ដែលគិតជាគម្រោងមានចំនួន ៦៦៨គម្រោង។ ក្រុមហ៊ុនដែលបានចុះកិច្ចសន្យា ឬធ្វើលក្ខន្តិកៈតម្កល់ទុកនៅលេខាធិការដ្ឋានគណៈកម្មាធិការជាតិវិនិយោគ មានដើមទុនសរុបប្រហែលជិត៤០០ លានដុល្លារ។ ក្រុមហ៊ុនភាគច្រើន ជាក្រុមហ៊ុនដែលបានបណ្ដាក់ទុនក្នុងការ ជួលរោងចក្រ សណ្ឋាគារ និងអគារចាស់ៗ។ គួរបញ្ជាក់ថា ក្រុមហ៊ុន ដែលបានធ្វើ

អាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា មានចំនួនប្រហែល ១៣០ ក្រុមហ៊ុនប៉ុណ្ណោះ ដែលបានបណ្តាក់ទុនវិនិយោគក្នុងវិស័យ ឧស្សាហកម្ម ធនាគារ កសិកម្ម ទេសចរណ៍ (សណ្ឋាគារ)។ ក្រុមហ៊ុន ទាំងនោះភាគច្រើនជាក្រុមហ៊ុនឯកជននៅក្រុងស្រុក និងមកពីប្រទេសក្រៅដូចជា ថៃ ហុងកុង សិង្ហបុរី ម៉ាឡេស៊ី

អាមេរិក។

204 ឈុន ពហុ, ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា (មេរៀនសង្ខេប), ភ្នំពេញ, ឆ្នាំ ២០០៤, ទំព័រ ១៧-១៨

ចាត់តាំងពីឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩៣ ការងារវិនិយោគរបស់ផ្នែកឯកជននៅប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់។ ដោយឡែកនៅក្នុងឆ្នាំ ១៩៩២ ប៉ុណ្ណោះ គណៈកម្មាធិការជាតិវិនិយោគបានចុះ បញ្ជីដែលមានចំនួនសរុប ១៤៥ ក្រុមហ៊ុនស្មើនឹង ៣១០គម្រោង។ ប៉ុន្តែដោយស្ថានភាពនយោបាយនៅក្នុងប្រទេសនា ដើមឆ្នាំ១៩៩៣ គឺនៅពុំទាន់មានស្ថេរភាពពេញលេញនៅឡើយ ដូច្នេះចំនួនអ្នកវិនិយោគទុន នៅកម្ពុជាមានការថយចុះជាក់ស្តែងគិតមកត្រឹមត្រីមាសទី៣ ឆ្នាំ ១៩៩៣ គណៈកម្មាធិការជាតិវិនិយោគ បានធ្វើការចុះបញ្ជីក្រុមហ៊ុន ដែលមានចំនួនប្រមាណតែ ៦២ ប៉ុណ្ណោះលើ ៧០ គម្រោង។

## ១០.៦. វិស័យសិក្សាអប់រំ

នៅសម័យរដ្ឋកម្ពុជា យោងតាមទិន្នន័យមួយចំនួនបានបង្ហាញថា វិស័យសិក្សាអប់រំ នាដំណាក់កាលនោះដំណើរការឡើងមិនទាន់បានល្អប្រសើរនៅឡើយទេ។ គ្រូបង្រៀននៅថ្នាក់បឋមសិក្សាប្រហែលជា ១០% មានកម្រិតមិនហួសពីកម្រិតបឋមសិក្សា និង ២៥% មានកម្រិត វិជ្ជាមិនពេញថ្នាក់អនុវិទ្យាល័យ ហើយមានតែ ៦០% ប៉ុណ្ណោះ ដែលមាន កម្រិតវិជ្ជាថ្នាក់អនុវិទ្យាល័យ។ ដោយឡែកអត្រាកុមារក្នុងវ័យមតេយ្យ សិក្សាបានចូលរៀនប្រមាណតែ ៨% ប៉ុណ្ណោះ។ អត្រាកុមារដល់វ័យសិក្សាបានចូលរៀនថ្នាក់បឋមសិក្សាមានប្រមាណ ៨២% ក្នុងនោះនៅរាជធានីភ្នំពេញ និងនៅទីប្រជុំជនមានចំនួន ៩០% និងនៅតំបន់ដាច់ស្រយាល និងតំបន់ភូមិភាគជនជាតិភាគតិចគឺមានចំនួនប្រមាណពី ៥០% ទៅ ៦០%។ ចំពោះបញ្ហាការបោះបង់ការសិក្សា និងការសិក្សាត្រួតថ្នាក់របស់កុមារ នៅកម្រិតបឋមសិក្សាមានប្រមាណ ៣០% ឯណោះ។ មានកុមារមួយចំនួន បានប្រើរយៈពេលរហូតដល់ ១០ឆ្នាំដើម្បីបញ្ចប់ការសិក្សា កម្រិតបឋមសិក្សា។ ម្យ៉ាងទៀត ការបោះបង់ការសិក្សា និងការរៀនត្រួតថ្នាក់ភាគច្រើន គឺជាកុមារដែលស្ថិតនៅតំបន់ដាច់ស្រយាល និងតំបន់ព្រៃភ្នំ។ ចំណេះដឹងរបស់កុមារខាងផ្នែកគណិតវិទ្យា និងអក្សរសាស្ត្រខ្មែរនៅមានកម្រិតទាប។ សិស្សានុសិស្សនៅថ្នាក់បឋមសិក្សា មិនទាន់ បានរៀនសូត្រអោយគ្រប់ពីរពេល (ព្រឹក និងល្ងាច) នៅឡើយទេ។

រហូតមកដល់ឆ្នាំ ១៩៩២ នៅប្រទេសកម្ពុជា គិតជាមធ្យមអត្រា ប្រលងជាប់វិញ្ញាប័នបត្របឋមសិក្សាមានចំនួន ៧០% និងអត្រាប្រលងជាប់អនុវិទ្យាល័យមានចំនួន ៧១% និងអត្រាប្រលងជាប់ថ្នាក់ទុតិយភូមិ មានចំនួន ៧៧%។ ដូច្នេះយើងឃើញថា ការប្រលងជាប់របស់សិស្សានុសិស្សនាសម័យនោះ មានអត្រាខ្ពស់ជាងសម័យមុនសង្គ្រាម ក៏ដូចជាសម័យបច្ចុប្បន្ននេះដែរ។ នៅសម័យកាល

នោះ សិស្សភាគច្រើនពុំសូវយកចិត្តទុកដាក់ក្នុងការសិក្សា និងមានភាពអសកម្មច្រើនក្នុងការសិក្សា ក៏ដូចជាក្នុងពេលប្រលង ដែលជះឥទ្ធិពលជាអវិជ្ជមានដល់សតិអារម្មណ៍ របស់សិស្សដែលយកចិត្តទុកដាក់ក្នុងការសិក្សា និងសិស្សពូកែ ដែលស្ថិតនៅក្នុងគ្រួសារក្រីក្រ។

ការបណ្តុះបណ្តាលធនធានមនុស្ស នៅតាមគ្រឹះស្ថានសិក្សាថ្នាក់ឧត្តមសិក្សា និងថ្នាក់វិទ្យាល័យ បានជួបប្រទះនូវការលំបាកស្មុគស្មាញច្រើន ដែលបណ្តាលមកពីខ្វះខាតចំនួនសាស្ត្រាចារ្យ និងគ្រូបង្រៀន ដែលមានសមត្ថភាព និងចេះភាសាបរទេស ព្រមទាំងខ្វះខាតសៀវភៅ សិក្សា និងសម្ភារៈបរិក្ខាសម្រាប់មន្ទីពិសោធន៍។ល។ ជាមួយគ្នានេះដែរការបណ្តុះបណ្តាលធនធានមនុស្សនៅតាមបណ្តាអតីតប្រទេសសង្គមនិយម ក៏បានជួបប្រទះនូវការលំបាកគ្រប់បែបយ៉ាងដែលទាក់ទងទៅនឹង បម្រែបម្រួលនៃសភាពការណ៍នយោបាយពិភពលោក ហើយទោះបី ជារាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងដោះស្រាយយ៉ាងណាក៏ដោយ ក៏សិស្សនិស្សិតមួយចំនួនធំ បានវិលត្រលប់មកប្រទេសកម្ពុជាវិញ មុនបញ្ចប់ការសិក្សារបស់ខ្លួន។ ចំពោះសិស្ស និស្សិតដែលបានបញ្ចប់ការសិក្សានៅបរទេសនាសម័យនោះ គិតជាសរុបមានប្រមាណ ៣.៩២១ នាក់ ក្នុងនោះក្រោយឧត្តមសិក្សាមានប្រមាណ ៨៤ នាក់ ថ្នាក់ឧត្តម សិក្សាមាន ១.០៤១ នាក់ និងមធ្យមសិក្សាបច្ចេកទេសមាន ១.០៦៣ នាក់ និងថ្នាក់កម្មករជំនាញមានចំនួន ១.៧៣៣ នាក់។

ចំពោះស្ថានភាពអក្ខរកម្មនៅក្នុងប្រទេសកម្ពុជា នាសម័យនោះ បើពិនិត្យជារួមឃើញថា មានការលំបាកស្មុគស្មាញច្រើនដូចជា អន្តរជន គឺនៅមានច្រើន ក្នុងនោះភាគច្រើនជានារីភេទ ហើយចំនួននេះចេះតែកើនឡើងជាលំដាប់រៀងរាល់ឆ្នាំ តាមរយៈអ្នកភ្លេចអក្សរ តាមរយៈកុមារ ដល់វ័យសិក្សា ហើយមិនបានចូលរៀន ឬបោះបង់ចោលការសិក្សា ដែលបណ្តាលមកពីការខ្វះខាតផ្នែកជីវភាព។

រីឯចំនួនសិស្សថ្នាក់បឋមសិក្សានាឆ្នាំសិក្សា១៩៩២-១៩៩៣គឺមានចំនួន ១.៤៦៨.៩៥៨ នាក់ ចំនួនសិស្សថ្នាក់អនុវិទ្យាល័យមានចំនួនប្រមាណ១៣១.១៣៦នាក់ និងចំនួនសិស្សថ្នាក់វិទ្យាល័យមានចំនួន ១០៨.២២៧ នាក់។ ទាក់ទងទៅនឹងចំនួនសាលារៀនបើធៀបទៅនឹងឆ្នាំសិក្សា ១៩៩១-១៩៩២ យើងឃើញថា ចំនួនអនុវិទ្យាល័យបានថយចុះ ប៉ុន្តែចំនួនវិទ្យាល័យបានកើនឡើងដោយសារតែអនុវិទ្យាល័យ មួយចំនួន បានប្រែក្លាយទៅជាវិទ្យាល័យ។

## ១០.៧. វិស័យសុខាភិបាលសាធារណៈ

នៅសម័យរដ្ឋកម្ពុជា បញ្ហាជម្ងឺរាតត្បាត ដែលគួរអោយព្រួយ បារម្ភជាងគេនោះ គឺជម្ងឺគ្រុនចាញ់ ជម្ងឺរាគរូស ជម្ងឺគ្រុនឈាម ជម្ងឺ អាសន្នរោគ ជម្ងឺផ្លូវដង្ហើម និងជម្ងឺខ្វះជីវជាតិចំណីអាហារ ដែលជម្ងឺទាំងអស់នោះ បង្កអោយមានគ្រោះថ្នាក់យ៉ាងខ្លាំងក្លាដល់សង្គមជាតិ។ ទន្ទឹមនឹងនេះ ជម្ងឺកាមរោគក៏កំពុងមានសកម្មភាពកើនឡើងដែរ ជាពិសេសការចាប់ផ្តើមចម្លងនៃវីរុសអេដស៍ដែលជាជម្ងឺមួយដ៏សាហាវបំផុតហើយនៅក្នុងស្រទាប់មហាជន នាដំណាក់កាលនោះ នៅពុំទាន់យល់ដឹងអំពីផលវិបាកនៃឥទ្ធិពលរបស់ជម្ងឺប្រភេទនេះនៅឡើយ។

ចំពោះការងារទាក់ទងទៅនឹង ការការពារជម្ងឺគ្រប់ប្រភេទ នៅដំណាក់កាលនោះ គឺត្រូវបានរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងនោះបញ្ហាអនាម័យនៅតាមមូលដ្ឋាន ក៏ដូចជាទីសាធារណៈ ដោយធ្វើការជម្រុញកែលម្អ និងធ្វើការណែនាំដល់ប្រជាពលរដ្ឋ ក្នុងទិសដៅថែរក្សាសុខភាព សង្គម។ ការបើកទូលាយជុំវិញការពិនិត្យជម្ងឺគ្រប់ប្រភេទ ការព្យាបាលជម្ងឺ និងមន្ទីរសម្ភពឯកជនក៏មានការរីកដុះដាល ដែលបានកាត់បន្ថយបន្ទុកដល់រដ្ឋាភិបាល និងបង្កលក្ខណៈងាយស្រួលក្នុងការបម្រើសេវាព្យាបាលជម្ងឺ។

អត្រាស្លាប់របស់កុមារនាសម័យនោះ គឺមានកម្រិតខ្ពស់ ក្នុងនោះ ទារកស្លាប់ក្នុងពេលសម្រាលកូនមានចំនួនរហូតដល់ ៩.០០០ នាក់ និងអត្រាស្លាប់របស់កុមារដែលមានអាយុក្រោមឆ្នាំ មានចំនួនរហូតដល់ ១៨០ភាគពាន់។ ចំពោះការផលិតឱសថនៅក្នុងប្រទេស ក៏មិនទាន់ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានដែរ ជាងនេះទៀតការគ្រប់គ្រងចរាចរឱសថស្ថាននៅតាមទីផ្សារ ទោះបីជាមានការណែនាំជា បន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏នៅតែមិនអាចសម្រេចបានតាមសំណូមពរ បច្ចេកទេស
សុខាភិបាលនៅឡើយ។ ហើយមានតែប្រជាជនប្រមាណ ៤០% ដែលរស់នៅទីក្រុង និង ១៥% ដែលរស់នៅតាមជនបទប៉ុណ្ណោះ ដែលមានទឹកស្អាតប្រើប្រាស់។

## ១០.៨. ការងារសង្គមកិច្ច

លទ្ធផលនៃការអនុវត្តនិន្នាការនយោបាយបរទេសពីរផ្សេងៗគ្នា នាពេលកន្លងមក ធ្វើអោយប្រទេសកម្ពុជា ជួបប្រទះនូវភ្នក់ភ្លើងសង្គ្រាម អស់ជិត ៣ ទសវត្ស។ ការអូសបន្លាយនៃសង្គ្រាម បានធ្វើអោយប្រជាជន ប្រមាណ ៣០.០០០ នាក់ ក្លាយទៅជាជនពិការ និងរបួស ហើយកុមារ ប្រហែល ២០០.០០០ នាក់ បានក្លាយជាកុមារកំព្រាគ្មានទីពឹង និងពិការ ក្នុងចំនួននេះ មានកុមារប្រមាណ ៦០.០០០ នាក់ ដែលកំព្រាឪពុក និង ម្តាយ កុមារ ៧០.០០០ កំព្រាឪពុក ឬកំព្រាម្តាយ និងកុមារ ៧០.០០០ នាក់ទៀតបានរស់នៅជាមួយឪពុកម្តាយ ប៉ុន្តែជាកុមារពិការ និងស្ថិតក្នុង ស្ថានភាពក្រីក្របំផុត។ នាសម័យកាលនោះ មានកុមារតែ ២.៥០០ នាក់ ដែលមានភ័ព្វវាសនារស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រា ហើយមានការគាំទ្រពីរដ្ឋ។

បរិមាណស្ត្រីភេទបានស្រូបយកសមាមាត្រ ៦០% នៃប្រជាជន ពេញវ័យ ក្នុងនោះភាគច្រើនជាស្ត្រីមេម៉ាយ ហើយ ២៥% ជាមេគ្រួសារ ដែលទទួលចំណូលប្រចាំឆ្នាំប្រមាណតែ ១០០ ដុល្លាប៉ុណ្ណោះ។ នៅសម័យនោះ មានអង្គការជាតិ និងអន្តរជាតិបានធ្វើសកម្មភាព ក្នុងនោះ អង្គការក្រៅរដ្ឋាភិបាលមានចំនួន ១៧ បានយកចិត្តទុកដាក់ជួយឧបត្ថម្ភដល់ស្ត្រី និង កុមារ។ ប៉ុន្តែការគ្រប់គ្រងស្ត្រីដែលមានមុខរបររកស៊ីផ្លូវភេទ យើងសង្កេតឃើញថា ពុំទាន់មានក្របខណ្ឌច្បាស់លាស់ដើម្បីការពារសុខភាព និងសុវត្ថិភាពជូនសង្គមជាតិឡើយ។

ចំពោះការដោះស្រាយគោលនយោបាយជូនបុគ្គលិកចូលនិវត្តន៍ ក៏បានអនុវត្ត ក្នុងនោះមានមន្ត្រីចូលនិវត្តន៍ប្រមាណ ៧.៤៣៨ នាក់ បុគ្គលិកបាត់បង់សមត្ថភាពពលកម្ម មានចំនួន ៤.១៤៨នាក់

គោលនយោបាយឧបត្ថម្ភចំពោះគ្រួសារយុទ្ធជនពលីជីវិតក្នុងសមរភូមិបាន ៣២.១៦១ គ្រួសារ និងជនពិការប្រមាណ ១៦.៣៦៩ នាក់។

## ១០.៩. វិស័យពត៌មាន និងវប្បធម៌

បន្ទាប់ពីមានការបោះឆ្នោតជាសាកលក្នុងខែឧសភា ឆ្នាំ ១៩៩៣ ដែលបានរៀបចំឡើងដោយអង្គការសហប្រជាជាតិ យើងសង្កេតឃើញថា ការងារពត៌មាន និងវប្បធម៌បានរួមចំណែកយ៉ាងសកម្មក្នុងការបម្រើសេចក្តីត្រូវការរបស់សង្គមជាតិបម្រើផ្នែកសតិអារម្មណ៍ ព្រមទាំងផ្តល់នូវការយល់ដឹងជុំវិញ ព្រឹត្តការណ៍សំខាន់ៗ ក្នុងនិងក្រៅប្រទេសក្នុងទិសដៅលើកកំពស់ជីវភាពរស់នៅខាងផ្នែកស្មារតីប្រជាពលរដ្ឋ។ ក្រៅពីនេះ សារពត៌មានផ្នែកឯកជន ក៏មានការរីកចម្រើន គួរអោយកត់សម្គាល់ក្នុង ការផ្សព្វផ្សាយព្រឹត្តិការណ៍សំខាន់ៗ ដើម្បីលើកកំពស់បន្ថែមនូវកម្រិតយល់ដឹងដល់ប្រជារាស្ត្រ។ ចំពោះការការពារថែរក្សាបេតិកភណ្ឌជាតិ វិស័យនេះ ក៏ត្រូវបានរដ្ឋាភិបាលយកចិត្តទុកដាក់ដែលបង្កលក្ខណៈអោយមានការចូលរួមចំណែកពីសំណាក់អង្គការយូនីស្កូផងដែរ។

## ១០.១០. ការគ្រប់គ្រងបរិស្ថាន

ផលវិបាកនៃសង្គ្រាមជាងពីរទសវត្សកន្លងមកនេះ បានធ្វើអោយ ស្ថានភាពបរិស្ថាននៅប្រទេសកម្ពុជា មានលក្ខណៈខូចខាតយ៉ាងខ្លាំង។ សម្បត្តិធម្មជាតិដ៏មានតម្លៃដែលជាដង្ហើមនៃសេដ្ឋកិច្ចជាតិ ដែលត្រូវបានចំរាញ់យកផលដោយខ្វះវិធីសាស្ត្រ និងខ្វះក្បួនខ្នាតបច្ចេកទេស បានឈានទៅរកការវិនាសអន្តរាយដូចជា ព្រៃឈើ ជលផល និងត្បូងមាន តម្លៃជាដើម។ ការបំពុលបរិយាកាសនៅក្នុងទឹក ព្រមទាំងបញ្ហាសំរាមស្អុយរលួយ កាកសំណល់ កង្វះអនាម័យ បានចោទមានឡើងនៅទូទាំងប្រទេសកម្ពុជា (ជាពិសេសនៅរាជធានីភ្នំពេញ) ដែលជាបន្ទុកដ៏ធ្ងន់ធ្ងរមួយសម្រាប់រាជរដ្ឋាភិបាលនាសម័យនោះ ហើយបានធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំង ដល់ដំណើរការកសាងសេដ្ឋកិច្ច-សង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ។

## ១០.១១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ ស្តីអំពី ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជាយើង នៅសម័យរដ្ឋកម្ពុជា ក្នុងឆ្នាំ ១៩៨៩-១៩៩៣ រួចមក យើងសង្កេតឃើញថា នៅក្នុងចន្លោះឆ្នាំខាងលើនេះ ប្រទេសកម្ពុជាបានបើកសករាជថ្មី ដែលជាដំណាក់កាលមួយឈានទៅរកការផ្លាស់ប្តូរនូវប្រព័ន្ធដែលជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចជាតិទាំងមូល (គឺការផ្លាស់ប្តូរពីរបបសេដ្ឋកិច្ចផែនការប្រមូលផ្តុំ ឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារសេរី) ហើយលើគ្រប់វិស័យសេដ្ឋកិច្ចសំខាន់ៗ មានការវិវត្តន៍ទៅមុខគួរអោយមោទនៈ ជាពិសេសបន្ទាប់ពីមានការបោះឆ្នោតនៅ ខែឧសភា ឆ្នាំ ១៩៩៣ ដែលបង្ហាញអំពីស្ថេរភាពខាងផ្នែក

នយោបាយ ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយបង្រួបបង្រួមជាតិ និងអនុវត្តន៍តាមព្រះរាជតម្រិះ របស់ព្រះមហាក្សត្រខ្មែរ ព្រះករុណា ព្រះបាទ សម្តេច នរោត្តម សីហនុ។

ក្នុងចន្លោះឆ្នាំ ១៩៨៩-១៩៩៣ កន្លមកនេះ ឌឿនសេដ្ឋកិច្ចជាតិ និងសង្គមទាំងមូលត្រូវបានរស់ឡើងវិញប្រកបដោយចរិករីកចម្រើនគួរអោយកត់សម្គាល់។ ចំពោះការធ្វើកំណែទម្រង់សេដ្ឋកិច្ចលើផ្នែក កសិកម្ម ឧស្សាហកម្ម និងសេវាកម្ម គឺជាយន្តការដ៏សំខាន់ដែលជំរុញអោយមូលដ្ឋានសេដ្ឋកិច្ច-សង្គម មានការអភិវឌ្ឍលើគ្រប់វិស័យ។

វិស័យកសិកម្មត្រូវបានស្តារឡើងវិញ និងមានការរីកចម្រើនឥតឈប់ឈរ តាមរយៈកំណែទម្រង់ដីធ្លីដែលរដ្ឋសភាជាតិ បានអនុម័តនាដើមឆ្នាំ ១៩៨៩ ព្រមទាំងបានអនុញ្ញាតអោយមានចរាចរផលិតផល កសិកម្មដោយសេរីទូទាំងប្រទេស ដោយប្រជាកសិករខ្មែរមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តក្នុងការផលិតទំនិញកសិកម្ម និងកំណត់តម្លៃនៃផលិតផលរបស់ខ្លួនស្របទៅតាមតម្លៃទីផ្សារ និងគ្មានការធ្វើអន្តរាគមន៍ ពីសំណាក់រាជរដ្ឋាភិបាលឡើយ។ ការទទួលស្គាល់កម្មសិទ្ធិដីធ្លីឯកជន បានធ្វើអោយប្រជាកសិករមានជំនឿទុកចិត្ត និងខិតខំព្យាយាមកែលម្អ ដីកម្មសិទ្ធិរបស់ខ្លួន ព្រមទាំងជម្រុញការផលិតទំនិញកសិកម្មឥតឈប់ឈរដែលទង្វើនេះ បានជះឥទ្ធិពលជាវិជ្ជមានដល់ផ្នែកសេដ្ឋកិច្ចសង្គម។

ទាក់ទងនឹងវិស័យឧស្សាហកម្មផលិតកម្ម ក៏ត្រូវបានចាប់ផ្តើមរៀបរយ និងមានស្ថេរភាពជាបណ្តើរៗ។ ប៉ុន្តែជារួមវិស័យនេះ នៅមានភាពទន់ខ្សោយនៅឡើយ ដោយសារតែរឿងរ៉ាវជួចត់ពីអតីតកាល ដែលបានបំផ្លាញស្ទើរខ្ទេចខ្ទី នូវហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច មានបណ្តាញផ្លូវគមនាគមន៍ ផ្លូវដែក ស្ពាន ថ្នល់ កំពង់ផែ ព្រលានយន្តហោះ រោងចក្រសហគ្រាសត្រូវបានស្ថិតក្នុងសភាពអន់ថយទ្រុឌទ្រោម ដោយសារតែសង្គ្រាម និងគ្មានអ្នកថែរក្សា។ រីឯបញ្ញវន្ត វិស្វករ អ្នកជំនាញ ក៏ត្រូវបានស្លាប់បាត់បង់ជីវិតស្ទើរគ្មានសល់ ហើយការស្តារឡើងវិញនូវធនធានមនុស្សរហូតដល់សម័យរដ្ឋកម្ពុជា ក៏ពុំអាចបំពេញសេចក្តីត្រូវការរបស់សង្គមជាតិបានឡើយ។ ម្យ៉ាងវិញទៀតការធ្វើកំណែទម្រង់ឧស្សាហកម្មផលិតកម្មសហគ្រាសរដ្ឋតាមរូបភាពស្វ័យភិបាលសេដ្ឋកិច្ចក្នុងផលិតកម្ម និងឯកជនភាវូបនីយកម្មសហគ្រាសរដ្ឋ នៅសម័យកាលនោះ ក៏ពុំទាន់បានផ្តល់លទ្ធផលជាផ្លែផ្កានៅឡើយទេ មូលហេតុបណ្តាលមកពីការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចជាតិ ការខ្វះខាតប្រាក់ដើមទុន ខ្វះខាតមូលដ្ឋានច្បាប់វិនិយោគ និងបម្រែបម្រួលស្ថានការណ៍នយោបាយពិភពលោក ទាំងអស់នេះបានជះឥទ្ធិពលជាអវិជ្ជមានដល់វិស័យឧស្សាហកម្មនៅកម្ពុជា។

ម៉្យាងវិញទៀត ចំពោះវិស័យសេវាកម្មនាសម័យនោះ គឺមានលក្ខណៈទន់ខ្សោយនៅឡើយ។ ចំពោះដំណើរការរបបសេដ្ឋកិច្ចទីផ្សារ សេរីដែលខ្វះខាតបទពិសោធន៍របស់ប្រជាជន ការកំណត់តម្លៃដោយខ្លួនឯង ការផលិតស្របតាមតម្រូវការទីផ្សារនាសម័យនោះ គឺពុំទាន់អាចធានាបាននូវភាពគ្រប់គ្រាន់សម្រាប់សង្គមជាតិឡើយ។ បញ្ហាឱនភាពជញ្ជាំងពាណិជ្ជកម្មអន្តរជាតិ មានការកើនឡើងជាលំដាប់ គឺ ៩០.៨ លានដុល្លាអាមេរិក នៅឆ្នាំ ១៩៨៩ និង ២៩០ លានដុល្លាអាមេរិក នៅឆ្នាំ ១៩៩២។ រីឯការនាំចេញវិញ បានប្រមូលផ្តុំតែទៅលើទំនិញកសិកម្ម (វត្ថុធាតុដើម) ប្រមាណ ៤-៥ មុខតែប៉ុណ្ណោះ។ លក្ខណៈបែបនេះ បានឆ្លុះបញ្ចាំងអោយឃើញថា វិស័យឧស្សាហកម្មកែច្នៃ នៅកម្ពុជានាសម័យនោះ

មានកម្រិតទាបបំផុត។ មុខទំនិញសំខាន់ៗ រួមទាំងទំនិញប្រណិត ទំនិញបច្ចេកទេស ប្រេងឥន្ធនៈ និងវត្ថុធាតុដើម ត្រូវបាននាំចូលទាំងស្រុង។ ប៉ុន្តែការស្តារប្រព័ន្ធផ្លូវគមនាគមន៍ ការបំពាក់គ្រឿងឧបករណ៍ទំនើបនៅតាមកំពង់ផែសំខាន់ៗ ការលើកដាក់ទំនិញ សម្រេចបានលទ្ធផលល្អប្រសើរ។ វិស័យប្រៃសណីយ៍ទូរគមនាគមន៍ ការបណ្តុះបណ្តាលធនធានមនុស្ស និងសេវាកម្មសុខាភិបាលសាធារណៈគឺមានការអភិវឌ្ឍប្រសើរជាងសម័យកាលឆ្នាំ ១៩៧៩-១៩៨៨។

សរុបសេចក្តីមក ការផ្ទេររបបសេដ្ឋកិច្ចនយោបាយពីសេដ្ឋកិច្ចផែនការប្រមូលផ្តុំ ទៅជាសេដ្ឋកិច្ចទីផ្សារសេរីរបស់ប្រទេសកម្ពុជា បានប្រព្រឹត្តទៅនៅសម័យនោះ គឺស្ថិតក្នុងលក្ខណៈខ្វះខាតបទពិសោធន៍។ សេដ្ឋកិច្ចជាតិទាំងមូល បានជួបប្រទះនូវបញ្ហាប្រឈមធំៗជាច្រើន ដូចជា ពុំមានតុល្យភាពរវាងផលិតកម្ម និងការប្រើប្រាស់ទំនិញរវាងការនាំចេញ និងការនាំចូលទំនិញ រវាងចំណូលនិងចំណាយរបស់សហគ្រាសរដ្ឋ។ ទោះបីជាមានឥទ្ធិពលជាអវិជ្ជមានខ្លះយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលសម័យនោះ បានប្រកាន់នូវជំហរនយោបាយសេដ្ឋកិច្ចដាច់ខាតឥតងាករេ ក្នុងការធ្វើកំណែទម្រង់សេដ្ឋកិច្ច និងអនុវត្តរបបសេដ្ឋកិច្ចទីផ្សារសេរី។ ពិតមែនតែយន្តការសេដ្ឋកិច្ចទីផ្សារដែលទើបតែមានពន្លក និងពុំទាន់មានទ្រង់ទ្រាយរចនាសម្ព័ន្ធត្រឹមត្រូវ ជាពិសេសផ្នែកផ្សេងៗ នៃទីផ្សារដូចជា ទីផ្សារពលកម្ម ទីផ្សារប្រាក់ដើមទុន ទីផ្សារហិរញ្ញវត្ថុ ទីផ្សារទំនិញដែលទើបនឹងកកើត និងមានចំណុចអសកម្មច្រើនក៏ដោយ ក៏ទិសដៅនេះបានកែប្រែមុខមាត់សេដ្ឋកិច្ចកម្ពុជាយ៉ាងច្រើនដែរ។ ការធ្វើកំណែទម្រង់រដ្ឋបាល ដែលបង្កើតអោយមានប្រព័ន្ធគ្រប់គ្រងរដ្ឋមួយ ស្របតាមលក្ខណៈប្រជាធិបតេយ្យ និងសេដ្ឋកិច្ចទីផ្សារសេរី ត្រូវបានអនុវត្តន៍ជាបណ្តើរៗ ទោះបីជាដំណើរការនេះ ពុំបានប្រព្រឹត្តទៅអោយ ស៊ីចង្វាក់គ្នាក៏ដោយ ក៏ប៉ុន្តែវាគឺជាការចាប់ផ្តើមមួយយ៉ាងសំខាន់បំផុត មិនអាចប្រកែកបាន។

# ជំពូកទី ១១ បង្កើតផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្ម កសិកម្ម

ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម ជាគោលដៅយុទ្ធសាស្ត្រមួយដ៏សំខាន់ ដើម្បីរួមចំណែកជំរុញកំណើនក្នុងវិស័យកសិកម្ម។ ការបង្កើតផលិតភាព គឺផ្តោតជាសំខាន់លើការបង្កើនរដូវដាំដុះដំណាំ(ឲ្យបានពីរដង ឬបីដងក្នុងមួយឆ្នាំ) និងការអនុវត្តតាមគោលការណ៍ «ប្រពលវប្បកម្ម » ដើម្បីបង្កើនទិន្នផល។ ពិពិធកម្មកសិកម្ម គឺត្រូវផ្តោតលើការជំរុញផលិតមុខដំណាំដែលមានផលចំណេញខ្ពស់និងមានតម្រូវការទីផ្សារ។ ពានិជ្ជូបនីយកម្មកសិកម្ម ពិសេសការនាំចេញ គឺត្រូវបានជំរុញឲ្យអនុវត្ត និងធានាថាមិនមានឲ្យប៉ះពាល់ដល់សន្តិសុខស្បៀងក្នុងប្រទេស។

**គោលបំណងកម្មវិធីទី១៖** «ជំរុញកំណើនផលិតកម្មគ្រប់មុខដំណាំក្នុងរង្វង់១០% ក្នុងមួយឆ្នាំតាមរយៈការបង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយកសិកម្ម សំដៅបង្កើនទិន្នផលដំណាំ លើកម្ពស់គុណភាពផលិតផល ពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដោយភ្ជាប់ជាមួយផលិតកម្មកសិកម្មតាមកិច្ចសន្យា និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និង ប្រើប្រាសើដីប្រកបដោយនិរន្តរភាព»។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តោតសកម្មភាពជាអាទិភាពសេរីលើះ

- ការបន្តបង្កើនផលិតភាពស្រូវ និងដំណាំផ្សេងទៀតតាមរយៈការពង្រឹង ការពង្រីក និងការធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេស និងព័ត៌មានទីផ្សារកសិកម្ម ដោយជំរុញសេវាទាំងនោះឲ្យមានរចនាសម្ព័ន្ធទៅដល់មូលដ្ឋាន ហើយភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្ត និងដៃគូដែលមានការពាក់ព័ន្ធ ការលើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍដើម្បីបង្កើន
  ផលិតភាព និងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ការផលិតនិងប្រើប្រាស់ពូជដែលមានគុណភាព និងឆ្លើយតបនឹងតម្រូវការទីផ្សារ ការកែលម្អប្រព័ន្ធប្រមូល និងទុកដាក់កសិផល ការរៀបចំ និងកែសម្រួលក្របខ័ណ្ឌគតិយុត្ត សម្រាប់គ្រប់គ្រងការផលិតពូជការនាំចូលធាតុចូលកសិកម្ម ប្រព័ន្ធកសិកម្មតាមកិច្ចសន្យា ការគ្រប់គ្រងដីកសិកម្ម និងការអភិវឌ្ឍធនធានមនុស្សសម្រាប់ផ្នែកផលិតកម្មដំណាំក

សិកម្ម។ ដើម្បីបំពេញសេចក្តីត្រូវការរបស់កសិករ ការផ្តល់សេវាកម្មផ្សព្វផ្សាយកសិកម្មរបស់ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាលត្រូវបានជំរុញឲ្យមានការចូលរួមកាន់តែច្រើនថែមទៀត។

- ការបន្តជំរុញពិពិធកម្ម តាមរយៈការលើកកម្ពស់ការស្រាវជ្រាវ និងអភិវឌ្ឍ ការផ្សព្វផ្សាយមុខដំណាំថ្មីៗ ដែលមានសក្តានុពលសម្រាប់ការដាំដុះ និងការនាំចេញ ការពង្រឹង បរិស្ថានអនុគ្រោះ សម្រាប់ទាក់ទាញការវិនិយោគឯកជន ពិសេសក្នុងការស្រាវជ្រាវ ការផលិត ការចែកចាយ និងការកែច្នៃកសិផល ការបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធទាំងអស់ ក្នុងការផ្ទេរចំណេះដឹង ចំណេះធ្វើ និងបច្ចេកវិទ្យាថ្មីៗដល់កសិករ ពិសេសការអនុវត្តផលិតកម្មល្អប្រសើរ (Good Agricultural Practices-GAP) និងការជំរុញការប្រើប្រាស់គ្រឿងយន្តកសិកម្ម។
- ការបន្តលើកកម្ពស់ពាណិជ្ជូបនីយកម្ម តាមរយៈការជំរុញការអនុវត្តច្បាប់ និងគោលនយោបាយព្រមទាំងការពង្រឹងយន្តការស្ថាប័ន ដើម្បីជំរុញការធ្វើពាណិជ្ជកម្ម និងការនាំចេញកសិផលរួមមានការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវច្បាប់ស្តីពីសហគមន៍កសិកម្ម ការលើកកម្ពស់សម្ថតភាពកែច្នៃ ការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម រួមបញ្ចូលនូវយន្តការ «**ច្រកចេញចូលតែមួយ**» ការលើកស្ទួយគុណភាពកសិផលឲ្យស្របតាមស្តង់ដារអន្តរជាតិការបង្កើនសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទានតាមថ្លៃសមស្រប ការលើកស្ទួយភាពជាដៃគូរវាងសហគមន៍កសិករ និងពាណិជ្ជករ ក៏ដូចជារវាងកសិ-ឧស្សាហកម្មខ្នាតធំ និងកសិកម្មលក្ខណៈគ្រួសារ តាមរយៈការដាក់ឲ្យអនុវត្តប្រព័ន្ធ «ផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming System)»។ ភាពជាដៃគូរវាងរដ្ឋ និងវិស័យឯកជននឹងត្រូវបានជំរុញ ក្នុងគោលដៅបង្កើតផលិតភាពកសិកម្មផងដែរ។
- បន្តពង្រឹង និងពង្រីកសមត្ថភាពពិសោធន៍ វិភាគក្នុងមន្ទីរពិសោធន៍កសិកម្មជាតិ តាមរយៈការពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីជាប្រចាំ និងស្វែងរកថវិកាដើម្បីបំពាក់នូវសម្ភារបរិក្ខារទំនើបទាន់សម័យគ្រប់គ្រាន់ សម្រាប់ដំណើរការពិសោធន៍វិភាគ និងជំរុញការអនុវត្តការងារធូបទកម្មលើផលិតផល និងសម្ភារវេចខ្ចប់ ចូលរួមចំណែកលើកកម្ពស់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្មសម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ និងជានាសុខភាពសាធារណៈ។
- បន្តជំរុញការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមកសិដ្ឋាន ស្ថានីយ៍ពិសោធន៍កសិកម្ម និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឲ្យការងារពិសោធន៍ស្រាវជ្រាវអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទំនើបសមស្រប លើគ្រប់មុខជំនាញពាក់ព័ន្ធនឹងផលិតកម្មដំណាំ ពិសេសដំណាំស្រូវ ដើម្បីឈានឆ្ពោះទៅសម្រេចបានជាបណ្តើរៗ នូវគោលដៅ

នៃគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ដែលបានដាក់ចេញដោយរដ្ឋាភិបាលកម្ពុជា។

- អនុវត្តវិធានការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាលធាតុ លើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដែលរួមមាន៖ ការជំរុញការធ្វើប្រពលវប្បកម្ម និងពិពិធកម្មដំណាំសមស្រប ការពង្រឹងសមត្ថភាពសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ ការជំរុញការអភិវឌ្ឍកសិកម្ម កសិ-ឧស្សាហកម្ម ដោយបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ការពង្រឹងសម្ថតភាពស្ថាប័នជំនាញ ក្នុងការធ្វើអន្តរាគន៍ចំពោះគ្រោះមហន្តរាយធម្មជាតិ ការអភិវឌ្ឍធនធានមនុស្ស និងការឆ្លើយតបចំពោះយេនឌ័រនិងកុមារ។
- ជំរុញការដាំដុះដំណាំកៅស៊ូតាមគ្រប់រូបភាព ទាំងការពង្រីកចម្ការកៅស៊ូមានស្រាប់ ចម្ការកៅស៊ូវិនិយោគឯកជន ពិសេសបង្កើនផ្ទៃដីដាំដុះកៅស៊ូគ្រួសារ។ ជំរុញនិងបង្កើនការធ្វើ
សហប្រតិបត្តិការ និងចូលរួមជាមួយបណ្ដាវិទ្យាស្ថាន និងអង្គការកៅស៊ូអន្តរជាតិនានា ដើម្បីផ្លាស់ប្តូរបទពិសោធន៍បច្ចេកវិទ្យា និងចំណេះដឹងទូទៅលើការងារស្រាវជ្រាវ និងអភិវឌ្ឍន៍កៅស៊ូ និងខិតខំកៀរគររកប្រភពទុនពីស្ថាប័នភ្នាក់ងារហិរញ្ញវត្ថុអភិវឌ្ឍន៍នានា ដើម្បីជំរុញការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារនៅទូទាំងប្រទេស។
- អនុវត្តវិធានការជាយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យកៅស៊ូ ដោយត្រូវផ្តោតជាសំខាន់លើការជំរុញការប្រើប្រាស់ខ្លូនកៅស៊ូដែលអាចបណ្តុំបានទៅនឹងការប្រែប្រួលអាកាសធាតុ ការបង្កើតខ្លូនកៅស៊ូថ្មី ការជំរុញការសិក្សាស្រាវជ្រាវពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើដំណាំកៅស៊ូ ការកសាងសមត្ថភាពមន្ត្រីជំនាញ ឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុលើដំណាំកៅស៊ូបង្កើនសមត្ថភាពបច្ចេកទេសដំណាំកៅស៊ូ ជំរុញការអនុវត្តកសិកម្មល្អប្រសើរ (GAP) និងការបង្កើនប្រសិទ្ធភាពប្រើប្រាស់ជាតុចូល ក្នុងផលិតកម្មកែច្នៃជ័រនិងឈើកៅស៊ូ។
- បន្តជំរុញការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីជាឧបករណ៍អនុវត្តការងារ និងឆ្លើយតបទៅនឹងនិន្នាការរីកចម្រើនរបស់វិស័យកសិកម្ម រួមមាន៖ ច្បាប់ស្តីពីការការពារដំណាំនិងភូតគាមអនាម័យ ច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្មច្បាប់ស្តីពីកៅស៊ូ លិខិតបទដ្ឋានក្រោមច្បាប់សម្រាប់គាំទ្រការអនុវត្តច្បាប់ស្តីពីសហគមន៍
កសិកម្ម ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម រៀបចំគោលនយោបាយសម្រាប់អភិវឌ្ឍសហគមន៍កសិកម្ម អនុក្រឹត្យនិងប្រកាសពាក់ព័ន្ធនឹងច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជ ប្រកាសរួមស្តីពីសោហ៊ុយសេវាកម្មត្រួតពិនិ

ត្យកូតគាមអនាម័យ និងការកម្ចាត់សមាសភាពចង្រៃ ប្រកាសស្តីពីការតែងតាំងនគរបាលយុត្តិធម៌សម្រាប់សមត្ថកិច្ចមន្ត្រីភូតគាមអនាម័យ វិសោធនកម្មលើប្រកាសស្តីពីការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងត្រារបស់មន្ត្រីភូតគាមអនាម័យ។ល។

- ជំរុញឱ្យមានការវិនិយោគផ្នែកកសិកម្មពិតប្រាកដ លើកកម្ពស់ការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធភាព ក្នុងគោលដៅពន្លឿនការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបន្តត្រួតពិនិត្យការអនុវត្តកិច្ចសន្យាវិនិយោគ និងឈានដល់ការស្នើឲ្យដកហូតមកវិញនូវដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនដែលបានបំពាននីតិវិធីនិងលក្ខខណ្ឌនៃកិច្ចសន្យា។

**កម្មវិធីទី២៖ ជំរុញផលិតកម្មសត្វនិងសុខភាពសត្វ**

រាជរដ្ឋាភិបាលនីតិកាលទី៥ មានគោលដៅជំរុញលើកកម្ពស់ចលនាចិញ្ចឹមសត្វ និងវារីវប្បកម្មឲ្យកាន់តែទូលាយថែមទៀត តាមរយៈការបង្កើតក្របខណ្ឌគោលនយោបាយ ដោយផ្អែកលើគោលការណ៍ខ្សែសង្វាក់តម្លៃ ដើម្បីដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍវិស័យនេះ ដោយគិតគូរយ៉ាងខ្លាំងដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និងភូតគាមអនាម័យ។

**គោលបំណងកម្មវិធីទី ២៖** "ជំរុញការចិញ្ចឹមសត្វក្នុងអត្រាកំណើន៣ភាគរយក្នុងមួយឆ្នាំ ដោយផ្អែកលើប្រសិទ្ធភាពនៃការពិសោធន៍ស្រាវជ្រាវនិងផ្សព្វផ្សាយ បង្កើនសមត្ថភាពបង្ការទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺសូណូស៊ីស ធានាការផ្គត់ផ្គង់សត្វ សាច់សត្វ ប្រកបដោយអនាម័យ សុវត្ថិភាព និងបង្កើនសក្តានុភាពនៃការនាំចេញ" ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តោតសកម្មភាពជាអាទិភាពលើ៖

- ការជំរុញរៀបចំ និងដាក់ឲ្យអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការចិញ្ចឹមសត្វ
- ការជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍលើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋានក្នុងវិស័យផលិតកម្មសត្វ
- អនុវត្តវិធានការជាយុទ្ធសាស្ត្រក្នុងផែនការសកម្មភាពដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ លើវិស័យផលិតកម្មសត្វនិងសុខភាពសត្វ ដោយត្រូវផ្តោតលើការសម្របសម្រួលផលិតកម្មសត្វ ការអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការពង្រឹងសមត្ថភាពនិងការផ្សព្វផ្សាយ ការធ្វើអន្តរាគមន៍និងការជួយសង្គ្រោះ ការគ្រប់គ្រងកាកសំណល់សត្វ និងការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋាននានា

- ការជំរុញអនុម័តនិងអនុវត្តច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រងវិស័យនេះ ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យលើផលិតផលពីសត្វ ការពង្រឹងនិងជំរុញអនុវត្តវិធានការអនាម័យសត្វភូតគាមអនាម័យ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ក៏ដូចជាដើម្បីការពារសុខភាពសាធារណៈ
- ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វ ក្នុងទ្រង់ទ្រាយមធ្យមនិងធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេសពូជ ឥណទាន និងការរកទីផ្សារជូនកសិករ ការលើកទឹកចិត្តការវិនិយោគឯកជនក្នុងការកែច្នៃផលិតផលសត្វ ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលពាណិជ្ជកម្មលើបសុសត្វ និងផលិតផលមានដើមកំណើតពីសត្វ។

## កម្មវិធីទី ៣៖ ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព

រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់ជលផល ក្នុងគោលដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ធានាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ នឹងថែរក្សាធនធានមច្ឆជាតិឲ្យគង់វង្ស តាមរយៈការរៀបចំសហគមន៍នេសាទ អភិរក្សព្រៃលិចទឹក ប្រយុទ្ធនឹងការនេសាទខុសច្បាប់ និងអភិវឌ្ឍន៍វារីវប្បកម្ម ដើម្បីចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។

កំណែទម្រង់ស៊ីជម្រៅវិស័យជលផល រាជរដ្ឋាភិបាលបានលុបឡូត៍នេសាទទាំងអស់ ដោយបាន ផ្តល់ជូនប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ទន្ទឹមនឹងការពង្រឹងនិងពង្រីកសហគមន៍និងកន្លែងអភិរក្សធនធានជលផល ព្រមទាំងអនុវត្តយ៉ាងសកម្មនូវវិធានការការពារព្រៃលិចទឹក ជាពិសេសព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ដែលជាជម្រកដ៏សំខាន់សម្រាប់ការរស់នៅនិងជាកន្លែងបន្តពូជរបស់មច្ឆជាតិ។

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវចំណុចដៅ៣សំខាន់ៗដូចខាងក្រោម៖

- ត្រូវសម្រេចឲ្យបានតាមទិសដៅ៥ឆ្នាំ(២០១៤-២០១៨) ដូចមាននៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលឆ្នាំ២០១០-២០១៩
- ជំរុញបន្តរៀបចំនិងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយមួយសម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ ក្នុងការកំណត់បញ្ហាប្រឈមជាលក្ខណៈអន្តរជាតិ ចំពោះវិស័យជលផលកម្ពុជា រួមមានបម្រែបម្រួលអាកាសធាតុ ការសាងសង់ទំនប់វារីអគ្គិសនី និងភាពរេចរិលនៃបរិស្ថាន

- ធានានូវការទទួលទានផលត្រីរបស់ប្រជាជនតាមកម្រិត ៥២,៥ គ.ក្រ សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ។

**គោលបំណងកម្មវិធីទី៣៖** "បង្កើនការការពារនិងអភិរក្សធនធានជលផល តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រង ១០០សហគមន៍នេសាទជារៀងរាល់ឆ្នាំ និងជំរុញការអភិវឌ្ឍវារីវប្បកម្មក្នុងរង្វង់១៥%ក្នុងមួយឆ្នាំដើម្បីធានាឱ្យបាននូវនិរន្តរភាពធនធានជលផល ព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផលផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ"។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងផ្តោតសកម្មភាពជាអាទិភាពលើ៖

- ការបន្តជំរុញអនុវត្តក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល២០១០-២០១៥ សំដៅបង្កើនផលិតផលត្រី ដើម្បីធានាសេចក្តីត្រូវការរបស់ប្រជាជន និងទីផ្សារនាំចេញ ដោយផ្តោតជាសំខាន់លើសសរស្តម្ភបីគឺ៖ (១)គ្រប់គ្រងប្រកបដោយនិរន្តរភាពនូវការធ្វើនេសាទទឹកសាបនិងសមុទ្រ (២)ជំរុញនិងអភិវឌ្ឍវារីវប្បកម្មទឹកសាប និងទឹកប្រៃ (៣)កែលម្អគុណភាពនិងសុវត្ថិភាពផល ផលិតផលជលផល សម្រាប់ការប្រើប្រាស់ក្នុងស្រុកនិងនាំចេញ។
- ការបន្តពង្រឹងការគ្រប់គ្រងនិងអភិរក្សធនធានជលផលប្រកបដោយចីរភាពស្របតាម«ក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផលឆ្នាំ២០១០-២០១៩» និង «សេចក្តីថ្លែងការណ៍ស្តីពីគោលនយោបាយវិស័យជលផលជាតិ»ពិសេសតាមរយៈ ការប្រយុទ្ធប្រឆាំងនឹងបទល្មើសនេសាទគ្រប់ប្រភេទ ជាអាទិ៍ ការពង្រឹងការគ្រប់គ្រងឧបករណ៍នេសាទ ការលុបបំបាត់ការនេសាទហួសកម្រិត ការពង្រឹងសមត្ថភាពសហគមន៍នេសាទ ក្នុងការគ្រប់គ្រង ប្រើប្រាស់ និងអភិរក្សធនធានជលផល ការការពារជីវចម្រុះ និងជម្រកវារីសត្វ ការគ្រប់គ្រងគុណភាពទឹកសាបនិងសមុទ្រ ដោយកាត់បន្ថយសារជាតិពុលជាអតិបរមា ការថែទាំនិងជំរុញការដាំព្រៃលិចទឹក និងព្រៃកោងកាង ការកំណត់ព្រំប្រទល់ព្រៃលិចទឹក និងតំបន់អភិរក្សជលផល ព្រមទាំងការកសាងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយ។
- ការបង្កើនវារីវប្បកម្ម គឺជាភាពចាំបាច់ ដើម្បីការពារធនធានមច្ឆជាតិ ដែលនឹងត្រូវផ្តល់នូវការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី រួមទាំងបច្ចេកទេស ពូជត្រីឥណទាន និងទីផ្សារ។ ការធ្វើឲ្យប្រសើរឡើងនូវការអនុវត្តច្បាប់ តាមរយៈការប្រើប្រាស់បន្តនូវយន្តការដែលមានស្រាប់ គឺជាអាទិភាពក្នុងការការពារធនធានជលផល។

**កម្មវិធីទី ៤៖ ការគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាពគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល**

បានផ្តោតលើការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ដើម្បីជានាកំណើនសេដ្ឋកិច្ចជាតិ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ តាមរយៈការជំរុញអនុវត្ត«កម្មវិធីព្រៃឈើជាត»ការត្រួតពិនិត្យតាមដានការធ្វើអាជីវកម្មព្រៃឈើ ការពង្រឹងការអនុវត្ត «ច្បាប់ស្តីពីព្រៃឈើ»និងការអនុវត្តវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ ការពង្រឹងប្រសិទ្ធភាពគ្រប់គ្រងព្រៃការពារ ការអនុវត្តស៊ីជម្រៅនូវកំណែទម្រង់ក្នុងវិស័យព្រៃឈើ។

ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងនិងពង្រីកថែមទៀត នូវការគ្រប់គ្រងធនធានធម្មជាតិសំដៅរក្សា «តុល្យភាពរវាងការអភិវឌ្ឍនិងការអភិរក្ស» ពិសេសលើកកម្ពស់វិភាគទាននៃធនធានធម្មជាតិ ចំពោះការអភិវឌ្ឍវិស័យកសិកម្ម តាមរយៈ (១)ការធានាគម្របបៃតង ការអភិរក្សព្រៃឈើនិងសត្វព្រៃ (២)ការធានាចីរភាពប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាគុណភាពដី និងចីរភាពនៃប្រភពទឹក ដោយផ្តោតទៅលើការការពារជីវចម្រុះ តំបន់ដីសើម និងតំបន់ឆ្នេរ។

**គោលបំណងកម្មវិធីទី៤៖** បង្កើនការគ្រប់គ្រងព្រៃឈើនិងសត្វព្រៃប្រកបដោយនិរន្តរភាព តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ជំរុញការដាំឈើឱ្យបានយ៉ាងតិច២៥.០០០ហ.តក្នុង១ឆ្នាំ បង្កើតព្រៃការពារនិងតំបន់អភិរក្សសត្វព្រៃឱ្យបាន៥០.០០០ហ.តក្នុង១ឆ្នាំ និងបង្កើតសហគមន៍ព្រៃឈើឱ្យបាន៣២សហគមន៍ក្នុងមួយឆ្នាំ។

ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តោតសកម្មភាពជាអាទិភាពលើ៖

- ការបន្តគ្រប់គ្រងធនធានព្រៃឈើនិងសត្វព្រៃ ប្រកបដោយចីរភាព និងសមធម៌ស្របតាមកម្មវិធីព្រៃឈើជាតិ»ពិសេសតាមរយៈការពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ការកំណត់ព្រំប្រទល់ ចំណាត់ថ្នាក់និងការចុះបញ្ជីដែនព្រៃឈើ ការគ្រប់គ្រងនិងប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវព្រៃឈើរដ្ឋនិងឯកជន។
- ការអនុវត្តវិធានការលើកកម្ពស់ជីវភាព និងការចូលរួមរបស់សហគមន៍ដែលរស់នៅអាស្រ័យព្រៃឈើ ការលើកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងនិងអភិរក្ស ការកាត់បន្ថយនូវការបាត់បង់និងរេចរិលព្រៃឈើ។ ការបង្កើនការដាំនិងស្តារព្រៃឈើឡើងវិញ ការពង្រឹងកិច្ចអភិរក្សសត្វព្រៃ និងជម្រកសត្វព្រៃ ការកសាងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការជំរុញការងារស្រាវជ្រាវនិងផ្សព្វផ្សាយក្នុងវិស័យព្រៃឈើ។
- ការបន្តជំរុញអនុវត្តវិធានការនានា ដើម្បីរក្សាចីរភាពនៃប្រព័ន្ធអេកូឡូស៊ី សំដៅធានាគុណភាពដីនិងទឹក រួមទាំងទឹកក្រោមដីផង សម្រាប់បម្រើឲ្យវិស័យកសិកម្មនិងជីវភាពរស់នៅរបស់ប្រជាជន តាមរយៈការជំរុញការរៀបចំ និងអនុវត្តគោលនយោបាយនិងបទដ្ឋានគតិយុត្ត ព្រមទាំងផែនការសកម្មភាព និងកម្មវិធីនានាឲ្យមានប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចជា ជម្រកសត្វព្រៃ តំបន់ព្រៃការពារ តំបន់អភិរក្សធម្មជាតិ។

- ការបន្តជំរុញអនុវត្តកិច្ចសហប្រតិបត្តិការជាមួយតួអង្គអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងក្របខណ្ឌគោលនយោបាយជាតិស្តីពីការអេភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអេភិវឌ្ឍបៃតងឆ្នាំ ២០១៣-២០៣០ តាមរយការអនុវត្តក្របខណ្ឌគតិយុត្ត និងយន្តការសម្រាប់ការធ្វើពាណិជ្ជកម្មកាបូន ការពង្រឹងសមត្ថភាព ការរៀបចំនិងអនុវត្តវិធានការសម្រាប់បណ្តុំទៅនឹងការប្រែប្រួលអាកាសធាតុ។

**កម្មវិធីទី ៥៖ ពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យកសិកម្ម**

ដើម្បីរួមចំណែកជំរុញវិស័យកសិកម្ម ការពង្រឹងស្ថាប័ន បង្កើនប្រសិទ្ធភាពសេវាគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស គឺជាចំណុចអាទិភាពមួយដ៏សំខាន់ ដែលត្រូវយកចិត្តទុកដាក់អនុវត្ត។

**គោលបំណងកម្មវិធីទី៥៖** "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័ន ការផ្តល់សេវាគាំទ្រ និងពង្រឹងសមត្ថភាពផ្នែកអប់រំនិងបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាពដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវផ្តោតសកម្មភាពជាអាទិភាពលើ៖

- ការពង្រឹងស្ថាប័ន៖ ជំរុញការគ្រប់គ្រងអង្គភាពជំនាញក្រោមឱវាទក្រសួង ឲ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការអនុវត្តគោលនយោបាយសម្រាប់អភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព
- ការបង្កើនប្រសិទ្ធភាពសេវាគាំទ្រ បង្កើនសមត្ថភាពកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រ ពង្រឹងប្រព័ន្ធព័ត៌មាននិងទីផ្សារកសិកម្ម ការគ្រប់គ្រងគម្រោងវិនិយោគ សាធារណៈនិងឯកជន ធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព ភាពស័ក្តិសិទ្ធក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ ការធ្វើអធិការកិច្ច សវនកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ និងសេវាគាំទ្រពាក់ព័ន្ធផ្សេងទៀតប្រកបដោយប្រសិទ្ធ ភាព។
- ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្ម៖ បង្កើនចំណេះដឹងផ្នែកបច្ចេកទេស និងជំនាញកសិកម្មពាក់ព័ន្ធនានា ស្រាវជ្រាវបន្ថែមនូវបច្ចេកវិទ្យានិងរបកគំហើញថ្មីៗ សំដៅពង្រឹងនិងពង្រីកធនធានមនុស្សក្នុងវិស័យកសិកម្ម ដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍន៍ សង្គម។

ច. អនុកម្មវិធីនិងគម្រោងសកម្មភាព តាមបណ្តាអនុវិស័យជំនាញដើម្បីសម្រេចគោលដៅចម្បងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់យ៉ាងច្បាស់នូវ «កម្មវិធី» ចំនួន៥ និងបានកំណត់នូវ «អនុកម្មវិធី» មួយចំនួន ដោយបានបង្ហាញជាក់លាក់ទៅតាមអនុវិស័យនីមួយៗ នៅក្នុងការអភិវឌ្ឍវិស័យកសិកម្មមានដូចខាងក្រោម៖

❖ **កម្មវិធីទី១៖** បង្កើនផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម

**អនុកម្មវិធីទី១.១ ៖** សម្របសម្រួលបច្ចេកទេស និងបង្កើនសមត្ថភាពអង្គភាព

គោលបំណង ៖ "បង្កើនសមត្ថភាពក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍផលិតកម្មកសិកម្ម និងសេវាកម្មគាំទ្រប្រកបដោយប្រសិទ្ធភាព"។

គម្រោងសកម្មភាព៖

១. លើកកម្ពស់ប្រសិទ្ធភាពការងាររបស់ស្ថាប័នទាំងមូល តាមរយៈការពង្រឹងសមត្ថភាពកសាងផែនការការងារនិងថវិកា ការអនុវត្តថវិកា ការតាមដាននិងវាយតម្លៃ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

២. ជំរុញការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តតាមបណ្តាកសិដ្ឋាន ស្ថានីយ និងមណ្ឌលអភិវឌ្ឍន៍កសិកម្ម ដើម្បីបម្រើឱ្យការងារផលិតកម្មពូជ ពិសោធន៍ស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យាលើគ្រប់មុខជំនាញពាក់ព័ន្ធនឹងការអភិវឌ្ឍផលិតកម្មដំណាំ ទៅដល់ស្រទាប់ប្រជាកសិករនិងផលិតករគ្រប់កម្រិត។

៣. ចូលរួមអនុវត្តយុទ្ធសាស្ត្រលើកកម្ពស់យេនឌ័រក្នុងវិស័យកសិកម្ម តាមរយៈការបញ្ជ្រាបការយល់ដឹងអំពីយេនឌ័រនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម និងការលើកទឹកចិត្តការចូលរួមរបស់ស្ត្រីនៅក្នុងការដឹកនាំនិងគ្រប់គ្រងសហគមន៍កសិកម្ម។

៤. លើកកម្ពស់ស្មារតីប្រកួតប្រជែង ការទទួលស្គាល់ ការផ្លាស់ប្តូរនូវស្នាដៃ គំនិតច្នៃប្រឌិតនិងបទពិសោធន៍ល្អៗផ្សេងៗរបស់កសិករនៅក្នុងកិច្ចដំណើរការអភិវឌ្ឍវិស័យកសិកម្មតាមរយៈការរៀបចំឱ្យមានជាវេទិកាសន្និបាតកសិករទូទាំងប្រទេសប្រចាំឆ្នាំ។

- **អនុកម្មវិធីទី១.២ ៖ ជំរុញការគ្រប់គ្រងធនធានដីកសិកម្មប្រកបដោយចីរភាព**

គោលបំណង ៖ "ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងជីជាតិដី កំណត់តំបន់ដាំដុះសម្រាប់ការប្រើប្រាស់ដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងទប់ស្កាត់បញ្ហាឱនភាពដី និងបណ្តុំជាមួយការប្រែប្រួលអាកាសធាតុ"។

គម្រោងសកម្មភាព៖

១. លើកកម្ពស់ការថែរក្សានិងកែលម្អជីជាតិដី ដែលជាមូលដ្ឋាននៃការធ្វើប្រពលវប្បកម្មដំណាំប្រកបដោយនិរន្តរភាព តាមរយៈការបង្កើនចំណេះដឹង ស្តីពីបច្ចេកទេសគ្រប់គ្រងជីជាតិដី ពិសេសជំរុញការប្រើប្រាស់ជីធម្មជាតិនិងជីគីមី សមស្របតាមបទដ្ឋានបច្ចេកទេស។

២. ជំរុញការសិក្សាចងក្រងព័ត៌មាននិងទិន្នន័យមូលដ្ឋានសម្រាប់ការវាយតម្លៃអំពីឱនភាពដីកសិកម្ម ការកំណត់តំបន់ដាំដុះ ចំណាត់ថ្នាក់ដីដំណាំស្រូវ សំដៅតម្រង់ទិសការកសាងផែនការប្រើប្រាស់ធនធានដីកសិកម្ម សម្រាប់ការលើកកម្ពស់ប្រពលវប្បកម្ម និងពិពិធភាវូបនីយកម្មកសិកម្មប្រកបដោយនិរន្តរភាព។

៣. ពង្រឹងសមត្ថភាពធន់ទ្រាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម តាមរយៈការលើកកម្ពស់ការសិក្សាស្រាវជ្រាវពីវិធានការបណ្តុំនានា សម្រាប់ធានានិរន្តរភាពនៃប្រព័ន្ធផលិតកម្មកសិកម្ម ការកំណត់តំបន់ងាយរងគ្រោះដោយកត្តាធម្មជាតិនានាមានជាអាទិ៍ទឹកជំនន់ គ្រោះរាំងស្ងួត និងការជ្រៀតចូលនៃទឹកប្រៃ ដើម្បីជាមូលដ្ឋាននៃការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនកាសកម្មភាព ស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្ម។

៤. បន្តជំរុញការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់ដីកសិកម្ម និងលិខិតបទដ្ឋានគតិយុត្តនិងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាឧបករណ៍ចង្អុលបង្ហាញផ្លូវនៃការអនុវត្តការងារ ចូលរួមធានានិរន្តរភាពនៃការប្រើប្រាស់ដីកសិកម្ម។

❖ **អនុកម្មវិធីទី១.៣ ៖ ជំរុញការអភិវឌ្ឍដំណាំស្រូវ**

គោលបំណង ៖ "បង្កើនផលិតភាពដំណាំស្រូវ ដើម្បីជានាសន្តិសុខស្បៀង និងការនាំចេញអង្ករតាមរយៈការអភិវឌ្ឍ និងការប្រើប្រាស់ពូជស្រូវមានគុណភាពល្អ និងបច្ចេកទេសសមស្របប្រកបដោយប្រសិទ្ធភាព"។

គម្រោងសកម្មភាព៖

១, សិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត និងផ្សព្វផ្សាយពូជស្រូវ ដែលមានសក្តានុពល និងទិន្នផលខ្ពស់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនិងតម្រូវការទីផ្សារ។

២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកទេសផលិតកម្មដំណាំស្រូវ ស្របតាមប្រព័ន្ធក្សេត្របរិស្ថាននីមួយៗ សំដៅជំរុញផលិតកម្ម លើកកម្ពស់គុណភាពផលិតផល និងប្រសិទ្ធភាពសេដ្ឋកិច្ច។

៣. រៀបចំចងក្រងឯកសារបច្ចេកទេស និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករអំពីបច្ចេកទេសផលិតកម្មដំណាំស្រូវ និងបច្ចេកទេសក្រោយពេលប្រមូលផល សំដៅពង្រឹងសមត្ថភាពអនុវត្តការដាំដុះ ឱ្យទទួលបានទិន្នផលខ្ពស់ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងរក្សាគុណភាពផលិតផលសំដៅងាយស្រួលរកទីផ្សារនិងទទួលបានតម្លៃខ្ពស់។

៤. កសាងលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីជំរុញផលិតកម្មស្រូវ និងការត្រួតពិនិត្យគុណភាព ស្របតាមស្តង់ដារជាតិនិងអន្តរជាតិ។

៥.អង្កេត វិភាគទិន្នន័យ និងរៀបចំវេទិកាផ្លាស់ប្តូរបទពិសោធន៍ ស្តីពីបច្ចេកទេស បញ្ហាប្រឈម និងដំណោះស្រាយក្នុងផលិតកម្ម និងវាយតម្លៃលទ្ធផលសម្រេចបាន។

❖ **អនុកម្មវិធីទី១.៤ ៖ ជំរុញការអភិវឌ្ឍដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ**

គោលបំណង ៖ "បង្កើនផលិតភាពនិងផលិតកម្មដំណាំសាកវប្បកម្ម សម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ តាមរយៈការស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាដំណាំសាកវប្បកម្ម ទទួលបានទិន្នផលខ្ពស់ ធន់ទ្រាំនឹងសមាសភាពចង្រៃ និងបណ្តុំការប្រែប្រួលអាកាសធាតុ"។

គម្រោងសកម្មភាព៖

១. សិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត និងផ្សព្វផ្សាយពូជដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំដែលមានសក្តានុពល និងទិន្នផលខ្ពស់ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងតម្រូវការទីផ្សារ។

២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកទេសផលិតកម្មសាកវប្បកម្ម និងដំណាំរួមផ្សំ សមស្របតាមប្រព័ន្ធក្សេត្របរិស្ថាននីមួយៗ សំដៅជំរុញផលិតភាព ពិពិធភាវូបនីយកម្ម លើកកម្ពស់គុណភាពផលិតផល និងប្រសិទ្ធភាពសេដ្ឋកិច្ច។

៣. រៀបចំឯកសារបច្ចេកទេស និងបណ្តុះបណ្តាលបច្ចេកទេសដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ ដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ អំពីបច្ចេកទេសផលិតកម្ម ផលិតកម្មពូជដំណាំរួមផ្សំ ការអនុវត្តកសិកម្មល្អ ការគ្រប់គ្រងក្រោយពេលប្រមូលផល សំដៅជំរុញទំនើបកម្មនៃផលិតកម្មសាកវប្បកម្ម និងដំណាំរួមផ្សំ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចនិងផលិតភាពស្របតាមស្តង់ដារគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម។

៤. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាឧបករណ៍ចង្អុលបង្ហាញផ្លូវនៃការអភិវឌ្ឍសាកវប្បកម្មនិងដំណាំរួមផ្សំ។

❖ **អនុកម្មវិធីទី១.៥ ៖ ជំរុញការអភិវឌ្ឍដំណាំឧស្សាហកម្ម**

គោលបំណង ៖ "បង្កើនផលិតភាពដំណាំឧស្សាហកម្ម ដើម្បីគាំទ្រដល់ការកែច្នៃក្នុងស្រុកនិងការនាំចេញ តាមរយៈ ការស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្សព្វផ្សាយបច្ចេកទេស"។

គម្រោងសកម្មភាព៖

១. សិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត និងផ្សព្វផ្សាយពូជដំណាំឧស្សាហកម្ម ដែលមានសក្តានុពល និងទិន្នផលខ្ពស់ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និតម្រូវការទីផ្សារ។

២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកទេសផលិតកម្មដំណាំឧស្សាហកម្មសមស្របតាមប្រព័ន្ធក្សេត្របរិស្ថាននីមួយៗ សំដៅលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មគុណភាពផលិតផល និងប្រសិទ្ធភាពសេដ្ឋកិច្ច។

៣. រៀបចំឯកសារបច្ចេកទេស និងបណ្តុះបណ្តាលបច្ចេកទេសដំណាំឧស្សាហកម្ម ដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ អំពីបច្ចេកទេសផលិតកម្ម និងការគ្រប់គ្រងក្រោយពេលប្រមូលផលដំណាំឧស្សាហកម្ម ផលិតកម្មពូជដំណាំឧស្សាហកម្មការគ្រប់គ្រងក្រោយពេលប្រមូលផល ការអនុវត្ត

កសិកម្មល្អ សំដៅជំរុញទំនើបកម្មនៃផលិតកម្មដំណាំឧស្សាហកម្មប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងផលិតភាពស្របតាមស្តង់ដារគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្ម។

៤. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនិងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាឧបករណ៍ចង្អុលបង្ហាញផ្លូវនៃការអភិវឌ្ឍ និងគ្រប់គ្រងផលិតកម្មដំណាំឧស្សាហកម្ម។

❖ **អនុកម្មវិធីទី១.៦ ៖ ជំរុញការអភិវឌ្ឍគ្រឿងយន្តកសិកម្ម**

គោលបំណង ៖ "បង្កើនការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ប្រកបដោយប្រសិទ្ធភាព ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ធានាសុវត្ថិភាពស្បៀង និងបណ្តុំទៅនឹងការប្រែប្រួលអាកាសធាតុ"។

គម្រោងសកម្មភាព៖

១. សិក្សាស្រាវជ្រាវ កែច្នៃផលិតសាកពិសោធន៍ និងកែលម្អគ្រឿងយន្តកសិកម្ម និងឧបករណ៍កសិកម្ម ទ្រទ្រង់ខ្សែសង្វាក់ផលិតកម្ម និងកែច្នៃផលិតផលឱ្យសមស្របទៅតាមប្រភេទមុខដំណាំ លក្ខខណ្ឌដី ស្ថានភាពភូមិសាស្ត្រ និងលទ្ធភាពទទួលយកបានរបស់អ្នកប្រើប្រាស់។

២. អប់រំនិងផ្សព្វផ្សាយស្តីពីបច្ចេកទេសប្រើប្រាស់ និងថែទាំគ្រឿងយន្តនិងឧបករណ៍កសិកម្មដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ តាមរយៈសកម្មភាពបណ្តុះបណ្តាលធ្វើបង្ហាញ និងកិច្ចអន្តរាគមន៍ផ្នែកគ្រឿងយន្តកសិកម្មនានា។

៣. កែលម្អប្រព័ន្ធដីស្រែចំការ និងប្រព័ន្ធគ្រប់គ្រងបញ្ចេញបញ្ចូលទឹកក្នុងស្រែ ឱ្យស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីបង្កើនផលិតភាព និងផលចំណេញនៅក្នុងផលិតកម្ម និងភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

៤. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានសម្រាប់តម្រង់ទិសការអភិវឌ្ឍ និងគ្រប់គ្រងយន្តូបនីយកម្មកសិកម្ម។

❖ **អនុកម្មវិធីទី១.៧ ៖ ជំរុញការអភិវឌ្ឍការងារការពារដំណាំ អនាម័យ និងភូតគាមអនាម័យ**

គោលបំណង ៖ "កាត់បន្ថយការបាត់បង់ទិន្នផលដំណាំ ធានាគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងសម្រួលការនាំចេញ"។

គម្រោងសកម្មភាព៖

១. សិក្សាស្រាវជ្រាវ ចងក្រងបញ្ជីឈ្មោះសមាសភាពចង្រៃ និងអភិវឌ្ឍន៍វិធានការគ្រប់គ្រងនិងកម្ចាត់សមាសភាពចង្រៃលើដំណាំនិងផលិតផលស្តុក។

២. លើកកម្ពស់ចំណេះដឹងស្តីពីបច្ចេកទេសការពារដំណាំនិងភូតគាមអនាម័យដល់មន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងកសិករ តាមរយៈសកម្មភាពបណ្តុះបណ្តាល ការធ្វើបង្ហាញ និងកិច្ចអន្តរាគមន៍នានា។

៣. លើកកម្ពស់ផលិតភាព គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម តាមរយៈការកសាងសមត្ថភាពស្តីពីការអនុវត្តកសិកម្មល្អ និងការតាមដាននិងវាយតម្លៃ សក្តានុពលហានិភ័យ។

៤. ទប់ស្កាត់ហានិភ័យនានា ពាក់ព័ន្ធនឹងការរាតត្បាតសមាសភាពចង្រៃផ្សេងៗ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយជំរុញការវិភាគតាមដាននិងវាយតម្លៃលើទំនិញ និងផលិតផលកសិកម្មនាំចូល ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យភូតគាមអនាម័យ ដោយអនុលោមតាមបទដ្ឋាននៃវិធានភូតគាមអនាម័យជាធរមាន។

៥. កសាងនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធ ដើម្បីជាមូលដ្ឋានសម្រាប់តម្រង់ទិសការអភិវឌ្ឍ និងគ្រប់គ្រងការការពាររុក្ខជាតិនិងភូតគាមអនាម័យ។

### ❖ អនុកម្មវិធីទី១.៨៖ ពង្រឹងនិងកែលម្អប្រព័ន្ធនិងសេវាផ្សព្វផ្សាយកសិកម្ម

គោលបំណង ៖ "ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធ និងសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងជំរុញកំណើននៃការទទួលយកទៅអនុវត្តរបស់កសិករប្រកបដោយប្រសិទ្ធភាព"។

គម្រោងសកម្មភាព៖

១. ពង្រឹងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម ដោយធ្វើការរៀបចំពង្រឹងស្ថាប័នផ្សព្វផ្សាយកសិកម្មនិងក្របខណ្ឌច្បាប់ ធ្វើការត្រួតពិនិត្យនិងវាយតម្លៃសេវាកម្មផ្សព្វផ្សាយកសិកម្ម និងប្រសិទ្ធភាពនៃការទទួលយកសេវាផ្សព្វផ្សាយកសិកម្ម និងកសាងមូលដ្ឋានទិន្នន័យវិភាគប្រព័ន្ធក្សេត្របរិស្ថាន និងស្ថានភាពសេដ្ឋកិច្ចគ្រួសារកសិករ។

២. ពង្រឹងនិងពង្រីកមូលដ្ឋានធនធានមនុស្ស ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សំដៅពង្រីកសេវាផ្សព្វផ្សាយកសិកម្ម ឱ្យដល់សហគមន៍ផលិតកម្មនៅទូទាំងប្រទេស តាមរយៈការបង្កើតគោលការណ៍ និងសៀវភៅណែនាំអំពីការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មសកម្មភាពបណ្តុះបណ្តាលមន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ជាពិសេសភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ឃុំ-សង្កាត់។

៣. ពង្រីកវិសាលភាពនៃការទទួលបានព័ត៌មានបច្ចេកទេសកសិកម្មនិងសេវាពាក់ព័ន្ធផ្សេងៗតាមរយៈការបង្កើត និងចងក្រងបង្កុំបច្ចេកវិទ្យាកសិកម្ម ផលិតផ្សព្វផ្សាយឯកសារបច្ចេកទេសកសិកម្ម សកម្មភាព បណ្តុះបណ្តាល ធ្វើបង្ហាញ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈផ្សេងៗ។

### ❖ អនុកម្មវិធីទី១.៩ ៖ លើកកម្ពស់ការអភិវឌ្ឍសហគមន៍កសិកម្ម

គោលបំណង ៖ "បង្កើតនិងពង្រឹងសមត្ថភាសហគមន៍កសិកម្ម ឲ្យមានប្រសិទ្ធភាពក្នុងប្រព័ន្ធខ្សែសង្វាក់ផលិតកម្មកសិកម្មនិងទីផ្សារ"។

គម្រោងសកម្មភាព៖

១. ជំរុញការបង្កើតនិងចុះបញ្ជីសហគមន៍កសិកម្ម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្តុំ ក្នុងភាពជាដៃគូជាមួយផ្នែកឯកជននានា ដើម្បីទទួលបានទាំងបច្ចេកវិទ្យាថ្មីនិងឥណទាន និងជានាស្ពេភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារក្នុងស្រុកនិងក្រៅស្រុក។

២. អភិវឌ្ឍន៍សហគមន៍កសិកម្មឱ្យក្លាយជាសហគ្រាសសេដ្ឋកិច្ចកសិកម្មជនបទ ដោយបង្កលក្ខណៈងាយស្រួលជូនសមាជិកសហគមន៍ ក្នុងការទទួលបាននូវឱកាសពង្រឹងសមត្ថភាពលើការងារដឹកនាំនិងគ្រប់គ្រងសហគមន៍ ការរៀបចំផែនការធុរកិច្ចការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ការចុះបញ្ជីគណនេយ្យ ការផ្គត់ផ្គង់ជាតុចូលកសិកម្ម ទីផ្សារកសិកម្ម តាមរយៈការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកាជាតិនិងអន្តរជាតិផ្សេងៗ។

៣. ជំរុញការអភិវឌ្ឍន៍ការងារជំនួញរបស់សហគមន៍កសិកម្ម តាមរយៈការរៀបចំវេទិកាធុរកិច្ចការរៀបចំសិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍ និងកាធ្វើទស្សនកិច្ចសិក្សា។ល។ ដើម្បីធ្វើឱ្យសហគមន៍កសិកម្មអាចបង្កើតដៃគូជំនួញ និងបង្កើនអំណាចចរចាថ្លៃទីផ្សារ ដែលនាំទៅដល់ការបង្កើនប្រាក់ចំណូលគ្រួសារកសិករ។

៤. ផ្សព្វផ្សាយច្បាប់ស្តីពីសហគមន៍កសិកម្មឱ្យបានទូលំទូលាយ និងកសាងគោលនយោបាយលិខិតបទដ្ឋានគតិយុត្ត និងយន្តការពាក់ព័ន្ធ ដើម្បីជំរុញអនុវត្តច្បាប់ស្តីពីសហគមន៍កសិកម្មឱ្យបានពេញលេញ។

### ❖ អនុកម្មវិធីទី១.១០ ៖ ពង្រឹងនិងអភិវឌ្ឍសមត្ថភាពមន្ទីរពិសោធន៍ជាតិកសិកម្ម

គោលបំណង ៖ "លើកកម្ពស់សមត្ថភាពការផ្តល់សេវាកម្មវិភាគ និងត្រួតពិនិត្យគុណភាពដី ដី ទឹក ថ្នាំកសិកម្ម សំណល់គីមីកសិកម្ម និងជីវបច្ចេកវិទ្យា ដើម្បីរួមចំណែកបង្កើនផលិតភាពកសិកម្មគុណភាព និងសុវត្ថិភាពកសិផល សម្រាប់ប្រើប្រាស់ក្នុងស្រុកនិងការនាំចេញ"។

គម្រោងសកម្មភាព៖

១. ពង្រឹងនិងពង្រីកសមត្ថភាពសេវាពិសោធន៍វិភាគគ្រប់ផ្នែកជំនាញ ដោយចងក្រងឯកសារពិធីសារវិភាគពាក់ព័ន្ធស្របតាមបទដ្ឋានស្តង់ដារអន្តរជាតិ សម្រាប់ជាមូលដ្ឋានវិទ្យាសាស្ត្រនៃដំណើរការពិសោធន៍វិភាគ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី។

២.ផ្តល់ការគាំទ្រសេវាសាធារណៈសម្រាប់ការពិសោធន៍ វិភាគគុណភាពលើធាតុចូលកសិកម្មផ្សេងៗ ដើម្បីជាមូលដ្ឋាននៃការសម្រេចចិត្តត្រឹមត្រូវ ក្នុងការប្រើប្រាស់ធាតុចូលសម្រាប់ការអភិវឌ្ឍផលិតកម្មកសិកម្ម។

៣. សិក្សាអង្កេត និងវិភាគគុណភាពថ្នាំនិងជីកសិកម្ម និងហានិភ័យនៃថ្នាំកសិកម្ម នៅលើបន្លែនិងផ្លែឈើ។

៤. រៀបចំនិងកសាងលិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ទីរពិសោធន៍ជាតិកសិកម្ម។

- **អនុកម្មវិធីទី១.១១៖ ជំរុញការវិនិយោគនិងអភិវឌ្ឍន៍ដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់និងចីរភាព**

គោលបំណង ៖ "បង្កើនសមត្ថភាពបច្ចេកទេសក្នុងការអភិវឌ្ឍដំណាំកៅស៊ូ សំដៅបង្កើនបរិមាណនិងគុណភាពកៅស៊ូ ពង្រឹងសមត្ថភាពសហគមន៍កសិករកៅស៊ូ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងប្រើប្រាស់ដីកៅស៊ូប្រកបដោយនិរន្តរភាព"។

គម្រោងសកម្មភាព៖ បណ្តុះបណ្តាលជំនាញចៀរជ័រដល់កសិករកៅស៊ូគ្រួសារ។

១. ផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូដល់កសិករកៅស៊ូគ្រួសារ។

៣. ស្រង់ស្ថិតិនិងកំណត់ទីតាំងចម្ការកៅស៊ូគ្រួសារ។

៤. បណ្តុះបណ្តាលបច្ចេកទេសដំណាំកៅស៊ូដល់មន្ត្រីបង្គោល។

៥. ពង្រឹងនិងចងក្រងសមាគមឬសហគមន៍កសិករកៅស៊ូគ្រួសារ។

៦. ផ្សព្វផ្សាយបច្ចេកទេសដំណាំកៅស៊ូតាមទូរទស្សន៍។

៧. សិក្សានិងកំណត់ទីតាំងដីកបនឹងដំណាំកៅស៊ូ។

៨- សិក្សាវាយតម្លៃលើលទ្ធផលនិងប្រសិទ្ធភាពនៃវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាល។

៩- សិក្សាអង្កេតលក្ខណៈសម្បត្តិ (Profile) របស់ចម្ការកៅស៊ូគ្រួសារ។

១០- ផលិតនិងបោះពុម្ពផ្សាយឯកសារបច្ចេកទេសកៅស៊ូ។

- **អនុកម្មវិធីទី១.១២ ៖ ជំរុញខ្សែចង្វាក់តម្លៃកៅស៊ូឱ្យបានល្អ**

គោលបំណង ៖ "ពង្រឹងនិងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាល ស្តីពីទីផ្សារកៅស៊ូ ដើម្បីបង្កើនប្រាក់ចំណូលដល់កសិករកៅស៊ូគ្រួសារ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ"។

គម្រោងសកម្មភាព៖

១-បណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីទីផ្សារកៅស៊ូដល់សហគមន៍កៅស៊ូគ្រួសារ ឱ្យបង្កើតមជ្ឈមណ្ឌលលក់ដូរកៅស៊ូរួម។

២- ផ្តល់ព័ត៌មានពីការផ្គត់ផ្គង់ តម្រូវការ និងតម្លៃកៅស៊ូដល់ប្រតិបត្តិករកៅស៊ូ។

៣-បង្កើតនិងគ្រប់គ្រងគេហទំព័រព័ត៌មានកៅស៊ូ។

- **អនុកម្មវិធីទី១.១៣ ៖ លើកកម្ពស់គុណភាពផលិតផលកៅស៊ូ**

គោលបំណង៖ "ពង្រឹងសមត្ថភាពកែច្នៃសំដៅបង្កើនទាំងបរិមាណនិងគុណភាពផលិតផលកៅស៊ូស្របតាមបទដ្ឋានបច្ចេកទេសកែច្នៃ"។

គម្រោងសកម្មភាព៖

១- ស្រង់ស្ថិតិរោងចក្រ សិប្បកម្មកែច្នៃផលិតផលកៅស៊ូ។

២- ផ្សព្វផ្សាយបច្ចេកទេសកែច្នៃដល់ប្រតិបត្តិករកៅស៊ូ។

៣- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក (USS) ដល់សហគមន៍កៅស៊ូគ្រួសារ។

៤- បង្កើតមណ្ឌលបង្ហាញការកែច្នៃកៅស៊ូសន្លឹក (USS) រួម។

- **អនុកម្មវិធីទី១.១៤៖ លើកកម្ពស់ការគ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្សក្នុងផ្នែកកៅស៊ូ**

គោលបំណង ៖ "បង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធនឹងផ្នែកកៅស៊ូ និងបង្កើនសមត្ថភាពជំនាញរបស់ប្រតិបត្តិករកៅស៊ូ"។

គម្រោងសកម្មភាព៖

១-សម្របសម្រួលរវាងម្ចាស់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម និងម្ចាស់ចម្ការកៅស៊ូគ្រួសារ។

២-រៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតបទដ្ឋានក្រោមច្បាប់។

៣-ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ។

៤-បណ្តុះបណ្តាលសមត្ថភាពជំនាញដល់ប្រតិបត្តិករកៅស៊ូ។

៥- សិក្សាពីតម្រូវការធនធានមនុស្សនិងកម្លាំងពលកម្មក្នុងផ្នែកកៅស៊ូ។

៦- ពិនិត្យ វាយតម្លៃលើលទ្ធផលនិងប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធដល់ផ្នែកកៅស៊ូ។

- **អនុកម្មវិធីទី១.១៥ ៖ ពង្រឹងការងាររដ្ឋបាល និងអភិបាលកិច្ចក្នុងផ្នែកកៅស៊ូ**

គោលបំណង ៖ "បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងនិងអភិបាលកិច្ចល្អក្នុងផ្នែកកៅស៊ូ"។

គម្រោងសកម្មភាព៖

១- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តថវិកា។

២- បណ្តុះបណ្តាលការរៀបចំនិងគ្រប់គ្រងអនុកម្មវិធី។

៣- រៀបចំសន្និបាត/ប្រជុំបូកសរុបប្រចាំឆ្នាំ។

៤- តាមដានការអនុវត្តផែនការកម្មវិធីវិនិយោគកៅស៊ូ និងវាយតម្លៃលទ្ធផលដែលសម្រេចបាន។

៥- គាំទ្រការសម្របសម្រួលការងារកិច្ចការរដ្ឋបាល។

៦- តាមដានត្រួតពិនិត្យដំណើរការរបស់ស្នាក់ការប្រមូលទិញជ័រកៅស៊ូគ្រួសារ។

៧- សិក្សាអង្កេតលក្ខណៈសម្បត្តិ (Profile) របស់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម។

- **អនុកម្មវិធីទី១.១៦៖ លើកកម្ពស់គុណភាពពូជកៅស៊ូថ្មី និងប្រសិទ្ធភាពគុណភាព ផលិតផលកៅស៊ូកម្ពុជា**

គោលបំណង ៖ "ធ្វើឲ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រើប្រាស់ពូជកៅស៊ូថ្មី បណ្តុំបាននឹងការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យផលិតផលកៅស៊ូកម្ពុជាមានគុណភាព ប្រកួតប្រជែង និងមានតម្លៃខ្ពស់លើទីផ្សារអន្តរជាតិ"។

គម្រោងសកម្មភាព៖

១. រៀបចំច្បារបង្កាត់ពូជថ្មី ថែទាំ និងបង្កាត់ពូជ។

២. បង្កើតចម្ការពិសោធន៍ខ្លួនទ្រង់ទ្រាយធំចំនួនពីរកន្លែង។

៣. តាមដានការលូតលាស់និងស្រង់ទិន្នន័យចម្ការពិសោធន៍ប្រាំតំបន់។

៤. គ្រប់គ្រងថែទាំច្បារពូជក្នុងស្ថានីយអនុវត្ត។

៥. គ្រប់គ្រង ថែទាំកៅស៊ូមិនទាន់ឲ្យផល និងថ្នាលបណ្តុះកូនកៅស៊ូក្នុងស្ថានីយអនុវត្ត។

៦. ស្រាវជ្រាវការប្រើប្រាស់ជីលើកៅស៊ូមិនទាន់ឲ្យផល និងកៅស៊ូឲ្យផល។

៧. បន្តការតាមដានលទ្ធផលចម្ការពិសោធន៍។

៨. ផ្សព្វផ្សាយបច្ចេកទេសដាំដុះថ្មី ថែទាំកៅស៊ូ និងព្យាបាល ជំងឺកៅស៊ូគ្រប់ប្រភេទដល់កសិករ។

៩. ពិសោធន៍ស្រាវជ្រាវលើគុណភាពដីសម្រាប់ដំណាំកៅស៊ូ។

១០. តាមដានលើប្រព័ន្ធចង្វាក់ចៀរជ័ររង្វើល លក្ខខណ្ឌក្នុងស្ថានីយអនុវត្ត។

១១.វិភាគសរីរៈទឹកជ័រកៅស៊ូចំការពិសោធន៍នានាក្នុងស្ថានីយអនុវត្ត លើការវិភាគអំពីអញ្ញត្តិ។

១២. បើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសប្រមូលផលទឹកដំរ។

១៣. ធ្វើតេស្តបញ្ជាក់គុណភាពកៅស៊ូអន្តរមន្ទីរពិសោធន៍ជាមួយសមាគមកៅស៊ូអន្តរជាតិ។

១៤. រៀបចំនិងធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុក។

១៥. ចុះត្រួតពិនិត្យរោងចក្រ CSR និង Lab CSR។

១៦. ទទួលធ្វើសវនកម្មផ្ទៃក្នុងនិងក្រៅពីការិយាល័យទទួលស្គាល់តាមស្តង់ដារអន្តរជាតិ ISO/IEC17025។

១៧. ចំណាយទូទៅលើដំណើរការពិសោធន៍ស្រាវជ្រាវ។

១៨. វិភាគទាន IRRDB និងធ្វើសំណាកដំរ។

❖ **អនុកម្មវិធីទី១.១៧ ៖ ជំរុញនិងលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម**

គោលបំណង ៖ "បង្កើតការងារ បង្កើនតម្លៃបន្ថែម និងជំរុញការឈានចូលទីផ្សារនៃផលិតផលកសិកម្មតាមរយៈការបង្កើនសមត្ថភាពជំនាញកសិឧស្សាហកម្ម ការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានិងការលើកកម្ពស់គុណភាព សុវត្ថិភាពនៃផលិតផលកសិកម្ម"។

គម្រោងសកម្មភាព៖

១. ការបណ្ដុះបណ្ដាលអំពីបច្ចេកទេសកែច្នៃផលិតផលកសិកម្ម។

២.ការបណ្ដុះបណ្ដាលអំពីស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្ម។

៣.ការបណ្ដុះបណ្ដាលអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យានិងក្របខណ្ឌគតិយុត្ត។

៤. ការបណ្ដុះបណ្ដាលអំពីបច្ចេកទេសក្រោយពេលប្រមូលផលនៃផលិតផលកសិកម្ម។

៥. ការសម្របសម្រួលការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា រវាងភាគីអ្នកផលិត (ក្រុមកសិករ) និងភាគីអ្នកទិញ (ក្រុមហ៊ុន)។

៦. ពង្រឹងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

៧. កសាងមណ្ឌលបណ្ដុះបណ្ដាលបច្ចេកទេស កសិ-ឧស្សាហកម្ម។

៨. ធ្វើបច្ចុប្បន្នភាពទិន្នន័យសហគ្រាសកសិ-ឧស្សាហកម្ម។

៩. ការចងក្រងសហគមន៍កសិ-ឧស្សាហកម្ម។

១០. កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងការផ្សព្វផ្សាយ។

១១. អនុវត្តល្អលើបច្ចេកទេសប្រមូលផល ការដឹកជញ្ជូន ការសម្ងួត ការរក្សាទុកផលិតផលកែច្នៃ

និងវេចខ្ចប់ ក្នុងការចូលរួមកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

១២. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាសមស្រប ផ្នែកក្រោយពេលប្រមូលផល ផ្នែកកែច្នៃនិងវេចខ្ចប់ផលិតផលកសិកម្ម ក្នុងការចូលរួមកាត់បន្ថការបាត់បង់ ទាំងបរិមាណ និងគុណភាព និងការបំភាយឧស្ម័នផ្ទះកញ្ចក់តិច។

១៣. គ្រប់គ្រង និងប្រើប្រាស់សំណល់កសិកម្ម និងកសិ-ឧស្សាហកម្មគ្រប់ប្រភេទ និងកែច្នៃសំណល់កសិកម្ម ជាប្រភពថាមពលជីធម្មជាតិនិងចំណីសត្វ ដើម្បីចូលរួមកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់តិច។

១៤. បណ្តុះបណ្តាលបច្ចេកវិទ្យាសមស្រប ដែលមានការបំភាយឧស្ម័នផ្ទះកញ្ចក់តិច ដល់សហគ្រាសវិនិយោគកសិ-ឧស្សាហកម្ម។

១៥. បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីមន្ទីរពិសោធន៍ លើការធ្វើវិភាគគុណភាពផលិតផល

កសិកម្ម។

១៦. ផ្គត់ផ្គង់ឧបករណ៍សម្ភារបរិក្ខា សម្រាប់កិច្ចដំណើរការមន្ទីរពិសោធន៍ វិភាគគុណភាព ផលិត

ផលកសិកម្ម។

១៧. ការគាំទ្រធានារ៉ាប់រងសុខភាពដល់មន្ត្រីមន្ទីរពិសោធន៍វិភាគគុណភាពផលិតផលកសិកម្ម។

❖ **អនុកម្មវិធីទី១.១៨៖ ការស្រាវជ្រាវដើម្បីលើកកម្ពស់ផលិតភាពដំណាំកសិកម្ម**

គោលបំណង៖ "ជំរុញការអភិរក្ស និងប្រើប្រាស់ពន្ធុរុក្ខជាតិ ការបង្កើតពូជដំណាំដែលបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានគុណភាពល្អ និងឆ្លើយតបទៅនឹងទីផ្សារ និងការស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ ក្នុងការប្រើប្រាស់ធាតុចូលកសិកម្ម ដើម្បីលើកកម្ពស់ផលិតភាពដំណាំកសិកម្ម" ។

គម្រោងសកម្មភាព៖

១. សមូហកម្ម អភិរក្សកម្ម (Genebank) វាយតម្លៃ និងប្រើប្រាស់ធនធានពន្ធុរុក្ខជាតិទាំងអស់ដែលមានគុណប្រយោជន៍ សម្រាប់ដំណាំស្បៀងនិងកសិកម្ម។

២. អភិវឌ្ឍពូជស្រូវទំនាបរំពឹងទឹកភ្លៀងដែលធន់នឹងកត្តាមិនអំណោយផលផ្នែកជីវៈ(Biotic stresses) និង អជីវៈ (Abiotic stresses) ព្រមទាំងមានទិន្នផលខ្ពស់ និងគុណភាពល្អ។

៣. អភិវឌ្ឍពូជស្រូវស្រាលមានទិន្នផលខ្ពស់គុណភាពអង្ករល្អ ហើយធន់នឹងមមាចត្នោត (BPH) និង កម្តៅ។

៤. អភិវឌ្ឍពូជដំណាំពពួកសណ្តែក លូ ពោត ស្វាយ និង បន្លែដែលមានទិន្នផលខ្ពស់និង គុណភាពល្អ។

៥. សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រ អំពីបច្ចេកទេសគ្រប់គ្រងដីប្រកបដោយនិរន្តរភាព និងកំណត់តម្រូវការសារធាតុចិញ្ចឹមរបស់ដំណាំសម្រាប់ប្រព័ន្ធផលិតកម្មដំណាំស្រូវ និងដំណាំដំឡូងមី។

៦. សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសប្រើប្រាស់និងគ្រប់គ្រងទឹកស្រោចស្រពដំណាំ ប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាន។

៧. សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាទេសគ្រប់គ្រងសមាសភាពចង្រៃ៖ ឡុងពណ៌មាស ពពួកមមាច ជំងឺ និង ស្មៅលើដំណាំស្រូវតាមក្បែត្របរិស្ថាន និងសត្វល្អិតលើដំណាំសណ្តែកសៀង។ និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេក

៨. សិក្សាស្រាវជ្រាវ អភិវឌ្ឍបច្ចេកវិទ្យា និងចំណេះដឹងវិទ្យាសាស្ត្រអំពីបច្ចេកទេសមុនប្រមូលផលដំណាំ ដែលឆ្លើយតបទៅនឹងបរិបទនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម តាមរយៈការអភិវឌ្ឍឧបករណ៍ដាំគ្រាប់ស្ងួតសម្រាប់ដំណាំស្រូវ។

៩. សិក្សាស្រាវជ្រាវអំពីពេលវេលា និងវិធីសាស្ត្រប្រមូលផលដំណាំស្រូវដោយកំលៃ (Combined harvester)។

១០.សិក្សាស្រាវជ្រាវពីកត្តាជះឥទ្ធិពលលើការវេចខ្ចប់បឋម និងដឹកជញ្ជូនសម្រាប់ដំណាំខាត់ណាស្ពៃ និងចេក ប្រកបដោយគុណភាព និងសុវត្ថិភាព។

១១.សិក្សាស្រាវជ្រាវ និងអភិវឌ្ឍឧបករណ៍ប្រើប្រាស់ សម្រាប់ញែកគ្រាប់ស្រូវ និងសណ្តែកបាយ។

១២.សិក្សាវាយតម្លៃសមត្ថភាពសហគមន៍ជនបទ ក្នុងការទទួលយកនិងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ បញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

១៣.សិក្សាវាយតម្លៃអំពីឥទ្ធិពលនៃការទទួលយក និងការប្រើប្រាស់បច្ចេកទេសថ្មីៗបញ្ចេញដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ទៅលើសង្គមសេដ្ឋកិច្ចជនបទ។

# បណ្ណាល័យសាស្ត្រ


ក្រុមអ្នកជំនាញ ប្រវត្តិរូបិយវត្ថុខ្មែរ, ភ្នំពេញ ឆ្នាំ ២០០០

ក្រុមអ្នកជំនាញ៤, ប្រវត្តិរូបិយវត្ថុខ្មែរ, ភ្នំពេញ, ឆ្នាំ ២០០០

ខូយ ខេមរិន, ប្រវត្តិសាស្ត្រកម្ពុជាសម័យបុរេអង្គរ និងអង្គរ

ខៀវ ថរិកា, ទំនាក់ទំនងអន្តរជាតិ, ឆ្នាំ ២០០១

ងួន ហេង, ម៉ម ចរិយាវុធ, សេដ្ឋកិច្ចនយោបាយ, ២០១៣

ឈុន ពហុ , ប្រវត្តិសេដ្ឋកិច្ចនៃប្រទេសកម្ពុជា(ឯកសារមេរៀន) ឆ្នាំ ២០០៤

ដៀប សុផល, ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២

ដៀប សុផល, របបកម្ពុជាប្រជាធិបតេយ្យ នយោបាយសេដ្ឋកិច្ច សង្គម, ភ្នំពេញ, ឆ្នាំ ២០០៥

ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ, ភាគ ២ ភ្នំពេញ,ឆ្នាំ ១៩៧៣

ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរ ភាគ ១ ភ្នំពេញ, ឆ្នាំ ១៩៧៣

ត្រឹង ងា,អរិយធម៌ខ្មែរ ភ្នំពេញ ឆ្នាំ ១៩៧៣

ថាច់ វាន់ផាត និងកែវ សុកុន, អាទិទេពក្រុងអង្គរ, ឆ្នាំ ១៩៨៩

ទស្សនាវដ្តី ស្វែងរកការពិត, លេខ ១៤, ១៦, ២៧, ឆ្នាំ ២០០១

ទស្សនាវដ្តីត្រឹមត្រូវបារាំងមួយឈ្មោះ អឺរ៉ុប-ហ្វ្រង្ស-អិត្រមើរ លេខ ៤៦៥ ខែតុលា ១៩៦៨

ទស្សនាវដ្តី ពន្លឺសភាជាតិ, ពីមួយថ្ងៃទៅមួយថ្ងៃ ទំនិញឡើងថ្លៃ មិនព្រមហត់, លេខ ៥, ឆ្នាំទី១,ខែកក្កដា ឆ្នាំ ១៩៧២

ធនាគារអភិវឌ្ឍន៍អាស៊ី របាយការណ៍សេដ្ឋកិច្ចកម្ពុជា ឆ្នាំ១៩៧០

បាង ខាត់, ប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរ, អត្ថបទចុះក្នុង សៀវភៅពុទ្ធសាសនា ២៥០០, ភ្នំពេញ

ផៃ ប៉េងស៊ីម,ទិន្នន័យសរុបនៃសេដ្ឋកិច្ចកម្ពុជា, (បកប្រែពីភាសា បារាំង) ភ្នំពេញ, ឆ្នាំ ២០០៤

ពៅ សារឿន, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ

មីសែល ត្រាណេ, ប្រវត្តិសាស្ត្រកម្ពុជាពីបុព្វសម័យ ដល់សតវត្ស ទី៨, ១៩៩៦

មីសែល ត្រាណេ, ប្រវត្តិសាស្ត្រកម្ពុជាសម័យអាណាចក្រភ្នំ ស.វទី ១–៦,

មៀច ប៉ុណ្ណ និងហ៊ុននាង, កម្រងឯកសារស្តីពីប្រពៃណី និងទំនៀមទំលាប់ខ្មែរ, ១៩៩៩

រស់ ចន្ត្រាបុត្រ, សាធារណៈខ្មែរ

លី ជាមតេង, កំណត់ហេតុរបស់ជីវ តាក្វាន់ អំពីប្រពៃណីអ្នក ស្រុកចេនឡាភ្នំពេញ, ១៩៧៣

សម្តេចព្រះសង្ឃមហាសុមេជាធិបតី ជួន ណាត,វចនានុក្រមខ្មែរ ភាគទី១, ឆ្នាំ ១៩៦៧

សារពត៌មាន រាស្ត្រសច្ចៈ, ការខ្វះខាតអង្ករ និងទំនិញឡើងថ្លៃ ពិបាករកទិញទទួលទានអាហារនៅទីក្រុងភ្នំពេញ ចេញផ្សាយថ្ងៃទី ១៣ ខែកញ្ញា លេខ ៨៩៣

សារពត៌មាន អរិយធម៌, ឆ្នាំទី៣, លេខ ៤០៩, ឆ្នាំ ១៩៧៤

សុង ស៊ីវ, ចលនាអរិយធម៌ ភ្នំពេញ, ឆ្នាំ ១៩៧១

សូ អៀ, ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាមួយអណ្ណាម និងសៀម ចាប់ពីសតវត្សទី១៦, ដ.ឯ.ម

ហ៊ុន សែន, ១០ឆ្នាំនៃដំណើរកម្ពុជា, ១៩៧៩-១៩៨៩

ឡុង បូរ៉ា, ប្រវត្តិរូបិយវត្ថុសាកលលោក, ឆ្នាំ ២០០១

ឡុង សៀម, ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា, ឆ្នាំ ១៩៨៥

អាដេម៉ារ ឡឺក្លែរ, ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់តាំងពីសតវត្ស ទី១ រហូតមក, ២០០៥

អនុស្សាវរីយ៍ដោយរូបភាពនៃកម្ពុជាសង្គមរាស្ត្រនិយម

ឥន្ទ ឱមសាម៉េង និង ឈុន ពហុ,ភូមិវិទ្យាសេដ្ឋកិច្ច និងមនុស្ស នៃប្រទេសកម្ពុជា,២០០៧

ឥន្ទ ឱមសាម៉េង ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០០៩

ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២

ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ឆ្នាំ ២០១២

A, Silisce, G.Groslier, arts et archeology Khmers, tome II

Alain Euzéby (2000) Introduction à l'économie politique (2000)

B.Ph.Groslier, Angkor, Hommes et pierres, paris 1956

Cf. P. Pelliot: Memoire sur les countumes du Cambodoge de TCheou Ta Koun nouvell version suivie d'uncomentaire inachve 1951

Cf. Sappho marchal, costumes et parures Khmers, G:vanoest. 1927

David P. Chandler, History of Cambodia, op.cit.

Henri Stierlin, Un chef d'oevre d'equilibre ecologique, in lecourrier, revue de UNESCO, XXive annee 1971

Louis Cheminais Le Cambodge

M.Citeaux Histoire du Cambodge, Didier 1958

Migot, Les Khmer, Le Livre Contemporian, Paris, 1960

NORODOM SIHANOUK photos souveniers de mon CAMBODGE (ANNEES 60)

P.Devillers, Histoirs du XXe S, Asie du Sud-Est, Siey, 1971

P.les Pays tropicaux, P.UF, coll, pays OuTre-Mer 1969

photos souveniers du CAMBODGE sangkum reastr niyum 1955-1969

URL: http//www.csua.berkeley.edu/~sophal